# អដ្ឋកថា សារត្ថប្បកាសិនី

## នៃព្រះសុត្តន្តបិដក

## សំយុត្តនិកាយ សគាថវគ្គ

## ទុតិយភាគ

## ភាគ ៣០

ព្រះរាជាណាចក្រកម្ពុជា

ពុទ្ធសករាជ ២៥៥៥

# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ សគាថវគ្គ

## ទុតិយភាគ

## ភាគ ៣០

ឈ្មោះ

# សារត្ថប្បកាសិនី

ពុទ្ធសករាជ ២៥៥៥

អធិប្បាយ

ភិក្ខុនីសំយុត្ត-ព្រហ្មសំយុត្ត-ព្រាហ្មណសំយុត្ត-ឧបាសកសំយុត្ត

វង្គីសសំយុត្ត-វនសំយុត្ត-យក្ខសំយុត្ត-សក្កសំយុត្ត

រួមមាន ១៣០ សូត្រ

# Signes et accents.



# ស្រះពេញតួ
# *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូម Romain | a . | ā | i | i | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
## Consonnes.

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រូប Romain | k | kh | g | gh | ṅ |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច | ឆ | ជ | ឈ | ញ |
| រូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សិង្ហ<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| [illegible] Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សិង្ហល Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដី*

រីករាយ និងស្មួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុញ្ញាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានធនូះក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ

សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់

ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្ដាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ចាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើង ហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះ របស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិតស្ពានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្សាយ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទយ័** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡ: សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុឋៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការបានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់ លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-ឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន

ឧបាសក ទុំ ទូន

ឧបាសក ជឹម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ឹម វ៉ៃយ៉ា

ឧបាសក សោម រតនៈ

ឧបាសក ម៉ៅ ផុន

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៉ែន រមណី

ឧបាសក នាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត ទិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ

ឧបាសក ជា ស៊ីបាន

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ប៊ុត សេដាដួង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នួវ បូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ឆុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក ហាយ ចំរើន |
| ឧបាសក ហុក សឹងហួត | ឧបាសក អ៊ឹម រ៉ៃយ៉ា |
| ឧបាសក ឈួន សំណាង | ឧបាសក ឃឿម សារ៉េន |

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# អដ្ឋកថា សំយុត្តនិកាយ សគាថវគ្គ

## ទុតិយភាគ

### រួមមាន

| | | |
|---|---|---|
| ភិក្ខុនីសំយុត្ត | មាន ១០ សូត្រ | |
| ព្រហ្មសំយុត្ត | មាន ១០ សូត្រ | |
| ព្រហ្មបញ្ចកៈ | មាន ៥ សូត្រ | |
| ព្រាហ្មណសំយុត្ត | មាន ២វគ្គ | ស្មើនឹង ២២ សូត្រ |
| វង្គីសសំយុត្ត | មាន ១២ សូត្រ | |
| វនសំយុត្ត | មាន ១៤ សូត្រ | |
| យក្ខសំយុត្ត | មាន ១២ សូត្រ | |
| សក្កសំយុត្ត | មាន ២វគ្គ | ស្មើនឹង ២០ សូត្រ |
| សក្កបញ្ចកៈ | មាន ៥ សូត្រ | |

សរុប : មាន ៨ សំយុត្ត ស្មើនឹង ១១០ សូត្រ

# មាតិកាធម៌

ឈ្មោះធម៌ នំព័រ

## ភិក្ខុនីសំយុត្ត

អដ្ឋកថា អាឡវិកសូត្រ ទី ១ ១
អដ្ឋកថា សោមាសូត្រ ទី ២ ៣
អដ្ឋកថា គោតមីសូត្រ ទី ៣ ៤
អដ្ឋកថា វិជយាសូត្រ ទី ៤ ៨
អដ្ឋកថា ឧប្បលវណ្ណាសូត្រ ទី ៥ ១០
អដ្ឋកថា ចាលាសូត្រ ទី ៦ ១១
អដ្ឋកថា ឧបចាលាសូត្រ ទី ៧ ១២
អដ្ឋកថា សីសុបចាលាសូត្រ ទី ៨ ១៣
អដ្ឋកថា សេលាសូត្រ ទី ៩ ១៥
អដ្ឋកថា វជិរាសូត្រ ទី ១០ ១៦

## ព្រហ្មសំយុត្ត

អដ្ឋកថា អាយាចនសូត្រ ទី ១ ១៧
អដ្ឋកថា គារវសូត្រ ទី ២ ៣៧
អដ្ឋកថា ព្រហ្មទេវសូត្រ ទី ៣ ៤១
អដ្ឋកថា ពកសូត្រ ទី ៤ ៥០

អដ្ឋកថា អបរាជិដ្ឋិសូត្រ ទី ៥ ៦០

អដ្ឋកថា បមាទសូត្រ ទី ៦ ៦៤

អដ្ឋកថា បឋមកោកាលិកសូត្រ ទី ៧ ៦៧

អដ្ឋកថា តិស្សកសូត្រ ទី ៨ ៦៨

អដ្ឋកថា តុទុព្រហ្មសូត្រ ទី ៩ ៦៩

អដ្ឋកថា ទុតិយកោកាលិកសូត្រ ទី ១០ ៧៣


## ព្រហ្មបញ្ចកៈ


អដ្ឋកថា សនង្កុមារសូត្រ ទី ១ ៨១

អដ្ឋកថា ទេវទត្តសូត្រ ទី ២ ៨៣

អដ្ឋកថា អន្ធកវិន្ទសូត្រ ទី ៣ ៨៤

អដ្ឋកថា អរុណវតីសូត្រ ទី ៤ ៨៨

អដ្ឋកថា បរិនិព្វានសូត្រ ទី ៥ ៩១


## ព្រាហ្មណសំយុត្ត អរហន្តវគ្គ


អដ្ឋកថា ធនញ្ជានីសូត្រ ទី ១ ៩៧

អដ្ឋកថា អក្កោសកសូត្រ ទី ២ ១០៤

អដ្ឋកថា អសុរិន្ទកសូត្រ ទី ៣ ១០៧

អដ្ឋកថា ពិលង្គិកសូត្រ ទី ៤ ១០៨

អដ្ឋកថា អហិង្សកសូត្រ ទី ៥ ១០៩

អដ្ឋកថា ជដាសូត្រ ទី ៦ ១១០

អដ្ឋកថា សុទ្ធិកសូត្រ ទី ៧ ១១១
អដ្ឋកថា អគ្គិកសូត្រ ទី ៨ ១១៣
អដ្ឋកថា សុន្ទរិកសូត្រ ទី ៩ ១១៨
អដ្ឋកថា ពហុធិតិសូត្រ ទី ១០ ១៣២

## ឧបាសកវគ្គ

អដ្ឋកថា កសិសូត្រ ទី ១ ១៤១
អដ្ឋកថា ឧទយសូត្រ ទី ២ ១៧៥
អដ្ឋកថា ទេវហិតសូត្រ ទី ៣ ១៧៩
អដ្ឋកថា មហាសាលសូត្រ ទី ៤ ១៨៤
អដ្ឋកថា មានត្ថទ្ធសូត្រ ទី ៥ ១៩៣
អដ្ឋកថា បច្ចនិកសូត្រ ទី ៦ ១៩៥
អដ្ឋកថា នវកម្មិកសូត្រ ទី ៧ ១៩៦
អដ្ឋកថា ករដ្ឋហារសូត្រ ទី ៨ ១៩៨
អដ្ឋកថា មាតុបោសកសូត្រ ទី ៩ ២០១
អដ្ឋកថា ភិក្ខកសូត្រ ទី ១០ ២០២
អដ្ឋកថា សង្គារវសូត្រ ទី ១១ ២០៣
អដ្ឋកថា ខោមទុស្សសូត្រ ទី ១២ ២០៥

## វង្គីសសំយុត្ត

អដ្ឋកថា និក្ខន្តសូត្រ ទី ១ ២០៧

| | | | |
|---|---|---|---|
| អដ្ឋកថា | អរតិសូត្រ | ទី ២ | ២១១ |
| អដ្ឋកថា | បេសលាតិមញ្ញនា | ទី ៣ | ២១៤ |
| អដ្ឋកថា | អានន្ទសូត្រ | ទី ៤ | ២១៦ |
| អដ្ឋកថា | សុភាសិតសូត្រ | ទី ៥ | ២១៨ |
| អដ្ឋកថា | សារីបុត្តសូត្រ | ទី ៦ | ២២៦ |
| អដ្ឋកថា | បវារណាសូត្រ | ទី ៧ | ២២៨ |
| អដ្ឋកថា | បរោសហស្សសូត្រ | ទី ៨ | ២៣៤ |
| អដ្ឋកថា | កោណ្ឌញ្ញោសូត្រ | ទី ៩ | ២៣៧ |
| អដ្ឋកថា | មោគ្គល្លានសូត្រ | ទី ១០ | ២៤៧ |
| អដ្ឋកថា | គគ្គរាសូត្រ | ទី ១១ | ២៤៨ |
| អដ្ឋកថា | វង្គីសសូត្រ | ទី ១២ | ២៤៩ |


## វនសំយុត្ត


| | | | |
|---|---|---|---|
| អដ្ឋកថា | វិវេកសូត្រ | ទី ១ | ២៥៤ |
| អដ្ឋកថា | ឧបដ្ឋានសូត្រ | ទី ២ | ២៥៦ |
| អដ្ឋកថា | កស្សបគោត្តសូត្រ | ទី ៣ | ២៥៩ |
| អដ្ឋកថា | សម្ពហុលសូត្រ | ទី ៤ | ២៦២ |
| អដ្ឋកថា | អានន្ទសូត្រ | ទី ៥ | ២៦៥ |
| អដ្ឋកថា | នាគទត្តសូត្រ | ទី ៦ | ២៧១ |
| អដ្ឋកថា | កុលឃរណីសូត្រ | ទី ៧ | ២៧៣ |
| អដ្ឋកថា | វជ្ជីបុត្តសូត្រ | ទី ៨ | ២៧៦ |

| | | | |
|---|---|---|---|
| អដ្ឋកថា | សជ្ឈាយសូត្រ | ទី ៩ | ២៧៨ |
| អដ្ឋកថា | អយោនិសោ..សូត្រ | ទី ១០ | ២៨១ |
| អដ្ឋកថា | មជ្ឈន្តិកសូត្រ | ទី ១១ | ២៨២ |
| អដ្ឋកថា | ចាកតិន្ទ្រិយសូត្រ | ទី ១២ | ២៨៣ |
| អដ្ឋកថា | បទុមបុប្ផសូត្រ | ទី ១៣ | ២៨៤ |

## យក្ខសំយុត្ត

| | | | |
|---|---|---|---|
| អដ្ឋកថា | ឥន្ទកសូត្រ | ទី ១ | ២៨៧ |
| អដ្ឋកថា | សក្កសូត្រ | ទី ២ | ២៩២ |
| អដ្ឋកថា | សូចិលោមសូត្រ | ទី ៣ | ២៩៣ |
| អដ្ឋកថា | មណិភទ្ទសូត្រ | ទី ៤ | ៣០១ |
| អដ្ឋកថា | សានុសូត្រ | ទី ៥ | ៣០៣ |
| អដ្ឋកថា | បិយង្ករសូត្រ | ទី ៦ | ៣១០ |
| អដ្ឋកថា | បុនព្វសុសូត្រ | ទី ៧ | ៣១៣ |
| អដ្ឋកថា | សុទត្តសូត្រ | ទី ៨ | ៣១៩ |
| អដ្ឋកថា | បឋមសុក្កាសូត្រ | ទី ៩ | ៣២៩ |
| អដ្ឋកថា | ទុតិយសុក្កាសូត្រ | ទី ១០ | ៣៣១ |
| អដ្ឋកថា | ចីរាសូត្រ | ទី ១១ | ៣៣២ |
| អដ្ឋកថា | អាឡវកសូត្រ | ទី ១២ | ៣៣៣ |

## សក្កសំយុត្ត

| | | | |
|---|---|---|---|
| អដ្ឋកថា | សុវីរសូត្រ | ទី ១ | ៣៨១ |

អដ្ឋកថា សុសិមសូត្រ ទី ២ ៣៨៨
អដ្ឋកថា ធជគ្គសូត្រ ទី ៣ ៣៨៩
អដ្ឋកថា វេបចិត្តិសូត្រ ទី ៤ ៣៩២
អដ្ឋកថា សុភាសិតជយសូត្រទី ៥ ៣៩៦
អដ្ឋកថា កុលាវកសូត្រ ទី ៦ ៣៩៧
អដ្ឋកថា នទុព្ភិយសូត្រ ទី ៧ ៣៩៩
អដ្ឋកថា វិរោចនអសុរិន្ទសូត្រទី ៨ ៤០១
អដ្ឋកថា អារញ្ញកសូត្រ ទី ៩ ៤០៣
អដ្ឋកថា សមុទ្ទកសូត្រ ទី ១០ ៤០៥

## ទេវវគ្គ ទី ២

អដ្ឋកថា បឋមទេវសូត្រ ទី ១ ៤០៨
អដ្ឋកថា ទុតិយទេវសូត្រ ទី ២ ៤០៩
អដ្ឋកថា តតិយទេវសូត្រ ទី ៣ ៤១០
អដ្ឋកថា ទឡិទ្ទសូត្រ ទី ៤ ៤១២
អដ្ឋកថា រាមណេយ្យកសូត្រ ទី ៥ ៤១៧
អដ្ឋកថា ជយមានសូត្រ ទី ៦ ៤១៨
អដ្ឋកថា វន្ទនសូត្រ ទី ៧ ៤២១
អដ្ឋកថា បឋមសក្ក...សូត្រ ទី ៨ ៤២២
អដ្ឋកថា ទុតិយសក្ក...សូត្រ ទី ៩ ៤២៤
អដ្ឋកថា តតិយសក្ក...សូត្រ ទី ១០ ៤២៥

## សក្កបញ្ហក


| | | |
|---|---|---|
| អដ្ឋកថា យត្វាសូត្រ | ទី ១ | ៤២៨ |
| អដ្ឋកថា ទុព្វណ្ណិយសូត្រ | ទី ២ | ៤២៩ |
| អដ្ឋកថា មាយាសូត្រ | ទី ៣ | ៤៣១ |
| អដ្ឋកថា អច្ចយសូត្រ | ទី ៤ | ៤៣៣ |
| អដ្ឋកថា អក្កោធសូត្រ | ទី ៥ | ៤៣៥ |

# ភិក្ខុនីសំយុត្ត

## អដ្ឋកថា

### អាឡវិកាសូត្រទី ១

*ក្នុងភិក្ខុនីសំយុត្ត* ***អាឡវិកាសូត្រទី ១*** *មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[១]** *បទថា* ***អាឡវិកា*** *សេចក្តីថា អ្នកកើតក្នុងក្រុងអាឡវី និងចេញបួសពីក្រុងអាឡវីនុ៎ះឯង ។ បទថា* ***អន្ធវនំ*** *សេចក្តីថា ព្រៃដែលឈ្មោះថា អន្ធវន តាំងពីវេលាដែលពួកចោរ ៥០០ នាក់ ខ្វេះភ្នែកទាំងពីររបស់ព្រះអរិយបុគ្គល (អនាគាមី) អ្នកពោលធម៌ នាមថា* ***យសោធរ*** *ជាអ្នករួបរួមទ្រព្យមកដើម្បីសាងព្រះចេតិយព្រះសម្មាសម្ពុទ្ធព្រះនាមថា* ***កស្សប*** *ខ្ទង់នងឯងក៏បែកភ្នែកនៅក្នុងទីនោះឯង ។ គេដំណាលមកថា ព្រៃនោះ ជាព្រៃរក្សាទុកពួកម្រឹគ ក្នុងផ្ទៃដីប្រមាណមួយគាវុតផ្នែកទិសទក្សិណក្រុងសាវត្ថី បុគ្គលដែលត្រូវការវិវេក និងភិក្ខុនីទាំងឡាយ ក៏នាំគ្នាទៅក្នុងព្រៃនោះ ។ ព្រោះដូច្នោះ សូម្បីភិក្ខុនីអាឡវិកានេះ ក៏មានសេចក្តីត្រូវការវិវេក ទើបចូលទៅកាន់ព្រៃនោះ ។*

**[៣]** *បទថា* ***និស្សរណំ*** *បានដល់ ព្រះនិព្វាន ។ បទថា* ***បញ្ញាយ***

បានដល់ បច្ចវេក្ខណញ្ញាណ ។ បទថា **ន ត្វំ ជានាសិ តំ បទំ** សេចក្ដីថា អ្នកមិនដឹងបទ គឺ ព្រះនិព្វាន ឬបទ គឺ មគ្គ ដែលទៅកាន់ព្រះនិព្វាន ។ បទថា **សត្តិសូលូបមា** បានដល់ ដូចជាលំពែង និងដែកស្រួច ព្រោះអត្ថថា ជាគ្រឿងចាក់ដោត ។ បទថា **ខន្ធាសំ អធិកុដ្ដនា** សេចក្ដីថា គំនរនៃកាមទាំងឡាយនោះ ដូចជាឫស ។

ចប់អដ្ឋកថា អាឡវិកាសូត្រទី ១

# អ ដ្ឋ ក ថា

## សោមាសូត្រទី ២

*ក្នុងសោមាសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[៤]** *បទថា* ***ឋានំ*** *បានដល់ ព្រះអរហត្ត ។ បទថា* ***ទុរភិសម្ភវំ*** *បានដល់ បានដោយក្រ ។ បទថា* ***ទ្វង្គុលបញ្ញាយ*** *បានដល់ បញ្ញាតិចតួច ម្យ៉ាងទៀត ស្ត្រីឈ្មោះថា* ***ទ្វង្គុលបញ្ញាយ*** *បានដល់ ព្រោះប្រើម្រាមដៃពីរចាប់សំឡីកប្បាសរវៃជាអំបោះ ។*

**[៦]** *បទថា* ***ញាណម្ហិ វត្តមានម្ហិ*** *សេចក្តីថា កាលញាណក្នុងផលសមាបត្តិប្រព្រឹត្តទៅហើយ ។ បទថា* ***ធម្មំ វិបស្សតោ*** *សេចក្តីថា អ្នកឃើញច្បាស់ធម៌ គឺ សច្ចៈ ៤ ឬឃើញចំពោះបញ្ចក្ខន្ធ ដែលជាអារម្មណ៍របស់វិបស្សនាក្នុងចំណែកខាងដើម ។ បទថា* ***កិញ្ចិ វាបន អស្មីតិ*** *ឬមានសេចក្តីកន្លល់ថាអាត្មាអញមាន ដូច្នេះ សេចក្តីថា ឬសេចក្តីកន្លល់ដទៃៗ នឹងគប្បីមានដល់បុគ្គលណា ដោយតណ្ហា មានះ និងទិដ្ឋិថា ជាយើង ដូច្នេះ ។*

ចប់អដ្ឋកថា សោមាសូត្រទី ២

# អ ដ្ឋ ក ថា

## គោតមីសូត្រទី ៣

ក្នុងគោតមីសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[៧]** ពាក្យថា **កិសាគោតមី** ជាឈ្មោះរបស់ភិក្ខុនីនោះ ព្រោះលោកមានសាច់ និងឈាមតិច ។ បានឮថា គ្រាមុន ទ្រព្យប្រមាណ ៤០ កោដិ ក្នុងផ្ទះនៃត្រកូលមួយក្នុងក្រុងសាវត្ថី ក្លាយទៅជាធ្យូងទាំងអស់ ។ កុដុម្ពីមិនបានជញ្ជូនធ្យូងទៅចោល គិតថា នឹងមានអ្នកមានបុណ្យណាៗ ដោយពិត ដោយបុណ្យរបស់អ្នកនោះ ទ្រព្យនឹងត្រឡប់ជាប្រក្រតីវិញ ទើបយកមាស និងប្រាក់ដាក់ថាសពេញជាច្រើនថាស យកទៅដាក់ទុកត្រង់ផ្សារហើយអង្គុយនៅជិតៗ ។ លំដាប់នោះធីតារបស់ត្រកូលក្រីក្រម្នាក់ គិតថា យើងនឹងកាន់យកទ្រព្យកន្ទះមាសក: ហើយនាំមែកឈើមក ដើរទៅតាមថ្នល់ ឃើញទ្រព្យនោះ ទើបពោលនឹងកុដុម្ពីថា ទ្រព្យនៅទីផ្សារមានដល់ប៉ុណ្ណេះហើយ ទម្រាំនៅឯផ្ទះនឹងមានប៉ុណ្ណា ។ កុដុម្ពីសួរថា នែនាង នាងឃើញអ្វី ទើបបាននិយាយយ៉ាងនេះ ។ នាងឆ្លើយថា ឃើញប្រាក់និងមាសនេះ ។ កុដុម្ពីគិតថា ស្រីម្នាក់នេះ ជាអ្នកមានបុណ្យ ទើបសួរដល់ទីនៅ

របស់នាង ប្រមូលវត្ថុទុកដាក់រួចហើយ ចូលទៅរកមាតាបិតារបស់នាង ពោលយ៉ាងនេះថា ក្នុងផ្ទះរបស់យើងមានក្មេងកម្លោះ អ្នកចូរឲ្យក្មេងស្រីម្នាក់នេះដល់គេចុះ មាតាបិតាពោលថា លោកនិយាយលេងនឹងអ្នកក្រីក្រដូចខ្ញុំធ្វើអ្វី ។ កុដុម្ពីពោលថា ធម្មតាថា សេចក្តីស្និទ្ធស្នាលដោយឋានៈជាមិត្ត រមែងមានជាមួយអ្នកក្រីក្រ អ្នកទាំងឡាយចូរឲ្យចុះ នាងនឹងបានជាម្ចាស់ទ្រព្យ ហើយនាំនាងមកគ្រប់គ្រងផ្ទះ ។ នាងនៅរួមគ្នា ទើបប្រសូតបុត្រប្រុស ។ បុត្រក៏បានស្លាប់ក្នុងវេលាចេះដើរបាន ។ នាងកើតក្នុងត្រកូលក្រខ្សត់ សូម្បីបាននៅក្នុងត្រកូលដ៏ធំ ក៏កើតសេចក្តីសោកយ៉ាងខ្លាំងថា យើងដល់សេចក្តីវិនាសព្រោះបុត្រ មិនដុតសាកសពបុត្រ ពសាកសពបុត្រនោះត្រាច់យំរៀបរាប់ទៅទូទាំងនគរ ។

ថ្ងៃមួយ នាងទៅកាន់សម្នាក់ព្រះទសពល តាមផ្លូវដែលនាងធ្លាប់ទៅគាល់ព្រះពុទ្ធ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គមេត្តាប្រទានថ្នាំដើម្បីឲ្យកូនជាអំពីរោគ ។ ព្រះមានព្រះភាគត្រាស់ថា នាងចូរទៅកាន់ក្រុងសាវត្ថី ចូរនាំគ្រាប់ស្ពៃអំពីផ្ទះដែលមិនធ្លាប់មានអ្នកស្លាប់មក ទុំះនឹងជាថ្នាំរបស់កូននាង នាងចូលទៅកាន់នគរ ទៅសូមគ្រាប់ស្ពៃ ដោយន័យដែលព្រះមានព្រះភាគត្រាស់ប្រាប់តាំងពីផ្ទះឆ្ងាយ ត្រូវអ្នកស្រុកគ្រប់ៗ ផ្ទះពោលថា នាងនឹងជួបផ្ទះយ៉ាងនេះពីទីណា

ដើរទៅពីរបីផ្ទះ គិតថា ន័យថា សេចក្តីស្លាប់នេះ ជារបស់មនុស្សគ្រប់ៗ គ្នា មិនថាយើង ឬកូន ដូច្នេះ ទើបបោលសាកសពទុកត្រង់សាលា ហើយសូមបព្វជ្ជា ។ ព្រះសាស្តាទ្រង់បញ្ជូនទៅសម្នាក់នាងភិក្ខុនី ដោយព្រះតម្រាស់ថា ចូរឲ្យនាងនេះបួសចុះ ។ នាងសម្រេចព្រះអរហត្ត ក្នុងខណៈទល់នឹងចុងកាំបិតកោរទុំ៎ះឯង ។ លោកសំដៅយកព្រះថេរីនោះ ទើបពោលថា **អថ ខោ កិសាគោតមី** ដូច្នេះ ។

**[៨]** បទថា **ឯកមាសី** កាត់ជា **ឯកា អាសី** ។ បទថា **រុទម្មុខី** បានដល់ មានមុខដូចស្រែកយំ ។

**[៩]** **អន្ត** ស័ព្ទ ក្នុងបទថា **អច្ចន្តំ ហតបុត្តម្ហិ** ជាអច្ចន្តៈចំណែកអតីត ។ បទថា **អច្ចន្តំ** នោះ ជាការទបុំសកលិង្គ ។ លោកអធិប្បាយថា ការស្លាប់របស់បុត្រជាទីបំផុត គឺ ជាអតីត យ៉ាងណា បុត្រដែលស្លាប់ហើយ ក៏ដូច្នោះ ឥឡូវនេះ យើងមិនមានកូនស្លាប់ទៀតទេ ។ បទថា **បុរិសា ឯតទន្តិកា** សេចក្តីថា សូម្បីបុគ្គលពួកនេះ ក៏មានសេចក្តីស្លាប់នេះជាទីបំផុតដូចគ្នា ទីបំផុតនៃសេចក្តីស្លាប់របស់បុត្រយើងនេះឯង ជាទីបំផុតសូម្បីរបស់បុគ្គលទាំងឡាយ យើងទើបមិនគួរស្វែងរកបុត្រដែលស្លាប់ក្នុងកាលឥឡូវនេះ ។ បទថា **សព្វត្ថ វិហតា នន្ទិ** សេចក្តីថា សេចក្តីត្រេកត្រអាល ដោយអំណាចតណ្ហាក្នុងខន្ធ អាយតនៈ ធាតុ ភព

*កំណើត គតិ ឋិតិ និងនិវាសៈទាំងអស់ យើងកម្ចាត់បានហើយ ។ បទថា* ***តមោក្ខន្ធោ*** *បានដល់ គំនរអវិជ្ជា ។ បទថា* ***បទាលិតោ*** *សេចក្តីថា ទម្លាយហើយដោយញាណ ។*

ចប់អដ្ឋកថា គោតមីសូត្រទី ៣

# អ ដ្ឋ ក ថា

## វិជយាសូត្រទី ៤

ក្នុងវិជយាសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១១] បទថា **បញ្ចង្គិកេន** សេចក្ដីថា ប្រកបដោយអង្គ ៥ យ៉ាងនេះ គឺ **អាតតៈ** ស្គរដែលពាសស្បែកតែម្ខាង **វិតតៈ** ពាសទាំងពីរខាង គឺ សម្ភោរ **អាតតវិតតៈ** ពាសទាំងអស់ មានស្គរតូចជាដើម **ឃនៈ** គឺ គង ប៉ី និងស័ង្ខ ជាដើម ។

[១២] បទថា **និយ្យាតយាមិ តុយ្ហេវ** សេចក្ដីថា យើងនឹងឲ្យតន្ត្រីទាំងអស់ដល់លោក ។ បទថា **មារ ន ហិ តេន អត្ថិកា** សេចក្ដីថា យើងមិនត្រូវតន្ត្រីនោះ ។ បទថា **បូតិ កាយេន** សេចក្ដីថា កាយសូម្បីមានវណ្ណៈដូចមាសក៏នៅឈ្មោះថា ជាកាយស្អុយ ព្រោះអត្ថថា ហូរចូលហូរចេញជានិច្ច ព្រោះដូច្នោះ **វិជយាភិក្ខុនី** ទើបពោលយ៉ាងនោះ ។ បទថា **ភិន្ទុនេន** បានដល់ មានការបែកទៅជាសភាវៈ ។ បទថា **បភង្គុនា** បានដល់ ការបែកធ្លាយជាចំណែកតូចៗ ជាធម្មតា ។ បទថា **អដ្ដិយាមិ** ប្រែថា ធុញទ្រាន់ ។ បទថា **ហរាយាមិ** ប្រែថា នឿយណាយ ។ បទថា **សន្តា សមាបត្តិ** សេចក្ដីថា លោកិយសមាបត្តិ ៨ យ៉ាង

លោកពោលថា ស្ងប់ ព្រោះស្ងប់ដោយអារម្មណ៍ និងស្ងប់ដោយអង្គ ។ បទថា **សព្វត្ថ** បានដល់ ក្នុងរូបភព និងអរូបភពទាំងអស់ ។ **វិជយាភិក្ខុនី** ទើបពោលថា សូម្បីសេចក្តីងងឹត គឺ អវិជ្ជា យើងកម្ចាត់បានហើយ ក្នុងឋានៈទាំងពួងនេះ គឺ ក្នុងកាមភព ដែលប្រកាន់ហើយ ព្រោះចាប់យកភពទាំង ២ នោះ និងក្នុងសមាបត្តិ ៨ ។

ចប់អដ្ឋកថា វិជយាសូត្រទី ៤

# អ ដ្ឋ ក ថា

## ឧប្បលវណ្ណាសូត្រទី ៥

ក្នុងឧប្បលវណ្ណាសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[១៤]** បទថា **សុបុប្ផិតគ្គំ** សេចក្តីថា ដើមសាលព្រឹក្សមានផ្ការីកស្គុសស្គាយតាំងពីចុង ។

ដោយពាក្យថា **ន ចត្ថិ តេ ទុតិយា វណ្ណធាតុ** មារពោលថា វណ្ណធាតុទី ២ ដែលដូចគ្នានឹងវណ្ណធាតុរបស់នាង រមែងមិនមាន គឺ មិនមានភិក្ខុនីដទៃដូចគ្នានឹងនាង ។

**[១៥]** បទថា **ឥធាគតា តាទិសិកា ភវេយ្យុំ** សេចក្តីថា លោកមកក្នុងទីនេះ រមែងមិនបានសេចក្តីស្និទ្ធស្នាល ឬសេចក្តីស្រឡាញ់អ្វី យ៉ាងណា សូម្បីជនទាំងនោះ ក៏ដូចជាលោកដូច្នោះដែរ ។

បទថា **បខុមន្តរិកាយំ** សេចក្តីថា សូម្បីយើងនឹងឈរលើក្តោងប្រមុះចន្លោះនេត្រាទាំងពីរ លោកក៏មិនឃើញយើង ។ បទថា **វសីភូតម្ហិ** ប្រែថា រមែងជាអ្នកជំនាញ ។

ចប់អដ្ឋកថា ឧប្បលវណ្ណាសូត្រទី៥

# អ ដ្ឋ ក ថា

## ចាលាសូត្រទី ៦

ក្នុងចាលាសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[១៨]** បទថា **កោ នុ តំ ឥទមាទបយិ** បានដល់ សេចក្តីថា នរណា ហ្ន៎ គឺ បុគ្គលពាល មានការដឹងតិច ឲ្យនាងកាន់យករឿងនេះ ។

**[១៩]** បទថា **បរិក្លេសំ** បានដល់ សេចក្តីខ្វល់ខ្វាយមានប្រការផ្សេងៗ សូម្បីយ៉ាងដទៃ ឥឡូវនេះ មារពោលពាក្យណាទុកថា នរណាហ្ន៎ ឲ្យនាងកាន់យករឿងនោះ ទើបសម្តែងពាក្យនោះថា បុគ្គលពាលមិនឲ្យយើងកាន់យក តែព្រះសាស្តាជាអគ្គបុគ្គលក្នុងលោកសម្តែងធម៌ហើយ ទើបពោលថា **ពុទ្ធោ** ដូច្នេះ ជាដើម ។ បណ្តាបទទាំងនោះ បទថា **សច្ចេ និវេសយិ** សេចក្តីថា ឲ្យតាំងនៅក្នុងព្រះនិព្វាន ដែលជាបរមត្ថសច្ចៈ ។

បទថា **និរោធំ អប្បជានន្តា** បានដល់ មិនដឹងនិរោធសច្ចៈ ។

ចប់អដ្ឋកថា ចាលាសូត្រទី៦

# អ ដ្ឋ ក ថា

## ឧបចាលាសូត្រទី ៧

ក្នុងឧបចាលាសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[២៣]** បទថា **ឯន្តិ មារវសំ បុន** សេចក្ដីថា មកកាន់អំណាចមរណមារ កិលេសមារ និងទេវបុត្តមារ ។ បទថា **បធូបិតោ** បានដល់ ឲ្យក្ដៅក្រហាយ ។ បទថា **អគតិ យត្ថ មារស្ស** សេចក្ដីថា ក្នុងព្រះនិព្វានណា អ្នក គឺ ជាមារទៅមិនបាន ។

បទថា **តត្ថ** បានដល់ ក្នុងព្រះនិព្វាននោះ ។

ចប់អដ្ឋកថា ឧបចាលាសូត្រទី៧

# អ ដ្ឋ ក ថា

## សីសុបចាលាសូត្រទី ៨

ក្នុងសីសុបចាលាសូត្រទី ៨ មានវិនិច្ឆ័យតទៅនេះ ៖

[២៦] បទថា **សមណី វិយ ទិស្សសិ** សេចក្ដីថា នាងប្រាកដដូចជាសមណៈ ។ បទថា **កិមិវ ចរសិ មោមុហា** សេចក្ដីថា ព្រោះហេតុអ្វី ទើបនាងប្រព្រឹត្តដូចស្ត្រីវង្វេង ។

[២៧] បទថា **ឥតោ ពហិទ្ធា** សេចក្ដីថា ខាងក្រៅព្រះសាសនានេះ ។ បទថា **បាសណ្ឌា** សេចក្ដីថា លទ្ធិដូចអន្ទាក់ គឺ ទិដ្ឋិដែលជាប់ក្នុងចិត្តរបស់សត្វទាំងឡាយ ។ តែព្រះសាសនា រមែងដោះអន្ទាក់ទាំងឡាយ ដូច្នោះ ទើបមិនពោលថា លទ្ធិ លទ្ធិ មានខាងក្រៅព្រះសាសនានេះប៉ុណ្ណោះ ។ បទថា **សំសីទន្តិ** បានដល់ លិច គឺ ជាប់ ។

ឥឡូវនេះ **សីសុបចាលាភិក្ខុនី** កាលពោលឆ្លើយបញ្ហាដែលសួរថា នាងបួសឧទ្ទិសនរណា ទើបពោលថា **អត្ថិ សក្យកុលេ ជាតោ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **សព្វាភិភូ** សេចក្ដីថា គ្របសង្កត់ធម៌ទាំងពួង មានខន្ធ ធាតុ

អាយតនៈ ភព កំណើត និងគតិជាដើម ។ ឈ្មោះថា **មារនុទៈ** ព្រោះបន្ទោបង់ គឺ បណ្តេញមរណមារជាដើម ។

បទថា **សព្វត្ថមបរាជិតោ** សេចក្តីថា មិនចាញ់ក្នុងកិលេសទាំងពួង មានរាគៈជាដើម ឬក្នុងការច្បាំងជាមួយមារ ។ បទថា **សព្វត្ថ មុត្តោ** សេចក្តីថា បង្អោនទៅក្នុងធម៌ទាំងពួង មានខន្ធជាដើម ។ បទថា **អស្សិតោ** សេចក្តីថា ដែលតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យមិនអាស្រ័យហើយ ។ បទថា **សព្វកម្មក្ខយំ** សេចក្តីថា សម្រេចព្រះអរហត្ត ពោលគឺ ធម៌ជាទីអស់ទៅនៃកម្មទាំងពួង ។ បទថា **ឧបធិសង្ខយេ** សេចក្តីថា ទ្រង់បង្អោនទៅក្នុងអារម្មណ៍ គឺ ព្រះនិព្វាន ពោលគឺ ធម៌ជាទីអស់ទៅនៃឧបធិ ។

ចប់អដ្ឋកថា សីសុបចាលាសូត្រទី៨

# អ ដ្ឋ ក ថា

## សេលាសូត្រទី ៩

ក្នុងសេលាសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៩] បទថា *កេនិទំ បកតំ* សេចក្តីថា អ្នកណាសាងរូបនេះ ។ ដោយបទថា *ពិម្ពំ* លោកពោលសំដៅយកអត្តភាព ។

[៣០] ដោយបទថា *អឃំ* លោកពោលចំពោះអត្តភាព ព្រោះជាទីតាំងនៃទុក្ខ ។ បទថា *ហេតុភង្គា* បានដល់ ហេតុរលត់ ព្រោះខ្វះបច្ច័យ ។

ចប់អដ្ឋកថា សេលាសូត្រទី ៩

# អ ដ្ឋ ក ថា

## វជិរាសូត្រទី ១០

ក្នុងវជិរាសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៣] បទថា **នយិធ សត្តុបលព្ភតិ** សេចក្តីថា ក្នុងគំនរនៃសង្ខារសុទ្ធនេះ ពោលដោយបរមត្ថ បានដល់ សត្វក៏ទេ ។ បទថា **ខន្ធេសុ សន្តេសុ** សេចក្តីថា កាលខន្ធ ៥ នៅមាន លោកកំណត់យកដោយអាការនោះៗ ។ បទថា **សម្មុតិ** គឺ ត្រឹមតែឈ្មោះហៅថា សត្វប៉ុណ្ណោះ ។ បទថា **ទុក្ខំ** បានដល់ ទុក្ខ គឺ ខន្ធ ៥ ។ បទថា **នាញ្ញត្រ ទុក្ខា** សេចក្តីថា ក្រៅពីទុក្ខ សភាវៈដទៃមិនមានការកើត មិនមានការរលត់ ។

ចប់អដ្ឋកថា វជិរាសូត្រទី ១០

## ចប់ភិក្ខុនីសំយុត្ត

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថាអាឡវិកាសូត្រ
២-អដ្ឋកថាសោមាសូត្រ
៣-អដ្ឋកថាគោតមីសូត្រ
៤-អដ្ឋកថាវិជយាសូត្រ
៥-អដ្ឋកថាឧប្បលវណ្ណាសូត្រ
៦-អដ្ឋកថាចាលាសូត្រ
៧-អដ្ឋកថាឧបចាលាសូត្រ
៨-អដ្ឋកថាសីសុបចាលាសូត្រ
៩-អដ្ឋកថាសេលាសូត្រ
១០-អដ្ឋកថាវជិរាសូត្រ

# ព្រហ្មសំយុត្ត

## អ ដ្ឋ ក ថា

### អាយាចនសូត្រទី ១

*បឋមវគ្គសូត្រទី* ១ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[៣៤]** *បទថា* **បរិវិតក្កោ ឧទបាទិ** *បានដល់ បរិវិតក្កក្នុងព្រះទ័យ ដែលព្រះពុទ្ធគ្រប់ព្រះអង្គធ្លាប់សន្សំអប់រំមកកើតឡើង ដូច្នេះ ។ សួរថា កើតឡើងកាលណា ។*

*ឆ្លើយថា កើតក្នុងសប្តាហ៍ទី ៨ ពេលដែលព្រះអង្គ ទ្រង់ជម្រះព្រះទន្តដោយឈើស្ទន់ និងចំណិតសម៉ជាឱសថ ដែលសក្កៈទេវរាជនាំមកថ្វាយ ក្រោមដើមរាជាយតនៈ (ដើមកេះ) ទ្រង់ខ្វាព្រះឱស្ឋហើយ សោយបិណ្ឌបាតរបស់តបុស្សៈនិងភល្លិកៈ ក្នុងបាត្រថ្មកែវទាំងឡាយដ៏មានតម្លៃ ដែលលោកបាលទេវរាជទាំង ៤ បង្អោនថ្វាយ ហើយស្តេចត្រឡប់មកប្រថាប់ក្រោមដើមអជបាលនិគ្រោធ ។*

*បទថា* **អធិគតោ** *ប្រែថា សម្រេចហើយ ។ បទថា* **ធម្មោ** *បានដល់ ធម៌*

គឺ សច្ចៈ ៤ ។ បទថា **គម្ភីរោ** នេះ ជាបទហាមសេចក្ដីរាក់ ។ បទថា **ទុទ្ទសោ** សេចក្ដីថា ឈ្មោះថា ឃើញបានលំបាក គឺ ឃើញបានដោយក្រ ដែលនរណាៗ មិនអាចឃើញបានងាយ ព្រោះជ្រាលជ្រៅ ឈ្មោះថា ដឹងតាមបានលំបាក គឺ គប្បី យល់ដឹងបានដោយក្រ ព្រោះឃើញបានដោយក្រ នរណាៗ មិនអាចនឹងយល់ដឹង បានដោយងាយ ។ បទថា **សន្តោ** បានដល់ រលត់ហើយ ។ បទថា **បណីតោ** បានដល់ មិនស្គាល់ការឆ្អែត ។ ពីរបទនេះ លោកពោលសំដៅលោកុត្តរៈប៉ុណ្ណោះ ។ បទថា **អតក្កាវចរោ** សេចក្ដីថា នឹងគប្បីស្ទង់មើល គប្បីពិចារណា ដោយការ ត្រិះរិះមិនបាន គប្បីពិចារណាបានដោយញាណប៉ុណ្ណោះ ។ បទថា **និបុណោ** បាន ដល់ ល្អិត ។ បទថា **បណ្ឌិតវេទនីយោ** បានដល់ ដែលបណ្ឌិតអ្នកបដិបត្តិដោយ ប្រពៃគប្បីជ្រាប ។ បទថា **អាលយរាមា** សេចក្ដីថា សត្វទាំងឡាយ ជាប់នៅ ក្នុងកាមគុណ ៥ ព្រោះដូច្នោះ សត្វទាំងនោះ លោកទើបហៅថា **អល្វយា** ។ តណ្ហាវិចរិត ១០៨ ជា **អល្វយៈ** ព្រោះហេតុនោះ លោកទើបហៅថា **អាលយា** ។ សត្វទាំងឡាយឈ្មោះថា **អាលយរាមា** ព្រោះត្រេកអរដោយអាល័យទាំងនោះ ។ ឈ្មោះថា **អាលយរតា** ព្រោះត្រេកអរក្នុងអាល័យទាំងឡាយ ។ ឈ្មោះថា **អាលយាសម្មុទិតា** ព្រោះរីករាយក្នុងអាល័យទាំងឡាយ ។

ដូចសេចក្តីថា ព្រះរាជាស្តេចប្រពាតព្រះរាជឧទ្យាន ដែលដល់ព្រមដោយដើមឈើមានផ្កាមានផ្លែជាដើម ដែលគេចាត់ចែងទុកយ៉ាងល្អ ទ្រង់រមែងត្រេកអរ គឺ ទ្រង់ត្រេកអររីករាយព្រះទ័យដោយសម្បត្តិនោះ ទ្រង់មិនបានធុញទ្រាន់ សូម្បីវេលាល្ងាចក៏មិនប្រាថ្នានឹងស្តេចចេញ យ៉ាងណា សត្វទាំងឡាយរមែងត្រេកអរ គឺ រីករាយ មិនទៀយណាយនៅក្នុងសង្សារវដ្ដ ដោយអាល័យ គឺ កាម និងអាល័យ គឺ តណ្ហាទាំងឡាយនេះ ដូច្នោះ ។ ហេតុនោះ ព្រះមានព្រះភាគកាលទ្រង់សម្តែងអាល័យទាំងពីរយ៉ាងរបស់សត្វទាំងនោះ ប្រៀបដូចជាទីកន្លែងព្រះរាជឧទ្យាន ទើបត្រាស់ថា **អាលយរាមា** ជាដើម ។

បណ្តាបទទាំងនោះ បទថា ***យទិទំ*** ជានិបាត ។ សំដៅយកឋានៈរបស់បទថា ***យទិទំ*** នោះ គឺ សំដៅយកថា ***យំ ឥទន្តិបដិច្ចសមុប្បាទំ*** គប្បីជ្រាបសេចក្តីយ៉ាងនេះថា ***យោ អយំ*** ដូច្នេះ ។ បទថា ***ឥទប្បច្ចយតាបដិច្ចសមុប្បាទោ*** សេចក្តីថា បច្ច័យនៃធម៌ មានសង្ខារជាដើមទាំងនេះ ឈ្មោះ ***ឥទប្បច្ចយា ឥទប្បច្ចយា*** នោះឯងជា ***ឥទប្បច្ចយតា ឥទប្បច្ចយតា*** នោះផង ជា ***បដិច្ចសមុប្បាទា*** ផង ឈ្មោះថា ***ឥទប្បច្ចយតាបដិច្ចសមុប្បាទោ*** ភាពជាបច្ច័យនៃធម៌ មានសង្ខារជាដើមជាធម៌អាស្រ័យគ្នានិងគ្នាកើតឡើង ។ ពាក្យនេះ ជាឈ្មោះនៃធម៌ជាបច្ច័យ មាន

សង្ខារជាដើម ។ បទទាំងអស់ មានបទថា **សព្វសង្ខារសមថោ** ជាដើម បានដល់ព្រះនិព្វានទុំះឯង ។ ក៏ព្រោះអាស្រ័យព្រះនិព្វាននោះ សេចក្ដីញាប់ញ័រនៃសង្ខារទាំងឡាយ រមែងស្ងប់រម្ងាប់បាន ដូច្នោះ លោកទើបហៅថា ជាទីរម្ងាប់សង្ខារទាំងពួង ។ ម្យ៉ាងទៀត ព្រោះអាស្រ័យព្រះនិព្វាននោះ រមែងលះបង់ឧបធិទាំងពួងបាន តណ្ហាទាំងពួងអស់ទៅ ប្រាសចាករាគកិលេសបាន ទុក្ខទាំងអស់រលត់ទៅ ដូច្នោះ លោកទើបហៅថា ជាទីលះបង់ឧបធិទាំងពួង ជាទីអស់ទៅនៃតណ្ហាជាទីប្រាសចាករាគៈ ជាទីរលត់ ។ ក៏តណ្ហានេះ លោកហៅថា **វានៈ** ព្រោះរួបរឹតចាក់ស្រេះភពនិងភព ឬកម្មនិងផល ឈ្មោះថា **និព្វាន** ព្រោះចេញចាកវានៈនោះ ។ បទថា **សោ មមស្ស កិលមថោ** សេចក្ដីថា ការទូន្មានបុគ្គលដែលមិនដឹងនោះគប្បីជាសេចក្ដីនឿយហត់របស់តថាគត គប្បីជាសេចក្ដីលំបាករបស់តថាគត ។ លោកអធិប្បាយថា គប្បីជាសេចក្ដីនឿយហត់កាយផង ជាសេចក្ដីលំបាកកាយផង ។ តែក្នុងព្រះហទយៈរបស់ព្រះពុទ្ធទាំងឡាយ មិនមានសេចក្ដីនឿយហត់និងសេចក្ដីលំបាកទាំងពីរយ៉ាងនេះ ។ បទថា **អបិស្សុទំ** ជានិបាត មានសេចក្ដីថាកពូន ។ និបាតនោះ បំភ្លឺសេចក្ដីថា មិនមែនកើតបរិវិតក្កនេះតែម្យ៉ាង គាថាទាំងនេះក៏ជាក់ច្បាស់ហើយ ។ បទថា **អនច្ឆរិយា** បានដល់ គួរអស្ចារ្យតិចតួច ។

បទថា **បដិកំសុ** សេចក្តីថា គាថាទាំងនោះ ជាអារម្មណ៍នៃញាណ ពោលគឺ បដិភាណ គឺ សូម្បីគាថាដែលនឹងគប្បីបរិវិតក្កៈ ។

បទថា **កិច្ឆេន** បានដល់ ការបដិបត្តិលំបាក ។ ពិតណាស់ មគ្គទាំង ៤ រមែងជាការបដិបត្តិងាយសម្រាប់ព្រះពុទ្ធទាំងឡាយ ក៏ពាក្យនេះ លោកពោលសំដៅយកបដិបទាដែលនាំមគ្គផលមករបស់ព្រះអង្គដែលនៅមានរាគៈ ទោសៈ និងមោហៈ ក្នុងកាលបំពេញបារមី ទ្រង់កាត់សីសៈដែលប្រដាប់តាក់តែង នាំឈាមក្នុងបំពង់ព្រះសូរង ខ្វេះព្រះនេត្រ ប្រទានរបស់ជាទីស្រឡាញ់ជាដើម យ៉ាងនេះគឺ បុត្រដែលជាប្រទីបនៃវង្សត្រកូល ភរិយាដែលគួរស្រឡាញ់ និងសូម្បីការលះបង់ដទៃៗ មានការកាត់អវយវៈក្នុងអត្តភាព (ជាតិ) ដូចជាខន្តិវាទីតាបសជាដើម ដល់ពួកយាចកដែលនាំគ្នាមកហើយ ។ ហ អក្សរក្នុងបទថា **ហលំ** នេះ ត្រឹមតែនិបាត សេចក្តីថា មិនគួរ ។ បទថា **បកាសិតុំ** បានដល់ ការសម្តែង ។ លោកអធិប្បាយថា មិនគួរសម្តែងធម៌ដែលតថាគតត្រាស់ដឹងដោយលំបាក គឺ សម្តែងធម៌ដែលតថាគតរៀនមកហើយ ប្រយោជន៍អ្វីដោយការសម្តែងធម៌ ។ បទថា **រាគទោសបរេតេហិ** សេចក្តីថា ដែលរាគៈ ទោសៈពាល់ត្រូវហើយ ឬថា ទៅតាមរាគៈ ទោសៈ ។

បទថា **បដិសោតគាមី** បានដល់ ធម៌ គឺ សច្ចៈ ៤ ដែលផ្ទុយពីសភាពទៀងជាដើម ដែលមានពិតយ៉ាងនេះថា មិនទៀង ជាទុក្ខ ជាអនត្តា ជាអសុភៈ ។ បទថា **រាគរត្តា** បានដល់ ត្រេកអរហើយ ដោយកាមរាគៈ ភវរាគៈ និងទិដ្ឋិរាគៈ ។ បទថា **ន ទក្ខន្តិ** សេចក្ដីថា សត្វទាំងឡាយរមែងមិនឃើញដោយសភាវៈយ៉ាងនេះថា មិនទៀង ជាទុក្ខ ជាអនត្តា ជាអសុភៈ នរណាៗ ក៏មិនអាចធ្វើសត្វដែលមិនឃើញទាំងនោះ ឲ្យកាន់យកយ៉ាងនេះបាន ។ បទថា **តមោក្ខន្ធេន អាវុតា** បានដល់ គំនរងងឹត គឺ អវិជ្ជាបិទបាំង ។

បទថា **អប្បោស្សុក្កតាយ** សេចក្ដីថា ដើម្បីភាពជាអ្នកមិនមានបំណងនឹងសម្ដែង ដោយប្រាសចាកសេចក្ដីខ្វល់ខ្វាយ ។ សួរថា ហេតុអ្វី ព្រះអង្គទើបបង្អោនព្រះទ័យទៅយ៉ាងនេះ ព្រះអង្គទ្រង់តាំងសេចក្ដីប្រាថ្នាទុកមិនមែនឬថា តថាគតរួចផុតហើយ នឹងឲ្យអ្នកដទៃរួចផុត តថាគតឆ្លងហើយ នឹងឲ្យអ្នកដទៃឆ្លង

តថាគតនឹងមានប្រយោជន៍អ្វី ដោយភេទដែលអ្នកដទៃ
មិនស្គាល់ នឹងប្រយោជន៍អ្វីដោយ ធម៌ដែលតថាគតធ្វើ
ឲ្យជាក់ច្បាស់ក្នុងលោកនេះ តថាគតសម្រេចព្រះសព្វញ្ញុ-

តញ្ញាណហើយ នឹងញុំាងមនុស្សលោក ព្រមទាំងទេវ-
លោក ឲ្យឆ្លងត្រើយ ដូច្នេះ ។

បំពេញបារមី សម្រេចព្រះសព្វញ្ញុតញ្ញាណ ។ ឆ្លើយថា នោះជាសេចក្តីពិត ។ ក៏ព្រះទ័យរបស់ព្រះអង្គបង្អោនទៅយ៉ាងនេះ ក៏ដោយអានុភាពបច្ចវេក្ខណញ្ញាណ ។ ពិតណាស់ កាលព្រះអង្គសម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ពិចារណាដល់សត្វដែលក្រាស់ទៅដោយកិលេស និងព្រះធម៌ជារបស់ជ្រាលជ្រៅ សភាពនៃសត្វដែលក្រាស់ទៅដោយកិលេស និងសភាពនៃធម៌ជារបស់ជ្រាលជ្រៅ ក៏ប្រាកដដោយអាការទាំងពួង ។ លំដាប់នោះ ព្រះអង្គទ្រង់ព្រះតម្រិះថា សត្វទាំងនេះ ដូចជាកុណ្ឌីដែលពេញដោយទឹកបាយ ដូចជាភាជនៈដែលពេញដោយតឹកដោះជូរ ដូចសំពត់ចាស់ដែលជោគដោយខ្លាញ់ និងប្រេង ដូចដៃដែលប្រលាក់ថ្នាំបន្តក់ភ្នែក ពេញទៅដោយកិលេស សៅហ្មងយ៉ាងក្រៃលែង ត្រេកអរព្រោះរាគៈ ប្រទូស្តព្រោះទោសៈ វង្វេងព្រោះមោហៈ សត្វទាំងនោះនឹងចាក់ធ្លុះបានដូចម្តេច ទើបទ្រង់បង្អោនព្រះទ័យទៅយ៉ាងនេះ សូម្បីដោយអានុភាពនៃការពិចារណាដល់សត្វដែលក្រាស់ដោយកិលេស ។

គប្បីជ្រាបថា ទ្រង់បង្អោនព្រះទ័យទៅយ៉ាងនោះ សូម្បីដោយអានុភាព

នៃការពិចារណាដល់ធម៌ដែលល្អិតជ្រាលជ្រៅថា ធម៌នេះ ជ្រាលជ្រៅដូចទឹកទ្រផែនដី ឃើញបានលំបាក ដូចគ្រាប់ស្ពៃត្រូវក្ដុំបាំងទុក ចាក់ធ្លុះបានលំបាក ដូចយកចុងរោមទ្រាយដែលចែកចេញ ៧ ចំណែក ចងភ្ជាប់គ្នា ពិតណាស់ កាលតថាគតព្យាយាមដើម្បីត្រាស់ដឹងធម៌ ឈ្មោះថា មិនឲ្យទានមិនមាន ឈ្មោះថា មិនរក្សាសីលមិនមាន ឈ្មោះថា មិនបានបំពេញបារមីណាៗ ក៏មិនមាន កាលតថាគតកម្ចាត់កងទ័ពមារ ដូចជាអស់សេចក្ដីព្យាយាម ផែនដីមិនញាប់ញ័រ សូម្បីកាលរលឹកបុព្វេនិវាសានុស្សតិញ្ញាណក្នុងបឋមយាម ក៏មិនញាប់ញ័រ សូម្បីកាលជម្រះទិព្វចក្ខុក្នុងមជ្ឈិមយាម ក៏មិនញាប់ញ័រ តែកាលតថាគតបានត្រាស់ដឹងបដិច្ចសមុប្បាទក្នុងបច្ឆិមយាម មុឺនលោកធាតុទើបញាប់ញ័រហើយ ដូច្នោះ សូម្បីមនុស្សដូចជាតថាគត ប្រើញាណដែលចាស់ក្លា ក៏នៅត្រាស់ដឹងធម៌នេះបានដោយលំបាក លោកិយមហាជននឹងចាក់ធ្លុះធម៌នោះបានដូចម្ដេច ។

ម្យ៉ាងទៀត កាលព្រហ្មទូលអារាធនាហើយ ព្រះអង្គក៏ទ្រង់បង្អោនព្រះទ័យទៅយ៉ាងនេះ សូម្បីកាលទ្រង់ប្រាថ្នានឹងសម្ដែងធម៌ប្រោស ពិតណាស់ ព្រះមានព្រះភាគទ្រង់ជ្រាបថា កាលចិត្តរបស់តថាគតបង្អោនទៅ ដើម្បីភាពជាអ្នកខ្វល់ខ្វាយតិច មហាព្រហ្មក៏នឹងអារាធនាតថាគតឲ្យសម្ដែងធម៌ និងសត្វ

ទាំងនេះជាអ្នកគោរពចំពោះព្រហ្ម សត្វទាំងនោះសម្គាល់ថា បានឮថា ព្រះសាស្តា ទ្រង់មិនមានព្រះបំណងសំដែងធម៌ បើដូច្នេះ មហាព្រហ្មនឹងអារាធនាតថាគត ឲ្យសំដែងធម៌ថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌នោះស្ងប់ ប្រណីត ដូច្នេះ ក៏នឹងតាំងចិត្តស្តាប់ ដូច្នោះ គប្បីជ្រាបថា ព្រោះអាស្រ័យហេតុនេះ ព្រះទ័យរបស់ព្រះអង្គទើបបង្អោនទៅដើម្បីភាពជាអ្នកខ្វល់ខ្វាយតិច មិនបានបង្អោនទៅដើម្បីសំដែងធម៌ ។

**[៣៥]** បទថា ***សហម្បតិស្ស*** សេចក្តីថា បានឮថា ព្រហ្មនោះ ជាព្រះថេរៈឈ្មោះថា ***សហកៈ*** ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា ***កស្សប*** ធ្វើបឋមជ្ឈានឲ្យកើត កើតជាព្រហ្មមានអាយុមួយកប្បក្នុងបឋមជ្ឈានភូមិ ។ ក្នុងបឋមជ្ឈានភូមិនោះ ជនទាំងឡាយស្គាល់លោកថា ***សហម្បតីព្រហ្ម*** ដែលលោកពោលសំដៅថា ***ព្រហ្មុនោ សហម្បតិស្ស*** ដូច្នេះ ។ បទថា ***នស្សតិ វត ភោ*** សេចក្តីថា បានឮថា ព្រហ្មនោះបន្លឺសំឡេងនេះ ដែលព្រហ្មម៉ឺនលោកធាតុបានស្តាប់ហើយ មកប្រជុំគ្នាទាំងអស់ ។ បទថា ***យត្រ ហិ នាម*** បានដល់ក្នុងលោកឈ្មោះណា ។ បទថា ***បុរតោ បាតុរហោសិ*** សេចក្តីថា បានប្រាកដព្រមនឹងព្រហ្មមួយម៉ឺនទាំងនោះ ។ បទថា ***អប្បរជក្ខជាតិកា*** សេចក្តីថា សត្វ

ឈ្មោះថា **អប្បរជក្ខជាតិកា** ព្រោះមានធូលី គឺ រាគៈ ទោសៈ និងមោហៈ ក្នុងភ្នែកដែលសម្រេចដោយបញ្ញាតិច គឺ តិចតួច ដោយសភាពយ៉ាងនេះ ។ បទថា **អស្សវនតា** បានដល់ ព្រោះមិនបានស្ដាប់ ។ ដោយបទថា **ភវិស្សន្តិ** លោកសម្ដែងថា អ្នកបំពេញបុណ្យចាស់មកហើយ ដោយអំណាចបុញ្ញកិរិយា-វត្ថុ ១០ ប្រការ ក្នុងព្រះពុទ្ធអង្គមុនៗ ដល់ភាពចាស់ក្លា ប្រាថ្នាតែការស្ដាប់ធម៌ប៉ុណ្ណោះ ដូចផ្កាបទុម ប្រាថ្នាតែនឹងសម្ផស្សរស្មីព្រះអាទិត្យដូច្នោះ គប្បីឈានចុះកាន់អរិយភូមិក្នុងទីបំផុតនៃគាថា ៤ បទ មិនមែនមួយនាក់ មិនមែនពីរនាក់ នឹងជាអ្នកដឹងទូទៅដល់ធម៌ចំនួនច្រើនសែន ។

បទថា **បាតុរហោសិ** ប្រែថា ប្រាកដហើយ ។ បទថា **សមលេហិ ចិន្តិតោ** បានដល់ ដែលគ្រូទាំង ៦ មានមន្ទិលគិតគ្នាហើយ ។ ពិតណាស់ គ្រូទាំង ៦ នោះ កើតមុន សម្ដែងធម៌ គឺ មិច្ឆាទិដ្ឋិដែលមានមន្ទិល ដូចរាយបន្លា និងជះថ្នាំពិសទៅទូទាំងជម្ពូទ្វីប ។ បទថា **អបាបុរេតំ** សេចក្ដីថា ចូរបើកទ្វារអមតនគរនោះ ។ បទថា **អមតស្ស ទ្វារំ** បានដល់ អរិយមគ្គ ដែលជាទ្វារនៃអមតនគរ គឺ ព្រះនិព្វាន ។ ដោយពាក្យថា **សុណន្តុ ធម្មំ វិមលេ-នានុពុទ្ធំ** ព្រហ្មទូលអារាធនាថា បពិត្រព្រះមានព្រះភាគ ក្នុងខណៈនោះសូម

សត្វទាំងនេះ ចូរស្តាប់ធម៌ គឺ សច្ចៈ ៤ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រាសចាក មន្ទិល ព្រោះមិនមានមន្ទិល មានរាគៈជាដើម ត្រាស់ដឹងហើយ ។

បទថា **សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ** សេចក្តីថា ដូចឈរនៅលើ កំពូលភ្នំថ្មសុទ្ធ ។ ពិតណាស់ កិច្ច គឺ ការអើត.កចេញទៅជាដើម ដើម្បី សម្លឹងដល់អ្នកដែលឈរក្នុងទីនោះ រមែងមិនមាន ។ បទថា **តថូបមំ** សេចក្តីថា មានចំណែកប្រៀបធៀបដោយភ្នំនោះ គឺ មានឧបមាដូចភ្នំថ្ម ។ ក៏សេចក្តី សង្ខេបក្នុងសេចក្តីនេះ មានដូច្នេះ បុរសអ្នកមានចក្ខុឈរលើកំពូលភ្នំថ្ម គប្បី មើលឃើញប្រជុំជនដោយជុំវិញ យ៉ាងណា បពិត្រព្រះមានព្រះភាគទ្រង់មាន មេធា ទ្រង់មានបញ្ញាល្អ ទ្រង់មានចក្ខុដោយជុំវិញ ដោយព្រះសព្វញ្ញុតញ្ញាណ សូម្បីព្រះអង្គក៏ដូច្នោះដែរ មេត្តាស្តេចឡើងកាន់ប្រាសាទដែលសម្រេចដោយ ធម៌ សម្រេចដោយបញ្ញា ព្រះអង្គក៏ប្រាសចាកសេចក្តីសោក ទ្រង់ពិចារណា ឃើញពួកជន ដែលសេចក្តីសោក និងត្រូវជាតិជរាគ្របសង្កត់ ។ ក៏ក្នុងសេចក្តី នោះ មានអធិប្បាយដូច្នេះ ។ ដូចជា ជនទាំងឡាយ ធ្វើស្រែជុំវិញដោយជុំវិញ ក្បែរជើងភ្នំ ធ្វើខ្ទមច្រើនខ្នងត្រង់ជួរភ្លឺស្រែ ក្នុងទីនោះ បង្កាត់ភ្លើងទុករហូត មួយយប់នៃរាត្រី នឹងគប្បីមានតែសេចក្តីងងឹតដែលប្រកបដោយអង្គ ៤ ដូច្នោះ

កាលបុរសអ្នកមានចក្ខុនោះ ឈរលើកំពូលភ្នំសម្លឹងមើលផែនដី ដូរក្ដីស្រែក៏មិនប្រាកដ ខ្ទមទាំងឡាយក៏មិនប្រាកដ អ្នកដែលដេកនៅក្នុងទីខ្ទមនោះក៏មិនប្រាកដ ប្រាកដត្រឹមតែពន្លឺភ្លើងក្នុងខ្ទមប៉ុណ្ណោះ យ៉ាងណា កាលព្រះតថាគតឡើងកាន់ប្រាសាទ គឺ ធម៌ ត្រួតមើលពួកសត្វ ក៏ដូច្នោះ ពួកសត្វអ្នកមិនធ្វើសេចក្ដីល្អទុក សូម្បីអង្គុយក្នុងខាងស្ដាំព្រះជានុ ក្នុងវិហារតែមួយ ក៏មិនប្រាកដដល់ពុទ្ធចក្ខុបាន ដូចជាកូនសរដែលបាញ់ទៅក្នុងវេលាយប់ តែពួកវេនេយ្យ-សត្វអ្នកបានធ្វើសេចក្ដីល្អទុកប៉ុណ្ណោះ សូម្បីនឹងនៅក្នុងទីឆ្ងាយ ក៏មកប្រាកដដល់ពុទ្ធចក្ខុនោះបាន ។ វេនេយ្យសត្វនោះ ដូចជាភ្លើង និងដូចជាភ្នំហិមវន្តសមដូចដែលព្រះអង្គត្រាស់ទុកថា ៖

ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ
អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរាតិ ។

សប្បុរសទាំងឡាយ រមែងប្រាកដក្នុងទីឆ្ងាយបាន ដូចជាភ្នំហិមពាន យ៉ាងនោះឯង ឯអសប្បុរសទាំងឡាយ (ទោះបីនៅក្នុងទីជិតនេះ) ក៏មិនប្រាកដ ដូចកូនសរ ដែលបុគ្គលបាញ់ចោលក្នុងពេលយប់ យ៉ាងនោះឯង ។

[៣៦] បទថា **អជ្ឈេសនំ** បានដល់ ការអារាធនា ។ បទថា **ពុទ្ធចក្ខុនា** បានដល់ ដោយឥន្ទ្រិយបរោបរិយត្តញាណ និងអាសយានុសយញាណ ។ ពិតណាស់ ពាក្យថា **ពុទ្ធចក្ខុ** ជាឈ្មោះរបស់ញាណទាំង ២ នេះ ។ ពាក្យថា **សមន្តចក្ខុ** ជាឈ្មោះរបស់សព្វញ្ញុតញ្ញាណ ។ ពាក្យថា **ធម្មចក្ខុ** ជាឈ្មោះរបស់មគ្គញាណទាំង ៣ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អប្បរជក្ខេ** ជាដើម ដូចតទៅនេះ ៖

ក៏ជនពួកណាមានធូលី គឺ កិលេស មានរាគៈជាដើមក្នុងចក្ខុ គឺ បញ្ញាតិច ដោយន័យដូចពោលហើយ ជនទាំងនោះ ឈ្មោះថា **អប្បរជក្ខា** អ្នកមានធូលី គឺ កិលេសក្នុងភ្នែកតិច ។ ជនពួកណា មានធូលី គឺ កិលេសក្នុងភ្នែកច្រើន ជនទាំងនោះ ឈ្មោះថា **មហារជក្ខា** អ្នកមានកិលេសក្នុងភ្នែកច្រើន ។ ជនពួកណា មានឥន្ទ្រិយ មានសទ្ធាជាដើមចាស់ក្លា ជនទាំងនោះ ឈ្មោះថា **តិក្ខិន្ទ្រិយា** មានឥន្ទ្រិយចាស់ក្លា ។ ជនពួកណា មានឥន្ទ្រិយទាំងនោះតិច ជនទាំងនោះ ឈ្មោះថា **មុទិន្ទ្រិយា** មានឥន្ទ្រិយទន់ខ្សោយ ។ ជនពួកណា មានអាការ គឺ មានសទ្ធាជាដើមល្អ ជនទាំងនោះ ឈ្មោះថា **ស្វាការា** មានអាការល្អ ។ ជនពួកណា កំណត់ហេតុដែលគេសម្តែងហើយ អាចឲ្យអ្នកដទៃយល់បានដោយ

ឆាយ ជនពួកនោះ ឈ្មោះថា **សុវិញ្ញាបយ** នឹងគប្បីទូន្មានឲ្យដឹងបានដោយងាយ ។ ជនពួកណា ឃើញបរលោក និងទោសថា ជាភ័យ ជនទាំងនោះ ឈ្មោះថា **បរលោកវជ្ជភយទស្សាវី** ។ ក្នុងសេចក្ដីនេះ មានព្រះបាលីដូចតទៅនេះ ៖

បុគ្គលដែលមានសទ្ធា ឈ្មោះថា **អប្បរជក្ខ** មានកិលេសដូចធូលីក្នុងភ្នែកតិច ។ បុគ្គលដែលមិនមានសទ្ធា ឈ្មោះថា **មហារជក្ខ** មានកិលេសដូចធូលីក្នុងភ្នែកច្រើន , អ្នកប្រារព្ធសេចក្ដីព្យាយាម ឈ្មោះថា **អប្បរជក្ខ** ។ អ្នកខ្ជិលច្រអូស ឈ្មោះថា **មហារជក្ខ** , អ្នកមានសតិតាំងមាំ ឈ្មោះថា **អប្បរជក្ខ** អ្នកមិនមានសតិ ឈ្មោះថា **មហារជក្ខ** អ្នកមានចិត្តតាំងមាំ ឈ្មោះថា **អប្បរជក្ខ** អ្នកមានចិត្តមិនតាំងមាំ ឈ្មោះថា **មហារជក្ខ** , អ្នកមានបញ្ញាឈ្មោះថា **អប្បរជក្ខ** , អ្នកមានបញ្ញាទន់ខ្សោយ ឈ្មោះថា **មហារជក្ខ** អ្នកមានកិលេសដូចធូលីក្នុងភ្នែកច្រើន ។ម្យ៉ាងទៀត បុគ្គលដែលមានសទ្ធា ឈ្មោះថា **តិក្ខិន្ទ្រិយ** មានឥន្ទ្រិយចាស់ក្លា បុគ្គលដែលមានបញ្ញា ឈ្មោះថា មានប្រក្រតីឃើញបរលោក និងទោសថា ជាភ័យ បុគ្គលមានបញ្ញាទន់ខ្សោយ ឈ្មោះថា មិនឃើញបរលោក និងទោសថា ជាភ័យ ។ បទថា **លោកោ** បាន

ដល់ ខន្ធលោក ធាតុលោក អាយតនលោក សម្បត្តិភវលោក វិបត្តិភវ-លោក ។ លោកមួយ បានដល់ សត្វទាំងពួងតាំងនៅបានដោយអាហារ , លោក ២ បានដល់ នាម និងរូប , លោក ៣ បានដល់ វេទនា ៣ , លោក ៤ បានដល់ អាហារ ៤ , លោក ៥ បានដល់ ឧបាទានខន្ធ ៥ , លោក ៦ បានដល់ អាយតនៈខាងក្នុង ៦ , លោក ៧ បានដល់ វិញ្ញាណឋិតិ ៧ , លោក ៨ បានដល់ លោកធម៌ ៨ , លោក ៩ បានដល់ សត្តាវាស ៩ , លោក ១០ បានដល់ អាយតនៈ ១០ , លោក ១២ បានដល់ អាយតនៈ ១២ , លោក ១៨ បានដល់ ធាតុ ១៨ ។ បទថា **វជ្ជំ** សេចក្ដីថា កិលេសទាំងអស់ ឈ្មោះថា **ទោស** , ទុច្ចរិតទាំងអស់ ឈ្មោះថា **ទោស** , អភិសង្ខារទាំងអស់ ឈ្មោះថា **ទោស** , កម្មដែលនាំសត្វទៅកាន់ភពទាំងអស់ ឈ្មោះថា **ទោស** សេចក្ដីសម្គាល់ថា ក្នុងលោកនេះ និងទោស នេះជាភ័យទាំងអស់ ប្រាកដដូចពេជ្ឈ-ឃាតងារដាវ ។ ដឹង ឃើញ ដឹងទូទៅ ចាក់ធ្លុះនូវឥន្ទ្រិយទាំង ៥ នេះ ដោយអាការ ៥០ នេះឈ្មោះថា ឥន្ទ្រិយបរោបរិយត្តញាណរបស់ព្រះតថាគត ។

បទ **ឧប្បលិនិយំ** បានដល់ ក្នុងគុម្ពឧប្បល ។ សូម្បីក្នុងបទក្រៅពីនេះ ក៏ន័យនេះដូចគ្នា ។ បទថា **អន្តោនិមុគ្គាបោសីនី** បានដល់ ផ្កាឈូកដែល

លិចនៅក្នុងទឹក និងលូតតាមទឹក ។ បទថា **ឧទកំ អច្ចុគ្គម្ម តិដ្ឋន្តិ** បានដល់ផ្កាឈូកដែលលូតផុតពីទឹក ។ ក្នុងផ្កាឈូកទាំងនោះ ផ្កាឈូកដែលផុតពីទឹករមែងរង់ចាំសម្ផស្សរស្មីព្រះអាទិត្យ ដែលនិងរីកក្នុងថ្ងៃនេះ តែផ្កាឈូកដែលតាំងនៅស្មើទឹក នឹងរីកក្នុងថ្ងៃស្អែកនេះ , ផ្កាឈូកដែលនៅមិនទាន់ផុតពីទឹកនៅក្នុងទឹក ត្រូវលូតលាស់តាមទឹក នឹងរីកបានក្នុងថ្ងៃទី ៣ សូម្បីផ្កាឈូកដែលកើតក្នុងទឹកជាដើមដទៃៗ ដែលនៅមិនទាន់ផុតពីទឹកក៏មាន ដែលមិនទាន់រីកក៏ជាចំណីរបស់ត្រី និងអណ្តើកប៉ុណ្ណោះ ផ្កាឈូកទាំងនោះ មិនបានលើកឡើងកាន់ព្រះបាលី តែលោកនាំទុកថា គួរសម្តែង ។

បុគ្គល ៤ ពួក គឺ ឧគ្ឃដិតញ្ញូ វិបចិតញ្ញូ នេយ្យៈ បទបរមៈ ក៏ដូចជាផ្កាឈូកទាំង ៤ ប្រភេទនោះឯង ។

ក្នុងបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាត្រាស់ដឹងធម៌ព្រមនឹងពេលដែលទ្រង់លើកមាតិកាធម៌ឡើងសម្តែង បុគ្គលនេះហៅថា **ឧគ្ឃដិតញ្ញូ** ។ បុគ្គលណាត្រាស់ដឹងធម៌ ក្នុងកាលដែលទ្រង់ចែកអត្ថនៃធម៌ ដែលពោលដោយសង្ខេបឲ្យពិស្តារ បុគ្គលនេះហៅថា **វិបចិតញ្ញូ** ។ បុគ្គលណា ពោលដោយឧទ្ទេសដោយសាកសួរ ធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ សេពគប់ ចូលទៅអង្គុយ

ជិតកល្យាណមិត្ត ត្រាស់ដឹងធម៌ដោយលំដាប់ បុគ្គលនេះហៅថា **នេយ្យ** ។ បុគ្គលណាស្តាប់ច្រើនក្តី ពោលច្រើនក្តី ចាំទុកបានច្រើនក្តី ឲ្យអ្នកដទៃទូន្មានច្រើនក្តី នឹងត្រាស់ដឹងធម៌ក្នុងជាតិនោះមិនបាន បុគ្គលនេះហៅថា **បទបរម** ។ ក្នុងបុគ្គលទាំង ៤ ពួកនោះ ព្រះមានព្រះភាគ ទ្រង់ត្រួតមើលមុឺនលោកធាតុដែលដូចគុម្ពឧប្បលជាដើម ទ្រង់បានឃើញថា ឧគ្ឃដិតញ្ញូ ដូចជាផ្កាឈូកដែលនឹងរីកក្នុងថ្ងៃនេះ , វិបចិតញ្ញូ ដូចជាផ្កាឈូក ដែលនឹងរីកក្នុងថ្ងៃស្អែក , នេយ្យៈ ដូចជាផ្កាឈូកដែលនឹងរីកក្នុងថ្ងៃទី ៣ , បទបរមៈ ដូចជាផ្កាឈូកដែលជាចំណីរបស់ត្រី និងអណ្តើក ។ ព្រះមានព្រះភាគ កាលទ្រង់ឃើញទ្រង់បានឃើញដោយអាការទាំងពួងយ៉ាងនេះថា សត្វមានប្រមាណប៉ុណ្ណោះមានកិលេសដូចធូលីក្នុងភ្នែកតិច សត្វមានប្រមាណប៉ុណ្ណោះ មានកិលេសដូចធូលីក្នុងភ្នែកច្រើន សូម្បីក្នុងសត្វទាំងនោះ សត្វមានប្រមាណប៉ុណ្ណោះ ជាឧគ្ឃដិតញ្ញូ ។

ក្នុងបុគ្គលទាំង ៤ ពួកនោះ ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគរមែងសម្រេចប្រយោជន៍ដល់បុគ្គល ៣ ពួក (ដំបូង) ក្នុងអត្តភាពនេះតែឯងចំណែកពួកបទបរមៈ រមែងជាវាសនា (អប់រំបន្ទុំបារមី) ដើម្បីសម្រេចប្រយោជន៍

ក្នុងអនាគតកាល ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា ការសម្តែងធម៌នឹងនាំប្រយោជន៍មកដល់បុគ្គលទាំង ៤ ពួកនេះ ទើបទ្រង់មានព្រះបំណងនឹងសម្តែងធម៌ ហើយទ្រង់បែងចែកពួកសត្វក្នុងភព ៣ ទាំងអស់ជា ២ ចំណែក គឺ ភព្វបុគ្គល និងអភព្វបុគ្គលទៀត ដែលទ្រាស់ទុកថា ៖

ពួកសត្វណាជាអភព្វបុគ្គល ដូចម្តេច គឺ ពួកសត្វដែលប្រកបដោយគ្រឿងរាំងគឺ **កម្ម** , ប្រកបដោយគ្រឿងរាំង គឺ **វិបាក** , ប្រកបដោយគ្រឿងរាំង គឺ **កិលេស** , ជាអ្នកមិនមានសទ្ធា មិនមានឆន្ទៈ មានបញ្ញាទន់ខ្សោយ មិនគួរឈានចុះកាន់សម្មត្តនិយាមក្នុងធម៌ជាកុសលទាំងឡាយនេះ គឺ ពួកសត្វនោះ ជាអភព្វបុគ្គល ។

ពួកសត្វជាភព្វបុគ្គល តើដូចម្តេច គឺ ពួកសត្វដែលមិនប្រកបដោយគ្រឿងរាំង គឺ **កម្ម** ។បេ។ នេះគឺ ពួកសត្វជាភព្វបុគ្គល ។ ក្នុងបុគ្គល ២ ពួកនោះ ព្រះមានព្រះភាគ ទ្រង់លះអភព្វបុគ្គលទាំងអស់ ទ្រង់ញុំាងព្រះញាណកំណត់ភព្វបុគ្គលទាំងនោះ បែងចែកជា ៦ ពួក ថា ក្នុងទីនេះ មានពួកដែលជារាគចរិតប្រមាណប៉ុណ្ណេះ ពួកទោសចរិតប្រមាណប៉ុណ្ណេះ ពួកមោហចរិតវិតក្កចរិត សទ្ធាចរិត និងពុទ្ធិចរិតប្រមាណប៉ុណ្ណេះ ។ លុះទ្រង់បែងចែកយ៉ាង

នេះហើយ ទើបមានព្រះពុទ្ធតម្រិះថា ទ្រង់នឹងសម្តែងធម៌ ។

បទថា **បចូ្ចកាសិ** បានដល់ បានត្រាស់តប ។ បទថា **អបារុតា** បាន ដល់ បើកហើយ ។ បទថា **អមតស្ស ទ្វារា** បានដល់ ព្រះអរិយមគ្គ ។ ពិត ណាស់ ព្រះមានព្រះភាគទ្រង់សម្តែងថា ព្រះអរិយមគ្គនោះជាទ្វារនៃព្រះនិព្វាន ពោលគឺ អមតនគរ ព្រះអរិយមគ្គនោះ តថាគតបើកហើយ ស្ថាបនាទុកហើយ ។ បទថា **បមុញ្ចន្តុ សទ្ធំ** សេចក្តីថា ជនទាំងពួងចូរបង្ហូរ គឺ បញ្ចេញសទ្ធារបស់ ខ្លួនចេញមក ។ ក្នុង ២ បទក្រោយ មានសេចក្តីដូច្នេះថា ពិតណាស់ តថាគត សម្គាល់ថា នឹងលំបាកកាយ និងវាចា ទើបមិនសម្តែងធម៌ដែលស្ទាត់ជំនាញ ហើយ ជាធម៌ប្រណីតឧត្តមរបស់តថាគត សូម្បីតថាគតក៏ព្រមប្រកាសហើយ ឥឡូវនេះ ជនទាំងពួងចូរបង្អោនភាជនៈ គឺ សទ្ធាចូលមក តថាគតនឹងធ្វើនូវ សេចក្តីត្រិះរិះរបស់ពួកគេឲ្យពេញ ។

**[៧៧]** បទថា **អន្តរធាយិ** សេចក្តីថា ស្តេចសហម្បតីព្រហ្មយករបស់ ក្រអូប និងផ្កាឈើជាដើម បូជាព្រះសាស្តាហើយក៏អន្តរធានទៅ អធិប្បាយ ថា ទៅកាន់ទីនៅរបស់ខ្លួនទុំះឯង ។ កាលស្តេចសហម្បតីព្រហ្មនោះ ស្តេច ទៅហើយ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា តថាគតនឹងគប្បីសម្តែងធម៌ដល់

អ្នកណាមុនហ្ន៎ ទ្រង់ជ្រាបថា អាឡារតាបស និងឧទ្ទកតាបស ធ្វើមរណកាលហើយ និងជ្រាបថា ពួកបញ្ចវគ្គិយ មានឧបការៈច្រើន ទ្រង់ប្រាថ្នាសម្ដែងធម៌ដល់បញ្ចវគ្គិយទាំងនោះ ទើបស្ដេចទៅកាន់ឥសិបតនមិគទាយវ័ន ក្រុងពារាណសី ហើយទ្រង់ប្រកាសធម្មចក្រ ដូច្នេះឯង ។

ចប់អដ្ឋកថា អាយាចនសូត្រទី ១

# អ ដ្ឋ ក ថា

## គារវសូត្រទី ២

ក្នុងគារវសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[៣៨]** បទថា ***ឧទបាទិ*** សេចក្ដីថា សេចក្ដីត្រិះរិះនេះ កើតឡើងក្នុងសប្ដាហ៍ទី ៥ ។ បទថា ***អគារវោ*** សេចក្ដីថា វៀរគារវៈក្នុងបុគ្គលណាមួយ គឺ ទ្រង់មិនតាំងអ្នកណាៗ ទុកក្នុងឋានៈជាទីគោរព ។ បទថា ***អប្បតិស្សោ*** សេចក្ដីថា វៀរចាកសេចក្ដីកោតក្រែង គឺ ទ្រង់មិនតាំងអ្នកណាៗ ទុកក្នុងឋានៈជាអ្នកប្រសើរបំផុត ។

**[៣៩]** ក្នុងបទថា ***សទេវកេ*** ជាដើម មានវិនិច្ឆ័យថា ព្រមដោយទេវតាទាំងឡាយ ឈ្មោះ ***សទេវកៈ*** ។ កាលកាន់យកពួកមារ និងព្រហ្ម ដោយទេវៈស័ព្ទ ក៏ក្នុងពាក្យនេះ ***ស្ដេចវសវត្តីមារ*** រមែងមានអំណាចលើមារ និងព្រហ្មទាំងអស់ ធម្មតាថា ព្រហ្មមានអានុភាពច្រើន ប្រើម្រាមដៃមួយផ្សាយរស្មីទៅក្នុងមួយចក្រវាឡ ប្រើម្រាមដៃ ២ ផ្សាយរស្មីទៅ ២ ចក្រវាឡ ។ល។ ប្រើម្រាមដៃ ១០ ផ្សាយរស្មីទៅម៉ឺនចក្រវាឡ ។ ព្រហ្មដែលមានអានុភាពច្រើន

នោះ កុំពោលថា មានសីលប្រសើរជាងព្រះមានព្រះភាគ ដូច្នោះ ទើបទ្រង់ត្រាស់ថា **សមារកេ សព្រហ្មកេ** ដូច្នេះ ។ មួយទៀត ធម្មតាសមណៈទាំងឡាយជាពហុស្សូត ដែលដឹងនិកាយមួយជាដើម មានសីល ជាបណ្ឌិត សូម្បីព្រាហ្មណ៍ទាំងឡាយជាពហុស្សូត ដែលចេះវិជ្ជាមើលផែនដីជាដើម សមណព្រាហ្មណ៍ទាំងនោះ កុំពោលថា ប្រសើរជាងព្រះមានព្រះភាគ ដូច្នោះ ទើបត្រាស់ថា **សស្សមណព្រាហ្មណិយា បជាយ** ដូច្នេះ ។ ក៏ពាក្យថា **សទេវមនុស្សាយ** នេះ ត្រាស់រួបរួមដើម្បីសម្ដែងដោយសព្វគ្រប់ ។ម្យ៉ាងទៀត ក្នុងពាក្យនេះ ៣ បទខាងដើម ត្រាស់សំដៅដល់លោក ។ ២ បទខាងក្រោយ ត្រាស់សំដៅដល់ពួកសត្វ ។ បទថា **សីលសម្បន្នតរំ** សេចក្ដីថា បរិបូណ៌ជាង គឺក្រៃលែងជាងដោយសីល ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ ក៏ក្នុងទីនេះធម៌ ៤ ប្រការ មានសីលជាដើម លោកពោលទុកទាំងលោកិយៈ ទាំងលោកុត្តរៈ ។ វិមុត្តិញាណទស្សនៈ ជាលោកិយៈប៉ុណ្ណោះ និងវិមុត្តិញាណ-ទស្សនៈនោះ ជាបច្ចវេក្ខណញ្ញាណ ។

**[៤០]** បទថា **បាតុរហោសិ** សេចក្ដីថា ស្ដេចសហម្បតីព្រហ្មគិតថាព្រះសាស្ដា ទ្រង់មិនឃើញអ្នកដ៏ធំក្រៃលែងជាងព្រះអង្គ ដោយសីលជាដើម

តាំងពីអវិចីដរាបដល់ភវគ្គព្រហ្ម ទ្រង់ត្រិះរិះថា តថាគតនឹងគោរពលោកុត្តរ-ធម៌ ៩ ដែលតថាគតត្រាស់ដឹងហើយនេះឯង ព្រះមានព្រះភាគទ្រង់ត្រិះរិះដល់ហេតុ ទ្រង់គិតដល់ប្រយោជន៍ពិសេស ចាំយើងនឹងទៅធ្វើឧស្សាហ៍ឲ្យកើតដល់ព្រះអង្គ ដូច្នេះ ហើយបានប្រាកដចំពោះមុខ គឺ ឈរក្នុងទីចំពោះព្រះភ័ក្ត្រ ។ ក្នុងបទថា **វិហរឹសុ វិហរន្តិ** ច នេះ មានវិនិច្ឆ័យដូចតទៅនេះ បុគ្គលណាគប្បីពោលថា សូម្បីក្នុងបច្ចុប្បន្នក៏មានព្រះពុទ្ធច្រើនព្រះអង្គ ដោយព្រះបាលីថា **វិហរន្តិ** ដូច្នេះ បុគ្គលនោះ គប្បីជំទាស់ដោយពាក្យនេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលឥឡូវនេះ សូម្បីព្រះមានព្រះភាគក៏ជាព្រះអរហន្តសម្មាសម្ពុទ្ធ តែគប្បីសម្តែងដល់បុគ្គលនោះថា ព្រះពុទ្ធដទៃៗ មិនមាន ដោយព្រះបាលីជាដើមថា ៖

ន មេ អាចរិយោ អត្ថិ សទិសោ មេ នវិជ្ជតិ
សទេវកស្មឹ លោកស្មឹ នត្ថិ មេ បដិបុគ្គលោតិ ។
តថាគតមិនមានអាចារ្យ អ្នកប្រាកដស្មើដូចតថាគត
មិនមានក្នុងលោក ព្រមទាំងទេវលោក មិនមានអ្នក
ប្រៀបផ្ទឹមនឹងតថាគត ដូច្នេះ ។

បទថា **តស្មា** សេចក្តីថា ព្រោះហេតុដែលព្រះពុទ្ធគ្រប់ព្រះអង្គជាអ្នកគោរពព្រះសទ្ធម្ម ។ បទថា **មហត្តមភិកង្ខតា** បានដល់ ប្រាថ្នាភាពជាធំ ។ បទថា **សរំ ពុទ្ធានសាសនំ** បានដល់ រលឹកដល់ពាក្យទូន្មានរបស់ព្រះពុទ្ធទាំងឡាយ ។

ចប់អដ្ឋកថា គារវសូត្រទី២

# អ ដ្ឋ ក ថា

## ព្រហ្មទេវសូត្រទី ៣

*ក្នុងព្រហ្មទេវសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤២] *បទថា* **ឯកោ** *សេចក្តីថា នៅតែម្នាក់ឯង គឺ នៅម្នាក់ឯងក្នុងឥរិយាបថទាំងឡាយ មានឈរជាដើម ។ បទថា* **វូបកដ្ឋោ** *បានដល់ ចៀសចេញទៅ គឺ ប្រាសចាកការប្រឫកប្រឫលដោយកាយ ។ បទថា* **អប្បមត្តោ** *បានដល់ នៅក្នុងកាលជាអ្នកមិនប្រាសចាកសតិ ។ បទថា* **អាតាបី** *បានដល់ ប្រកបដោយសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។ បទថា* **បហិតត្តោ** *បានដល់ មានខ្លួនបញ្ជូនទៅហើយ ។ បទថា* **កុលបុត្តា** *បានដល់ កុលបុត្រជាអ្នកមានមារយាទ ។ បទថា* **សម្មទេវ** *សេចក្តីថា មិនមែនបួសព្រោះជំពាក់បំណុល មិនមែនបួសព្រោះមានភ័យ មិនមែនបួសដើម្បីចិញ្ចឹមជីវិត ។ សូម្បីអ្នកដែលបួសមិនដោយករណីណាៗ បំពេញបដិបទាដែលសមគួរ ក៏ឈ្មោះថាចេញចាកផ្ទះបួសជាបព្វជិតដោយប្រពៃដូចគ្នា ។ បទថា* **ព្រហ្មចរិយបរិយោ-សានំ** *បានដល់ អរិយផលដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ បទថា* **ទិដ្ឋេវ**

ធម្មេ បានដល់ ក្នុងអត្តភាពនេះឯង ។ បទថា **សយំ អភិញ្ញា សច្ឆិកត្វា** បានដល់ ដឹងដោយខ្លួនឯង គឺ ធ្វើឲ្យប្រចក្ស ។ បទថា **ឧបសម្បជ្ជ** បានដល់ បានចំពោះ គឺ សម្រេចនូវផលហើយ ។ ក៏ព្រះព្រហ្មទេវៈ នៅដោយប្រការដូច្នេះ បានដឹងច្បាស់ហើយ ដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់សម្តែងបច្ចវេក្ខណភូមិរបស់លោកដោយបទនេះ ។

សួរថា ក៏ជាតិណារបស់ព្រះព្រហ្មទេវៈនោះអស់ហើយ និងជាតិដែលព្រះព្រហ្មទេវៈដឹងច្បាស់ ប្រការនោះតើដូចម្តេច ។ ឆ្លើយថា ជាតិចំណែកអតីតរបស់ព្រះព្រហ្មទេវៈនោះ ឈ្មោះថា អស់ហើយក៏មិនមែន ព្រោះអស់ទៅហើយក្នុងកាលមុន ជាតិចំណែកអនាគត ឈ្មោះថា អស់ហើយក៏មិនមែន ព្រោះមិនមានសេចក្តីព្យាយាមក្នុងជាតិនោះ ជាតិចំណែកបច្ចុប្បន្ន ក៏ឈ្មោះថា អស់ហើយក៏មិនមែន ព្រោះនៅមាន (គឺកំពុងរស់នៅ) ។ តែជាតិណាផ្សេងដោយជាខន្ធមួយ ខន្ធ ៤ និងខន្ធ ៥ ក្នុងបណ្តាឯកវោការភព ចតុវោការភព និងបញ្ចវោការភព គប្បីកើតឡើង ព្រោះមិនទាន់បានអប់រំមគ្គ ជាតិនោះ ឈ្មោះថា អស់ហើយ ព្រោះដល់ការមិនកើតឡើងជាធម្មតា ព្រោះអប់រំមគ្គហើយ ។ ព្រះព្រហ្មទេវៈនោះ ពិចារណាកិលេសដែលលះបង់បាន

ដោយមគ្គភាវនា រមែងដឹងច្បាស់នូវជាតិនោះថា កម្មសូម្បីមាននៅ ក៏មិនជាហេតុឲ្យបដិសន្ធិតទៅ ព្រោះមិនមានកិលេស ។

បទថា **វុសិតំ** សេចក្តីថា នៅហើយ នៅជុំវិញហើយ អធិប្បាយថា ធ្វើហើយ ប្រព្រឹត្តហើយ គឺ ឲ្យសម្រេចហើយ ។ បទថា **ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ។ បទថា **កតំ ករណីយំ** សេចក្តីថា កិច្ចសូម្បី ១៦ យ៉ាង គឺ បរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច និងភាវនាកិច្ច ដោយមគ្គទាំង ៤ ក្នុងសច្ចៈ ៤ [៤×៤=១៦] ធ្វើស្រេចហើយ ។ បទថា **នាបរំ ឥត្ថត្តាយ** សេចក្តីថា ឥឡូវនេះ មគ្គភាវនាដើម្បីកិច្ចជាយ៉ាងនេះ គឺ ដើម្បីកិច្ចទាំង ១៦ យ៉ាងនេះ ឬដើម្បីការអស់កិលេស មិនមានទៀត ។ម្យ៉ាងទៀត បទថា **ឥត្ថត្តាយ** បានដល់ សភាពយ៉ាងនេះ គឺ ចាកប្រការយ៉ាងនេះ ព្រះព្រហ្មទេវៈបានជ្រាបថា ខន្ធសន្តានដទៃក្រៅពីខន្ធសន្តានដែលប្រព្រឹត្តទៅក្នុងកាលឥឡូវនេះ មិនមាន តែបញ្ចខន្ធទាំងនេះ លោកកំណត់ដឹងហើយ តាំងនៅបាន ដូចដើមឈើមានឫសដាច់ហើយ ។ បទថា **អញ្ញតរោ** ប្រែថា មួយអង្គ ។ បទថា **អរហត្តំ** សេចក្តីថា បានជាព្រះអរហន្តមួយអង្គ ក្នុងបណ្តាព្រះអរហន្តសាវករបស់ព្រះមានព្រះភាគ ។

[៤៣] បទថា **សបទានំ** បានដល់ ត្រាច់ទៅតាមលំដាប់ច្រកផ្លូវ គឺត្រាច់ទៅតាមលំដាប់មិនរំលងផ្ទះដែលដល់ហើយ ។ បទថា **ឧបសង្កមិ** បានដល់ ចូលទៅនៅ ។ ក៏មាតារបស់គេពេលឃើញបុត្រ ក៏ចេញពីផ្ទះ នាំចូលទៅខាងក្នុងទីនៅ ឲ្យអង្គុយលើអាសនៈដែលក្រាលទុក ។

បទថា **អាហុតឹ និច្ចំ បគ្គណ្ហាតិ** សេចក្តីថា ទទួលរបស់បូជា គឺបិណ្ឌបាតក្នុងកាលជានិច្ច ។ ក៏ក្នុងថ្ងៃនោះ មានពលីកម្មដើម្បីកូត (ព្រហ្ម) ក្នុងផ្ទះនោះ ។ គ្រប់ផ្ទះ មានលាបពណ៌ខៀវ ហើយរោយរាយលាជពាសពេញលោមព័ទ្ធជុំវិញដោយទ្រព្យ និងផ្កាឈើ លើកទង់ជ័យ និងទង់សំពត់ពណ៌លឿង តាំងថ្នាំងទឹកមានទឹកពេញទុកក្នុងទីនោះៗ អុជប្រទីបបំភ្លឺ ប្រដាប់ដោយលម្អិតគ្រឿងក្រអូប និងផ្កាឈើជាដើម ។ មានពពិលកាន់ហុចបន្តគ្នាដោយលំដាប់ ។ នាងព្រាហ្មណីនោះ ក្រោកឡើងពីព្រឹកព្រលឹម ងូតទឹកក្រអូប ១៦ ថ្នាំង តាក់តែងរាងកាយដោយគ្រឿងប្រដាប់ជាច្រើន ។ សម័យនោះ នាងឲ្យព្រះមហាខីណាស្រពគង់ហើយ មិនបានថ្វាយសូម្បីត្រឹមតែយាគូមួយបោយគិតថា យើងនឹងឲ្យមហាព្រហ្មបរិភោគ ដាក់បាយបាយាសពេញថាសមាសផ្សំដោយទឹកដោះថ្លាទឹកឃ្មុំ និងដុំស្ករជាដើម ត្រង់ជំបូលផ្ទះ ដែលមានលាប

ពណ៌ខៀវជាដើម នាងកាន់ថាសនោះទៅទីនោះ ដាក់ដុំបាយបាយាសត្រង់ជ្រុងទាំង ៤ និងត្រង់កណ្ដាល ក្នុងដុំនីមួយៗ កាន់ទៅ មានទឹកដោះថ្លាហូរស្រក់ចុះដល់កែងដៃ នាងលុតជង្គង់លើផែនដី ពោលអញ្ជើញព្រហ្មឲ្យបរិភោគថា សូមមហាព្រហ្មចូរបរិភោគ សូមមហាព្រហ្មចូរនាំទៅ សូមមហាព្រហ្មចូរឆ្អែតស្កប់ស្កល់ ដូច្នេះ ។

បទថា **ឯតទ ហោសិ** សេចក្ដីថា សេចក្ដីគិតនេះ បានដឹងដល់ស្ដេចសហម្បតីព្រហ្ម ដែលដឹងក្លិនសីលរបស់ព្រះមហាខីណាស្រព ដែលផ្សាយទៅកាន់ទេវលោក រហូតដល់ព្រហ្មលោក ។ បទថា **សំវេជេយ្យំ** បានដល់ ដាស់តឿនឲ្យសង្វេគ គឺ គប្បីឲ្យប្រកបក្នុងសម្មាបដិបត្តិ ។ អធិប្បាយថា ពិតហើយនាងព្រាហ្មណីនោះ ឲ្យព្រះមហាខីណាស្រព ដែលជាអគ្គទក្ខិណេយ្យបុគ្គលមានសភាពបែបនេះ គង់ហើយ មិនបានថ្វាយអាហារសូម្បីត្រឹមតែយាគូមួយបោយ គិតថា យើងនឹងឲ្យមហាព្រហ្មបរិភោគ ដូចបោលជញ្ជីងចេញ ហើយប្រើដៃថ្លឹង ដូចបោលស្គរចេញ ហើយប្រគំពោះ ដូចបោលភ្លើងចេញ ហើយផ្លុំអំពិលអំពែក ធ្វើពលីដល់ភូត ព្រហ្មគិតថា យើងនឹងទៅទម្លាយមិច្ឆាទិដ្ឋិរបស់នាង លើកនាងឡើងចេញពីផ្លូវអបាយ នឹងញ៉ាំងនូវឧបាយឲ្យនាងសាបព្រោះ

ទ្រព្យ ៨០ កោដិ ចុះក្នុងព្រះពុទ្ធសាសនា ហើយឡើងកាន់ផ្លូវសួគ៌ ។

**[៤៤]** បទថា *ទូរេ ឥតោ* សេចក្ដីថា ឆ្ងាយពីទីនេះ ។ ពិតណាស់ ដុំសិលាប្រមាណប៉ុនផ្ទះកំពូល ធ្លាក់អំពីព្រហ្មលោក មួយថ្ងៃមួយយប់បានចម្ងាយ ៤៨.០០០ យោជន៍ ប្រើវេលាអស់ ៤ ខែ ដោយទំនងនេះ ទើបធ្លាក់ដល់ផែនដី ព្រហ្មលោកជាន់ក្រោមគេបង្អស់ នៅឆ្ងាយយ៉ាងនេះ ។ បទថា **យស្សាហុតឹ** សេចក្ដីថា ឋានរបស់ព្រហ្មដែលនាងព្រាហ្មណីបូជាដោយដុំបាយនុ៎ះ នៅឆ្ងាយ ។ ក្នុងបទថា ព្រហ្មបថំ នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

មហាព្រហ្មពោលថា ឈ្មោះថា ផ្លូវរបស់ព្រហ្ម បានដល់ កុសលឈាន ៤ ចំណែកវិបាកឈាន ៤ ឈ្មោះថា ជាផ្លូវជីវិតរបស់ព្រហ្មទាំងនោះ នាងមិនដឹងផ្លូវរបស់ព្រហ្មនោះ តើនាងកន្ទួល់ធ្វើអ្វី រវើរវាយធ្វើអ្វី ពិតណាស់ ម្នាលនាង ព្រហ្មទាំងឡាយរមែងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅដោយឈាន ដែលមានបីតិ មិនបានញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបាយនៃស្រូវសាលី និងទំពារស៊ីទឹកដោះដែលរម្ងាស់ហើយនុ៎ះទេ នាងកុំលំបាកព្រោះវត្ថុដែលមិនមែនហេតុឡើយ លុះពោលយ៉ាងនេះហើយ ទើបផ្គងអញ្ជលី ចង្អុលទៅព្រះថេរៈពោលថា ម្នាលនាងព្រាហ្មណី ក៏ព្រះព្រហ្មទេវៈរបស់នាងនៅទីនេះ ដូច្នេះ ជា

ដើម ។ បណ្ដាបទទាំងនោះ បទថា **និរុបធិកោ** សេចក្ដីថា វៀរចាកឧបធិ គឺ កិលេស អភិសង្ខារ និងកាមគុណ ។ បទថា **អតិទេវបត្តោ** សេចក្ដីថា ដល់ភាពជាទេវតាក្រៃលែងជាងទេវតា ដល់ភាពជាព្រហ្មក្រៃលែងជាងព្រហ្ម ។ បទថា **អនញ្ញបោសី** សេចក្ដីថា ឈ្មោះថា មិនចិញ្ចឹមអ្នកដទៃ ព្រោះមិនចិញ្ចឹមអត្តភាពរបស់អ្នកដទៃ ឬបុត្រ និងភរិយា ក្រៅអំពីអត្តភាពរបស់ខ្លួននេះ ។

បទថា **អាហុនេយ្យោ** សេចក្ដីថា គួរដើម្បីនឹងទទួលបិណ្ឌៈដែលគេបូជា បិណ្ឌៈដែលគេទទួលភ្ញៀវ ។ បទថា **វេទគូ** បានដល់ ដល់ទីបំផុតទុក្ខដោយវេទ គឺ មគ្គ ៤ ។ បទថា **ភាវិតត្តោ** បានដល់ អប់រំខ្លួនឲ្យចម្រើនហើយតាំងនៅ ។ បទថា **អនូបលិត្តោ** បានដល់ គ្រឿងលាប គឺ តណ្ហា និងទិដ្ឋិ មិនប្រឡាក់ហើយ ។ បទថា **ឃាសេសនំ ឥរិយតិ** បានដល់ ត្រាច់ស្វែងរកអាហារ ។

បទថា **ន តស្ស បច្ឆា ន បុរត្ថមត្ថិ** សេចក្ដីថា ខាងក្រោយ ហៅថា អតីត ខាងមុខ ហៅថា អនាគត ។ លោកពោលទុកថា ខាងក្រោយ ឬខាងមុខ រមែងមិនមានដល់អ្នកវៀរចាកឆន្ទរាគៈ ក្នុងខន្ធចំណែកអតីត និងខន្ធចំណែកអនាគត ដោយប្រការដូច្នេះ ។ ក្នុងបទថា **សន្តោ** ជាដើម មានវិនិច្ឆ័យដូច

តទៅនេះ ៖

ឈ្មោះថា **សន្តោ** ព្រោះស្ងប់កិលេស មានរាគៈជាដើម ។ ឈ្មោះថា **វិធូម** ព្រោះប្រាសចាកផ្សែង គឺ សេចក្តីក្រោធ ។ ឈ្មោះថា **អនីឃ** ព្រោះមិនមានទុក្ខ ។ សូម្បីកាន់ឈើច្រត់ជាដើមត្រាច់ទៅ ក៏ឈ្មោះថា ដាក់ចុះនូវអាជ្ញាហើយ ព្រោះមិនមានចេតនានឹងសម្លាប់ ។ ក្នុងពាក្យថា **តសថាវរេសុ** នេះ មានវិនិច្ឆ័យដូច្នេះ បុថុជ្ជនទាំងឡាយ ឈ្មោះថា ជាអ្នកតក់ស្លុត ព្រះ-ខីណាស្រពទាំងឡាយ ឈ្មោះថា ជាអ្នករឹងមាំ ។ ព្រះសេក្ខបុគ្គល ៧ ពួក មិនអាចនឹងហៅថា ជាអ្នកតក់ស្លុត និងលោកទាំងនោះមិនមែនជាអ្នករឹងមាំ តែកាលបែងចែកជាពួក ក៏ចែកជាពួករឹងមាំនុ៎ះឯង ។ បទថា **សោ ត្យាហុតឹ** កាត់បទជា **សោ តវ អាហុតឹ** ។

បទថា **វិសេនិភូតោ** សេចក្តីថា ជាអ្នកប្រាសចាកកងទ័ព ដោយកងទ័ព គឺ កិលេស ។ បទថា **អនេជោ** បានដល់ ប្រាសចាកតណ្ហា ។ បទថា **សុសីលោ** បានដល់ ជាអ្នកមានសីលល្អ ដោយសីលរបស់ព្រះខីណាស្រព ។ បទថា **សុវិមុត្តចិត្តោ** សេចក្តីថា មានចិត្តរួចផុតហើយដោយល្អ ដោយផល-វិមុត្តិ ។

បទថា **ឱយតិណ្ណំ** បានដល់ ឆ្លងឱឃៈ ៤ បាន ។ ដោយកថាមគ្គត្រឹមតែប៉ុណ្ណេះ ព្រហ្មសរសើរគុណរបស់ព្រះថេរៈ ហើយប្រកបនាងព្រាហ្មណីទុកក្នុងសម្មាទិដ្ឋិ ។ ក៏អវសានគាថា [គាថាចុងបង្អស់] ព្រះសង្គីតិកាចារ្យទាំងឡាយតាំងទុកហើយ ។ បទថា **បតិដ្ឋបេសិ ទក្ខិណំ** សេចក្ដីថា តាំងទក្ខិណាគឺ បច្ច័យ ៤ ។ បទថា **សុខមាយតិកំ** សេចក្ដីថា មានសុខក្នុងអនាគត គឺមានសុខជាផលក្នុងអនាគត អធិប្បាយថា នាំសុខមកឲ្យ ។

ចប់អដ្ឋកថា ព្រហ្មទេវសូត្រទី ៣

# អ ដ្ឋ ក ថា

## ពកសូត្រទី ៤

ក្នុងពកសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[៤៥]** បទថា **បាបកំ ទិដ្ឋិគតំ** បានដល់ សស្សតទិដ្ឋិដ៏លាមក ។ បទថា **ឥទំ និច្ចំ** សេចក្តីថា ពកព្រហ្ម ពោលឋានៈនៃព្រហ្មព្រមទាំងឱកាសនេះ ដែលមិនទៀង ថាទៀង ។ បទថា **ធុវំ** ជាដើម ជាវេវចនៈរបស់បទថា និច្ចំ នោះឯង ។ បណ្តាបទទាំងនោះ បទថា **ធុវំ** បានដល់ ស្ថិតស្ថេរ ។ បទថា **អចវនធម្មំ** បានដល់ មានការមិនចុតិជាសភាវៈ ។ ក្នុងពាក្យថា **ឥទំ ហិ ន ជាយតិ** ជាដើម លោកពោលសំដៅយកថា ក្នុងស្ថាននេះ មិនមានអ្នកកើត អ្នកចាស់ អ្នកស្លាប់ អ្នកចុតិ ឬអ្នកឧប្បត្តិណាៗ ។ បទថា **ឥតោ ច បនញ្ញំ** សេចក្តីថា ឈ្មោះថា ឧបាយជាគ្រឿងចេញដ៏ក្រៃលែងយ៉ាងដទៃពីស្ថាននៃព្រហ្មព្រមទាំងឱកាសនេះ មិនមាន ។ ពកព្រហ្មនោះ កើតសស្សតទិដ្ឋិយ៉ាងខ្លាំងដោយប្រការយ៉ាងនេះ ។ ក៏ពកព្រហ្មអ្នកមានទិដ្ឋិយ៉ាងនេះ រមែងបដិសេធគុណវិសេសគ្រប់យ៉ាង គឺ ឈានភូមិ ៣ ខាងលើ មគ្គ ៤ ផល ៤ និងព្រះ-

និព្វាន ។ សួរថា ក៏ទិដ្ឋិនោះកើតឡើងដល់ព្រហ្មនោះក្នុងកាលណា ។ ឆ្លើយថា កាលគេកើតក្នុងបឋមជ្ឈានភូមិ ។ អាចារ្យពួកខ្លះពោលថា កើតក្នុងទុតិយ-ជ្ឈានភូមិ ។

ក្នុងសេចក្ដីនោះ មានអនុបុព្វីកថា ដូចតទៅនេះ ៖

បានឮថា ព្រហ្មនេះ ឧប្បត្តិខាងក្រោយកាលមិនទាន់មានព្រះពុទ្ធ ក៏បួសជាឥសី ធ្វើកសិណបរិកម្ម និងធ្វើសមាបត្តិឲ្យកើត មិនសាបសូន្យឈាន ធ្វើកាលៈហើយ កើតក្នុងព្រហ្មលោកជាន់វេហប្ផលាក្នុងចតុត្ថជ្ឈានភូមិ ។ មានអាយុ ៥០០ កប្ប ។ គេតាំងនៅក្នុងព្រហ្មលោកជាន់វេហប្ផលានោះ រហូតដល់អស់អាយុខ័យ ចន្លោះវេលាដែលកើតខាងក្រោយ ចម្រើនតតិយជ្ឈានឲ្យប្រណីត កើតក្នុងព្រហ្មលោកជាន់សុភកិណ្ហៈ មានអាយុ ៦៤ កប្ប ។ ពកព្រហ្មនុ៎ះ ដឹងកម្មដែលខ្លួនធ្វើ និងទីកន្លែងដែលខ្លួនកើតក្នុងបឋមកាល កើតគ្រាដំបូងកាលកាលកន្លងយូរៗ ទៅ ភ្លេចកម្ម និងស្ថានទីទាំង ២ ទើបកើតសស្សត-ទិដ្ឋិ ។

**[៤៧]** បទថា ***អវិជ្ជាគតោ*** សេចក្ដីថា ទៅដោយអវិជ្ជា គឺ ប្រកបដោយសេចក្ដីមិនដឹង មិនមានញាណ ជាបុគ្គលងងឹតដូចមនុស្សខ្វាក់ភ្នែក ។

បទថា **យត្រ ហិ** នាម បានដល់ **យោ** នាម ។

បទថា **វក្ខតិ** ប្រែថា រមែងពោល ។ ក៏ព្រោះប្រកបស័ព្ទនិបាតថា **យត្រ** ពាក្យថា **វក្ខតិ** ក៏ក្លាយជាអនាគតកាល ប្រែថា នឹងពោល ។

កាលពោលយ៉ាងនេះហើយ ព្រហ្មនោះ ត្រូវព្រះមានព្រះភាគសង្កត់សង្កិន បានសតិ កើតការភ័យខ្លាចថា ព្រះមានព្រះភាគទ្រង់សម្លឹងយើងគ្រប់ជំហាន ប្រាថ្នានឹងបង្កិតបង្ខំយើង កាលនឹងប្រាប់សម្លាញ់របស់ខ្លួន ទើបពោលពាក្យថា **ទ្វាសត្តតិ** ជាដើម ដូចចោរត្រូវវាយ ២-៣ ដងក្នុងចន្លោះផ្លូវ អត់ទ្រាំមិនព្រមប្រាប់ដល់ពួកសម្លាញ់ កាលត្រូវវាយធ្ងន់ ទើបប្រាប់ថា អ្នកឯណោះៗ ជាសម្លាញ់របស់យើង ដូច្នោះ សេចក្តីនោះ មានអធិប្បាយដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពួកខ្ញុំព្រះអង្គ ៧២ នាក់ បានធ្វើបុណ្យទុក ទើបកើតក្នុងទីនេះដោយបុញ្ញកម្មនោះ ជាអ្នកមានអំណាចខ្លួនឯង មិននៅក្នុងអំណាចរបស់អ្នកដទៃ ធ្វើអ្នកដទៃឲ្យនៅក្នុងអំណាចរបស់ខ្លួន កន្លងជាតិ និងជរាបាន ។ បពិត្រព្រះមានព្រះភាគ ការឧប្បត្តិក្នុងព្រហ្មលោក ជាគ្រាចុងក្រោយបង្អស់នេះ រាប់ថា **វេទគូ** ព្រោះពួកខ្ញុំព្រះអង្គដល់នូវវេទទាំងឡាយ ។ បទថា **អស្មាភិជប្បន្តិ ជនា អនេកា** សេចក្តីថា ជនជាច្រើន រមែងពេញចិត្តពួកខ្ញុំព្រះអង្គ រមែងប្រាថ្នា

រមែងសន្និដ្ឋានក្នុងចិត្តយ៉ាងនេះថា បពិត្រព្រហ្ម អ្នកនេះឯង ជាមហាព្រហ្មដែលធំក្រៃលែង មិនមានអ្នកណាគ្របសង្កត់បាន ជាអ្នកឃើញច្បាស់ ជាអ្នកប្រើអំណាច ជាឥស្សរៈ ជាអ្នកសាង ជាអ្នកនិម្មិត ជាអ្នកប្រសើរបំផុត ជាអ្នកតាក់តែង ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់វត្ថុដែលកើតហើយនឹងកំពុងកើត ។

**[៤៩]** លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ចំពោះពកព្រហ្មនោះថា **អប្បំ ហិ ឯតំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ឯតំ** សេចក្តីថា អ្នកសម្គាល់អាយុណារបស់អ្នកក្នុងទីនេះថា វែង អាយុនោះតិច គឺ បន្តិចបន្តួច ។ បទថា **សតសហស្សានំ និរព្វុទានំ** បានដល់ មួយសែននិរព្វុទៈ ដោយចំនួននិរព្វុទៈ (និរព្វុទៈជាសង្ខ្យាដែលមានចំនួនលេខសូន្យ ៦៨ សូន្យ) ។ បទថា **អាយុំ បជានាមិ** សេចក្តីថា តថាគតដឹងថា អាយុរបស់អ្នកក្នុងពេលនេះ នៅសល់ត្រឹមតែប៉ុណ្ណោះ ។

**[៥០]** បទថា **អនន្តទស្សី ភគវាហមស្មិ** សេចក្តីថា បពិត្រព្រះមាន-ព្រះភាគ ព្រះអង្គត្រាស់ថា ខ្ញុំព្រះអង្គជាអ្នកមានប្រ ក្រតីឃើញមិនមានទីបំផុតកន្លងជាតិជាដើមបានហើយ ។ បទថា **កិំ មេ បុរាណំ** សេចក្តីថា បើព្រះអង្គជាអ្នកមានប្រក្រតីឃើញមិនមានទីបំផុត បើដូច្នោះ សូមព្រះអង្គមេត្តាត្រាស់

ប្រាប់ប្រការនេះ ដល់ខ្ញុំព្រះអង្គ គឺ អ្វីជាវត្តចាស់របស់ខ្ញុំព្រះអង្គ (ក្នុងអតីត:) ។ សីលទាំងឯង លោកហៅថា សីលវត្ត ។ បទថា **យមហំ វិជញ្ញា** សេចក្ដីថា ពកព្រហ្មពោលថា ខ្ញុំព្រះអង្គគួរជ្រាបប្រការណា ដែលព្រះអង្គត្រាស់ សូមព្រះអង្គមេត្តាប្រាប់ប្រការនោះដល់ខ្ញុំព្រះអង្គ ។

**[៩១]** ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងត្រាស់ប្រាប់ដល់ពកព្រហ្មនោះ បានត្រាស់ព្រះពុទ្ធវចនៈជាដើមថា **យំ ត្វំ អបាយេសិ** ដូច្នេះ ។ ក្នុងសេចក្ដីនោះ មានអធិប្បាយដូច្នេះ បានឮថា កាលមុន ពកព្រហ្មនេះ កើតក្នុងផ្ទះនៃត្រកូលឃើញទោសក្នុងកាមទាំងឡាយ គិតនឹងធ្វើជាតិ ជរា និងមរណៈឲ្យអស់ ទើបចេញបួសជាឥសី ធ្វើសមាបត្តិឲ្យកើត បានឈានដែលជាបាទនៃអភិញ្ញា ធ្វើបណ្ណសាលានៅក្បែរមាត់ច្រាំងទន្លេគង្គា ឲ្យវេលាកន្លងទៅដោយសេចក្ដីត្រេកអរក្នុងឈាន ។ ក៏ក្នុងគ្រានោះ មានពួកឈ្មួញរទេះ ប្រើរទេះ ៥០០ ធ្វើដំណើរឆ្លងកាត់សមុទ្រខ្សាច់រាបស្មើ ។ ក៏ក្នុងសមុទ្រខ្សាច់ មិនមានអ្នកណាអាចធ្វើដំណើរពេលថ្ងៃបាន ដើរបានតែពេលយប់ ។ គ្រានោះ គោដែលទឹមនៅខាងមុខគេបង្អស់ កាលដើរផ្លូវបានវិលត្រឡប់មកកាន់ផ្លូវដើមវិញ រទេះទាំងអស់ ក៏ត្រឡប់យ៉ាងនោះដូចគ្នា ជនទាំងនោះក៏ដឹងក្នុងកាលនៃអរុណរះ។

ក្នុងគ្រានោះ ពួកឈ្មួញរទេះនឹងធ្វងផុតផ្លូវកន្តារបាន ត្រូវប្រើវេលាមួយថ្ងៃ ឧស និងទឹកក៏អស់គ្រប់យ៉ាង ។ ដូច្នោះ ពួកមនុស្សគេគិតថា គ្រានេះពួកយើងនឹងស្លាប់ ចងគោដែលកង់ ហើយចូលទៅដេកត្រង់មួប់រទេះ ។

សូម្បីព្រះតាបស ក៏ចេញចាកបណ្ណសាលាពីព្រឹកព្រលឹម អង្គុយត្រង់ទ្វារបណ្ណសាលា ក្រឡេកមើលទន្លេគង្គា បានឃើញទន្លេគង្គាពេញប្រៀបដោយ អន្លង់ទឹកធំហូរមក ដូចដុំកែវមណី គ្រាឃើញហើយ ទើបគិតថា ក្នុងលោកនេះ មានពួកសត្វដែលលំបាក ព្រោះមិនមានទឹកដែលឆ្ងាញ់បែបនេះ ឬហ្ន៎ ។ ព្រះតាបសនោះ កាលរំពឹងយ៉ាងនោះហើយ ទើបបានឃើញពួករទេះនោះក្នុងសមុទ្រខ្សាច់ គិតថា សត្វទាំងនេះចូរកុំវិនាស ទើបអធិដ្ឋានដោយអភិញ្ញាចិត្តថា សូមទឹកដ៏ធំ ចូរប្រែះខាងឯណោះខ្លះ ខាងនេះខ្លះ ហើយហូរត្រង់ទៅកាន់ពួករទេះក្នុងសមុទ្រខ្សាច់ ។ ព្រមជាមួយចិត្តុប្បាទ ទឹកបានទៅកាន់ទីនោះ ដូចទៅកាន់អណ្តូងដ៏ច្រើន ពួកមនុស្សក្រោកឡើង ព្រោះឮសំឡេងទឹក ឃើញទឹកហើយក៏រីករាយ ត្រេកអរ ងូតផឹក ឲ្យគោទាំងឡាយផឹកទឹកហើយ បានទៅដល់កន្លែងដែលខ្លួនប្រាថ្នាដោយសួស្តី ។ ព្រះសាស្តា កាលទ្រង់សម្តែងបុព្វកម្មរបស់ព្រហ្មនោះ បានត្រាស់គាថាទី ១ ។ បណ្តាបទទាំងនោះ បទថា **អបា-**

**យេសិ** បានដល់ ឲ្យផឹក ។ **អ** អក្សរត្រឹមតែជានិបាត ។ បទថា **យម្ហិ** បានដល់ ក្នុងរដូវក្តៅ ។ បទថា **សម្បរេតេ** សេចក្តីថា ដែលក្តៅក្នុងរដូវក្តៅពាល់ត្រូវ គឺ ជាប់តាម ។

សម័យតមក តាបសសាងបណ្ណសាលាត្រង់មាត់ច្រាំងទន្លេគង្គា អាស្រ័យពួកអ្នកស្រុកជិតព្រៃនោះ ។ ក៏សម័យនោះ ពួកចោរប្លន់អ្នកស្រុកនោះ នាំមេគោ និងមនុស្សទាំងឡាយ ទៅទាំងគោ ទាំងសុនខ ទាំងមនុស្សទាំងឡាយស្រែកឮសំឡេងខ្លាំងៗ ។ តាបសបានឮសំឡេងនោះ រំពឹងថា នេះជាអ្វីហ្នឹ៎ ជ្រាបថា ពួកមនុស្សកើតភ័យ គិតថា កាលយើងឃើញហើយ សត្វទាំងនេះចូរកុំវិនាស ទើបចូលឈានដែលជាបាទនៃអភិញ្ញា ចេញចាកឈានហើយញុំាងអភិញ្ញាចិត្ត និម្មិតកងទ័ព ៤ ពួក ត្រង់ផ្លូវដែលពួកចោរមក ហើយត្រៀមចាំ ។ ពួកចោរឃើញហើយគិតថា កងទ័ពរបស់ព្រះរាជាមក ទើបចោលវត្ថុដែលប្លន់មក និងគេចចេញទៅ ។ ព្រះតាបសអធិដ្ឋានថា គ្រប់យ៉ាងចូរដូចដើម ។ វត្ថុទាំងនោះក៏បានដូចដើម ។ មហាជនក៏មានសេចក្តីសេរីសួស្តី ។ ព្រះសាស្តា កាលទ្រង់សម្តែងបុព្វកម្មរបស់ពកព្រហ្មនោះ ទើបបានត្រាស់គាថាទី ២ ។ បណ្តាបទទាំងនោះ បទថា **ឯណិកូលស្មឹ** បានដល់ ជិតត្រើយទន្លេ

គង្គា ។ បទថា **គយ្ហកំ នីយមានំ** សេចក្តីថា ចាប់នាំទៅ ។ អធិប្បាយថា នាំទៅជាឈ្លើយ ដូច្នេះក៏មាន ។

សម័យតមក ត្រកូលមួយនៅត្រង់ទន្លេគង្គាផ្នែកខាងលើ ចងមេត្រីនឹងត្រកូលមួយដែលនៅត្រង់ទន្លេគង្គាផ្នែកខាងក្រោម ចងទូកភ្ជាប់គ្នា ផ្ទុករបស់ស៊ី របស់ប្រើ គ្រឿងក្រអូប និងផ្កាឈើជាដើមជាច្រើន មកតាមក្រសែទឹកទន្លេគង្គា ។ ពួកមនុស្ស ទំពារស៊ី បរិភោគ រាំច្រៀង បានកើតសោមនស្សរីករាយ ដូចបានទៅក្នុងទេវវិមាន ។ គង្គេយ្យកនាគរាជ ឃើញហើយ ក៏ក្រោធ គិតថា មនុស្សទាំងនេះមិនធ្វើសេចក្តីកោតក្រែងដល់យើង ឥឡូវនេះ យើងនឹងឲ្យពួកវាលិចក្នុងទន្លេឲ្យបាន ទើបនិម្មិតអត្តភាពធំ ញែកទឹកជា ២ ចំណែក អើតក្បាល បើកពពារ បញ្ចេញសំឡេងគម្រាមឃ្ហូរៗ ។ មហាជនឃើញហើយក៏ខ្លាច បានស្រែកលាន់ឮសំឡេងខ្លាំងៗ ។ ក៏ព្រះតាបសអង្គុយនៅក្នុងសាលា បានឮសំឡេងនោះ នឹកថា មនុស្សពួកនេះ នាំគ្នាច្រៀងរាំកើតសោមនស្សរីករាយ ឥឡូវនេះ ស្រាប់តែស្រែកសម្តែងសេចក្តីភ័យខ្លាច ព្រោះហេតុអ្វីហ្ន៎ ព្រះតាបស បានឃើញនាគរាជ គិតថា កាលយើងឃើញហើយ សូមពួកសត្វកុំវិនាស ទើបចូលឈានដែលជាបាទនៃអភិញ្ញា និម្មិត

ជាគ្រុឌសម្តែងដល់នាគរាជ ។ នាគរាជខ្លាច បិទពពារមុជចុះក្នុងទឹកទៅ ។ មហាជនក៏មានសេរីសួស្តី ។ ព្រះសាស្តា កាលទ្រង់សម្តែងបុព្វកម្មរបស់ពកព្រហ្មសូម្បីនេះ ទើបពោលគាថា ទី ៣ ។ បណ្តាបទទាំងនោះ បទថា **លុទ្ធេន** បានដល់ អំណាច ។ បទថា **មនុស្សកម្យា** សេចក្តីថា ព្រោះសេចក្តីអាណិតចំពោះមនុស្ស អធិប្បាយថា ព្រោះប្រាថ្នានឹងដោះលែងពួកមនុស្ស ។

សម័យតមក ពកព្រហ្មនោះបួសជាឥសី បានឈ្មោះថា **កេសវៈ** ។ សម័យនោះ ព្រះពោធិសត្វរបស់ពួកយើងជាមាណព ឈ្មោះថា **កប្បៈ** ជាសិស្សរបស់កេសវតាបស បដិបត្តិចំពោះអាចារ្យ ប្រព្រឹត្តជាទីពេញចិត្ត ជាអ្នកដល់ព្រមដោយបញ្ញា បានជាអ្នកទ្រទ្រង់ទុកនូវអត្ថៈ ។ កេសវតាបសមិនអាចនៅបែកពីកប្បៈជាសិស្សបាន ។ អាស្រ័យកប្បៈប៉ុណ្ណោះ ដើម្បីចិញ្ចឹមជីវិត ។ ព្រះសាស្តា កាលទ្រង់សម្តែងបុព្វកម្មរបស់ពកព្រហ្ម សូម្បីនេះ ទើបត្រាស់គាថា ទី ៤ ។

បណ្តាបទទាំងនោះ បទថា **បដចរោ** បានដល់ អន្តេវាសិក ។ ក៏កប្បមាណពនោះ ជាប្រធានអន្តេវាសិក ។ បទថា **សម្ពុទ្ធិវន្តំ វតិនំ អមញ្ញិ** សេចក្តីថា កប្បមាណពសម្គាល់ថា អាចារ្យកេសវៈនេះមានបញ្ញា សម្បូរណ៍

ដោយវត្តដ៏ប្រពៃ ទើបសម្តែងថា ក្នុងសម័យនោះ តថាគតបានជាអន្តេវាសិករបស់អ្នក ។ បទថា **អញ្ញាសិជានាសិ** សេចក្តីថា មិនមែនដឹងត្រឹមតែអាយុរបស់ខ្ញុំព្រះអង្គតែម៉្យាងប៉ុណ្ណោះ សូម្បីវត្តដទៃៗ ព្រះអង្គក៏ដឹង ។ បទថា **តថា ហិ ពុទ្ធោ** សេចក្តីថា ព្រោះព្រះអង្គជាព្រះពុទ្ធ គឺ ព្រោះជាព្រះពុទ្ធ ដូច្នោះព្រះអង្គទើបជ្រាប ។ បទថា **តថា ហិ ត្យាយំ ជលិតា នុភាវោ** សេចក្តីថា ក៏ព្រោះព្រះអង្គជាព្រះពុទ្ធ ដូច្នោះ ព្រះអង្គទើបមានអានុភាពរុងរឿង ។ បទថា **ឱភាសយំ តិដ្ឋតិ** សេចក្តីថា ញុំាងព្រហ្មលោកទាំងពួងឲ្យភ្លឺស្វាង តាំងនៅ ។

ចប់អដ្ឋកថា ពកសូត្រ ទី ៤

# អ ដ្ឋ ក ថា

## អបរាទិដ្ឋិទី ៥

ក្នុងអបរាទិដ្ឋិសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[៥៧]** បទថា **តេជោធាតុំ សមាបជ្ជិតា** សេចក្តីថា ព្រះថេរៈធ្វើបរិកម្មក្នុងតេជោកសិណ ហើយចេញចាកឈានដែលជាបាទនៃអភិញ្ញា អធិដ្ឋានថា សូមអណ្តាតភ្លើងចូរផ្សាយចេញពីសរីរៈ ដោយអានុភាពនៃចិត្តអធិដ្ឋាន អណ្តាតភ្លើងក៏ផ្សាយចេញទូទាំងសរីរៈ ព្រះថេរៈឈ្មោះថា ចូលតេជោធាតុសមាបត្តិយ៉ាងនេះ ។ លុះចូលសមាបត្តិយ៉ាងនោះហើយ ក៏ទៅក្នុងព្រហ្មលោកនោះ ។ សួរថា ព្រោះហេតុអ្វី ព្រះថេរៈទើបបានទៅក្នុងទីនោះ ។ ឆ្លើយថា បានឮថា ព្រះថេរៈចូលសមាបត្តិមានតេជោធាតុជាអារម្មណ៍ ឃើញព្រះតថាគតប្រថាប់អង្គុយលើព្រហ្មនោះ ទើបមានសេចក្តីត្រិះរិះដូច្នេះថា បុគ្គលនេះជាអ្នកចាក់ទម្លុះអដ្ឋិ[១] ក៏យើងគប្បីទៅក្នុងទីនោះ ដូច្នោះ ទើបបានទៅក្នុងទីនោះ ។ សូម្បីក្នុងការទៅរបស់ព្រះថេរៈដ៏សេស ក៏មានន័យនេះដូចគ្នា ។

---

១- បាលី អដ្ឋិវេធី អយំ បុគ្គលោ ។

សុប្បីព្រហ្មនោះ មិនបានឃើញអានុភាពរបស់ព្រះតថាគត និងសាវករបស់ព្រះតថាគត ទើបមិនគួរចូលដល់ការណែនាំ ។ ដោយហេតុនោះ ទើបបានមានប្រជុំគ្នាយ៉ាងនោះ ក្នុងទីប្រជុំនោះ អណ្តាតភ្លើងដែលផ្សាយចេញពីព្រះសរីរៈរបស់ព្រះតថាគត កន្លងហួសព្រហ្មលោកទាំងអស់ ផ្សាយទៅក្នុងអជ-ជាកាស ក៏វណ្ណៈទាំងនោះ មាន ៦ ពណ៌ ឯរស្មីរបស់សាវកព្រះតថាគត ក៏មានវណ្ណៈធម្មតាន់ុះឯង ។

[៥៨] ដោយពាក្យថា **បស្សសិ វីតិវត្តន្តំ** នេះ ព្រះថេរៈសួរថា អ្នកឃើញរស្មីដែលផ្សាយចេញចាកព្រះសរីរៈរបស់ព្រះមានព្រះភាគ ដែលកន្លងបង់នូវរស្មីនៃសរីរៈរបស់ព្រហ្មវិមាន និងគ្រឿងប្រដាប់ជាដើម យ៉ាងដទៃក្នុងព្រហ្មលោកនេះឬទេ ។

[៥៩] បទថា **ន មេ មារិស សា ទិដ្ឋិ** សេចក្តីថា ទិដ្ឋិនោះ របស់យើងថា អ្នកដទៃ មិនថាសមណៈ ឬព្រាហ្មណ៍ក៏ដោយ មិនអាចនឹងមកក្នុងទីនេះបាន តែទិដ្ឋិរបស់យើងនោះពីមុនមិនមានទេ ។ បទថា **កថំ វជ្ជំ** សេចក្តីថា ព្រោះហេតុអ្វី យើងទើបពោល ។ បទថា **និច្ចោម្හិសស្សតោ** សេចក្តីថា បានឮថា ព្រហ្មនេះមានទិដ្ឋិ ២ យ៉ាង គឺ លទ្ធិទិដ្ឋិ និងសស្សតទិដ្ឋិ ។ ក្នុងទិដ្ឋិ

២ យ៉ាងនោះ ព្រហ្មនោះកាលឃើញព្រះតថាគត និងសាវករបស់ព្រះតថាគត រមែងជាការលះលទ្ធិទិដ្ឋិបាន ក៏ព្រះមានព្រះភាគ ទ្រង់សម្តែងព្រះធម៌ទេសនាជាច្រើនក្នុងរឿងទិដ្ឋិ ២ យ៉ាងនោះ ។ ក្នុងទីបំផុតនៃទេសនា ព្រហ្មតាំងនៅក្នុងសោតាបត្តិផល ។ ព្រហ្មនោះ លះសស្សតទិដ្ឋិដោយមគ្គ ព្រោះដូច្នោះ ព្រះថេរៈទើបពោលយ៉ាងនេះ ដោយប្រការដូច្នេះ ។

[៦០] បទថា **ព្រហ្មបារិសជ្ជំ** បានដល់ ព្រហ្មបរិចារិកាអ្នកប្រណិបត្តិព្រហ្ម ពិតហើយ ឈ្មោះថា ព្រហ្មបារិសជ្ជៈ សូម្បីរបស់ព្រហ្មទាំងឡាយ ក៏ដូចកិក្ខុកម្មោះ និងសាមណេរអ្នកកាន់ថង់យាមរបស់ព្រះថេរៈ ។ បទថា **តេ-នុបសង្កមិ** សេចក្តីថា ព្រោះហេតុអ្វី ព្រហ្មទើបបញ្ជូនព្រហ្មបារិសជ្ជៈទៅកាន់សម្នាក់របស់ព្រះថេរៈនុ៎ះ បានឮថា ព្រហ្មនោះមានសេចក្តីស្និទស្នាល ដោយការចរចាប្រាស្រ័យក្នុងព្រះថេរៈ ព្រោះដូច្នោះ ព្រហ្មនោះទើបបញ្ជូនព្រហ្ម-បារិសជ្ជៈទៅកាន់សម្នាក់របស់ព្រះថេរៈនុ៎ះឯង ។ បទថា **អញ្ញេបិ** សេចក្តីថា ជនទាំង ៤ ក៏ដូចពួកអ្នកដែរ ពួកសាវកសូម្បីដទៃៗ បែបនោះ នៅមានឫទ្ធិបុមានតែពួកអ្នកទាំង ៤ ប៉ុណ្ណោះ ដែលមានឫទ្ធិច្រើន ។

[៦២] បទថា **តេវិជ្ជា** បានដល់ អ្នកប្រកបដោយវិជ្ជា ៣ គឺ បុព្វេនិ-

វាសញ្ញាណ ទិព្វចក្ខុញ្ញាណ និងអាសវក្ខយញ្ញាណ ។ បទថា **ឥទ្ធិប្បត្តា** បានដល់ សម្រេចឥទ្ធិវិធិញ្ញាណ ។ បទថា **ចេតោបរិយាយកោវិទា** បានដល់ ជាអ្នកឆ្លាតក្នុងវារចិត្តរបស់ជនពួកដទៃ ។ ក្នុងទីនេះ លោកពោលអភិញ្ញា ៥ ទុកដោយសរុប ដោយប្រការដូច្នេះ ។ តែទិព្វសោតញ្ញាណ បានមកដោយអំណាចអភិញ្ញា ៥ នោះ ដូចគ្នា ។ បទថា **ពហូ** សេចក្តីថា ពួកពុទ្ធសាវក អ្នកបានអភិញ្ញា ៦ យ៉ាងនេះ មាននៅសល់គណនារាប់មិនបាន ធ្វើជម្ពូទ្វីប ទាំងមូលឲ្យរុងរឿងដោយសំពត់កាសាវពស្ត្រ ។

ចប់អដ្ឋកថា អបរាទិដ្ឋិសូត្រទី៥

# អ ដ្ឋ ក ថា

## បមានសូត្រទី ៦

ក្នុងបមាទសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[៦៥]** បទថា **បច្ចេកំ ទ្វារពាហំ** សេចក្ដីថា បានឈរផ្អែកនឹងសន្ទឹកទ្វារម្នាក់ម្នាក់ ដូចជាទ្វារ ។ បទថា **ឥទ្ធោ** សេចក្ដីថា សម្រេចសេចក្ដីសុខក្នុងឈាន ។ បទថា **ផីតោ** បានដល់ រីកស្គុះស្គាយដោយផ្កាឈើ គឺ អភិញ្ញា ។ បទថា **អនធិវាសេន្តោ** បានដល់ អត់ទ្រាំមិនបាន ។ បទថា **ឯតទវោច** សេចក្ដីថា អង្គុយត្រង់កណ្ដាលនិម្មិតនៃពួកព្រហ្មទាំងនោះ បានពោលពាក្យនេះថា **បស្សសិ មេ** ជាដើម ។

**[៦៨]** ក្នុងគាថាថា **តយោ សុបណ្ណា** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **សត** ក្នុងបទថា **បញ្ចសតា** គប្បីប្រកបដោយរូប ឬដោយជួរ ។ នឹងពោលអំពីរូបមុន បទថា **តយោ សុបណ្ណា** បានដល់ រូបគ្រុឌ ៣០០ ។ បទថា **ចតុរោ ចហំសា** បានដល់ រូបហង្ស ៤០០ ។ បទថា **ព្យគ្ឃិនិសា**

បញ្ចសតា បានដល់ ម្រឹគពួកខ្លះដូចនឹងខ្លាធំ ឈ្មោះថា ព្យគ្ឃនិសា ។ រូបម្រឹគ ដែលដូចជាខ្លាធំទាំងនោះ មានចំនួន ៥០០ ។ ពោលអំពីជួរ បទថា តយោ សុបណ្ណា បានដល់ គ្រុឌ ៣០០ ជួរ ។ បទថា ចតុរោ ហំសា បានដល់ ហង្ស ៤០០ ជួរ ។ បទថា ព្យគ្ឃនិសាបញ្ចសតា បានដល់ រូបម្រឹគដែលស្រដៀង នឹងខ្លាធំ ៥០០ ជួរ ។ ដោយបទថា ឈាយិនោ ព្រហ្មសម្ដែងថា ក្នុងវិមាន របស់យើង អ្នកបានឈានមានសេចក្ដីរុងរឿងយ៉ាងនេះ ។

[៦៩] បទថា ឱភាសយំ បានដល់ ភ្លឺស្វាង ។ បទថា ឧត្តរស្សំ ទិសាយំ សេចក្ដីថា បានឮថា វិមានមាសធំនោះ ប្រាកដក្នុងទិសឧត្តរ អំពីដែល មហាព្រហ្មទាំងនោះស្ថិតនៅ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ ។ ក៏ព្រហ្ម នោះមានសេចក្ដីប្រាថ្នាដូច្នេះថា យើងនៅក្នុងវិមានមាសបែបនេះ តើនឹងទៅ កាន់ទីបម្រើអ្នកដទៃណា ដូចម្ដេចបាន ។ បទថា រូបេ រណំ ទិស្វា បានដល់ ឃើញទោស ពោលគឺ កើត ចាស់ និងការបែកធ្លាយក្នុងរូប ។ បទថា សទា បវេធិតំ សេចក្ដីថា ឃើញរូបដែលញាប់ញ័រ និងត្រូវវិភេទប្បច្ច័យ មានសេចក្ដី ត្រជាក់ជាដើមបៀតបៀនជានិច្ច ។ បទថា តស្មា ន រូបេ រមតី សុមេធោ សេចក្ដីថា ឃើញទោសក្នុងរូប និងឃើញរូបដែលញាប់ញ័រគ្រប់កាល ព្រោះ

*ដូច្នោះ ព្រះសាស្តាទ្រង់ប្រកបដោយមេធាល្អ គឺ ទ្រង់មានបញ្ញាល្អ ទើបមិនត្រេកអរក្នុងរូប ។*

ចប់អដ្ឋកថា បមាទសូត្រ ទី៦

# អ ដ្ឋ ក ថា

## បឋមកោកាលិកសូត្រទី ៧

ក្នុងបឋមកោកាលិកសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៧២] បទថា *អប្បមេយ្យំ បមិនន្តោ* សេចក្តីថា កំណត់យកបុគ្គលដែលជាព្រះខីណាស្រព អ្នកមានគុណដែលអ្នកណាៗ ប្រមាណមិនបាន យ៉ាងនេះថា សីលមានប្រមាណប៉ុណ្ណេះ សមាធិមានប្រមាណប៉ុណ្ណេះ បញ្ញាមានប្រមាណប៉ុណ្ណេះ ។ ដោយពាក្យថា *កោធ វិទ្វា វិកប្បយេ* សេចក្តីថា តើបុគ្គលណាមានបញ្ញា មានការឈ្លាសវៃក្នុងលោកនេះ គប្បីកំណត់រាប់នូវគុណរបស់ព្រះខីណាស្រពបាន លោកសម្តែងថា ព្រះខីណាស្រពប៉ុណ្ណេះ គប្បីកំណត់រាប់នូវគុណរបស់ព្រះខីណាស្រព (ផងគ្នាបាន) ។ បទថា *និវុតន្តំ មញ្ញេ* សេចក្តីថា ក៏បុគ្គលណាជាបុថុជ្ជន ប្រារព្ធនូវវត្តរបស់ព្រះខីណាស្រពនោះ យើងពោលបុគ្គលនោះថា មិនមានធុតធម៌ គឺ មិនមានបញ្ញា ។

ចប់អដ្ឋកថា បឋមកោកាលិកសូត្រទី ៧

# អ ដ្ឋ ក ថា

## តិស្សកសូត្រទី ៨

ក្នុងតិស្សកសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៧៨] *បញ្ញា លោកហៅថា កិស្សវា ក្នុងបទថា អកិស្សវំ ដូច្នេះ ។ អធិប្បាយថា ប្រាសចាកបញ្ញា ។*

ចប់អដ្ឋកថា តិស្សកសូត្រទី៨

# អ ដ្ឋ ក ថា

## តុទុព្រហ្មសូត្រទី ៩

ក្នុងតុទុព្រហ្មសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[៧៥]** បទថា *អាពាធិកោ* សេចក្តីថា អ្នកមានអាពាធ ដោយអាពាធដែលមកក្នុងអនន្តរសូត្រ ដោយន័យថា **សាសបមត្តីហិ បិឡកាហិ** ជាដើម ។ បទថា **ពាឡ្ហគិលានោ** បានដល់ មានអាពាធជាទម្ងន់ ។ បទថា **តុទុ** សេចក្តីថា ព្រះឧបជ្ឈាយ៍របស់ភិក្ខុកោកាលិកៈ ឈ្មោះថា **តុទុត្ថេរ** សម្រេចអនាគាមិផល ហើយកើតក្នុងព្រហ្មលោក ។ តុទុព្រហ្មនោះ បានជ្រាបដំណឹងបាបកម្មរបស់ភិក្ខុកោកាលិកៈ ចាប់តាំងពីភូម្មដ្ឋកទេវតា ដោយបន្តជាលំដាប់ដរាបដល់ព្រហ្មលោកថា ភិក្ខុកោកាលិកៈ ពោលមួលបង្កាច់ព្រះអគ្គសាវកដោយអន្ទិមវត្ថុធ្វើកម្មដែលមិនសមគួរ ទើបមកប្រាកដចំពោះមុខភិក្ខុកោកាលិកៈនោះ ដោយប្រាថ្នាថា កាលយើងឃើញហើយ លោកកុំជាមនុស្សកំព្រា (ប្រាសចាកពួក) នឹងត្រូវវិនាស យើងនឹងដាស់តឿនលោក ដើម្បីឲ្យកើតចិត្តជ្រះថ្លាក្នុងព្រះថេរៈលោកសំដៅយក តុទុព្រហ្មនោះ ទើបពោលថា **តុទុបច្ចេកព្រហ្ម** ។ បទថា

**បេសលា** ប្រែថា អ្នកមានសីលជាទីស្រឡាញ់ ។ បទថា **កោសិ ត្វំ អាវុសោ** សេចក្តីថា ដេកបើកភ្នែកដែលស្រអាប់ ទើបពោលយ៉ាងនេះ ។ បទថា **បស្ស យាវញ្ច តេ** សេចក្តីថា តុទុព្រហ្មពោលថា លោកចូរឃើញទោសដែលលោកធ្វើខុសចុះ តើលោកមិនឃើញបូសធំត្រឹមថ្ងាស់របស់ខ្លួនទេឬ ឃើញខ្ទុំដែលគួរជាស់តៀនដោយបូសប៉ុនគ្រាប់ស្ពៃ ។

គ្រានោះ តុទុព្រហ្មដឹងថា កោកាលិកៈនេះ បានប្រសព្វវត្ថុដែលខ្លួនមិនធ្លាប់ឃើញ ជាមនុស្សកំព្រា និងមិនជឿពាក្យរបស់អ្នកណាៗ ដូចលេបថ្នាំពិសនៅក្នុងដើមក ទើបពោលនឹងកោកាលិកភិក្ខុថា **បុរិសស្ស ហិ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **កុធារី** បានដល់ វាចាគ្រោតគ្រាត ដូចជាផ្លែដឹង ។ បទថា **ឆិន្ទតិ** បានដល់ កាត់ឫស ពោលគឺ កុសលនោះឯង ។ បទថា **និន្ទិយំ** បានដល់ បុគ្គលទ្រុស្តសីលដែលគួរតិះដៀល ។ ដោយបទថា **បសំសតិ** លោកពោលសរសើរក្នុងអត្ថដែលខ្ពស់បំផុតថា ព្រះខីណាស្រព ។ បទថា **តំ វា និន្ទតិ យោ បសំសិយោ** សេចក្តីថា ម្យ៉ាងទៀត ពោលចោទព្រះខីណាស្រពដែលគួរសរសើរដោយអន្តិមវត្ថុ ថា អ្នកនេះជាអ្នកទ្រុស្តសីល ។ បទថា **វិចិនាតិ មុខេនសោ កលឹ** សេចក្តីថា បុគ្គលនោះឈ្មោះថា បង្កើតកំហុស

ដោយមាត់ ។ បទថា **កលិនា តេន** សេចក្ដីថា រមែងមិនប្រសព្វសេចក្ដីសុខ ព្រោះកំហុសនោះ ។ ក៏ការសរសើរបុគ្គលដែលគួរតិះដៀល និងការតិះដៀល បុគ្គលដែលគួរសរសើរ មានផលប៉ុនគ្នា ។

បទថា **សព្វស្សាបិ សហាបិ អត្តនា** សេចក្ដីថា សេចក្ដីអស់ទ្រព្យ ព្រោះការភ្នាល់ទាំងឡាយ ព្រមទាំងវត្ថុគ្រប់ជំពូកក្ដី ព្រមទាំងខ្លួនឯងក្ដី ឈ្មោះថា ជាការចាញ់ត្រឹមតែបន្តិចបន្តួច ។ បទថា **យោ សុគតេសុ** សេចក្ដីថា ក៏បុគ្គលណាគប្បីមានចិត្តគិតប្រទូសរ៉ាយក្នុងពួកបុគ្គលដែលបដិបត្តិល្អ ការប្រទូសរ៉ាយនៃចិត្តរបស់បុគ្គលនោះ នេះមានទោសច្រើនជាងទោសក្នុងការភ្នាល់នោះទៅទៀត ។

ឥឡូវនេះ កាលនឹងសម្ដែងសេចក្ដីប្រទូសរ៉ាយនៃចិត្តនោះថា មានទោសច្រើនជាង ទើបពោលពាក្យជាដើមថា **សតំ សហស្សានំ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **សតំសហស្សានំ** បានដល់ ចំនួនសែននិរព្វុទៈ[១] ។ បទថា **ឆត្តឹសតិ** បានដល់ ៣៦ និរព្វុទៈទៀត ។ បទថា **បញ្ច ច** បានដល់ ចំនួន ៥ អព្វុទៈ ។ បទថា **យមរិយេ គរហី** សេចក្ដីថា ក្នុងប្រការដែលបុគ្គលតិះដៀល

---

១- ១ និរព្វុទៈ ស្មើនឹងលេខ ១ មានសូន្យតាមក្រោយ ៦៣ បើសែននិរព្វុទៈជាប៉ុន្មាន? ។

*ព្រះអរិយ រមែងធ្លាក់នរក មានអាយុប្រមាណប៉ុណ្ណេះ ។*

ចប់អដ្ឋកថា តុទុព្រហ្មសូត្រទី៩

# អ ដ្ឋ ក ថា

## ទុតិយកោកាលិកសូត្រទី ១០

*ក្នុងទុតិយកោកាលិកសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[៧៧]** *បទថា កោកាលិកោ ភិក្ខុ យេន ភគវា តេនុបសង្កមិ សេចក្ដីថា សួរថា កោកាលិកៈនេះ ជានរណា និងហេតុដូចម្ដេចទើបចូលទៅគាល់ ។ ឆ្លើយថា បានឮថា ភិក្ខុនេះ ជាបុត្រកោកាលិកសេដ្ឋី ក្នុងកោកាលិកនគរ នៃកោកាលិករដ្ឋ បួសហើយអាស្រ័យនៅក្នុងវិហារដែលបិតាសាងទុក មានឈ្មោះថា ចូឡកោកាលិក មិនមែនជាសិស្សរបស់ព្រះទេវទត្ត ។ ចំណែកភិក្ខុដែលជាសិស្សរបស់ព្រះទេវទត្តនោះ ជាបុត្រព្រាហ្មណ៍ មានឈ្មោះថា មហាកោ-កាលិកៈ ។ ក៏កាលព្រះមានព្រះភាគប្រថាប់នៅក្នុងក្រុងសាវត្ថី ព្រះអគ្គសាវកទាំងពីរ ព្រមដោយភិក្ខុប្រមាណ ៥០០ រូប ចារិកទៅក្នុងជនបទ កាលជិតដល់ថ្ងៃចូលវស្សា ប្រាថ្នានឹងនៅស្ងប់ស្ងាត់ ទើបបញ្ជូនភិក្ខុទាំងនោះទៅ ខ្លួនលោកកាន់បាត្រចីវរ ទៅដល់នគរនោះ ក្នុងជនបទ បានទៅកាន់វិហារនោះ ។ ឯក្នុងទីនោះ កោកាលិកភិក្ខុ បានសម្ដែងវត្តដល់ព្រះអគ្គសាវកទាំងពីរ ព្រះអគ្គ-*

សាវកទាំងពីរវិរកវាយជាមួយព្រះកោកាលិកៈនោះ ហើយពោលថា អាវុសោ ពួកយើងនឹងនៅក្នុងទីនេះរហូតដល់អស់ត្រៃមាស សូមលោកកុំប្រាប់ដល់អ្នកណាៗ ឡើយ ហើយគេក៏ទទួលបេ្តជ្ញា ។ គ្រានៅចាំវស្សា បវារណាក្នុងថ្ងៃបវារណាហើយ ព្រះអគ្គសាវកទាំងពីរ ទើបលាភិក្ខុកោកាលិកៈថា អាវុសោ យើងនឹងទៅ ។ ភិក្ខុកោកាលិកៈថា អាវុសោ ពួកលោកនៅក្នុងថ្ងៃនេះមួយថ្ងៃ ស្អែកនេះសឹមទៅ ដូច្នេះ ហើយថ្ងៃស្អែក ទើបចូលក្រុង ប្រាប់ពួកមនុស្សថា អាវុសោ ព្រះអគ្គសាវកមកនៅក្នុងទីនេះ ពួកអ្នកមិនដឹង មិនមានអ្នកណាថ្វាយបច្ច័យបួនឡើយ ។ ពួកអ្នកក្រុងពោលថា លោកម្ចាស់ ព្រះថេរៈនៅទីណា ហេតុដូចម្តេច ទើបមិនប្រាប់ពួកយើង ។ ភិក្ខុកោកាលិកពោលថា អាវុសោ ប្រាប់ហើយ នឹងមានប្រយោជន៍អ្វី ពួកអ្នកមិនឃើញភិក្ខុ ២ រូប ដែលអង្គុយលើគ្រែអាសនៈ ឬ ទុំះឯងជាព្រះអគ្គសាវក ។ ពួកមនុស្សប្រញាប់ប្រជុំគ្នា រួបរួមទឹកដោះថ្លា ទឹកអំពៅជាដើម និងសំពត់ចីវរ ។

ភិក្ខុកោកាលិកៈ គិតថា ព្រះអគ្គសាវកជាអ្នកប្រាថ្នាតិចយ៉ាងក្រៃលែង នឹងមិនត្រេកអរក្នុងលាភ ដែលកើតឡើងដោយវាចា កាលមិនត្រេកអរ ក៏នឹងប្រាប់ថា អ្នកទាំងឡាយ ចូរថ្វាយដល់ភិក្ខុដែលនៅចាំអាវាស ដូច្នេះ ឲ្យពួក

មនុស្សនាំគ្នាកាន់លាភសក្ការៈនោះ ៗ ទៅសម្នាក់របស់ព្រះថេរៈទាំងពីរ ។ ព្រះថេរៈទាំងពីរឃើញដូច្នោះ ទើបហាមថា បច្ច័យទាំងនេះមិនគួរដល់ពួកយើង មិនគួរដល់ភិក្ខុកោកាលិកៈ ដូច្នេះ ហើយក៏ចៀសទៅ ។ ភិក្ខុកោកាលិកៈ កើតអាឃាតឡើងថា តើហេតុអ្វី ព្រះអគ្គសាវកទាំងពីរ កាលខ្លួនឯងមិនទទួល មិនទាន់ឲ្យពួកមនុស្សថ្វាយដល់យើង ហើយចៀសទៅ ។ សូម្បីព្រះអគ្គ-សាវកទាំងពីរ ទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ នាំបរិស័ទរបស់ខ្លួនត្រាច់ចារិកទៅតាមជនបទ ហើយត្រឡប់មកកាន់ក្រុងនោះ ក្នុងរដ្ឋនោះតាមលំដាប់ ។ អ្នកក្រុងចាំព្រះថេរៈបាន ត្រៀមទានព្រមទាំងគ្រឿងបរិក្ខារទាំងឡាយ សាងមណ្ឌបកណ្ដាលក្រុងថ្វាយទាន ។ បង្អោនបរិក្ខារទាំងឡាយចូលទៅថ្វាយព្រះថេរៈ ។ ព្រះថេរៈបានប្រគល់ថ្វាយដល់ភិក្ខុសង្ឃ ភិក្ខុកោកា-លិកៈឃើញដូច្នោះ គិតថា កាលមុនព្រះអគ្គសាវកទាំងនេះ ជាអ្នកប្រាថ្នាតិច ឥឡូវនេះក្លាយជាអ្នកប្រាថ្នាច្រើន សូម្បីក្នុងកាលមុន ធ្វើដូចជាអ្នកប្រាថ្នាតិច សន្ដោស និងពេញចិត្តទីស្ងាត់ ទើបចូលទៅរកព្រះថេរៈ ពោលថា អាវុសោ កាលមុនលោកដូចជាប្រាថ្នាតិច តែឥឡូវនេះលោកក្លាយជាភិក្ខុលាមក គិតថា យើងនឹងទម្លាយទីពឹងរបស់ព្រះអគ្គសាវកទាំងនោះ ក៏ប្រញាប់ចេញទៅកាន់

ក្រុងសាវត្ថី ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។ គប្បីជ្រាបថា ភិក្ខុកោកាលិកៈនេះ ចូលគាល់ព្រោះហេតុនេះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់ទតឃើញភិក្ខុកោកាលិកៈកំពុងមក ដោយប្រញាប់ប្រញាល់ ទ្រង់ព្រះតម្រិះ ក៏ជ្រាបថា ភិក្ខុកោកាលិកៈនេះ ប្រាថ្នានឹងជេរព្រះអគ្គសាវក ទើបបានមក និងទ្រង់ព្រះតម្រិះទៀតថា តថាគតអាចហាមបានទេហ្ន៎ ទ្រង់ជ្រាបថា មិនអាចហាមបាន ភិក្ខុកោកាលិកនេះ ធ្វើខុសក្នុងព្រះថេរៈទាំងឡាយទើបមក ស្លាប់ហើយនឹងកើតក្នុងបទុមនរកតែម្យ៉ាង ដើម្បីនឹងដោះវាទៈថា ព្រះមានព្រះភាគទ្រង់ជ្រាបបុគ្គលដែលតិះដៀលព្រះសារីបុត្រ និងព្រះមោគ្គល្លានហើយនៅតែហាមមិនបាន និងដើម្បីសម្តែងការពោលប្រទូស្តព្រះអរិយៈថា មានទោសច្រើន ទើបទ្រង់ហាមថា **មា ហេវំ** ដូច្នេះ ដល់ ៣ ដង ។

**[៧៨]** បណ្តាបទទាំងនោះ បទថា **មា ហេវំ** សេចក្តីថា អ្នកកុំពោលយ៉ាងនេះឡើយ ។ បទថា **សទ្ធាយិកោ** សេចក្តីថា បុគ្គលធ្វើខ្លួនឲ្យជាទីមកនៃសទ្ធា បុគ្គលនាំមកនូវសេចក្តីជ្រះថ្លា ម្យ៉ាងទៀត បុគ្គលមានពាក្យដែលគេគប្បីជឿបាន ។ បទថា **បច្ចយិកោ** សេចក្តីថា បុគ្គលមានពាក្យដែលនឹងគប្បី

ជាទីអាស្រ័យបាន ។

[៧៩] បទថា **អចិរបក្កន្តស្ស** សេចក្តីថា កាលភិក្ខុកោកាលិកៈចៀស ទៅ មិនយូរប៉ុន្មាន ។ បទថា **សព្វោ កាយោ ផុដ្ឋោ អហោសិ** សេចក្តីថា កន្ទួលពកទាំងឡាយផុសឡើង ទម្លាយឆ្អឹងទូទាំងរាងកាយ មិនវៀរទីចន្លោះ សូម្បីត្រឹមតែប៉ុនចុងសរសៃសក់ ។ ក៏ព្រោះកម្មមានសភាពបែបនោះ មិនឲ្យ ផលក្នុងខណៈនៅចំពោះព្រះភក្ត្រព្រះពុទ្ធទាំងឡាយដោយពុទ្ធានុភាព ល្មមផុត ទស្សនវិស័យហើយ រមែងឲ្យផល ដូច្នោះ ។ កាលភិក្ខុកោកាលិកៈនោះ ចៀសចេញទៅហើយ មិនយូរប៉ុន្មាន កន្ទួលទាំងឡាយទើបផុសឡើង ។

បទថា **បក្កាមិ** សេចក្តីថា ភិក្ខុកោកាលិកៈត្រូវអានុភាពនៃកម្មជាស់ តឿន ទើបចៀសទៅ ។ ពិតហើយ អ្នកណាៗ មិនអាចទីងហាមកម្ម ដែល ធ្វើឱកាសហើយ កម្មនោះ មិនឲ្យភិក្ខុកោកាលិកៈនោះនៅក្នុងទីនោះ ។ បទថា **កឡាយមត្តិយោ** បានដល់ ប្រមាណប៉ុនគ្រាប់សណ្តែកបាយ ។ បទថា **វេ-លុវសលាដុកមត្តិយោ** បានដល់ ប្រមាណប៉ុនផ្លៃព្នៅ ។ បទថា **បភិជ្ជីសុ** ប្រែថា បែកហើយ ។ កាលពងកន្ទួលទាំងនោះបែកហើយ សរីរៈទាំងអស់ របស់ភិក្ខុកោកាលិកៈនោះ ក៏ពោរពេញដោយទឹករងៃ ដេកលើស្លឹកចេកត្រង់

ខ្វាងទ្វារវត្តជេតពន ដូចត្រីដែលត្រូវថ្នាំពិស លំដាប់នោះ ពួកមនុស្សដែលនាំគ្នាមកស្តាប់ធម៌ ពោលថា ភិក្ខុកោកាលិកៈ បានធ្វើកម្មដែលមិនសមគួរ ដល់នូវសេចក្តីវិនាស ព្រោះអាស្រ័យមាត់ ដូចកាំបិតរបស់ខ្លួនទុំះឯង ។ ពួកអារក្ខទេវតាបានស្តាប់ពួកមនុស្សទាំងនោះ បានធ្វើការតិះដៀល ។ អាកាស-ទេវតាបានស្តាប់អារក្ខទេវតា បានធ្វើការតិះដៀល បានកើតការតិះដៀលដូចគ្នា ដរាបដល់អកនិដ្ឋកព ដោយឧបាយនេះ ដោយប្រការដូច្នេះ គ្រានោះឯងឧបជ្ឈាយ៍របស់លោកមក ដឹងថា លោកមិនទទួលឱវាទ ហើយក៏ចៀសចេញទៅ ។

បទថា **កាលមកាសិ** សេចក្តីថា កាលឧបជ្ឈាយ៍ចៀសចេញទៅ ភិក្ខុកោកាលិកៈបានធ្វើកាលៈហើយ ។ បទថា **បទុមនិរយំ** សេចក្តីថា ឈ្មោះថា បទុមនរកមិនមានចំពោះ[១] ។ ភិក្ខុកោកាលិកៈកើតក្នុងទីមួយ ក្នុងអវិចីមហា-នរក ដែលនឹងគប្បីធេះ ដោយការគណនាចំនួនមួយបទុម (បទុមនោះជាសង្ខ្យាដែលមានចំនួនសូន្យ ១២៤ សូន្យ) ។

**[៨៣]** បទថា **វីសតិខារិកោ** បានដល់ ៤ បត្ថៈ (នាឡិ) នៃអ្នកដែន

---

១- គឺកំណត់មិនបានថា កន្លែងណាមួយក្នុងអវិចីមហានរកឡើយ ។

មគធៈ ជា ១ បត្ថៈក្នុងដែនកោសល ។ ៤ បត្ថៈ ស្មើ ១ អឡ្ហកៈ , ៤ អឡ្ហកៈ ជា ១ ទោណៈ ។ ៤ ទោណៈ ជា ១ មានិកៈ ។ ៤ មានិកៈ ជា ១ ខារិ (១ អម្រែក) ដោយខារិនោះ ជា ២០ ខារិកៈ ។ បទថា **តិលវាហោ** បានដល់ រទេះបន្ទុកគ្រាប់ល្ងរបស់អ្នកដែនមគធៈ ។ បទថា **អព្វុទោ និរយោ** បានដល់ ដែលឈ្មោះថា អព្វុទៈ មិនមែនជាចំណែកមួយនៃនរក ។ តែពាក្យនេះ ជា ឈ្មោះស្ថានទីដែលគប្បីឆេះក្នុងអវិចីមហានរកនុ៎ះឯង ដោយការរាប់អព្វុទៈ ។ សូម្បីក្នុងពាក្យថា និរព្វុទៈជាដើម ក៏ន័យនេះដូចគ្នា សូម្បីចំនួនឆ្នាំក្នុងសេចក្តី នេះ ក៏គប្បីជ្រាបយ៉ាងនេះ ។ ដូចជា មួយរយសែន ស្មើមួយកោដិ យ៉ាងណា មួយរយសែនកោដិ ឈ្មោះថា មួយបកោដិ ដូច្នោះ មួយរយសែនបកោដិ ស្មើមួយកោដិបកោដិ មួយរយសែនកោដិបកោដិ ស្មើមួយនហុត មួយរយ សែននហុត ស្មើមួយនិន្នហុត មួយរយសែននិន្នហុត ស្មើមួយអព្វុទៈ តពីនោះ យក ២០ គុណនិងមួយនិរព្វុទៈ ។ ក្នុងបទទាំងពួង ក៏មានន័យនេះដូចគ្នា ។

ចប់អដ្ឋកថា ទុតិយកោកាលិកសូត្រទី ១០

# ចប់បឋមវគ្គ

# ចប់ព្រហ្មសំយុត្ត

**រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា**


១-អដ្ឋកថាអាយាចនសូត្រ
២-អដ្ឋកថាគារវសូត្រ
៣-អដ្ឋកថាព្រហ្មទេវសូត្រ
៤-អដ្ឋកថាពកព្រហ្មសូត្រ
៥-អដ្ឋកថាអបរាទិដ្ឋិសូត្រ
៦-អដ្ឋកថាបមាទសូត្រ
៧-អដ្ឋកថាបឋមកោកាលិកៈសូត្រ
៨-អដ្ឋកថាតិស្សកៈសូត្រ
៩-អដ្ឋកថាតុទុព្រហ្មសូត្រ
១០-អដ្ឋកថាទុតិយកោកាលិកៈសូត្រ

# ទុតិយវគ្គ

## អ ដ្ឋ ក ថា

## សនង្កុមារសូត្រទី ១

*សនង្កុមារសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[៨៤]** *បទថា* ***សប្បិនីតីរេ*** *សេចក្តីថា ត្រង់ច្រាំងទន្លេឈ្មោះសប្បិនី ។ បទថា* ***សនង្កុមារោ*** *សេចក្តីថា បានឮថា សនង្កុមារព្រហ្មនោះ ក្នុងវេលាជាបញ្ចសិខកុមារចម្រើនឈានកើតក្នុងព្រហ្មលោក ត្រាច់ទៅដោយភេទកុមារនុ៎ះឯង ។ ហេតុនោះ ជនទាំងឡាយទើបចាំគេបានថា កុមារ ។ តែពេលលោកចាស់ ទើបហៅថា* ***សនង្កុមារ*** *។*

**[៨៥]** *បទថា* ***ជនេតស្មឹ*** *បានដល់ ក្នុងប្រជុំជន អធិប្បាយថា ក្នុងពពួកជន ។ បទថា* ***យេគោត្តបដិសារិនោ*** *សេចក្តីថា ក្នុងពពួកជនដែលអាស្រ័យនូវគោត្រទាំងនោះ ក្នុងលោកមានតែក្សត្រិយ៍ប៉ុណ្ណោះ ជាបុគ្គលដ៏ប្រសើរបំផុត ។ បទថា* ***វិជ្ជាចរណសម្បន្នោ*** *សេចក្តីថា ប្រកបដោយវិជ្ជា ៣*

មានបុព្វេនិវាសានុស្សតិញ្ញាណជាដើម ដោយបរិយាយនៃ **ភយភេរវសូត្រ** ឬ វិជ្ជា ៨ គឺ វិបស្សនាញាណ មនោមយិទ្ធិ អភិញ្ញា ៦ ដោយបរិយាយនៃ **អម្ពដ្ឋសូត្រ** និងដោយចរណៈ ១៥ យ៉ាងនេះ គឺ ភាពជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ភាពជាអ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ភាពជាអ្នកស្គាល់ប្រមាណក្នុងភោជន ជាគរិយានុយោគ សទ្ធម្ម ៧ រូបឈាន ៤ ។ បទថា **សោ សេដ្ឋោ ទេវមានុសេ** សេចក្តីថា ព្រាហ្មណ៍ជាខីណាស្រពនោះ ជាអ្នកប្រសើរបំផុត គឺ ខ្ពង់ខ្ពស់បំផុតក្នុងពួកទេវតា និងពួកមនុស្ស ។

ចប់អដ្ឋកថា សនង្កុមារសូត្រ ទី ១

# អ ដ្ឋ ក ថា

## ទេវទត្តសូត្រទី ២

ក្នុងទេវទត្តសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៨៨] បទថា *អចិរបក្កន្តេ* សេចក្តីថា កាលព្រះទេវទត្តបំបែកសង្ឃហើយ ក៏ធ្វើដំណើរពីព្រះវេឡុវ័នទៅកាន់គយាសីសៈប្រទេស ចំណាយពេលមិនយូរឡើយ ។ បទថា *អស្សតរី* បានដល់ កូនកើតពីបាលា មេសេះ ។

ចប់អដ្ឋកថា ទេវទត្តសូត្រទី២

# អ ដ្ឋ ក ថា

## អន្ធកវិន្ទសូត្រទី ៣

ក្នុងអន្ធកវិន្ទសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[៩០]** បទថា **អន្ធកវិន្ទេ** សេចក្ដីថា ស្រុកមានឈ្មោះយ៉ាងនោះ ។ បទថា **ឧបសង្កមិ** សេចក្ដីថា សហម្បតីព្រហ្មគិតថា ព្រះសាស្ដាទ្រង់ធ្វើសេចក្ដីព្យាយាមហើយសូម្បីក្នុងកាលឥឡូវនេះ ជនទាំងឡាយប្រកបសេចក្ដីព្យាយាមជាប់តគ្នារឿយៗ យើងនឹងទៅឈរក្នុងសម្នាក់នៃព្រះសាស្ដា ហើយនឹងពោលគាថា ពោលអំពីរឿងសេចក្ដីព្យាយាមដែលសមគួរដល់ពាក្យទូន្មាន ដូច្នេះ ទើបចូលទៅគាល់ ។

**[៩១]** បទថា **បន្តានិ** សេចក្ដីថា សេនាសនៈដែលនៅក្រៅដែនរបស់មនុស្ស ដាច់ពីទីប្រជុំជនចេញទៅ ។ បទថា **សញ្ញោជនវិប្បមោក្ខា** សេចក្ដីថា កាលសេពសេនាសនៈនោះ នឹងគប្បីសេពដើម្បីត្រូវការចីវរជាដើម ក៏មិនមែន សេចក្ដីពិត គប្បីជាអ្នកប្រព្រឹត្តដើម្បីត្រូវការរួចផុតអំពីសញ្ញោជនៈ ១០ ។ បទថា **សចេ រតឹ នាធិគច្ឆេយ្យ** សេចក្ដីថា កាលមិនបានសេចក្ដីត្រេកអរក្នុងសេនាសនៈ

ទាំងនោះ ក៏មិននៅក្នុងព្រៃដែលកើតឡើងដូចជាធូលីលើខ្នងលា គប្បីនៅត្រង់កណ្តាលសង្ឃ ដើម្បីរក្សាទឹកចិត្តញាតិញោមជាដើម ។ បទថា **រក្ខិតត្តោស-តិមា** សេចក្តីថា ក៏ភិក្ខុកាលនៅក្នុងទីនោះ មិនចាក់ដោត មិនប៉ះទង្គិចជាមួយនឹងសព្រហ្មចារី រក្សាខ្លួន មានសតិប្បដ្ឋាននៅខាងមុខ នៅដូចជាគោឈ្មោលកាច ក្នុងអាវាសរបស់ខ្លួន ។

ឥឡូវនេះ សហម្បតីព្រហ្មនោះ ប្រាប់ភិក្ខាចារវត្តដល់ភិក្ខុដែលនៅក្នុងសង្ឃ ទើបពោលពាក្យថា **កុលា កុលំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **បិណ្ឌិកាយ ចរន្តោ** បានដល់ ត្រាច់ទៅដើម្បីត្រូវការអាហារ ។ បទថា **សេវេថ បន្តានិ សយនាសនានិ** សេចក្តីថា សូម្បីនៅកណ្តាលសង្ឃហើយ ក៏មានការដាំដើមត្នោត និងដើមដូងជាដើមក្នុងបរិវេណជិតៗ តែមិនគប្បីជាអ្នកនៅប្រឡូកប្រឡល់ដោយឧបដ្ឋាកជាដើម ធ្វើការសមគួរដល់ចិត្ត ឲ្យចិត្តរីករាយត្រេកអរ ហើយនៅក្នុងសេនាសនៈដែលស្ងាត់ទៀត ព្រោះដូច្នោះ ទើបពោលសរសើរព្រៃតែម្យ៉ាង ។ បទថា **ភយា** បានដល់ ចាកភ័យក្នុងវដ្តៈ ។ បទថា **អភយេ** បានដល់ ព្រះនិព្វាន ។ បទថា **វិមុត្តោ** បានដល់ គប្បីជាអ្នកបង្អោនចិត្តទៅ ។

បទថា **យត្ថ ភេរវា** សេចក្ដីថា សត្វដែលមានវិញ្ញាណគ្រប់គ្រង មានសីហៈ និងខ្លាធំជាដើម ដែលបណ្ដាលឲ្យកើតភ័យក្នុងទីណា និងវត្ថុដែលមិនមានវិញ្ញាណ មានដង្គត់ឈើ និងវល្លិ៍ជាដើម មានច្រើនក្នុងពេលយប់ មានក្នុងទីនោះ ។ បទថា **សិរីសបា** បានដល់ សត្វល្អូន មានពស់ជាដើម ។ បទថា **និសីទិ តត្ថ ភិក្ខុ** សេចក្ដីថា ភិក្ខុគង់ក្នុងទីនោះ ។ ដោយពាក្យថា **និសីទិ តត្ថ ភិក្ខុ** នេះ ព្រះមានព្រះភាគទ្រង់សម្ដែងសេចក្ដីទុកដូច្នេះថា ឥឡូវនេះ ពួកអ្នកអង្គុយមិនដាក់ចិត្តដល់អារម្មណ៍ដែលគួរតក់ស្លុត នៅក្នុងទីនោះ សត្វល្អូន និងផ្គរផ្កាបន្ទោរជាដើម ដោយប្រការណា ភិក្ខុទាំងឡាយ រមែងអង្គុយប្រកបសេចក្ដីព្យាយាមដោយប្រការនោះ ដូចគ្នា ។

បទថា **ជាតុ មេ ទិដ្ឋំ** ប្រែថា ដែលយើងឃើញហើយដោយចំណែកមួយ ។ ពាក្យថា **ឥទំ ឥតិហ** ក្នុងពាក្យថា **នយិទំ ឥតិហីតិហំ** នេះ សេចក្ដីថា យើងពោលព្រោះហេតុនៃសេចក្ដីត្រិះរិះ ព្រោះហេតុនៃការអាងន័យ ឬព្រោះហេតុអាងបិដក គឺ តម្រា (ក្បួនច្បាប់) ក៏មិនមែន ។ បទថា **ឯកស្មឹ ព្រហ្មចរិយស្មឹ** បានដល់ ក្នុងព្រះធម្មទេសនាមួយយ៉ាង ពិតណាស់ ព្រះធម្មទេសនា លោកបំណងថា ព្រហ្មចរិយៈក្នុងទីនេះ ។ បទថា **មច្ចុហាយិនំ** បាន

ដល់ ព្រះនិព្វានស្រេច ដែលលះបង់សេចក្តីស្លាប់ ។

ក្នុងពាក្យថា **ទសា ច ទសធា ទសា** នេះ បទថា **ទសា** បានដល់ចំនួន ១០ ប៉ុណ្ណោះ ។ ឈ្មោះថា **សតំ** ព្រោះយក ១០ គុណនឹង ១០ មួយទៀត លោកពោលថា យើងឃើញភិក្ខុពួកដទៃជាព្រះសេក្ខៈ ១១០ រូប ។ បទថា **សោតំ សមាបន្នា** បានដល់ សម្រេចក្រសែនៃមគ្គ ។ បទថា **អតិ-រច្ឆានគាមិនោ** នេះ ជាប្រធាននៃទេសនា ។ អធិប្បាយថា អ្នកមិនមានការធ្លាក់ចុះជាធម្មតា ។ បទថា **សង្ខាតុំ នោបិ សក្កោមិ** សេចក្តីថា អ្នកមិនមានការធ្លាក់ចុះជាធម្មតា ។ បទថា **សង្ខាតុំ នោបិ សក្ខោមិ** សេចក្តីថា យើងមិនអាចរាប់ថា ពួកសត្វដែលភាគីនៃបុណ្យមានប៉ុណ្ណោះ ព្រោះខ្លាចមុសាវាទ ព្រោះហេតុនោះ លោកសំដៅយកព្រហ្មទេសនា ទើបពោលយ៉ាងនេះ ។

ចប់អដ្ឋកថា អន្ធកវិន្ទសូត្រ ទី ៣

# អ ដ្ឋ ក ថា

## អរុណវតីសូត្រទី ៤

ក្នុងអរុណវតីសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[៩៣]** បទថា ***អភិភូសម្ភវំ*** បានដល់ ព្រះអភិភូ និងព្រះសម្ភវៈ ។ លោកទាំង ២ នោះ ព្រះអភិភូត្ថេរ ជាភិក្ខុកំពូលលើសខាងបញ្ញា ដូចព្រះ-សារីបុត្តត្ថេរ ព្រះសម្ភវត្ថេរ ជាភិក្ខុកំពូលលើសខាងសមាធិ ដូចព្រះមហា-មោគ្គល្លានត្ថេរ ។

**[៩៥]** បទថា ***ឧជ្ឈាយន្តិ*** បានដល់ រមែងមើលងាយ គឺ រមែងគិតខាងផ្លូវអាក្រក់ ។ បទថា ***ខីយន្តិ*** បានដល់ និយាយគ្នាថា តើនេះជាអ្វី តើនេះជាអ្វី ។ បទថា ***វិបាចេន្តិ*** បានដល់ រមែងនិយាយវែងអន្លាយ គឺ និយាយដដែលៗ ។ បទថា ***ហេដ្ឋិមេន ឧបឌ្ឍកាយេន*** បានដល់ កាយខាងក្រោមតាំងពីផ្ចិតចុះទៅ ក្នុងព្រះបាលីមកត្រឹមតែប៉ុណ្ណោះឯង ។ ចំណែកព្រះថេរៈសម្ដែងការធ្វើឫទ្ធិផ្សេងៗ ច្រើនប្រការ ដែលមកដោយន័យជាដើមថា លះបង់ភេទប្រក្រតី សម្ដែងភេទនាគខ្លះ សម្ដែងភេទគ្រុឌខ្លះ ។ បទថា ***ឥមា គាថាយោ***

**អកាសិ** សេចក្តីថា បានឮថា ព្រះថេរៈគិតថា សម្តែងធម៌យ៉ាងណា ទើបជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ជនទាំងពួង អំពីនោះកាលរំពឹងដល់ ទើបដឹងថា មេលទ្ធិសូម្បីទាំងពួង ទេវតា និងមនុស្សទាំងពួងនឹងសរសើរសេចក្តីព្យាយាមរបស់បុរសក្នុងលទ្ធិរបស់ខ្លួន អ្នកដែលមិនសរសើរសេចក្តីព្យាយាមមិនមាន យើងនឹងសម្តែងឲ្យជាប់ដោយសេចក្តីព្យាយាម ការសម្តែងធម៌យ៉ាងនេះ នឹងជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ជនគ្រប់ជំពូកបាន ជ្រើសរើសក្នុងព្រះត្រៃបិដកហើយ ទើបបានពោលគាថាទាំងនេះ ។

**[៩៦]** បណ្តាបទទាំងនោះ បទថា **អារព្ភថ** បានដល់ ចូរផ្តើមសេចក្តីព្យាយាម ។ បទថា **និក្កមថ** បានដល់ ចូរធ្វើសេចក្តីខ្មីឃ្មាត ។ បទថា **យុញ្ជថ** បានដល់ ចូរប្រកបព្យាយាម គឺ ចូរសង្វាត ។ បទថា **មច្ចុនោ សេនំ** សេចក្តីថា កងទ័ព គឺ កិលេស ឈ្មោះថា កងទ័ពនៃមច្ចុ ។ បទថា **ជាតិសំសារំ** បានដល់ ជាតិ និងសង្សារ ឬសង្សារ ពោលគឺ ជាតិ ។ បទថា **ទុក្ខស្សន្តំ ករិស្សតិ** បានដល់ នឹងធ្វើការកំណត់វដ្តទុក្ខ ។ សួរថា ក៏ព្រះថេរៈធ្វើយ៉ាងណា ទើបធ្វើឲ្យមុឺនលោកធាតុដឹងគ្នាបាន ។ ឆ្លើយថា មុនដំបូងព្រះថេរៈចូលនីលកសិណ ហើយផ្សាយកាពងងឹតទៅក្នុងទីមានពន្លឺទាំងពួង ។ ចូលឱទាត-

កសិណហើយ ធ្វើទីងងឹតឲ្យភ្លឺ សម្ដែងអាលោកកសិណ ក្នុងកាលពួកសត្វកើតត្រិះរិះថា ហេតុដូចម្ដេចទើបងងឹតយ៉ាងនេះ ។ ក្នុងទីមានពន្លឺ មិនមានកិច្ចដោយពន្លឺ ។ កាលពួកសត្វត្រិះរិះថា ពន្លឺនេះ គឺអ្វី ទើបសម្ដែងខ្លួន ។ គ្រានោះ កាលសត្វទាំងនោះនិយាយគ្នាថា ព្រះថេរៈ ទើបបានពោលគាថាទាំងនេះ ។ សត្វទាំងពួងស្ដាប់សំឡេងព្រះថេរៈ ដូចគង់សម្ដែងធម៌នៅត្រង់កណ្ដាលបរិស័ទដែលប្រជុំគ្នា ។ សូម្បីអត្ថ ក៏បានប្រាកដដល់សត្វទាំងនោះ ។

ចប់អដ្ឋកថា អរុណវតីសូត្រទី ៤

# អ ដ្ឋ ក ថា

## បរិនិព្វានសូត្រទី ៥

ក្នុងបរិនិព្វានសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៩៧] បទថា *ឧបវត្តនេ មល្លានំ សាលវនេ* សេចក្តីថា សាលវនឧទ្យាន នៅត្រើយឯណោះនៃទន្លេ ឈ្មោះហិរញ្ញវតី ដូចផ្លូវទៅថូបារាមតាមប្រកផ្លូវទ្វាររាជមាតុវិហារពីត្រើយស្ទឹងកទម្ពៈ ។ សាលវនឧទ្យាននោះ នៅក្នុងក្រុងកុសិនារា ដូចថូបារាមនៃអនុរាធបុរី ។ ជួរដើមសាលព្រឹក្ស ចាប់ពីសាលវនឧទ្យានឆ្ពោះទៅខាងទិសបស្ចិម ហើយបត់ទៅទិសឧត្តរ ដូចផ្លូវដែលទៅកាន់ព្រះនគរតាមទិសទក្សិណ ពីថូបារាមត្រង់ទៅផ្លូវខាងទិសបច្ចិម ហើយបត់ទៅទិសឧត្តរ ដូច្នោះ ។ ព្រោះដូច្នោះ សាលវនឧទ្យាននោះ លោកទើបហៅថា ផ្លូវបត់ ។ ដើមសាលព្រឹក្សទាំងគូក្នុងសាលវនរបស់ពួកមល្លក្សត្រដែលជាផ្លូវបត់ចូលទៅក្រុងកុសិនារា ។ បទថា *អន្តរេន យមកសាលានំ* សេចក្តីថា ក្នុងចន្លោះនៃដើមសាលៈ ដែលមានមែកជាប់គ្នា ចំណែកឫសក៏ជាប់គ្នា ។ បទថា *អប្បមាទេន សម្បាទេថ* សេចក្តីថា អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចទាំងពួង

ឲ្យសម្រេចដោយការមិនទៅប្រាសចាកសតិចុះ ។ ដូច្នោះ ព្រះមានព្រះភាគ ទ្រង់ផ្ដុំលើព្រះវែទនបរិនិព្វាន ទើបទ្រង់ប្រទានព្រះឱវាទទាំងអស់ដែលទ្រង់ប្រទានមកអស់ ៤៥ វស្សា ចុះក្នុងបទអប្បមាទធម៌ តែមួយប៉ុណ្ណោះ ដូចកុដុម្ពីអ្នកមានទ្រព្យច្រើន ដែលដេកលើគ្រែជាទីស្លាប់ គប្បីប្រាប់ទ្រព្យដែលជាសារៈដល់បុត្រទាំងឡាយ ដូច្នោះ ។ ក៏ពាក្យថា **អយំ តថាគតស្ស បច្ឆិមវាចា** នេះ ជាពាក្យរបស់ព្រះសង្គីតិកាចារ្យ ។

**[១០០]** ខាងមុខពីនេះ ដើម្បីនឹងសម្ដែងដល់បរិកម្មនៃបរិនិព្វាន ដែលព្រះមានព្រះភាគទ្រង់ធ្វើហើយ ដើម្បីបរិនិព្វាន ព្រះសង្គីតិកាចារ្យ ទើបពោលថា **អថខោ ភគវា បឋមជ្ឈានំ** ដូច្នេះជាដើម ។ កាលព្រះមានព្រះភាគ ទ្រង់ចូលសញ្ញាវេទយិតនិរោធសមាបត្តិ ក្នុងទីនោះ ទេវតា និងមនុស្សឃើញការមិនប្រព្រឹត្តទៅនៃខ្យល់អស្សាសបស្សាសៈ ទើបបានស្រែកឡើងព្រមគ្នាដោយយល់ថា ព្រះសាស្ដាបរិនិព្វានហើយ ។ ចំណែកព្រះអានន្ទត្ថេរ សួរព្រះអនុរុទ្ធត្ថេរថា អាវុសោអនុរុទ្ធ ព្រះមានព្រះភាគបរិនិព្វានហើយឬ ។ ព្រះអនុរុទ្ធឆ្លើយថា អាវុសោអានន្ទ ព្រះតថាគតមិនទាន់បរិនិព្វានទេ តែព្រះអង្គទ្រង់ចូលសញ្ញាវេទយិតនិរោធសមាបត្តិ ។ សួរថា ព្រះអនុរុទ្ធដឹងបានយ៉ាងណា ។ ឆ្លើយ

ថា បានឮមកថា ព្រះថេរៈចូលសមាបត្តិនោះៗ ដំណាលគ្នានឹងព្រះសាស្តាតែម្តង ដរាបដល់ចេញចាកនេវសញ្ញានាសញ្ញាយតនសមាបត្តិ បានដឹងថា ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ចូលនិរោធសមាបត្តិ ដែលឈ្មោះថា ការធ្វើកាលៈខាងក្នុងនិរោធសមាបត្តិ រមែងមិនមាន ។

ព្រះមានព្រះភាគ ទ្រង់ចូលបឋមជ្ឈានក្នុងឋានៈ ២៤ ក្នុងពាក្យនេះថា គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ចេញចាកសញ្ញាវេទយិតនិរោធសមាបត្តិ ហើយចូលនេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ល។ ចេញចាកតតិយជ្ឈាន ហើយចូលចតុត្ថជ្ឈាន ។ ក្នុងឋានៈ ១៣ ចូលទុតិយជ្ឈាន តតិយជ្ឈាន ក៏ដូចគ្នា ក្នុងឋានៈ ១៥ ទ្រង់ចូលចតុត្ថជ្ឈាន ។ សួរថា តើចូលយ៉ាងណា ? ឆ្លើយថា ចូលដូច្នេះ គឺ លំដាប់ដំបូង ទ្រង់ចូលបឋមជ្ឈាន ក្នុងឋានៈ ២៤ ទាំងនេះ គឺ អសុភ ១០ អាការ ៣២ (អាការ ៣២ រាប់តែ ១ ឋានៈ) កសិណ ៨ មេត្តា ករុណា មុទិតា អានាបានស្សតិ ១ បរិច្ឆេទាកាសកសិណ ១ ។ តែទ្រង់វៀរអាការ ៣២ អសុភ ១០ ទ្រង់ចូលទុតិយជ្ឈាន និងតតិយជ្ឈាន ក្នុងបណ្តាឈាន ១៣ ដ៏សេស ។ មួយទៀត ទ្រង់ចូលចតុត្ថជ្ឈានក្នុងឋានៈ ១៥ ទាំងនេះ គឺ កសិណ ៨ ឧបេក្ខាព្រហ្មវិហារ ១ អានាបានស្សតិ ១ បរិច្ឆេទាកាស-

កសិណ ១ អរូបឈាន ៤ ។ ក៏កថាដោយសង្ខេបត្រឹមតែប៉ុណ្ណេះ ។ ព្រះមាន-ព្រះភាគ ជាម្ចាស់នៃធម៌ ស្តេចចូលកាន់នគរនិព្វាន ទ្រង់ចូលសមាបត្តិទាំងអស់រាប់បាន ២៤ សែនកោដិ ហើយចូលសោយសុខក្នុងសមាបត្តិទាំងអស់ ដូចអ្នកទៅកាន់ប្រទេសផ្សេងៗ ឱបជនដែលជាញាតិ ។

ក៏ក្នុងពាក្យថា **ចតុត្ថជ្ឈានា វុដ្ឋហិត្វា សមនន្តរា ភគវាបរិនិព្វុតោ** នេះ សេចក្តីថា មានលំដាប់ ២ យ៉ាងគឺ លំដាប់នៃឈាន ១ លំដាប់នៃបច្ចវេក្ខណញ្ញាណ ១ ។ ការដែលព្រះមានព្រះភាគចេញពីចតុត្ថជ្ឈាន ធ្លាក់ចុះកាន់ភវង្គចិត្ត ហើយបរិនិព្វានក្នុងខណៈនោះឯង ឈ្មោះថា លំដាប់នៃឈាន ។ ការដែលព្រះមានព្រះភាគ ចេញចាកចតុត្ថជ្ឈាន ហើយពិចារណាអង្គឈានដដែលទៀត ធ្លាក់ចុះកាន់ភវង្គចិត្តហើយបរិនិព្វាន ក្នុងខណៈនោះឯង ឈ្មោះថា លំដាប់នៃបច្ចវេក្ខណញ្ញាណ ។ លំដាប់ ២ យ៉ាងដូចពោលមកនេះ ។ ចំណែកព្រះមានព្រះភាគ ចូលឈានហើយ ចេញចាកឈាន ហើយទ្រង់ពិចារណាអង្គឈាន ហើយបរិនិព្វានដោយអព្យាកតទុក្ខសច្ចដែលជាភវង្គចិត្ត ។ ក៏ជនពួកណាមួយ មិនថា ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ឬព្រះអរិយសាវក ដោយហោចទៅសូម្បីស្រមោចខ្មៅ ស្រមោចក្រហមទាំងអស់ រមែងធ្វើកាលៈដោយអព្យា-

កតទុក្ខសច្ច ដែលជាកវគ្គិចិត្តនោះ ដូច្នេះឯង ។

**[១០១]** បទថា **ភូតា** ប្រែថា ពួកសត្វ ។ បទថា **អប្បដិបុគ្គលោ** បានដល់ វៀរចាកបុគ្គលដែលនឹងប្រៀបធៀបបាន ។ បទថា **ពលប្បត្តោ** បានដល់ ជាបុគ្គលដែលសម្រេចពលញ្ញាណ ១០ ។

**[១០២]** បទថា **ឧប្បាទវយធម្មិនោ** បានដល់ មានការកើត និងការរលត់ជាសភាវៈ ។ បទថា **តេសំ វូបសមោ សុខោ** សេចក្តីថា ព្រះនិព្វានពោលគឺ ការចូលទៅស្ងប់នូវសង្ខារទាំងនោះឯង គឺ ជាសុខ ។

**[១០៣]** ដោយពាក្យថា **តទាសិ** លោកពោលសំដៅយកផែនដីញ័រដែលលោកពោលទុកក្នុងមហាបរិនិព្វានសូត្រ យ៉ាងនេះថា ផែនដីធំញាប់ញ័ររមែងមានព្រមនឹងការបរិនិព្វាន សេចក្តីពិត ផែនដីធំញាប់ញ័រនោះ ឲ្យកើតការព្រឺរោម និងមានសភាពគួរខ្លាច ។ បទថា **សព្វាការវរូបេតេ** បានដល់ប្រកបដោយការធ្វើដ៏ប្រសើរដោយអាការទាំងពួង ។

**[១០៤]** បទថា **នាហុ អស្សាសបស្សាសោ** បានដល់ ខ្យល់អស្សាសបស្សាសៈមិនកើត ។ បទថា **អនេជោ** សេចក្តីថា ឈ្មោះថា អនេជៈ ព្រោះមិនមានកិលេសជាតិជាគ្រឿងញាប់ញ័រ ពោលគឺ តណ្ហា ។ បទថា **សន្តិ-**

**មារត្ថ** បានដល់ អាស្រ័យ គឺ សំដៅយកអនុបាទិសេសនិព្វាន ។ បទថា **ចក្ខុមា** បានដល់ អ្នកមានចក្ខុ ដោយចក្ខុ ៥ ។ បទថា **បរិនិព្វុតោ** បានដល់ បរិនិព្វាន ដោយខន្ធបរិនិព្វាន ។

បទថា **អសល្លីនេន** បានដល់ មានចិត្តមិនរួញរា មិនកោង គឺ រីករាយ ដោយល្អនុ៎ះឯង បទថា **វេទនំ អជ្ឈាវសយិ** បានដល់ គ្របសង្កត់នូវវេទនា មិនបណ្តោយតាមវេទនា ដែលរសាប់រសល់ទៅខាងនេះខាងនោះ ។ បទថា **វិមោក្ខោ** បានដល់ រួចផុត មិនមានគ្រឿងរាំង ។ អធិប្បាយថា ចូលដល់ សភាពមិនមានបញ្ញត្តិដោយប្រការទាំងពួង ដូចជាភ្លើងដែលឆេះសន្ធោសន្ធៅ ហើយរលត់ទៅ ដូច្នេះឯង ។

ចប់អដ្ឋកថា បរិនិព្វានសូត្រទី ៥

**វគ្គទី ២ នៃព្រហ្មសំយុត្ត ចប់ត្រឹមតែប៉ុណ្ណេះ**

## ព្រហ្មសំយុត្តចប់

**រួមក្នុងវគ្គនេះមាន ០៥ អដ្ឋកថា**

១-អដ្ឋកថាសនង្កុមារសូត្រ
២-អដ្ឋកថាទេវទត្តសូត្រ
៣-អដ្ឋកថាអន្ធកវិន្ទសូត្រ
៤-អដ្ឋកថាអរុណវតីសូត្រ
៥-អដ្ឋកថាបរិនិព្វានសូត្រ

# ព្រាហ្មណសំយុត្ត

## អរហន្តវគ្គទី ១

## អ ដ្ឋ ក ថា

### ធនញ្ជានីសូត្រទី ១

*ធនញ្ជានីសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[១០៥]** *បទថា* **ធនញ្ជានី** *បានដល់ នាងព្រាហ្មណី ជាធនញ្ជានីគោត្រ បានឮថា ធនញ្ជានីគោត្រនោះ ជាគោត្រខ្ពង់ខ្ពស់ ។ បានឮមកថា ពួកព្រាហ្មណ៍ក្រៅពីនោះកើតពីមាត់របស់ព្រហ្ម ។ តែព្រាហ្មណ៍ទាំងនោះ មានលទ្ធិដូច្នេះថា ធនញ្ជានីគោត្រទម្លាយក្បាលព្រហ្មចេញមក ។ បទថា* **ឧទានំ ឧទានេសិ** *សេចក្តីថា សួរថា ព្រោះហេតុអ្វី ព្រាហ្មណីទើបបានបន្លឺវាចា បានឮថា ព្រាហ្មណ៍ជាប្តីមាននោះ ជាអ្នកមានមិច្ឆាទិដ្ឋិ កាលនាងពោលថា* **ពុទ្ធោ ធម្មោ សង្ឃោ** *ក៏បិទត្រចៀក គេជាមនុស្សរឹងរូសដូចដង្កត់ឈើ ចំណែកព្រាហ្មណីជាអរិយ-*

សាវកថ្នាក់សោតាបន្នបុគ្គល ។ ព្រាហ្មណ៍កាលឲ្យទាន រមែងឲ្យបាយបាយាស មានទឹកតិចដល់ព្រាហ្មណ៍ ៥០០ នាក់ ។ ព្រាហ្មណីបានឲ្យភោជន មានរស ផ្សេងៗ ដល់ពួកភិក្ខុមានព្រះពុទ្ធជាប្រធាន ។ ក្នុងថ្ងៃដែលព្រាហ្មណ៍ឲ្យទាន ព្រាហ្មណី បានអង្គាសដោយដៃរបស់ខ្លួន ព្រោះជាអ្នកនៅក្នុងអំណាចរបស់ ព្រាហ្មណ៍នោះ និងព្រោះលះសេចក្តីកំណាញ់ចេញបាន ។ តែក្នុងថ្ងៃដែល ព្រាហ្មណីឲ្យទាន ព្រាហ្មណ៍ក៏គេចចេញអំពីផ្ទះពីព្រឹកព្រលឹម ។ តមកថ្ងៃមួយ ព្រាហ្មណ៍ទើបប្រឹក្សានឹងព្រាហ្មណីថា យើងអញ្ជើញព្រាហ្មណ៍ ៥០០ នាក់មក ហើយពោលនឹងព្រាហ្មណីថា នែនាងដ៏ចម្រើន ស្អែកនេះ ព្រាហ្មណ៍ ៥០០ នាក់ នឹងបរិភោគក្នុងផ្ទះរបស់យើង ។ នាងសួរថា ខ្ញុំនឹងជួយធ្វើអ្វីបានខ្លះ ព្រាហ្មណ៍ ។ ព្រាហ្មណ៍ពោលថា មិនមានកិច្ចអ្វីដទៃដែលនាងនឹងត្រូវជួយទេ មនុស្សដទៃនឹងធ្វើការដាំស្ល និងអង្គាសទាំងអស់ តែនៅពេលនាងឈរក្តី អង្គុយ ក្តី កណ្តាស់ក្តី ក្អកក្តី ធ្វើការនមស្ការដល់សមណៈត្រងោលនោះថា **នមោ ពុទ្ធស្ស** នោះ ស្អែកនេះ នាងកុំពោលពាក្យនោះត្រឹមតែមួយថ្ងៃចុះ ព្រោះថា ព្រាហ្មណ៍ទាំងឡាយ បានឮដូច្នោះហើយ នឹងមិនពេញចិត្ត នាងកុំធ្វើយើងឲ្យ បែកអំពីព្រាហ្មណ៍ទាំងឡាយឡើយ ។ នាងពោលថា លោកបែកអំពីព្រាហ្មណ៍

ក្តី អំពីទេវតាក្តី ចំណែកខ្ញុំរលឹកដល់ព្រះសាស្តា បើមិនទមស្មារ មិនអាចនឹងអត់ទ្រាំបាន ។ ព្រាហ្មណ៍ពោលថា នែនាងដ៏ចម្រើន ពេលមុននាងធ្លាប់ព្យាយាមបិទទ្វារក្នុងស្រុក ១០០ ត្រកូល (ហេតុអ្វីនាង) មិនអាចបិទមាត់ដែលនឹងគប្បីបិទដោយដៃទាំង ២ ក្នុងខណៈដែលពួកព្រាហ្មណ៍បរិភោគប៉ុណ្ណោះ ។ ព្រាហ្មណ៍នោះសូម្បីនិយាយដដែលៗ យ៉ាងនេះ ក៏មិនអាចហាមបាន ព្រោះសេចក្តីស្រឡាញ់ទើបកាន់យកដាវដែលដាក់លើក្បាលដំណេក ពោលថា នែ៎នាងដ៏ចម្រើន កាលព្រាហ្មណ៍អង្គុយប្រជុំគ្នាស្អែកនេះ បើនាងឯងនមស្ការសមណៈត្រងោលនោះសោត យើងនឹងយកដាវនេះកាប់ចិញ្ច្រាំនាងឯង តាំងពីបាតជើងដរាបដល់ចុងសក់ ធ្វើឲ្យជាគំនរដូចពន្លកឈើ ដូច្នេះ ហើយបានពោលគាថាទាំងនេះថា ៖

បើនាងនៅក្នុងផ្ទះរបស់យើង មិនធ្វើតាមបំណងដែលយើង
ប្រាថ្នា នៅតែនិយាយថា ពុទ្ធោ ធម្មោ សង្ឃោ ដូច្នេះ យើង
នឹងយកដាវនេះ កាត់នាងឯង តាំងពីជើងដរាបដល់សីសៈ
ដូចកាត់ពន្លកឈើ ។

ចំណែកព្រាហ្មណី ដែលជាអរិយសាវិកា មិនមានសេចក្តីញាប់ញ័រដូចផែនដី មិនមានសេចក្តីកម្រើករញ្ជួយដូចភ្នំសិនេរុ ។ ព្រោះដូច្នោះ នាង

ទើបពោលនឹងព្រាហ្មណ៍នោះ យ៉ាងនេះថា ៖

បពិត្រព្រាហ្មណ៍ បើលោកនឹងកាត់អវយវៈតូចធំរបស់យើង
ក៏ដោយ យើងមិនវៀរចាកសាសនារបស់ព្រះពុទ្ធដ៏ប្រសើរ
ឡើយ លោកមិនអាចហាមយើងចាកពីព្រះជិនស្រីអ្នកទ្រ
ទ្រង់គុណដ៏ប្រសើរ ជាទីពឹងរបស់ខ្ញុំបានទេ លោកនឹងកាត់
ឬនឹងស្ងោរខ្ញុំក៏ដោយចុះ ខ្ញុំក៏ឈ្មោះថា ជាធីតារបស់ព្រះ-
ពុទ្ធដ៏ប្រសើរហើយ ។

ធនញ្ជានីព្រាហ្មណី គម្រាមព្រាហ្មណ៍ដែលគម្រាមហើយ ទើបបានពោលគាថា ៥០០ គាថា ដោយប្រការដូច្នេះ ។ ព្រាហ្មណ៍មិនអាចចាប់ ឬវាយព្រាហ្មណី ទើបពោលថា នែ៎នាងដ៏ចម្រើន នាងចូរធ្វើតាមដែលនាងឯងពេញចិត្តចុះ ហើយក៏បោះដាវទៅលើទីដេក ។ ក្នុងថ្ងៃស្អែក ទើបឲ្យរៀបចំផ្ទះលាបដោយពណ៌ខៀវសុទ្ធ ឲ្យប្រដាប់ដោយលាជ មានឆ្នាំងពេញដោយទឹក មានផ្កាឈើ និងគ្រឿងក្រអូបជាដើមក្នុងទីនោះៗ ហើយឲ្យចាត់បាយបាយាសមានទឹកតិចផ្សំដោយទឹកដោះខាប់ ទឹកដោះថ្លា ស្ករក្រួស និងទឹកឃ្មុំ ហើយឲ្យប្រាប់វេលាដល់ព្រាហ្មណ៍ ៥០០ នាក់ ។

ចំណែកព្រាហ្មណី ងូតទឹកក្រអូបពីព្រឹកព្រលឹម ស្លៀកសំពត់ថ្មី មានតម្លៃ ១.០០០ យកសំពត់មានតម្លៃ ៥០០ ធៀងស្មាម្ខាង ប្រដាប់ដោយគ្រឿងប្រដាប់គ្រប់យ៉ាង កាន់វែកមាសអង្គាសពួកព្រាហ្មណ៍ក្នុងរោងអាហារ បង្អោននាំអាហារទៅឲ្យព្រាហ្មណ៍ជាប្តីដែលអង្គុយក្នុងជួរ តែមួយជាមួយព្រាហ្មណ៍ទាំងនោះ ក៏ជំពប់ជើងនឹងគ្រឿងឈើដែលគេរក្សាទុកមិនរៀបរយ ទុក្ខវេទនាកើតឡើងដល់នាង ព្រោះប៉ះទង្គិចក្នុងការជំពប់ ។ ខណៈនោះនាងរលឹកដល់ព្រះទសពល ។ តែព្រោះនាងសម្បូរណ៍ដោយសតិ នាងក៏មិនបោលថាសបាយបាយាស ដាក់ចុះសន្សឹមៗ លើផែនដី ផ្គងអញ្ជលីលើសិរសាត្រង់កណ្តាលពួកព្រាហ្មណ៍ ៥០០ នាក់ ហើយផ្គងអញ្ជលីទៅកាន់វត្តជេតពន ទើបបានបន្លឺឧទាននេះ ។

ក៏វេលានោះ បណ្តាព្រាហ្មណ៍ទាំងនោះ ពួកខ្លះបរិភោគស្រេចហើយ ពួកខ្លះកំពុងបរិភោគ ពួកខ្លះលូកដៃចុះ ពួកខ្លះត្រឹមតែដាក់ភោជនទុកខាងមុខព្រាហ្មណ៍ទាំងនោះ គ្រាន់តែបានឮសំឡេងនោះ ដូចជាត្រូវញញួរប៉ុនភ្នំសិនេរុសំពងចុះលើសីសៈ និងដូចត្រូវលំពែងចាក់ត្រង់ត្រចៀក សោយទុក្ខទោមនស្សក្រោធថា ពួកយើងត្រូវអ្នកក្រៅលទ្ធិនេះលួងលោម យើងឲ្យចូលទៅកាន់ផ្ទះ

ទើបចោលដុំបាយ ស្តោះវត្ថុដែលទុកដូចជាក្អែកឃើញធ្នូ ព្រាហ្មណ៍ទាំងនោះដើរបណ្តើរជេរបណ្តើរ ហើយនាំគ្នាចេញទៅ ម្នាក់មួយទិស ម្នាក់មួយផ្លូវ ។ ព្រាហ្មណ៍ជាប្តី ឃើញពួកព្រាហ្មណ៍នាំគ្នាបែកផ្លូវគ្នាយ៉ាងនោះ សម្លឹងមើលនាងព្រាហ្មណីតាំងពីសិរសៈ គិតថា យើងឃើញភ័យនេះឯង ទើបសូមអង្វរនាងតាំងពីថ្ងៃម្សិលមិញក៏មិនបាន ទើបជេរនាងព្រាហ្មណីដោយប្រការផ្សេងៗ ហើយបានពោលនឹងនាងមានពាក្យជាដើមថា **ឯវមេវ បន** ដូច្នេះ ។

**[១០៧]** បទថា **ឧបសង្កមិ** សេចក្តីថា ព្រាហ្មណទៅដោយគិតថា ព្រះសមណគោតម ដែលអ្នកស្រុក អ្នកនិគម និងអ្នកដែនបូជាហើយ នរណាៗ មិនអាចនឹងទៅពោលគម្រាមយ៉ាងណាៗ បាន ចាំយើងនឹងសួរបញ្ហាត្រឹមតែមួយប្រការ ទើបបានតែងគាថាថា **កឹសុ ឆេត្វា** ជាដើម ហើយគិតថា បើព្រះ-សមណគោតមនឹងពោលថា យើងពេញចិត្តការសម្លាប់បុគ្គលឈ្មោះឯណោះ បើដូច្នេះ យើងនឹងគ្របសង្កត់ព្រះអង្គថា ព្រះអង្គប្រាថ្នានឹងសម្លាប់ពួកជនដែលព្រះអង្គមិនពេញព្រះទ័យ ព្រះអង្គកើតមកដើម្បីសម្លាប់សត្វលោក ភាពជាសមណៈរបស់ព្រះអង្គនឹងមានប្រយោជន៍អ្វី បើព្រះសមណគោតមនឹងពោលថា យើងមិនពេញចិត្តការសម្លាប់អ្នកណាៗ បើដូច្នេះ យើងនឹងគ្របសង្កត់ព្រះអង្គ

ថា ព្រះអង្គមិនប្រាថ្នានឹងសម្លាប់កិលេស មានរាគៈជាដើម ព្រោះហេតុអ្វីព្រះអង្គ ទើបជាសមណៈត្រាច់ទៅ ដូច្នោះ បញ្ហា ២ ចំណុចនេះ ព្រះសមណគោតមក៏នឹងលេបមិនចូល ខ្ជាក់មិនចេញ ដូច្នេះ ហើយក៏ចៀសចេញទៅ បទថា **សម្មោទី** សេចក្តីថា ព្រាហ្មណ៍មិនសម្តែងសេចក្តីក្រោធ ព្រោះខ្លួនជាបណ្ឌិត ទើបពោលពាក្យពីរោះលើកសរសើរ ។ លោកពោលបញ្ហានេះទុកក្នុងទេវតាសំយុត្ត ។ សូម្បីពាក្យដ៏សេស លោកពោលទុកពិស្តារហើយក្នុងខាងក្រោយនោះឯង ។

ចប់អដ្ឋកថា ធនញ្ជានីសូត្រ ទី ១

# អ ដ្ឋ ក ថា

## អក្កោសកសុត្រទី ២

*ក្នុងអក្កោសកសូត្រទី* ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[១១០]** *បទថា* ***អក្កោសកភារទ្វាជោ*** *បានដល់ ព្រាហ្មណ៍នោះ ឈ្មោះថា ភារទ្វាជៈ ។ ក៏ព្រាហ្មណ៍នោះបានមកជេរព្រះតថាគតដោយគាថា ប្រមាណ ៥០០ ព្រោះហេតុនោះ ព្រះសង្គីតិកាចារ្យទាំងឡាយទើបតាំងឈ្មោះថា* ***អក្កោស-កភារទ្វាជ*** *។ បទថា* ***កុបិតោ អនត្តមនោ*** *សេចក្ដីថា ព្រាហ្មណ៍មិនពេញចិត្ត ដោយខឹងក្រោធថា ព្រះសមណគោតមឲ្យបងប្រុសរបស់យើងបួស ធ្វើឲ្យសាប-សូន្យ ឲ្យបែកជាពួក ។ បទថា* ***អក្កោសតិ*** *សេចក្ដីថា ជេរដោយអក្កោសវត្ថុ ១០ គឺ ឯងជាចោរ ជាបុគ្គលល្ងង់ ជាបុគ្គលវង្វេង ជាអូដ្ឋ ជាគោ ជាលា ជាសត្វនរក ជាសត្វតិរច្ឆាន អ្នកឯងមិនមានសុគតិ អ្នកឯងប្រាថ្នាតែទុគ្គតិ ប៉ុណ្ណោះ ។ បទថា* ***បរិភាសតិ*** *សេចក្ដីថា កាលពោលពាក្យជាដើមថា សមណៈ ត្រងោលប្រការនោះចូរលើកទុកចុះ ព្រះអង្គនៅសង្គាល់ថា ព្រះអង្គមិនមាន ទោស ឥឡូវនេះ ខ្ញុំព្រះអង្គនឹងទៅកាន់រាជត្រកូល ហើយនឹងប្រាប់គេឲ្យដាក់*

អាជ្ញាដល់ព្រះអង្គ ដូច្នេះ ឈ្មោះថា **បរិភាស** ។

បទថា **សម្ភុញ្ជតិ** បានដល់ បរិភោគរួមគ្នា ។ បទថា **វីតិហរតិ** បានដល់ ធ្វើតាមចំពោះបុគ្គលដែលធ្វើហើយ ។ បទថា **កស្មា ខោ គោតមំ** សួរថា ព្រោះហេតុអ្វី ព្រាហ្មណ៍ទើបពោលយ៉ាងនេះ ។ ឆ្លើយថា ព្រោះព្រាហ្មណ៍បានស្តាប់ពាក្យរបស់ព្រះសមណគោតមនោះថា ម្នាលព្រាហ្មណ៍ នុ៎ះជារបស់អ្នកតែម្យ៉ាង ម្នាលព្រាហ្មណ៍ នុ៎ះជារបស់អ្នកតែម្យ៉ាង ដោយបានស្តាប់តៗគ្នាមកថា ដែលឈ្មោះថា ឥសីទាំងឡាយក្រោធហើយ រមែងដាក់បណ្តាសាឲ្យដូចជាកូនគោស្គមជាដើម ទើបកើតសេចក្តីភ័យខ្លាចនឹងពាក្យបណ្តាសាថា ព្រះសមណគោតមខឹងយើង នឹងបណ្តាសាយើងក៏បាន ព្រោះដូច្នោះ ព្រាហ្មណ៍ទើបបានពោលយ៉ាងនេះ ។

**[១១២]** បទថា **ទន្តស្ស** បានដល់ បុគ្គលមិនមានអស្មិមានះ ។ បទថា **តាទិនោ** បានដល់ បុគ្គលដល់នូវលក្ខណៈមិនញាប់ញ័រ ។ បទថា **តស្សេវ តេន បាបិយោ** សេចក្តីថា បុគ្គលនោះឯងជាមនុស្សអាក្រក់ជាងបុគ្គលដែលក្រោធនោះ ។ បទថា **សតោ ឧបសម្មតិ** សេចក្តីថា បុគ្គលជាអ្នកប្រកបដោយសតិ រមែងអត់សង្កត់សេចក្តីក្រោធបាន ។ បទថា **ឧភិន្នំ តិកិច្ឆន្តានំ** បានដល់

អ្នកអត់ទ្រាំបានទាំង ២ ចំណែក ។ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។ បុគ្គលណាមានសតិចូលទៅរម្ងាប់ ប្រព្រឹត្តប្រយោជន៍ អត់សង្កត់នូវសេចក្តីក្រោធឲ្យសម្រេចប្រយោជន៍ទាំងពីរចំណែក ។ ជនទាំងឡាយ រមែងសម្គាល់បុគ្គលនោះថា ជាជនពាល ជនទាំងឡាយដូចជានរណា គឺ ជាអ្នកមិនឆ្លាតក្នុងធម៌ ។ បទថា **ធម្មស្ស** បានដល់ ធម៌ គឺ បញ្ចក្ខន្ធ ឬសច្ចធម៌ ៤ ។ បទថា **អកោវិទា** បានដល់ អ្នកមិនឆ្លាតក្នុងធម៌ គឺ ជាបុថុជ្ជនអន្ធពាល ។

ចប់អដ្ឋកថា អក្កោសកសូត្រ ទី២

# អ ដ្ឋ ក ថា

## អសុរិន្ទកសូត្រទី ៣

*អសុរិន្ទកសូត្រទី ៣* មានវិនិច្ឆ័យដូចតទៅនេះ ៖

**[១១៤]** បទថា *អសុរិន្ទកភារទ្វាជោ* បានដល់ ប្អូនប្រុសរបស់អក្កោសកភារទ្វាជព្រាហ្មណ៍ ។ បទថា **កុបិតោ** សេចក្តីថា ជាអ្នកក្រោធ ព្រោះហេតុនោះឯង ។ បទថា **ជយញ្ចេវស្ស តំ ហោតិ** សេចក្តីថា នោះជាជ័យជំនះរបស់អ្នកនោះឯង ។ អធិប្បាយថា នោះជាជ័យជំនះ ។ សួរថា ជាជ័យជំនះរបស់បុគ្គលដូចម្តេច ។ ឆ្លើយថា សេចក្តីអត់ទ្រាំឯណារបស់បុគ្គលដឹងច្បាស់ សេចក្តីអត់ទ្រាំ គឺ សេចក្តីអត់ធន់របស់បុគ្គលដឹងច្បាស់នូវគុណដោយសេចក្តីអត់ទ្រាំនោះ នេះជាជ័យជំនះរបស់បុគ្គលដឹងច្បាស់នោះឯង ។ ចំណែកជនពាល ពោលពាក្យគ្រោតគ្រាត រមែងសម្គាល់ជ័យជំនះតែម្យ៉ាងថា ជាជ័យជំនះរបស់យើង ។

ចប់អដ្ឋកថា អសុរិន្ទកសូត្រទី ៣

# អ ដ្ឋ ក ថា

## ពិលង្គិកសូត្រទី ៤

*ពិលង្គិកសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[១១៧]** *បទថា* ***ពិលង្គិកភារទ្វាជោ*** *បានដល់ ព្រាហ្មណ៍នោះ ឈ្មោះថា ភារទ្វាជៈ ។ តែគេឲ្យធ្វើទឹកបាយស្ងួតៗ និងផ្សំដោយគ្រឿងផ្សំ មានប្រការផ្សេងៗ ទុកលក់ បានសន្សំទ្រព្យទុកជាច្រើន ព្រោះដូច្នោះ ព្រះសង្គីតិកាចារ្យទាំងឡាយ ទើបតាំងឈ្មោះគេថា* ***ពិលង្គិកភារទ្វាជ*** *។ បទថា* ***តណ្ហីភូតោ*** *សេចក្តីថា គេគិតថា អ្នកនេះឲ្យបងប្រុសទាំង ៣ របស់យើងបួស ក៏ក្រោធយ៉ាងខ្លាំង កាលមិនអាចនិយាយអ្វីបាន ទើបបានឈប់ស្ងៀម ។ លោកពោលគាថាទុកហើយ ក្នុងទេវតាសំយុត្តនោះឯង ។*

ចប់អដ្ឋកថា ពិលង្គិកសូត្រទី ៤

# អ ដ្ឋ ក ថា

## អហិង្សកសូត្រទី ៥

ក្នុងអហិង្សកសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[១២០]** បទថា *អហឹសកភារទ្វាជោ* បានដល់ ព្រាហ្មណ៍នោះឈ្មោះថា អហិង្សកភារទ្វាជៈ ។ ព្រោះព្រាហ្មណ៍នោះ សួរអហិង្សកបញ្ហា ។ ព្រោះហេតុនោះ ព្រះសង្គីតិកាចារ្យទាំងឡាយ ទើបបានតាំងឈ្មោះគេដូច្នោះ ។ មួយាងទៀត ព្រាហ្មណ៍នោះទើបពោលដោយឈ្មោះ ឈ្មោះថា អហិង្សកៈ បើពោលដោយគោត្រ ឈ្មោះថា ភារទ្វាជៈ ។ បទថា *អហឹសកាហំ* សេចក្ដីថា គេពោលថា ព្រះសមណគោតមដ៏ចម្រើន ស្គាល់យើងថា យើងឈ្មោះថា អហិង្សកៈ ។

**[១២១]** បទថា *តថា ចស្ស* កាត់បទជា *តថា ចេ អស្ស* សេចក្ដីថា គួរជា (អ្នកមិនបៀតបៀន) ។ បទថា *ន ហឹសតិ* បានដល់ មិនបៀតបៀន គឺ មិនឲ្យដល់សេចក្ដីលំបាក ។

ចប់អដ្ឋកថា អហិង្សកសូត្រទី ៥

# អ ដ្ឋ ក ថា

## ជដាសូត្រទី ៦

*ជដាសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[១២៣]** *បទថា ជដាភារទ្វាជោ បានដល់ ព្រាហ្មណ៍នោះឈ្មោះថាភារទ្វាជៈ ក៏ព្រោះគេសួរជដាបញ្ហា ព្រះសង្គីតិកាចារ្យទើបពោលយ៉ាងនោះ ។ ពាក្យដ៏សេស លោកពោលទុកហើយក្នុងទេវតាសំយុត្តនោះឯង ។*

ចប់អដ្ឋកថា ជដាសូត្រទី ៦

# អ ដ្ឋ ក ថា

## សុទ្ធិកសូត្រទី ៧

*ក្នុងសុទ្ធិកសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[១២៧]** *បទថា* ***សុទ្ធិកការទ្វាជោ*** *បានដល់ សូម្បីព្រាហ្មណ៍នេះ ក៏ឈ្មោះថា ការទ្វាជៈដូចគ្នា ព្រោះគេសួរសុទ្ធិកបញ្ហា ព្រះសង្គីតិកាចារ្យទើបពោលយ៉ាងនោះ ។*

**[១២៨]** *បទថា* ***សីលវាបិ តបោករំ*** *សេចក្តីថា សូម្បីគេសម្បូរណ៍ដោយសីល ក៏នៅតែបំពេញតបៈ ។ ក្នុងបទថា* ***វិជ្ជាចរណសម្បន្នោ*** *នេះ បទថា* ***វិជ្ជា*** *បានដល់ វេទ ៣ ។ បទថា* ***ចរណំ*** *បានដល់ ការប្រព្រឹត្តរបស់ត្រកូល ។*

**[១២៩]** *ដោយពាក្យថា* ***សោ សុជ្ឈតិ ន អញ្ញា ឥតរា បជា*** *លោកពោលថា ព្រាហ្មណ៍នោះបានវិជ្ជា ៣ រមែងបរិសុទ្ធិ តែពួកសត្វដែលរាប់ថាមិនមានសេចក្តីដឹង រមែងមិនបរិសុទ្ធិ ។ បទថា* ***ពហុម្បិ បលបំ ជប្បំ*** *សេចក្តីថា សូម្បីពោលពាក្យច្រើន អធិប្បាយថា ពោលសូម្បីទាំងពាន់ ពាក្យថា*

ព្រាហ្មណ៍ប៉ុណ្ណោះ បរិសុទ្ធិ ។ បទថា **អនោ្ដកសម្ពុ** សេចក្ដីថា ជាអ្នកស្អុយ ដោយសេចក្ដីស្អុយ គឺ កិលេសក្នុងខាងក្នុង ។ បទថា **សង្កិលិដ្ឋោ** សេចក្ដីថា ប្រកបដោយកាយកម្មជាដើមដែលសៅហ្មង ។

ចប់អដ្ឋកថា សុទ្ធិកសូត្រទី ៧

# អ ដ្ឋ ក ថា

## អគ្គិកសូត្រទី ៨

*អគ្គិកសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[១៣១]** *បទថា* ***អគ្គិកភារទ្វាជោ*** *បានដល់ សូម្បីព្រាហ្មណ៍នេះ ក៏ឈ្មោះថា ភារទ្វាជៈដូចគ្នា ក៏ព្រោះតែគេបម្រើភ្លើង ព្រះសង្គីតិកាចារ្យទើប តាំងឈ្មោះគេយ៉ាងនោះ ។ បទថា* ***សន្និហិតោ*** *បានដល់ ដែលគេផ្សំយ៉ាង ល្អ ។ បទថា* ***អដ្ឋាសិ*** *សេចក្តីថា ព្រោះហេតុអ្វី ទើបឈរក្នុងទីនោះ ។ បាន ឮមកថា ព្រះមានព្រះភាគទ្រង់ត្រួតមើលលោកក្នុងវេលាជិតភ្លឺ ទ្រង់ឃើញ ព្រាហ្មណ៍នេះ ទ្រង់ព្រះមានតម្រិះថា ព្រាហ្មណ៍នេះកាន់បាយបាយាសដ៏ប្រសើរ បែបនេះទៅដុតភ្លើង ដោយតាំងចិត្តនឹងឲ្យមហាព្រហ្មបរិភោគ រមែងធ្វើវត្ថុដែល គ្មានផល ឈានចុះកាន់ផ្លូវអបាយ កាលមិនលះបង់លទ្ធិនេះ ក៏នឹងធ្វើអបាយ ឲ្យពេញ បើដូច្នោះ តថាគតនឹងទៅទម្លាយទិដ្ឋិរបស់គេដោយធម៌ទេសនា ហើយ ឲ្យបព្វជ្ជា ញ៉ាំងមគ្គ ៤ ផល ៤ ដល់គេ ព្រោះដូច្នោះ ក្នុងវេលាព្រឹក ទើប ស្តេចចូលក្រុងរាជគ្រឹះ បានប្រថាប់ឈរក្នុងទីនោះ ។*

**[១៣១]** *បទថា **តីហិ វិជ្ជាហិ** បានដល់ ដោយវេទ ៣ ។ បទថា **ជាតិមា** សេចក្តីថា ប្រកបដោយជាតិដែលបរិសុទ្ធ ៧ តំណ ។ បទថា **សុត្វា ពហូ** សេចក្តីថា ស្តាប់គម្ពីរផ្សេងៗ ជាច្រើន ។ បទថា **សោមំ ភុញ្ជេយ្យ** សេចក្តីថា ព្រាហ្មណ៍ពោលថា ព្រាហ្មណ៍នោះបានវិជ្ជា ៣ គួរបរិភោគបាយ-បាយាសនេះ តែបាយបាយាសនេះ មិនគួរដល់ព្រះអង្គ ។*

**[១៣១]** *បទថា **វេទិ** សេចក្តីថា ដឹង គឺ ចាក់ធ្លុះដោយបុព្វេនិវាស-ញាណ ។ បទថា **សគ្គាបាយំ** បានដល់ ឃើញទាំងសួគ៌ទាំងអបាយ ដោយទិព្វចក្ខុ ។ បទថា **ជាតិក្ខយំ** បានដល់ ព្រះអរហត្ត ។ បទថា **អភិញ្ញាវោ-សិតោ** សេចក្តីថា អ្នកមានព្រហ្មចរិយៈនៅរួចហើយ ព្រោះដឹងក្រៃលែង ។ បទថា **ព្រាហ្មណោ ភវំ** សេចក្តីថា ព្រាហ្មណ៍ទីណាស្រេពអ្នកសម្បូរណ៍ដោយជាតិ ដូចព្រះគោតមដ៏ចម្រើននោះ តាំងពីអវិចី ដរាបដល់ភវគ្គព្រហ្មមិនមានព្រះអង្គដ៏ចម្រើននេះឯងជាព្រាហ្មណ៍ ។ ក៏គ្រាពោលយ៉ាងនេះហើយ ព្រាហ្មណ៍បានដាក់បាយបាយាសពេញថាសមាស ហើយបង្អោនចូលទៅថ្វាយព្រះទស-ពល ។*

**[១៣៥]** *ព្រះសាស្តាទ្រង់សម្តែងឧប្បត្តិហេតុ ទើបទ្រង់ហាមភោជនចេញ*

ទើបត្រាស់ពាក្យជាដើមថា **គាថាភិគីតំ មេ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **គាថាភិគីតំ** បានដល់ បានមកដោយការច្រៀង ។ បទថា **អភោជនេយ្យំ** បានដល់ មិនគួរបរិភោគ ។ លោកពោលអធិប្បាយទុកថា ព្រាហ្មណ៍ អ្នកមិនអាចឲ្យអាហារត្រឹមតែមួយវែកដល់តថាគត អ្នកតាំងនៅដោយកិច្ចាចារវត្តរហូតដល់អស់កាលប៉ុណ្ណេះ តែឥឡូវនេះ តថាគតប្រកាសព្រះពុទ្ធគុណទាំងពួងដល់អ្នកដូចអ្នកសាបព្រោះល្ងចុះលើកន្ទេលផែនដូច្នោះ ចំណែកភោជននេះ បានមកព្រោះដូចជាចម្រៀង ដូច្នោះ តថាគតមិនគួរបរិភោគភោជនដែលបានមកដោយការច្រៀងទេ ។ បទថា **សម្បស្សតំ ព្រាហ្មណ នេស ធម្មោ** សេចក្តីថា ព្រាហ្មណ៍ដែលពិចារណាឃើញអត្ថ និងធម៌ មិនមានទំនៀមនេះថា គួរបរិភោគភោជនបែបនេះ តែព្រះពុទ្ធទាំងឡាយ ទ្រង់រង្កៀសសុធាភោជនដែលបានមកដោយការច្រៀង គឺ ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងបន្ទោបង់នូវភោជនដែលបានមកព្រោះការច្រៀង ។ បទថា **ធម្មេ សតិ ព្រាហ្មណ វុត្តិ រេសា** សេចក្តីថា ព្រាហ្មណ៍ កាលធម៌មានហើយ កាលបុគ្គលពិចារណាធម៌ តាំងនៅក្នុងធម៌ ហើយចិញ្ចឹមជីវិត នេះជាការប្រព្រឹត្ត គឺ នេះជាការចិញ្ចឹមជីវិតថា គួរលះបង់ភោជនបែបនេះចេញ ហើយគួរបរិភោគភោជនដែលបានមកដោយធម៌

ប៉ុណ្ណោះ ។

លំដាប់នោះ ព្រាហ្មណ៍គិតថា កាលមុនយើងមិនដឹងដល់គុណ ឬទោស របស់ព្រះសមណគោតម តែឥឡូវនេះយើងដឹងគុណ ៥ របស់ព្រះសមណ-គោតមនោះហើយ ទើបប្រាថ្នានឹងដាក់គំនរទ្រព្យប្រមាណ ៨០ កោដិ ក្នុងផ្ទះរបស់យើងចុះក្នុងព្រះសាសនា ក៏ព្រះសមណគោតមនេះ នឹងត្រាស់ថា បច្ច័យដែលយើងថ្វាយជាអកប្បិយៈ ព្រះសមណគោតមគង់តែទ្រង់មិនតិះដៀលយើង លំដាប់នោះ ព្រះមានព្រះភាគទ្រង់បញ្ជូនព្រះសព្វញ្ញុតញ្ញាណពិចារណាវារចិត្ត របស់ព្រាហ្មណ៍នោះ ទ្រង់មានព្រះតម្រិះថា ព្រាហ្មណ៍នេះ កំណត់បច្ច័យដែលខ្ញុំនឲ្យស្មូម្បីទាំងអស់ថា ជាអកប្បិយៈ សេចក្តីពិត កថាកើតឡើងព្រោះប្រារព្ធភោជនណា ភោជននោះឯងមិនមាន កថាក្រៅពីនោះមិនមានទោស ដូច្នេះ កាលទ្រង់នឹងសម្តែងទ្វារនៃការថ្វាយបច្ច័យ ៤ ដល់ព្រាហ្មណ៍ ទើបត្រាស់ពាក្យមានជាដើមថា **អញ្ញេន ច** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **កុក្កុច្ចំ វូបសន្តំ** សេចក្តីថា ស្ងប់សេចក្តីរពឹសចេញបាន ដោយអំណាចការរពឹសដៃជាដើម ។ ពាក្យថា **អន្នេន បានេន** នេះ ត្រឹមតែជាទេសនា ។ ក៏សេចក្តីនេះ គប្បីជ្រាបដូចតទៅនេះ អ្នកចូរទំនុកបម្រុងដោយបច្ច័យដល់ពួកដទៃ មានចីវរជាដើម

ដែលអ្នកកំណត់ថា នឹងបរិច្ចាគ ប្រការនោះជាខេត្តរបស់អ្នកប្រាថ្នាបុណ្យ ។ ឈ្មោះថា ពាក្យទូន្មានរបស់ព្រះតថាគតនេះ ជាការញ៉ាំងអ្នកដែលប្រាថ្នាបុណ្យ គឺ ប្រាថ្នាបុណ្យដែលបានតាក់តែងហើយ ដូចពូជសូម្បីតិច តែសាបព្រោះចុះក្នុងស្រែល្អ រមែងឲ្យផលច្រើន ដូច្នេះឯង ។

ចប់អដ្ឋកថា អគ្គិកសូត្រទី ៨

# អ ដ្ឋ ក ថា

## សុន្ទរិកសូត្រទី ៩

សុន្ទរិកសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[១៣៧]** បទថា *សុន្ទរិកភារទ្វាជោ* បានដល់ អ្នកមានឈ្មោះយ៉ាងនោះ ព្រោះបូជាភ្លើងទៀបឆ្នេរស្ទឹងឈ្មោះថា *សុន្ទរិកា* ។ បទថា *សុន្ទរិកាយ* បានដល់ ស្ទឹងមានឈ្មោះយ៉ាងនោះ ។ បទថា *អគ្គឹ ជុហតិ* បានដល់ ឲ្យភ្លើងឆេះសន្ធោរឡើងដោយការដាក់របស់បូជា ។ បទថា *អគ្គិហុត្តំ* បានដល់ ចូលទៅកាន់រោងភ្លើងដោយការខាត់ពណ៌ បូកលាប និងពលីកម្មជាដើម ។ បទថា *កោនុខោ ឥមំ ហព្យសេសំ ភុញ្ជេយ្យ* សេចក្តីថា បានឮថា ព្រាហ្មណ៍នោះឃើញបាយបាយាសដែលសល់ពីការបូជាភ្លើងហើយ គិតថា បាយបាយាសដែលដាក់ចុះក្នុងភ្លើង ដែលមហាព្រហ្មបរិភោគមុនហើយ តែបាយបាយាសនេះនៅសល់ បើថា យើងគប្បីឲ្យបាយបាយាសនោះដល់ព្រាហ្មណ៍អ្នកកើតពីមាត់ព្រះព្រហ្ម បើដូច្នេះ សូម្បីបុត្រព្រមទាំងបិតា ក៏ជាអ្នកដែលយើងចិញ្ចឹមឲ្យឆ្អែតគ្រប់គ្រាន់ហើយ និងផ្លូវទៅព្រហ្មលោក ក៏យើងបានធ្វើឲ្យបរិសុទ្ធិល្អ

ហើយ ។ សុន្ទរិកភារទ្វាជព្រាហ្មណ៍នោះ ក្រោកចាកអាសនៈ ក្រឡេកមើលទិសទាំង ៤ ដោយជុំវិញ ដើម្បីនឹងមើលព្រាហ្មណ៍ ដោយគិតថា អ្នកណាហ្ន៎គួរបរិភោគបាយបាយាសដែលសល់ពីការបូជានេះ ។

[១៣៨] បទថា *រុក្ខមូលេ* សេចក្តីថា ត្រង់គល់ឈើធំក្នុងដងព្រៃនោះ ។ បទថា **សសីសំ បារុតំ និសិន្នំ** សេចក្តីថា ប្រថាប់គង់គ្របព្រះ-វរកាយ ព្រមទាំងព្រះសិរសា ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបប្រថាប់គង់ក្នុងទីនោះ ។ ឆ្លើយថា បានឮថា ព្រះមានព្រះភាគទ្រង់ត្រួតមើលលោកក្នុងវេលាជិតភ្លឺ ឃើញព្រាហ្មណ៍នេះហើយ ទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះ កាន់បាយបាយាសដ៏ប្រសើរបែបនេះយកទៅដុតភ្លើង ដោយតាំងចិត្តនឹងឲ្យមហាព្រហ្មបរិភោគ ឈ្មោះថា ធ្វើវត្ថុដែលគ្មានផល ។ល។ តថាគតនឹងញ៉ាំងមគ្គ ៤ ផល ៤ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបស្តេចតើនឡើងពីព្រឹកព្រលឹម ទ្រង់ជម្រះព្រះវរកាយស្រេចហើយ ទ្រង់ប្រដាប់បាត្រ និងចីវរស្តេចទៅប្រថាប់ត្រង់គល់ដើមឈើនោះ ដោយន័យដូចពោលហើយនុ៎ះឯង ។ សួរថា បើដូច្នោះ ហេតុអ្វី ព្រះអង្គទើបទ្រង់គ្របចីវរហូតដល់ព្រះសិរសា ។ ឆ្លើយថា ដើម្បីការពារសន្សើម និងខ្យល់ត្រជាក់ ។ ពះតថាគតទ្រង់អាចអត់

ទៅចំពោះសាទៀម និងខ្យល់ត្រជាក់នោះបាន តែបើមិនបាន ទ្រង់ត្រូវគង់គ្រប ព្រះវរកាយ ព្រាហ្មណ៍ចាំបានពីចម្ងាយក៏នឹងត្រឡប់មកវិញ ។ បើដូច្នេះ ក៏នឹង មិនបាននិយាយចចារ ដូច្នោះ ព្រះមានព្រះភាគមានព្រះតម្រិះថា កាលព្រាហ្មណ៍ មក តថាគតនឹងបើកសីសៈ ពេលនោះព្រាហ្មណ៍ក៏នឹងឃើញតថាគត នឹងបាន និយាយចចារ តថាគតនឹងសម្ដែងធម៌តាមការនិយាយចចារជាមួយព្រាហ្មណ៍ ដូច្នេះ ទើបបានទ្រង់ធ្វើយ៉ាងនោះ ដើម្បីនឹងបាននិយាយចចារ ។

បទថា **ឧបសង្កមិ** សេចក្ដីថា ព្រាហ្មណ៍គិតថា បុគ្គលនេះទទូរសីសៈ ប្រកបសេចក្ដីព្យាយាមមួយយប់ញុំាងអារុណឲ្យរះ យើងនឹងថ្វាយទក្ខិណោ-ទក ហើយថ្វាយបាយបាយាសដែលសល់ពីការបូជាភ្លើងនេះ ដល់បុគ្គលនេះ ដូច្នេះ ព្រាហ្មណ៍មានសេចក្ដីសម្គាល់ថា បុគ្គលនេះជាព្រាហ្មណ៍ ទើបចូលទៅ រក ។ បទថា **មុណ្ឌោ អយំ ភវំ មុណ្ឌកោ អយំ ភវំ** សេចក្ដីថា ពេល ព្រះមានព្រះភាគបើកព្រះសិរសា ព្រាហ្មណ៍ឃើញព្រះអង្គមានសក់ខ្លី ទើប ពោលថា បុគ្គលនេះជាព្រះសមណៈត្រងោល ។ កាលពិនិត្យមើល ដឹងច្បាស់ ក្រៃលែងជាងនោះ ក៏មិនបានឃើញសូម្បីចុងសក់ល្មមនឹងកម្រើកបាន ទើប ពោលតិះដៀលថា សមណៈត្រងោល ។ បទថា **តតោវ** បានដល់ ចាកប្រទេស

ដែលខ្លួនឈរឃើញនោះឯង ។ បទថា **មុណ្ឌាបិ ហិ** សេចក្ដីថា ដោយហេតុណាមួយ ព្រាហ្មណ៍មានសីសៈត្រងោលក៏មាន ។

**[១៣៩]** បទថា **មា ជាតឹ បុច្ឆ** សេចក្ដីថា បើលោកប្រាថ្នាថា ទានមានផលច្រើន ក៏កុំសួរដល់ជាតិឡើយ ។ ព្រោះជាតិមិនមែនជាហេតុនៃទក្ខិ-ណេយ្យបុគ្គល ។ បទថា **ចរណញ្ច បុច្ឆ** សេចក្ដីថា ម្យ៉ាងទៀត ចូរសួរដល់ការប្រព្រឹត្ត គឺ ប្រភេទនៃគុណ មានសីលជាដើម ។ ព្រោះប្រការនោះ ជាហេតុនៃភាពជាព្រះទក្ខិណេយ្យបុគ្គល ។ ឥឡូវនេះ កាលទ្រង់នឹងធ្វើសេចក្ដីនោះឲ្យជាក់ច្បាស់ដល់ព្រាហ្មណ៍នោះ ទើបត្រាស់ថា **កដ្ឋា ហវេ ជាយតិ ជាត-វេទោ** ជាដើម ។ ក្នុងសេចក្ដីនោះ មានអធិប្បាយដូចតទៅនេះ ៖

ក្នុងទីនេះ ភ្លើងរមែងកើតអំពីឈើ និងភ្លើងដែលកើតអំពីឈើ មានដើមសាលៈជាដើមនោះ មិនបានធ្វើនាទីរបស់ភ្លើង ភ្លើងដែលកើតពីឈើ មានទ្រទឹកផឹកជាដើម មិនបានធ្វើមុខនាទីរបស់ភ្លើង តែភ្លើងដែលកើតអំពីទីណាមួយក៏ដោយ រមែងធ្វើមុខនាទីរបស់ភ្លើងដោយគុណសម្បត្តិ មានអណ្ដាតរបស់ខ្លួនជាដើម ។ ដោយប្រការដូច្នេះ អ្នកដែលកើតក្នុងត្រកូលព្រាហ្មណ៍ជាដើម រមែងជាទក្ខិណេយ្យបុគ្គល តែអ្នកដែលកើតក្នុងត្រកូលចណ្ឌាលជាដើម ជា

ទក្ខិណេយ្យបុគ្គលមិនបាន ។ អ្នកដែលកើតក្នុងត្រកូលទាបក៏ដោយ អ្នកដែលកើតក្នុងត្រកូលខ្ពស់ក៏ដោយ ជាមុនីអ្នកមានអាសវៈអស់ហើយ មានសេចក្ដីព្យាយាម កម្ចាត់ទោសដោយហិរិ ជាអ្នកដឹងទូទៅដល់ហេតុ រមែងជាអ្នកមានជាតិ គឺ ជាទក្ខិណេយ្យបុគ្គលដ៏ខ្ពង់ខ្ពស់បំផុត ដោយគុណសម្បត្តិ ដែលមានសេចក្ដីព្យាយាម និងហិរិជាប្រធាននេះ ។ ព្រោះថា គេរមែងទ្រទ្រង់ទុកនូវគុណទាំងឡាយដោយសេចក្ដីព្យាយាម រមែងកម្ចាត់បង់នូវទោសទាំងឡាយដោយហិរិ ។ម្យ៉ាងទៀត បទថា **មុនិ** ក្នុងទីនេះ បានដល់ អ្នកប្រកបដោយមោនធម៌ (គឺជាអ្នកមានបញ្ញា) ។ បទថា **ធិតិមា** បានដល់ មានសេចក្ដីព្យាយាម ។ បទថា **អាជានីយោ** បានដល់ ដឹងដល់ហេតុ ។ បទថា **ហិរិនិសេធោ** បានដល់ ហាមឃាត់នូវបាបដោយហិរិ ។ បទថា **សច្ចេន ទន្តោ** បានដល់ ទូន្មានខ្លួនដោយបរមត្ថសច្ចៈ ។ បទថា **ទមសា ឧបេតោ** បានដល់ ចូលដល់ដោយការទូន្មានឥន្ទ្រិយ ។ បទថា **វេទន្តគូ** សេចក្ដីថា ដល់ទីបំផុតនៃវេទ គឺ មគ្គ ៤ ឬដល់ទីបំផុតនៃកិលេសដោយវេទ គឺ មគ្គ ៤ ។ បទថា **វុសិតព្រហ្មចរិយោ** បានដល់ មានព្រហ្មចរិយៈនៅចប់ហើយ ។ បទថា **យញ្ញូបនីតោ** បានដល់ នាំទៅនូវយញ្ញ ឬចាត់ចែងយញ្ញ ។ បទថា **តមុបវ្ហយេថ**

សេចក្តីថា អ្នកដែលចាត់ចែងយញ្ញនោះ ឈ្មោះថា បូជាព្រាហ្មណ៍នោះ គឺ ព្រាហ្មណ៍ដោយបរមត្ថ ។ ក៏ពាក្យថា ខ្ញុំហៅ គឺ ហៅព្រះឥន្ទ ហៅព្រះសោមៈ ហៅព្រះវរុណ ហៅព្រះឦសានៈ ជាពាក្យហៅដែលគ្មានប្រយោជន៍ ។ បទថា **កាលេន** សេចក្តីថា ព្រាហ្មណ៍កាលសម្តែងការបូជា គប្បីបូជាព្រាហ្មណ៍នោះ ពេលថ្ងៃត្រង់តែប៉ុណ្ណោះ ដោយពាក្យថា ដល់វេលាហើយលោកម្ចាស់ កត្តាហារសម្រេចហើយ ។ បទថា **សោ ជុហតិ ទក្ខិណេយ្យេ** សេចក្តីថា អ្នកណានិមន្តព្រះខីណាស្រពមក ថ្វាយទក្ខិណា គឺ បច្ច័យបួនក្នុងព្រះខីណាស្រពនោះ អ្នកនោះឈ្មោះថា បូជាព្រះទក្ខិណេយ្យបុគ្គលតាមកាល ដោយប្រការដូច្នេះ មិនមែនដាក់ចូលក្នុងភ្លើងដែលមិនមានចិត្ត ។

**[១៤០]** ព្រាហ្មណ៍ ស្តាប់ព្រះតម្រាស់របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ជ្រះថ្លាហើយ ឥឡូវនេះ កាលនឹងធ្វើសេចក្តីជ្រះថ្លារបស់ខ្លួនឲ្យជាក់ច្បាស់ ទើបក្រាបទូលថា **អទ្ធា សុយិដ្ឋំ** ជាដើម ។ ប្រការនោះ មានសេចក្តីដូចតទៅនេះ ៖

ការបូជារបស់ខ្ញុំព្រះអង្គនេះ ឥឡូវនេះនឹងជាការបូជាដោយល្អ សែនប្តូងសួងដោយល្អពិតប្រាកដ តែកាលមុន ខ្ញុំព្រះអង្គយកដុតភ្លើងជាវត្ថុដែល

គ្មានប្រយោជន៍ ។ បទថា **អញ្ញោ ជនោ** បានដល់ បុថុជ្ជនអន្ធពាល និយាយថា យើងជាព្រាហ្មណ៍ យើងជាព្រាហ្មណ៍ ។ បទថា **ហព្យសេសំ** បានដល់ នៅសល់ពីការបូជា ។ ពាក្យថា **កុញ្ចតុ ករំ** ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយក្នុងអសុរតមុន ។

**[១៤២]** បទថា **ន ខ្វាហំ** កាត់បទជា **ន ខោ អហំ** ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។ ឆ្លើយថា បានឮមកថា វេលាដែលព្រាហ្មណ៍បង្អោនភោជននោះចូលទៅប៉ុណ្ណោះ ទេវតាក្នុងទ្វីបធំ ៤ ទ្វីបតូច ២.០០០ កាន់យកផ្កាឈើ ផ្លែឈើ និងទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើម ដោយសម្គាល់ថា ព្រះសាស្តានឹងសោយ ទើបកាន់យកឱជៈដែលឲ្យកើតនូវអានុភាពដែលជាទិព្វដាក់ចូល ដូចច្របាច់ក្បាលទឹកហើយកាន់យកទឹកឃ្មុំ ។ ព្រោះដូច្នោះ ភោជននោះទើបដល់ភាពជារបស់ប្រណីតដ៏សុខុម ។ ក៏ភោជននោះ ជាវត្ថុគ្រោតគ្រាតសម្រាប់មនុស្ស ដូច្នោះ ទើបមិនដល់ភាពរលួយទៅដោយល្អសម្រាប់មនុស្សទាំងនោះ ព្រោះជាវត្ថុគ្រោតគ្រាតទុំះឯង ។ តែផ្សំពូជ ៣ យ៉ាង ចុះក្នុងទឹកដោះគោ ភោជននោះទើបក្លាយជាភោជនលាយដោយរបស់គ្រោតគ្រាត ។ មួយទៀត ភោជននោះ ជាវត្ថុល្អិត

សុខុមសម្រាប់ពួកទេវតា ព្រោះដូច្នោះ ទើបមិនដល់ការល្អយទៅដោយល្អ សម្រាប់ទេវតាពួកនោះ ព្រោះជាវត្ថុល្អិតសុខុម ។ សូម្បីក្នុងផ្ទៃរបស់ព្រះខីណាស្រពដែលជាសុក្ខវិបស្សក: ក៏មិនរលួយទៅ ។ តែព្រះខីណាស្រពអ្នកបានសមាបត្តិ ៨ គប្បីរលួយដោយអំណាចសមាបត្តិ ។ តែសម្រាប់ព្រះមានព្រះភាគ គប្បីរលួយទៅដោយតេជោធាតុកើតពីកម្មតាមប្រក្រតីតែម្យ៉ាង ។

បទថា **អប្បហរិតេ** ប្រែថា ប្រាសចាករបស់ខៀវ ។ ប្រសិនបើគប្បីចាក់ចុះលើស្មៅស្រស់ ស្មៅទាំងឡាយក៏នឹងគប្បីរលួយដោយបាយបាយាសដែលល្អិតសុខុម ធម្មតាព្រះពុទ្ធទាំងឡាយ រមែងមិនកន្ទងកួតគាមសិក្ខាបទ ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនេះ ។ តែគួរចាក់ក្នុងទីមានស្មៅដើមធំៗ កម្ពស់ប្រមាណត្រាន់តែក ។

បទថា **អប្បាណកេ** សេចក្ដីថា ព្រោះថា កាលចាក់ចុះក្នុងទឹកតិចដែលមានសត្វ សត្វក៏នឹងស្លាប់ ព្រោះទឹកនោះ ទើបត្រាស់យ៉ាងនោះ តែទីណាមានទឹកជ្រៅ សូម្បីកាលដាក់ទាំង ១០០ ថាស ១,០០០ ថាស ទឹករមែងមិនល្អក់ គួរចាក់ក្នុងទឹកដូច្នោះ ។ បទថា **ឱបិលាបេសិ** សេចក្ដីថា ឲ្យលិចចុះព្រមទាំងថាសមាស ។

[១៨៣] បទថា **វិចិជាយតិ វិជិចិជាយតិ** សេចក្តីថា រមែងធ្វើសំឡេងយ៉ាងនោះ ។ សួរថា ក៏សំឡេងនោះជាអានុភាពរបស់បាយបាយាស ឬជាអានុភាពរបស់ព្រះតថាគត ។ ឆ្លើយថា ជាអានុភាពរបស់ព្រះតថាគត ។ ក៏ព្រាហ្មណ៍នេះឲ្យបាយបាយាសលិចចុះហើយ ក៏នឹងដើរក្រៅផ្លូវ មិនមកកាន់សម្នាក់ព្រះសាស្តាឡើយ ។

លំដាប់នោះ ព្រះមានព្រះភាគមានព្រះតម្រិះថា ព្រាហ្មណ៍ឃើញការអស្ចារ្យនេះហើយ នឹងមកកាន់សម្នាក់របស់តថាគត បើដូច្នោះ តថាគតនឹងទម្លាយមិច្ឆាទិដ្ឋិរបស់គេដោយព្រះធម៌ទេសនា ឲ្យចុះកាន់ក្នុងព្រះសាសនា ឲ្យផឹកទឹកអម្រឹត ដូច្នេះ ទើបទ្រង់ធ្វើយ៉ាងនោះ ដោយកម្លាំងអធិដ្ឋាន ។

[១៨៤] បទថា **ទារុសមាទហានោ** បានដល់ ដុតឧស ។ បទថា **ពហិទ្ធា ហិ ឯតំ** សេចក្តីថា ឈ្មោះថា ការដុតឧសនេះ មាននៅតែខាងក្រៅអរិយធម៌ ប្រសិនបើសេចក្តីបរិសុទ្ធិគប្បីមានដោយការដុតឧសនេះ អ្នកដុតព្រៃជាដើម ដុតឧសជាច្រើន ក៏នឹងដល់ភាពបរិសុទ្ធិមុនគេ ។ បទថា **កុសលា** បានដល់ អ្នកឆ្លាតក្នុងខន្ធជាដើម ។ បទថា **អជ្ឈត្តមេវ ជលយាមិជោតឹ** សេចក្តីថា យើងនឹងញ៉ាំងភ្លើង គឺ ញាណឲ្យឆេះខាងក្នុងខ្លួន គឺ ក្នុងសន្តានរបស់ខ្លួន ។

បទថា **និច្ចគ្គិនី** បានដល់ មានភ្លើងឆេះជានិច្ច ដោយសព្វញ្ញុតញ្ញាណ ដែលជាប់ដោយអាវជ្ជនចិត្ត ។ បទថា **និច្ចសមាហិតត្តោ** បានដល់ អ្នកមានចិត្តតាំងមាំដោយប្រពៃជានិច្ច ។ បទថា **ព្រហ្មចរិយំ ចរាមិ** បានដល់ ព្រះអង្គទ្រង់កាន់ព្រហ្មចរិយៈដែលទ្រង់ប្រព្រឹត្តត្រង់ពោធិមណ្ឌលស្ថាន ទើបត្រាស់យ៉ាងនេះ ។

បទថា **មានោ ហិ តេ ព្រាហ្មណ ខារិភារោ** សេចក្តីថា ភារៈ គឺអម្រែកដែលបុគ្គលនាំទៅដោយ.កសូម្បីនៅខាងលើ ក៏រមែងពាល់ត្រូវនឹងផែនដីក្នុងទីដែលជាន់ទៅ យ៉ាងណា មានះដែលលើកឡើងព្រោះអាស្រ័យវត្ថុដែលប្រកាន់ មានជាតិ គោត្រ ត្រកូលជាដើម ដូច្នោះ កាលញុំាងសេចក្តីឫស្យាឲ្យកើតឡើង រមែងឲ្យលិចចុះក្នុងអបាយ ៤ ។ ដោយហេតុនោះ ព្រះមាន-ព្រះភាគទើបត្រាស់ថា ព្រាហ្មណ៍ ក៏មានះរបស់អ្នកដូចជាអម្រែកដ៏ធ្ងន់ ។ បទថា **កោធោ ធូមោ** សេចក្តីថា សេចក្តីក្រោធ ឈ្មោះថា ដូចជាផ្សែងភ្លើង ព្រោះអត្ថថា ជាសេចក្តីសៅហ្មងនៃភ្លើង គឺ ញាណរបស់អ្នក ។ ព្រោះហេតុនោះឯង ភ្លើង គឺ ញាណដែលសៅហ្មងរបស់អ្នក ទើបមិនរុងរឿង ។ ដោយបទថា **ភស្មនិម្មោសវជ្ជំ** លោកសម្តែងថា **មុសាវាទ** ឈ្មោះថា ផេះ ។ ព្រោះអត្ថ

ថា ប្រាសចាករស ។ លោកអធិប្បាយថា ដូចជា ភ្លើងដែលផេះបិទបាំងរមែង មិនរុងរឿង យ៉ាងណា ញាណរបស់អ្នកដែលមុសាវាទបិទបាំង ក៏ដូច្នោះ ។ ដោយពាក្យថា **ជិវ្ហា សុជា** លោកពោលថា អ្នកមានវែកដែលធ្វើដោយមាស ប្រាក់ លោហៈ ឈើ និងដីយ៉ាងណាមួយ ទុកដើម្បីបូជាយញ្ញ យ៉ាងណា តថាគតមានអណ្តាតជំដូចជាវែកដែលសម្រាប់បូជា ដើម្បីប្រយោជន៍ដល់ការ បូជាធម៌ ដូច្នោះ ។ បទថា **ហទយំ ជោតិដ្ឋានំ** សេចក្តីថា ហទយៈរបស់សត្វ ទាំងឡាយ ដូចជាទីតាំងនៃភ្លើង ដោយអត្ថថា ជាទីតាំងនៃការបូជាធម៌របស់ តថាគត ដូចហទយៈរបស់អ្នក ជាទីតាំងនៃគំនរភ្លើងត្រង់ប្រាំងនៃស្ទឹង ។ បទថា **អត្តា** បានដល់ ចិត្ត ។

បទថា **ធម្មោ រហទោ** សេចក្តីថា អ្នកបម្រើភ្លើងមានរាងកាយប្រលាក់ ដោយផ្សែង កម្ទេចផេះ និងញើស ចុះងូតទឹកក្នុងស្ទឹងសុន្ទរិកា យ៉ាងណា តថាគតមិនត្រូវការដោយអន្លង់ទឹកខាងក្រៅដូចស្ទឹងសុន្ទរិកា តែតថាគតមានធម៌ គឺ មគ្គមានអង្គ ៨ ជាអន្លង់ទឹក តថាគតឲ្យសត្វមួយរយខ្លះ មួយពាន់ខ្លះ ប្រាំ-បីម៉ឺនបួនពាន់ខ្លះ ឲ្យងូតក្នុងធម៌ គឺ មគ្គមានអង្គ ៨ នោះព្រមៗ គ្នា ដូច្នោះ ។ ដោយបទថា **សីលតិត្ថោ** លោកសម្តែងថា ចតុប្បារិសុទ្ធិសីល ជាកំពង់នៃ

អន្លង់ទឹក គឺ ធម៌របស់តថាគតនោះ ។ បទថា **អនាវិលោ** សេចក្តីថា ស្អឹង សុន្ទរិការបស់អ្នក កាលមនុស្ស ៤-៥ នាក់ងូតព្រមគ្នា ធ្វើឲ្យមានខ្សាច់ទាំងខាងក្រោមទាំងខាងលើកករល្អក់ យ៉ាងណា អន្លង់ទឹករបស់តថាគតមិនដូច្នោះទេ សូម្បីកាលសត្វច្រើនពាន់ចុះទៅងូតអន្លង់ទឹកនោះ ក៏មិនកករល្អក់ គង់នៅថ្លា ។ បទថា **សព្ភិ សតំ បសដ្ឋោ** សេចក្តីថា ធម៌របស់បណ្ឌិតទាំងឡាយដែលពួកបណ្ឌិតសរសើរ ។ ម្យ៉ាងទៀត ធម៌នោះរបស់សប្បុរសទាំងឡាយលោកហៅថា **សព្ភិ** ព្រោះអត្ថថា ខ្ពស់បំផុត លោកហៅថា **បសដ្ឋ** ព្រោះបណ្ឌិតសរសើរ ។ បទថា **តរន្តិ បារំ** បានដល់ ត្រើយ គឺ ព្រះនិព្វាន ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់លើកអង្គនៃអន្លង់ទឹក គឺ អរិយមគ្គឡើងសម្តែង ទើបត្រាស់ពាក្យថា **សច្ចំ ធម្មោ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **សច្ចំ** បានដល់ វចីសច្ចៈ ។ ដោយបទថា **ធម្មោ** នេះ ទ្រង់សម្តែង សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ ដោយបទថា **សំយមោ** នេះ ទ្រង់សំដៅយកសម្មាកម្មន្តៈ និងសម្មាអាជីវៈ ។ ម្យ៉ាងទៀត ដោយបទថា **សច្ចំ** នេះ ទ្រង់សំដៅយកមគ្គសច្ចៈ ។ **ធម្មោ** គឺ មគ្គសច្ចៈនោះ ដោយអត្ថ បានដល់ សម្មាទិដ្ឋិ ។ សមពិតដូចពាក្យដែលត្រាស់

ទុកថា សម្មាទិដ្ឋិ ទាំងជាតួមគ្គ ទាំងជាតួហេតុ , តែកាលសំដៅយកសម្មាទិដ្ឋិ ក៏ទ្រង់សំដៅយកសម្មាសង្កប្បៈដូចគ្នា ព្រោះមានគតិដូចសម្មាទិដ្ឋិនោះ ។ ដោយបទថា **ធម្មោ** នេះ ទ្រង់សំដៅយកសម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ ។ ដោយបទថា **សំយមោ** នេះ ទ្រង់សំដៅយកសម្មាវាចា សម្មាកម្មន្តៈ និងសម្មា-អាជីវៈ រួមសេចក្តីថា ទ្រង់សម្តែងមគ្គមានអង្គ ៨ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត បទថា **សច្ចំ** បានដល់ បរមត្ថសច្ចៈ ។ បរមត្ថសច្ចៈនោះ ដោយអត្ថបានដល់ ព្រះនិព្វាន ។ ដោយបទថា **ធម្មោ** លោកសំដៅយកអង្គ ៥ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ ដោយបទថា **សំយមោ** សំដៅយកអង្គ ៣ គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ រមែងជាការដែលលោកសម្តែងមគ្គមានអង្គ ៨ សូម្បីដោយប្រការដូច្នេះ ។ បទថា **ព្រហ្មចរិយំ** នេះ ក៏គឺ ឈ្មោះថា ព្រហ្មចរិយៈ ។ បទថា **មជ្ឈេ សិតា** បានដល់ វៀរសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ គឺ នៅត្រង់កណ្តាល ។ បទថា **ព្រហ្មបត្តិ** បានដល់ ដល់ភាពជាអ្នកប្រសើរ ។ **ត** អក្សរ ក្នុងពាក្យថា **សតុ-ជ្ជុភូតេសុ នមោ ករោហិ** នេះ ធ្វើជាបទសន្ធិ ។ អធិប្បាយថា បុគ្គលនោះចូរធ្វើការនមស្ការក្នុងព្រះខីណាស្រពទាំងឡាយជាបុគ្គលត្រង់ ។ បទថា **តមហំ**

នរំ ធម្មសារីតិ ព្រូមិ សេចក្ដីថា តថាគតហៅបុគ្គលដែលបដិបត្តិយ៉ាងនេះថា បុគ្គលនេះជាធម្មសារី និងថា បុគ្គលនេះ បដិបត្តិដើម្បីធម្មសារី ឬថា បុគ្គលនេះលះបង់អកុសលធម៌ដោយកុសលធម៌ ហើយតាំងនៅ ដូច្នេះ ។

ចប់អដ្ឋកថា សុន្ទរិកសូត្រ ទី ៩

# អ ដ្ឋ ក ថា

## ពហុធិតិសុត្រទី ១០

ពហុធិតិសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[១៤៦]** បទថា **អញ្ញតរស្មឹ វនសណ្ឌេ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ត្រួតមើលសត្វលោកក្នុងវេលាជិតភ្លឺ ទ្រង់ឃើញធម៌ដែលជាឧបនិស្ស័យព្រះអរហត្តរបស់ព្រាហ្មណ៍នោះ ទ្រង់មានព្រះតម្រិះថា តថាគតនឹងទៅសង្គ្រោះព្រាហ្មណ៍ ទើបស្តេចទៅប្រថាប់នៅក្នុងព្រៃស្រោងនោះ ។

**[១៤៧]** បទថា **បល្លង្កំ** បានដល់ ប្រថាប់ចម្រើនសមាធិ ។ បទថា **អាភុជិត្វា** បានដល់ ចងទុក ។ បទថា **ឧជុំ កាយំ បណិធាយ** សេចក្តីថា តាំងកាយខាងលើឲ្យត្រង់ ឲ្យចុងឆ្អឹងខ្នង ១៨ កង់ទល់គ្នា ។ បទថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** សេចក្តីថា តាំងសតិឆ្ពោះព្រះកម្មដ្ឋាន ឬធ្វើព្រះកម្មដ្ឋានទុកចំពោះមុខ ។ ដោយហេតុនោះឯង លោកពោលទុកក្នុងគម្ពីរវិភង្គថា សតិនេះប្រាកដហើយ តាំងនៅដោយល្អហើយត្រង់ចុងច្រមុះ ឬត្រង់មុខ ហេតុនោះលោកទើបពោលថា តាំងសតិចំពោះព្រះភ័ក្ត្រ ។

បទថា **បរិ** បានដល់ ការកាន់យក ។ បទថា **មុខំ** បានដល់ នាំចេញ ។ បទថា **សតិ** បានដល់ ចូលទៅតាំងទុក ។ ក៏ក្នុងសេចក្ដីនេះ គប្បីឃើញសេចក្ដីតាមន័យដែលពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គថា **តេន វុច្ចតិ បរិមុខំ សតឹ** ហេតុនោះ លោកទើបពោលថា តាំងសតិត្ពោះមុខទៅរកកម្មដ្ឋាន ដូច្នេះ ។ ក្នុងសេចក្ដីនោះ មានសេចក្ដីសង្ខេបដូច្នេះថា ធ្វើសតិកំណត់ធម៌ជាគ្រឿងនាំចេញចាកទុក្ខ ។ ក៏កាលប្រថាប់យ៉ាងនេះ បានប្រថាប់បញ្ចេញព្រះរស្មីដែលមានពន្លឺដ៏ក្រៃលែងទាំង ៦ ពណ៌ ។ បទថា **នដ្ឋា ហោន្តិ** សេចក្ដីថា គោដែលព្រាហ្មណ៍ប្រើភ្ជួរស្រែហើយ ព្រលែងឲ្យត្រាច់ទៅមាត់ព្រៃ គោបានចៀសទៅកាលដែលព្រាហ្មណ៍ទៅបរិភោគអាហារ ។ បទថា **ឧបសង្កមិ** សេចក្ដីថា ព្រាហ្មណ៍មានសេចក្ដីទោមនស្សគ្របសង្កត់ត្រាច់ទៅ គិតថា ព្រះសមណគោ-តមនេះ ប្រថាប់គង់ជាសុខហ្ន៎ ដូច្នេះ ទើបចូលទៅគាល់ ។ បទថា **អជ្ជ សដ្ឋឹ នទិស្សន្តិ** សេចក្ដីថា បាត់ទៅប្រមាណ ៦០ ថ្ងៃនឹងថ្ងៃនេះ ។ បទថា **បាបិកា** បានដល់ ដើមល្ងដែលខូច ។ បានឮថា កាលព្រាហ្មណ៍នោះ សាបព្រោះល្ងក្នុងចំការ ភ្លៀងបានធ្លាក់ចុះក្នុងថ្ងៃនោះឯង ធ្វើគ្រាប់ល្ងឲ្យលិចចុះក្នុងដី មិនអាចមានផ្កាផ្លែបាន ។ ចំណែកដើមដែលចម្រើនល្អ ក៏មានសត្វតូចៗ ហើរមក

ស៊ីស្លឹកជាដើមអស់ សល់តែដើម និងស្លឹកមួយពីរ ។ ព្រាហ្មណ៍ទៅមើលចំការ ឃើញដូច្នោះ ទើបគិតថា យើងដាំល្ងក៏ដើម្បីប្រាថ្នាផល តែល្ងទាំងនោះខូចហើយ ព្រាហ្មណ៍ក៏កើតទោមនស្ស គេកាន់យករឿងនោះទើបពោលគាថានេះ ។

បទថា **ឧស្សោឡ្ហិកាយ** សេចក្តីថា កណ្តុរទាំងឡាយលើកត្រចៀកលើកកន្ទុយជាដើម លោតលេងយ៉ាងសប្បាយដោយឧស្សាហ៍ បានឮថា ព្រាហ្មណ៍នោះ កាលគោគៈវិនាសអស់ជាលំដាប់ ជង្រុកក៏នៅទទេ ព្រោះមិនមានវត្ថុដែលនឹងគប្បីទុកដាក់ ។ កណ្តុរទាំងឡាយមកផ្លូវឯណោះផ្លូវឯណោះអំពី ៧ ជុំបូលផ្ទះ ចូលទៅក្នុងជង្រុកទទេរបស់ព្រាហ្មណ៍នោះ លោតលេង ដូចលេងកីឡាក្នុងសួន គេកំណត់រឿងនោះ ទើបពោលយ៉ាងនេះ ។

បទថា **ឧប្បាទកេហិ សញ្ឆន្នោ** សេចក្តីថា ដេរដាស់ទៅដោយសត្វតូចៗ ដែលកើតឡើង ។ បានឮថា កម្រាលដែលធ្វើដោយស្មៅ និងស្លឹកឈើ ដែលក្រាលទុកឲ្យព្រាហ្មណ៍នោះដេក មិនមានអ្នកណាៗ បោសសំអាតម្តងឡើយ ។ ព្រាហ្មណ៍ធ្វើការងារក្នុងព្រៃពេញមួយថ្ងៃ មកក្នុងវេលាល្ងាច ដេកលើកម្រាលនោះ ។ លំដាប់នោះ សត្វតូចៗ ដែលកើតក្នុងទីនោះ រមែងចោះស៊ីសរីរៈរបស់ព្រាហ្មណ៍នោះពេញទាំងអស់ គេកាន់យករឿងនោះ ទើបពោលយ៉ាងនេះ ។

បទថា **វិធវា** បានដល់ ស្ត្រីដែលមានស្វាមីស្លាប់ ។ បានឮថា ស្ត្រីទាំងឡាយ សូម្បីមេម៉ាយ ក៏អាចនៅក្នុងត្រកូលស្វាមីក្នុងវេលាដែលនៅមានសម្បត្តិនៅក្នុងផ្ទះរបស់ព្រាហ្មណ៍នោះ តែកាលណាគេគ្មានទ្រព្យ កាលនោះស្រីទាំងឡាយដែលត្រូវម្តាយក្មេកឪពុកក្មេកជាដើមបណ្តេញថា ចូរនាងទៅផ្ទះបិតា ដូច្នេះ ស្ត្រីទាំងនោះរមែងមកនៅក្នុងផ្ទះរបស់ព្រាហ្មណ៍នោះឯង ។ ក្នុងវេលាព្រាហ្មណ៍បរិភោគ ជនពួកណាបញ្ជូនបុត្រទៅថា ពួកឯងចូរទៅបរិភោគរួមជាមួយនឹងជីតា កាលជនទាំងនោះលូកដៃចុះក្នុងថាស ព្រាហ្មណ៍ណាមិនបានឱកាសនឹងប្រើដៃ (ចាប់អាហារ) គេសំដៅដល់ព្រាហ្មណ៍នោះ ទើបពោលគាថានេះ ។

បទថា **បិង្គលា** បានដល់ ស្រមោចខ្មៅ ស្រមោចក្រហម ស្រមោចលឿង ។ បទថា **តិលកាហតា** បានដល់ មានខ្លួនអុចៗ មានពណ៌ខ្មៅ និងសជាដើម ។ បទថា **សោត្តំ បាទេន បោថេតិ** បានដល់ ប្រើជើងវាឡើងលើអ្នកដេកលក់ឲ្យភ្ញាក់ ។ បានឮថា ព្រាហ្មណ៍នេះ ត្រូវបានរំខានដោយសំឡេងកណ្តុរ និងត្រូវសត្វតូចៗ ខាំ មិនបានដេកលក់រហូតដល់អស់មួយយប់ មកដេកលក់ក្នុងកាលជិតភ្លឺ លំដាប់នោះ ពេលព្រាហ្មណ៍បើកភ្នែកឡើងប៉ុណ្ណោះ ម្ចាស់

បំណុលម្នាក់ក៏ពោលនឹងព្រាហ្មណ៍នោះថា នឹងធ្វើយ៉ាងណាព្រាហ្មណ៍ បំណុលដែលលោកខ្ចីក្នុងពេលក្រោយ និងពេលមុន ការប្រាក់កើនឡើង លោកនឹងត្រូវចិញ្ចឹមធីតា ៧ នាក់ ឥឡូវនេះ ពួកម្ចាស់បំណុលមកលោមព័ទ្ធផ្ទះ លោកចូរទៅធ្វើការងារ ដូច្នេះ ហើយប្រើជើងរំខានឲ្យភ្ញាក់ គេសំដៅយករឿងនោះ ទើបពោលគាថានេះ ។

បទថា **ឥណាយិកា** បានដល់ អ្នកមានរបស់ឲ្យគេខ្ចីអំពីដៃ ។ បានពួថា ព្រាហ្មណ៍នោះ ខ្ចីអំពីដៃអ្នកខ្លះ ១ កហាបណៈ អ្នកខ្លះ ២ កហាបណៈ អ្នកខ្លះ ១០ កហាបណៈ អ្នកខ្លះ ១០០ កហាបណៈ រួមសេចក្តីថា ព្រាហ្មណ៍បានខ្ចីបំណុលអំពីដៃមនុស្សច្រើនអ្នក ។ ម្ចាស់បំណុលទាំងនោះ កាលមិនឃើញព្រាហ្មណ៍ពេលថ្ងៃ គិតនឹងចាប់គេដែលកំពុងចេញចាកផ្ទះ ទើបទៅទារពេលជិតភ្លឺ ព្រាហ្មណ៍សំដៅយករឿងនោះ ទើបពោលគាថានេះ ។

**[១៤៩]** ព្រះមានព្រះភាគ កាលព្រាហ្មណ៍នោះ ពណ៌នាសេចក្តីទុក្ខដោយគាថា ៧ គាថានេះ កាលនឹងទ្រង់សម្តែងថា ម្នាលព្រាហ្មណ៍ ទុក្ខដែលអ្នកពណ៌នាមកទាំងអស់នោះ មិនមានដល់តថាគត ទើបត្រាស់ព្រះគាថាតបនឹងព្រាហ្មណ៍ ពង្រីកព្រះធម៌ទេសនា ។ ដើម្បីនឹងសម្តែងថា ព្រាហ្មណ៍ស្តាប់

ព្រះគាថាទាំងនោះ ជ្រះថ្លាក្នុងព្រះមានព្រះភាគ តាំងនៅក្នុងសរណៈ ៣ បួស ហើយ សម្រេចព្រះអរហត្ត ។ ទើបត្រាស់ព្រះតម្រាស់ថា **ឯវំ វុត្តេ** ការទូលជា ជាដើម ។ បណ្ដាបទទាំងនោះ បទថា **អលត្ថ** ប្រែថា បានហើយ ។

ព្រះមានព្រះភាគ ឲ្យព្រាហ្មណ៍នោះបួសហើយ នាំទៅកាន់វត្តជេតពន ក្នុងថ្ងៃស្អែកមានព្រះថេរៈនោះជាបច្ឆាសមណៈ ស្ដេចបានទៅកាន់ទ្វារព្រះរាជវាំង របស់ព្រះបាទកោសល ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ថា ព្រះសាស្ដាស្ដេច យាងមក ទើបស្ដេចចុះអំពីប្រាសាទថ្វាយបង្គំ ហើយទ្រង់ទទួលបាត្រពីព្រះហស្ត អារាធនាព្រះតថាគតឲ្យស្ដេចឡើងលើប្រាសាទ ឲ្យប្រថាប់លើព្រះទែន ទ្រង់ លាងព្រះយុគលបាទដោយទឹកក្រអូប លាបដោយប្រេងដែលស្ងួរយដង ឲ្យនាំ បាយយាគូមក ទ្រង់កាន់វែកមាសដងប្រាក់ ទ្រង់បង្អោនចូលទៅថ្វាយព្រះសាស្ដា ។ ព្រះសាស្ដាទ្រង់យកព្រះហស្តបិទ ។ ព្រះរាជាទ្រង់ក្រាបចុះទៀបព្រះយុគល-បាទរបស់ព្រះតថាគតក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គមាន ទោស សូមព្រះអង្គមេត្តាអត់ទោស ។ ព្រះសាស្ដាត្រាស់ថា មិនមានទោស ទេ មហាបពិត្រ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ ព្រោះហេតុអ្វីព្រះអង្គមិន ទទួលបាយយាគូ ។ បលិពោធសេចក្ដីកង្វល់ មានហើយមហាបពិត្រ ។ បពិត្រ

ព្រះអង្គដ៏ចម្រើន ក៏ហេតុអ្វីហ្ន៎ បុគ្គលមិនទទួលបាយយាគូ គប្បីបានបលិពោធ ខ្ញុំព្រះអង្គអាចធ្វើបលិពោធឬ សូមព្រះអង្គមេត្តាទទួលបាយយាគូចុះ ។ ព្រះសាស្តាទ្រង់ទទួលហើយ ។ សូម្បីព្រះថេរៈដែលស្រេកឃ្លានមកយូរ ទើបធាន់បបរតាមសេចក្តីត្រូវការ ។ ព្រះរាជាទ្រង់ថ្វាយខាទនីយភោជនិយៈ ក្នុងវេលាសម្រេចភត្តកិច្ច ថ្វាយបង្គំព្រះមានព្រះភាគក្រាបទូលថា បពិត្រ ព្រះមានព្រះ-ភាគ ព្រះអង្គឧប្បត្តិក្នុងវង្សក្សត្រិយ៍ ដែលមានមកតាមប្រពៃណី ទ្រង់លះបង់សិរីរាជសម្បត្តិរបស់ស្តេចចក្រពត្តិ ទ្រង់ព្រះផ្នួសសម្រេចភាពជាបុគ្គលកំពូលលើសក្នុងលោកហើយ ព្រះអង្គនៅមានបលិពោធអ្វីទៀតហ្ន៎ ។ មហាបពិត្រ បលិពោធរបស់ព្រះថេរៈចាស់រូបនេះ ក៏ដូចជាបលិពោធរបស់តថាគតដែរ ។

ព្រះរាជាទ្រង់ថ្វាយបង្គំព្រះថេរៈ ត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន តើលោកម្ចាស់មានបលិពោធអ្វី ។ ព្រះថេរៈថ្វាយព្រះពរថា អាត្មាមានបលិពោធក្នុងរឿងជំពាក់បំណុល មហាបពិត្រ ។ តើលោកម្ចាស់ ជំពាក់បំណុលប៉ុន្មាន? ។ ចូរទ្រង់រាប់មើលចុះ មហាបពិត្រ ។ កាលព្រះរាជាទ្រង់រាប់ថា ១ , ២ , ១០០ , ១.០០០ ដូច្នេះ ម្រាមព្រះហស្តមិនល្មម (ក្នុងការរាប់) ។ លំដាប់នោះ ព្រះរាជត្រាស់ហៅបុរសម្នាក់មក ត្រាស់បង្គាប់ថា នាយ

ចូរទៅវាយស្គរ ស្រែកប្រកាសក្នុងព្រះនគរថា ម្ចាស់បំណុលរបស់ពហុធិតិក-ព្រាហ្មណ៍ទាំងអស់ ចូរប្រជុំគ្នាត្រង់មុខព្រះលាន ។ ពួកមនុស្សបានឮសំឡេងស្គរ ក៏បានមកប្រជុំគ្នាហើយ ។ ព្រះរាជាឲ្យនាំបញ្ជីមកពីដៃរបស់ម្ចាស់បំណុលទាំងនោះ ទ្រង់បានព្រះរាជទានទ្រព្យមិនឲ្យខ្វះមិនឲ្យលើសបំណុល ដែលខ្ចីមកទាំងអស់ ។ ក្នុងទីនោះមាសមានតម្លៃមួយសែន ទ្រង់បានសងដល់ម្ចាស់បំណុល ។ ព្រះរាជាត្រាស់សួរទៀតថា លោកម្ចាស់បលិពោធដទៃនៅមានទៀតទេ ។ ព្រះថេរៈថ្វាយព្រះពរថា បពិត្រព្រះមហារាជ រួចបំណុលហើយ តែនៅមានក្មេងស្រី ៧ នាក់នេះ ជាបលិពោធធំរបស់អាត្មា ។ ព្រះរាជាទ្រង់បញ្ជូនយានទៅទទួលធីតាទាំងឡាយរបស់ព្រះថេរៈនោះ មកធ្វើជាធីតារបស់ព្រះអង្គ ហើយទ្រង់បញ្ជូនទៅកាន់ផ្ទះត្រកូលស្វាមីនោះៗ ហើយត្រាស់សួរថា លោកម្ចាស់នៅមានបលិពោធដទៃទៀតទេ ។ ព្រះថេរៈថ្វាយព្រះពរថា នាងព្រាហ្មណីមហាបពិត្រ ។ ព្រះរាជាទ្រង់បញ្ជូនយានទៅនាំនាងព្រាហ្មណីមក ទ្រង់តាំងទុកក្នុងតំណែងព្រះអយ្យិកា ហើយត្រាស់សួរទៀតថា លោកម្ចាស់នៅមានបលិពោធដទៃទៀតទេ ។ ព្រះថេរៈថ្វាយព្រះពរថា មិនមានទេ មហាបពិត្រ ។ ព្រះរាជា ត្រាស់បង្គាប់ឲ្យប្រគេនសំពត់ចីវរ ទើបត្រាស់ថា បពិត្រលោកម្ចាស់

សូមលោកម្ចាស់ចូរជ្រាបនូវការៈជាកិច្ចរបស់លោកម្ចាស់ថា ជាសម្បត្តិរបស់ខ្ញុំព្រះករុណា ។ ព្រះថេរៈថ្វាយព្រះពរថា សូមថ្វាយព្រះពរមហាបពិត្រ ។ លំដាប់នោះ ព្រះរាជាត្រាស់ថា លោកម្ចាស់ បច្ច័យគ្រប់យ៉ាង មានចីវរ និងបិណ្ឌបាតជាដើម នឹងជារបស់ពួកយើងចាត់ចែងថ្វាយ សូមលោកម្ចាស់ផ្គាប់ព្រះទ័យព្រះតថាគតហើយ បំពេញសមណធម៌ចុះ ។ ព្រះថេរៈមិនប្រមាទបំពេញសមណធម៌តែម្យ៉ាង ក៏ដល់ការអស់អាសវៈក្នុងកាលមិនយូរនោះឯង ។

ចប់អដ្ឋកថា ពហុធិតិសូត្រទី ១០

## ចប់អរហន្តវគ្គទី ១

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថាធនញ្ជានីសូត្រ
២-អដ្ឋកថាអក្កោសកៈសូត្រ
៣-អដ្ឋកថាអសុរិន្ទកៈសូត្រ
៤-អដ្ឋកថាពិលង្គិកៈសូត្រ
៥-អដ្ឋកថាអហិង្សកៈសូត្រ
៦-អដ្ឋកថាជដាសូត្រ
៧-អដ្ឋកថាសុទ្ធិកៈសូត្រ
៨-អដ្ឋកថាអគ្គិកៈសូត្រ
៩-អដ្ឋកថាសុន្ទរិកៈសូត្រ
១០-អដ្ឋកថាពហុធិតិសូត្រ

# ព្រាហ្មណសំយុត្ត

## ឧបាសកវគ្គទី ២

## អ ដ្ឋ ក ថា

### កសិសូត្រទី ១

*កសិសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[១៥០]** *បទថា **មគធេសុ** បានដល់ ក្នុងជនបទមានឈ្មោះយ៉ាងនោះ ។ បទថា **ទក្ខិណាគិរិស្មឹ** នោះឯងជាឈ្មោះនៃវិហារក្នុងជនបទដែលមាននៅក្នុងទិសខាងត្បូង នៃភ្នំដែលហោមព័ទ្ធក្រុងរាជគ្រឹះ ។ បទថា **ឯកនាលា** ក្នុងពាក្យថា **ឯកនាលាយំ ព្រាហ្មណគាមេ** នេះ ជាឈ្មោះរបស់ស្រុកនោះ ។ ចំណែកពួកព្រាហ្មណ៍អាស្រ័យនៅក្នុងស្រុកនោះជាច្រើន មានសេចក្តីរីករាយដោយការឃុំគ្រងរបស់កសិការទ្វាជព្រាហ្មណ៍ ព្រោះដូច្នោះលោកទើបហៅថាព្រាហ្មណគ្រាម ។*

*បទថា **តេនខោ បន សមយេន** សេចក្តីថា ព្រះមានព្រះភាគទ្រង់*

អាស្រ័យព្រាហ្មណគ្រាម ឈ្មោះថា **ឯកនាល** ក្នុងមគធរដ្ឋ ទ្រង់រង់ចាំភាពចាស់ក្លានៃឥន្ទ្រិយរបស់ព្រាហ្មណ៍ ក្នុងទក្ខិណាគិរីវិហារ រហូតដល់អស់សម័យណា ដោយសម័យនោះ ។ បទថា **កសិភារទ្វាជស្ស** សេចក្តីថា ព្រាហ្មណ៍នោះអាស្រ័យកសិកម្មចិញ្ចឹមជីវិត និងគោត្ររបស់គេ ឈ្មោះថា ភារទ្វាជៈ ។ បទថា **បញ្ចមត្តានិ** ប្រែថា មានប្រមាណ ៥ ។ លោកអធិប្បាយទុកថា មាននង្គ័លប្រមាណ ៥០០ មិនខ្វះមិនលើស ។ បទថា **បយុត្តានិ** ប្រែថា ប្រកបហើយ អធិប្បាយថា យកខ្សែបង់កគោទាំងឡាយ ។ បទថា **វប្បកាលេ** បានដល់ ក្នុងវេលាសាបព្រោះ គឺ ក្នុងសម័យព្រោះពូជ ។ ក្នុងការសាបព្រោះនោះមាន ២ យ៉ាង គឺ សាបព្រោះក្នុងផ្ទៃដីដែលសើម និងសាបព្រោះក្នុងផ្ទៃដីដែលស្ងួត ក៏ការសាប ព្រោះក្នុងដីដែលស្ងួតនោះ លោកបំណងយកក្នុងទីនេះ ។ ក៏ការសាបព្រោះក្នុងផ្ទៃដីដែលស្ងួតនោះឯង ជាការសាបព្រោះដែលជាមង្គលក្នុងថ្ងៃដំបូង ក្នុងពេលនោះត្រូវមានគ្រឿងឧបករណ៍គ្រប់គ្រាន់ គឺ ត្រូវប្រើគោដល់បីពាន់ក្បាល ។ គោទាំងអស់ត្រូវគេបំពាក់ដោយស្នែងមាស ត្រង់ទ្រូងប្រដាប់ដោយប្រាក់ ។ គោទាំងអស់ប្រដាប់ដោយផ្កាឈើស ព្រោះព្រំរបស់ក្រអូបដោយម្រាមទាំង ៤ គោទាំងអស់មានអវយវៈគ្រប់បរិបូណ៌ និង

សម្បូរណ៍ដោយលក្ខណៈល្អគ្រប់យ៉ាង ពួកខ្លះខ្មៅ មានពណ៌ស្រដៀងផ្កាអញ្ចន ពួកខ្លះស មានពណ៌ស្រដៀងពពក ពួកខ្លះក្រហម មានពណ៌ស្រដៀងកែវប្រវាឡ ពួកខ្លះដាំងមានពណ៌ស្រដៀងកែវមុក្តា ។ អ្នកភ្ជួរ ៥០០ នាក់ គ្រប់គ្នាប្រដាប់ដោយសំពត់ថ្មី ពណ៌ស និងពាក់កម្រងផ្កាលើស្មាខាងស្តាំ មានរាយកាយរុងរឿង លាបដោយលំអិតថ្មហរិតាល និងមនោសិលាជាដើម បែងចែកជាពួកៗ មួយពួកមាននង្គ័ល ១០ និងជន្ទួញប្រដាប់មាស នង្គ័លដំបូងទឹមដោយគោ ៨ នង្គ័លដ៏សេសល់ទឹមដោយគោ ៤ គោក្រៅពីនោះនាំមកសម្រាប់ផ្លាស់ប្តូរគោដែលនឿយហត់ ។

មួយពួកៗ មានរទេះផ្ទុកគ្រាប់ពូជមួយរទេះ មានអ្នកភ្ជួរម្នាក់ អ្នកសាបព្រោះម្នាក់ ។

ចំណែកព្រាហ្មណ៍ ចាស់ជាងគេគាត់តែងពុកមាត់ ងូតទឹក លាបដោយគ្រឿងក្រអូប ស្លៀកសំពត់មានតម្លៃ ៥០០ ដណ្តប់សំពត់ចៀងស្មាតម្លៃ ១.០០០ ពាក់ចិញ្ចៀនម្រាមមួយវង់ រួមមានចិញ្ចៀន ២០ វង់ ក្រវិលមានរូបរាជសីហ៍ត្រង់ត្រចៀកទាំងពីរ ជូតក្បាលដោយសំពត់ជូតដ៏ប្រសើរ ពាក់កម្រងផ្កាមាសត្រង់.ក ហែហមទៅដោយពួកព្រាហ្មណ៍ ហើយបន្តាប់ការងារ ។

លំដាប់នោះ នាងព្រាហ្មណីរបស់គេ ដាំស្លបាយបាយាសដាក់ភាជនៈ ច្រើនរយ ផ្ទុកក្នុងរទេះធំជាច្រើន ហើយងូតទឹកក្រអូប ប្រដាប់ដោយគ្រឿង ប្រដាប់ទាំងពួង ហែហមទៅដោយពួកព្រាហ្មណី បានទៅកាន់ទីការងារ ។ សូម្បី ផ្ទះរបស់ព្រាហ្មណ៍នោះក៏លាបពណ៌ខៀវ រោយលាជយ៉ាងច្រើនដេរដាស ប្រដាប់ ដោយថ្នាំងពេញដោយទឹក ដើមចេកទង់ជ័យ និងទង់សំពត់ ធ្វើពលីកម្មយ៉ាង ល្អដោយគ្រឿងក្រអូប និងផ្កាឈើជាដើម ។ សូម្បីទីវាលស្រែ ក៏បានលើក ទង់ជ័យ និងទង់សំពត់ឡើងក្នុងទីនោះៗ ។ ជនជាបរិវារ និងជនដែលធ្វើការងារ រួមទាំងបរិស័ទមានអ្នកប្រមាណ ២.៥០០ នាក់ ។ អ្នកទាំងអស់នាំសំពត់មក ។ មនុស្សទាំងអស់នាំតែបាយបាយាសមកប៉ុណ្ណោះ ។

លំដាប់នោះ ព្រាហ្មណ៍ឲ្យលាងថាសមាស ដាក់បាយបាយាសពេញ ប្រដាប់ដោយទឹកដោះថ្លា ទឹកឃ្មុំ ទឹកអំពៅ ឲ្យធ្វើពលីកម្ម ។ នាងព្រាហ្មណី ឲ្យចែកភាជន៍មាស ប្រាក់ និងសំរឹទ្ធ អង្គាសដល់អ្នកភ្ជួរ ៥០០ នាក់ នាង ព្រាហ្មណីកាន់វែកមាសដើរអង្គាសបាយបាយាស ។ ចំណែកព្រាហ្មណ៍ ឲ្យធ្វើ ពលីកម្មហើយ ក្រវាត់រុំកាយដោយសំពត់ក្រហម ពាក់ស្បែកជើង កាន់ឈើ ច្រត់មាសពណ៌ក្រហម ត្រាច់បង្គាប់ថា ត្រង់នេះចូរឲ្យបាយបាយាស ត្រង់នេះ

ចូរឲ្យទឹកដោះថ្លា ។ ការប្រព្រឹត្តទៅក្នុងការងារប៉ុណ្ណោះមុន ។ ក្នុងទីដែលព្រះ-សម្ពុទ្ធទាំងឡាយប្រថាប់នៅក្នុងវិហារ ព្រះសម្ពុទ្ធទាំងនោះ រមែងមានកិច្ចប្រចាំថ្ងៃ ៥ យ៉ាង ។ កិច្ច ៥ យ៉ាងតើអ្វីខ្លះ ។ កិច្ចក្នុងបរេភត្ត ១ កិច្ចក្នុងបច្ឆាភត្ត ១ កិច្ចក្នុងបឋមយាម ១ កិច្ចក្នុងមជ្ឈិមយាម ១ កិច្ចក្នុងបច្ឆិមយាម ១ ។

ក្នុង ៥ យ៉ាងនោះ កិច្ចក្នុងបុរេភត្ត ដូច្នេះ ព្រះមានព្រះភាគទ្រង់តើនពីព្រឹក ទ្រង់ធ្វើបរិកម្មព្រះវរកាយ មានខ្ពុរព្រះឱស្ឋជាដើម ដើម្បីអនុគ្រោះភិក្ខុជាឧបដ្ឋាក និងដើម្បីសប្បាយព្រះវរកាយ ហើយទ្រង់ឲ្យវេលាកន្លងទៅក្នុងសេនាសនៈដែលស្ងាត់រហូតដល់វេលាស្ដេចភិក្ខាចារ ដល់វេលាភិក្ខាចារ ទ្រង់ស្លៀកស្បង់ ក្រវាត់វត្ថពន្ធចង្កេះ ហើយទ្រង់ដណ្ដប់ចីវរ ទ្រង់កាន់បាត្រ ពេលខ្លះស្ដេចយាងតែមួយព្រះអង្គឯង ពេលខ្លះហែហមទៅដោយភិក្ខុសង្ឃ ស្ដេចចូលទៅកាន់ស្រុក ឬនិគមដើម្បីបិណ្ឌបាត ។ ពេលខ្លះ ស្ដេចចូលទៅតាមប្រក្រតី ពេលខ្លះក៏មានបាដិហារ្យច្រើនយ៉ាងប្រព្រឹត្តទៅ ។ គឺ កាលព្រះលោក-នាថស្ដេចត្រាច់បិណ្ឌបាត ខ្យល់បក់ផាត់ជម្រះផែនដីឲ្យស្អាតទៅខាងមុខ ភ្លៀងបង្អុរទឹកចុះជាតំណក់ៗ ឲ្យល្អងធូលីក្នុងផ្លូវរាបស្មើ ដូចជាពិតានទៅខាងលើ ។ ខ្យល់ម្យ៉ាង បក់យកផ្កាឈើមកខាងលើចាក់រោយក្នុងផ្លូវ ។ ភូមិប្រទេសដែល

ខ្ពស់ឡើង ក៏ទាបចុះ ភូមិប្រទេសដែលទាប ក៏ខ្ពស់ឡើង ក្នុងកាលដាក់ព្រះបាទចុះ ផ្ទៃដីរមែងរាបស្មើ ។ ផ្កាបទុមដែលមានសម្ផស្សជាសុខ រមែងផុសឡើងទទួលព្រះបាទ ។ ខណៈដែលព្រះអង្គដាក់ព្រះបាទស្តាំចុះខាងក្នុងសសរខឿន រស្មីមានពណ៌ ៦ បានផ្សាយចាកព្រះសរីរៈ ធ្វើកំពូលប្រាសាទឲ្យមានពណ៌ពណ៌ក្រហមដូចទឹកមាស និងដូចជាស្រោបដោយផែនសំពត់ដ៏វិចិត្រ ពន្លឺក៏ផ្សាយពាសពេញទៅខាងនេះខាងនោះ ។ ដំរី សេះ និងបក្សីជាដើម ឈរក្នុងទីនៅរៀងៗ ខ្លួន បញ្ចេញសំឡេងដ៏ពីរោះ ។ តន្ត្រី មានស្គរ និងពិណជាដើម និងអាភរណៈដែលសម្រាប់ប្រដាប់កាយរបស់មនុស្សនៅ ក៏ជាយ៉ាងនោះ ។ ព្រោះសំឡេងនោះជាគ្រឿងសម្គាល់ ពួកមនុស្សរមែងដឹងថា ថ្ងៃនេះព្រះមានព្រះភាគ ស្តេចចូលមកបិណ្ឌបាតក្នុងទីនេះ ។ ពួកគេស្លៀកដណ្តប់រៀបរយកាន់គ្រឿងក្រអូប និងផ្កាឈើជាដើម ចេញពីផ្ទះដើរទៅឈរអមសងខាងថ្នល់ បូជាព្រះមានព្រះភាគដោយផ្កាឈើជាដើម ដោយគោរព ថ្វាយបង្គំហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាប្រទានភិក្ខុដល់ពួកខ្ញុំព្រះអង្គ ១០ រូប ដល់ពួកខ្ញុំព្រះអង្គ ២០ រូប ដល់ពួកខ្ញុំព្រះអង្គ ១០០ រូប ។ បរិស័ទទទួលបាត្រពីព្រះមានព្រះភាគ ហើយឲ្យក្រាលអាសនៈ ថ្វាយបិណ្ឌបាតដោយ

គោរព ។

ព្រះមានព្រះភាគ សោយព្រះក្រយាហារស្រេចហើយ ទ្រង់ត្រួតមើលសន្តានរបស់មនុស្សទាំងនោះ ហើយទ្រង់សម្តែងធម៌យ៉ាងនោះ ។ ព្រះមានព្រះភាគទ្រង់អនុគ្រោះមហាជន ទ្រង់ញ៉ាំងជនពួកខ្លះឲ្យតាំងនៅក្នុងសរណគមន៍ ពួកខ្លះឲ្យតាំងនៅក្នុងសីល ៥ ពួកខ្លះឲ្យតាំងនៅក្នុងសោតាបត្តិផល សកទាគាមិផល និងអនាគាមិផលយ៉ាងណាមួយ ពួកខ្លះបួសហើយតាំងនៅក្នុងអរហត្ត ដែលជាផលដ៏ប្រសើរ ទ្រង់ក្រោកចាកពីអាសនៈ ស្តេចទៅកាន់ព្រះវិហារ ។ ប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរដែលក្រាលទុកក្នុងមណ្ឌលជិតព្រះគន្ធកុដិ ទ្រង់រង់ចាំឲ្យភិក្ខុទាំងឡាយឆាន់រួច តពីនោះ កាលភិក្ខុទាំងឡាយឆាន់ស្រេច ភិក្ខុជាឧបដ្ឋាក ក៏ក្រាបទូលព្រះមានព្រះភាគឲ្យទ្រង់ជ្រាប ។ លំដាប់នោះ ព្រះមានព្រះភាគស្តេចចូលព្រះគន្ធកុដិ ។ **នេះជាកិច្ចក្នុងបុរេភត្ត** ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ធ្វើកិច្ចក្នុងបុរេភត្តយ៉ាងនេះហើយ ប្រថាប់ក្នុងឧបដ្ឋានសាលាជិតព្រះគន្ធកុដិ ទ្រង់ឲ្យលាបព្រះបាតហើយ ប្រថាប់ឈរលើតាំងទ្រព្រះបាទ ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃថា

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរញ៉ាំងសេចក្តីមិនប្រមាទ

ឲ្យដល់ព្រមចុះ ការឧប្បត្តិនៃព្រះពុទ្ធទាំងឡាយ បានដោយលំបាកក្នុងលោក ការបានអត្តភាពជាមនុស្សជាការក្រ ការដល់ព្រមដោយសទ្ធាជាការក្រ ការបព្វជ្ជារកបានដោយក្រ ការស្តាប់ព្រះសទ្ធម្មរកបានដោយក្រ ដូច្នេះ ។

ក្នុងទីនោះ ភិក្ខុពួកខ្លះទូលសួរកម្មដ្ឋានចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ប្រទានកម្មដ្ឋានដែលសមគួរដល់ចរិយារបស់ភិក្ខុទាំងនោះ ។ តពីនោះ ភិក្ខុទាំងអស់ថ្វាយបង្គំព្រះមានព្រះភាគហើយ ទៅកាន់ទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃរៀងៗ ខ្លួន ពួកខ្លះទៅកាន់ព្រៃ ពួកខ្លះទៅកាន់គល់ឈើ ពួកខ្លះទៅកាន់ភ្នំជាដើមកន្លែងណាមួយ ពួកខ្លះទៅកាន់ឋានចាតុម្មហារាជិកា ពួកខ្លះទៅកាន់ឋានវសវត្តី ដូច្នេះឯង ។

លំដាប់នោះ ព្រះមានព្រះភាគស្តេចចូលព្រះគន្ធកុដិ បើព្រះអង្គមានព្រះពុទ្ធបំណង (ទីងផ្ទុំ) ក៏ទ្រង់ផ្ទុំដោយព្រះសតិសម្បជញ្ញៈ សម្រេចសីហសេយ្យាសនៈ មួយក្អែតដោយទ្រង់ផ្ទុំផ្អៀងទៅខាងស្តាំ ។

លំដាប់នោះ ព្រះអង្គទ្រង់មានព្រះវរកាយរហ័សរហួន ទ្រង់តើនឡើងគ្រួតមើលលោក នេះ ជាពុទ្ធកិច្ចទី ២ ។ ក្នុង ពុទ្ធកិច្ចទី ៣ ក្នុងស្រុក ឬនិគម

ដែលព្រះមានព្រះភាគស្តេចចូលទៅអាស្រ័យ ប្រថាប់នៅក្នុងបុរេភត្ត មហាជនថ្វាយទានក្នុងបច្ឆាភត្ត គេស្លៀកដណ្តប់ស្អាតបាត កាន់គ្រឿងក្រអូប និងផ្កាឈើជាដើម ប្រជុំគ្នាក្នុងវិហារ ។

លំដាប់នោះ ព្រះមានព្រះភាគ ស្តេចទៅដោយបដិហារ្យដែលសមគួរដល់បរិស័ទដែលប្រជុំគ្នា ប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេក្រាលទុកក្នុងធម្មសភាសម្រាប់សម្តែងធម៌ នេះសមគួរដល់កាល សមគួរដល់សម័យលុះទ្រង់ជ្រាបវេលា ទើបទ្រង់បញ្ជូនបរិស័ទទៅ ។ មនុស្សទាំងឡាយនាំគ្នាថ្វាយបង្គំព្រះមានព្រះភាគ ហើយចៀសទៅ ។ នេះ **ជាកិច្ចក្នុងបច្ឆាភត្ត** ។

គ្រាព្រះអង្គសម្រេចកិច្ចក្នុងបច្ឆាភត្តយ៉ាងនេះហើយ ប្រសិនបើទ្រង់មានព្រះបំណងនឹងស្រោចស្រប់ព្រះវរកាយ ទ្រង់ក្រោកចាកពុទ្ធាសនៈ ស្តេចចូលទៅកាន់ទីស្រង់ ធ្វើព្រះវរកាយឲ្យសមនឹងរដូវកាលដោយទឹក ដែលឧបដ្ឋាករៀបចំថ្វាយ ។ ចំណែកឧបដ្ឋាក បាននាំពុទ្ធាសនៈ មកក្រាលទុកក្នុងបរិវេណព្រះគន្ធកុដិ ។ ព្រះមានព្រះភាគ ទ្រង់ស្លៀកសំពត់ដែលជ្រលក់ហើយ ២ ជាន់ ក្រវាត់វត្ថពន្ធបង្កេះ ធ្វើឆៀងស្មា ស្តេចមកប្រថាប់គង់ក្នុងទីនោះ ពួនសម្ងំមួយក្អែតតែមួយព្រះអង្គឯង ។ លំដាប់នោះ ភិក្ខុទាំងឡាយមកពីទីនោះៗ ទៅកាន់ទីបម្រើ

ព្រះមានព្រះភាគ ។ បណ្ដាភិក្ខុទាំងនោះ ពួកខ្លះសួរបញ្ហា ពួកខ្លះសូមកម្មដ្ឋាន ពួកខ្លះសូមស្ដាប់ធម៌ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើសេចក្ដីប្រាថ្នារបស់ភិក្ខុទាំងនោះឲ្យសម្រេច ឲ្យបឋមយាមកន្លងទៅ ។ នេះ **ជាកិច្ចក្នុងបឋមយាម** ។

ក៏ក្នុងវេលាដែលកិច្ចក្នុងបឋមយាមចប់ហើយ កាលភិក្ខុទាំងឡាយថ្វាយបង្គំព្រះមានព្រះភាគហើយចៀសទៅ ពួកទេវតាក្នុងមុឺនលោកធាតុទាំងអស់ បានឱកាសចូលគាល់ព្រះមានព្រះភាគ សួរបញ្ហាតាមដែលតែងឡើងដោយហោចទៅ សួរសូម្បី ៤ អក្ខរ ព្រះមានព្រះភាគ កាលទ្រង់ដោះស្រាយបញ្ហារបស់ទេវតាទាំងនោះ ក៏ឲ្យមជ្ឈិមយាមកន្លងទៅ ។ **នេះជាកិច្ចក្នុងមជ្ឈិមយាម** ។

ក៏ព្រះមានព្រះភាគ ទ្រង់បែងចែកបច្ឆិមយាមចេញជា ៣ ចំណែក ហើយទ្រង់ឲ្យចំណែកមួយកន្លងទៅដោយការចង្រ្កម ដើម្បីនឹងទ្រង់សម្រួលការលំបាកនៃព្រះវរកាយ ដែលត្រូវបៀតបៀនព្រះវរកាយ ព្រោះប្រថាប់គង់ចាប់តាំងពីបុរេភត្តមក ។ ក្នុងចំណែកទី ២ ព្រះអង្គស្ដេចចូលទៅកាន់ព្រះគន្ធកុដិ ទ្រង់មានព្រះសតិសម្បជញ្ញៈ សម្រេចព្រះសីហសេយ្យាសនៈដោយផ្ទៀងទៅខាងស្ដាំ ។ ក្នុងចំណែកទី ៣ ព្រះអង្គស្ដេចតើនឡើង ប្រថាប់គង់ត្រួតមើលសត្វ

លោកដោយពុទ្ធចក្ខុ ដើម្បីទ្រង់ទតមើលបុគ្គលដែលដែលបានសាងបុញ្ញាធិការទុក ដោយគុណ មានទាន និងសីលជាដើម ក្នុងសម្នាក់នៃព្រះពុទ្ធទាំងឡាយក្នុងកាលមុន ។ **នេះជាកិច្ចក្នុងបច្ឆិមយាម** ។

សូម្បីក្នុងពេលថ្ងៃ ព្រះអង្គទ្រង់ត្រួតមើលយ៉ាងនេះ ទ្រង់ឃើញកសិភារទ្វាជព្រាហ្មណ៍ ដល់ព្រមដោយធម៌ដែលជាឧបនិស្ស័យនៃព្រះអរហត្ត ទ្រង់ជ្រាបថា កាលតថាគតទៅកាន់ទីនោះ នឹងមានការចចារគ្នា កាលចប់ការចចារព្រាហ្មណ៍ ព្រមទាំងបុត្ត និងករិយានោះ ស្តាប់ធម្មទេសនាហើយ នឹងតាំងនៅក្នុងសរណៈ ៣ នឹងសាបព្រោះទ្រព្យ ៨០ កោដិ ក្នុងសាសនារបស់តថាគតខាងក្រោយនឹងចេញបព្វជ្ជា នឹងសម្រេចព្រះអរហត្ត ដូច្នេះ ទើបស្តេចទៅកាន់ទីនោះ ទ្រង់ប្រារព្ធរឿងឡើង ហើយសម្តែងធម៌ ។ ដើម្បីនឹងសម្តែងសេចក្តីនោះ លោកទើបពោលថា **អថខោ ភគវា** ដូច្នេះជាដើម ។

**[១៩១]** បណ្តាបទទាំងនោះ ពាក្យថា **បុព្វណ្ហសមយំ** នេះ ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ សេចក្តីថា វេលាព្រឹក ។ បទថា **និវាសេត្វា** បានដល់ ទ្រង់ស្លៀកដណ្តប់ ។ ពាក្យនោះ លោកពោលពីការផ្លាស់ប្តូរចីវរក្នុងវិហារ ។ បទថា **បត្តចីវរមាទាយ** សេចក្តីថា ប្រើដៃកាន់បាត្រ ប្រើកាយ

ទ្រទ្រង់ចីវរ អធិប្បាយថា ទទួល គឺ ទ្រទ្រង់ទុក ។ បានឮថា កាលព្រះមាន-ព្រះភាគ មានព្រះបំណងនឹងស្តេចចូលទៅបិណ្ឌបាត្រ ថ្មមានពណ៌ដូចកែវ-ឥន្ទនិល និងកែវមណី រមែងមកកាន់ត្រង់កណ្តាលព្រះហស្តទាំងពីររបស់ព្រះមានព្រះភាគ ដូចភមរជាតិមកកាន់កណ្តាលផ្កាបទុមទាំង ២ ដែលរីក ដូច្នោះ ។ អធិប្បាយថា ទទួលបាត្រនោះដែលមកដល់ហើយយ៉ាងនេះ ដោយព្រះហស្តទាំង ២ ទ្រង់ស្លៀកដណ្តប់ចីវរជាបរិមណ្ឌលដោយព្រះវរកាយ ។ បទថា **តេ-នុបសង្កមិ** សេចក្តីថា ព្រះអង្គតែមួយអង្គឯង ស្តេចចូលទៅតាមផ្លូវទីការវង្វារនឹងគប្បីប្រព្រឹត្តទៅ ។ សួរថា ក៏ព្រោះហេតុអ្វីភិក្ខុទាំងឡាយ ទើបមិនជាប់តាមព្រះអង្គទៅ ។ ឆ្លើយថា ព្រោះក្នុងកាលណា ព្រះមានព្រះភាគ មានព្រះបំណងនឹងស្តេចទៅក្នុងទីណាៗ តែមួយព្រះអង្គឯងក្នុងវេលាភិក្ខាចារ ព្រះអង្គទ្រង់បិទទ្វារ ទ្រង់ប្រថាប់គង់ក្នុងខាងក្នុងព្រះគន្ធកុដិ ។ ភិក្ខុទាំងឡាយដឹងដោយសញ្ញានោះថា ថ្ងៃនេះព្រះមានព្រះភាគ មានព្រះបំណងស្តេចនឹងត្រាច់បិណ្ឌ-បាតតែមួយព្រះអង្គឯង ព្រះអង្គទ្រង់ឃើញបុគ្គលដែលគួរណែនាំសូម្បីតែម្នាក់ដោយពិត ។ ភិក្ខុទាំងឡាយនោះ កាន់បាត្រ និងចីវររបស់ខ្លួនព្រះធ្វើប្រទក្សិណព្រះគន្ធកុដិ ថ្វាយបង្គំហើយ ទើបទៅកាន់ទីភិក្ខាចារ ។ ក្នុងកាលនោះឯងព្រះ

មានព្រះភាគទ្រង់បានធ្វើយ៉ាងនោះ ។ ព្រោះហេតុនោះ ភិក្ខុទាំងឡាយ ទើបមិនជាប់តាម ។

បទថា **បរិវេសនា វត្តតិ** សេចក្ដីថា ការអង្គាសអាហារដល់អ្នកភ្ជួរស្រែ ៥០០ នាក់ ដែលអង្គុយកាន់ភាជនៈមាសជាដើមទាំងនោះ នៅពេលសម្រាក ។ បទថា **ឯកមន្តំ អដ្ឋាសិ** សេចក្ដីថា ប្រថាប់ឈរក្នុងទីដែលនុស្សឈរ ហើយព្រាហ្មណ៍នឹងឃើញបាន គឺ ក្នុងទីខ្ពស់ឆ្ងាយក្នុងទស្សនូបចារបែបនោះ ។

ក៏គ្រាព្រះអង្គប្រថាប់ឈរហើយ ទ្រង់បញ្ចេញរស្មីពីព្រះវរកាយ មានពណ៌លឿងដូចមាសរតជះដោយជុំវិញ រុងរឿងកន្លងរស្មីព្រះចន្ទ និងព្រះអាទិត្យ ផ្សាយគ្របដណ្ដប់រោងការងារ ជញ្ជាំងផ្ទះ ដើមឈើ និងដុំដី ត្រង់នង្គ័លជាដើមរបស់ព្រាហ្មណ៍ ឲ្យមានសភាពដូចជាធ្វើដោយមាស លំដាប់នោះ ពួកអ្នកកំពុងបរិភោគនៅក៏ដោយ កំពុងភ្ជួរស្រែនៅក៏ដោយ នាំគ្នាលះបង់ចោលកិច្ចគ្រប់យ៉ាង ព្រោះបានឃើញព្រះសម្មាសម្ពុទ្ធមានព្រះវរកាយប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ មានអនុព្យញ្ជនៈ ៨០ ជាបរិវារ និងព្រះពាហាទាំងគូ (កំភួនដៃ) ដែលស្រស់ល្អដោយរស្មីដែលផ្សាយចេញប្រមាណមួយព្យាម

ទ្រទ្រង់នូវរឿងដោយព្រះសិរី ហាក់បីដូចជាស្រះបទុមដែលកើតលើផែនដី ឬដូច ផ្ទៃអាកាសដែលមានពួកផ្កាយបំភ្លឺ និងដូចជាសុវណ្ណបពិតដ៏ប្រសើរ ដែលគ្រប ដណ្តប់ដោយខ្សែផ្គូកបន្ទោរ អ្នកខ្លះលាងដៃ និងជើង ចូលទៅឈរហែហម ផ្គងអញ្ជលី ។ កសិភារទ្វាជព្រាហ្មណ៍បានឃើញព្រះមានព្រះភាគ ហែហម ទៅដោយជនទាំងនោះ ស្តេចបិណ្ឌបាតដោយអាការយ៉ាងនេះ លុះឃើញហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា **អហំ ខោ សមណ កសាមិ ច វបាមិ ច** ដូច្នេះ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រាហ្មណ៍នេះ ទើបពោលយ៉ាងនេះថា យើង ចាត់ចែងបាយបាយាសដល់ជន ២.៥០០ នាក់ តែសេចក្តីមិនជ្រះថ្លាក្នុងព្រះ- តថាគត ដែលជាអ្នកមានខ្លួនបានទូន្មាន និងជាអ្នកស្ងប់រម្ងាប់ហើយ ទាំងជា អ្នកនាំមកនូវសេចក្តីជ្រះថ្លាដោយជុំវិញ ជាទីតាំងនៃសេចក្តីជ្រះថ្លា ឬព្រះមាន- ព្រះភាគពោលអំពីសេចក្តីកំណាញ់កិក្ខាក្នុងវែកឬ ។ ឆ្លើយថា មិនមែនទាំង ២ យ៉ាង តែព្រាហ្មណ៍ឃើញជនមិនឆ្អែតដោយការមើលព្រះមានព្រះភាគ លះបង់ ចោលការងារ ទើបមិនពេញចិត្តថា ព្រះមានព្រះភាគស្តេចមកទម្លាយការងារ របស់យើង ដូច្នោះ ព្រាហ្មណ៍ទើបពោលយ៉ាងនោះ ។ និងព្រោះព្រាហ្មណ៍

បានឃើញព្រះមានព្រះភាគ ទ្រង់សម្បូរណ៌ដោយព្រះលក្ខណៈ គិតថា បើព្រះមានព្រះភាគនេះនឹងបានប្រកបការងារសោត ព្រះអង្គក៏នឹងប្រៀបដូចជាចូឡាមណីលើសីសៈរបស់ពួកមនុស្សទូទាំងជម្ពូទ្វីប ប្រយោជន៍អ្វីនឹងមិនសម្រេចដល់ព្រះអង្គហ្ន៎ ដោយអាការយ៉ាងនេះឯង តែព្រះអង្គមិនប្រកបការងារ ព្រោះសេចក្តីខ្ជិលច្រអូស ទើបស្តេចត្រាច់បិណ្ឌបាតក្នុងពិធីវប្បមង្គលជាដើម ដូច្នេះ ទើបកើតសេចក្តីមិនពេញចិត្ត ។ ដោយហេតុនោះ ព្រាហ្មណ៍ទើបពោលថា **អហំ ខោ សមណ កសាមិ ច វបាមិ ច កសិត្វា ច វបិត្វា ច ភុញ្ជាមិ** ដូច្នេះ ។

បានឮថា ព្រាហ្មណ៍នោះមានសេចក្តីប្រាថ្នាដូច្នេះថា ការងារទាំងឡាយសូម្បីរបស់យើងមិនទាន់វិនាស យើងមិនបានជាអ្នកមានលក្ខណៈសម្បូរណ៍ដូចព្រះអង្គ សូម្បីព្រះអង្គក្ខួរ និងសាបព្រោះហើយ ចូរបរិភោគចុះ ប្រយោជន៍អ្វីនឹងមិនគប្បីសម្រេចដល់ព្រះអង្គអ្នកសម្បូរណ៍ដោយលក្ខណៈយ៉ាងនេះហ្ន៎ ។ម្យ៉ាងទៀត ព្រាហ្មណ៍បានស្តាប់ថា បានឮមកថា ព្រះមានព្រះភាគនោះ ជាកុមារកើតក្នុងសក្យរាជត្រកូល លះបង់ភាពជាស្តេចចក្រពត្តិ ទ្រង់ព្រះផ្នួស ព្រោះហេតុដូច្នេះ ព្រាហ្មណ៍ដឹងក្នុងកាលឥឡូវនេះថា ព្រះអង្គនេះ គឺ ព្រះរាជកុមារនោះ ទើបលើកឡើងតិះដៀលថា ព្រះអង្គព្រមលំបាកហើយ ទើបលះបង់ភាព

ជាស្តេចចក្រពត្តិ ព្រាហ្មណ៍ទើបពោលយ៉ាងនេះ ។ម្យ៉ាងទៀត ព្រាហ្មណ៍នេះមានបញ្ញាចាស់ក្លា ពោលនឹងព្រះមានព្រះភាគដោយមិនជ្រះថ្លាក៏ទេ ។ គ្រាន់តែបានឃើញរូបសម្បត្តិរបស់ព្រះមានព្រះភាគ ទើបសរសើរបុញ្ញសម្បត្តិ ពោលយ៉ាងនេះដើម្បីឲ្យមានការប្រាស្រ័យនឹងខ្លះ ។ លំដាប់នោះ ព្រះមានព្រះភាគកាលទ្រង់សម្តែងភាវៈនៃព្រះអង្គថា ជាអ្នកក្ករាស់ដ៏ប្រសើរក្នុងលោក ព្រមទាំងទេវលោក ដោយជាវេនេយ្យសត្វ ទើបបានត្រាស់ថា **អហម្បិ ខោ ព្រាហ្មណ** ជាដើម ។

លំដាប់នោះ ព្រាហ្មណ៍គិតថា សមណៈនេះពោលថា តថាគតក្ករផង ព្រោះផង តែយើងមិនឃើញគ្រឿងនង្គ័ល មាននឹមនិងនង្គ័លជាដើមរបស់សមណៈនេះ សមណៈនេះពោលកុហកឬហ្ន៎ ត្រួតមើលព្រះមានព្រះភាគ តាំងពីផ្ទៃព្រះបាតដរាបដល់ចុងព្រះកេសា ព្រោះខ្លួនសម្រេចវិជ្ជាមើលលក្ខណៈ ទើបដឹងថា សមណៈនោះសម្បូរណ៍ដោយលក្ខណៈប្រសើរ ៣២ ប្រការ ព្រោះបានសន្សំបុញ្ញាធិការទុក កើតមានះយ៉ាងខ្លាំងក្លាថា ប្រការដែលសមណៈបែបនេះនិយាយមុសាមិនមែនជាឋានៈ ទើបលះបង់វាទៈថាសមណៈក្នុងព្រះមានព្រះ-ភាគចេញ នឹងកាលហៅព្រះមានព្រះភាគដោយគោត្រ ទើបពោលថា **ន ខោ**

បទមយំ បសុព្រាម ភោតោ គោតមស្ស ជាដើម ។ ចំណែកព្រះមានព្រះភាគ កាលទ្រង់នឹងសម្ដែងពុទ្ធានុភាព ព្រោះហេតុដែលឈ្មោះថា ការពោលអំពីភាព ជាអ្នកមានចំណែកស្មើគ្នាដោយធម៌មានក្នុងកាលមុន គឺ ជាអានុភាពរបស់ព្រះពុទ្ធទាំងឡាយ ទើបត្រាស់ពាក្យមានជាដើមថា **សទ្ធាពីជំ** ដូច្នេះ ។

សួរថា ក៏ក្នុងសេចក្ដីនេះ ភាពជាអ្នកមានចំណែកស្មើគ្នាដោយធម៌មានក្នុងកាលមុន គឺអ្វី ព្រះមានព្រះភាគត្រូវព្រាហ្មណ៍សួរដល់គ្រឿងនង្គ័ល មាននឹម និងនង្គ័លជាដើមមិនមែនឬ តែព្រះអង្គត្រាស់ថា **សទ្ធា ពីជំ** ជាដើម ព្រោះពូជដែលមិនដូចគ្នា នឹងបើដូច្នោះ សូម្បីពាក្យក៏តគ្នាមិនបាន ធម្មតាថា ពាក្យរបស់ព្រះពុទ្ធទាំងឡាយ ដែលតគ្នាមិនបាននឹងមិនមានឡើយ ។ ព្រះពុទ្ធទាំងឡាយ នឹងត្រាស់ដោយភាពនៃធម៌ដែលមិនដូចគ្នាក្នុងកាលមុន ក៏មិនមែន ។ ក៏ក្នុងសេចក្ដីនេះ គប្បីជ្រាបអនុសន្ធិយ៉ាងនេះថា ពិតណាស់ ព្រះមានព្រះភាគត្រូវព្រាហ្មណ៍សួរដល់ការភ្ជួរដោយគ្រឿងនង្គ័ល មាននឹម និងនង្គ័លជាដើម ។ ដោយសេចក្ដីអនុគ្រោះព្រាហ្មណ៍នោះ ព្រះអង្គប្រាថ្នាឲ្យព្រាហ្មណ៍ជ្រាបរឿងក្នុងការភ្ជួរព្រមទាំងមូល ព្រមទាំងឧបការៈ ព្រមទាំងសម្ភារៈដ៏សេស ព្រមទាំងផលមិនឲ្យសាបសូន្យ ដោយព្រះតម្រិះថា ប្រការនេះគេមិនបានសួរ កាលនឹង

ទ្រង់សម្តែងចាប់តាំងពីដើមមក ទើបត្រាស់ពាក្យមានជាដើមថា **សទ្ធា ពីជំ** ដូច្នេះ ពូជក្នុងរឿងនោះ ជាមូលនៃការភ្ជួរ ព្រោះកាលពូជមាន ក៏គួរធ្វើ កាលពូជមិនមាន ក៏មិនគួរធ្វើ តែគួរធ្វើឲ្យល្មមសមគួរដល់ពូជនោះ ព្រោះកាលមានពូជ អ្នកស្រែ រមែងភ្ជួរស្រែ កាលមិនមាន ក៏មិនភ្ជួរ ។ អ្នកស្រែដែលឆ្លាតរមែងភ្ជួរស្រែឲ្យល្មមសមគួរដល់ពូជប៉ុណ្ណោះ ។ មិនធ្វើឲ្យខ្វះ ដោយគិតថា សន្ទូងរបស់យើងកុំវិនាសឡើយ មិនធ្វើឲ្យលើស ដោយគិតថា សេចក្តីព្យាយាមរបស់យើងចូរកុំឥតប្រយោជន៍ឡើយ ។ ក៏ព្រោះពូជនុ៎ះឯងជាមូល ដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងការភ្ជួរផ្តើមពីមូល គឺ ទ្រង់សម្តែងធម៌ខាងដើមនៃការភ្ជួររបស់ព្រះអង្គ ដោយពូជ គឺ ធម៌ខាងដើម ប្រៀបដូចនឹងការភ្ជួររបស់ព្រាហ្មណ៍នោះ ទើបត្រាស់ **សទ្ធា ពីជំ** ដូច្នេះ ។ ក្នុងសេចក្តីនេះ សូម្បីការភ្ជួររបស់ព្រាហ្មណ៍ ប្រៀបដោយធម៌ខាងដើម ក៏គប្បីជ្រាបយ៉ាងនេះ ។

ប្រសិនបើមានពាក្យសួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបត្រាស់ចំពោះតែពាក្យដែលព្រាហ្មណ៍សួរប៉ុណ្ណោះ មិនត្រាស់ដល់ប្រការដែលមិនសួរខាងក្រោយ ។ ឆ្លើយថា ព្រោះព្រះអង្គជាអ្នកមានឧបការៈដល់ព្រាហ្មណ៍នោះ និងព្រោះព្រះអង្គជាអ្នកអាចភ្ជាប់ព្រះធម៌ ។ ពិតណាស់ ព្រាហ្មណ៍នេះជាអ្នក

មិនមានសទ្ធា ព្រោះកើតក្នុងត្រកូលមិច្ឆាទិដ្ឋិមួយ តែជាអ្នកមានបញ្ញា មិនបដិបត្តិក្នុងធម៌ដែលមិនមែនវិស័យរបស់ខ្លួន ព្រោះជាប់ទាក់ទិននឹងអ្នកដទៃ ទើបមិនបានសម្រេចគុណវិសេស ។ ក៏សទ្ធារបស់ព្រាហ្មណ៍នោះ បានត្រឹមតែប្រាសចាកកិលេស និងធម៌ចំណែកខ្មៅដែលប៉ោងឡើង មានលក្ខណៈត្រឹមតែថ្លាផូរផង់ មានកម្លាំងតិច ប្រព្រឹត្តទៅជាមួយបញ្ញាដែលមានកម្លាំងខ្លាំង ទើបមិនធ្វើឲ្យសម្រេចប្រយោជន៍ ដូចគោដែលទឹមក្នុងនឹមតែមួយជាមួយដំរី ដូច្នោះ សទ្ធារបស់គេទើបជាគ្រឿងគាំទ្រ ដូច្នោះ ព្រះមានព្រះភាគកាលនឹងទ្រង់ស្ដាបនាព្រាហ្មណ៍នោះទុកក្នុងសទ្ធា ទើបត្រាស់សេចក្ដីនេះ ដែលគួរនឹងត្រាស់សូម្បីក្នុងខាងក្រោយ យកមកត្រាស់មុន ព្រោះទ្រង់ជាអ្នកច្លាតក្នុងទេសនា ។ ក៏ភ្លៀងជាឧបការៈដល់ពូជ ភ្លៀងនោះ ព្រះអង្គត្រាស់ក្នុងលំដាប់នោះឯង ទើបជាធម្មជាតិដែលអាច (ឧបការៈដល់ពូជ) ។ សេចក្ដីនេះ ព្រះអង្គគួរត្រាស់សូម្បីខាងក្រោយ ព្រោះទ្រង់អាចភ្ជាប់ព្រះធម៌ ។ គ្រឿងនង្គ័លដទៃៗ មានយាមនង្គ័ល និងខ្សែជាដើមនេះ គប្បីជ្រាបថា ត្រាស់មុនហើយ ។

ក្នុងសេចក្ដីនោះ សទ្ធា មានសេចក្ដីថ្លាផូរផង់ជាលក្ខណៈ ឬមានសេចក្ដីមិនកម្រើកជាលក្ខណៈ ។ បទថា ពីជំ បានដល់ ពូជ ៥ យ៉ាង គឺ ពូជកើត

ពីឫស ពូជកើតពីដើម ពូជកើតពីថ្នាំង ពូជកើតពីចុង ពូជកើតពីគ្រាប់ជាទី ៥ ទាំងអស់នោះរាប់ថា ពូជកើតពីគ្រាប់តែម្យ៉ាង ព្រោះដុះបាន ។

ក្នុងសេចក្ដីនោះ ពូជជាមូលនៃកសិកម្មរបស់ព្រាហ្មណ៍ បែកចេញជាពីរ គឺ ខាងក្រោមដុះឫស ខាងលើចេញពន្លក យ៉ាងណា សទ្ធាជាមូលនៃកសិកម្មរបស់ព្រះមានព្រះភាគ ខាងក្រោមមានសីលជាឫស ខាងលើមានសមថៈនិងវិបស្សនាជាពន្លក ដូច្នោះ ។ ដូចជា ពូជនោះ ទទួលរសបឋវីធាតុ អាបោធាតុដោយឫស រមែងលូតលាស់ឡើងដើម្បីទទួលនូវផ្លៃនៃធញ្ញជាតិដោយទង យ៉ាងណា សទ្ធានេះទទួលរស គឺ សមថៈ និងវិបស្សនា ដោយឫស គឺ សីល ធំធាត់ឡើងដើម្បីទទួលនូវកាណចាស់ក្លានៃធញ្ញជាត គឺ អរិយផល ដោយទង គឺ អរិយមគ្គ ដូច្នោះ ។ មួយទៀត ពូជនោះ តាំងនៅក្នុងផែនដីល្អ ចម្រើនលូតលាស់ដោយឫស ពន្លក ស្លឹក ទង និងត្រួយ ឲ្យកើតទឹកដោះ ឲ្យសម្រេចជាទងស្រូវសាលី និងពេញទៅដោយគ្រាប់ស្រូវសាលីជាច្រើន យ៉ាងណា សទ្ធានេះក៏ដូច្នោះ តាំងមាំនៅក្នុងចិត្តសន្តាន ចម្រើនលូតលាស់ល្អបរិបូណ៌ដោយវិសុទ្ធិ ៦ ឲ្យកើតទឹកដោះ គឺ ញាណទស្សនវិសុទ្ធិ ឲ្យសម្រេចជាព្រះអរហត្តផល ដែលបរិបូណ៌ទៅដោយបដិសម្ភិទាញាណជាអនេក ។ ដោយហេតុ

នោះ ទើបត្រាស់ថា **សទ្ធា ពីជំ** ដូច្នេះ ។ ប្រសិនបើនឹងមានពាក្យសួរថា ក៏កាលកុសលធម៌ជាង ៥០ កើតរួមគ្នា ហេតុដូចម្តេចទើបត្រាស់ថា **សទ្ធា ពីជំ** ដូច្នេះ ។ ឆ្លើយថា ព្រោះសទ្ធាធ្វើកិច្ចដូចជាពូជ ។ ប្រៀបដូចកុសលធម៌ទាំងនោះ វិញ្ញាណធ្វើកិច្ចដឹងច្បាស់ យ៉ាងណា សទ្ធាក៏ធ្វើនាទីដូចពូជ (ដើមហេតុ) ដូច្នោះ ។ ក៏សទ្ធានោះ ជាមូលនៃកុសលធម៌ទាំងពួង ។ ដូចដែលត្រាស់ទុកថា **សទ្ធាជាតោ ឧបសង្កមិ** សេចក្តីថា អ្នកមានសទ្ធាកាលចូលទៅរក រមែងអង្គុយជិត ។ល។ និងចាក់ធ្លុះកុសលធម៌នោះ ឃើញដោយបញ្ញា ។ ឈ្មោះថា **តបោ** ព្រោះដុតអកុសលធម៌ និងកាយ ។ ពាក្យថា **តបោ** នេះ ជាឈ្មោះរបស់ឥន្ទ្រិយសំវរៈ សេចក្តីព្យាយាម ធុតង្គៈ និងទុក្ករកិរិយា ។ តែក្នុងទីនេះបំណងយកឥន្ទ្រិយសំវរៈ ។ បទថា **វុដ្ឋិ** បានដល់ ភ្លៀងច្រើនយ៉ាងជាដើមថា ភ្លៀង ខ្យល់លាយភ្លៀង ។ ក្នុងទីនេះបំណងយកភ្លៀងឥតខ្យល់ ។ ដូចជាសន្ទូងរបស់ព្រាហ្មណ៍ មានពូជជាមូល មានទឹកភ្លៀងជាជំនួយយ៉ាងល្អ រមែងលូតលាស់ មិនក្រៀមស្វិត រមែងឲ្យសម្រេចផល យ៉ាងណា ធម៌ទាំងឡាយមានសីលជាដើម របស់ព្រះមានព្រះភាគ ក៏ដូច្នោះ មានសទ្ធាជាមូល មានឥន្ទ្រិយសំវរៈជាគ្រឿងឧបត្ថម្ភ រមែងចម្រើនលូតលាស់ល្អ មិនក្រៀមស្វិត និង

ឲ្យសម្រេចផល ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **តបោ វុដ្ឋិ** ដូច្នេះ ។ **មេ** ស័ព្ទ ដែលលោកពោលទុកក្នុងពាក្យថា **បញ្ញា មេ** នេះ គប្បីប្រកបសូម្បីក្នុងបទខាងដើមថា **សទ្ធា មេ ពីជំ តបោ មេ វុដ្ឋិ** ។ ដោយពាក្យនោះ ទ្រង់ត្រាស់សម្តែងទុកយ៉ាងណា ។ ទ្រង់ត្រាស់សម្តែងទុកថា ម្នាលព្រាហ្មណ៍ កាលស្រែដែលអ្នកសាបព្រោះទុកហើយ បើមានភ្លៀង ប្រការនោះជាការល្អ បើមិនមានភ្លៀងត្រូវបញ្ចូលទឹកមុន យ៉ាងណា តថាគតប្រើខ្សែ គឺចិត្ត ចងនឹម និងនង្គ័ល ដែលមានយាម គឺ ហិរិឲ្យជាប់គ្នា ទឹមគោ គឺ សេចក្តីព្យាយាម ចាក់ដោយជន្លួញ គឺ សតិ កាលសាបព្រោះពូជ គឺ សទ្ធា ចុះក្នុងស្រែ គឺ ចិត្តរបស់ខ្លួន ឈ្មោះថា ភ្លៀងមិនមាន តថាគតក៏ប្រើតបៈ គឺ ឥន្ទ្រិយសំវរៈអស់កាលជានិច្ច ជាទឹកភ្លៀង ដូច្នោះ ។ បទថា **បញ្ញា** បានដល់ បញ្ញាច្រើនយ៉ាង មានបញ្ញាជាចំណែកកាមាវចរជាដើម ។ តែក្នុងទីនេះ លោកបំណងមគ្គប្បញ្ញា ព្រមទាំងវិបស្សនា ។ បទថា **យុគនង្គលំ** បានដល់ នឹម និងនង្គ័ល ។ ប្រៀបដូចជាព្រាហ្មណ៍ មាននឹម និងនង្គ័ល យ៉ាងណា ព្រះ-មានព្រះភាគទ្រង់ក៏មានបញ្ញា ២ យ៉ាង ដូច្នោះ ។ ក្នុង ២ យ៉ាងនោះ នឹមរមែងជាទីអាស្រ័យរបស់ដងនង្គ័ល ខាងមុខជាប់ជាមួយដងនង្គ័ល ដែលជាទី

អាស្រ័យរបស់ខ្សែជន្ទោលឲ្យគោដើរទៅព្រមគ្នា យ៉ាងណា បញ្ញាក៏ដូច្នោះ រមែងជាទីអាស្រ័យនៃធម៌ទាំងឡាយ ដែលមានហិរិជាប្រធាន ដូច្នោះ ។ ដូចដែលលោកពោលទុកថា កុសលធម៌ទាំងអស់ប្រសើរទៅបានដោយបញ្ញា បណ្ឌិតទាំងឡាយតែងពោលថា បញ្ញាប្រសើរបំផុត ដូចបណ្ដាដួងទាំងឡាយ ព្រះចន្ទប្រសើរបំផុត ដូច្នោះ ឈ្មោះថា នៅខាងមុខ ព្រោះអត្ថថា ជាប្រធាននៃកុសលធម៌ ។ ដូចដែលលោកពោលទុកថា សីលក្ដី សិរីក្ដី និងធម៌របស់សប្បុរសទាំងឡាយ រមែងជាប់តាមបុគ្គលដែលមានបញ្ញា ។ តែបញ្ញារមែងជាប់ដោយហិរិដូចយាមនង្គ័ល ព្រោះមិនកើតឡើងដោយប្រាសចាកហិរិ រមែងជាទីអាស្រ័យនៃខ្សែ (គឺចិត្ត) ដោយជានិស្ស័យប្បច្ច័យរបស់ខ្សែ គឺ សមាធិពោលគឺ ចិត្ត រមែងជួយឲ្យគោ គឺ វីរិយៈ ដើរទៅព្រមគ្នា ព្រោះហាមការប្រារព្ធព្យាយាមពេក និងសេចក្ដីធូរថយពេក ។ នង្គ័លប្រកបដោយផាលរមែងទម្លាយកម្រាស់របស់ផែនដីក្នុងការភ្ជួរ ទម្លាយការជាប់នៃផែនដី យ៉ាងណា បញ្ញាដែលប្រកបដោយសតិ ក៏ដូច្នោះ រមែងទម្លាយកម្រាស់នៃអកុសលទាំងឡាយ ដែលមានកិច្ច គឺ ការប្រជុំនៃសន្តតិជាអារម្មណ៍ ក្នុងវេលាចម្រើនវិបស្សនា រមែងទម្លាយការបន្តនៃមូលរបស់កិលេសទាំងពួង និងបញ្ញានោះឯង

ជាលោកុត្តរៈតែម្យ៉ាង ។

ចំណែកបញ្ញាក្រៅពីនេះ ជាលោកិយៈ ។ ដោយហេតុនោះ ព្រះដ៏មាន-ព្រះភាគទើបត្រាស់ថា **បញ្ញា មេ យុគនង្គលំ** ។ ឈ្មោះថា **ហិរិ** ព្រោះខ្ពើមក្នុងធម៌ដ៏លាមក ។ ដោយការកាន់យកហិរិនោះ សូម្បីឱត្តប្បៈដែលមិនបានពោលនោះ ក៏លោកកាន់យកហើយដោយ **ហិរិ** ស័ព្ទនោះ ។

បទថា **ឦសា** (យាមនង្គ័ល) បានដល់ កំណាត់នៃដើមឈើសម្រាប់ភ្ជាប់ដងនង្គ័លទៅនឹងនឹម ។ ដូចជាយាមនង្គ័លរបស់ព្រាហ្មណ៍ រមែងភ្ជាប់ដងនង្គ័លជាមួយនឹងនឹម យ៉ាងណា សូម្បីហិរិរបស់ព្រះមានព្រះភាគក៏ដូច្នោះ រមែងទ្រទ្រង់ទុកនូវនឹម និងនង្គ័ល ពោលគឺ លោកិយបញ្ញា និងលោកុត្តរ-បញ្ញា ។ ឈ្មោះថា មិនមានហិរិ ក៏ព្រោះមិនមានបញ្ញា ។ សេចក្តីថា នឹមនិងដងនង្គ័ល ដែលជាប់ដោយយាមនង្គ័ល ធ្វើកិច្ចមិនធូរ មិនរលុង យ៉ាងណា បញ្ញាសូម្បីប្រកបដោយហិរិក៏ដូច្នោះ ធ្វើកិច្ចមិនញាប់ញ័រ មិនឃ្លេងឃ្លោង មិនរារាំងការមិនមានហិរិ ។ ដោយហេតុនោះ លោកទើបពោលថា **ហិរិ ឦសា** ដូច្នេះ ។ ឈ្មោះថា **មនៈ** ព្រោះអត្ថថា ដឹង ។ ពាក្យថា **មនៈ** នេះ ជាឈ្មោះរបស់ចិត្ត ។ តែក្នុងទីនេះ លោកបំណងយកសមាធិ ដែលប្រកបដោយមនៈ

នោះ ដោយលើកយកមនៈឡើងជាប្រធាន ។ បទថា **យោត្តំ** បានដល់ គ្រឿងចង គឺ ខ្សែ ។ ខ្សែនោះមាន ៣ យ៉ាង គឺ ជាគ្រឿងចងនឹមភ្ជាប់ជាមួយនឹងដងនង្គ័ល ១ ជាគ្រឿងចងគោជាមួយនឹម ១ ជាគ្រឿងចង គោបន្តមកនាយសារថី ១ ។

ក្នុង ៣ យ៉ាងនោះ ខ្សែរបស់ព្រាហ្មណ៍ រមែងធ្វើនង្គ័ល នឹម និងគោឲ្យបដិបត្តិក្នុងកិច្ចរបស់ខ្លួន យ៉ាងណា សមាធិរបស់ព្រះមានព្រះភាគ ក៏ដូច្នោះ ចងធម៌ គឺ ហិរិ បញ្ញា និងវីរិយៈទាំងអស់នោះទុកក្នុងអារម្មណ៍តែមួយជាមួយគ្នា ដោយសភាវៈ គឺ មិនបណ្តោយចិត្តឲ្យបដិបត្តិក្នុងនាទីរបស់ខ្លួន ។ ដោយហេតុនោះ ទើបត្រាស់ថា **មនោ យោត្តំ** ដូច្នេះ ។

ឈ្មោះថា **សតិ** ព្រោះអត្ថថា រលឹកដល់កិច្ចដែលធ្វើទុកមកយូរហើយជាដើមបាន ។ ឈ្មោះថា **ផាលៈ** ព្រោះអត្ថថា ពុះ ។ ឈ្មោះថា **បាជនៈ** ព្រោះអត្ថថា ជាគ្រឿងដេញទៅ ។ ក្នុងទីនេះលោកពោលថា **បាចនៈ** ។ បទថា **បាចនៈ** នោះ ជាឈ្មោះរបស់ជន្លួញ ។ ផាល និងជន្លួញ ឈ្មោះថា **ផាល-បាចនៈ** ។ សតិដែលប្រកបដោយវិបស្សនា និងប្រកបដោយមគ្គរបស់ព្រះមាន-ព្រះភាគ ប្រៀបដូចជាផាល និងជន្លួញរបស់ព្រាហ្មណ៍ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្តីនោះ ដូចតទៅនេះ ៖

សតិស្វែងរកគតិរបស់កុសល និងអកុសលធម៌ទាំងឡាយ ឬចូលទៅតាំងទុកក្នុងអារម្មណ៍ សតិរមែងរក្សានង្គ័ល គឺ បញ្ញា ដូចផាលរក្សាផ្ទៀងនង្គ័ល និងទៅខាងមុខផ្ទៀងនង្គ័លនោះ ។ ដោយហេតុនោះឯង សតិនោះ លោកទើបពោលថា **អារក្ខា** ជាគ្រឿងរក្សា ដូចក្នុងប្រយោគមានជាដើមថា **សតារក្ខេន ចេតសា វិហរតិ** ជាអ្នកនៅដោយចិត្ត និងសតិជាគ្រឿងរក្សា ដូច្នេះ ។ ក៏បញ្ញានោះ មានសតិនៅខាងមុខ ធ្វើមិនឲ្យវង្វេងភ្លេច ព្រោះថា បញ្ញា រមែងជាក់ច្បាស់ក្នុងធម៌ដែលសតិអប់រំហើយ មិនមែនដោយសេចក្តីវង្វេងភ្លេច ។ ដូចជាជន្ទញ សម្តែងក័យ គឺ ការចាក់គោទាំងឡាយ មិនឲ្យខ្ជិលប្រអូស និងការពារគោមិនឲ្យដើរខុសគន្លង យ៉ាងណា សតិក៏ដូច្នោះ សម្តែងក័យ គឺ អបាយដល់គោ គឺ វីរិយៈ មិនឲ្យខ្ជិលប្រអូស ការពារការត្រាច់ទៅ ពោលគឺ កាមគុណ ហើយប្រកបទុកក្នុងកម្មដ្ឋាន ការពារការដើរចេញក្រៅផ្លូវ ។ ដោយហេតុនោះទើបត្រាស់ថា **សតិ មេ ផាលបាចនំ** ដូច្នេះ ។

បទថា **កាយគុត្តោ** បានដល់ ឃុំគ្រងដោយកាយសុចរិត ៣ យ៉ាង ។ បទថា **វចីគុត្តោ** បានដល់ ឃុំគ្រងដោយវចីសុចរិត ៤ យ៉ាង ។ ក៏ដោយពាក្យ

មានប្រមាណប៉ុណ្ណោះ ជាការដែលលោកពោលបាតិមោក្ខសំវរៈសីលហើយ ។ ក្នុងបទថា **អាហារេ ឧទរេ យតោ** នេះ មានសេចក្ដីថា សង្រួមក្នុងបច្ច័យទាំង ៤ យ៉ាង ព្រោះលោកសង្គ្រោះបច្ច័យគ្រប់យ៉ាងដោយមុខ គឺ អាហារ អធិប្បាយថា សង្រួមហើយ គឺ ប្រាសចាកឧបក្កិលេស ។ ដោយពាក្យនេះ ក៏ជាការដែលលោកពោលអាជីវបារិសុទ្ធិសីលហើយ ។ បទថា **ឧទរេ យតោ** បានដល់ សង្រួមផ្ទៃ គឺ សង្រួមក្នុងការបរិភោគល្មមប្រមាណ ។ លោកអធិប្បាយទុកថា ស្គាល់ប្រមាណក្នុងអាហារ ។ ដោយមុខ គឺ ភាពជាអ្នកស្គាល់ប្រមាណក្នុងការបរិភោគនេះ ជាការដែលលោកពោលដល់ការសេពចំពោះ បច្ចយសន្និស្សិតសីលហើយ ។ សួរថា ដោយប្រការនោះ លោកសម្ដែងសេចក្ដីយ៉ាងណា ។ ឆ្លើយថា លោកសម្ដែងសេចក្ដីថា ម្នាលព្រាហ្មណ៍ អ្នកសាបព្រោះពូជហើយ លោមព័ទ្ធដោយរបងបន្ទា របងដើមឈើ ឬកំផែង ដើម្បីរក្សាសន្ទូង ហ្វូងគោ ក្របី និងម្រឹកទាំងឡាយ ចូលទៅបៀតបៀនសន្ទូងមិនបាន ព្រោះការលោមព័ទ្ធនោះ យ៉ាងណា តថាគតក៏ដូច្នោះ សាបព្រោះពូជ គឺ សទ្ធាជាច្រើនហើយ លោមព័ទ្ធរបង ៣ ជាន់ បានដល់ ឃុំគ្រងកាយ ឃុំគ្រងវាចា និងឃុំគ្រងអាហារ ដើម្បីរក្សាកុសលធម៌នានា ហ្វូងគោ ក្របី និងម្រឹគ ពោលគឺ

អកុសលធម៌ មានរាគៈជាដើម ចូលទៅបៀតបៀនសន្ដានមិនបាន គឺ កុសលនានារបស់តថាគត ព្រោះការលោមព័ទ្ធនោះ ។ ការនិយាយមិនខុស ដោយអាការ ២ យ៉ាង ឈ្មោះថា សច្ចៈ ក្នុងពាក្យថា **សច្ចំករោមិ និទ្ទានំ** នេះ ។ បទថា **និទ្ទានំ** បានដល់ កាត់ ជម្រះ ដក ។ ឯពាក្យនេះ គប្បីជ្រាបថា ជាទុតិយាវិភត្តិប្រើក្នុងអត្ថនៃតតិយាវិភត្តិ ។ ក៏ក្នុងពាក្យនេះ មានសេចក្ដីដូច្នេះថា តថាគតជម្រះស្មៅដោយសច្ចៈ ។ ពាក្យនេះ មានអធិប្បាយថា អ្នកធ្វើការក្នុរខាងក្រៅ ប្រើដៃ ឬកាំបិត ជម្រះស្មៅដែលធ្វើសន្ដូនឲ្យវិនាស យ៉ាងណា សូម្បីតថាគតក៏ដូច្នោះ ក្នុរក្នុងខាងក្នុងហើយ ញ៉ាំងសច្ចៈជម្រះស្មៅ គឺ ការពោលពាក្យកុហកដែលប្រទូសរ៉ាយដល់សន្ដាន គឺ កុសល ។ម្យ៉ាងវិញទៀត គប្បីជ្រាបសច្ចៈ ក្នុងពាក្យថា **សច្ចំករោមិ និទ្ទានំ** នេះ សំដៅយក **យថាភូតញ្ញាណ** ។ លោកសម្ដែងថា តថាគតធ្វើការជម្រះស្មៅ មានអត្តសញ្ញាជាដើម ដោយ **យថាភូតញ្ញាណ** នោះ ។ ម្យ៉ាងទៀត បទថា **និទ្ទានំ** សេចក្ដីថា កាត់ ជម្រះ ដកឡើង ។ លោកសម្ដែងថា អ្នកប្រើទាសៈ ឬកម្មករឲ្យសម្លាប់ គឺ កាត់ ជម្រះ ដកស្មៅទាំងឡាយ ដោយពាក្យថា ចូរជម្រះស្មៅទាំងឡាយ យ៉ាងណា តថាគតក៏ដូច្នោះ ប្រើសច្ចៈជម្រះស្មៅ ។ ម្យ៉ាងទៀត បទថា **សច្ចំ**

បានដល់ ទិដ្ឋិសច្ចៈ ។ សេចក្ដីថា តថាគតធ្វើការជម្រះស្មៅនោះ គឺ កាត់វត្ថុ ដែលគួរកាត់ ជម្រះវត្ថុដែលគួរជម្រះ ដកវត្ថុដែលគួរដក ។ ក្នុងវិកប្បទាំង ២ នេះ គួរប្រកបសេចក្ដីដោយទុតិយាវិភត្តិប៉ុណ្ណោះ ។

ក្នុងពាក្យថា **សោរច្ចំ មេ បមោចនំ** នេះ សីល គឺ ការមិនកន្លង ល្មើសផ្លូវកាយ ការមិនកន្លងល្មើសផ្លូវវាចាទាំងឯង លោកពោលថា **សោរច្ច** ប្រការនោះលោកមិនបំណង ។ ក៏ពាក្យថា **សោរច្ចំ** នោះ លោកពោលទុក ដោយពាក្យថា **កាយគុត្តោ** ជាដើមប៉ុណ្ណោះ ។ តែលោកបំណងយកអរហត្ត-ផល ។ ក៏ព្រះអរហត្តផលនោះ លោកហៅថា សោរច្ចៈ ព្រោះត្រេកអរក្នុង ព្រះនិព្វាន ។ បទថា **បមោចនំ** បានដល់ លះបង់យោគកិលេសដែលជា គ្រឿងប្រកប ។ ពាក្យនេះ មានអធិប្បាយថា ការឈប់សម្រាករបស់អ្នក រមែង មិនជាការឈប់សម្រាកឡើយ ព្រោះត្រូវប្រកបក្នុងវេលាល្ងាច ក្នុងថ្ងៃទីពីរ ឬក្នុងឆ្នាំមុខទៀត យ៉ាងណា ការឈប់សម្រាករបស់តថាគតមិនដូច្នោះទេ ។ ដែលឈ្មោះថា ការឈប់សម្រាកក្នុងចន្លោះរបស់តថាគតមិនមានទេ ។ ព្រោះ តថាគតទីមគោ គឺ សេចក្ដីព្យាយាម ដោយនង្គ័ល គឺ បញ្ញា ចាប់តាំងពីព្រះ ទសពលព្រះនាមថា **ទីបង្ករ** ការក្ដួរដ៏ធំអស់បួនអសង្ខេយ្យមួយសែនកប្ប ក៏

មិនទាន់រួចផុត ដរាបណានៅមិនទាន់សម្រេចសម្មាសម្ពោធិញ្ញាណ ។ ក៏កាលណាតថាគតញុំាងវេលាទាំងអស់ ឲ្យអស់ទៅដោយការអង្គុយលើអបរាជិត-បល្ល័ង្កត្រង់មណ្ឌលពោធិព្រឹក្ស កាលនោះ ព្រះអរហត្តផលដែលមានគុណទាំងពួងជាបរិវារក៏កើតឡើង តថាគតរួចស្រឡះដោយព្រះអរហត្តផលនោះ ហើយបានរម្ងាប់សេចក្តីខ្វល់ខ្វាយគ្រប់យ៉ាង ឥឡូវនេះ តថាគតនឹងមិនព្យាយាមតទៅទៀត ទ្រង់សំដៅសេចក្តីដូចដែលពោលមកនេះ ទើបត្រាស់ថា **សោរច្ចំ មេ បមោចនំ** ។

បទថា **វីរិយំ** ក្នុងពាក្យថា **វីរិយំ មេ ធុរធោរយ្ហំ** នេះ បានដល់ ការប្រារព្ធសេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **ធុរធោរយ្ហំ** សេចក្តីថា នាំទៅនូវធុរៈ អធិប្បាយថា នាំធុរៈទៅ ដូចជា នង្គ័លរបស់ព្រាហ្មណ៍ ដែលអូសទៅ ឬទាញទៅនូវធរៈ រមែងទម្លាយផែនដី និងការបន្តនៃអាចម៍បំណាស់យ៉ាងណា នង្គ័ល គឺ បញ្ញា ដែលព្រះមានព្រះភាគនាំមកដោយសេចក្តីព្យាយាមក៏ដូច្នោះ រមែងទម្លាយកិលេសតាមដែលពោលហើយ និងទម្លាយការបន្តនៃកិលេស ។ ដោយហេតុនោះ លោកទើបពោលថា **វីរិយំ មេធុរធោរយ្ហំ** ។ម្យ៉ាងទៀត សភាវៈដែលនាំធុរៈខាងដើមទៅ ឈ្មោះថា ធុរៈ សភាវៈដែលនាំ

ធុរៈពីដើមទៅ ឈ្មោះថា **ធោរយ្ហា** ធុរៈ និងធោរយ្ហៈ ឈ្មោះថា **ធុរធោរយ្ហ** ធុរធោរយ្ហៈ ដែលផ្សងគ្នាដោយគោ ៤ ក្បាល ក្នុងនង្គ័លតែមួយរបស់ព្រាហ្មណ៍ កាលនាំទៅ ធ្វើនាទីកម្ចាត់ឫសស្មៅដែលកើតឡើង និងធ្វើសេចក្តីបរិបូណ៌នៃសន្ទូងឲ្យសម្រេច យ៉ាងណា ធុរធោរយ្ហៈ ដែលផ្សងដោយសេចក្តីព្យាយាម គឺ សម្មប្បធាន ៤ របស់ព្រះមានព្រះភាគក៏ដូច្នោះ កាលនាំមក រមែងធ្វើនាទីកម្ចាត់អកុសលដែលកើតឡើងហើយ និងធ្វើសេចក្តីបរិបូណ៌នៃកុសលឲ្យបានសម្រេច ។ ព្រោះហេតុនោះ ទើបពោលថា **វីរិយំ មេ ធុរធោរយ្ហំ** ដូច្នេះ ។

ក្នុងពាក្យថា **យោគក្ខេមាធិវាហនំ** នេះ មានវិនិច្ឆ័យថា ព្រះនិព្វាន ឈ្មោះថា យោគក្ខេមៈ ព្រោះជាដែនក្សេមអំពីយោគៈទាំងឡាយ ។ ព្រះនិព្វាននោះ ឈ្មោះថា **អធិវាហន** ព្រោះនាំទៅដោយចំពោះ ឬថា នាំទៅចំពោះមុខ ការនាំទៅចំពោះមុខនូវធម៌ដែលក្សេមចាកយោគៈ ឈ្មោះថា **យោគក្ខេមាធិ-វាហន** ។ លោកពោលពាក្យអធិប្បាយទុកដូច្នេះថា ធុរធោរយ្ហៈ របស់អ្នកដែលនាំឆ្ពោះទៅកាន់ទិសណាមួយ មានបុរត្ថិមទិសជាដើម យ៉ាងណា ធុរធោ-រយ្ហៈរបស់តថាគត រមែងនាំឆ្ពោះទៅកាន់ព្រះនិព្វាន ក៏ដូច្នោះ ។ ធុរធោរយ្ហៈ ដែលតថាគតនាំទៅយ៉ាងនេះ ឈ្មោះថា ទៅមិនវិលត្រឡប់ គឺ ទៅ ចាប់តាំង

ពីវេលាដែលព្រះពុទ្ធព្រះនាមថា **ទីបង្ករ** ឈ្មោះថា ទៅមិនវិលត្រឡប់ មិនដូចធុរពេរឃ្ញៈ (របស់អ្នក) នាំទង្គ័លទៅដល់ស្រែ ក៏នៅតែត្រឡប់មកវិញទៀត ។ ម្យ៉ាងទៀត ព្រោះកិលេសដែលតថាគតលះបង់បានដោយមគ្គនោះ ៗ មិនចាំបាច់លះបង់ទៀត ដូចស្មៅដែលក្ជួរដោយនង្គ័លរបស់អ្នក ក៏ត្រូវក្ជួរក្នុងវេលាតមកទៀត ដូច្នោះ ធុរធោរឃ្ញៈកម្ចាត់ស្មៅ គឺ កិលេសដែលឃើញហើយដោយបឋមមគ្គ លះកិលេសគ្រោតគ្រាតដោយទុតិយមគ្គ លះកិលេសដែលជាអនុស័យដោយតតិយមគ្គ លះកិលេសគ្រប់យ៉ាងដោយចតុត្ថមគ្គ ទៅមិនវិលត្រឡប់ដោយអាការយ៉ាងនេះ ។ ម្យ៉ាងទៀត បទថា **គច្ឆតិអនិវត្តំ** សេចក្តីថា ជាធម្មជាតិវៀរការវិលត្រឡប់មកវិញ ។ បទថា **តំ** ក្នុងពាក្យថា **តំ ធុរ-ធោរយ្ហំ** នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះ ក៏ធុរធោរឃ្ញៈរបស់តថាគត កាលទៅដោយប្រការដែលធុរធោរឃ្ញៈរបស់អ្នកមិនទៅកាន់ទីនោះ តែធុរធោរឃ្ញៈរបស់តថាគតនោះ រមែងទៅកាន់ស្រែដែលមិនសោកសៅ ប្រាសចាកធូលី មិនសោយសោក ។ បទថា **យត្ថ គន្ត្វា នសោចតិ** សេចក្តីថា អ្នកស្រែដូចតថាគត ជាស់តឿនការនាំធុរៈទៅដោយសេចក្តីព្យាយាមនោះដោយជន្ទញ គឺសតិ ទៅក្នុងទីណាមិនសោកសៅ ប្រាសចាកធូលី មិនសោយសោកក្នុងទី

នោះទាំងអស់ ពោលគឺ អមតនិព្វាន ដែលជាទីដកកូនសរ គឺ សេចក្តីសោក ។ ឥឡូវនេះ កាលនឹងទ្រង់បញ្ជាក់បទខាងចុង ទើបត្រាស់គាថាថា **ឯវមេសា កសី** ដូច្នេះជាដើម ។ ប្រការនោះ មានសេចក្តីសង្ខេបដូចតទៅនេះ ៖

ចូរឃើញចុះ ព្រាហ្មណ៍ ពូជ គឺ សទ្ធា ទឹកភ្លៀង គឺ តបៈ ជួយជាជំនួយដល់ការនង្គ័ល តថាគតប្រើខ្សែ គឺ ចិត្ត ចងនឹម និងនង្គ័ល គឺ បញ្ញា និងយាមនង្គ័ល គឺ ហិរិទុកជាមួយគ្នា ប្រើនង្គ័ល គឺ បញ្ញាពុះបំបែក ដោយផាល គឺ សតិ ជេញដោយជន្លួញ គឺ សតិ ឃុំគ្រងកាយវាចា និងអាហារ ប្រើសច្ចៈជាគ្រឿងជម្រះស្មៅ នាំធុរធោរយ្ហៈ គឺ សេចក្តីព្យាយាម ឲ្យកើតសោរច្ចៈឆ្ពោះត្រង់ព្រះនិព្វានដែលជាដែនក្សេមចាកយោគៈ មិនត្រឡប់វិញ ការភ្ជួរ មានសាមញ្ញផល ៤ យ៉ាង ដែលជាទីបំផុតនៃការងារ ដូច្នេះ ។ បទថា **សា ហោតិ អមតប្ផលា** សេចក្តីថា ការភ្ជួរនេះ រមែងមានផលជាអមតៈ ។ ព្រះនិព្វាន លោកហៅថា អមតៈ ។ អធិប្បាយថា ការភ្ជួរនោះ មានព្រះនិព្វានជាអានិសង្ស ។ ការភ្ជួរនេះ នឹងមានផលជាអមតៈចំពោះតថាគត អ្នកម្នាក់ប៉ុណ្ណោះក៏មិនមែន អ្នកណាៗ ទោះជាក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ ក៏ដោយ គ្រហស្ថ ឬបព្វជិតក៏ដោយ ភ្ជួរយ៉ាងនេះ កាលភ្ជួរយ៉ាងនេះហើយ

គេទាំងអស់នោះ រមែងរួចផុតចាកទុក្ខទាំងពួងដោយពិត ។

ព្រះមានព្រះភាគទ្រង់ត្រាស់ទេសនាដល់ព្រាហ្មណ៍ លើកយកព្រះនិព្វានសម្តែងជាខាងក្រោយ និងបញ្ចប់ឲ្យដល់កំពូល គឺ ព្រះអរហត្ត ដោយប្រការដូច្នេះ ។ បន្ទាប់ពីព្រាហ្មណ៍ស្តាប់ព្រះធម្មទេសនា ដែលមានសេចក្តីជ្រាលជ្រៅហើយ ជ្រាបថា អ្នកបរិភោគផលនៃការភ្ជួររស្រែរបស់យើង រមែងនឹងស្រេកឃ្លានក្នុងថ្ងៃស្អែកដោយពិត តែអ្នកបរិភោគផលនៃការភ្ជួររដែលជាអមតៈនេះ រមែងរួចផុតចាកទុក្ខទាំងពួង ដូច្នេះ ព្រាហ្មណ៍មានសេចក្តីជ្រះថ្លា កាលនឹងសម្តែងអាការជ្រះថ្លា ទើបពោលពាក្យជាដើមថា **ភុញ្ជតុ ភវំ គោតមោ** ដូច្នេះ ។ ពាក្យទាំងអស់និងពាក្យក្រៅពីនោះ ខ្ញុំអធិប្បាយសេចក្តីទុកហើយនោះឯង ។

ចប់អដ្ឋកថា កសិសូត្រទី ១

# អ ដ្ឋ ក ថា

## ឧទយសូត្រទី ២

ឧទយសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៥៦] បទថា **ឱទនេន បូរេសិ** សេចក្តីថា ព្រាហ្មណ៍យកបាយព្រមទាំងសម្ល និងភោជនដែលគេចាត់ចែងទុកដើម្បីខ្លួន ដាក់បាត្រដរាបដល់ពេញ ហើយថ្វាយ ។ បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់ត្រួតមើលលោកក្នុងវេលាជិតភ្លឺ ទ្រង់ឃើញព្រាហ្មណ៍នោះ ទ្រង់បដិបត្តិព្រះសរីរៈតាំងពីព្រឹក ស្តេចចូលព្រះគន្ធកុដិ ទ្រង់បិទទ្វារ ហើយប្រថាប់គង់ ទ្រង់ឃើញភោជនដែលគេលើកចូលទៅទុកជិតព្រាហ្មណ៍ ព្រះអង្គតែមួយអន្លើប៉ុណ្ណោះ ទ្រង់ស្ពាយបាត្រនឹងស្មាស្តេចចេញចាកព្រះគន្ធកុដិ ស្តេចដល់ទ្វារព្រះនគរ ទ្រង់នាំបាត្រចេញ ហើយស្តេចចូលខាងក្នុងព្រះនគរ ទ្រង់ស្តេចយាងទៅតាមលំដាប់ ប្រថាប់ឈរត្រង់ខាងទ្វារផ្ទះរបស់ព្រាហ្មណ៍ ។ ព្រាហ្មណ៍ឃើញព្រះមានព្រះភាគហើយ បានថ្វាយភោជនដែលគេចាត់ចែងទុកដើម្បីខ្លួន ។ បទថា **ឱទនេន បុរេសិ** នេះលោកសំដៅយកភោជននោះ ។

**[១៥៧]** បទថា **ទុតិយម្បិ** បានដល់ សូម្បីក្នុងថ្ងៃទី ២ ។ បទថា **តតិ-យម្បិ** បានដល់ សូម្បីក្នុងថ្ងៃទី ៣ បានឮថា ក្នុងវាងដែលព្រះមានព្រះភាគស្តេចទៅកាន់ផ្ទះរបស់ព្រាហ្មណ៍ជាប់ៗ គ្នារហូតដល់អស់ ៣ ថ្ងៃ ក៏មិនមានអ្នកណាៗ ដែលអាចនឹងក្រោកឡើងទទួលបាត្របាន ។ មហាជនបានត្រឹមតែឈរមើលដូចគ្នា ។

**[១៥៨]** បទថា **ឯតទវោច** សេចក្តីថា ព្រាហ្មណ៍សូម្បីថ្វាយដរាបពេញបាត្ររហូតដល់អស់ ៣ ថ្ងៃ ក៏មិនបានថ្វាយដោយសទ្ធា ។ ព្រាហ្មណ៍បរិភោគដោយមិនបានថ្វាយ សូម្បីត្រឹមតែកិក្ខាដល់បព្វជិតដែលមកឈរត្រង់ទ្វារផ្ទះ តែបានថ្វាយព្រោះខ្លាចត្រូវតិះដៀលថា បព្វជិតមកឈរដល់ទ្វារផ្ទះហើយសូម្បីត្រឹមតែកិក្ខាក៏មិនថ្វាយ បរិភោគតែម្នាក់ឯង ដូច្នេះ ។ និងកាលថ្វាយ ២ ថ្ងៃដំបូង ថ្វាយហើយមិនបាននិយាយអ្វីៗ ឡើយ ក៏ត្រឡប់ចូលផ្ទះ ។ ទាំងព្រះមានព្រះភាគក៏ទ្រង់មិនបានត្រាស់អ្វីៗ ដូចគ្នា ស្តេចចៀសចេញទៅ តែក្នុងថ្ងៃទី ៣ ព្រាហ្មណ៍មិនអាចនឹងអត់ទ្រាំបាន ទើបបានពោលពាក្យនេះថា បក-ដ្ឋកោ ដូច្នេះជាដើម ។ សូម្បីព្រះមានព្រះភាគ ស្តេចក៏បានយាងទៅដរាបដល់ ៣ ដង ក៏ដើម្បីនឹងឲ្យគេថ្លែងវាចានោះឯង ។

បណ្តាបទទាំងនោះ បទថា **បកដ្ឋក្វាយ** បានដល់ ជាប់ក្នុងរស ។

**[១៥៩]** ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ព្រាហ្មណ៍ហើយ ត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកថ្វាយបិណ្ឌបាតរហូតដល់អស់ ៣ ថ្ងៃ អ្នកនៅតែរួញរាក្នុងលោកមានធម៌ ១៦ ប្រការ ដែលគួរធ្វើរឿយៗ ដូច្នេះ ដើម្បីនឹងទ្រង់សម្តែងធម៌ទាំងនោះ ទើបទ្រង់ផ្តើមព្រះធម៌ទេសនានេះថា **បុនប្បុនំ ចេវ វបន្តិ ពីជំ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **បុនប្បុនំ ចេវ វបន្តិ** លោកពោលទុកក្នុងសស្សវារៈមួងហើយ សូម្បីក្នុងសស្សវារៈ (វារៈពោលអំពីសន្ទូង) ដទៃៗ អ្នកស្រែរមែងសាបព្រោះដោយមិនរួញរាឡើយថា ប៉ុណ្ណេះល្មម ដូច្នេះ ។ បទថា **បុនប្បុនំ វស្សតិ** សេចក្តីថា មិនមែនភ្លៀងមួយថ្ងៃឈប់ ។ ភ្លៀងហើយភ្លៀងទៀតៗ រាល់ៗ ថ្ងៃ គ្រប់ៗ ឆ្នាំ ជនបទរមែងស្តុកស្តមដោយអាការយ៉ាងនេះ ។ គប្បីជ្រាបន័យនៃសេចក្តីក្នុងគ្រប់ៗ បទ ដោយឧបាយនេះ ។

ក្នុងបទថា **យាចកា** នេះ ព្រះសាស្តាទ្រង់សម្តែងអាងដល់ព្រះអង្គព្រោះព្រះអង្គទ្រង់ឆ្ងាតក្នុងទេសនា ។ បទថា **ខីរណិកា** បានដល់ អ្នករូតទឹកដោះគោ ព្រោះទឹកដោះជាហេតុ ។ ពិតណាស់ ជនទាំងនោះមិនប្រាថ្នាទឹកដោះតែម្តងប៉ុណ្ណោះ អធិប្បាយថា រមែងប្រាថ្នារូតទឹកដោះរឿយៗ ។ បទថា **កិលមតិ**

ផន្ទតិ ច សេចក្តីថា សត្វនេះ រមែងលំបាក នឹងញាប់ញ័រដោយឥរិយាបថ នោះៗ ។ បទថា គត្តំ បានដល់ ផ្ទៃសត្តតិរច្ឆានមានសុនខស្រុក និងចចក ជាដើម ។ បទថា សីវថិកំ បានដល់ ព្រៃជាទីចោលសាកសព ។ អធិប្បាយថា នាំសត្វដែលស្លាប់ហើយ ទៅកាន់ព្រៃជាទីចោលសាកសពនោះរឿយៗ ។ បទថា មគ្គញ្ច លទ្ធាអបុនព្ភវាយ សេចក្តីថា ព្រះនិព្វាន ឈ្មោះថា មគ្គ ព្រោះមិន កើតទៀត អធិប្បាយថា បានព្រះនិព្វាននោះ ។

**[១៦០]** បទថា ឯវំ វុត្តេ សេចក្តីថា កាលព្រះមានព្រះភាគ ប្រថាប់ ឈរត្រង់ចន្លោះថ្នល់ទុំះឯង ទ្រង់សម្តែង បុនប្បុនធម៌ ១៦ ប្រការ បានត្រាស់ យ៉ាងនេះ ។ បទថា ឯតទវោច សេចក្តីថា ក្នុងទីបំផុតទេសនា ព្រាហ្មណ៍ ព្រមទាំងបុត្រភរិយា ពួកមិត្ត និងញាតិ ជ្រះថ្លាថ្វាយបង្គំទៀបព្រះយុគលបាទ របស់ព្រះមានព្រះភាគ ពោលពាក្យនេះថា អភិក្កន្តំ ភោ ជាដើម ។

ចប់អដ្ឋកថា ឧទយសូត្រទី២

# អ ដ្ឋ ក ថា

## ទេវហិតសូត្រទី ៣

*ទេវហិតសូត្រទី ៣* មានវិនិច្ឆ័យដូចតទៅនេះ ៖

**[១៦១]** *បទថា* ***វាតេហិ*** *បានដល់ ដោយខ្យល់ក្នុងព្រះឧទរ ។ បាន ឮមកថា កាលព្រះមានព្រះភាគទ្រង់ធ្វើទុក្ករកិរិយា ៦ វស្សា ទ្រង់នាំយកសណ្ដែកបាយ និងសណ្ដែកជ្រូងជាដើម មួយក្ដាប់ៗ មកសោយ ខ្យល់ក្នុងព្រះឧទរក៏កម្រើកឡើង ព្រោះសោយមិនល្អ និងផ្ទុំលំបាក ។ សម័យតមក ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ សូម្បីសោយភោជនដ៏ប្រណីត អាពាធនោះក៏នៅប្រាកដជារឿយៗ ពាក្យនេះ លោកពោលសំដៅយកអាពាធនោះ ។ បទថា* ***ឧបដ្ឋាកោ ហោតិ*** *សេចក្ដីថា ព្រះឧបវានត្ថេរជាឧបដ្ឋាកក្នុងសម័យដែលមិនទាន់មានឧបដ្ឋាកពិតប្រាកដក្នុងបឋមពោធិកាល ។ បានឮថា ក្នុងវេលានោះ បណ្ដាព្រះអសីតិមហាថេរៈ អ្នកដែលមិនធ្លាប់ជាឧបដ្ឋាករបស់ព្រះសាស្ដាមិនមាន ។ ក៏ព្រះថេរៈទាំងនេះ គឺ ព្រះនាគសមនៈ ព្រះឧបវាណៈ ព្រះសុនក្ខត្តៈ ព្រះចុន្ទៈ ព្រះសមណុទ្ទេសៈ ព្រះសាគតៈ ព្រះមេឃិយៈ ជាឧបដ្ឋានដែលមាន*

ឈ្មោះមកក្នុងបាលី តែក្នុងវេលានេះ ព្រះឧបវាណត្ថេរក្រោកឡើងពីព្រឹកព្រលឹម បានបម្រើព្រះមានព្រះភាគគ្រប់យ៉ាង ដូចជា បោសបរិវេណ ថ្វាយឈើជម្រះព្រះទន្ត ចាត់ចែងថ្វាយទឹកស្រង់ កាន់បាត្រចីវរតាមព្រះអង្គ ។ បទថា **ឧបសង្កមិ** សេចក្តីថា បានឮថា រហូតដល់អស់វេលា ២០ ឆ្នាំ ក្នុងបឋមពោធិកាល ព្រៃប្រាសចាកផ្សែងភ្លើង (ដែលកើតពីភិក្ខុ) សូម្បីព្រះមានព្រះភាគក៏ទ្រង់មិនទាន់បានអនុញ្ញាត ការដាំទឹកដល់ភិក្ខុទាំងឡាយ ក៏ព្រាហ្មណ៍នោះឲ្យធ្វើចង្ក្រានជាជួរ លើកភាជនៈធំៗ តាំងលើចង្ក្រាន ឲ្យដាំទឹកក្តៅ ហើយលាយទឹកក្តៅព្រមទាំងកម្ទេចផង់សម្រាប់ងូតទឹកជាដើម ចិញ្ចឹមជីវិត ។ អ្នកប្រាថ្នាងូតទឹកទៅក្នុងទីនោះ ហើយឲ្យតម្លៃ ងូតទឹកលាបស្រឡាប ដោយរបស់ក្រអូបប្រដាប់ផ្កាឈើហើយចៀសចេញទៅ ។ ព្រោះដូច្នោះ ព្រះថេរៈទើបចូលទៅកាន់ទីនោះ ។

**[១៦២]** បទថា **កឹ បត្ថយានោ** បានដល់ ប្រាថ្នាអ្វី ។ បទថា **កឹ ឯសំ** បានដល់ ស្វែងរកអ្វី ។

**[១៦៣]** បទថា **បូជិតោ បូជនេយ្យានំ** សេចក្តីថា ព្រះថេរៈផ្តើមពោលសរសើរព្រះទសពល ។ លោកពោលពាក្យនេះទុកថា បានឮថា ព្រះថេរៈទៅ

ដើម្បីគិលានភេសជ្ជៈ ពោលសរសើរភិក្ខុឈឺ ដូច្នេះ ។ ពិតណាស់ ពួកមនុស្ស បានស្តាប់ពាក្យសរសើរហើយ រមែងសម្គាល់ភេសជ្ជៈ ដែលគួរថ្វាយដោយគោរព ។ ភិក្ខុឈឺបានភេសជ្ជៈដែលជាទីសប្បាយហើយ រមែងបាត់ឈឺយ៉ាងឆាប់រហ័ស សេចក្តីពិត កាលនឹងពោល មិនគួរពោលឲ្យទាក់ទងដល់ឈានវិមោក្ខ សមាបត្តិ និងមគ្គផល ។ តែគួរពោលអាគមនីយបដិបទាយ៉ាងនេះ គឺ អ្នកមានសីល មានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀស ពហុស្សូត ជាអ្នកទ្រទ្រង់បរិយត្តិ ជាអ្នករក្សាអរិយវង្ស ។ បទថា **បូជនេយ្យានំ** សេចក្តីថា ព្រះអសីតិមហាថេរៈ ឈ្មោះថា **បូជនេយ្យា** ព្រោះមនុស្សលោកព្រមទាំងទេវលោកគួរបូជា ។ ព្រះថេរៈទាំងនោះឯង ឈ្មោះថា **សក្ករេយ្យា** ព្រោះគួរដល់សក្ការៈ ឈ្មោះថា **អបចិនេយ្យា** ព្រោះគួរធ្វើការនមស្ការដល់លោកទាំងនោះដោយពិត ។ ព្រះថេរៈកាលប្រកាសគុណរបស់ព្រះមានព្រះភាគនោះថា ព្រះមានព្រះភាគ ជាអ្នកដែលទេវតា និងមនុស្សទាំងនោះគួរបូជា គួរគោរព គួរកោតក្រែង ដូច្នេះ ទើបពោលយ៉ាងនេះ ។ បទថា **ហាតវេ** ប្រែថា ដើម្បីនាំទៅ ។

**[១៦៤]** បទថា **ផាណិតស្ស ច បុដំ** បានដល់ ដុំស្ករអំពៅធំ ដែល

ប្រាសចាកកម្មេចផេះ បានឮថា ព្រាហ្មណ៍នោះសួរថា ព្រះសមណគោតមទ្រង់មិនសប្បាយព្រោះអ្វី បានជ្រាបថា ព្រោះខ្យល់ក្នុងព្រះឧទរ ទើបពោលថា បើដូច្នោះ ពួកយើងស្គាល់ថ្នាំក្នុងរឿងនេះ ឥឡូវនេះ សូមលោកម្ចាស់ចូរយកទឹកបន្តិច លាយនឹងស្ករអំពៅនេះ ថ្វាយឲ្យទ្រង់សោយក្នុងវេលាស្រង់ទឹករួចហើយ ព្រះសេទនឹងចេញមកខាងក្រៅព្រះសរីរៈដោយទឹកក្តៅ ខ្យល់ក្នុងព្រះឧទរនឹងបាត់ដោយថ្នាំនេះ ដោយប្រការដូច្នេះ ព្រះសមណគោតមទ្រង់នឹងសប្បាយដោយអាការដូចពោលមកនេះ ដូច្នេះ ហើយទើបបានដាក់ចុះក្នុងបាត្រព្រះថេរៈ ។

បទថា **ឧបសម្មិ** សេចក្តីថា បានឮថា កាលអាពាធនោះស្ងប់ហើយ បានកើតរឿងពិស្តារថា ទេវហិតព្រាហ្មណ៍ ថ្វាយកេសជ្ជៈចំពោះព្រះតថាគត ព្រះអាពាធក៏ស្ងប់ ព្រោះកេសជ្ជៈនោះឯង គួរអស្ចារ្យ ទានរបស់ព្រាហ្មណ៍ជាបរមទាន ។ ព្រាហ្មណ៍នោះ ជាអ្នកប្រាថ្នានូវកិត្តិស័ព្ទ បានស្តាប់ដូច្នោះហើយ កើតសោមនស្សថា កិត្តិស័ព្ទរបស់យើងនេះខ្ចរខ្ចាយទៅ សូម្បីដោយហេតុត្រឹមតែប៉ុណ្ណោះឯង ក៏ប្រាថ្នានឹងឲ្យគេដឹងរឿងដែលខ្លួនធ្វើហើយ ក្នុងខណៈនោះឯង ទើបចូលទៅគាល់ធ្វើសេចក្តីស្និទ្ធស្នាលជាមួយព្រះទសពល ។

**[១៦៥]** បទថា ទជ្ជា ប្រែថា គប្បីឲ្យ ។ បទថា **កឋំ ហិ យជមានស្ស**

បានដល់ បូជាដោយហេតុអ្វី ។ បទថា **ឥជ្ឈតិ** បានដល់ មានផលច្រើន ។

**[១៦៦]** បទថា ***យោ វេទិ*** សេចក្ដីថា បានដល់ បុគ្គលណាដឹងប្រាកដ គឺ ជាអ្នកបានដឹង បានជ្រាប ។ បាឋៈថា ***យោ វេតិ*** ដូច្នេះក៏មាន ។ អធិប្បាយថា អ្នកណារមែងដឹង គឺ ដឹងទូទៅ ។ បទថា ***បស្សតិ*** បានដល់ រមែងឃើញដោយទិព្វចក្ខុ ។ បទថា ***ជាតិក្ខយំ*** បានដល់ ព្រះអរហត្ត ។ បទថា ***អភិញ្ញា វោសិតោ*** សេចក្ដីថា ជាអ្នកមានព្រហ្មចរិយៈចប់ហើយ គឺ ដល់ទីបំផុតនៃព្រហ្មចរិយៈ គឺ ភាពជាអ្នកធ្វើកិច្ចសម្រេចហើយ ព្រោះដឹង ។

បទថា ***ឯវំ ហិ យជមានស្ស*** សេចក្ដីថា បូជាដោយអាការនេះ គឺ អាការបូជាចំពោះព្រះខីណាស្រព ។

ចប់អដ្ឋកថា ទេវហិតសូត្រទី ៣

# អ ដ្ឋ ក ថា

## មហាសាលសូត្រទី ៤

*មហាសាលសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[១៦៨]** *បទថា លូខោ លូខបាបុរណោ បានដល់ ជាមនុស្សចាស់ មានសំពត់ដណ្តប់ចាស់ ។ បទថា* **ឧបសង្កមិ** *សេចក្តីថា ព្រោះហេតុអ្វី ទើបព្រាហ្មណ៍ចូលទៅរក ។ ដំណាលមកថា ក្នុងផ្ទះរបស់ព្រាហ្មណ៍នោះមានទ្រព្យដល់ ៨ សែន ។ ព្រាហ្មណ៍នោះ បានធ្វើអាវាហមង្គលដល់បុត្រ ៤ នាក់ ចាយវាយទ្រព្យអស់ ៤ សែន ។ លំដាប់នោះ កាលនាងព្រាហ្មណីរបស់ព្រាហ្មណ៍នោះធ្វើកាលៈហើយ បុត្រទាំងឡាយប្រឹក្សាគ្នាថា បើបិតានឹងនាំនាងព្រាហ្មណីដទៃមក ត្រកូលនឹងបែក (ជាពីរ) ដោយអំណាចបុត្រដែលកើតក្នុងផ្ទៃរបស់នាង ណ្ហើយចុះ យើងនឹងសង្គ្រោះដល់បិតា ។ បុត្រទាំង ៤ នាក់នោះ ទំនុកបម្រុងដោយរបស់បរិភោគ និងគ្រឿងស្លៀកដណ្តប់ជាដើម ដែលប្រណីត ធ្វើការប្រេបាច់ដៃ និងជើងជាដើម ថ្ងៃមួយ កាលព្រាហ្មណ៍នោះដេកពេលថ្ងៃហើយក្រោកឡើង ទើបនាំគ្នាប្រេបាច់ដៃ និងជើងពោលទោសក្នុងការ*

នៅគ្រប់គ្រងផ្ទះតែម្នាក់ឯង ទើបប្រាប់ថា ពួកខ្ញុំនឹងទំនុកបម្រុងបិតា ដោយទំនង នេះ រហូតដល់អស់ជីវិត សូមបិតាចូរឲ្យទ្រព្យដែលសល់ដល់ពួកខ្ញុំ ។ ព្រាហ្មណ៍ បានឲ្យទ្រព្យដល់បុត្រម្នាក់ៗ មួយសែនទៀត ហើយបែងចែកគ្រឿងឧបភោគ បរិភោគទាំងអស់ចេញជា ៤ ចំណែក ក្រៅអំពីសំពត់ស្លៀកដណ្តប់របស់ខ្លួន ប្រគល់ឲ្យទៅ ។ បុត្រច្បងទំនុកបម្រុងព្រាហ្មណ៍នោះ ២-៣ ថ្ងៃ ។

ថ្ងៃមួយ ស្ត្រីកូនប្រសារឈរត្រង់ខ្លោងទ្វារ និយាយនឹងព្រាហ្មណ៍ដែល ងូតទឹក ហើយមក យ៉ាងនេះថា ហេតុអ្វី បិតាឲ្យទ្រព្យដល់កូនច្បងជារយ ឬ ជាពាន់រហូតនៅសល់ តែបុត្រដ៏សេស បិតាឲ្យម្នាក់ៗ ពីរសែនមិនមែនឬ បិតា មិនដឹងផ្លូវទៅផ្ទះរបស់បុត្រដទៃៗ ឬ ។ ព្រាហ្មណ៍ក្រោធថា ស្ត្រីថោកទាប ចូរវិនាសទៅ ហើយបានទៅផ្ទះបុត្រដទៃ ។ អំពីនោះ ២-៣ ថ្ងៃ ក៏គេចចេញ ទៅផ្ទះដទៃ ដោយទំនងយ៉ាងនេះ ហេតុនោះ កាលមិនបានចូលទៅសូម្បីក្នុង ផ្ទះណាមួយ ក៏បួសជាបព្វជិត ស្លៀកពាក់ស ដើរសូមភិក្ខា ដោយកាលកន្លង ទៅ ក៏ដល់ភាពចាស់ជរា មានរាងកាយស្វិតក្រៀម ព្រោះការបរិភោគមិន គ្រប់គ្រាន់ និងដេកលំបាក ត្រឡប់អំពីភិក្ខាចារដេកលើតាំងលក់ទៅ ក្រោកឡើង អង្គុយត្រួតមើលខ្លួន កាលមិនឃើញទីពឹងក្នុងបុត្រ ទើបគិតថា បានឮថា ព្រះ

សមណគោតម មានព្រះភ័ក្ត្រមិនស្រពោន មានព្រះភ័ក្ត្រស្រស់ថ្លា និយាយចរចាគួរសប្បាយចិត្ត ឆ្លាតក្នុងបដិសណ្ឋារៈ យើងអាចចូលទៅគាល់ព្រះសមណគោតម និងបានបដិសណ្ឋារៈ ។ ព្រាហ្មណ៍ស្លៀកដណ្តប់សំពត់រៀបរយ កាន់ភាជន៍ភិក្ខា ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។

[១៦៩] បទថា **ទារេហិ សំបុច្ឆ ឃរា និក្ខាមេន្តិ** សេចក្តីថា បុត្រទាំងឡាយកាន់យកទ្រព្យដែលជារបស់ខ្ញុំព្រះអង្គទាំងអស់ ដឹងថា ខ្ញុំព្រះអង្គមិនមានទ្រព្យ ទើបប្រឹក្សានឹងភរិយារបស់ខ្លួន ហើយបណ្តេញខ្ញុំព្រះអង្គចេញអំពីផ្ទះ ។

បទថា **នន្ទិស្សំ** សេចក្តីថា យើងកើតសេចក្តីរីករាយ ត្រេកអរ បាមោជ្ជៈ ។ បទថា **ភាវមិច្ឆិសំ** សេចក្តីថា យើងប្រាថ្នាសេចក្តីចម្រើន ។ បទថា **សាវ វាទេន្តិ សូករំ** សេចក្តីថា ពួកសុនខជាហ្វូងៗ ព្រុសដេញជ្រូក ព្រុសឡើងខ្លាំងៗ រឿយៗ យ៉ាងណា បុត្រទាំងឡាយព្រមទាំងភរិយា បណ្តេញខ្ញុំព្រះអង្គដោយសំឡេងខ្លាំងៗ ឲ្យចេញទៅ ក៏ដូច្នោះ ។

បទថា **អសន្តា** បានដល់ អសប្បុរសទាំងឡាយ ។ បទថា **ជម្មា** ប្រែថា ដ៏លាមក ។ បទថា **ភាសរេ** ប្រែថា រមែងពោល ។ បទថា **បុត្តរូបេន**

បានដល់ ដោយកេទរបស់បុត្រ ។ បទថា **វិយោគតំ** បានដល់ រមែងលះ គឺ លះបង់នូវខ្ញុំ ដែលជាអ្នកកន្លងវ័យទាំង ៣ តាំងនៅក្នុងបច្ឆិមវ័យ ។

បទថា **និព្ភោគោ** ប្រែថា មិនមានគ្រឿងបរិភោគ ។ បទថា **ខាទនា អបនីយតិ** សេចក្ដីថា ជនទាំងឡាយ រមែងឲ្យរបស់ស៊ីមានរសផ្សេងៗ ដល់សេះ ក្នុងវេលាដែលវានៅជំទង់ មានកម្លាំងរត់លឿន តអំពីនោះ ពេលវាមានកម្លាំងខ្សោយ ក៏លះបង់វាចោល វាមិនបានទទួលការថែរក្សា ត្រូវត្រាច់ទៅរកស្មៅស្ងួតក្នុងព្រៃជាមួយនឹងមេគោទាំងឡាយ បិតាឈ្មោះថា មិនមានភោគៈ ព្រោះទ្រព្យទាំងពួងត្រូវប្ទូទៅអស់ ក៏ដូចគ្នានឹងសេះនោះ ដែលគេបោះបង់ បិតាចាស់របស់ជនពាលទាំងឡាយ មានសភាពដូចយើង តែងសូមអាហារក្នុងទីប្រេបផ្ទះនៃអ្នកដទៃ ។

ស័ព្ទថា **យញ្ចេ** ជានិបាត ។ លោកពោលអធិប្បាយទុកថា គេថា ឈើច្រត់នៅប្រសើរជាង ល្អជាងបុត្ររបស់ខ្ញុំដែលមិនស្ដាប់បង្គាប់ មិនកោតក្រែង មិននៅក្នុងការឃុំគ្រង ។ ឥឡូវនេះ ទ្រង់នឹងសម្ដែងថា ឈើ ប៉ុណ្ណោះ ជារបស់ប្រសើរ ទើបត្រាស់ថា **ចណ្ឌំបិគោណំ** ដូច្នេះ ជាដើម ។

បទថា **បុរេ ហោតិ** បានដល់ ប្រើនាំមុខ អធិប្បាយថា យកឈើច្រត់

នោះទុកខាងមុខ រមែងសប្បាយ ។ បទថា **គាធមេតិ** សេចក្ដីថា វេលាចុះទឹក ប្រើឈើច្រត់ជាទីពឹងក្នុងទឹកជ្រៅ ។

**[១៧០]** បទថា **បរិយាបុណិត្វា** បានដល់ រៀនជាប់រត់មាត់ ។ បទថា **សន្និសិន្នេសុ** សេចក្ដីថា ក្នុងថ្ងៃដែលពួកព្រាហ្មណ៍ប្រជុំគ្នានោះ កាលពួកបុត្រប្រដាប់ដោយគ្រឿងអលង្ការទាំងពួងចូលទៅក្នុងទីប្រជុំនោះ អង្គុយលើអាសនៈដ៏ប្រសើរ កណ្ដាលពួកព្រាហ្មណ៍ ។ បទថា **អភាសិ** សេចក្ដីថា ព្រាហ្មណ៍គិតថា នេះជាវេលារបស់យើងហើយ ទើបចូលទៅកណ្ដាលទីប្រជុំ លើកដៃឡើងពោលថា លោកដ៏ចម្រើនទាំងឡាយ យើងមានសេចក្ដីប្រាថ្នានឹងពោលគាថាដល់លោកទាំងឡាយ កាលយើងពោលដល់ពួកលោក លោកទាំងឡាយនឹងស្ដាប់ឬទេ កាលពួកព្រាហ្មណ៍ពោលថា ពោលចុះ ពោលចុះ លោកដ៏ចម្រើន ពួកយើងនឹងស្ដាប់ ដូច្នេះ ទើបបានឈរពោលតែម្ដង ។ ក៏ក្នុងសម័យនោះឯង ពួកមនុស្សមានប្រពៃណីថា អ្នកណាបរិភោគទ្រព្យរបស់បិតាមាតាហើយ មិនចិញ្ចឹមរក្សាបិតាមាតា អ្នកនោះគួរដល់ការស្លាប់ ដូច្នេះ ព្រោះដូច្នោះ បុត្រព្រាហ្មណ៍ទាំងនោះ ទើបក្រាបចុះត្រង់ជើងទាំងពីររបស់បិតា អង្វរថា សូមបិតាឲ្យជីវិតដល់ពួកខ្ញុំចុះ ។ ព្រោះចិត្តរបស់បិតាទោទន់ចំពោះកូនៗ ព្រាហ្មណ៍

នោះទើបពោលថា លោកដ៏ចម្រើនទាំងឡាយ សូមលោកទាំងឡាយ កុំឲ្យកូនល្ងង់ៗ របស់ខ្ញុំវិនាសឡើយ ពួកគេនឹងចិញ្ចឹមរក្សាខ្ញុំ ដូច្នេះ ។

លំដាប់នោះ ព្រាហ្មណ៍ទាំងឡាយពោលនឹងកូនៗ របស់ព្រាហ្មណ៍នោះថា អ្នកដ៏ចម្រើនទាំងឡាយ តាំងពីថ្ងៃនេះទៅ បើពួកអ្នកមិនប្រណិបត្តិបិតាឲ្យល្អទេ ពួកយើងនឹងសម្លាប់ពួកអ្នក ។ កូនៗ ទាំងនោះ មានសេចក្តីខ្លាចទើបនាំបិតាទៅកាន់ផ្ទះដើម្បីប្រណិបត្តិ ។ ដើម្បីនឹងសម្តែងរឿងនោះ លោកទើបពោលពាក្យជាដើមថា **អថខោ តំ ព្រាហ្មណមហាសាលំ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **នេត្វា** សេចក្តីថា ឲ្យបិតាអង្គុយលើតាំងហើយ លើកឡើង នាំទៅដោយខ្លួនឯង ។ បទថា **ន្ហាបេត្វា** សេចក្តីថា យកប្រេងលាបខ្លួន ហើយប្របាច់ធ្វើសរសៃ ឲ្យងូតទឹកដោយលំអិតគ្រឿងក្រអូបជាដើម ។ ឲ្យហៅនាងព្រាហ្មណីទាំងឡាយ ហើយពោលថា តាំងពីថ្ងៃនេះទៅ ពួកនាងចូរប្រណិបត្តិបិតារបស់យើងឲ្យល្អ បើពួកនាងប្រមាទ ពួកយើងនឹងបណ្តេញពួកនាងចេញពីផ្ទះ ដូច្នេះ ហើយឲ្យបិតាបរិភោគភោជនយ៉ាងប្រណីត ។

**[១៧២]** ព្រាហ្មណ៍បានអាហារល្អ ដេកជាសុខ តែពីរបីថ្ងៃប៉ុណ្ណោះក៏មានកម្លាំង ព្រាហ្មណ៍មានរាងកាយឆ្អែតស្កប់ស្កល់ រមិលមើលខ្លួនហើយ គិត

ថា យើងបានសម្បត្តិនេះ ព្រោះអាស្រ័យព្រះសមណគោតម ទើបកាន់គ្រឿងបណ្ណាការទៅគាល់ព្រះមានព្រះភាគ ។ ដើម្បីនឹងសម្តែងសេចក្តីនោះ លោកទើបពោលពាក្យជាដើមថា **អថខោ សោ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឯកមន្តំ** សេចក្តីថា ព្រាហ្មណ៍ដាក់សំពត់មួយគូទៀបបាទមូល ហើយបានពោលពាក្យនេះ គឺ ក្រាបទូលព្រះមានព្រះភាគក្នុងវេលាទទួលសរណគមន៍ចប់ទុំះឯង យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពួកកូនៗ ឲ្យភត្តាហារជាប្រចាំដល់ខ្ញុំព្រះអង្គ ៤ ចំណែក ខ្ញុំព្រះអង្គសូមថ្វាយចំពោះព្រះអង្គ ២ ចំណែកអំពី ៤ ចំណែកនោះ ខ្ញុំព្រះអង្គនឹងបរិភោគ ២ ចំណែក ។ ព្រះមាន-ព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកកុំប្រគល់ឲ្យនូវចំណែកដែលល្អឡើយ តថាគតនឹងទៅកាន់ស្ថានទីពេញចិត្តរបស់តថាគតប៉ុណ្ណោះ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រអង្គដ៏ចម្រើន យ៉ាងនោះហើយ ថ្វាយបង្គំព្រះមានព្រះភាគហើយ ទៅផ្ទះហៅពួកកូនមកប្រាប់ថា កូនៗ ទាំងឡាយ ព្រះសមណគោតមជាសម្លាញ់របស់យើង យើងថ្វាយភត្តាហារជាប្រចាំរបស់យើង ២ ចំណែកដល់ព្រះសមណគោតមនោះ កាលព្រះអង្គមកដល់ផ្ទះ ពួកអ្នកឯងកុំភ្លេចឲ្យសោះ ពួកកូននាំគ្នាទទួលដោយពាក្យថា ល្អហើយបិតា ។ ស្អែកឡើង ព្រះមានព្រះ-

ភាគ ទ្រង់កាន់បាត្រចីវរ ស្តេចទៅកាន់ទ្វារនិវេសន៍របស់កូនច្បង ។ ក្នុងខណៈដែលគេឃើញព្រះសាស្តាប៉ុណ្ណោះ ក៏ស្ទុះទៅទទួលបាត្រអំពីព្រះហស្ត និមន្តស្តេចឲ្យចូលផ្ទះ ឲ្យប្រថាប់គង់លើបល្ល័ង្កដ៏ប្រសើរ ហើយបានថ្វាយភោជនដ៏ប្រណីត ។ ស្អែកឡើង ព្រះសាស្តាស្តេចទៅកាន់ផ្ទះរបស់កូនម្នាក់ទៀត ថ្ងៃស្អែកឡើងទៀត ស្តេចទៅផ្ទះរបស់កូនម្នាក់ទៀត ព្រះអង្គស្តេចទៅកាន់ផ្ទះកូនរបស់ព្រាហ្មណ៍គ្រប់គ្នាតាមលំដាប់ ដោយប្រការដូច្នេះ ។ ពួកកូនរបស់ព្រាហ្មណ៍គ្រប់គ្នា បានធ្វើសក្ការៈដូចៗ គ្នា ។ ថ្ងៃមួយ ក្នុងផ្ទះរបស់កូនច្បងមានពិធីមង្គល ។ កូនច្បងនោះពោលនឹងបិតាថា បពិត្របិតា ពួកយើងនឹងថ្វាយមង្គលដល់អ្នកណា ។ ព្រាហ្មណ៍ពោលថា ពួកយើងមិនស្គាល់អ្នកណាដទៃឡើយ ព្រះសមណគោតមជាសម្លាញ់របស់បិតាមិនមែនឬ កូនច្បងពោលថា បើដូច្នោះ បិតាចូរនិមន្តព្រះសមណគោតមមកឆាន់ភត្តាហារក្នុងថ្ងៃស្អែក ព្រមដោយភិក្ខុប្រមាណ ៥០០ រូប ព្រាហ្មណ៍បានធ្វើដូចយ៉ាងនោះ ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តហើយ ហែហមទៅដោយភិក្ខុសង្ឃ ស្តេចបានទៅកាន់ផ្ទះរបស់កូនប្រុសច្បងនោះ ក្នុងថ្ងៃស្អែក ។ កូនប្រុសច្បងនោះ អារាធនាព្រះសាស្តាឲ្យចូលទៅកាន់ផ្ទះ ដែលលាបដោយរបស់ខៀវ ប្រដាប់ដោយគ្រឿងប្រដាប់គ្រប់

យ៉ាង និមន្តភិក្ខុសង្ឃដែលមានព្រះពុទ្ធជាប្រធាន ឲ្យគង់លើអាសនៈដែលក្រាល ហើយ បានថ្វាយបាយបាយាសមានទឹកតិច និងរបស់ទំពារផ្សេងៗ ។ លំដាប់នោះ កូនទាំងបួននាក់របស់ព្រាហ្មណ៍អង្គុយគាល់ព្រះសាស្តា ក្រាបទូលក្នុងចន្លោះសោយកត្តាហារថា បពិត្រព្រះគោតមដ៏ចម្រើន ពួកខ្ញុំព្រះអង្គប្រណិបត្តិបិតារបស់ពួកខ្ញុំព្រះអង្គ មិនបានប្រមាទឡើយ សូមព្រះអង្គចូរមើលអត្តភាព ។ ព្រះសាស្តាត្រាស់ថា ដែលឈ្មោះថា ការចិញ្ចឹមរក្សាបិតាមាតា ដែលពួកអ្នកធ្វើហើយជាសេចក្តីល្អ ពួកបុរាណបណ្ឌិតធ្លាប់ប្រព្រឹត្តមកហើយ ទើបត្រាស់នាគរាជជាតក លើកអរិយសច្ច ៤ សម្តែង ក្នុងវេលាចប់ទេសនា ព្រាហ្មណ៍ព្រមទាំងកូន ៤ នាក់ កូនប្រសារ ៤ នាក់ បញ្ជូនញាណទៅតាមក្រសែទេសនា បានតាំងនៅក្នុងសោតាបត្តិផល ។ ចាប់តាំងពីថ្ងៃនោះមក ព្រះសាស្តាមិនបានទៅកាន់ផ្ទះរបស់ជនទាំងនោះក្នុងកាលទាំងពួង ដូច្នេះឯង ។

ចប់អដ្ឋកថា មហាសាលសូត្រទី ៤

# អ ដ្ឋ ក ថា

## មានត្ថទ្ធសូត្រទី ៥

*មានត្ថទ្ធសូត្រទី ៥* មានវិនិច្ឆ័យដូចតទៅនេះ ៖

**[១៧៣]** *បទថា* **មានត្ថទ្ធោ** *សេចក្ដីថា ជាអ្នករឹងត្អឹងព្រោះមានះ ដូចស្បែកពេញទៅដោយខ្យល់ ។ បទថា* **អាចរិយំ** *សេចក្ដីថា ក្នុងវេលារៀនសិល្បៈ អាចារ្យមិនឲ្យសិល្បៈដល់អ្នកមិនថ្វាយបង្គំ ។ តែក្នុងកាលដទៃ ព្រាហ្មណ៍នោះ មិនថ្វាយបង្គំអាចារ្យ ។ សូម្បីអាចារ្យនោះមាន ព្រាហ្មណ៍ក៏មិនដឹង ។*

**[១៧៤]** *បទថា* **នាយំ សមណោ** *សេចក្ដីថា ព្រាហ្មណ៍នោះបានគិតយ៉ាងនេះថា ព្រោះហេតុអ្វី បានជាព្រះសមណៈនេះ កាលព្រាហ្មណ៍ដែលដល់ព្រមដោយជាតិដូចយើងចូលមកដល់ហើយ ក៏មិនធ្វើកិច្ច សូម្បីត្រឹមតែបដិសណ្ឋារៈ សមណៈនេះ មិនដឹងអ្វីសោះ ។*

**[១៧៦]** *បទថា* **អព្ភុតចិត្តជាតា** *បានដល់ ប្រកបដោយសេចក្ដីត្រេកអរដែលមិនធ្លាប់មានមក ។ បទថា* **កេស្សស្ស**[១] *សេចក្ដីថា គប្បីគោរពក្នុងអ្នក*

---

១ បាលីថា កថំ ស្វស្ស ។

ណា ។ បទថា **ក្យស្ស** សេចក្ដីថា បុគ្គលពួកណា ជាទីគោរពរបស់បុគ្គលណា ។ បទថា **អបចិតា អស្សុ** សេចក្ដីថា បុគ្គលបែបណា គប្បីជាអ្នកគួរដើម្បីសម្ដែងសេចក្ដីលំអុតលំអោន ។ ដោយគាថានេះថា **អរហន្តេ** ជាដើម ទ្រង់សម្ដែងបូជនីយបុគ្គល ដោយលើកព្រះអង្គជាឧបមា ព្រោះព្រះអង្គទ្រង់ជាអ្នកច្វាតក្នុងទេសនា ។

ចប់អដ្ឋកថា មានត្ថទ្ធសូត្រទី៥

# អ ដ្ឋ ក ថា

## បច្ចនិកសូត្រទី ៦

*បច្ចនិកសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[១៨០]** *កាលគេពោលថា វត្ថុទាំងពួង.ស ព្រាហ្មណ៍នោះក៏ធ្វើការជំទាស់ ដោយន័យជាដើមថា វត្ថុទាំងពួងខ្មៅ រមែងមានសេចក្តីសប្បាយ គឺមានសេចក្តីសុខ ព្រោះហេតុនោះ ទើបឈ្មោះថា* **បច្ចនិកសាតៈ** ។

**[១៨២]** *បទថា* **យោ ច វិនេយ្យ សារម្ភំ** *សេចក្តីថា អ្នកណាកម្ចាត់ការប្រណាំងប្រជែង មានលក្ខណៈធ្វើគ្រាន់បើ ហើយស្តាប់* ។

ចប់អដ្ឋកថា បច្ចនិកសូត្រទី៦

# អ ដ្ឋ ក ថា

## នវកម្មិកសូត្រទី ៧

ក្នុងនវកម្មិកសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[១៨២]** បទថា **នវកម្មិកភារទ្វាជោ** សេចក្តីថា បានឮមកថា ព្រាហ្មណ៍នោះ ឲ្យគេកាត់ដើមឈើក្នុងព្រៃដើម្បីជាគ្រឿងប្រកបប្រាសាទ និងផ្ទះកំពូលក្នុងព្រៃនោះឯង ហើយនាំមកលក់ក្នុងព្រះនគរ ឈ្មោះថា **នវកម្មិក** ព្រោះអាស្រ័យនវកម្មចិញ្ចឹមជីវិតដូចពោលហើយ ដោយគោត្រឈ្មោះថា **ភារទ្វាជៈ** ហេតុនោះទើបឈ្មោះថា **នវកម្មិកភារទ្វាជៈ** ។ បទថា **ទិស្វានស្ស ឯតទហោសិ** សេចក្តីថា ព្រាហ្មណ៍នោះមានការគិតដូច្នេះ ព្រោះឃើញព្រះមានព្រះភាគប្រថាប់គង់ បញ្ចេញព្រះឆព្វណ្ណរង្សី ។

**[១៨៦]** បទថា **វនស្មឹ** បានដល់ ក្នុងដងព្រៃនេះ ។ បទថា **ឧច្ឆិន្នមូលំ មេ វនំ** សេចក្តីថា ព្រៃ គឺ កិលេស ដែលយើងដកឫសចេញហើយ ។ បទថា **និព្វនថោ** បានដល់ ប្រាសចាកព្រៃ គឺ កិលេស ។ បទថា **ឯកោ រមេ** បានដល់ យើងត្រេកអរតែម្នាក់ឯងប៉ុណ្ណោះ ។ បទថា **អរតឹ វិប្បហាយ** សេចក្តីថា

*លះបង់ការធុញទ្រាន់ក្នុងការសេពសេនាសនៈដែលស្ងាត់ ហើយចម្រើនភាវនា ។*

ចប់អដ្ឋកថា នវកម្មិកសូត្រទី ៧

# អ ដ្ឋ ក ថា

## ករដ្ឋហារសូត្រទី ៨

ករដ្ឋហារសូត្រទី ៨ វិនិច្ឆ័យដូចតទៅនេះ ៖

[១៨៨] បទថា **អន្តេវាសិកា** បានដល់ មានអ្នកធ្វើការខ្វល់ខ្វាយ រៀនទូវសិល្បៈ ឈ្មោះថា **ធម្មន្តេវាសិក** ។ បទថា **និសិន្នំ** បានដល់ ប្រថាប់គង់បញ្ចេញព្រះរស្មី មានវណ្ណៈ ៦ ។

[១៨៩] បទថា **គម្ភីររូបេ** បានដល់ មានសភាពជ្រៅ ។

បទថា **ពហុភេរវេ** បានដល់ ដែលគួរភ័យខ្លាចច្រើន ព្រោះវត្ថុដែលមានវិញ្ញាណ និងមិនមានវិញ្ញាណ ដែលគួរភ័យខ្លាចនៅក្នុងទីនោះ ។ បទថា **វិគាហិយ** បានដល់ ចូលទៅហើយដោយលំដាប់ ។ បទថា **អនិញ្ជមានេន** ជាដើម បានដល់ មានកាយពិសេស ។ អធិប្បាយថា ព្រោះកាយមានសភាពបែបនេះ ។ ដោយពាក្យថា **សុចារុរូបំ វត** លោកពោលថា លោកសម្លឹងឈានដ៏ល្អក្រៃលែងហ្ន៎ ។

បទថា **វនវស្សិតោ មុនិ** បានដល់ ព្រះមុនី គឺ ព្រះពុទ្ធទ្រង់អាស្រ័យ

នៅក្នុងព្រៃ ។ បទថា **ឥទំ** សេចក្តីថា ហេតុដែលលោកគង់ក្នុងព្រៃយ៉ាងនេះ រមែងប្រាកដជាវត្ថុដែលគួរអស្ចារ្យដល់ខ្ញុំ ។ បទថា **បីតិមនោ** បានដល់ អ្នកមានចិត្តត្រេកអរ ។ បទថា **វនេ វសេ** បានដល់ នៅក្នុងព្រៃ ។

បទថា **មញ្ញាមហំ** សេចក្តីថា ខ្ញុំរមែងសម្គាល់ ។ បទថា **លោកា-ធិបតិសហព្យតំ** បានដល់ ភាពជាសម្លាញ់របស់មហាព្រហ្មអ្នកជាធំក្នុងលោក ។ បទថា **អាកង្ខមានោ** ប្រែថា ប្រាថ្នា ។ ពាក្យថា **តិទិវំ អនុត្តរំ** នេះ លោកពោលសំដៅដល់ព្រហ្មលោកនុ៎ះឯង ។ បទថា **កស្មា ភវំ វិជនមរញ្ញមស្សិតោ** សេចក្តីថា បើមិនដូច្នេះទេ យើងយល់ថា លោកប្រាថ្នាព្រហ្មលោកជាលំដាប់ដំបូង ព្រាហ្មណ៍សួរថា បើដូច្នេះ លោកចូរប្រាប់ដល់យើង ព្រោះហេតុណា លោកទើបពេញចិត្តនៅព្រៃ ។ បទថា **ព្រហ្មបត្តិយា** ប្រែថា ដើម្បីដល់ភាពជាអ្នកប្រសើរក្នុងទីនេះ ប្រការនេះ ព្រាហ្មណ៍សួរដោយអាការដទៃទៀតថា ព្រោះហេតុអ្វី លោកទើបធ្វើសេចក្តីព្យាយាម ។

**[១៩០]** បទថា **កង្ខា** បានដល់ តណ្ហា ។ ដោយបទថា **អភិនន្ទនា** នេះ សូម្បីតណ្ហា លោកក៏ហៅថា **អភិនន្ទនា** ។ បទថា **អនេកធាតូសុ** បានដល់ ក្នុងអារម្មណ៍ទាំងឡាយ មានសភាពមិនមែនតែមួយ ។ បទថា **បុថូ** បាន

ដល់ តណ្ហា ឬកិលេសដ៏សេសមានប្រការផ្សេងៗ ។ បទថា **សទា សិតា** បានដល់ នៅក្នុងអំណាចរហូតអស់កាលជានិច្ច ។ បទថា **អញ្ញាណមូលប្បភាវា** គឺ មានអវិជ្ជាជាមូលកើតឡើង ។ ក៏តណ្ហាលោកហៅថា **បជប្បិតា** ព្រោះជាប្រកតញាំងជនឲ្យជាប់ជំពាក់ ថាជារបស់យើង សូម្បីនេះក៏ជារបស់យើង ។ បទថា **សព្វា មយា ព្យន្តិកតា** សេចក្ដីថា តណ្ហាទាំងអស់ដែលយើងធ្វើឲ្យអស់ គឺ ឲ្យដល់ទីបំផុតហើយដោយអរហត្តមគ្គ ។ បទថា **សមូលិកា** បានដល់ ព្រមទាំងមូល គឺ អវិជ្ជា ។

បទថា **អនូបយោ** បានដល់ មិនមានតណ្ហាចូលទៅជិត ។ ដោយបទថា **សព្វេសុ ធម្មេសុ វិសុទ្ធទស្សនោ** នេះ ទ្រង់សម្ដែងដល់ព្រះសព្វញ្ញុតញ្ញាណ ។ ដោយបទថា **សម្ពោធិមនុត្តរំ** ត្រាស់សំដៅយកព្រះអរហត្ត ។ បទថា **សិវំ** បានដល់ ប្រសើរបំផុត ។ បទថា **ឈាយាមហំ** សេចក្ដីថា យើងរមែងសម្លឹងដោយឈានទាំង ២ ។ បទថា **វិសារទោ** បានដល់ ប្រាសចាកតម្រេក ។

ចប់អដ្ឋកថា ការដ្ឋហារសូត្រទី ៨

# អ ដ្ឋ ក ថា

## មាតុបោសកសូត្រទី ៩

*មាតុបោសកសូត្រទី ៩ វិនិច្ឆ័យដូចតទៅនេះ ៖*

**[១៩៣]** *បទថា បេច្ច បានដល់ ទៅអំពីលោកនេះ ។*

ចប់អដ្ឋកថា មាតុបោសកសូត្រទី៩

# អ ដ្ឋ ក ថា

## ភិក្ខុកសូត្រទី ១០

*ភិក្ខុកសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[១៩៥]** *បទថា ឥធ បានដល់ ក្នុងភាពជាភិក្ខុនេះនុ៎ះឯង ។*

**[១៩៦]** *បទថា **វិសំ ធម្មំ** បានដល់ អកុសលធម៌ដែលមានក្លិនអាក្រក់ ។ បទថា **វាហេត្វា** បានដល់ លះបង់បានដោយអរហត្តមគ្គ ។ បទថា **សង្ខាយ** បានដល់ ញាណ ។ បទថា **ស វេ ភិក្ខូតិ វុច្ចតិ** សេចក្តីថា អ្នកនោះឯង លោកហៅឈ្មោះថា ភិក្ខុ ព្រោះជាអ្នកទម្លាយកិលេស ។*

ចប់អដ្ឋកថា ភិក្ខុកសូត្រទី ១០

# អ ដ្ឋ ក ថា

## សង្គារវសូត្រទី ១១

*សង្គារវសូត្រទី ១១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[១៩៨]** *បទថា* **បច្ចេតិ** *បានដល់ រមែងប្រាថ្នា គឺ រមែងត្រូវការ ។ ព្រះអានន្ទអារាធនាព្រះមានព្រះភាគដោយពាក្យថា* **សាធុ ភន្តេ** *។ បានឮថា គ្រហស្ថនោះជាសម្លាញ់របស់ព្រះថេរៈ ។ ព្រោះដូច្នោះ ព្រះថេរៈទូលអារាធនា ដោយគិតថា ព្រាហ្មណ៍ជាមនុស្សកំព្រា សូម្បីបានយើងជាសម្លាញ់ កុំមាននូវមិច្ឆាទិដ្ឋិ ដែលមានអបាយនៅខាងមុខឡើយ ។ ន័យមួយទៀត ព្រះថេរៈយល់ថា គ្រហស្ថនេះ មានបរិវារច្រើន កាលគេជ្រះថ្លាហើយ ត្រកូល ៥០០ ត្រកូល នឹងប្រព្រឹត្តតាមពាក្យប្រៀនប្រដៅ ទើបបានទូលអារាធនា ។*

**[២០០]** *បទថា* **អត្ថវសំ** *បានដល់ អានិសង្សរបស់ប្រយោជន៍ គឺ ហេតុរបស់ប្រយោជន៍ ។ បទថា* **បាបំ** *បានដល់ អកុសលកម្ម មានបាណាតិបាតជាដើម ។ បទថា* **បវាហេមិ** *បានដល់ យើងចុះទឹកត្រឹម.កដើម្បីបណ្តែតបង់នូវបាបឲ្យសោត់ទៅ ។ សេចក្តីថា* **ធម្មោ** *មានសេចក្តីដូចពោលហើយ*

ទុះឯង ។

ចប់អដ្ឋកថា សង្គារវសូត្រទី ១១

# អ ដ្ឋ ក ថា

## ខោមទុស្សសូត្រទី ១២

*ខោមទុស្សសូត្រទី ១២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២០០] *បទថា* ***ខោមទុស្សន្នាម*** *បានដល់ និគមដែលមានឈ្មោះយ៉ាងនេះ ព្រោះមានសំពត់សម្បកឈើច្រើន ។ បទថា* ***សភាយំ*** *បានដល់ក្នុងសាលា ។ បទថា* ***ផុសាយតិ*** *សេចក្ដីថា តំណក់ទឹកភ្លៀងស្រក់ គឺ ធ្លាក់បានឮថា ព្រះសាស្ដា មានព្រះបំណងនឹងចូលកាន់សាលាសភានោះ ទ្រង់ព្រះតម្រិះថា កាលតថាគតចូលទៅដោយអាការយ៉ាងនេះ នឹងមិនមានសេចក្ដីសប្បាយ ព្រោះហេតុនោះ តថាគតអាស្រ័យហេតុមួយ ហើយនឹងចូលទៅដូច្នេះហើយ ទ្រង់បណ្ដាលឲ្យភ្លៀងធ្លាក់ដោយការអធិដ្ឋាន ។ បទថា* ***សភាធម្មំ*** *សេចក្ដីថា បានឮថា ការមិនធ្វើជនដែលអង្គុយយ៉ាងសប្បាយ ឲ្យក្រោកឡើងហើយចូលទៅម្នាង ឈ្មោះថា ធម្មសភារបស់គេទាំងនោះ មិនមែនការធ្វើមហាជនឲ្យក្រោកឡើង ហើយចូលទៅត្រង់ៗ នោះទេ ។ ព្រះមានព្រះភាគស្ដេចយាងទៅត្រង់តែម្ដង ។ ព្រោះហេតុនោះ ព្រាហ្មណ៍ និងគហបតីទាំងនោះ*

ក្រោធ ពោលចំអកឡកឡឺយដាក់ព្រះមានព្រះភាគថា ជនពួកណាហ្ន៎ ជាសមណៈ ត្រងោល និងជនពួកណាហ្ន៎ នឹងដឹងសភាធម៌ ។

[២០៤] បទថា សន្តោ បានដល់ បណ្ឌិត គឺ សប្បុរស ។ បទថា បហាយ សេចក្តីថា ជនដែលលះបង់រាគៈជាដើមទាំងនោះ ពោលធម៌ដើម្បីកម្ចាត់រាគៈជាដើម ឈ្មោះថា សប្បុរស ។

ចប់អដ្ឋកថា ខោមទុស្សសូត្រទី ១២

## ឧបាសកវគ្គទី ២

## នៃព្រាហ្មណសំយុត្តចប់ត្រឹមតែប៉ុណ្ណោះ

### រួមក្នុងវគ្គនេះមាន ១២ អដ្ឋកថា


១-អដ្ឋកថាកសិសូត្រ
២-អដ្ឋកថាឧទយសូត្រ
៣-អដ្ឋកថាទេវហិតសូត្រ
៤-អដ្ឋកថាមហាសាលសូត្រ
៥-អដ្ឋកថាមានត្ថទ្ធសូត្រ
៦-អដ្ឋកថាបច្ចនិកសូត្រ
៧-អដ្ឋកថានវកម្មិកសូត្រ
៨-អដ្ឋកថាកដ្ឋហារសូត្រ
៩-អដ្ឋកថាមាតុបោសកសូត្រ
១០-អដ្ឋកថាភិក្ខកសូត្រ
១១-អដ្ឋកថាសង្គារវសូត្រ
១២-អដ្ឋកថាខោមទុស្សសូត្រ

# វង្គីសសំយុត្ត

## អ ដ្ឋ ក ថា

### និក្ខន្តសូត្រទី ១

*និក្ខន្តសូត្រទី ១ នៃវង្គីសសំយុត្ត មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២០៦] *បទថា* **អគ្គាឡវេ ចេតិយេ** *បានដល់ ក្នុងអគ្គាឡវចេតិយជិតក្រុងអាឡវី ។ កាលព្រះពុទ្ធមិនទាន់ស្ដេចឧប្បត្តិ បានមានចេតិយជាច្រើនដែលជាអាវាសរបស់យក្ខ និងនាគជាដើម មានអគ្គាឡវចេតិយ និងគោតមកចេតិយជាដើម ។ កាលព្រះពុទ្ធស្ដេចឧប្បត្តិឡើងហើយ មនុស្សទាំងឡាយនាំគ្នារុះរើចេតិយទាំងនោះសាងជាវិហារ ។ ចេតិយទាំងនោះឯង ទើបកើតជាឈ្មោះរបស់អ្នកទាំងនោះ ។ បទថា* **និគ្រោធកប្បេន** *បានដល់ ព្រះកប្បត្ថេរដែលនៅត្រង់គល់ដើមជ្រៃ ។ បទថា* **ឱហិយ្យកោ** *បានដល់ ជាភិក្ខុតូចទាប ។ បទថា* **វិហារបាលោ** *សេចក្ដីថា បានឮថា ក្នុងគ្រានោះ លោកមិនទាន់មានវស្សា មិនយល់ក្នុងការទទួលបាត្រចីវរ ។ លំដាប់នោះ ភិក្ខុដែលជាថេរៈទាំង*

ឡាយ ទើបពោលនឹងលោកថា អាវុសោ អ្នកចូរនៅរក្សាវិហារ ។ ស្បែក ជើង និងឈើច្រត់ជាដើម តាំងឲ្យជាអ្នកចាំវិហារហើយចូលទៅបិណ្ឌបាត ។ ព្រោះហេតុនោះ លោកទើបពោលថា **វិហារបាលោ** ។

[២០៧] បទថា **សមលង្ករិត្វា** សេចក្ដីថា ប្រដាប់ដោយគ្រឿងប្រដាប់ សមរម្យដល់សម្បត្តិរបស់ខ្លួន ។ បទថា **ចិត្តំ អនុទ្ធំសេតិ** សេចក្ដីថា កម្ចាត់ គឺ ធ្វើកុសលចិត្តឲ្យវិនាស ។ បទថា **តំ កុតេត្ថ លព្ភា** សេចក្ដីថា កាលរាគៈ កើតឡើង នឹងបានហេតុនោះពីទីណា ។ បទថា **យំ មេ បរេ** សេចក្ដីថា ព្រោះហេតុណា បុគ្គល ឬធម៌យ៉ាងដទៃ គប្បីបន្ទោបង់សេចក្ដីអផ្សុកចង់សឹក ហើយ ធ្វើសេចក្ដីត្រេកអរក្នុងព្រហ្មចរិយៈឲ្យកើតឡើងដល់យើង ក្នុងកាល ឥឡូវនេះហ្ន៎ សូម្បីអាចារ្យ និងព្រះឧបជ្ឈាយ៍ ក៏លះបង់យើងក្នុងវិហារហើយ ចេញទៅ ។

[២០៨] បទថា **អគារស្មា** បានដល់ ចេញចាកផ្ទះ ។ បទថា **អនា-គារិយំ** សេចក្ដីថា ចូលដល់បព្វជ្ជា ។ បទថា **កណ្ហតោ** សេចក្ដីថា ត្រាច់ មកពីធម៌ចំណែកខ្មៅ គឺ ចំណែកមារ ។ បទថា **ឧគ្គបុត្តា** បានដល់ បុត្ររបស់ បុគ្គលជាន់ខ្ពស់ ជាខ្សែស្រឡាយអ្នកមានសក្ដិធំ ។ បទថា **ទឡ្ហធម្មិនោ** បាន

ដល់ អ្នកទ្រទ្រង់ធ្នូដ៏មាំ ។ គឺ កាន់ធ្នូរបស់អាចារ្យ ដែលមានទំហំធំបំផុត ។ បទថា **សហស្សំ អបលាយិនំ** សេចក្ដីថា កាលសម្ដែងចំនួនរបស់សត្វទាំងឡាយ ដែលមិនឲ្យរត់រួច ទើបយកកូនសរបាញ់បាចសាចទៅដោយជុំវិញ ទើបពោលថា **សហស្សំ** ដូច្នេះ ។ បទថា **ឯត្តកា ភិយ្យោ** សេចក្ដីថា សូម្បីស្ត្រីទាំងពាន់នេះ ។ បទថា **នេវ មំ ព្យាធយិស្សន្តិ** សេចក្ដីថា នឹងមិនអាចឲ្យយើងញាប់ញ័របាន ។ បទថា **ធម្មេសម្ហិ បតិដ្ឋិតំ** សេចក្ដីថា តាំងនៅក្នុងធម៌ដែលជាឱវាទរបស់ខ្លួន ហើយអាចបន្ទោបង់សេចក្ដីអផ្សុកចង់សឹក និងធ្វើសេចក្ដីត្រេកអរក្នុងព្រហ្មចរិយៈឲ្យកើតឡើង ។ លោកពោលពាក្យអធិប្បាយទុកដូច្នេះថា ក្នុងកាលមុន នាយខ្មាន់ធ្នូទាំងពាន់ បាញ់កូនសរមកជុំវិញ ដាក់អ្នកដែលសិក្សាជំនាញហើយ ក៏ប្រើកំណាត់ឈើក្រវៀសកូនសរទាំងអស់ ក្នុងចន្លោះមិនឲ្យត្រូវខ្លួន ឲ្យធ្លាក់ចុះជិតជើង បណ្ដានាយខ្មាន់ធ្នូទាំងនោះ ខ្មាន់ធ្នូម្នាក់បាញ់កូនសរបានម្ដង ២ កូន ។ ចំណែកស្ត្រីទាំងនេះ បាញ់កូនសរបានម្ដង ៥ កូន គឺ អារម្មណ៍ មានរូបារម្មណ៍ជាដើម ។ ស្ត្រីដែលបាញ់កូនសរបានយ៉ាងនោះ សូម្បីនឹងមានទាំងពាន់ ក៏មិនអាចធ្វើយើងឲ្យញាប់ញ័របានឡើយ ។

បទថា **សក្ខី ហិ មេ សុតំ ឯតំ** សេចក្ដីថា ផ្លូវទៅកាន់ព្រះនិព្វាននេះ

យើងបានស្តាប់ហើយចំពោះព្រះភ័ក្ត្រព្រះមានព្រះភាគ ។ បទថា **និព្វានគមនំ មគ្គំ** សំដៅយកវិបស្សនា ។ ពិតណាស់ មគ្គនោះ ជាមគ្គចំណែកខាងដើមនៃព្រះនិព្វាន ។ តែលោកពោលថា **មគ្គំ** ព្រោះជាលិង្គវិបល្លាស ។ បទថា **តត្ថ មេ** សេចក្តីថា ចិត្តរបស់យើងមិនត្រេកអរក្នុងផ្លូវទៅកាន់ព្រះនិព្វាន ពោលគឺ វិបស្សនាយ៉ាងទន់ខ្ចីរបស់ខ្លួននោះ ។ លោកហៅកិលេសថា **បាបិមា** ។ ហៅកិលេសនោះឯងថា **មច្ចុ** ក៏មាន ។ បទថា **ន មេ មគ្គម្បិ** សេចក្តីថា យើងនឹងធ្វើដោយប្រការដែលមារមើលមិនឃើញ សូម្បីផ្លូវដែលយើងទៅកាន់ភព និងកំណើតជាដើម ។

ចប់អដ្ឋកថា និក្ខន្តសូត្រទី ១

# អ ដ្ឋ ក ថា

## អរតិសូត្រទី ២

*អរតិសូត្រទី* ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[២០៩]** *បទថា* ***និក្ខមតិ*** *បានដល់ ចេញចាកវិហារ ។ បទថា* ***អបរជ្ជុ កាលេ*** *បានដល់ ក្នុងថ្ងៃទី ២ ឬក្នុងវេលាភិក្ខាចារ ។ បានឮថា ព្រះថេរៈនោះជាអ្នកជូន់ក្នុងវិហារ ។*

**[២១១]** *បទថា* ***អរតិញ្ច រតិញ្ច*** *បានដល់ សេចក្ដីមិនត្រេកអរក្នុងសាសនា និងសេចក្ដីត្រេកអរក្នុងកាមគុណទាំងឡាយ ។ បទថា* ***សព្វសោ គេហសិតញ្ច វិតក្កំ*** *សេចក្ដីថា និងលះវិតក្កៈដ៏លាមក ដែលអាស្រ័យផ្ទះក្នុងកាមគុណ ៥ ដោយអាការទាំងពួង ។ បទថា* ***វនថំ*** *បានដល់ ព្រៃធំ គឺកិលេស ។ បទថា* ***កុហិញ្ចិ*** *បានដល់ ក្នុងអារម្មណ៍ណាៗ ។ បទថា* ***និព្វនថោ*** *បានដល់ អ្នកប្រាសចាកព្រៃ គឺ កិលេស ។ បទថា* ***អរតោ*** *បានដល់ វៀរចាកសេចក្ដីត្រេកអរដោយអំណាចតណ្ហា ។*

*បទថា* ***បឋវិញ្ច វេហាសំ*** *សេចក្ដីថា រូបដែលតាំងនៅលើផែនដី បាន*

ដល់ រូបស្រីប្រុស សំពត់ និងគ្រឿងប្រដាប់ជាដើម និងរូបដែលតាំងនៅក្នុងអាកាស មានពន្លឺព្រះចន្ទ និងព្រះអាទិត្យជាដើម ។ បទថា **រូបគតំ** បានដល់ រូបទាំងឯង ។ បទថា **ជគតោគធំ** បានដល់ រូបដែលនៅក្នុងផែនដី អធិប្បាយថា បានដល់ នាគពិភពខាងក្នុងផែនដី ។ បទថា **បរិជិយ្យតិ** បានដល់ ទ្រុឌទ្រោម ។ បទថា **សព្វមនិច្ចំ** សេចក្ដីថា នុ៎ះ មិនទៀងទាំងអស់ ។ អាចារ្យពួកខ្លះពោលថា នេះជាមហាវិបស្សនារបស់ព្រះថេរៈ ។ បទថា **ឯវំ សមេច្ច** បានដល់ មករួមគ្នាយ៉ាងនេះ ។ បទថា **ចរន្តិ មុតត្តា** សេចក្ដីថា អ្នកមានអត្តភាពដែលដឹងច្បាស់ហើយ ។

បទថា **ឧបធីសុ** បានដល់ ខន្ធ កិលេស និងអភិសង្ខារ ។ បទថា **គធិតា** បានដល់ ជាប់នៅហើយ ។ បទថា **ទិដ្ឋសុតេ** បានដល់ ក្នុងរូបដែលចក្ខុឃើញហើយ ក្នុងសំឡេងដែលសោតៈបានឮហើយ ។ ក្លិន និងរសលោកកាន់យកដោយបទថា **បដិឃៈ** ផោដ្ឋព្វារម្មណ៍ លោកកាន់យកដោយបទថា **មុតៈ** ក្នុងពាក្យថា **បដិឃេ ច មុតេ ច** នេះ ។ បទថា **យោ ឯត្ថ ន លិម្បតិ** សេចក្ដីថា បុគ្គលណាមិនជាប់ជំពាក់នៅក្នុងកាមគុណ ៥ ទាំងនេះ ដោយកិលេស គឺ តណ្ហា និងទិដ្ឋិ ។

បទថា **អថ សដ្ឋិសិតា សវិតក្កា បុថុជ្ជនតាយ អធម្មនិវិដ្ឋា** សេចក្ដី

ថា បើដូច្នោះ វិតក្កៈដែលជាចំណែកអធម៌ជាច្រើន ដែលអាស្រ័យអារម្មណ៍ ៦ ក៏តាំងចុះក្នុងពួកជន ។ បទថា **ន ច វគ្គគតស្ស កុហិញ្ចិ** សេចក្ដីថា មិនគប្បីធ្លាក់ទៅក្នុងវគ្គៈ គឺ កិលេសក្នុងទីណាៗ ដោយអំណាចវិតក្កៈដែលជាចំណែកអធម៌ទាំងនោះ ។ បទថា **នោ បន ទុដ្ឋុល្លភាណី** សេចក្ដីថា មិនគប្បីជាអ្នកពោលវាចាអាក្រក់ គ្រោតគ្រាត ។ បទថា **ស ភិក្ខុ** សេចក្ដីថា អ្នកមានចិត្តយ៉ាងនេះ រមែងឈ្មោះថា ជាភិក្ខុ ។

បទថា **ទព្វោ** បានដល់ បណ្ឌិតមានជាតិជាអ្នកមានបញ្ញា ។ បទថា **ចិររត្តសមាហិតោ** បានដល់ អ្នកមានចិត្តតាំងមាំរហូតដល់អស់កាលយូរ ។ បទថា **និបកោ** បានដល់ អ្នកប្រកបដោយបញ្ញាជាគ្រឿងរក្សាខ្លួន គឺ មានបញ្ញាចាស់ក្លា ។ បទថា **អបិហាលុ** បានដល់ អ្នកប្រាសចាកតណ្ហា ។ បទថា **សន្តំ បទំ** បានដល់ ព្រះនិព្វាន ។ បទថា **អជ្ឈគមា មុនិ** បានដល់ មុនីដែលជាអ្នកបានសម្រេចហើយ ។ បទថា **បដិច្ច បរិនិព្វុតោ កង្ខតិ កាលំ** សេចក្ដីថា អាស្រ័យព្រះនិព្វាន ក៏រលត់ដោយការរលត់កិលេស តែងទន្ទឹងនូវបរិនិព្វានកាល ។

ចប់អដ្ឋកថា អរតិសូត្រទី២

# អ ដ្ឋ ក ថា

## បេសលាតិមញ្ញនាសុត្រទី ៣

*បេសលាតិមញ្ញនាសូត្រទី ៣* មានវិនិច្ឆ័យដូចតទៅនេះ ៖

**[២១២]** *បទថា* ***អតិមញ្ញតិ*** *សេចក្តីថា ព្រះវង្គីសៈមើលងាយថា ភិក្ខុចាស់ៗ ទាំងនេះនឹងដឹងអ្វី បាលីក៏មិនដឹង អដ្ឋកថាក៏មិនដឹង សេចក្តីពីរោះរបស់បទ និងព្យញ្ជនៈក៏មិនដឹង ចំណែកពួកយើង ទាំងបាលី ទាំងអដ្ឋកថាប្រាកដទាំងរយន័យ ពាន់ន័យ ។ ព្រោះខ្លួនជាសាវករបស់ព្រះពុទ្ធ ព្រះនាមគោតម ទើបហៅខ្លួនថា គោតមៈ ។*

**[២១៣]** *បទថា* **មានបថំ** *បានដល់ អារម្មណ៍នៃមានះ និងធម៌ដែលកើតជាមួយមានះ ។ បទថា* ***វិប្បដិសារីហុវា*** *សេចក្តីថា បានជាអ្នកមានសេចក្តីក្តៅក្រហាយចិត្ត ។ បទថា* ***មគ្គជិនោ*** *បានដល់ អ្នកឈ្នះកិលេសដោយមគ្គ ។ បទថា* ***កិត្តិញ្ច សុខញ្ច*** *បានដល់ បានទូវការសរសើរផង និងសេចក្តីសុខផ្លូវកាយផ្លូវចិត្តផង ។ បទថា* ***អខិលោធ បធានវា*** *សេចក្តីថា ភិក្ខុក្នុងលោកនេះ ជាអ្នកមិនមានកិលេស មានសេចក្តីព្យាយាម គឺ បរិបូរណ៍ដោយ*

សេចក្តីព្យាយាម ។ បទថា *វិសុទ្ធោ* សេចក្តីថា គប្បីជាអ្នកបរិសុទ្ធិ ។ បទថា *អសេសំ* បានដល់ លះបង់មានៈ ៩ យ៉ាងមិនឲ្យនៅសល់ ។ បទថា *វិជ្ជាយន្តកវោ* បានដល់ អ្នកធ្វើនូវទីបំផុតនៃកិលេសទាំងឡាយដោយវិជ្ជា ។ បទថា *សមិតាវី* បានដល់ ជាអ្នកស្ងប់ ព្រោះកិលេសមានរាគៈជាដើមស្ងប់ ។

ចប់អដ្ឋកថា បេសលាតិមញ្ញនាសូត្រ ទី ៣

# អ ដ្ឋ ក ថា

## អានន្ទសូត្រទី ៤

*អានន្ទសុត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

**[២១៣]** *បទថា រាគោ ជាដើម សេចក្តីថា ព្រះអានន្ទជាអ្នកមានបញ្ញាច្រើន បានអប់រំខ្លួនល្អហើយ ព្រះរាជា និងមហាមាត្ររបស់ព្រះរាជា និមន្តលោកឲ្យគង់ខាងក្នុងនិវេសន៍ ។ ពួកស្ត្រីប្រដាប់ដោយគ្រឿងប្រដាប់ទាំងពួងចូលទៅរកព្រះថេរៈ ថ្វាយបង្គំហើយបក់ផ្លិតដោយផ្លិតស្លឹកត្នោត ។ អង្គុយសួរបញ្ហា និងស្តាប់ធម៌ ។ ក្នុងទីនោះកាលព្រះវង្គីសៈដែលបួសថ្មី មិនអាចកំណត់អារម្មណ៍បាន តម្រេកក្នុងរូបារម្មណ៍ គឺ ស្ត្រីក៏បៀតបៀនចិត្ត ។ ព្រោះបួសដោយសទ្ធា លោកទើបជាអ្នកត្រង់ គិតថា តម្រេករបស់យើងនេះ កម្រើកខ្លាំងឡើង គប្បីធ្វើប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ខាងមុខឲ្យវិនាស ។ គង់នៅបន្ទាប់ព្រះថេរៈនុ៎ះឯង កាលនឹងបើកបង្ហាញដល់ព្រះថេរៈ ទើបបានពោលពាក្យជាដើមថា* **កាមរាគេន** *ដូច្នេះ ។*

**[២១៤]** *បណ្តាបទទាំងនោះ បទថា* **និព្វាបនំ** *បានដល់ ហេតុជាគ្រឿង*

រំលត់រាគៈ ។

**[២១៦]** បទថា **វិបរិណាមតោ** បានដល់ ដោយឃើញឃ្លាតចាកការពិត ។ បទថា **រាគូបសញ្ហិតំ** បានដល់ ឥដ្ឋារម្មណ៍ជាទីតាំងនៃរាគៈ ។ បទថា **បរតោ បស្ស** សេចក្តីថា ចូរឃើញថាជារបស់មិនទៀង ។ បទថា **មា ច អត្តតោ** សេចក្តីថា ចូរកុំឃើញថាជាអត្តា ។ បទថា **កាយគតា ត្យត្ថុ** សេចក្តីថា លោកចូរមានសតិទៅក្នុងកាយ ។ បទថា **អនិមិត្តញ្ច ភាវេហិ** សេចក្តីថា ព្រោះលោកបើកនិច្ចនិមិត្តជាដើមចេញបាន វិបស្សនា ទើបឈ្មោះថា អនិមិត្ត ។ ព្រះអានន្ទត្រេពោលនឹងព្រះវង្គីសៈនោះថា **ភាវេហិ** លោកចូរចម្រើន ដូច្នេះ ។ បទថា **មានាភិសមយា** បានដល់ ដឹងដោយការឃើញច្បាស់នូវមានះ ព្រោះលះបង់ដោយការដឹងច្បាស់ ។ បទថា **ឧបសន្តោ** បានដល់ ឈ្មោះថា ជាអ្នកស្ងប់ ព្រោះរាគៈជាដើមស្ងប់ ។

ចប់អដ្ឋកថា អានន្ទសូត្រទី ៤

# អ ដ្ឋ ក ថា

## សុភាសិតសូត្រទី ៥

ក្នុងសុភាសិតសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[២១៧]** បទថា *អង្គេហិ* បានដល់ ដោយហេតុ ឬដោយចំណែកទាំងឡាយ ។ ពិតហើយ ហេតុនៃវាចាជាសុភាសិត ៤ មានចេតនាជាគ្រឿងវៀរ-ចាកការនិយាយពាក្យកុហកជាដើម ឬចំណែក ៤ មានសច្ចវាចាជាដើម ។ ក៏បទថា **ចតូហិ** ជាបញ្ចមីវិភត្តិចុះក្នុង **អង្គ** ស័ព្ទ ដែលប្រែថា **ហេតុ** ជាតតិយាវិភត្តិចុះក្នុង **អង្គ** ស័ព្ទ ដែលប្រែថា **ចំណែក** ។ បទថា **សមន្នាគតា** បានដល់ មកព្រមហើយ គឺ ប្រព្រឹត្តទៅហើយ និងប្រកបហើយ ។ បទថា **វាចា** បានដល់ វាចាដែលសន្ទនាគ្នា ។ វាចា ដែលមកក្នុងបាលី មានជាដើមយ៉ាងនេះថា វាចាដែលប្រើនិយាយគ្នា វាចាដែលថ្លែង ពាក្យជាគន្លងដូច្នេះក្តី និងវាចាមិនមានទោស សប្បាយត្រចៀក ដូច្នេះក្តី ឈ្មោះថា វាចា ។ តែវិញ្ញត្តិវាចា យ៉ាងនេះថា បើកម្មដែលបុគ្គលធ្វើដោយវាចាដូច្នេះក្តី វិរតិវាចា យ៉ាងនេះថា ការវៀរចាកវចីទុច្ចរិត ៤ ។ល។ នេះហៅថា សម្មាវាចាដូច្នេះក្តី

ចេតនាវាចាយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ វាចាគ្រោតគ្រាតដែលបុគ្គល សេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងជាផ្លូវនៃនរកដូច្នេះក្តី នេះណា វាចានោះ មកដោយឈ្មោះថា **វាចា** ។ វិញ្ញត្តិវាចាជាដើមនោះ មិនបំណងយកក្នុងបទថា វាចានេះ ព្រោះហេតុអ្វី ។ ព្រោះមិនមែនវាចាដែលគេគប្បីប្រើនិយាយគ្នា ។ បទថា **សុភាសិតា** បានដល់ វាចាដែលគេប្រើនិយាយគ្នាដោយល្អ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់សម្តែងភាពនៃវាចាសុភាសិតនោះថា នាំមកនូវប្រយោជន៍ ។ បទថា **នោ ទុព្ភាសិតា** បានដល់ មិនមែនវាចាដែលគេនិយាយអាក្រក់ ។ ដោយហេតុនោះ ព្រះដ៏មាន-ភាគទើបសម្តែងភាពនៃវាចាទុព្ភាសិតនោះ មិននាំប្រយោជន៍មកឲ្យ ។ បទថា **អនវជ្ជា** បានដល់ វៀរចាកទោស មានរាគៈជាដើម ។ ដោយពាក្យថា **អនវជ្ជា** នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីបរិសុទ្ធិនៃហេតុរបស់វាចានោះ និងសេចក្តីមិនមានទោស ៤ ប្រការ ។ បទថា **អននុវជ្ជា** បានដល់ ផុតអំពីពាក្យតិះដៀលហើយ ។ ដោយពាក្យនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងសម្បត្តិនៃគ្រឿងប្រដាប់ទាំងពួងរបស់វាចានោះ ។ បទថា **វិញ្ញូនំ** បានដល់ បណ្ឌិតទាំងឡាយ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់សម្តែងថា ជន

ពាល កាន់យកជាប្រមាណមិនបានក្នុងការនិន្ទា និងសរសើរ ។ ពាក្យថា **សុភា-សិតំ យេវ ភាសតិ** នេះ ជាពាក្យសម្តែងខែអង្គនៃវាចា ៤ ប្រការណាមួយ ដោយទេសនាជាបុគ្គលាធិដ្ឋាន ។ បទថា **នោ ទុព្ភាសិតំ** នេះ ជាការហាមការ និយាយដែលជាបដិបក្ខចំពោះអង្គរបស់វាចានោះឯង ។ ម្យ៉ាងទៀត ដោយពាក្យ ថា **នោ ទុព្ភាសិតំ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងការលះបង់មិច្ឆាវាចា ។ ដោយពាក្យថា **សុភាសិតំ** នេះ សម្តែងដល់លក្ខណៈនៃពាក្យដែលអ្នកលះបង់ មិច្ឆាវាចាបានហើយគប្បីនិយាយ ។ តែដើម្បីសម្តែងដល់អង្គ ព្រះមានព្រះភាគ មិនបានត្រាស់ពាក្យដែលមិនគួរនិយាយមុន ត្រាស់តែពាក្យដែលគួរនិយាយ ប៉ុណ្ណោះ ។ សូម្បីក្នុងពាក្យថា **ធម្មំ យេវ** ជាដើមក៏ន័យនេះ ។ ក៏ក្នុងអង្គ ទាំងនោះ ដោយអង្គទីមួយ ព្រះអង្គត្រាស់ដល់ពាក្យដែលធ្វើសេចក្តីព្រមព្រៀង ដែលវៀរចាកទោស គឺ ការស៊កសៀត ។ ដោយអង្គទី ២ ត្រាស់ដល់ពាក្យ ប្រកបដោយមេត្តា វៀរចាកទោសសម្ផប្បលាបៈ គឺ មិនប្រាសចាកធម៌ ។ ដោយ ២ អង្គក្រៅនេះ ត្រាស់ដល់ការពោលពាក្យសច្ចៈដែលគួរស្រឡាញ់ ដែលវៀរពាក្យគ្រោតគ្រាត និងពាក្យឡេះឡោះ ។ ព្រះមានព្រះភាគ កាល ទ្រង់សម្តែងអង្គទាំងនោះ មានពាក្យថា **ឥមេហិខោ** ជាដើម ដើម្បីឲ្យជាក់ច្បាស់

ទើបត្រាស់ពាក្យដដែលនោះ ។ ក៏ព្រះមានព្រះភាគទ្រង់បដិសេធ សូម្បីការពោលមុសាវាទជាដើម ដែលប្រកបដោយចំណែកមានបដិញ្ញាជាដើម ដោយបទ មាននាមជាដើម និងដោយសម្បត្តិ គឺ លិង្គ វចនៈ វិភត្តិ កាល និងការកៈជាដើម ដែលបុគ្គលពួកដទៃសម្គាល់ថា ជាវាចាសុភាសិត ។ ពិតណាស់វាចាបែបនោះ សូម្បីប្រកបដោយចំណែកជាដើម ជាវាចាទុព្ភាសិត ព្រោះនាំសេចក្តីវិនាសមកឲ្យដល់ខ្លួន ទាំងដល់ជនដទៃ ។ ចំណែកវាចាដែលប្រកបដោយអង្គ ៤ នេះ សូម្បីបើជាវាចារាប់បញ្ចូលក្នុងភាសាមិលក្ខៈ (ភាសាមនុស្សព្រៃ) ក្តី ជាវាចារាប់បញ្ចូលក្នុងចម្រៀងរបស់ក្មេងស្រីអ្នកនាំថ្នាំងទឹកក្តី វាចាបែបនោះ ឈ្មោះថា ជាវាចាសុភាសិត ព្រោះនាំមកនូវសេចក្តីសុខ ទាំងជាលោកិយៈ និងលោកុត្តរៈ ។ ពិតយ៉ាងនោះ ភិក្ខុដែលចម្រើនវិបស្សនាប្រមាណ ៦០ រូប កំពុងធ្វើដំណើរ បានឮចម្រៀងរបស់ក្មេងស្រីអ្នកសីហឡៈអ្នករក្សាសន្ទូងនៅក្បែរផ្លូវ កំពុងច្រៀងនូវចម្រៀងដែលជាប់ទាក់ទងជាតិជរានិងមរណៈ ដោយភាសាអ្នកសីហឡៈ ក៏សម្រេចព្រះអរហត្ត ។ មួយទៀតភិក្ខុដែលប្រារព្ធវិបស្សនា ឈ្មោះថា តិស្សៈ កំពុងធ្វើដំណើរជិតស្រះបទុមបានឮចម្រៀងរបស់ក្មេងស្រីអ្នកកាច់ផ្កាបទុមក្នុងស្រះបទុមច្រៀងបណ្តើរថា ៖

ផ្កាបទុម ឈ្មោះ កោកនទៈ រីកពីព្រឹកព្រលឹម
រមែងស្ថិតទៅដោយពន្លឺព្រះអាទិត្យ យ៉ាងណា
សត្វទាំងឡាយដែលដល់ភាពជាមនុស្ស រមែង
ស្ថិតស្រពោនទៅ ដោយកម្លាំងខ្លាំងក្លានៃជរា
ដូច្នោះ ។

ហើយសម្រេចព្រះអរហត្ត ។ មួយទៀត បុរសម្នាក់ក្នុងពុទ្ធន្តរ (ក្នុងវេលាចន្លោះព្រះពុទ្ធ) ត្រឡប់អំពីព្រៃព្រមទាំងបុត្រ ៧ នាក់ ស្ដាប់ចម្រៀងរបស់ស្ត្រីម្នាក់ ដែលកំពុងបុកស្រូវ ដូច្នេះថា ៖

សរីរៈនេះ អាស្រ័យស្បែកមានសម្បុរស្ងួតៗ ត្រូវ
ជរាញាំញីហើយ សរីរៈនេះដល់ភាពជាអាមិស គឺ
ចំណីរបស់មច្ចុ រមែងបែកធ្លាយទៅ ព្រោះមរណៈ
សរីរៈនេះ ជាទីនៅរបស់ពួកដង្កូវ ពេញទៅដោយ
សាកសពផ្សេងៗ សរីរៈនេះ ជាភាជនៈរបស់មិន
ស្អាត សរីរៈនេះ ស្មើដោយកំណាត់ដើមចេក ។

បុរសនោះពិចារណាហើយ ក៏សម្រេចបច្ចេកពោធិញ្ញាណ ព្រមទាំង

បុត្រទាំងឡាយ ។ វាចាប្រកបដោយអង្គ ៤ ទាំងនេះ សូម្បីរាប់បញ្ចូលក្នុងកាសារបស់អ្នកមិលក្ខៈ ឬរាប់បញ្ចូលក្នុងចម្រៀងរបស់ស្ត្រីអ្នកកាន់ថ្នាំងទឹកទៅសោត ទោះជាយ៉ាងនោះ ក៏គប្បីជ្រាបថា ជាវាចាសុភាសិត ។ វាចាឈ្មោះថាមិនមានទោស ទាំងវិញ្ញូជនអ្នកប្រាថ្នាប្រយោជន៍ អាស្រ័យតែអត្ថ មិនមែនអាស្រ័យព្យញ្ជនៈ មិនគប្បីតិះដៀល ព្រោះជាវាចាសុភាសិត ។

[២១៩] បទថា **សរូបាហិ** បានដល់ សមគួរ ។ បទថា **អភិត្ថវិ** បានដល់ សរសើរហើយ ។ បទថា **ន តាបយេ** សេចក្តីថា មិនគប្បីធ្វើខ្លួនឲ្យក្តៅក្រហាយ គឺ មិនគប្បីបៀតបៀនខ្លួនឲ្យក្តៅចិត្ត ។ បទថា **បរេ** សេចក្តីថា មិនទម្លាយអ្នកដទៃឲ្យក្តៅក្រហាយ ។ ព្រះវង្គីសៈសរសើរព្រះមានព្រះភាគដោយអបិសុណាវាចាដោយគាថានេះ ដោយប្រការដូច្នេះ ។ បទថា **បដិនន្ទិតា** បានដល់ ប្រព្រឹត្តជាទីគួរស្រឡាញ់ ។ បទថា **យំ អនាទាយ** សេចក្តីថា ព្រះវង្គីសៈសរសើរដោយអំណាចវាចាដែលគួរស្រឡាញ់ថា បុគ្គលកាលពោលវាចាណា មិនកាន់យកពាក្យគ្រោតគ្រាតដ៏លាមក មិនជាទីស្រឡាញ់របស់បុគ្គលពួកដទៃ ពោលតែពាក្យជាទីស្រឡាញ់ដ៏ពីរោះទាំងអត្ថៈ និងព្យញ្ជនៈប៉ុណ្ណោះ គប្បីពោលតែវាចានោះ ។

បទថា **អមតា** បានដល់ ជាវាចាប្រាកដដូចទឹកអម្រឹត ព្រោះញ៉ាំងប្រយោជន៍ឲ្យសម្រេច ។ សមពិតដូចដែលត្រាស់ទុកថា **សច្ចំ ហវេ សាធុតរំ រសានំ** ពាក្យសច្ចនោះឯងប្រសើរជាងរសទាំងឡាយ ដូច្នេះ ។ម្យ៉ាងទៀត ឈ្មោះថា **អមតវាចា** ព្រោះជាបច្ច័យនៃព្រះអមតមហានិព្វាន ។ បទថា **ឯស ធម្មោ សនន្តនោ** សេចក្តីថា ឈ្មោះថា សច្ចវាចានេះ ជាធម៌ ជាចរិយា ជាប្រពៃណីចាស់ ។ ពិតណាស់ ពាក្យសច្ចនេះឯងបណ្ឌិតក្នុងកាលមុនធ្លាប់ប្រព្រឹត្តមកហើយ ។ លោកទាំងនោះមិនពោលពាក្យឡេះឡោះ ។ ដោយហេតុនោះឯងព្រះមានព្រះភាគ ទើបត្រាស់ថា សប្បុរសទាំងឡាយជាអ្នកតាំងនៅក្នុងសច្ចៈដែលជាអត្ថ និងជាធម៌ ដូច្នេះ ។

ក្នុងព្រះបាលីនោះ គប្បីជ្រាបថា សច្ចវាចានេះ ឈ្មោះថា តាំងនៅក្នុងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ព្រោះតាំងនៅក្នុងសច្ចៈនុ៎ះឯង និងឈ្មោះថា តាំងនៅក្នុងធម៌ ព្រោះតាំងនៅក្នុងប្រយោជន៍នុ៎ះឯង ។ ម្យ៉ាងទៀត ពាក្យថា អត្ថៈ និងធម៌ ទាំងពីរនោះ ជាវិសេសនៈរបស់ពាក្យថា សច្ចៈ នុ៎ះឯង ។ សេចក្តីពិត លោកពោលពាក្យអធិប្បាយទុកដូច្នេះថា វាចានោះតាំងនៅក្នុងសច្ចៈ តាំងនៅក្នុងសច្ចៈយ៉ាងណា ។ តាំងនៅក្នុងសច្ចៈ ដែលជាអត្ថ និង

ជាធម៌ ដែលឲ្យសម្រេចប្រយោជន៍ គឺ ធ្វើមិនខុសប្រយោជន៍ ព្រោះមិនប្រាសចាកប្រយោជន៍អ្នកដទៃ ឲ្យសម្រេចប្រយោជន៍ដែលជាធម៌ គឺ ប្រកបដោយធម៌នុ៎ះឯង ព្រោះមិនប្រាសចាកធម៌ ។ ព្រះវង្គីសៈសរសើរព្រះមានព្រះភាគ ដោយសច្ចដោយគាថានេះ ដោយប្រការដូច្នេះ ។ បទថា **ខេមំ** បានដល់ រួចផុតភ័យ គឺ ប្រាសចាកអន្តរាយ ។ ប្រសិនបើសួរថា ព្រោះហេតុអ្វី ។ គប្បីឆ្លើយថា ព្រោះដល់សេចក្តីរលត់ ព្រោះធ្វើឲ្យអស់ទុក្ខ ។ អធិប្បាយថា ព្រោះឲ្យដល់សេចក្តីរលត់កិលេស និងប្រព្រឹត្តទៅដើម្បីធ្វើឲ្យអស់ទុក្ខក្នុងវដ្តៈ ។ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់ព្រះវាចាណា ដែលជាវាចាក្សេម ព្រោះប្រកាសមគ្គដែលក្សេម ដើម្បីប្រយោជន៍របស់និព្វានធាតុទាំងពីរ គឺ ដើម្បីដល់ព្រះនិព្វាន ដើម្បីធ្វើឲ្យអស់ទុក្ខ ។ ក្នុងពាក្យថា **សា វេ វាចានមុត្តមា** នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា វាចានោះប្រសើរបំផុតជាងវាចាទាំងពួង ដូច្នេះ ។ ព្រះវង្គីសៈកាលសរសើរព្រះមានព្រះភាគដោយពាក្យប្រកបដោយបញ្ញា ដោយគាថានេះ ឲ្យចប់ទេសនាដល់កំពូលធម៌ គឺ ព្រះអរហត្ត ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា សុភាសិតសូត្រទី៥

# អ ដ្ឋ ក ថា

## សារីបុត្តសូត្រទី ៦

ក្នុងសារីបុត្តសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[២២០]** បទថា **បោរិយា** បានដល់ បរិបូណ៌ដោយអក្ខរ និងបទ ។ បទថា **វិសដ្ឋាយ** បានដល់ វាចាដែលមិនជាប់ទាក់ទងដោយទោស ។ ក៏កាលព្រះធម្មសេនាបតីពោល រមែងមានវាចាមិនពាក់ព័ន្ធដោយពាក្យប្រមាត់ ជាដើម រមែងបន្លឺសំឡេងដូចសំឡេងរគាំង ដែលត្រូវគោះដោយកំណាត់ដែក ។ បទថា **អនេលគឡាយ** បានដល់ មិនមានទោស មិនឃ្លៀងឃ្លាត គឺ ប្រាសចាកទោស និងមានបទព្យញ្ជនៈមិនឃ្លៀងឃ្លាត ។ ពិតហើយ កាលព្រះថេរៈពោលដោយបទ ឬព្យញ្ជនៈរមែងមិនបាត់បង់ ។ បទថា **អត្ថស្ស វិញ្ញាបនិយា** បានដល់ អាចធ្វើអ្នកស្តាប់ឲ្យដឹងនូវអត្ថយ៉ាងជាក់ច្បាស់ ។ បទថា **ភិក្ខូនំ** គឺ បានដល់ ភិក្ខុទាំងឡាយ ។

**[២២២]** បទថា **សង្ខិត្តេនបិ** សេចក្តីថា ព្រះសារីបុត្តត្រេរសម្តែងដោយសង្ខេបយ៉ាងនេះខ្លះថា អាវុសោ អរិយសច្ច ៤ ទាំងនេះ អរិយសច្ច ៤ គឺ អ្វី

ខ្វះ គឺ ទុក្ខអរិយសច្ច ។ល។ អាវុសោ អរិយសច្ច ៤ ទាំងនេះឯង ព្រោះហេតុនោះឯង ម្នាលអាវុសោ លោកគប្បីធ្វើសេចក្តីព្យាយាមថា នេះទុក្ខអរិយសច្ច ។ បទថា **វិត្ថារេនបិ** សេចក្តីថា ព្រះសារីបុត្រកាលនឹងចែកអរិយសច្ច ៤ ទាំងនោះ ទើបពោលដោយពិស្តារដោយន័យមានជាដើមថា ម្នាលអាវុសោ ទុក្ខអរិយសច្ច តើដូចម្តេច ដូច្នេះ ។ សូម្បីក្នុងទេសនា ខន្ធជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **សាលិកា វិយ និគ្ឃោសោ** សេចក្តីថា កាលព្រះថេរៈសម្តែងធម៌ រមែងមានសំឡេងពីរោះដូចសំឡេងរបស់សត្វសាលិកា ដែលភ្លក់រសស្វាយទុំមានរសផ្អែម ទទះស្លាបបន្លឺសំឡេងពីរោះ ។ បទថា **បដិភានំ មុទីរយិ** សេចក្តីថា បដិភាណកើតឡើងមិនមានទីបំផុត ដូចរលកកើតអំពីសមុទ្រ ។ បទថា **ឱធេន្តិ** បានដល់ ភិក្ខុពួកនោះ រមែងផ្ទៀងសោតៈស្តាប់ ។

ចប់អដ្ឋកថា សារីបុត្តសូត្រទី៦

# អ ដ្ឋ ក ថា

## បវារណាសូត្រទី ៧

ក្នុងបវារណាសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២២៣] បទថា **តទហុ** កាត់បទជា **តស្មឹ អហុ** សេចក្ដីថា ក្នុងថ្ងៃនោះ ។ ឈ្មោះថា **ឧបោសថ** ព្រោះជាទីចូលទៅរក្សា ។ បទថា **ឧបវសន្តិ** សេចក្ដីថា ជាអ្នកចូលទៅរក្សាសីល ឬដោយការមិនបរិភោគបាយ ។ ក៏ថ្ងៃឧបោសថនេះ មាន ៣ យ៉ាង ដោយចែកជាថ្ងៃ ៨ ថ្ងៃ ១៤ និងថ្ងៃ ១៥ ព្រោះដូច្នោះ ដើម្បីនឹងហាមថ្ងៃទាំង ២ ដ៏សេសទើបពោលថា **បណ្ណរសេ** ។ បទថា **បវារណាយ** បានដល់ ចេញវស្សាបវារណាហើយ ។ សូម្បីពាក្យថា **វិសុទ្ធិ-បវារណា** ដូច្នេះ ក៏ជាឈ្មោះរបស់បវារណានោះ ។ បទថា **និសិន្នោ ហោតិ** សេចក្ដីថា ក្នុងវេលាល្ងាច ព្រះមានព្រះភាគទ្រង់សម្ដែងធម៌ដែលសមគួរដល់កាល ដល់បរិស័ទអ្នកមកប្រជុំគ្នា ទ្រង់ស្រង់ព្រះវរកាយក្នុងបន្ទប់ទឹក ទ្រង់ស្លៀកដណ្ដប់ ធ្វើសុគតមហាចីវរចៀងស្មា ប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរដែលគេរៀបចំទុក ផ្អែកត្រង់សសរកណ្ដាល ។ បទថា **តុណ្ហីភូតំ** សេចក្ដីថា ជាអ្នក

សៀមស្ងាត់នៅក្នុងទិសដែលទ្រង់ក្រឡេកមើល ។ ក្នុងពួកភិក្ខុទាំងនោះសូម្បីតែមួយអង្គក៏មិនបានមានសេចក្ដីឃ្នើសឃ្នងដៃជើង ទាំងអស់ស្ងៀមស្ងាត់អង្គុយដោយឥរិយាបថស្ងប់ ។ បទថា **អនុវិលោកេត្វា** សេចក្ដីថា ទ្រង់ប្រើព្រះនេត្រដែលមានប្រសាទទាំង ៥ ប្រាកដរមិលមើល ។ ស័ព្ទថា **ហន្ទ** ជានិបាតចុះក្នុងអត្ថនៃឧបសគ្គ ។ ន អក្សរក្នុងពាក្យថា **ន ច មេ កិញ្ចិ គរហថ** នេះប្រើក្នុងអត្ថនៃពាក្យសួរថា **ន ច កិញ្ចិ** ដូច្នេះ ។ អធិប្បាយថា ពួកអ្នកនឹងតិះដៀលអ្វីៗ ដល់យើងឬ បើពួកអ្នកនឹងតិះដៀល តថាគតបំណងឲ្យពួកអ្នកពោលស្ដី ។ ដោយពាក្យថា **កាយិកំ វា វាចសិកំ វា** នេះ ព្រះអង្គបវារណាកាយទ្វារ និងវចីទ្វារប៉ុណ្ណោះ មិនបានបវារណាដល់មនោទ្វារ ។ ព្រោះហេតុអ្វី ។ ព្រោះប្រាកដហើយ ។ ពិតណាស់ ក្នុងកាយទ្វារ និងវចីទ្វារ មានកំហុសប្រាកដ ក្នុងមនោទ្វារមិនបានប្រាកដ សូម្បីកាលដេកនៅលើគ្រែតែមួយជាមួយគ្នា សួរថា លោកគិតអ្វី ទើបជ្រាបវារៈចិត្តបាន ។ ព្រះមានព្រះភាគ ទ្រង់មិនបានបវារណាដល់មនោទ្វារ ព្រោះសេចក្ដីមិនប្រាកដដោយប្រការដូច្នេះ មិនមែនទ្រង់មិនបវារណា ព្រោះមិនបរិសុទ្ធិ ។ ពិតណាស់ មនោទ្វាររបស់ព្រះ-មានព្រះភាគ សូម្បីជាព្រះពោធិសត្វ ក្នុងជាតិជាភូរិទត្ត ឆទ្ទន្ត សង្ខបាល និង

ធម៌បាលជាដើម ក៏បរិសុទ្ធ ។ ឥឡូវនេះ មិនមានពាក្យដែលនឹងត្រូវពោល ក្នុងសេចក្ដីនេះឡើយ ។

[២២៤] បទថា **ឯតទវោច** សេចក្ដីថា ព្រោះលោកតាំងនៅក្នុងតំណែងព្រះធម្មសេនាបតី លោកទទួលនាទីគ្រប់គ្រងភិក្ខុសង្ឃ ទើបបានក្រាបទូលយ៉ាងនេះ ។ បទថា **ន ខោ មយំ ភន្តេ** សេចក្ដីថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមិនតិះដៀលអ្វីៗ ចំពោះព្រះមានព្រះភាគ ។ បទថា **កាយិកំ វា វាចសិកំ វា** នេះ ព្រះថេរៈពោលសំដៅយកសេចក្ដីបរិសុទ្ធិ ៤ យ៉ាង មានកាយសមាចារដែលបរិសុទ្ធិជាដើម ដែលមិនត្រូវរក្សា ។ ពិតហើយ ព្រះមាន-ព្រះភាគទ្រង់មិនចាំបាច់រក្សាសេចក្ដីបរិសុទ្ធិ ៤ យ៉ាង ។ ដូចដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីបរិសុទ្ធិដែលតថាគតមិនត្រូវរក្សា ៤ យ៉ាងទាំងនេះ ៤ យ៉ាងអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគត មានកាយសមាចារបរិសុទ្ធិ តថាគតមិនមានកាយទុច្ចរិតដែលនឹងគប្បីរក្សាថា អ្នកដទៃកុំបានដឹងវត្ថុនេះរបស់យើងឡើយ ម្នាលភិក្ខុទាំងឡាយ តថាគត មានវចីសមាចារ-បរិសុទ្ធិ តថាគតមិនមានវចីទុច្ចរិតដែលនឹងគប្បីរក្សាថា អ្នកដទៃកុំបានដឹងវត្ថុនេះរបស់យើងឡើយ ម្នាលភិក្ខុទាំងឡាយ តថាគត មានមនោសមាចារបរិ-

សុទ្ធិ តថាគតមិនមានមនោទុច្ចរិតដែលនឹងគប្បីរក្សាថា អ្នកដទៃកុំបានដឹងវត្ថុនេះរបស់យើងឡើយ ម្នាលភិក្ខុទាំងឡាយ តថាគត មានអាជីវៈបរិសុទ្ធិ តថាគតមិនមានមិច្ឆាជីវៈដែលនឹងគប្បីរក្សាថា អ្នកដទៃកុំបានដឹងវត្ថុនេះរបស់យើងឡើយ ដូច្នេះ ។

ឥឡូវនេះ ព្រះថេរៈកាលសរសើរព្រះគុណតាមសេចក្តីពិតរបស់ព្រះ-មានព្រះភាគ ទើបពោលពាក្យជាដើមថា **ភគវា ហិ ភន្តេ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អនុប្បន្នស្ស** សេចក្តីថា ដែលសមណៈដទៃមិនធ្លាប់ឲ្យកើតឡើង តាំងពីព្រះកស្សបសម្មាសម្ពុទ្ធ ។ បទថា **អសញ្ជាតស្ស** នេះ ជាវេវចនៈរបស់បទថា **អនុប្បន្នស្ស** នុ៎ះឯង ។ បទថា **អនក្ខាតស្ស** បានដល់អ្នកដទៃមិនបានសម្តែង ។ បទថា **បច្ឆា សមន្នាគតា** សេចក្តីថា ព្រះមាន-ព្រះភាគស្តេចទៅមុនហើយ ព្រះសាវកមកប្រជុំគ្នាខាងក្រោយ ។ ដូច្នោះ ព្រះថេរៈអាស្រ័យព្រះអរហត្តមគ្គនុ៎ះឯង សរសើរព្រះគុណ ព្រោះហេតុដែលព្រះគុណទាំងឡាយ មានសីលជាដើមរបស់ព្រះមានព្រះភាគទាំងអស់ ក៏មកប្រជុំចុះហើយ ព្រោះអាស្រ័យព្រះអរហត្តមគ្គប៉ុណ្ណោះ ។ ដោយហេតុនោះ ព្រះគុណទាំងពួង រមែងជាការដែលលោកពោលហើយឯង ។ ពាក្យថា **អហញ្ច ខោ**

**ភន្តេ** នេះ ព្រះថេរៈពោលបវារណាសមាចារផ្លូវកាយ ផ្លូវវាចា ទាំងរបស់ខ្លួន ទាំងរបស់សង្ឃចំពោះព្រះមានព្រះភាគដែលជាអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក ។

បទថា **បិតរា បវត្តិតំ** សេចក្តីថា កាលស្តេចចក្រពត្តិសោយទិវង្គត ឬទ្រង់ព្រះផ្នួសកន្លងទៅ ៧ ថ្ងៃ ចក្រ រមែងអន្តរធាន តពីនោះ កាលព្រះឱរសទ្រង់អង្គុយបំពេញចក្កវត្តិវត្ត ១០ យ៉ាង ឬ ១២ យ៉ាង ចក្រដទៃ រមែងប្រាកដ ព្រះឱរសនោះទ្រង់ឲ្យចក្រនោះប្រព្រឹត្តទៅ តែព្រះមានព្រះភាគ ទ្រង់ធ្វើចក្កនោះឯងឲ្យជាវត្ត ព្រោះមានអត្ថដូចគ្នា ព្រោះជាហេតុឲ្យសម្រេចរតនៈ ទើបត្រាស់ថា **បិតរា បវត្តិតំ** ដូចេះ ។ ន័យម្យ៉ាងទៀត ព្រោះហេតុដែលព្រះឱរសត្រាស់ថា សូមព្រះអង្គចូរជាអ្នកខ្វល់ខ្វាយតិចចុះ ខ្ញុំព្រះអង្គនឹងគ្រប់គ្រង ដូច្នេះ ដូច្នោះ ទើបឈ្មោះថា រមែងគ្រប់គ្រងអាណាចក្រដែលព្រះបិតាគ្រប់គ្រង ។ បទថា **សម្មទេវ អនុបវត្តេសិ** សេចក្តីថា ចូរឲ្យប្រព្រឹត្តទៅដោយប្រពៃ គឺ ដោយន័យ ដោយហេតុ ដោយការណ៍នុ៎ះឯង ។ ក៏ព្រះមាន-ព្រះភាគត្រាស់ធម៌ គឺ អរិយសច្ច ៤ ព្រះថេរៈក៏ពោលតាមធម៌ គឺ អរិយសច្ច ៤ នោះឯង ហេតុនោះ ទើបត្រាស់យ៉ាងនេះ ។ បទថា **ឧភតោភាគវិមុត្តា**

សេចក្ដីថា រួចផុតដោយចំណែកទាំង ២ គឺ រួចផុតពីរូបកាយ ដោយអរូបាវចរសមាបត្តិ រួចផុតពីនាមកាយ ដោយអរិយមគ្គ ។ បទថា **បញ្ញាវិមុត្តា** បានដល់ រួចផុតដោយបញ្ញា ។ គឺ ជាព្រះខីណាស្រពអ្នកមិនបានវិជ្ជា ៣ ជាដើម ។

**[២២៥]** បទថា **វិសុទ្ធិយា** បានដល់ ដើម្បីត្រូវការសេចក្ដីបរិសុទ្ធិ ។ បទថា **សញ្ញោជនពន្ធនច្ឆិទា** បានដល់ កាត់កិលេស ពោលគឺ គ្រឿងប្រកប និងកិលេស ពោលគឺ គ្រឿងចងបាន ។ បទថា **វិជិតសង្គាមំ** បានដល់ ឈ្នះសង្គ្រាម គឺ រាគៈ ទោសៈ មោហៈ ។ សូម្បីឈ្នះកងទ័ពមារ ក៏ឈ្មោះថា ឈ្នះសង្គ្រាម ។ បទថា **សត្ថវាហំ** សេចក្ដីថា ព្រះមានព្រះភាគ ព្រះនាមថា **សត្ថវាហៈ** ជាអ្នកនាំពួកសត្វ ព្រោះទ្រង់នាំពួកវេនេយ្យសត្វ លើកឡើងលើរថ គឺ មគ្គប្រកបដោយអង្គ ៨ ឲ្យឆ្លងសង្សារវដ្ដ ។ ព្រះមានព្រះភាគទ្រង់នាំពួកសត្វទាំងនោះ ។ បទថា **បយិរុបា** បានដល់ ខាងក្នុងទទេ គឺ ទ្រុស្ដសីល ។ ដោយបទថា **អាទិច្ចពន្ធុំ** នេះ ព្រះវង្គីសៈពោលថា ខ្ញុំព្រះអង្គសូមថ្វាយបង្គំព្រះមានព្រះភាគទ្រង់ជាផៅពង្សនៃព្រះអាទិត្យ ជាសាស្ដា ជាព្រះទសពលញ្ញាណ ដូច្នេះ ។

ចប់អដ្ឋកថា បវារណាសូត្រទី ៧

# អ ដ្ឋ ក ថា

## បរោសហស្សសូត្រទី ៨

ក្នុងបរោសហស្សសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២២៨] បទថា **បរោសហស្សំ** បានដល់ លើស ១,០០០ ។ បទថា **អកុតោភយំ** សេចក្ដីថា ក្នុងព្រះនិព្វានមិនមានភ័យអំពីទីណាៗ ។ ពិតណាស់ អ្នកសម្រេចព្រះនិព្វានក៏មិនមានភ័យអំពីទីណាៗ ដូច្នោះ ព្រះនិព្វានទើបឈ្មោះថា មិនមានភ័យពីទីណាៗ ។ បទថា **ឥសីនំ ឥសិសត្តមោ** សេចក្ដីថា ជាឥសីអង្គទី ៧ ចាប់តាំងពីព្រះពុទ្ធទ្រង់ព្រះនាមថា វិបស្សី ។

ពាក្យថា **កឹ នុ តេ វង្គីស** នេះ ព្រះមានព្រះភាគត្រាស់តាមរឿងដែលកើតឡើង ។ បានឮថា មានរឿងកើតឡើងកណ្ដាលសង្ឃថា ព្រះវង្គីសត្ថេរលះបង់វត្ត មិនខ្វល់ខ្វាយដល់ឧទ្ទេស បរិបុច្ឆា និងយោនិសោមនសិការ ត្រាច់តែផ្គងគាថាធ្វើបទរឿយៗ ទៅ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះ មិនដឹងបដិភាណសម្បត្តិរបស់ព្រះវង្គីសៈ យល់ថា ព្រះវង្គីសៈគិតហើយគិតទៀតទើបពោល តថាគតនឹងឲ្យភិក្ខុទាំងនេះ ដឹងបដិភាណសម្បត្តិ

របស់គេ លុះទ្រង់ព្រះតម្រិះហើយ ទើបត្រាស់ពាក្យមានជាដើមថា **កឹ នុ តេ វង្គីស** ដូច្នេះ ។

[២២៩] បទថា **ឧម្មគ្គសតំ** បានដល់ កិលេសដែលផុសឡើងច្រើនរយ ។ មួយទៀត លោកពោល **សត** ព្រោះជាផ្លូវដែលប្រព្រឹត្តទៅ ។ បទថា **បភិជ្ជ ខីលានិ** សេចក្តីថា ទ្រង់យាងទៅទម្លាយបង្គោល គឺ កិលេសទាំង ៥ មានបង្គោល គឺ រាគៈជាដើម ។ បទថា **តំ បស្សថ** សេចក្តីថា ចូរមើលព្រះពុទ្ធនោះ ទ្រង់ស្តេចយាងទៅគ្រប់សង្កាត់ និងបំបាក់យ៉ាងនេះ ។ បទថា **ពន្ធបមុញ្ចករំ** បានដល់ ទ្រង់ធ្វើការស្រាយកិលេសដែលជាគ្រឿងចង ។ បទថា **អសិតំ** បានដល់ ទ្រង់ជាបុគ្គលដែលកិលេសមិនអាស្រ័យហើយ ។ បទថា **ភាគសោ បវិភជ្ជំ** សេចក្តីថា ព្រះអង្គទ្រង់ចែកធម៌ជាចំណែកៗ មានសតិប្បដ្ឋានជាដើម ។ បាឋៈថា **បវិភជ** ដូច្នេះក៏មាន សេចក្តីថា ចូរចែកជាចំណែកតូចធំ ។

បទថា **ឱឃស្ស** បានដល់ ឱឃៈ ៤ ។ បទថា **អនេកវិហិតំ** បានដល់ មានច្រើនយ៉ាង មានសតិប្បដ្ឋានជាដើម ។ បទថា **តស្មឹ ចេ អមតេ អក្ខាតេ** សេចក្តីថា កាលព្រះអង្គត្រាស់ប្រាប់ផ្លូវដែលជាអមតៈនោះ ។ បទថា **ធម្មទ្ទសា**

បានដល់ ទ្រង់ឃើញធម៌ ។ បទថា **ឋិតា** **អសំហិរា** សេចក្តីថា ជាអ្នកស្ថិតនៅ

មិនរសេមរសាម ។

បទថា **អតិវិជ្ឈ** បានដល់ ចាក់ធ្លុះហើយ ។ បទថា **សព្វទិដ្ឋីនំ** បានដល់

ទីតាំងនៃទិដ្ឋិ ឬវិញ្ញាណដ្ឋិតិទាំងពួង ។ បទថា **អតិក្កម្មទ្ទស** បានដល់ បាន

ឃើញព្រះនិព្វានដែលជាធម៌ឈានកន្លងនូវវដ្តៈ ។ បទថា **អគ្គំ** បានដល់ ជា

ធម៌ខ្ពង់ខ្ពស់ ។ បាឋៈថា **អគ្គេ** ដូច្នេះក៏មាន ។ សេចក្តីថា មុនដំបូង ។ បទថា

**ទសដ្ឋានំ** សេចក្តីថា ទ្រង់សម្តែងធម៌ដ៏ប្រសើរដល់ភិក្ខុ ៥ រូប គឺ បញ្ចវគ្គិយ

ឬទ្រង់សម្តែងធម៌ក្នុងឋានៈដ៏ប្រសើរដល់ភិក្ខុបញ្ចវគ្គិយ ។ បទថា **តស្មា** សេចក្តី

ថា ព្រោះហេតុដែលអ្នកដឹងថា ធម៌នេះ ទ្រង់សម្តែងល្អហើយ មិនគប្បីធ្វើ

សេចក្តីប្រមាទ ដូច្នោះ ។ បទថា **អនុសិក្ខេ** បានដល់ គប្បីសិក្សាសិក្ខា ៣ ។

ចប់អដ្ឋកថា បរោសហស្សសូត្រទី ៨

# អ ដ្ឋ ក ថា

## កោណ្ឌញ្ញសូត្រទី ៩

ក្នុងកោណ្ឌញ្ញសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[២៣០]** បទថា *អញ្ញាកោណ្ឌញ្ញោ* បានដល់ ព្រះថេរៈដែលមានឈ្មោះយ៉ាងនោះ ព្រោះសម្រេចនូវធម៌មុនគេ ។ បទថា *សុចិរស្សេវ* បានដល់ អស់កាលយូរប៉ុនណា គឺ អស់កាលប្រមាណ ១២ ឆ្នាំនេះ ។ សួរថា នៅក្នុងទីណា ។ ឆ្លើយថា នៅក្នុងស្ថានទីនៅនៃព្រះបច្ចេកពុទ្ធទាំងឡាយ ជិតស្រះមន្ទាគិនីបោក្ខរណី ក្នុងអាវាសដ៏វិត្រកូលឆទ្ទន្តៈ ។ ព្រោះហេតុអ្វី ។ ព្រោះជាអ្នកជូន់ក្នុងវិហារ ។ ក៏លោកជាព្រះមហាសាវកអ្នកមានបុណ្យ គុណរបស់លោក ផ្សាយទៅក្នុងខាងក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងមុំនចក្រវាឡដូចព្រះគុណរបស់ព្រះមានព្រះភាគ ។ ទេវតា និងមនុស្សទាំងឡាយទៅកាន់សម្នាក់របស់ព្រះតថាគត ធ្វើការបូជាដោយគ្រឿងក្រអូប និងផ្កាឈើជាដើម គិតថា លោកជាព្រះសាវកដែលចាក់ធ្លុះនូវធម៌មុន ហើយចូលទៅបូជាព្រះថេរៈតាមលំដាប់ ពិតណាស់ ធម្មតា បុគ្គលដែលមកកាន់សម្នាក់របស់ព្រះមាន-

ព្រះភាគ តែងត្រូវការធម្មកថា ឬបដិសណ្ឋារៈមានសភាពយ៉ាងនោះ ។ ក៏ព្រះថេរៈជាអ្នកចូលក្នុងវិហារ ដោយហេតុនោះ ធម៌នោះរបស់លោកទើបប្រាកដដូចជាយឺតយូរ ។ ព្រោះលោកជាអ្នកចូលក្នុងវិហារ ដូចពោលមកនេះ លោកទើបទៅនៅក្នុងទីនោះ ។

ម្យ៉ាងទៀត ក្នុងកាលមុន ក្នុងវេលាភិក្ខាចារ ព្រះសាវកទាំងពួងរមែងមិនទៅតាមលំដាប់វស្សា ។ ក៏ក្នុងវេលាសម្តែងធម៌ កាលព្រះសាស្តាប្រថាប់គង់លើពុទ្ធាសនៈដែលគេក្រាលទុកត្រង់កណ្តាល ព្រះធម្មសេនាបតីគង់ខាងខាងស្តាំ ព្រះមោគ្គល្លានគង់ខាងឆ្វេង ។ ចំណែកខាងក្រោយនៃព្រះសាវកទាំង ២ នោះ គេក្រាលអាសនៈទុកសម្រាប់ព្រះអញ្ញាកោណ្ឌញ្ញៈ ។ ពួកភិក្ខុដ៏សេសគង់ចោមរោមលោក ។ ព្រះអគ្គសាវកទាំង ២ មានសេចក្តីគោរពក្នុងព្រះថេរៈព្រោះលោកសម្រេចធម៌មុន និងជាព្រះថេរៈចាស់ ។ ភិក្ខុទាំងឡាយសម្គាល់ព្រះថេរៈដូចមហាព្រហ្ម ដូចគំនរភ្លើង និងដូចអាសិរពិស គង់អាសនៈក្នុងទីជិតក៏ខ្លាចក្រែងចិត្ត ។ ព្រះថេរៈគិតថា ក៏ភិក្ខុទាំងនេះបំពេញបារមីអស់មួយអសង្ខេយ្យមួយសែនកប្ប ដើម្បីត្រូវការអាសនៈជិត ឥឡូវនេះគង់ក្នុងអាសនៈជិតកោតក្រែងខ្លាចចំពោះយើង យើងនឹងឲ្យភិក្ខុទាំងនោះនៅដោយសុខសប្បាយ ។

ព្រះថេរៈចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបំណងនឹងទៅនៅក្នុងជនបទ ។ ព្រះសាស្តា ទ្រង់អនុញ្ញាតិហើយ ។

ព្រះថេរៈរក្សាទុកដាក់សេនាសនៈ កាន់បាត្រចីវរ ទៅកាន់មាត់ស្រះមន្ទាគិនីបោក្ខរណីជាទីនៅរបស់ដំរីត្រកូលឆទ្ទន្តៈ ។ ក្នុងកាលមុន ហ្វូងដំរីដ៏ប្រសើរប្រមាណ ៨.០០០ ធ្លាប់ប្រណិបត្តិព្រះបច្ចេកពុទ្ធទាំងឡាយ កាលបានឃើញព្រះថេរៈហើយ គិតថា បុញ្ញខេត្តរបស់ពួកយើងមកដល់ហើយ ទើបយកក្រចកកៀរទីចង្រ្កម យកស្មៅចេញ នាំមែកឈើចេញ ចាត់ចែងទីនៅប្រគេនព្រះថេរៈធ្វើវត្តទាំងអស់ ប្រជុំប្រឹក្សាដាក់វេនគ្នាទុកថា ក៏បើយើងនឹងលះបង់ព្រះថេរៈបុគ្គលដទៃនឹងធ្វើកិច្ចដែលគួរធ្វើដល់ព្រះថេរៈសោត ព្រះថេរៈទាំងដែលមានបាត្រទទេ នឹងទៅកាន់ស្រុករបស់ញាតិ ដោយវារៈណាៗ យើងក៏នឹងប្រណិបត្តិដោយវារៈនោះៗ តែកាលវេនរបស់ដំរីមួយមកដល់ សូម្បីពួកក្រៅពីនោះក៏មិនគួរលះបង់ឡើយ ។

ដំរីដែលដល់វេន តាំងទឹកខ្ពុរមាត់ និងឈើស្ទន់ ធ្វើវត្តចំពោះព្រះថេរៈពីព្រឹកព្រលឹម ។

ក៏ស្រះបោក្ខរណី ឈ្មោះមន្ទាគិនីនេះ មានទទឹង ៥០ យោជន៍ ។ ស្រះ

នោះមិនមានសារាយ ឬចកក្នុងទីប្រមាណ ២៥ យោជន៍ ។ ទឹកនោះឯង រមែងថ្លាដូចពណ៌កែវផលឹក ។ តអំពីនោះ មានព្រៃបទុមស លាតសន្ធឹងទៅកន្លះយោជន៍ ក្នុងទឹកជម្រៅមួយជំហរ តាំងនៅហោមព័ទ្ធស្រះ ៥០ យោជន៍ ។ បន្ទាប់អំពីនោះ លំដាប់ដំបូង មានព្រៃបទុមក្រហមទំហំធំ បន្ទាប់អំពីនោះ ព្រៃកុមុទក្រហម បន្ទាប់ពីនោះ ព្រៃកុមុទស បន្ទាប់ពីនោះ ព្រៃឧប្បលខៀវ បន្ទាប់ពីនោះ ព្រៃឧប្បលក្រហម បន្ទាប់អំពីនោះព្រៃស្រូវសាលីក្រហមមានក្លិនក្រអូប បន្ទាប់អំពីនោះ ផ្លែកើតពីដើមឈើ វល្លិ៍មានរសឆ្ងាញ់ មានផ្លែល្ពៅទុំ ឃ្លោក និងល្ពៅខ្ទិជាដើម បន្ទាប់អំពីនោះ ព្រៃអំពៅលាតសន្ធឹងទៅកន្លះយោជន៍ បណ្តាអំពៅទាំងនោះ អំពៅតែមួយដើមៗ ប៉ុនដើមស្លា បន្ទាប់អំពីនោះ ព្រៃចេក ផ្លែចេកនោះ បុគ្គលបរិភោគតែ ២ ផ្លែ រមែងលំបាក ។ បន្ទាប់អំពីនោះ ព្រៃខ្នុរ មានផ្លែប៉ុនថាស បន្ទាប់អំពីនោះ ព្រៃស្វាយ ព្រៃព្រីង ព្រៃខ្វិត ។ ដោយសង្ខេប ក្នុងស្រះនោះ ដែលឈ្មោះថា ផ្លែឈើដែលបរិភោគបាន មិនគប្បីពោលថា មិនមាន ។ ក្នុងវេលាផ្កាឈើរីក ខ្យល់បក់កៀរលំអងកេសរទៅទុកលើស្លឹកឈូក ។ ក្នុងស្លឹកឈូកនោះ តំណក់ទឹកធ្លាក់ជាតំណក់ៗក៏ឆ្អិនដោយកំដៅព្រះអាទិត្យ រមែងដូចជាស្ករម្នាស់ ។ នេះឈ្មោះថា **បោក្ខរមធុ**

ទឹកផ្អែមលើស្លឹកឈូក ។ ដំរីទាំងឡាយនាំ បោក្ខរមធុនោះ មកថ្វាយព្រះ-ថេរៈ ។ ក្រអៅឈូកសទំហំប៉ុនចុងនង្គ័ល សូម្បីក្រអៅឈូកនោះ ដំរីទាំងឡាយក៏នាំមកថ្វាយ ។ មើមឈូកមានទំហំប៉ុនស្គរធំ និងប៉ុនស្លឹកឈូក ។ មើមឈូកនោះតែមួយមើម មានទឹកដោះប្រមាណមួយឆ្នាំង មើមឈូកនោះ ដំរីទាំងឡាយក៏នាំមកថ្វាយ ដំរីទាំងឡាយផ្សំគ្រាប់ឈូកនឹងដុំស្ករថ្វាយ ។ យកអំពៅដាក់លើផ្ទាំងថ្ម ហើយប្រើជើងជាន់ ទឹកផ្អែមក៏ហូរចេញពេញក្នុងថ្មុក និងរណ្តៅនិងធ្និនដោយកម្តៅព្រះអាទិត្យ ក្លាយជាដុំទឹកដោះប្រៀបបីដូចដុំថ្ម ដុំទឹកដោះនោះ ដំរីទាំងឡាយក៏នាំមកថ្វាយ ។ ក្នុងខ្នុរ ចេក ស្វាយទុំជាដើម មិនចាំបាច់ពោលដល់ ។

ទេវបុត្រឈ្មោះ នាគទត្តៈ នៅក្នុងភ្នំកៃលាស ។ ព្រះថេរៈទៅកាន់ទ្វារវិមានរបស់ទេវបុត្រនោះ មួងម្កាល ទេវបុត្រនោះ យកបាយបាយាសមិនមានទឹក ដែលផ្សំដោយទឹកដោះថ្លាថ្មី និងលំអិតផង់ដែលមានរសផ្អែម ដាក់លើស្លឹកឈូក ដាក់ពេញបាត្រថ្វាយ ។ បានឮថា កាលព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ ទេវបុត្តនោះ បានថ្វាយស្លាកទឹកដោះព្រមទាំងទឹកដោះថ្លាក្រអូប រហូតដល់អស់ ២ ម៉ឺនឆ្នាំ ។ ដោយហេតុនោះ ភោជន ទើបកើតឡើងដល់លោក

ដោយអាការយ៉ាងនេះ ។ ព្រះថេរៈនៅយ៉ាងនេះអស់ ១២ ឆ្នាំ ពិចារណាមើលអាយុសង្ខាររបស់ខ្លួនដឹងថា អស់ហើយ គិតថា យើងនឹងបរិនិព្វានទីណា ហើយក៏ហោះទៅកាន់សម្នាក់ព្រះមានព្រះភាគ ដោយគិតថា ដំរីទាំងឡាយទំនុកបម្រុងយើងអស់ ១២ ឆ្នាំ ធ្វើកិច្ចដែលធ្វើបានលំបាក យើងនឹងសូមអនុញ្ញាតព្រះសាស្តាបរិនិព្វានក្នុងទីជិតៗ ដំរីទាំងនោះឯង ។ ព្រោះហេតុនោះ លោកទើបពោលថា **សុចិរស្សំ យេន កតវា តេនុបសង្កមិ** ដូច្នេះ ។

បទថា **នាមញ្ច** សេចក្តីថា ព្រះថេរៈប្រកាសឈ្មោះព្រោះហេតុអ្វី ។ ព្រោះបុគ្គលពួកខ្លះចាំព្រះថេរៈបាន ពួកខ្លះចាំមិនបាន ។ បណ្តាអ្នកទាំងនោះព្រះថេរៈគិតថា បុគ្គលពួកណាមិនស្គាល់យើង នឹងគិតប្រទូស្តថា ភិក្ខុចាស់អង្គនេះ មានសីសៈស ខ្នងកោង មានធ្មេញជំនីរគីមរគាមរូបនេះ ធ្វើបដិសណ្ឋារៈនឹងព្រះសាស្តា បុគ្គលទាំងនោះនឹងពេញក្នុងអបាយ តែបុគ្គលពួកណាស្គាល់យើង នឹងជ្រះថ្លាថា ជាមហាសាវកប្រាកដក្នុងម៉ឺនចក្រវាឡ ដូចព្រះសាស្តា បុគ្គលទាំងនោះនឹងចូលដល់សួគ៌ ដូច្នេះ កាលនឹងបិទផ្លូវអបាយ បើកផ្លូវសួគ៌សម្រាប់សត្វទាំងនោះ ទើបប្រកាសឈ្មោះ ។

**[២៣២]** បទថា **ពុទ្ធានុពុទ្ធោ** សេចក្តីថា ព្រះពុទ្ធត្រាស់ដឹងសច្ចៈ ៤

មុន ព្រះថេរៈត្រាស់ដឹងតាមក្រោយ ព្រោះដូច្នោះ លោកទើបហៅថា **ពុទ្ធានុពុទ្ធ** អ្នកត្រាស់ដឹងតាមព្រះពុទ្ធអង្គ ។ បទថា **តិព្វនិក្កមោ** បានដល់ មានសេចក្ដីព្យាយាមមាំ ។ បទថា **វិវេកានំ** បានដល់ វិវេក ៣ ។ ដោយបទថា **តេវិជ្ជោ ចេតោបរិយាយកោវិទោ** នេះ លោកពោលដល់អភិញ្ញា ៤ ក្នុងបណ្ដាអភិញ្ញា ៦ ។ អភិញ្ញា ២ ទៀតក្រៅពីនេះ សូម្បីមិនបានពោលដល់ ក៏ពិត តែព្រះថេរៈក៏បានអភិញ្ញា ៦ នោះឯង ។ បរិស័ទបានប្រជុំគ្នាក្នុងវេលាចប់គាថានេះ ។ ព្រះថេរៈដឹងថា បរិស័ទប្រជុំគ្នា ទើបធ្វើបដិសណ្ឋារៈនឹងព្រះសាស្ដាសូមអនុញ្ញាតកាលបរិនិព្វានថា បពិត្រព្រះអង្គដ៏ចម្រើន អាយុសង្ខាររបស់ខ្ញុំព្រះអង្គអស់ហើយ ខ្ញុំព្រះអង្គនឹងបរិនិព្វាន ។ ព្រះមានព្រះភាគត្រាស់សួរថា កោណ្ឌញ្ញៈអ្នកនឹងបរិនិព្វានទីណា ។ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដំរីទាំងឡាយដែលជាឧបដ្ឋាករបស់ខ្ញុំព្រះអង្គ បានធ្វើកិច្ចដែលធ្វើបានលំបាក ខ្ញុំព្រះអង្គនឹងបរិនិព្វានក្នុងទីជិតៗ ដំរីទាំងនោះ ។ ព្រះសាស្ដាទ្រង់អនុញ្ញាត ។

ព្រះថេរៈធ្វើប្រទក្សិណព្រះទសពលហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការឃើញគ្រានោះ ជាការឃើញគ្រាដំបូងរបស់ខ្ញុំព្រះអង្គ គ្រានេះជាការឃើញគ្រាចុងក្រោយបង្អស់ ដូច្នេះ កាលមហាជនទួញយំហើយ ព្រះ

ថេរៈថ្វាយបង្គំព្រះសាស្តាហើយចេញមកឈរត្រង់ខ្លោងទ្វារ ប្រៀនប្រដៅមហាជនថា លោកទាំងឡាយកុំសោកសៅឡើយ កុំទួញយំឡើយ ជាព្រះពុទ្ធក៏ដោយ ជាពុទ្ធសាវកក៏ដោយ សង្ខារដែលកើតឡើងហើយ ឈ្មោះថា មិនបែកធ្លាយ រមែងមិនមាន ដូច្នេះ កាលមហាជនកំពុងឃើញនុ៎ះឯង ក៏ហោះឡើងទៅកាន់អាកាស ចុះត្រង់មាត់ស្រះមន្ទាគិនី ស្រង់ទឹកក្នុងស្រះបោក្ខរណី ស្លៀកស្បង់ ដណ្តប់ចីវរហើយ រក្សាទុកដាក់សេនាសនៈ ចូលផលសមាបត្តិ កន្លង ៣ យាម បរិនិព្វានវេលាភ្លឺស្រាងៗ ។ ដើមឈើគ្រប់ដើមក្នុងហិមវន្តប្រទេស បានបង្អោនចេញផ្លែផ្កាបូជាព្រមគ្នានឹងវេលាព្រះថេរៈបរិនិព្វាន ។ ដំរីដែលដល់វេន មិនដឹងថា ព្រះថេរៈបរិនិព្វាន ចាត់ចែងទឹកខ្ពុរមាត់ និងឈើជម្រះធ្មេញ ធ្វើវត្តបដិបត្តិពីព្រឹកព្រលឹម នាំរបស់គួរទំពារ និងផ្លែឈើមកឈរត្រង់ចុងទីចង្រ្កម ។ ដំរីនោះមិនឃើញព្រះថេរៈចេញមក ដរាបព្រះអាទិត្យរះ ឡើងគិតថា នេះយ៉ាងណាហ្ន៎ កាលមុន លោកម្ចាស់ ចង្រ្កម លុបលាងមុខពីព្រឹកព្រលឹម ថ្ងៃនេះមិនទាន់ចេញពីបណ្ណសាលា ទើបអង្រួនទ្វារកុដិ មើលឃើញព្រះថេរៈកំពុងអង្គុយ ទើបយកក្ទុកស្ទាបអង្អែលស្វែងរកខ្យល់អស្សាសបស្សាសៈ ដឹងថា ខ្យល់អស្សាសបស្សាសៈដាច់ ក៏បានដឹងថា ព្រះថេរៈបរិនិព្វានហើយ ទើបស៊ក

ប្រមោយចូលក្នុងមាត់ បញ្ចេញសំឡេងស្រែកយ៉ាងខ្លាំង ទូទៅក្នុងហិមវន្តប្រទេស បានមានសំឡេងបន្លឺដូចគ្នាតែមួយ ។ ដំរី ៨.០០០ ប្រជុំគ្នា លើកព្រះថេរៈឡើងដេកលើខ្នងរបស់មេហ្វូង កាន់មែកឈើដែលមានផ្ការីកស្គុះស្គាយ ហែហមទៅទូទាំងហិមវន្ត ហើយមកកាន់ទីរបស់ខ្លួនដូចដើម ។

សក្កទេវរាជប្រឹក្សាជាមួយព្រះវិស្សុកម្មទេវបុត្រថា នែ៎បា បងប្រុសរបស់ពួកយើងបរិនិព្វានហើយ យើងនឹងធ្វើសក្ការៈ លោកចូរនិម្មិតផ្ទះកំពូលកំពស់ប្រមាណ ៩ យោជន៍ ដែលសម្រេចដោយរតនៈគ្រប់យ៉ាង ។ ព្រះវិស្សុកម្ម-ទេវបុត្រធ្វើតាមទេវបញ្ជាហើយ តម្កល់ព្រះថេរៈក្នុងផ្ទះកំពូលនោះ ទើបបានប្រគល់ឲ្យដល់ដំរីទាំងឡាយ ។ ដំរីទាំងនោះ លើកផ្ទះកំពូលប្រទក្សិណភ្នំហេមពន្ត ប្រមាណ ៣,០០០ យោជន៍ ជាច្រើនជុំ ។ ពួកអាកាសទេវតាទទួលអំពីប្រមោយរបស់ដំរីទាំងនោះ ហើយលេងសាធុកីឡាសម្តែងគារវៈ ។ តអំពីនោះ វស្សវលាហកទេវតា សីតវលាហកទេវតា វាតវលាហកទេវតា ទេវតាជាន់ចាតុម្មហារាជ ទេវតាជាន់តាវត្តិង្ស រួមសេចក្តីថា ផ្ទះកំពូលបានទៅដរាបដល់ព្រហ្មលោកដោយឧបាយនេះ ដោយប្រការដូច្នេះ ។ ពួកព្រហ្មបានឲ្យផ្ទះកំពូលដល់ពួកទេវតា ពួកទេវតាបានឲ្យផ្ទះកំពូលដល់ដំរីទាំងឡាយ

ដូចដើមដោយលំដាប់ ដោយប្រការដូច្នេះឯង ។ ទេវតាមួយអង្គ បាននាំកំណាត់ចន្ទប្រមាណ ៤ អង្គុលីមក ។ មានជើងថ្ករកំពស់ប្រមាណ ៩ យោជន៍ ។ ពួកទេវតាលើកផ្ទះកំពូលឡើងកាន់ជើងថ្ករ ។ ភិក្ខុប្រមាណ ៥០០ រូប ហោះមកស្វាធ្យាយរហូតអស់មួយយប់ ។ ព្រះអនុរុទ្ធត្ថេរសម្ដែងធម៌ ។ ទេវតាជាច្រើនបានត្រាស់ដឹងធម៌ ។ ថ្ងៃស្អែកវេលាអរុណរះនោះឯង ទេវតាទាំងឡាយពន្លត់ជើងថ្ករហើយ យកព្រះធាតុមានពណ៌ដូចផ្កាម្លិះរួត ដាក់ក្នុងសំពត់តម្រងទឹក នាំមកដាក់ក្នុងព្រះហស្តរបស់ព្រះសាស្តា ក្នុងកាលព្រះអង្គស្ដេចចេញដល់ខ្លោងទ្វារវត្តវេឡុវ័ន ។ ព្រះសាស្តាទ្រង់ទទួលសំពត់តម្រងទឹកបញ្ចុះព្រះធាតុហើយ ទ្រង់លាព្រះហស្តទៅត្រង់ផែនដី ។ ព្រះចេតិយមានរស្មីដូចពន្លប្រាក់ជ្រែកផែនដីធំចេញមក ។ ព្រះសាស្តា ទ្រង់បញ្ចុះព្រះធាតុក្នុងព្រះចេតិយដោយព្រះហស្តរបស់ព្រះអង្គ ។ បានឮថា ព្រះចេតិយនោះ ក៏តាំងនៅដរាបដល់សព្វថ្ងៃនេះឯង ។

ចប់អដ្ឋកថា កោណ្ឌញ្ញសូត្រទី៩

# អ ដ្ឋ ក ថា

## មោគ្គល្លានសូត្រទី ១០

ក្នុងមោគ្គល្លានសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៣៣] បទថា *សមន្នេសតិ* បានដល់ ស្វែងរក គឺ ពិចារណា ។

[២៣៤] បទថា *នគស្ស* បានដល់ ភ្នំ ។ បទថា *មុនឹ* បានដល់ ព្រះពុទ្ធមុនី ។ បទថា *ទុក្ខស្ស បារគុំ* បានដល់ អ្នកដល់នូវត្រើយនៃទុក្ខ ។ បទថា *សមន្នេសំ* បានដល់ ពិចារណាហើយ ។ បទថា *ឯវំ សព្វង្គសម្បន្នំ* បានដល់ បរិបូរណ៍ដោយគុណទាំងពួង ដោយអាការយ៉ាងនេះ ។ បទថា *អនេកាការសម្បន្នំ* បានដល់ ប្រកបដោយគុណសន្ធឹកសន្ធាប់ ។

ចប់អដ្ឋកថា មោគ្គល្លានសូត្រទី ១០

# អ ដ្ឋ ក ថា

## គគ្គរាសូត្រទី ១១

ក្នុងគគ្គរាសូត្រទី ១១ មានវិនិច្ឆ័យដូចតទៅនេះ ៖

**[២៣៦]** *បទថា* **តុយ្ហស្សុទំ** *កាត់បទជា* **តេ អស្សុទំ** *។ ពាក្យថា* **អស្សុទំ** *ត្រឹមតែនិបាត ។*

**[២៣៧]** *បទថា* **វណ្ណេន** *បានដល់ ពណ៌នៃសរីរៈ ។ បទថា* **យសេន** *បានដល់ ដោយបរិវារ ។ បទថា* **វិតមោនុទោ** **ភាណុមា** *បានដល់ ដូចព្រះ-អាទិត្យប្រាសចាកមន្ទិល ។*

ចប់អដ្ឋកថា គគ្គរាសូត្រទី ១១

# អ ដ្ឋ ក ថា

## វង្គីសសូត្រទី ១២

ក្នុងវង្គីសសូត្រទី ១២ មានវិនិច្ឆ័យតទៅនេះ ៖

**[២៣៩]** បទថា *អាយស្មា* គឺ ជាពាក្យគួរស្រឡាញ់ ។ បទថា *វង្គីសោ* ជាឈ្មោះរបស់ព្រះថេរៈនោះ ។ បានឮថា ក្នុងសម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរ** ក្នុងកាលមុន ព្រះថេរៈនោះ ឃើញព្រះសាវកអ្នកសម្បូរណ៍ដោយបដិភាណ ទើបឲ្យទាន ធ្វើសេចក្តីប្រាថ្នា បំពេញបារមីមួយសែនកប្ប ក្នុងកាលនៃព្រះ-មានព្រះភាគរបស់យើងទាំងឡាយ គេកើតក្នុងគភ៌របស់បរិព្វាជិកាម្នាក់ ដែលលោមព័ទ្ធមែកព្រីងទុក ព្រោះប្រាថ្នានឹងប្រកួតវាទៈទូទាំងជម្ពូទ្វីប ហើយបានប្រកួតវាទៈនឹងបរិព្វាជកម្នាក់ ព្រោះឈ្នះខ្លះ ចាញ់ខ្លះ ទើបនៅរួមជាមួយបរិ-ព្វាជកនោះ វង្គីសកុមារចម្រើនវ័យហើយ រៀនវាទៈ ១.០០០ គឺ ចំណែកមាតា ៥០០ ចំណែកបិតា ៥០០ ចារិកទៅ គេចេះវិជ្ជាម្យ៉ាង នៅពេលដែលវាយមន្ត ហើយយកម្រាមដៃគោះក្បាលខ្មោច ក៏ដឹងថា អ្នកនេះកើតក្នុងទីឯណោះ ។ គេត្រាច់ទៅក្នុងស្រុក និងនិគមជាដើម ដោយលំដាប់ ដល់ក្រុងសាវត្ថីព្រមទាំង

មាណព ៥០០ នាក់ អង្គុយត្រង់សាលាជិតទ្វារព្រះនគរ ។

ក្នុងគ្រានោះ ពេលមុនអាហារ អ្នកព្រះនគរនាំគ្នាឲ្យទាន ពេលក្រោយអាហារស្លៀកដណ្តប់រៀបរយហើយ ក៏កាន់គ្រឿងក្រអូប និងផ្កាឈើជាដើមទៅកាន់វិហារដើម្បីស្តាប់ធម៌ ។ មាណពឃើញហើយ សួរថា ពួកលោកទៅណា ។ ពួកគេឆ្លើយថា ពួកយើងទៅស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះទសពល ។ សូម្បីគេព្រមទាំងបរិវារ ក៏ទៅជាមួយនឹងអ្នកនគរទាំងនោះ ធ្វើបដិសណ្ឋារៈហើយ បានឈរក្នុងទីដ៏សមគួរមួយ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ចំពោះគេថា វង្គីសៈ បានឮថា អ្នកចេះសិល្បៈល្អឬ ។ គេក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គចេះច្រើន តើព្រះអង្គត្រាស់សំដៅយកសិល្បៈប្រភេទណា ។ ព្រះសាស្តាត្រាស់ថា សិល្បៈដែលជាប់ទាក់ទងនឹងសាកសព ។ សូមនិមន្តចុះព្រះគោតម ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់សម្តែងសីសៈរបស់សត្វអ្នកកើតក្នុងនរក ដោយអានុភាពរបស់ព្រះអង្គដល់គេ ហើយត្រាស់សួរថា វង្គីសៈ អ្នកនេះកើតក្នុងទីណា ។ គេរាយមន្តហើយ យកម្រាមដៃគោះមើល ទូលថា កើតក្នុងនរក ។ ព្រះសាស្តា ត្រាស់ថា ប្រពៃណាស់ វង្គីសៈ អ្នកឆ្លើយត្រូវហើយ ។ ព្រះអង្គទ្រង់សម្តែងសីសៈរបស់សត្វដែលកើតក្នុងទេវ-

លោក សូម្បីសីសៈនោះគេ ក៏ព្យាករណ៍បានយ៉ាងនោះដូចគ្នា ។ លំដាប់នោះ ព្រះសាស្តា ទើបទ្រង់សម្តែងសីសៈរបស់ព្រះខីណាស្រពដល់គេ ។ គេរាយមន្ត ហើយរាយមន្តទៀត យកម្រាមដៃគោះ ក៏មិនដឹងទីកើត ។

លំដាប់នោះ ព្រះមានព្រះភាគទើបត្រាស់ដល់គេថា លំបាកឬទេ វង្គីសៈ ។ គេទូលថា លំបាក ព្រះគោតម ។ ព្រះមានព្រះភាគត្រាស់ថា អ្នកចូរពិចារណា រឿយៗ ចុះ ។ គេសូម្បីធ្វើយ៉ាងនោះ ក៏មិនឃើញ ទើបទូលថា បពិត្រព្រះ-គោតម ព្រះអង្គដឹងឬ ។ ព្រះមានព្រះភាគត្រាស់ថា ដឹងវង្គីសៈ បុគ្គលនោះ ឈ្មោះថា ទៅល្អហើយ ព្រោះមិនមានទីអាស្រ័យ តថាគតដឹងគតិរបស់គេ ។ ទូលសួរថា បពិត្រព្រះគោតម ព្រះអង្គដឹងបានដោយមន្តឬ ។ ត្រូវហើយវង្គីសៈ តថាគតដឹងបានដោយមន្តម្យ៉ាង ។ ទូលថា បពិត្រព្រះគោតម សូមព្រះអង្គ មេត្តាជូនមន្តនឹងខ្ញុំព្រះអង្គចុះ ។ ត្រាស់ថា វង្គីសៈ មន្តរបស់តថាគតមិនយក ថ្លៃឈ្នួលទេ ។ គេក្រាបទូលថា បពិត្រព្រះគោតម សូមព្រះអង្គមេត្តាប្រទាន ចុះ ។ ព្រះអង្គត្រាស់ថា តថាគតមិនអាចឲ្យមន្តដល់អ្នកដែលមិនបានបួស ក្នុងសម្នាក់របស់តថាគតទេ ។ វង្គីសៈហៅពួកកូនសិស្សមកប្រាប់ថា ម្នាលបា ទាំងឡាយ ព្រះសមណគោតមចេះសិល្បៈច្រើនណាស់ យើងនឹងបួសក្នុងសម្នាក់

របស់ព្រះសមណគោតមនេះ ដើម្បីរៀនសិល្បៈ តអំពីនោះ នឹងមិនមានអ្នកដែលចេះសិល្បៈច្រើនជាងយើងទូទាំងជម្ពូទ្វីប ពួកអ្នកចូរកុំកន្ទល់ឡើយ ចូរនៅរួមគ្នាជរាបដល់យើងត្រឡប់មក ដូច្នេះ ហើយបញ្ជូនកូនសិស្សទាំងនោះទៅ ហើយក្រាបទូលថា សូមព្រះអង្គមេត្តាឲ្យខ្ញុំព្រះអង្គបព្វជ្ជាចុះ ។ ព្រះសាស្តាទ្រង់ប្រគល់សំដៅឲ្យព្រះថេរៈឈ្មោះនិគ្រោធកប្បៈ ។ ព្រះថេរៈនាំវង្គីសៈទៅកាន់ទីនៅរបស់ខ្លួន ហើយឲ្យបព្វជ្ជា ។ លោកបព្វជ្ជាហើយ មកគាល់ព្រះ-សាស្តា ថ្វាយបង្គំហើយ ទូលអារាធនាថា សូមព្រះអង្គមេត្តាប្រទានសិល្បៈដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តាត្រាស់ថា ម្នាលវង្គីសៈ កាលពួកអ្នកនឹងរៀនសិល្បៈ (ជាដំបូង) ត្រូវធ្វើបរិកម្មដោយមិនបរិភោគរបស់ប្រៃ និងដេកលើផែនដីជាដើម ហើយរៀនសិល្បៈនោះ សូម្បីសិល្បៈនេះក៏មានបរិកម្ម អ្នកចូរធ្វើបរិកម្មនោះជាមុន ។ ព្រះវង្គីសៈក្រាបទូលថា ព្រះករុណា ព្រះអង្គ ។ លំដាប់នោះ ព្រះសាស្តាត្រាស់ប្រាប់ព្រះកម្មដ្ឋាន គឺ អាការ ៣២ ដល់គេ ។ លោកមនសិការព្រះកម្មដ្ឋាននោះ ទាំងអនុលោមបដិលោម ចម្រើនវិបស្សនាសម្រេចព្រះអរហត្តដោយលំដាប់ ។

បទថា **វិមុត្តិសុខំ បដិសំវេទី** សេចក្តីថា កាលសម្រេចព្រះអរហត្ត

ដូច្នេះហើយក៏សោយវិមុត្តិសុខ ។ បទថា **ការវេយ្យមត្តា** បានដល់ ស្រវឹងដោយកាពជាកវី គឺ អ្នកតែងកំណាព្យ ។ បទថា **ខន្ធេ អាយតនានិ ធាតុយោ** សេចក្តីថា កាលទ្រង់សម្តែងធម៌ ប្រកាសខន្ធជាដើមទាំងនេះ ។ បទថា **យេ និយាមគតទ្ទសា** បានដល់ អ្នកដល់និយាមធម៌ និងអ្នកឃើញនិយាមធម៌ ។ បទថា **ស្វាគតំ** បានដល់ ការមកដោយល្អ ។ ដោយពាក្យថា **ឥទ្ធិប្បត្តោម្ហិ** នេះ សំដៅយកឥទ្ធិវិធិញ្ញាណ ។ ដោយពាក្យថា **ចេតោបរិយាយកោវិទោ** នេះ សំដៅយកចេតោបរិយញ្ញាណ ។ ចំណែកទិព្វសោត សូម្បីលោកមិនបានពោលទុក ក៏សង្គ្រោះចូលដូចគ្នា ។ ព្រះវង្គីសៈនេះ សម្រេចអភិញ្ញា ៦ គប្បីជ្រាបថាជាមហាសាវក ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា វង្គីសសូត្រទី ១២

## ចប់វង្គីសសំយុត្តត្រឹមតែប៉ុណ្ណោះ

### រួមក្នុងវគ្គនេះមាន ១២ អដ្ឋកថា


១-អដ្ឋកថានិក្ខន្តសូត្រ ២-អដ្ឋកថាអរតិសូត្រ
៣-អដ្ឋកថាបេសលាតិមញ្ញនាសូត្រ ៤-អដ្ឋកថាអានន្ទសូត្រ
៥-អដ្ឋកថាសុភាសិតសូត្រ ៦-អដ្ឋកថាសារីបុត្តសូត្រ
៧-អដ្ឋកថាបវារណាសូត្រ ៨-អដ្ឋកថាបរោសហស្សសូត្រ
៩-អដ្ឋកថាកោណ្ឌញ្ញសូត្រ ១០-អដ្ឋកថាមោគ្គល្លានសូត្រ
១១-អដ្ឋកថាគគ្គរាសូត្រ ១២-អដ្ឋកថាវង្គីសសូត្រ

# វនសំយុត្ត

## អ ដ្ឋ ក ថា

### វិវេកសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យ* **ក្នុងវិវេកសូត្រទី ១** *នៃវនសំយុត្តដូចតទៅនេះ ៖*

**[២៤០]** *បទថា* **កោសលេសុ វិហរតិ** *សេចក្តីថា ភិក្ខុរូបណាមួយរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាហើយទៅនៅក្នុងដែនកោសល នោះព្រោះជនបទនោះ រកភិក្ខាបានងាយ ។*

**[២៤១]** *បទថា* **សំវេជេតុកាមា** *បានដល់ ប្រាថ្នាដើម្បីនឹងឲ្យភិក្ខុនោះដល់វិវេក ។ បទថា* **វិវេកកាមោ** *គឺ បំណងវិវេក ៣ ។ បទថា* **និច្ឆរតិពហិទ្ធា** *គឺ ត្រាច់ទៅក្នុងអារម្មណ៍ដ៏ច្រើនដែលជាខាងក្រៅ ។ បទថា* **ជនោជនស្មិំ** *សេចក្តីថា លោកចូរលះបង់ឆន្ទរាគៈក្នុងអ្នកដទៃ ។ បទថា* **បជហាសិ** *ប្រែថា ចូរលះ ។ បទថា* **ភវាសិ** *ប្រែថា ចូរជា ។ បទថា* **សតំ តំ សារយាមសេ** *សេចក្តីថា សូម្បីយើងរមែងញុំាងបណ្ឌិតអ្នកមានសតិឲ្យរលឹកដល់ធម៌នោះ ឬថា យើងរមែងញុំាងអ្នកនោះឲ្យរលឹកដល់ធម៌របស់សប្បុរស ។*

បទថា **បាតាល រជោ** សេចក្តីថា ធូលី គឺ កិលេស ដែលហៅថា បាតាល ព្រោះអត្ថថា មិនមានទីតាំង ។ បទថា **មា តំ កាមរជោ** សេចក្តីថា ធូលី គឺ កាមរាគៈនេះ កុំគ្របសង្កត់លោក អធិប្បាយថា កុំនាំទៅកាន់អបាយឡើយ ។ បទថា **បំសុកុណ្ឋិតោ** ប្រែថា ប្រឡាក់ធូលី ។ បទថា **វិធុនំ** ប្រែថា កម្ចាត់ ។ បទថា **សិតំ រជំ** បានដល់ ធូលីដែលជាប់នឹងខ្លួន ។ បទថា **សំវេគមាបាទិ** សេចក្តីថា ឈ្មោះថា សូម្បីទេវតារមែងញាំងយើងប៉ុណ្ណោះ ឲ្យរលឹកដល់ ដូច្នោះ ទើបឈ្មោះថា ដល់វិវេក ឬថា ផ្គងសេចក្តីព្យាយាមដែលខ្ពស់បំផុត ហើយបដិបត្តិដើម្បីឲ្យដល់វិវេកដ៏ប្រសើរ ។

ចប់អដ្ឋកថា វិវេកសូត្រទី ១

# អ ដ្ឋ ក ថា

## ឧបដ្ឋានសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យ ក្នុងឧបដ្ឋានសូត្រទី ២ តទៅនេះ ៖

**[២៨២]** បទថា *សុបសិ* សេចក្តីថា បានឮថា ភិក្ខុនេះជាព្រះខីណាស្រព លោកទៅកាន់ស្រុកដែលស្វែងរកភិក្ខាក្នុងទីឆ្ងាយ លុះត្រឡប់មកវិញ រក្សាបាត្រនិងចីវរទុកក្នុងបណ្ណសាលា ចុះក្នុងស្រះដែលកើតឯងក្នុងទីមិនឆ្ងាយ ពេលឲ្យខ្លួនស្ងួតហើយ បោសទីសម្រាកពេលថ្ងៃ រៀបចំគ្រែតូចមួយទុកក្នុងទីនោះ ហើយក៏សឹងលក់ទៅ ។ ពិតណាស់ សូម្បីព្រះខីណាស្រព ក៏មានសេចក្តីខ្វល់ខ្វាយផ្លូវកាយដូចគ្នា ព្រោះដូច្នោះ លោកទើបពោលពាក្យដែលប្រើនៅក្នុងបច្ចុប្បន្ន ដើម្បីបន្ទោបង់សេចក្តីខ្វល់ខ្វាយផ្លូវកាយនោះថា លក់ ។

**[២៨៣]** បទថា *អជ្ឈភាសិ* សេចក្តីថា ទេវតាយល់ថា ភិក្ខុនេះរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាហើយ សឹងលក់ពេលថ្ងៃ ក៏ឯឈ្មោះថាការដេកលក់ពេលថ្ងៃនោះចម្រើនឡើង សូម្បីនឹងញុំាងប្រយោជន៍ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងដែលប្រព្រឹត្តទៅក្នុងជាតិមុខនោះឲ្យវិនាស គិតថា យើង

នឹងជាស់តឿនលោក ទើបបានពោល ។

បទថា **អាតុរស្ស** សេចក្ដីថា សេចក្ដីក្ដៅក្រហាយមាន ៣ យ៉ាង គឺ ក្ដៅក្រហាយដោយជរា ក្ដៅក្រហាយដោយជម្ងឺ ក្ដៅក្រហាយដោយកិលេស លោកពោលសំដៅដល់សេចក្ដីក្ដៅក្រហាយដោយកិលេស ក្នុងសេចក្ដីក្ដៅ-ក្រហាយ ៣ នោះ ។ បទថា **សល្លវិទ្ធស្ស** សេចក្ដីថា ចាក់ត្រង់បេះដូងដោយកូនសរ គឺ តណ្ហា ដែលត្រូវបោះទៅដោយអវិជ្ជា ដូចត្រូវចាក់ដោយកូនសរ គឺ លំពែងដែលលាបដោយថ្នាំពិស ។ បទថា **រុប្បតោ** បានដល់ ចាក់ដោត ។ ឥឡូវនេះ កាលទេវតានឹងពោលដល់ទោសក្នុងកាមរបស់ភិក្ខុនោះ ទើបពោលពាក្យជាដើមថា មិនទៀង ។

**[២៤៤]** ក្នុងបទទាំងនោះ បទថា **អសិតំ** គឺ មិនអាស្រ័យដោយតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ ។ បទថា **កស្មា បព្វជិតំ តបេ** សេចក្ដីថា លោករមែងពោលថា ការដេកពេលថ្ងៃ រមែងមិនដុតព្រះខីណាស្រពបែបនេះ ក៏ព្រោះហេតុអ្វី ទើបមិនដុតព្រះខីណាស្រព ដូច្នោះ ។ ក៏ព្រោះនេះជាពាក្យរបស់ព្រះថេរៈ ។ នេះជាអត្ថក្នុងសេចក្ដីនេះថា ការដេកលក់ពេលថ្ងៃ ដូចម្ដេចនឹងគប្បីធ្វើបព្វជិតអ្នកមិនមានអាសវៈដូចយើង ជាអ្នករួចផុតហើយចាកចំណង

ជាអ្នកអស់កិលេសដែលធ្វើឲ្យក្តៅ ។ សូម្បីក្នុងគាថាដ៏សេស ក៏មានន័យនេះដូចគ្នា ។ ពិតណាស់ ក្នុងចំណែកពាក្យរបស់ទេវតា មានអត្ថថា ការដេកលក់ពេលថ្ងៃដូចម្តេច ទើបមិនដុតបព្វជិតអ្នកមិនមានអាសវៈ ការដេកលក់ពេលថ្ងៃ ដូចម្តេច ទើបមិនដុតបព្វជិត ដូច្នោះ ។ ក្នុងចំណែកពាក្យរបស់ព្រះថេរៈ មានអត្ថថា ការដេកលក់ពេលថ្ងៃដូចម្តេច នឹងគប្បីដុតបព្វជិតអ្នកមិនមានអាសវៈ ដូចយើងដែលមានសភាពបែបនេះ ក៏ឈ្មោះថា មិនដុត ។ តែនេះជាការពណ៌នាបទដ៏ជ្រាលជ្រៅក្នុងសេចក្តីនេះ ។

បទថា **វិនយា** ប្រែថា ព្រោះកម្ចាត់ ។ បទថា **សមតិក្កមា** ប្រែថា ព្រោះឈានកន្លងអវិជ្ជាដែលជាឫសគល់វដ្តៈ ។ បទថា **តំ ញាណំ** បានដល់ ដឹងសច្ចៈ ៤ នោះ ។ បទថា **បរមោទាតំ** បានដល់ បរិសុទ្ធិយ៉ាងក្រៃលែង ។ បទថា **បព្វជិតំ** គឺ បព្វជិតអ្នកប្រកបដោយសេចក្តីដឹងបែបនេះ ។ បទថា **វិជ្ជាយ** គឺ វិជ្ជាក្នុងមគ្គទី ៤ ។ បទថា **អារទ្ធាវីរិយំ** គឺ ផ្គងសេចក្តីព្យាយាមទុកហើយ មានសេចក្តីព្យាយាមបរិបូណ៌ហើយ ។

ចប់អដ្ឋកថា ឧបដ្ឋានសូត្រទី ២

# អ ដ្ឋ ក ថា

## កស្សបគោត្តសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យ ក្នុងកស្សបគោត្តសូត្រទី ៣ តទៅនេះ ៖

**[២៤៥]** បទថា **ឆេតំ** គឺ ព្រានបាញ់ម្រឹគម្នាក់ ។ បទថា **ឱវទតិ** សេចក្ដីថា បានឮថា ព្រានម្រឹគនោះបរិភោគបាយព្រឹកហើយគិតថា យើងនឹងបាញ់ម្រឹគ ទើបចូលទៅកាន់ព្រៃ ឃើញរមាំងមួយក្បាល គិតថា យើងនឹងប្រហារវាដោយលំពែង ក៏ដាប់តាមទៅ ម្រឹគគេចទៅមិនឆ្ងាយអំពីទីដែលព្រះថេរៈគង់ក្នុងទីសម្រាកពេលថ្ងៃ ដោយន័យដែលពោលហើយក្នុងអសុរតទី ១ ។ លំដាប់នោះ ព្រះថេរៈទើបពោលនឹងគេថា ឧបាសក ដែលឈ្មោះថា បាណាតិបាតនេះ ប្រព្រឹត្តទៅដើម្បីអបាយ ប្រព្រឹត្តទៅជាហេតុឲ្យមានអាយុខ្លី គេអាចនឹងធ្វើការចិញ្ចឹមប្រពន្ធដោយការងារយ៉ាងដទៃ មានកសិកម្ម និងពាណិជ្ជកម្មជាដើមក៏បាន លោកកុំធ្វើកម្មគ្រោតគ្រាតយ៉ាងនេះឡើយ ។ សូម្បីគេក៏គិតថា ព្រះថេរៈជាអ្នកទ្រទ្រង់នូវសំពត់មហាបង្សុកូលនិយាយ ទើបផ្ដើមឈរស្ដាប់ដោយសេចក្ដីគោរព ។ លំដាប់នោះ ព្រះថេរៈនោះគិតថា យើងនឹងញ៉ាំងសេចក្ដី

ប្រាថ្នាក្នុងការស្តាប់ឲ្យកើតដល់គេ ទើបញ៉ាំងមេដៃឲ្យមានពន្លឺភ្លឺរន្ទាលឡើង ។ គេឃើញសូម្បីដោយភ្នែក បានឮសូម្បីដោយត្រចៀក តែចិត្តរបស់គេត្រាច់ទៅតាមស្នាមជើងម្រឹគ យ៉ាងនេះថា ម្រឹគនឹងទៅកាន់ទីឯណោះ ចុះកំពង់ឯណោះ យើងនឹងទៅសម្លាប់វាក្នុងទីនោះ ស៊ីសាច់តាមត្រូវការ ហើយនឹងវែកសាច់ដែលសល់ទៅផ្ញើកូនៗ ។ បទថា **ឱវទតិ** ដូច្នេះ លោកពោលសំដៅដល់ព្រះថេរៈអ្នកសម្តែងធម៌នោះ ដល់ព្រានដែលរវើរវាយយ៉ាងនេះ ។ បទថា **អជ្ឈភាសិ** សេចក្តីថា ព្រះថេរៈនេះ ញ៉ាំងការងាររទាំងរបស់ខ្លួន ទាំងរបស់ព្រាននោះឲ្យវិនាស ដូចអ្នកចាំងឈើដែលមិនមែនជាឧសឲ្យខូច និងដូចអ្នកព្រោះស្រូវក្នុងទីមិនមែនស្រែ ទេវតាគិតថា យើងនឹងដាស់តឿនគេ ទើបពោលថា **អជ្ឈភាសិ** ដូច្នេះ ។ បទថា **អប្បបញ្ញោ** ប្រែថា មិនមានបញ្ញា ។ បទថា **អចេតសំ** បានដល់ ប្រាសចាកការគិតដែលអាចដឹងហេតុការណ៍ ។ បទថា **មន្ទោវ** ប្រែថា ដូចអ្នកល្ងង់ខ្លៅ ។ បទថា **សុណាតិ** បានដល់ ស្តាប់ធម្មកថារបស់លោក ។ បទថា **ន វិជានាតិ** បានដល់ មិនដឹងសេចក្តីនៃធម៌នោះ ។ បទថា **អាលោកេតិ** បានដល់ ញ៉ាំងមេដៃឲ្យមានពន្លឺដោយឫទ្ធិរបស់បុថុជ្ជនរបស់លោកឲ្យភ្លឺរន្ទាល ។ បទថា **ន បស្សតិ** សេចក្តីថា រមែងមិនឃើញ

ហេតុការណ៍នេះថា ក្នុងទីនេះមិនមានប្រេង មិនមានបញ្ចេះ មិនមានចង្កៀង តែមេដៃនេះភ្លឺរន្ទាលដោយអានុភាពរបស់ព្រះថេរៈ ។ បទថា **ទស បជ្ជោតេ** គឺ ប្រទីប ១០ ក្នុងម្រាមដៃ ១០ ។ បទថា **រូបានិ** បានដល់ រូបដែលជាហេតុ បទថា **ចក្ខុំ** គឺ បញ្ញាចក្ខុ ។ បទថា **សំវេគមាបាទិ** សេចក្តីថា ព្រះកស្សប-គោត្រគិតថា នឹងមានប្រយោជន៍អ្វីដល់យើង ព្រោះនេះទើបផ្គងសេចក្តីព្យា-យាម បដិបត្តិដើម្បីអរហត្តមគ្គ ដែលជាបរមវិវេក ។

ចប់អដ្ឋកថា កស្សបគោត្តសូត្រទី ៣

# អ ដ្ឋ ក ថា

## សម្ពហុលសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងសម្ពហុលសូត្រទី ៤ តទៅនេះ ៖*

**[២៤៧]** *បទថា **សម្ពហុលា** គឺ ជាអ្នកទ្រទ្រង់ព្រះសូត្រ ជាអ្នកទ្រទ្រង់ព្រះអភិធម្ម ជាអ្នកទ្រទ្រង់ព្រះវិន័យ ជាច្រើនអង្គ ។ បទថា **វិហរន្តិ** បានដល់ រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដាហើយ ។ បទថា **បក្កមឹសុ** សេចក្តីថា បានឮថា មនុស្សទាំងឡាយឃើញភិក្ខុទាំងនោះ ចូលទៅកាន់ស្រុកមួយកន្លែងក្នុងជនបទនោះ ក៏មានចិត្តជ្រះថ្លា ក្រាលសំពត់រោមកែះជាដើមទុកត្រង់រោងឆាន់ ថ្វាយបបរ និងរបស់ទំពារ ហើយអង្គុយជិត ។ ព្រះមហាថេរៈពោលនឹងព្រះធម្មកថិកមួយរូបថា លោកចូរពោលធម៌ ។ ព្រះធម្មកថិកនោះ ទើបពោលធម្មកថា យ៉ាងពីរោះ ។ មនុស្សទាំងឡាយជ្រះថ្លា ហើយបានថ្វាយភោជនដ៏ប្រណីតក្នុងវេលាឆាន់ ។ ព្រះមហាថេរៈ បានធ្វើអនុមោទនាអាហារយ៉ាងពេញចិត្ត ។ មនុស្សទាំងឡាយជ្រះថ្លាយ៉ាងក្រៃលែង ហើយពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមនិមន្តចាំវស្សានៅក្នុងទីនេះ រហូតដល់អស់*

៣ ខែចុះ ឲ្យលោកទទួលបដិញ្ញាហើយ ឲ្យសាងសេនាសនៈក្នុងទីដែលសប្បាយ ដោយការទៅមក ហើយទំនុកបម្រុងដោយបច្ច័យ ៤ ។

ព្រះមហាថេរៈ ទូន្មានភិក្ខុក្នុងថ្ងៃចូលវស្សាថា ម្នាលអ្នកមានអាយុ ពួកលោករៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាដែលជាគ្រូ ឈ្មោះថា សេចក្តីប្រាកដនៃព្រះពុទ្ធរកបានលំបាក ពួកលោកចូរស្តាប់ធម៌ក្នុងមួយខែ ៨ ថ្ងៃ លះបង់សេចក្តីប្របូកប្របល់ដោយពួកគណៈហើយ ចូរកុំប្រមាទ ដូច្នេះ ។ ចាប់តាំងពីនោះមក ភិក្ខុទាំងនោះរមែងខ្វល់ខ្វាយប្រារព្ធព្យាយាម ថ្ងៃខ្លះក៏ធ្វើការស្តាប់ធម៌រហូតមួយយប់ ថ្ងៃខ្លះក៏ដោះស្រាយបញ្ហា គ្រាខ្លះក៏ធ្វើសេចក្តីព្យាយាម ។ ក្នុងថ្ងៃស្តាប់ធម៌ ភិក្ខុទាំងនោះពោលធម៌ជាបអរុណារៈ ក្នុងថ្ងៃដោះស្រាយបញ្ហា ធ្វើការសួរ និងការឆ្លើយ គឺ ភិក្ខុដែលឆ្លាតសួរបញ្ហា ភិក្ខុជាបណ្ឌិតដោះស្រាយ ក្នុងថ្ងៃធ្វើសេចក្តីព្យាយាម វាយរគាំងក្នុងវេលាព្រះអាទិត្យលិច ចុះកាន់ទីចង្ក្រម ធ្វើសេចក្តីព្យាយាម ។ ភិក្ខុទាំងនោះចាំវស្សាយ៉ាងនេះ បវារណាហើយចៀសចេញទៅ ។ ពាក្យនេះ លោកពោលសំដៅដល់សេចក្តីនោះ ។

**[២៤៨]** បទថា *បរិទេវមានា* សេចក្តីថា ទេវតាពោលពាក្យជាដើមថា ឥឡូវនេះយើងនឹងបានស្តាប់ធម៌ នឹងពោលបញ្ហាដ៏ពីរោះបែបនោះអំពីទីណាហ្ន៎

ដូច្នេះ ហើយក៏ទូញយំ ។ បទថា **ខាយតិ** ប្រែថា រមែងប្រាកដ គឺ ចូលទៅតាំងទុក ។ បទថា **កោមេ** ប្រែថា (ព្រះសាវក) ទាំងនេះ (ទៅ) ណា ។

**[២៨៩]** បទថា **វជ្ជិភូមិយា** ប្រែថា ឆ្ពោះទៅដែនវជ្ជី ។ បទថា **មក្កដាវិយ** ប្រែថា ដូចស្វា ។ ភិក្ខុត្រាច់ទៅត្រង់ជើងភ្នំ ឬត្រង់ដងព្រៃនោះៗ មិនប្រកាន់ថា ទីនេះជាសម្បត្តិរបស់មាតា ។ ជាសម្បត្តិរបស់បិតារបស់យើង ដែលមកតាមប្រពៃណី ភិក្ខុទាំងនោះមានសេចក្តីសុខដោយគោចរគ្រាម និងមិនមានសេចក្តីអន្តរាយនៅក្នុងទីណា ក៏នៅក្នុងទីនោះ សូម្បីភិក្ខុទាំងឡាយអ្នកមិនមានផ្ទះយ៉ាងនេះ ពោលថា ម្នាលអ្នកមានអាយុ នេះជាសម្បត្តិរបស់ឧបជ្ឈាយ៍អាចារ្យរបស់យើង ដែលមកតាមប្រពៃណី ដូច្នេះ ក៏មិនប្រកាន់ ភិក្ខុទាំងនោះមានសេចក្តីសប្បាយដោយឧតុ សប្បាយដោយភោជន សប្បាយដោយសេនាសនៈ សប្បាយដោយការស្តាប់ធម៌ រកបានងាយ មាននៅក្នុងទីណា ក៏រមែងនៅក្នុងទីនោះ ។

ចប់អដ្ឋកថា សម្ពហុលសូត្រទី ៤

# អ ដ្ឋ ក ថា

## អានន្ទសូត្រទី ៥

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអានន្ទសូត្រទី ៥ តទៅនេះ ៖

[២៥០] បទថា **អានន្ទោ** គឺ ព្រះថេរៈជាឃ្លាំងនៃព្រះធម៌ ។ បទថា **អតិវេលំ** ប្រែថា ហួសវេលា ។ បទថា **គិហិសញ្ញត្តិពហុលោ** សេចក្តីថា លោកពន្យល់គ្រហស្ថអស់វេលាជាច្រើន គឺ ទាំងពេលថ្ងៃ និងពេលយប់ ។ ពិតណាស់ កាលព្រះមានព្រះភាគបរិនិព្វាន ព្រះមហាកស្សបត្ថេរពោលនឹងព្រះថេរៈថា ម្នាលអ្នកមានអាយុ យើងនឹងទៅចាំវស្សាក្នុងក្រុងរាជគ្រឹះ ហើយសង្គាយនាព្រះធម៌ លោកចូរចូលទៅកាន់ព្រៃហើយធ្វើសេចក្តីព្យាយាមដើម្បីប្រយោជន៍ដល់មគ្គទាំង ៣ ខាងលើចុះ ។ ព្រះអានន្ទត្ថេរ កាន់យកបាត្រចីវររបស់ព្រះមានព្រះភាគទៅកាន់ដែនកោសល ស្នាក់នៅក្នុងព្រៃមួយកន្លែង ស្អែកឡើង ទើបចូលទៅកាន់ស្រុកមួយកន្លែង ។ មនុស្សទាំងឡាយឃើញព្រះថេរៈហើយ ពោលពាក្យជាច្រើនថា បពិត្រព្រះអានន្ទដ៏ចម្រើន ក្នុងគ្រាមុនលោកមកជាមួយព្រះសាស្តា ថ្ងៃនេះមកតែមួយអង្គឯងប៉ុណ្ណោះ លោកបោះបង់ចោល

ព្រះសាស្តាទុកទីណា ឥឡូវនេះ លោកកាន់បាត្រ និងចីវររបស់អ្នកណាមក លោកថ្វាយទឹកលាងមុខ និងបោសសម្អាតបរិវេណ និងធ្វើវត្តបដិបត្តិដល់អ្នកណា ដូច្នេះ ហើយនាំគ្នាទួញយំ ព្រះថេរៈពោលពាក្យជាដើមថា ម្នាលអ្នកទាំងឡាយ កុំសោកសៅឡើយ កុំទួញយំឡើយ សន្ធារទាំងឡាយមិនទៀង ហើយញ៉ាំងគេឲ្យដឹងព្រម ធ្វើកត្តកិច្ចហើយទៅកាន់ទីសម្រាក ។ សូម្បីក្នុងវេលាល្ងាច មនុស្សទាំងឡាយទៅក្នុងទីនោះ នាំគ្នាទួញយំយ៉ាងនោះ ព្រះថេរៈក៏ប្រៀនប្រដៅយ៉ាងនោះដូចគ្នា ។ ពាក្យនេះ លោកពោលសំដៅដល់ប្រការនោះ ។

**[២៥១]** បទថា ***អជ្ឈភាសិ*** សេចក្តីថា ទេវតាគិតថា ព្រះថេរៈនេះគិតថា យើងស្តាប់ពាក្យរបស់ភិក្ខុសង្ឃហើយ នឹងបំពេញសមណធម៌ ដូច្នេះ ហើយចូលទៅកាន់ព្រៃ ឥឡូវនេះញ៉ាំងគ្រហស្ថឲ្យដឹងព្រម លោកនៅមិនទាន់ធ្វើសាសនារបស់ព្រះសាស្តាដែលតាំងនៅ មិនទាន់បានរូបរូមធម៌ ដូចគំនរផ្កាដែលមិនបានក្រង យើងនឹងដាស់តឿនលោក ដូច្នេះ ហើយទើបពោល ។ បទថា ***បសក្កិយ*** ប្រែថា ចូលទៅហើយ ។ បទថា ***ហទយស្មឹ ឱប្បិយ*** បានដល់ ដាក់ទុកក្នុងហទយៈដោយកិច្ច និងដោយអារម្មណ៍ ។ ព្រះថេរៈគិត

ថា យើងនឹងសម្រេចព្រះនិព្វាន ដូច្នេះហើយ ធ្វើសេចក្តីព្យាយាម ឈ្មោះថា ដាក់ព្រះនិព្វានទុកក្នុងហទយៈដោយកិច្ច តែដើម្បីញ៉ាំងសមាបត្តិមានព្រះនិព្វានជាអារម្មណ៍ឲ្យតម្កល់មាំ ទើបអន្ទុយ (ឈ្មោះថា ដាក់ព្រះនិព្វានទុកក្នុងហទយៈ) ដោយអារម្មណ៍ ។ ទេវតានេះ រមែងពោលសំដៅដល់កិច្ច និងអារម្មណ៍ទាំង ២ នោះ ។ បទថា **ឈាយ** គឺ ចូរជាអ្នកសម្ញឹងដោយឈានទាំងពីរ ។ បទថា **បីឡិបីឡិកា** ប្រែថា នេះជាពាក្យនិយាយនឹងគ្រហស្ថ ។

ចប់អដ្ឋកថា អានន្ទសូត្រទី ៥

# អ ដ្ឋ ក ថា

# អនុរុទ្ធសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងអនុរុទ្ធសូត្រទី ៦ តទៅនេះ ៖*

**[២៥៣]** *បទថា* **បុរាណទុតិយិកា** *គឺ អគ្គមហេសីក្នុងអត្តភាពមុន ។ បទថា* **សោភសិ** *បានដល់ កាលមុនក៏ល្អ ឥឡូវនេះក៏ល្អ ។*

**[២៥៤]** *បទថា* **ទុគ្គតា** *សេចក្តីថា ទៅអាក្រក់ដោយគតិដែលអាក្រក់ក៏ទេ ។ ពិតណាស់ ទេវកញ្ញានៅក្នុងសុគតិ រមែងសោយសម្បត្តិ ។ តែទៅអាក្រក់ដោយគតិអាក្រក់ព្រោះផ្លូវបដិបត្តិ ។ ព្រោះថា ទេវកញ្ញាទាំងនោះ ចុតិពីសុគតិនោះហើយ នឹងកើតក្នុងនរកក៏បាន ព្រោះដូច្នោះ ទើបឈ្មោះថា ទៅអាក្រក់ ។ បទថា* **បតិដ្ឋិតា** *សេចក្តីថា ពិតហើយ កាលបុគ្គលតាំងនៅក្នុងសក្កាយទិដ្ឋិ រមែងតាំងនៅដោយហេតុ ៨ ប្រការ គឺ ស្រឡាញ់ដោយអំណាចរាគៈ ក្រោធដោយអំណាចទោសៈ វង្វេងដោយអំណាចមោហៈ ប្រកាន់ខ្ជូនដោយអំណាចមានះ ប្រកាន់ខុសដោយអំណាចទិដ្ឋិ ដល់ភាពក្ញៀវក្លាដោយអំណាចអនុស្ស័យ ដល់ភាពមិនដាច់ស្រេចដោយអំណាចនៃវិចិកិច្ឆា រវើរវាយដោយ*

អំណាចឧទ្ទេស: សូម្បីទេវកញ្ញាទាំងនោះ ក៏តាំងនៅយ៉ាងនេះ ។

**[២៥៥]** បទថា **នរទេវានំ** សេចក្តីថា ជាអាវាសរបស់ទេវតាទាំងឡាយ ។

**[២៥៦]** បទថា **នត្ថិទានិ** សេចក្តីថា បានឮថា ទេពធីតានោះមានសេចក្តីស្នេហាដ៏ខ្លាំងក្នុងព្រះថេរៈ មិនអាចនឹងត្រឡប់ទៅ ។ នាងមកតាមវេលា បោសសម្អាតបរិវេណ ចូលទៅតាំងទឹកលាងមុខ ឈើស្ទន់ ទឹកឆាន់ ទឹកប្រើប្រាស ។ ព្រះថេរៈប្រើប្រាស់ដោយមិនបានពិចារណា ក្នុងថ្ងៃមួយ ព្រះថេរៈមានចីវរចាស់ត្រាច់ទៅ សូមកំណាត់សំពត់ នាងដាក់សំពត់ទិព្វទុកត្រង់គំនរសម្រាម ហើយចៀសចេញទៅ ។ ព្រះថេរៈឃើញសំពត់នោះហើយ លើកឡើងមើល ក៏ដឹងថា នេះជាសំពត់ គិតថា ប៉ុណ្ណេះក៏ល្មម ដូច្នេះ ហើយក៏កាន់យក ។ ចីវររបស់លោកសម្រេចដោយសំពត់នោះឯង ។ ព្រះថេរៈ ៣ រូប គឺ ព្រះអគ្គសាវក ២ រូប និងព្រះអនុរុទ្ធត្ថេរ ជួយគ្នាធ្វើចីវរ ។ ព្រះសាស្តាទ្រង់ប្រទានម្ជុលជាគ្រឿងប្រកប ។ កាលព្រះអនុរុទ្ធត្ថេរធ្វើចីវរស្រេចហើយ ត្រាច់ទៅបិណ្ឌបាត ទេវតាក៏ថ្វាយបិណ្ឌបាត ។ ទេពធីតានោះ ពេលខ្លះមកកាន់សម្នាក់ព្រះថេរៈតែមួយអង្គឯង គ្រាខ្លះ ២ អង្គ ។ តែគ្រានោះ មក ៣ អង្គចូលទៅរកព្រះថេរៈដល់ទីសម្រាកពេលថ្ងៃ ហើយពោលថា យើងឈ្មោះថា

មានរាងកាយគួរពេញចិត្ត នឹងនិម្មិតរូបដែលចិត្តប្រាថ្នាហើយ ។ ព្រះថេរៈគិតថា ទេពធីតាទាំងនេះពោលយ៉ាងនេះ បើដូច្នោះ យើងនឹងសាកល្បងមើលថា ទេពធីតាទាំងពួងចូរខៀវចុះ ដូច្នេះ ។ ទេពធីតាទាំងនោះដឹងចិត្តរបស់ព្រះថេរៈហើយ ក៏និម្មិតខ្លួនជាពណ៌ខៀវទាំងអស់ (សាកល្បងថា) មានពណ៌លឿង ពណ៌ក្រហម ពណ៌ស ក៏ជាយ៉ាងនោះដូចគ្នា ។ លំដាប់នោះ ពួកគេគិតថា ព្រះថេរៈពេញចិត្តនឹងឃើញពួកយើង ដូច្នេះ ហើយក៏ផ្តើមនូវរបាំ គឺ មួយអង្គច្រៀង មួយអង្គរាំ មួយអង្គទះដៃ ។ ព្រះថេរៈសង្រួមឥន្ទ្រិយទាំងឡាយ ។ លំដាប់នោះ ទេពធីតាដឹងថា ព្រះថេរៈមិនពេញចិត្តមើលពួកយើង កាលមិនបានសេចក្តីស្នេហា ឬសេចក្តីសរសើរ ក៏នឿយណាយ ទេពធីតាទាំងនោះរៀបនឹងទៅ ព្រះថេរៈដឹងថា គេនឹងទៅ ទើបពោលថា នាងចូរកុំមករឿយៗឡើយ ។ កាលនឹងព្យាករណ៍ជាព្រះអរហត្ត ទើបពោលគាថានេះ ។

ក្នុងបទទាំងនេះ បទថា **វិក្ខីណោ** ប្រែថា អស់ហើយ ។ បទថា **ជាតិសំសារោ** សេចក្តីថា ការអន្ទោលទៅដែលរាប់ថា កើតក្នុងទីនោះៗ ។

ចប់អដ្ឋកថា អនុរុទ្ធសូត្រទី ៦

# អ ដ្ឋ ក ថា

## នាគទត្តសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យ ក្នុងនាគទត្តសូត្រទី ៧ តទៅនេះ ៖

**[២៥៧]** បទថា **អតិកាលេន** សេចក្តីថា ភិក្ខុនាគទត្តៈ ដេកលក់រហូតអស់មួយយប់ ក្នុងវេលាជិតភ្លឺ យកចុងឈើបោសសំអាតចេញបន្តិច លាងមុខហើយចូលទៅសូមបបរពីព្រឹក ។ បទថា **អតិទិវា** សេចក្តីថា ទទួលបបរហើយត្រាច់ទៅរោងឆាន់ៗ ហើយ គិតថា យើងនឹងបានអាហារយ៉ាងល្អក្នុងវេលាបរិភោគរបស់មនុស្សទាំងឡាយ ហើយដេកលក់ក្នុងទីមួយកន្លែង ដូច្នេះកាលវេជិតត្រង់ ក៏ក្រោកឡើងយកតម្រងទឹកជងទឹកលុបមុខ ហើយទៅរកអាហារឆាន់តាមត្រូវការ លុះវេលាហួសត្រង់ហើយ ក៏ចៀសចេញទៅ ។

**[២៥៨]** បទថា **ទិវា ច អាគន្ត្វា** សេចក្តីថា ឈ្មោះថា ជាអ្នកចូលទៅព្រឹកពេក ក៏គប្បីមកមុនភិក្ខុទាំងឡាយដទៃ តែលោកមកយឺតពេក ។ បទថា **ភាយាមិ នាគទត្តំ** បានដល់ យើងខ្លាចព្រះនាគទត្តៈនោះ ។ បទថា **សុបគព្ភំ** បានដល់ ឃ្នើសឃ្នងដ៏ក្រៃលែង ។ បទថា **កុលេសុ** គឺ ក្នុងត្រកូល

ឧបដ្ឋាក មានត្រកូលក្សត្រិយ៍ជាដើម ។

ចប់អដ្ឋកថា នាគទត្តសូត្រទី ៧

# អ ដ្ឋ ក ថា

## កុលឃរណីសូត្រទី ៨

គប្បីជ្រាបវិនិច្ឆ័យ ក្នុងកុលឃរណីសូត្រទី ៨ តទៅនេះ ៖

**[២៥៩]** បទថា អជ្ឈោគាឡ្ហប្បត្តោ ប្រែថា ដល់ភាពប្រឫកប្រឫល់ ។ បានឮថា ភិក្ខុនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ចូលទៅកាន់ដងព្រៃ ចូលទៅបិណ្ឌបាតក្នុងស្រុកក្នុងថ្ងៃទី ២ ។ ដោយមារយាទដែលគួរជ្រះថ្លា ។ ត្រកូលខ្លះជ្រះថ្លាក្នុងឥរិយាបថរបស់លោក ក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយថ្វាយបិណ្ឌបាត ។ ឯគេបានស្តាប់កត្តានុមោទនាហើយ ក៏ជ្រះថ្លាក្រៃលែងឡើង និមន្តថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់និមន្តទទួលភិក្ខាក្នុងទីនេះរហូតអស់កាលជានិច្ចចុះ ។ ព្រះថេរៈនោះទទួលហើយ កាលបរិភោគអាហាររបស់គេ ក៏ផ្តងសេចក្តីព្យាយាម ប្រារព្ធព្យាយាមដរាបសម្រេចព្រះអរហត្ត ហើយគិតថា ត្រកូលនេះ មានឧបការៈដល់យើងច្រើន យើងនឹងទៅក្នុងទីដទៃដូចម្តេចកើត ដូច្នេះ ទើបសោយសេចក្តីសុខនៃផលសមាបត្តិនៅក្នុងទីនោះ ។

**[២៦០]** បទថា **អជ្ឈភាសិ** សេចក្ដីថា បានពូថា ទេពធីតានោះមិនដឹងថា ព្រះថេរៈជាព្រះខីណាស្រព ទើបគិតថា ព្រះថេរៈនេះមិនទៅកាន់ស្រុកដទៃ មិនទៅកាន់ផ្ទះដទៃ មិនអង្គុយក្នុងទីដទៃ មានគល់ឈើ និងសាលាជាដើម ចូលទៅអង្គុយក្នុងផ្ទះតែមួយ រហូតអស់កាលជានិច្ច ក៏ឯភិក្ខុទាំង ២ នេះ ដល់ភាពប្រឫកប្រឫល់ ពេលខ្លះភិក្ខុនេះនឹងគប្បីប្រទូសរ៉ាយត្រកូលនេះ យើងនឹងជាសត្រៀនភិក្ខុនោះ ដូច្នេះ ព្រោះដូច្នោះ ទើបពោល ។

បទថា **សណ្ឋានេ** សេចក្ដីថា ក្នុងទីជិតទ្វារក្រុងដែលមនុស្សទាំងឡាយបោលវត្ថុក្នុងទីមិនរាបស្មើ ។ បទថា **សង្គម្ម** ប្រែថា មកប្រជុំគ្នា ។ បទថា **មន្តេន្តិ** ប្រែថា និយាយគ្នា ។ បទថា **មញ្ច តញ្ច** ប្រែថា ពោលនឹងយើងផង ពោលនឹងគេផង ។ បទថា **កិមន្តរំ** ប្រែថា ព្រោះហេតុអ្វី ។

**[២៦១]** បទថា **ពហូ ហិ សទ្ទា បច្ចូហា** សេចក្ដីថា សំឡេងដែលជាសត្រូវទាំងនេះ មានច្រើនក្នុងលោក ។ បទថា **ន តេន** ប្រែថា ព្រោះហេតុនោះ បុគ្គលអ្នកមានតបៈនោះ មិនគប្បីអៀនខ្មាសឡើយ ។ បទថា **ន ហិ តេន** សេចក្ដីថា ក៏ សត្វនឹងសៅហ្មងព្រោះពាក្យដែលមនុស្សដទៃនោះពោលហើយ ក៏មិនមែន លោកសម្ដែងថា សត្វតែងសៅហ្មងដោយបាបកម្មដែលខ្លួន

ធ្វើ ។ បទថា **វាតមិគោ យថា** សេចក្តីថា ម្រឹគក្នុងព្រៃ រមែងតក់ស្លុតដោយសំឡេងនៃស្លឹកឈើជាដើម ដែលត្រូវខ្យល់បក់ យ៉ាងណា គេឈ្មោះថា ជាអ្នកតក់ស្លុតដោយសំឡេងនោះ ដូច្នោះ ។ បទថា **នាស្ស សម្បជ្ជតេ** សេចក្តីថា វត្តរបស់អ្នកមានចិត្តស្រោលនោះ រមែងមិនបរិបូរ ។ ឯព្រះថេរៈ គប្បីជ្រាបថា មានវត្តបរិបូណ៌ហើយ ព្រោះជាព្រះខីណាស្រព ។

ចប់អដ្ឋកថា កុលឃរណីសូត្រ ទី ៨

# អ ដ្ឋ ក ថា

## វជ្ជីបុត្តសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងវជ្ជីបុត្តសូត្រទី ៩ តទៅនេះ ៖*

**[២៦២]** *បទថា* ***វជ្ជីបុត្តកោ*** *គឺ រាជបុត្រក្នុងដែនវជ្ជីលះបង់ស្វេតឆត្រចេញបួស ។ បទថា* ***សព្វរត្តិចារោ*** *គឺ វារៈនៃមហោស្រពអស់រាត្រីទាំងពួងសេចក្ដីថា សេចក្ដីរីករាយដែលអ្នកស្រុកសើចសប្បាយក្នុងការលេងក្នុងខែ ១២ តុបតែងដោយទង់ជ័យ និងទង់សំពត់ប្រព្រឹត្តទៅទូទាំងព្រះនគរ ឈ្មោះថាវារៈ នៃមហោស្រពរហូតអស់យប់ ។ ពិតហើយ នក្ខត្តឫក្សនេះ មានជាប់តែមួយរហូតដល់ចាតុម្មហារាជិកា ។ បទថា* ***តុរិយតាឡិតវាទិតនិគ្ឃោសសទ្ទំ*** *គឺ សំឡេងគឹកកងនៃតន្ត្រី មានស្គរជាដើម ដែលគេប្រគុំហើយ និងគ្រឿងខ្សែ មានពិណជាដើមដែលគេលេងហើយ ។*

**[២៦៣]** *បទថា* ***អភាសិ*** *សេចក្ដីថា បានពោលថា ក្នុងក្រុងវេសាលីមានព្រះរាជា ៧.៧០៧ អង្គ ឯឧបរាជ និងសេនាបតីជាដើមរបស់ព្រះរាជាទាំងនោះ ក៏មានប៉ុណ្ណោះដូចគ្នា ។ កាលព្រះរាជាទាំងនោះតែងខ្លួនហើយ ចុះ*

កាន់ថ្កល់ ដើម្បីប្រាថ្នានឹងលេងនក្សត្រ ភិក្ខុវជ្ជិបុត្រដើរចង្ក្រមនៅក្នុងទីចង្ក្រម ធំ ប្រមាណ ៦០ ហត្ថ ឃើញព្រះចន្ទអណ្តែតនៅលើផ្ទៃអាកាស ឈរអាស្រ័យផែនក្តាចុងទីចង្ក្រមហើយពោល ។ បទថា **អបវិទ្ធំវ វនស្មឹ ទារុកំ** សេចក្តីថា ដូចកំណាត់ឈើដែលគេចោលក្នុងព្រៃ ព្រោះជាអ្នកវៀរចាកគ្រឿងតុបតែងខ្លួន គឺ សំពត់ជូតក្បាល ។ បទថា **បាបិយោ** សេចក្តីថា នឹងមានអ្នកដទៃណាដែលអាក្រក់ជាងយើង ។

**[២៦៤]** បទថា **បិហយន្តិ** សេចក្តីថា ទេវតា និងមនុស្ស ជាច្រើនប្រាថ្នាចំពោះលោកថា ព្រះថេរៈនៅព្រៃ ជាអ្នកទ្រទ្រង់នូវសំពត់បង្សុកូល ជាអ្នកកាន់បិណ្ឌបាត ជាអ្នកត្រាច់បិណ្ឌបាតតាមលំដាប់ផ្ទះ មានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស ។ បទថា **សគ្គគាមិនំ** គឺ កំពុងទៅកាន់សួគ៌ខ្លះ ទៅហើយខ្លះ ។

ចប់អដ្ឋកថា វជ្ជិបុត្តសូត្រ ទី ៩

# អ ដ្ឋ ក ថា

## សជ្ឈាយសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសជ្ឈាយសូត្រទី ១០ តទៅនេះ ៖

**[២៦៥]** បទថា *យំ សុទំ* ត្រឹមតែជានិបាត ។ បទថា *សជ្ឈាយពហុលោ* សេចក្តីថា កាលស្វាធ្យាយដោយអំណាចនៃនិស្សរណៈ និងបរិយត្តិ គឺស្វាធ្យាយច្រើនហួសវេលា ។ បានឮថា ភិក្ខុនោះបោសសម្អាតទីសម្រាកពេលថ្ងៃរបស់អាចារ្យ ហើយឈរមើលអាចារ្យ ។ កាលឃើញអាចារ្យនោះកំពុងដើរមក ទើបក្រោកឡើងទៅទទួលបាត្រ និងចីវរ ។ កាលអាចារ្យអង្គុយលើអាសនៈដែលក្រាលទុកហើយ ក៏យកផ្ចិតស្លឹកត្នោត បក់ឲ្យ ប្រាប់ទឹកឆាន់ ទឹកលាងជើង ហើយលាបប្រេង ថ្វាយបង្គំ ឈររៀនឧទ្ទេស ធ្វើការស្វាធ្យាយរហូតដល់ព្រះអាទិត្យលិច ។ ភិក្ខុនោះ យកទឹកចូលទៅតាំងទុកក្នុងបន្ទប់ទឹក ដុតភ្លើងក្នុងបន្ទ្រានមុនកាលអាចារ្យងូតទឹករួចហើយ ដើរមកក៏ជូតទឹកត្រង់ជើង គក់ប្របាច់ខ្នង ថ្វាយបង្គំហើយរៀនឧទ្ទេស ធ្វើការស្វាធ្យាយក្នុងបឋមយាម សម្រាកកាយក្នុងមជ្ឈិមយាម ក្រោកឡើងក្នុងបច្ឆិមយាម រៀនឧទ្ទេស ធ្វើការ

ស្វាធ្យាយជាបដល់អរុណរះ ទើបពិចារណាសំឡេងដែលរលត់ទៅហើយ ដោយការអស់ទៅ ។ ចម្រើនវិបស្សនាក្នុងខន្ធ ៥ គឺ ឧបាទាយរូបដ៏សេសអំពីនោះមានភូតរូប និងនាមរូប ហើយសម្រេចព្រះអរហត្ត ។ បទថា **អប្បោស្សុក្កោ** សេចក្តីថា មិនខ្វល់ខ្វាយក្នុងការរៀនឧទ្ទេស និងក្នុងការស្វាធ្យាយ ។ បទថា **សកមាយតិ** សេចក្តីថា ភិក្ខុនោះគិតថា ឥឡូវនេះយើងនឹងគប្បីធ្វើការស្វាធ្យាយដើម្បីប្រយោជន៍ណា ប្រយោជន៍របស់យើងនោះដល់ទីបំផុតហើយ ឥឡូវនេះប្រយោជន៍អ្វីដោយការស្វាធ្យាយរបស់យើង ដូច្នេះ ហើយញុំាងវេលាឲ្យកន្លងទៅដោយសេចក្តីសុខដែលកើតអំពីផលសមាបត្តិ ។

**[២៦៦]** បទថា **អជ្ឈភាសិ** សេចក្តីថា ទេវតាគិតថា ការតមិនសប្បាយកើតដល់ព្រះថេរៈ ឬថា ដល់អាចារ្យរបស់លោក ព្រោះហេតុអ្វីហ្ន៎ លោកទើបមិនស្វាធ្យាយដោយសំឡេងដ៏ពីរោះដូចក្នុងកាលមុន ដូច្នេះ ទើបទៅឈរនិយាយនៅក្នុងទីជិត ។ ព្រះពុទ្ធវចនៈទាំងពួងលោកប្រាថ្នាយកក្នុងបទថា **ធម្មបទានិ** ។ បទថា **នាធិយសិ** ប្រែថា មិនស្វាធ្យាយ ។ បាលីថា **នាទិយសិ** ខ្លះ សេចក្តីថា មិនកាន់យក ។ បទថា **បសំសំ** គឺ អ្នកពោលធម៌ រមែងបាននូវសេចក្តីសរសើរ ។ អ្នកដែលពោលធម៌នោះ រមែងមានអ្នកសរសើរថា ជាអ្នកទ្រទ្រង់

អភិធម្ម ជាអ្នកទ្រទ្រង់ព្រះសូត្រ ជាអ្នកទ្រទ្រង់ព្រះវិន័យ ។

**[២៦៧]** បទថា *វិភាគេន* បានដល់ ដោយអរិយមគ្គ ។ បទថា *អញ្ញាយ* ប្រែថា ដឹងហើយ ។ បទថា **និក្ខុបនំ** សេចក្ដីថា លោកសម្ដែងដល់ព្រះថេរៈ នោះថា សប្បុរស រមែងពោលវិសជ្ជនាវត្ថុដែលឃើញហើយ និងស្ដាប់ហើយ ជាដើម ។ (តែនេះ) មិនមែន (សម្ដែង) ដល់ព្រះពុទ្ធ ។ អធិប្បាយថា ព្រះថេរៈ ឲ្យវិសជ្ជនាពុទ្ធវចនៈដោយពាក្យប្រមាណប៉ុណ្ណោះ ។ មិនគប្បីជាអ្នកស្វាធ្យាយ រហូតអស់កាលជានិច្ច ។ តែថា ភិក្ខុនោះស្វាធ្យាយហើយ ដឹងថា យើងអាច ជាអ្នកទ្រទ្រង់អត្ថ ឬធម៌ ប្រមាណប៉ុណ្ណោះ ដូច្នេះ ហើយគប្បីបដិបត្តិដើម្បី ធ្វើនូវទីបំផុតនៃវដ្ដទុក្ខ ។

ចប់អដ្ឋកថា សជ្ឈាយសូត្រទី ១០

# អ ដ្ឋ ក ថា

## អយោនិសោមនសិការសូត្រទី ១១

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអយោនិសោមនសិការសូត្រទី ១១ តទៅនេះ ៖

[២៦៨] បទថា *អកុសលេ វិតក្កេ* បានដល់ មហាវិតក្កៈ ៣ មានកាមវិតក្កៈជាដើម ។

[២៦៩] បទថា *អយោនិសោមនិកាក* ប្រែថា ព្រោះមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ។ បទថា *សោ* ប្រែថា លោកនោះ ។ បទថា *អយោនិសោ បដិនិស្សជ្ជ* គឺ លោកចូរវៀរការមិនធ្វើទុកក្នុងចិត្តដោយឧបាយនោះចេញ ។ បទថា *សត្ថារំ* បានដល់ ពោលកម្មដ្ឋានដែលគួរជ្រះថ្លាដោយគាថានេះ ។ បទថា *បីតិសុខមសំសយំ* បានដល់ សម្រេចបីតិដែលមានកម្លាំងនិងសេចក្ដីសុខដោយចំណែកមួយ ។

ចប់អដ្ឋកថា អយោនិសោមនសិការសូត្រទី ១១

# អ ដ្ឋ ក ថា

## មជ្ឈន្តិកសូត្រទី ១២

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងមជ្ឈន្តិកសូត្រទី ១២ ។ ពាក្យណាគួរពោល ពាក្យនោះ ខ្ញុំពោលទុកហើយក្នុងនន្ទនវគ្គ ក្នុងទេវតាសំយុត្ត ។*

ចប់អដ្ឋកថា មជ្ឈន្តិកសូត្រទី ១២

# អ ដ្ឋ ក ថា

## បាកតិន្ទ្រិយសូត្រទី ១៣

*អដ្ឋកថាបាកតិន្ទ្រិយសូត្រទី ១៣ មានពិស្ដារហើយក្នុងជន្ទុទេវបុត្តក្នុងទេវបុត្តសំយុត្ត ។*

# អ ដ្ឋ ក ថា

## បទុមបុប្ផសូត្រទី ១៤

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទុមបុប្ផសូត្រទី ១៤ តទៅនេះ ៖*

**[២៧៥]** *បទថា* **អជ្ឈភាសិ** *សេចក្តីថា ទេវតានោះឃើញភិក្ខុនោះចាប់ទងផ្កាឈូកបង្អោនមក (ហិត) ទើបគិតថា ភិក្ខុនេះរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាហើយចូលព្រៃដើម្បីបំពេញសមណធម៌ នឹងពិចារណាយកក្លិនជាអារម្មណ៍ ក្នុងថ្ងៃនេះ ភិក្ខុនេះហិតក្លិនហើយ សូម្បីក្នុងថ្ងៃស្អែកនេះ សូម្បីក្នុងថ្ងៃខានស្អែកនេះក៏នឹងហិតក្លិនទៀត តណ្ហាក្នុងក្លិននោះ របស់ភិក្ខុនោះនឹងចម្រើនឡើងហើយ នឹងញុំាងប្រយោជន៍ក្នុងជាតិនេះ និងក្នុងជាតិខាងមុខឲ្យវិនាស កាលយើងឃើញហើយ ភិក្ខុនេះកុំវិនាសឡើយ យើងនឹងជាស់តឿនលោក ដូច្នេះ ហើយទើបចូលទៅនិយាយ ។*

*បទថា* **ឯកង្គមេតំ ថេយ្យានំ** *សេចក្តីថា នេះជាអង្គមួយ គឺ ជាចំណែកមួយនៃចំណែកទាំង ៥ មានរូបារម្មណ៍ជាដើមដែលគប្បីលួចយក ។*

**[២៧៦]** *បទថា* **ន ហរាមិ** *ប្រែថា មិនកាន់យកទៅ ។ បទថា* **អារា** *គឺ ភិក្ខុពោលថា យើងចាប់ទងក្នុងទីឆ្ងាយបង្អោនមកហិត ។ បទថា* **វណ្ណេន** *ប្រែថា ព្រោះហេតុ ។ បទថា* **យ្វាយំ** *កាត់បទថា* **យោ អយំ** *(ប្រែថានេះ*

ណា) ។ បានឮថា កាលភិក្ខុនោះកំពុងនិយាយនឹងទេវតា តាបសម្នាក់ក៏ចុះទៅជីកក្រអៅឈូកជាដើម ។ លោកពោលសំដៅយកសេចក្ដីនោះ ។ បទថា **អាកិណ្ណកម្មន្តោ** គឺ មានការងារមិនបរិសុទ្ធិយ៉ាងនេះ ។ បាលីថា **អខីណកម្មន្តោ** ខ្លះ សេចក្ដីថា មានការងារគ្រោតគ្រាត ។ បទថា **ន វុច្ចតិ** សេចក្ដីថា ព្រោះហេតុអ្វីទើបមិនពោលថា លួចក្លិន ឬថា លួចផ្កា ។

**[២៧៧]** បទថា **អាកិណ្ណលុទ្ទោ** គឺ មានសេចក្ដីអាក្រក់ច្រើន ឬថា មានសេចក្ដីថោកទាប ។ បទថា **អតិវេលំវ មក្ខិតោ** សេចក្ដីថា បុរសនេះប្រឡាក់ដោយកិលេស មានរាគៈ និងទោសៈជាដើម ដូចជាសំពត់សៅហ្មងដែលមេដោះស្នៀកហើយ ប្រឡាក់ដោយឧច្ចារៈបស្សាវៈ ធូលី ម្រេងភ្លើង និងភក់ជាដើម ។ បទថា **អរហាមិ វត្តវេ** ប្រែថា គួរពោល ។ បានឮថា ការដាស់តឿនរបស់ទេវតា ក៏ដូចគ្នានឹងពាក្យទូន្មានរបស់ព្រះសុគត ។ បុគ្គលអាក្រក់បង្អោនទៅខាងអាក្រក់ និងបដិបត្តិខុស រមែងមិនបានទទួលការដាស់តឿននោះឡើយ ។ ចំណែកបុគ្គលគួរដល់មគ្គផលក្នុងអត្តភាពនោះ រមែងបានការដាស់តឿននោះឯង ។ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ ។ បទថា **សុចិគវេសិនោ** គឺ អ្នកស្វែងរកសីល សមាធិ និងញាណដែលល្អស្អាត ។ បទថា **អព្ភាមត្តំវ** គឺ ប្រាកដដូចដុំប៉ុនមេឃ ។

**[២៧៨]** បទថា **ជានាសិ** បានដល់ ដឹងថា អ្នកនេះបរិសុទ្ធិ ។ បទថា

វជ្ជាសិ ប្រែថា គប្បីពោល ។

[២៧៩] បទថា *នេវ តំ ឧបជីវាមិ* សេចក្តីថា បានឮថា ភិក្ខុនេះគិតថា មានទេវតាអ្នកប្រាថ្នាល្អដល់យើង នឹងជាស់តឿនយើង នឹងចង្អុលបង្ហាញយើង ដូច្នេះ ភិក្ខុនឹងប្រកបសេចក្តីប្រមាទ ដោយហេតុនោះ យើងនឹងមិនទទួលពាក្យរបស់ភិក្ខុនោះ ព្រោះដូច្នោះ ទេវតាទើបពោលយ៉ាងនេះ ។ បទថា *តវមេវ* បានដល់ គួរដឹងដោយខ្លួនលោក ។ បទថា *ជានេយ្យ* ប្រែថា គប្បីដឹង ។ បទថា *យេន* គឺ ដោយកម្មណា ។ សេចក្តីថា លោកនឹងទៅកាន់សុគតិ លោកនឹងដឹងកម្មនោះ ។

ចប់អដ្ឋកថា បទុមបុប្ផសូត្រ ទី ១៤

## ចប់វនសំយុត្ត ត្រឹមតែប៉ុណ្ណេះ

### រួមក្នុងវគ្គនេះមាន ១៣ អដ្ឋកថា


| | |
|---|---|
| ១-អដ្ឋកថាវិវេកសូត្រ | ២-អដ្ឋកថាឧបដ្ឋានសូត្រ |
| ៣-អដ្ឋកថាកស្សបគោត្រសូត្រ | ៤-អដ្ឋកថាសម្ពហុលសូត្រ |
| ៥-អដ្ឋកថាអានន្ទសូត្រ | ៦-អដ្ឋកថាអនុរុទ្ធសូត្រ |
| ៧-អដ្ឋកថានាគទត្តសូត្រ | ៨-អដ្ឋកថាកុលឃរណីសូត្រ |
| ៩-អដ្ឋកថាវជ្ជីបុត្តសូត្រ | ១០-អដ្ឋកថាសជ្ឈាយសូត្រ |
| ១១-អដ្ឋកថាអយោនិសោ..សូត្រ | ១២-អដ្ឋកថាមជ្ឈន្តិកសូត្រ |
| ១៣-អដ្ឋកថាបាកតិន្ទ្រិយសូត្រ | ១៤-អដ្ឋកថាបទុមបុប្ផសូត្រ |

# យក្ខសំយុត្តវណ្ណនា

## អ ដ្ឋ ក ថា

### ឥន្ទកសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យ ក្នុងឥន្ទកសូត្រទី ១ នៃយក្ខសំយុត្តដូចតទៅនេះ ៖

[២៨០] បទថា *ឥន្ទកស្ស* គឺ យក្ខនៅត្រង់ភ្នំឥន្ទកូដ ។ ពិតណាស់ ព្រះសូត្រនេះបានឈ្មោះអំពីយក្ខ (ឥន្ទក:) និងកូដ: (កំពូល) និងអំពីកូដ: ។

[២៨១] បទថា *រូបំ ន ជីវន្តិ វទន្តិ* សេចក្តីថា បើព្រះពុទ្ធទាំងឡាយមិនពោលរូបយ៉ាងនេះថា សត្វ បុគ្គល ។ បទថា **កថំ ន្វយំ** កាត់បទថា **កថំ នុ អយំ** ។ បទថា *កុតស្ស* **អដ្ឋិយកបិណ្ឌមេតិ** សេចក្តីថា ឆ្អឹង និងដុំសាច់របស់សត្វនោះ នឹងមកពីណា ។ ក៏ក្នុងពាក្យនេះ លោកកាន់យកឆ្អឹង ៣០០ កំណាត់ ដោយស័ព្ទថា **អដ្ឋិ** ដុំសាច់ ៩០០ ដោយស័ព្ទថា **យកបិណ្ឌ** ។

សួរថា បើរូបមិនមែនជីវ: បើដូច្នោះ ឆ្អឹងទាំងនេះ និងដុំសាច់ទាំងនេះរបស់គេ រមែងបានពីណា ។ បទថា **កថំ ន្វយំ សជ្ជតិ គព្ភស្មឹ** សេចក្តីថា សត្វនេះជាប់នៅ គឺ ជំពាក់នៅ កើតនៅក្នុងគភ៌របស់មាតា ដោយហេតុណាហ្ន៎ ។

បានឮថា យក្ខនេះច្រើនតែនិយាយនឹងបុគ្គលដែលយល់ថា សត្វកើតក្នុងគភ៌របស់មាតា ដោយការនៅរួមក្នុងគ្រាតែមួយ ដូច្នេះ ទើបពោលយ៉ាងនេះ តាមការឃើញថា មាតារបស់សត្វដែលកើតក្នុងផ្ទៃ មាតានោះរមែងបរិភោគត្រីនិងសាច់ជាដើម ត្រី និងសាច់ជាដើមទាំងពួង ត្រូវដុតត្រឹមតែមួយយប់ ក៏រលួយទៅ ដូចពពុះទឹក បើរូបមិនមែនជាសត្វ ក៏រមែងរលួយទៅយ៉ាងនេះ ។ លំដាប់នោះ កាលព្រះមានព្រះភាគទ្រង់សម្តែងដល់យក្ខនោះថា សត្វមិនបានកើតក្នុងគភ៌របស់មាតា ដោយការនៅរួមក្នុងគ្រាតែមួយប៉ុណ្ណោះ គឺ តែងតែចម្រើនឡើងដោយលំដាប់ ទើបត្រាស់ថា **បឋមំ កលលំ ហោតិ** ជាដើម ។

**[២៨២]** ក្នុងបទទាំងនោះ បទថា **បឋមំ** សេចក្តីថា ឈ្មោះថា តិស្សៈ ឬថា បុស្សៈ រមែងមិនមានព្រមនឹងបដិសន្ធិវិញ្ញាណក្នុងគ្រាដំបូង ។ ដោយពិត កលលៈ មានប្រមាណប៉ុនតំណក់ប្រេងល្ង ដែលតាំងនៅត្រង់ចុងសរសៃអំបោះ ដែលធ្វើដោយរោមសត្វ ៣ សរសៃ លោកពោលសំដៅសេចក្តីថា

តំណក់នៃប្រេងល្ង ទឹកដោះថ្លា ថ្លាមិនកករល្អក់
យ៉ាងណា គេហៅថា កលលៈ មានពណ៌ស្រដៀង
គ្នា ដូច្នោះ ។

បទថា កលលា ហោតិ អម្ពុទំ (បាលីជា អព្វុទំ អព្វុទា) សេចក្ដីថា កាលកលលៈនោះកន្លងទៅ ៧ ថ្ងៃ ក៏មានពណ៌ដូចទឹកលាងសាច់ ទើបឈ្មោះថា អម្ពុទៈ ។ ឈ្មោះថា កលលៈ ក៏បាត់ទៅ ។ សមដូចពាក្យដែលលោកពោល ថា ៖

ជាកលលៈ ៧ ថ្ងៃ លុះដល់ខាប់ឡើង
ផ្លាស់ភាវៈនោះ កើតជាអម្ពុទៈ ។

បទថា អម្ពុទា ជាយតេ បេសិ សេចក្ដីថា កាលអម្ពុទៈនោះកន្លងទៅ ៧ ថ្ងៃ ក៏កើតជា បេសិ ស្រដៀងគ្នានឹងសំណាក ។ បេសិនោះ គប្បីសម្ដែង ដោយទឹកម្ទេសលាយស្ករ ។ ពិតណាស់ ក្មេងអ្នកស្រុកកាន់យកម្ទេសទុំវិច ទុកត្រង់សំពត់ ហើយបុកយកចំណែកដែលល្អ ដាក់លើក្បៀងហាលថ្ងៃ ។ ម្ទេសនោះក៏ស្ងួត រមែងជ្រុះសំបកអស់ ។ បេសិ មានរូបរាងយ៉ាងនេះ ។ ឈ្មោះថា អម្ពុទៈ ក៏បាត់ទៅ ។ សមដូចដែលលោកពោលទុកថា ៖

ជាអម្ពុទៈបាន ៧ ថ្ងៃ ដល់ខាប់រឹងឡើង
ផ្លាស់ភាវៈនោះ កើតជាបេសិ ។

បទថា បេសិ និព្វត្តតី ឃនោ សេចក្ដីថា កាលបេសិនោះកន្លងទៅ ៧

ថ្ងៃ ដុំសាច់ឈ្មោះ ឃនៈ មានសណ្ឋានដូចជាពងមាន់កើតឡើង ។ ឈ្មោះថា បេសិក៏បាត់ទៅ ។ សមដូចដែលលោកពោលទុកថា ៖

ជាបេសិ បាន ៧ ថ្ងៃ លុះដល់ខាប់ឡើង
ផ្លាស់ការៈនោះ កើតជា ឃនៈ សណ្ឋាននៃ
ឃនៈកើតឡើង ព្រោះហេតុនៃកម្មដូចពងមាន់
កើតជាដុំមូលដោយជុំវិញ ។

បទថា **ឃនា ច សាខា ជាយន្តិ** សេចក្តីថា ក្នុងសប្តាហ៍ទី ៥ ក៏កើតជាបញ្ចសាខា គឺ ដៃ ២ ជើង ២ និងក្បាល ១ ។ មានពាក្យដែលព្រះសម្ពុទ្ធត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ក្នុងសប្តាហ៍ ទី ៥ ពកតាំងឡើង ៥ កន្លែងតាមកម្ម ដូច្នេះ ។ តពីនេះទៅ ទ្រង់សង្ខេបទេសនាកន្លងសប្តាហ៍ទី ៦ ទី ៧ ជាដើម កាលទឹងទ្រង់សម្តែងយកវេលាដែលកន្លងទៅ ៤២ សប្តាហ៍ ទើបត្រាស់ថា សក់ជាដើម ។

ក្នុងបទទាំងនោះ បទថា **កេសា លោមា នខាបិ ច** សេចក្តីថា សក់ជាដើមទាំងនេះ រមែងកើតក្នុងសប្តាហ៍ទី ៤២ ។ បទថា **តេន សោ តត្ថ យាបេតិ** សេចក្តីថា ពិតណាស់ ទងផ្ចិតតាំងឡើងអំពីផ្ចិតរបស់ក្មេងនោះ ជាប់គ្នានឹងផ្ទៃ

របស់មាតា ។ ទងផ្ចិតនោះ មានសណ្ឋានដូចទងឈូក ។ រសអាហារជ្រួត ជ្រាបតាមទងផ្ចិតនោះ រូប ដែលមានអាហារជាសមុដ្ឋានក៏តាំងឡើង ។ ទារក នោះ រមែងជានៅ ១០ ខែ ដោយប្រការដូច្នេះ ។ បទថា **មាតុ កុច្ឆិគតោ នរោ** សេចក្តីថា សត្វនៅក្នុងផ្ទៃមាតា គឺ នៅខាងក្នុងផ្ទៃ ។

ព្រះមានព្រះភាគទ្រង់សម្តែងថា ម្នាលយក្ខ សត្វនេះចម្រើនឡើងក្នុង ផ្ទៃរបស់មាតាដោយលំដាប់ មិនមែនកើតដោយការនៅរួមក្នុងគ្រាតែមួយទេ ។

ចប់អដ្ឋកថា ឥន្ទកសូត្រទី ១

# អ ដ្ឋ ក ថា

## សក្កសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសក្កសូត្រទី ២ តទៅនេះ ៖

**[២៨៤]** បទថា *សក្កនាមកោ* គឺ យក្ខមានឈ្មោះយ៉ាងនេះ ។ បានឮថា យក្ខនេះ ជាបក្ខពួកមារ ។ បទថា *វិប្បមុត្តស្ស* បានដល់ ផុតពីកព ៣ ។ បទថា *យទញ្ញំ* កាត់បទថា *យំ អញ្ញំ* (ដទៃណា) ។ បទថា *វណ្ណេន* គឺ ព្រោះហេតុ ។

**[២៨៥]** បទថា *សំវាសោ* គឺ នៅរួមគ្នា ។ អធិប្បាយថា ជាសហាយធម៌ ជាមិត្តធម៌ ។ បទថា *សប្បញ្ញោ* គឺ អ្នកមានបញ្ញាដោយជុំវិញ ។

ចប់អដ្ឋកថា សក្កសូត្រទី ២

# អ ដ្ឋ ក ថា

## សូចិលោមសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងសូចិលោមសូត្រទី ៣ តទៅនេះ ៖*

**[២៨៦]** *បទថា* **គយាយំ** *គឺ ក្នុងស្រុកគយា ។ អធិប្បាយថា ចូលទៅអាស្រ័យក្នុងស្រុកដែលតាំងនៅមិនឆ្ងាយពីស្រុកគយា ។ បទថា* **ដង្កិតមញ្ចេ** *សេចក្តីថា គ្រែដែលជើងវែង គឺ គ្រែដែលគេចោះត្រង់កណ្តាល ស៊កបញ្ចូលធ្វើដោយមេគ្រែ ។ គ្រែនោះមិនមានពាក្យថា នេះខាងលើ នេះខាងក្រោម ។ គ្រែនោះ នឹងផ្លាស់ទៅជាដូច្នោះ ក៏បានតាមត្រូវការ ។ គេរមែងតាំងគ្រែនោះទុកក្នុងទេវស្ថាន ។ គ្រែដែលគេក្រាលផ្ទាំងថ្មទុកលើផ្ទាំងថ្ម ៤ ផ្ទាំង គេហៅថា គ្រែដង្កិត ។ បទថា* **សូចិលោមស្ស** *គឺ មានរោមដូចបន្ទា ។ បានឮថា យក្ខនោះ បួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា* **កស្សប** *មកពីទីឆ្ងាយ មានញើសក្អែលពេញខ្លួន មិនក្រាលកម្រាលលើគ្រែរបស់សង្ឃដែលគេតាំងទុកល្អហើយ ដេកដោយសេចក្តីមិនអើពើ ។ ភិក្ខុដែលមានសីលបរិសុទ្ធិនោះ បានធ្វើកម្មនោះដូចពណ៌ខ្មៅដែលប្រឡាក់សំពត់ស ។ លោកមិនអាច*

ញុំាងគុណវិសេសឲ្យកើតឡើងក្នុងអត្តភាពនោះបាន ធ្វើកាលៈហើយ មកកើតជាយក្ខត្រង់ទីចោលសម្រាម ជិតទ្វារស្រុកគយា ។ កាលគេកើតមកហើយក៏មានរោមស្រួចរឹងទូទៅពេញខ្លួនដូចរោមគោ ។ តមកថ្ងៃមួយ ព្រះមានព្រះ-ភាគ ទ្រង់ត្រួតមើលលោកក្នុងវេលាជិតភ្លឺ ទ្រង់ឃើញយក្ខនោះមកកាន់គន្លងអាវជ្ជនចិត្តគ្រាដំបូង ទើបទ្រង់ត្រិះរិះថា យក្ខនេះសោយទុក្ខធំរហូតអស់មួយពុទ្ធន្តរ ឥឡូវនេះសិរីសួស្តីនឹងគប្បីមានដល់គេ ព្រោះអាស្រ័យតថាគតឬទេហ្ន៎ ទ្រង់ក៏ឃើញឧបនិស្ស័យនៃមគ្គខាងដើម ។ លំដាប់នោះ ទ្រង់បំណងនឹងធ្វើការសង្គ្រោះយក្ខនោះ ទ្រង់ស្លៀកស្បង់ ២ ជាន់ ដែលជ្រលក់ហើយ ឃ្លុំព្រះសុគតមហាចីវរចេញចាកព្រះគន្ធកុដិ ដូចវិមានទេវតា ស្តេចទៅកាន់ទីចោលសម្រាម ដែលស្អុយដោយសាកសពដំរី គោ សេះ មនុស្ស និងសុនខជាដើមប្រថាប់គង់ក្នុងទីនោះ ដូចប្រថាប់គង់ក្នុងព្រះគន្ធកុដិធំ ។

លោកសំដៅយកសេចក្តីនោះ ទើបពោលថា ក្នុងទីនៅរបស់យក្ខសូចិ-លោមៈ ដូច្នេះ ។ បទថា **ខរោ** សេចក្តីថា មានរោមរឹងដូចខ្នងក្រពើ និងដូចក្បឿងដែលគេប្រក់ប្រក់ដំបូល មិនរាបស្មើ ។ បានឮថា គេជាឧបាសកម្នាក់ប្រកបដោយសីលក្នុងសម័យព្រះកស្សបសម្មាសម្ពុទ្ធ ក្នុងថ្ងៃមួយ គេមិនបាន

ក្រាលសំពត់ដណ្តប់របស់ខ្លួនលើកម្រាលរបស់សង្ឃ ដេកលើទីក្រាលទុកដោយ ក្បៀនកម្រាលដ៏វិចិត្រក្នុងវិហារ ។ អាចារ្យពួកខ្លះពោលថា បែងចែកប្រេង របស់សង្ឃលាបសរីរៈដោយដៃរបស់ខ្លួន ។ គេមិនអាចកើតក្នុងសួគ៌ដោយ កម្មនោះ ទើបមកកើតជាយក្ខត្រង់គំនរសម្រាម ជិតទ្វារស្រុកនៃស្រុកគយា នោះ ។ ឯសរីរៈទាំងអស់របស់គេដែលកើតហើយ ទើបមានប្រការដូចពោល ហើយ ។ គេទាំង ២ ជាសម្លាញ់នឹងគ្នា ។ សភាពរឹងនៃសរីរៈរបស់យក្ខនោះ គប្បីជ្រាបដោយប្រការដូច្នេះឯង ។

បទថា **អវិទូរេ អតិក្កមន្តិ** សេចក្តីថា យក្ខទាំង ២ នោះ ស្វែងរក អាហារ ឬទៅកាន់ទីសមាគម តែងទៅក្នុងទីជិតគ្នា ។ ក្នុងយក្ខទាំង ២ នោះ យក្ខសូចិលោមៈ មិនឃើញព្រះសាស្តា ។ ខរយក្ខ ឃើញព្រះសាស្តាមុន ទើប និយាយនឹងសូចិលោមយក្ខថា នុ៎ះជាសមណៈ ។ យក្ខសូចិលោមៈទើបពោល ថា ម្នាលសម្លាញ់ សមណៈនេះចូលមកកាន់ទីនៅរបស់យើង លោកអង្គុយ តែម្នាក់ឯង ។ សូចិលោមយក្ខពោលទៀតថា នុ៎ះមិនមែនសមណៈធំ នុ៎ះជា សមណៈតូច ។ បានឮថា គេសម្គាល់ថា អ្នកណាឃើញយើងហើយ នឹងខ្លាច គេចចេញទៅ គេហៅអ្នកនោះថា សមណៈតូច ។ អ្នកណាមិនខ្លាច គេហៅ

អ្នកនោះថា សមណៈធំ ។ ព្រោះដូច្នោះ សូចិលោមយក្ខសម្គាល់ថា សមណៈនេះ ឃើញយើងហើយក៏ខ្លាចគេចចេញទៅ ដូច្នេះ ទើបពោលយ៉ាងនេះ ។

**[២៨៧]** បទថា **កាយំ ឧបនាមេសិ** សេចក្ដីថា និម្មិតរូបដែលគួរខ្លាចហាមាត់ធំ ញ៉ាំងរោមឲ្យបះទូទៅទាំងខ្លួន បង្អោនចូលទៅរក ។ បទថា **អប-នាមេសិ** សេចក្ដីថា ព្រះមានព្រះភាគងាកទៅបន្តិច ដូចមាសដែលមានតម្លៃប្រកបដោយរតនៈច្រើនរយ ។ បទថា **បាបកោ** គឺ អាក្រក់ មិនគួររីករាយ ។ គេគួរវៀរដូចជាលាមក ដូចជាភ្លើង និងដូចជាពស់វែក គឺ មិនគួរប៉ះពាល់ដោយសរីរៈដែលមានពណ៌សម្បុរដូចមាសនេះ ។ ក៏កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះ សូចិលោមយក្ខក្រោធចំពោះពាក្យថា បានឮថា សម្ផស្សរបស់យើងអាក្រក់ ដូច្នេះ ទើបពោលពាក្យថា **បញ្ហំ តំ** សមណៈជាដើម ។ បទថា **ចិត្តំ វា តេ ខិបិស្សាមិ** សេចក្ដីថា ពិតហើយ អមនុស្សត្រូវការនឹងបន្សាត់ចិត្តរបស់មនុស្សពួកណា វាក៏និម្មិតអត្តភាពដែលគួរខ្លាចឲ្យមានមុខស ពោះខៀវ ដៃ និងជើងក្រហម ក្បាលធំ ភ្នែកក្រហមដូចភ្លើង សម្ដែងដល់មនុស្សទាំងនោះ បញ្ចេញសំឡេងដែលគួរខ្លាច លូកដៃចូលទៅក្នុងមាត់របស់ពួកមនុស្សដែលកំពុងនិយាយ ហើយច្របាច់បេះដូង សត្វទាំងនោះរមែងឆ្កួត មានចិត្ត

រវើរវាយ ។ សូចិលោមយក្ខ សំដៅសេចក្ដីនោះ ទើបពោលយ៉ាងនេះ ។ **បារគង្គាយ** សេចក្ដីថា គេពោលថា យើងនឹងចាប់ជើងទាំង ២ របស់លោក គ្រវែងទៅត្រើយទន្លេគង្គា ដោយមិនឲ្យត្រឡប់មកវិញបាន ។ បទថា **សទេវកេ** ជាដើម មានសេចក្ដីតាមដែលពោលហើយ ។

បទថា **បច្ឆ យទាកង្ខសិ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់បវារណាថា អ្នកត្រូវការវត្ថុណាមួយ ក៏សួរបានទាំងអស់ តថាគតនឹងចម្លើយបង្ហាញដល់អ្នកមិនឲ្យសល់ ។

**[២៨៨]** បទថា **កុតោ និទានា** សេចក្ដីថា មានអ្វីជាមូល មានអ្វីជាបច្ច័យ ។ បទថា **កុមារកា ធង្កមិវោស្សជ្ជន្តិ** សេចក្ដីថា សួរថា ពួកក្មេងចាប់ក្អែកមកហើយ បោះចោលទៅ យ៉ាងណា បាបវិតក្កៈដែលតាំងឡើងពីទីណា ក៏លែងចោលនូវចិត្តទៅ ដូច្នោះ ។

**[២៨៩]** បទថា **ឥតោនិទានា** សេចក្ដីថា អត្តភាពនេះ ជាហេតុខាងដើមរបស់វិតក្កៈទាំងនោះ ហេតុនោះ វិតក្កៈនោះទើបឈ្មោះថា **ឥតោនិទានា** (មានអត្តភាពជាហេតុខាងដើម) ។ បទថា **ឥតោជា** ប្រែថា កើតអំពីអត្តភាពនោះ ។ បទថា **ឥតោ សមុដ្ឋាយ មនោវិតក្កា** សេចក្ដីថា ពួកក្មេងចងខ្សែត្រង់កជើង

របស់វា ហើយបោះក្អែកដែលចងទុកដោយខ្សែវែង សូម្បីវាទៅបានឆ្ងាយ ក៏ធ្លាក់ចុះមកទៀបជើងរបស់ក្មេងទាំងនោះទៀត យ៉ាងណា ។ បាបវិតក្កៈដែលតាំងឡើងអំពីអត្តភាពនេះ ក៏បោះបោលនូវចិត្ត ដូច្នោះ ។ បទថា **ស្នេហជា** បានដល់ ស្នេហាកើតពីតណ្ហា ។ បទថា **អត្តសម្ភូតា** ប្រែថា កើតក្នុងខ្លួន ។ បទថា **និគ្រោធស្សេវ ខន្ធជា** គឺ ដូចឫសដែលកើតអំពីដើមជ្រៃ ។ បទថា **បុថូ** គឺ បាបវិតក្កៈ និងកិលេសដែលប្រកបដោយបាបវិតក្កៈនោះដ៏ច្រើន គឺច្រើនប្រការ ។ បទថា **វិសត្តា** បានដល់ ជាប់ជំពាក់ ។ បទថា **កាមេសុ** បានដល់ វត្ថុកាម ។ បទថា **មាលុវា វិតតា វនេ** សេចក្តីថា វល្លិ៍ជ្រៃក្នុងព្រៃអាស្រ័យដើមឈើណាកើតឡើង វាព័ទ្ធពាន់ដើមឈើនោះជុំវិញទៅមក តាំងពីគល់ដល់ចុង តាំងពីចុងដល់គល់ គ្របដណ្តប់រយើងរយោង យ៉ាងណា កិលេស-កាមជាច្រើនជំពាក់នៅក្នុងវត្ថុកាម ឬសត្វជាច្រើនជាប់ជំពាក់នៅក្នុងវត្ថុកាមដោយកិលេសកាមនោះ ដូច្នោះ ។ បទថា **យេ នំ បជានន្តិ** សេចក្តីថា ក៏បុគ្គលណា រមែងដឹងអត្តភាពតាមដែលពោលទុក ក្នុងបទថា **អត្តសម្ភូតា** (កើតក្នុងខ្លួន) ។ នេះ បទថា **យតោនិទានំ** សេចក្តីថា រមែងដឹងវត្ថុដែលជាហេតុខាងដើមរបស់អត្តភាពនោះ ។ បទថា **តេ នំ វិនោទេន្តិ** សេចក្តីថា

បុគ្គលនោះ រមែងបន្ទោបង់ គឺ នាំចេញនូវសមុទយសច្ច ដែលជាហេតុខាងដើមរបស់ទុក្ខសច្ច ពោលគឺ អត្តភាព ដោយមគ្គសច្ច ដោយប្រការដូច្នេះ ។ បទថា **តេ ទុត្តរំ** សេចក្តីថា អ្នកនោះកាលនាំសមុទយសច្ចចេញបាន ទើបឆ្លងឱឃៈ គឺ កិលេសដែលឆ្លងបានដោយលំបាកនេះបាន ។ បទថា **អតិណ្ណ-បុព្វំ** សេចក្តីថា មិនធ្លាប់ឆ្លងសង្សារវដ្ត ដែលមានខាងចុងដែលបុគ្គលណាៗ ដឹងមិនបាន សូម្បីក្នុងខាងក្នុងនៃសេចក្តីយល់សប្តិ ។

បទថា **អបុនព្ភវាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់និរោធសច្ច គឺការមិនកើតទៀត ។

ព្រោះហេតុនេះ ដើម្បីនឹងទ្រង់ប្រកាសអរិយសច្ច ៤ ដោយគាថានេះ ទើបទ្រង់ញុំាងព្រះធម៌ទេសនាឲ្យចប់ស្រេចដោយធម៌ មានព្រះអរហត្តជាទីបំផុត ។ ក្នុងទីបំផុតនៃទេសនា សូចិលោមយក្ខឈរក្នុងទីនោះឯង បញ្ជូនញាណទៅតាមក្រសែព្រះធម៌ទេសនា បានតាំងនៅក្នុងសោតាបត្តិផល ។ ក៏ឈ្មោះថា ព្រះសោតាបន្នទាំងឡាយ រមែងមិនតាំងនៅក្នុងអត្តភាពដែលសៅហ្មង ព្រោះដូច្នោះ ក្បាល ត្រចៀក និងរោមស្រួចដូចម្ជុលទាំងពួងត្រង់រាងកាយរបស់សូចិលោម-យក្ខ ជ្រុះទៅព្រមគ្នាក្នុងខណៈដែលបានសោតាបត្តិផល ។ សូចិលោមយក្ខ

នោះទើបស្លៀកសំពត់ទិព្វ ដណ្តប់សំពត់ទិព្វ ជូតក្បាលសំពត់ទិព្វ ទ្រទ្រង់គ្រឿងប្រដាប់របស់ក្រអូប និងកម្រងផ្កាទិព្វ មានពណ៌សម្បុរដូចមាស បានគ្រប់គ្រងភូម្មទេវតា ។

ចប់អដ្ឋកថា សូចិលោមសូត្រទី៣

# អ ដ្ឋ ក ថា

## មណិភទ្ទសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងមណិភទ្ទសូត្រទី ៤ ដូចតទៅនេះ ៖*

**[២៩១]** *បទថា* ***សុខមេធតិ*** *បានដល់ រមែងបានសេចក្ដីសុខ ។ បទថា* ***សុវេ សេយ្យោ*** *សេចក្ដីថា ប្រសើរជានិច្ច ។ បទថា* ***វេរា ន បរិមុច្ចតិ*** *សេចក្ដីថា រមែងមិនរួចផុតអំពីពៀរដោយហេតុប៉ុណ្ណេះថា យើងមានសតិ ។*

**[២៩២]** *បទថា* ***យស្ស*** *បានដល់ របស់ព្រះអរហន្តណា ។ បទថា* ***អហឹសាយ*** *បានដល់ ក្នុងករុណា និងក្នុងចំណែកខាងដើមនៃករុណា ។ បទថា* ***មេត្តំ សោ*** *សេចក្ដីថា ព្រះអរហន្តនោះ ចម្រើនមេត្តា និងចំណែកខាងដើមនៃមេត្តា ។ម្យ៉ាងទៀត ចំណែក ហៅថា* ***អំសោ*** *។ ឈ្មោះថា ចំណែកនៃមេត្តា ព្រោះអត្ថថា គេមានចំណែកមេត្តា ។ មានអធិប្បាយដូច្នេះថា ចិត្តរបស់ព្រះ-អរហន្តណាត្រេកអរហើយ ក្នុងសេចក្ដីមិនបៀតបៀនរហូតដល់អស់កាលទាំងពួង ។ មួយទៀត ចំណែកនៃមេត្តារបស់ព្រះអរហន្តណា មាននៅក្នុងសព្វសត្វ ម្នាលយក្ខ ឈ្មោះថា ពៀរវេរារបស់ព្រះអរហន្តនោះ ទើបមិនមានជាមួយនឹង*

បុគ្គលណាៗ ឡើយ។

ចប់អដ្ឋកថា មណិភទ្ទសូត្រទី ៤

# អ ដ្ឋ ក ថា

## សានុសូត្រទី ៥

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសានុសូត្រទី ៥ តទៅនេះ ៖

[២៩៣] បទថា យក្ខេន គហិតោ ហោតិ សេចក្តីថា បានពួមកថា សាមណេរនោះ ជាបុត្រម្នាក់របស់ឧបាសិកានោះ ។ គ្រានោះ នាងឲ្យបុត្រនោះបព្វជ្ជាក្នុងវ័យជំទង់ ។ សានុសាមណេរនោះ តាំងពីវេលាបួសហើយ មានសីលដល់ព្រមដោយវត្ត ។ សាមណេរបានធ្វើវត្តដល់អាចារ្យ ឧបជ្ឈាយ៍ និងព្រះអាគន្តុកៈជាដើម ក្នុងថ្ងៃទី ៨ នៃខែ ក្រោកពីព្រឹកចូលទៅតាំងទឹកទុកក្នុង បន្ទប់ទឹក បោសសម្អាតរោងស្តាប់ធម៌ ដុតប្រទីប ប្រកាសការស្តាប់ធម៌ដោយសំឡេងពីរោះ ។ ពួកភិក្ខុជ្រាបកម្លាំងរបស់សាមណេរនោះ ទើបអារាធនាថា នែ៎សាមណេរ លោកចូរពោលបទសរភញ្ញៈចុះ ។ សាមណេរនោះ មិននាំអ្វីមកអាងថា ខ្យល់ចាក់សៀតបេះដូងរបស់ខ្ញុំ ឬរោគក្អកបៀតបៀនខ្ញុំ លោកក៏ឡើងកាន់ធម្មាសនៈ ពោលបទសរភញ្ញៈ ដូចញាំងទឹងក្នុងអាកាសឲ្យធ្លាក់ចុះ ដូច្នោះ លោកចុះមកពោលថា សូមចំណែកបុណ្យក្នុង

សរភញ្ញៈនេះ ចូរមានដល់មាតាបិតារបស់ខ្ញុំចុះ ។ ឯចំណែកមាតាបិតារបស់សាមណេរក្នុងអត្តភាពនេះ មិនដឹងនូវចំណែកបុណ្យ ដែលសាមណេរនោះឲ្យហើយ ។ ក៏មាតារបស់សាមណេរក្នុងអត្តភាពមុននោះ កើតជានាងយក្ខិណី នាងមកជាមួយពួកទេវតា ស្តាប់ធម៌ហើយ ទើបពោលថា បពិត្រលោកកូនញោមសូមអនុមោទនាចំណែកបុណ្យ ដែលលោកកូនឲ្យហើយ ។ ក៏ធម្មតាពួកភិក្ខុដែលដល់ព្រមដោយសីល រមែងជាទីស្រឡាញ់របស់មនុស្ស និងទេវតាដោយប្រការដូច្នេះ ។ ពួកទេវតាមានសេចក្តីកោតក្រែង មានសេចក្តីគោរពក្នុងសាមណេរនោះ រមែងសម្គាល់សាមណេរនោះ ដូចជាមហាព្រហ្ម និងដូចគំនរភ្លើង ទេវតាទាំងឡាយ ក៏ធ្វើនូវសេចក្តីគោរពក្នុងយក្ខិណីនោះ ព្រោះតែការគោរពក្នុងសាមណេរ បានឲ្យអាសនៈ ទឹក និងភោជនដ៏ប្រណីតដល់នាងយក្ខិណី ដោយសម្គាល់ថា ជាមាតារបស់សាធុ ដូច្នេះ ក្នុងទីស្តាប់ធម៌ និងទីសមាគមរបស់យក្ខជាដើម កាលពួកយក្ខអ្នកមានសក្តិធំ ជួបនាងយក្ខិណីនោះ ក៏ឲ្យផ្លូវ និងឲ្យអាសនៈ ។

គ្រានោះ សាមណេរនោះ ដល់នូវភាពចម្រើននៃវ័យ មានរាងកាយបរិបូណ៌ ត្រូវសេចក្តីមិនត្រេកអរបៀតបៀន កាលមិនអាចនឹងបន្ទោបង់សេចក្តី

មិនត្រេកអរបាន ទើបបណ្ដោយឲ្យសក់ និងក្រចកវែង ទាំងស្បង់ និងចីវរ ស្មោកគ្រោកហួសប្រមាណ មិនប្រាប់ដល់អ្នកណា កាន់បាត្រ និងចីវរទៅកាន់ផ្ទះរបស់មាតាតែម្នាក់ឯងប៉ុណ្ណោះ ។ ឧបាសិកាឃើញសាមណេរ ថ្វាយបង្គំហើយបានពោលថា លោកកូន កាលមុន លោកកូនមកក្នុងទីនេះ មានទាំងអាចារ្យ និងឧបជ្ឈាយ៍ ឬភិក្ខុកម្លោះ និងសាមណេរ ព្រោះហេតុអ្វី ក្នុងថ្ងៃនេះ លោកកូនមកតែមួយអង្គឯង ។ សាមណេរនោះ ប្រាប់សេចក្ដីអផ្សុកដល់មាតា ។ ឧបាសិកាជាអ្នកមានសទ្ធា សម្ដែងទោសក្នុងការនៅគ្រប់គ្រងផ្ទះដោយប្រការផ្សេងៗ ពោលទូន្មានសាមណេរ កាលមិនអាចនឹងឲ្យសាមណេរនោះព្រមតាមបាន ក៏គិតថា ធ្វើដូចម្ដេចហ្ន៎ នឹងឲ្យសាមណេរពិចារណាតាមធម្មតារបស់ខ្លួនបាន ទើបពោលថា លោកកូន ចូរលោកកូនរង់ចាំសិន ញោមនឹងចាត់ចែងបបរ និងកត្តប្រគេន ហើយនឹងថ្វាយសំពត់ជាទីពេញចិត្តដល់លោកកូន លោកកូនឆាន់រួចហើយសឹមទៅ ដូច្នេះ ទើបចាត់ចែងអាសនៈថ្វាយ ។

សាមណេរអង្គុយហើយ ។ ឧបាសិកាឲ្យគេចាត់ចែងបាយយាគូ និងរបស់ទំពារថ្វាយ ដោយត្រឹមតែមួយភ្លែតប៉ុណ្ណោះ ។ ឧបាសិកាប្រគេនកត្តហើយ គមកនាងបោសសម្អាត រួចអង្គុយក្នុងទីជិតសាមណេរនោះឯង ។ សម័យ

នោះ នាងយក្ខិណី រំពឹងគិតថា សាមណេរបានអាហារក្នុងទីណាហ្ន៎ ឬមិនបាន ដឹងថា សាមណេរនោះអត់ឃ្លានហើយព្រោះចង់សឹក គិតថា លោកកុំគប្បីឲ្យសេចក្តីខ្មាសកើតឡើងដល់យើងក្នុងទេវតា យើងនឹងទៅធ្វើអន្តរាយ ក្នុងការសឹករបស់សាមណេរនោះ មកហើយ ចូលសន្និតក្នុងកាយ ទាញកឲ្យវៀចហើយដួលចុះលើផែនដី ។ សាមណេរនោះ មានភ្នែកត្រឡប់ មានទឹកមាត់ហូរ បម្រះនៅលើផែនដី ។ ព្រោះហេតុនោះ លោកទើបពោលថា បុត្រឈ្មោះថា សានុរបស់ឧបាសិកា ត្រូវយក្ខចូលសន្និតហើយ ។

**[២៩៤]** បទថា **អភាសិ** សេចក្តីថា ឧបាសិកាឃើញអាការប្លែកនោះរបស់បុត្រក៏ស្ទុះមកយ៉ាងរហ័ស ក្រសោបបុត្រឲ្យដេកលើខ្លួន ។ អ្នកស្រុកទាំងអស់មកធ្វើពិធី មានពលីកម្មជាដើម ។ ឧបាសិកា កាលទួញយំ បានពោលគាថាទាំងនេះ ។

**[២៩៥]** បទថា **បាដិហារិកបក្ខញ្ច** សេចក្តីថា ពួកមនុស្សគិតថា យើងនឹងធ្វើការទទួល និងការបញ្ជូនឧបោសថតិថីទី ៨ ទើបសមាទានអដ្ឋឧបោសថក្នុងតិថីទី ៧ ខ្លះ តិថីទី ៩ ខ្លះ ។ កាលធ្វើការទទួល និងការបញ្ជូនតិថីទី ១៤ និង ១៥ សមាទានក្នុងតិថីទី ១៣ ខ្លះ ក្នុងថ្ងៃបាដិបទខ្លះ (គឺថ្ងៃ ១ រោច) ។

ពួកមនុស្សគិតថា ពួកយើងនឹងធ្វើការបញ្ជូនការនៅចាំវស្សា ជាអ្នករក្សាឧបោ-សថជានិច្ច កន្លះខែវាងបវារណាទាំងពីរ ។ ឧបាសិកាសំដៅយកប្រការនេះ ទើបពោលថា **បាដិហារិកបក្ខញ្ច** ។ បទថា **អដ្ឋង្គសុសមាគតំ** សេចក្តីថា ប្រកបព្រម គឺ ប្រកបល្អហើយដោយអង្គ ៨ ។ បទថា **ព្រហ្មចរិយំ** ប្រែថា ប្រព្រឹត្តប្រសើរ ។ បទថា **ន តេហិ យក្ខា កីឡន្តិ** សេចក្តីថា ពួកយក្ខ រមែង មិនចូលសន្និតក្នុងជនទាំងនោះឡើយ ។ នាងយក្ខិណីសន្និតក្នុងត្រចៀករបស់ សាមណេរហើយ ទើបពោលគាថាទាំងនេះថា **ចាតុទ្ទសឹ** ដូច្នេះទៀត ។

**[២៩៦]** បទថា **អាវិ វា យទិ វា រហោ** សេចក្តីថា ក្នុងទីចំពោះមុខ ឬក្នុងទីកំបាំងមុខអ្នកណាៗ ។ បទថា **បមុត្យត្ថិ** កាត់បទជា **បមុត្តិ អត្ថិ** ប្រែថា សេចក្តីរួចផុតមាន ។

បទថា **ឧប្បច្ចាបិ** ប្រែថា សូម្បីហោះទៅ ។ នាងយក្ខិណីពោលថា បើលោកនឹងហោះគេចចេញទៅដូចសត្វ សូម្បីយ៉ាងនោះ លោកក៏រួចផុតទៅ មិនបាន ។ កាលពោលយ៉ាងនេះហើយ ទើបចេញពីសាមណេរ ។ សាមណេរ បើកភ្នែក (ឃើញ) មាតា រំសាយសក់ ស្រែកយំខ្សឹកខ្សួល ។ សាមណេរនោះ មិនដឹងថាខ្លួនត្រូវអមនុស្សចូលសន្និតឡើយ ។ សាមណេរ ក៏ក្រឡេកមើល

ហើយគិតថា អម្បាញ់មិញនេះ យើងអង្គុយលើតាំង មាតារបស់យើងបោស សម្អាតហើយ ក៏អង្គុយក្នុងទីជិតយើង តែឥឡូវនេះ យើងអង្គុយលើផែនដី ចំណែកមាតារបស់យើង ស្រែកយំខ្សឹកខ្សួល សូម្បីអ្នកស្រុកទាំងអស់ក៏មក ប្រជុំគ្នា អង្គុយធ្វើអ្វីក្នុងទីនេះ ដូច្នេះ ទាំងដែលកំពុងដេកទុំះឯង ពោលគាថា ថា **មតំ វា អម្ម** ជាដើម ។

**[២៩៧]** បទថា **កាមេ ចជិត្វាន** សេចក្តីថា លះកាមសូម្បីពីរយ៉ាង ។ បទថា **បុនរាគច្ឆតេ** បានដល់ មកដោយអំណាចការចង់សឹក ។ បទថា **បុន ជីវំ មតោ ហិ សោ** សេចក្តីថា អ្នកណាសឹកហើយ សូម្បីនឹងរស់នៅតទៅ ទៀត ក៏ដូចជាស្លាប់ហើយ ព្រោះដូច្នោះញាតិ និងមិត្តទាំងឡាយ រមែងស្រែក យំដល់បុគ្គលនោះ ។ ឥឡូវនេះ នាងកាលសម្តែងទោសក្នុងការនៅគ្រប់គ្រង ផ្ទះដល់សាមណេរនោះ ទើបពោលពាក្យជាដើមថា **កុក្កុឡា** ដូច្នេះ ។ បណ្តា បទទាំងនោះ បទថា **កុក្កុឡា** សេចក្តីថា បានឮថា ការនៅគ្រប់គ្រងផ្ទះ ឈ្មោះ ថា ផេះក្តៅ ព្រោះអត្ថថា ក្តៅគគុក ។ បទថា **កស្ស ឧជ្ឈាបយាមសេ** សេចក្តី ថា មាតាពោលយ៉ាងនេះថា សូមលោកកូនចូរត្រឡប់វិញ សូមសេចក្តីចម្រើន ចូរមានដល់លោកកូន ដូច្នេះ ហើយពោលទៀតថា លោកកូនចង់សឹកត្រូវយក្ខ

ចូលសន្និត យើងនឹងលើកទោស ប្រាប់អាការដែលប្លែកនេះដល់អ្នកណាកើត ។ បទថា **ចុន ឧយ្យិតុមិច្ឆតិ** សេចក្ដីថា លោកកូនចេញចាកផ្ទះហើយបួសក្នុងព្រះពុទ្ធសាសនា ដូចវត្ថុដែលគេជញ្ជូនចេញអំពីផ្ទះដែលត្រូវភ្លើងឆេះ តែលោកកូនចង់ឆេះក្នុងឃរាវាស ដូចដែលធ្លាប់ឆេះទៀតឬ ។ កាលមាតាពោលហើយ សាមណេរនោះពិចារណា ត្រឡប់បានហិរិ និងឱត្តប្បៈ ទើបពោលថា យើងមិនត្រូវការជាគ្រហស្ថ ។ គ្រានោះ មាតារបស់សាមណេរត្រេកអរបានពោលថា ល្អល្អលោកកូន ដូច្នេះ ថ្វាយភោជនដ៏ប្រណីតឲ្យឆាន់ហើយ ទើបសួរថា លោកកូន មានអាយុប៉ុន្មានឆ្នាំហើយ ។ សាមណេរឆ្លើយថា អាយុគ្រប់ ២០ ឆ្នាំហើយញោម ។ ឧបាសិកាពោលថា បើដូច្នោះ សូមលោកកូនចូរបំពេញឧបសម្បទចុះ ក៏បានថ្វាយសំពត់ចីវរ ។ សាមរណេរនោះ ឲ្យគេធ្វើចីវរហើយ ឧបសម្បទា រៀនព្រះពុទ្ធវចនៈទ្រទ្រង់ព្រះត្រៃបិដក ញុំាងព្រះពុទ្ធវចនៈនោះឲ្យបរិបូណ៌ក្នុងអនាគតស្ថាននៃសីលជាដើម មិនយូរប៉ុន្មានក៏បានសម្រេចជាអរហន្ត ជាព្រះធម្មកថិកធំ តាំងនៅបាន ១២០ វស្សា ញុំាងជម្ពូទ្វីបទាំងអស់ឲ្យញាប់ញ័រ ហើយក៏បរិនិព្វាន ។

ចប់អដ្ឋកថា សានុសូត្រទី ៥

# អ ដ្ឋ ក ថា

## បិយង្ករសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងបិយង្ករសូត្រទី ៦ តទៅនេះ ៖*

**[២៩៨]** *បទថា* ***ជេតវនេ*** *សេចក្តីថា ព្រះអនុរុទ្ធគង់នៅក្នុងកុដិឈ្មោះកោសម្ពកុដិចុងវត្តព្រះជេតវ័ន ។ ធម៌ ២៦ វគ្គ លោកលើកឡើងរួបរួមទុកមួយផ្នែក បំណងយកក្នុងបទនេះថា* ***ធម្មបទានិ*** *។ សម័យនោះ ព្រះថេរៈគង់ខាងក្នុងកុដិនោះ សូត្រអប្បមាទវគ្គជាសរភញ្ញៈ ដោយសំឡេងពីរោះ ។*

**[២៩៩]** *បទថា* ***ឯវំ តោសេសិ*** *សេចក្តីថា បានឮថា នាងយក្ខិណីនោះ ពបុត្រឈ្មោះបិយង្ករៈ ស្វែងរកអាហារ តាំងពីខាងក្រោយវត្តជេតពនតម្រង់ទៅកាន់ព្រះនគរដោយលំដាប់ ស្វែងរករបស់ស៊ីដែលសៅហ្មង គឺ ឧច្ចារៈ បស្សាវៈ ទឹកមាត់ ទឹកសម្បោរ ដល់ទីនៅរបស់ព្រះថេរៈ បានស្តាប់សំឡេងដ៏ពីរោះ ។ សំឡេងនោះ ជ្រួតជ្រាបតាមស្បែកជាដើមប្រព្រឹត្តទៅដល់ខួរក្នុងឆ្អឹង ចូលទៅដល់បេះដូងរបស់នាង ។ គ្រានោះ នាងយក្ខិណី មិនគិតក្នុងការស្វែងរកអាហារ ។ នាងឈរផ្ទៀងត្រចៀកស្តាប់ធម៌ ។ ចំណែកយក្ខជាកូនមិន*

មានចិត្តក្នុងការស្តាប់ធម៌ ព្រោះនៅក្មេង ។ គេត្រូវសេចក្តីហេវហៀតបៀន ទើបដាស់តឿនមាតាហើយ ដាស់តឿនទៀតថា ព្រោះហេតុអ្វីម៉ែទើបឈរមិនកម្រើកដូចដង្កត់ ក្នុងដែលម៉ែមកហើយ បែរជាមិនស្វែងរករបស់ទំពារ ឬរបស់បរិភោគសម្រាប់កូន ។ នាងគិតថា បុត្រនឹងធ្វើអន្តរាយដល់ការស្តាប់ធម៌របស់ខ្លួន ទើបលួងលោមបុត្រតូចយ៉ាងនេះថា នែ៎បិយង្ករៈ អ្នកកុំបញ្ចេញសំឡេងខ្លាំងឡើយ ។ ក្នុងបទនោះ បទថា **មា សទ្ទមករិ** បានដល់ កុំបានបញ្ចេញសំឡេងខ្លាំង ។

**[៣០០]** នាងយក្ខិណីសម្តែងសីល ៥ ដែលសមាទានហើយតាមធម្មតារបស់ខ្លួន ដោយគាថាថា **បាណេសុ ច** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **សញ្ញមាមសេ** បានដល់ យើងសង្រួម គឺ ជាអ្នកសង្រួមហើយ ។ នាងវៀរចាកបាណាតិបាតដោយបទនេះ ។ វៀរចាកមុសាវាទដោយបទទីពីរ ។ ការវៀរចាកសិក្ខាបទបីដ៏សេស ដោយបទទីបី ។ បទថា **អបិ មុច្ចេម បិសាចយោនិយា** (យើងនឹងរួចផុតចាកកំណើតបិសាច) នាងយក្ខិណីពោលថា នែ៎កូន យើងលះបង់ពៀរទាំង ៥ នេះ ដែលកើតឡើងក្នុងយក្ខលោកចេញហើយ បដិបត្តិដោយឧបាយដ៏ប្រពៃហើយ ទើបនឹងផុតពីកំណើតយក្ខបិសាច ដែល

*មានកិច្ចាហារលំបាក ទាំងមានសេចក្ដីអត់ឃ្លាន ។*

ចប់អដ្ឋកថា បិយង្គរសូត្រទី ៦

# អ ដ្ឋ ក ថា

## បុនព្វសុសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបុនព្វសុសូត្រទី ៧ ដូចតទៅនេះ ៕

**[៣០១]** បទថា *តេន ខោ បន សមយេន* បានដល់ សម័យណា ៗ គឺ សម័យព្រះអាទិត្យលិច ៗ បានឮថា ក្នុងកាលនោះ ព្រះមានព្រះភាគទ្រង់សម្តែងធម៌ខាងក្រោយសោយព្រះក្រយាហារដល់មហាជន ទ្រង់បញ្ជូនមហាជនហើយ ទ្រង់ស្រង់ទឹកក្នុងបន្ទប់ទឹកហើយ ប្រថាប់គង់ត្រួតមើលលោកធាតុផ្នែកទិសខាងកើត លើពុទ្ធាសនៈដ៏ប្រសើរដែលគេចាត់ចែងទុកក្នុងព្រះគន្ធកុដិ ៗ គ្រានោះ ពួកភិក្ខុដែលសមាទានសំពត់បង្សុកូល និងបិណ្ឌបាតជាវត្ត ចារិកទៅមួយរូប ឬពីររូបជាដើម ចេញចាកទីសម្រាកពេលថ្ងៃពីទីនៅរៀងៗ ខ្លួនហើយមកថ្វាយបង្គំព្រះទសពល អង្គុយដូចជាព័ទ្ធដោយរាំងននពណ៌ក្រហម ៗ គ្រានោះ ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យរបស់ភិក្ខុទាំងនោះ ទើបត្រាស់ធម្មីកថាប្រកបដោយនិព្វាន ៕

**[៣០២]** បទថា *ឯវំ តោសេសិ* សេចក្តីថា បានឮថា នាងយក្ខិណី

ដែលជាមាតារបស់បុនព្វសុនោះ ពកូនស្រី ដឹកដៃកូនប្រុស កំពុងស្វែងរក ឧច្ចារៈ បស្សាវៈ ទឹកមាត់ និងទឹកសម្បោរជាដើមត្រង់កំផែង និងត្រង់ប្រឡាយ ខាងក្រោយវត្តជេតពន ទៅដល់ខ្លោងទ្វារវត្តជេតពនដោយលំដាប់ ។ ក៏ព្រះសូរសេងរបស់ព្រះមានព្រះភាគ ត្រាស់ថា ម្នាលអានន្ទ អ្នកចូរនាំបាត្រមកចុះ នាំចីវរមកចុះ ចូរឲ្យទានដល់អ្នកស៊ីរបស់សល់ចុះ ដូច្នេះ ព្រះសូរសេងរបស់ព្រះអង្គ ផ្សាយទៅដោយជុំវិញប្រមាណ ១២ ហត្ថប៉ុណ្ណោះ ។ តែកាលទ្រង់សម្តែងធម៌ បើបរិស័ទអង្គុយនៅសូម្បីក្នុងទីបំផុតនៃចក្រវាឡ ព្រះសូរសេងរបស់ព្រះអង្គ រមែងឮទៅដល់បរិស័ទ រមែងមិនចេញទៅខាងក្រៅបរិស័ទឡើយ សូម្បីត្រឹមតែមួយអង្គុលី ដោយព្រះតម្រិះថា ព្រះសូរសេងដ៏ពីរោះចូរកុំចេញទៅដោយមិនមានហេតុឡើយ ។ នាងយក្ខិណីនេះ ឈរខាងក្រៅបរិស័ទ ទើបមិនបានឮសំឡេងក្នុងទីនោះ ។ កាលនាងឈរត្រង់ខ្លោងទ្វារ ឈរផ្ចង់មុខទៅកាន់ពុទ្ធវិថីដ៏ធំ ព្រះគន្ធកុដិរមែងប្រាកដ ។ នាងឃើញបរិស័ទស្ងៀមស្ងាត់ វៀរការឃ្លើសឃ្លងដែលជាដើម ដោយសេចក្តីគោរពក្នុងព្រះពុទ្ធ ដូចអណ្តាតប្រទីបក្នុងទីមិនមានភ្លៀងខ្យល់ ក៏គិតថា ក្នុងទីនេះនឹងមានវត្ថុខ្លះ ចែកដោយពិតឃើញនឹងបានទឹកដោះថ្លា ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើមណាមួយដោយ

ពិត ដែលហូរចេញអំពីបាត្រខ្លះ អំពីដៃខ្លះ ឬដែលធ្លាក់ហើយលើផែនដី ដូច្នេះ ទើបចូលទៅខាងក្នុងវត្ត ។ អារក្ខទេវតាស្ថិតនៅត្រង់ខ្លោងទ្វារដើម្បីហាមពួកអ្នកដែលត្រូវដេញ ឃើញឧបនិស្ស័យរបស់នាងយក្ខិណីហើយ ទើបមិនហាម ។ ព្រះសូរសេងដ៏ពីរោះ ចូលកាត់ស្បែកជាដើមរហូតដល់ខួរក្នុងឆ្អឹងរបស់នាង ព្រមទាំងការទៅរបស់បរិស័ទនោះឯង ។ បុត្រតូចទាំងឡាយជាស់តៀននាងយក្ខិណីនោះដែលឈរមិនស្ងៀម ដើម្បីស្តាប់ធម៌ ដោយន័យមុនទុំះឯង ។ នាងយក្ខិណីនោះគិតថា បុត្រតូចទាំងឡាយ នឹងធ្វើអន្តរាយដល់ការស្តាប់ធម៌របស់យើង ដូច្នេះ ទើបលួងលោមបុត្រតូចទាំងឡាយយ៉ាងនេះថា ម្នាលនាងឧត្តរា ចូរនាងស្ងៀមទៅ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យាវ** សេចក្តីថា ចូរកូននៅស្ងៀមរហូតដល់ពេលដែលម៉ែស្តាប់ធម៌ (ចប់) ចុះ ។ បទថា **សព្វគន្ថប្បមោចនំ** សេចក្តីថា កិលេសជាគ្រឿងរួបរឹតទាំងពួង រមែងរួចផុតទៅ ព្រោះដល់និព្វាន ព្រោះដូច្នោះ និព្វាននោះ លោកពោលថា ជាទីរួចផុតចាកកិលេសជាគ្រឿងរួបរឹតទាំងពួង ។ បទថា **អតិវេលា** សេចក្តីថា កន្លងវេលា គឺ ហួសប្រមាណ ។ បទថា **បិយាយនា** បានដល់ ការស្វែងរក គឺ ប្រាថ្នា ។ បទថា **តតោ បិយតរំ** សេចក្តី

ថា ការស្វែងរក ការប្រាថ្នាក្នុងធម៌នេះ រមែងជាទីស្រឡាញ់របស់យើងជាង កូន និងប្តីនោះទៅទៀត ។ មួយទៀត ព្រះបាលីថា **បិយតរា** ដូច្នេះក៏មាន ។ បទថា **បាណិនំ** សេចក្តីថា ដូចការស្តាប់ព្រះសទ្ធម្ម រមែងរំដោះពួកសត្វពីទុក្ខបាន ។ តើរមែងរំដោះពួកសត្វអ្វី ។ សេចក្តីនេះ គួរនាំបទថា **បាណិនំ** មកពោល ។ បទថា **យំ ធម្មំ អភិសម្ពុទ្ធំ** សេចក្តីថា ព្រះមានព្រះភាគត្រាស់ដឹងធម៌ណា ។ បទថា **តុណ្ហីភូតាយមុត្តរា** សេចក្តីថា **បុនព្វសុ** ពោលថា ខ្ញុំនឹងមិននិយាយឡើយ សូម្បី ឧត្តរាប្អូនស្រីរបស់ខ្ញុំនេះ ក៏នៅស្ងៀម ។ បទថា **សទ្ធម្មស្ស អនញ្ញាយ** សេចក្តីថា បពិត្រអ្នកម៉ែ យើងមិនដឹងព្រះសទ្ធម្មនេះឯងក្នុងកាលមុន ឥឡូវនេះទើបសោយទុក្ខ មានសេចក្តីស្រេកឃ្លាន ក្តៅក្រហាយជាដើម បានត្រាច់ទៅដោយលំបាក គឺ នៅជាទុក្ខ ។

បទថា **ចក្ខុមា** បានដល់ មានចក្ខុ ដោយចក្ខុ ៥ ។ ព្រះមានព្រះភាគកាលទ្រង់សម្តែងធម៌ ទ្រង់កំណត់បរិស័ទ ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់នាងយក្ខិណីនោះ និងយក្ខជាកូន ទ្រង់ផ្លាស់ទេសនា ទើបសម្តែងសច្ចៈ ៤ ។ នាងយក្ខិនីនោះ ឈរស្តាប់ធម៌នៅក្នុងប្រទេសនោះឯង ជាមួយបុត្រ បានតាំងនៅក្នុងសោតាបត្តិផល ។ ចំណែកជីតារបស់នាងយក្ខិណីនោះ

ក៏មានឧបនិស្ស័យដែរ ។ តែមិនអាចនឹងទទួលទេសនាបាន ព្រោះនៅក្មេងពេក ។

ឥឡូវនេះ នាងយក្ខិណីនោះ កាលនឹងធ្វើអនុមោទនាដល់បុត្រ ទើបពោលពាក្យថា ល្អហើយកូន ឈ្មោះថា ជាបណ្ឌិតដូច្នេះ ជាដើម ។

**[៣០៤]** បទថា **អជ្ជាហម្ហិ សមុគ្គតា** សេចក្តីថា ម៉ែបានខ្ពង់ខ្ពស់ហើយ ចាប់តាំងពីថ្ងៃនេះទៅ ។ម្យ៉ាងទៀត ម៉ែជាអ្នកខ្ពង់ខ្ពស់ហើយក្នុងព្រះសាសនា សូមប្បីកូន ចូរជាអ្នកមានសេចក្តីសុខចុះ ។ បទថា **ទិដ្ឋានិ** សេចក្តីថា ម៉ែ និងឯងឃើញអរិយសច្ច ៤ ហើយ ។ បទថា **ឧត្តរាបិ សុណាតុ មេ** នាងយក្ខិណីពោលថា សូមប្បីនាងឧត្តរា ក៏ចូរចាំស្តាប់នូវអរិយសច្ចៈ ៤ ដែលម៉ែបានចាក់ធ្លុះហើយចុះ ។ នាងយក្ខិណីនោះ លះភាវៈដ៏អាក្រក់របស់ខ្លួនទាំងអស់ ដូចសុបិនលោមយក្ខ ព្រមគ្នានឹងការចាក់ធ្លុះសច្ចៈនុ៎ះឯង ទើបត្រឡប់បានទិព្វសម្បត្តិព្រមទាំងបុត្រ ។ កាលមាតា និងបិតាបានភាពជាធំក្នុងលោក ភាពជាធំនោះក៏មានដល់បុត្រទាំងឡាយដោយឈ្មោះ យ៉ាងណា ចំណែកធីតារបស់នាងបានសម្បត្តិហើយដោយអានុភាពរបស់មាតា ក៏យ៉ាងនោះ ។ ចាប់តាំងពីនោះនាង និងដោយបុត្រតូចទាំងឡាយ បានដើមឈើជាទីនៅជិតព្រះគន្ធកុដិ ហើយបានគាល់ព្រះពុទ្ធ ស្តាប់ព្រះធម៌ទាំងព្រឹកល្ងាចជាប្រចាំក្នុងទីនោះឯង រហូតអស់

*កាលយូរ ។*

ចប់អដ្ឋកថា បុនព្វសុសូត្រ ទី៧

# អ ដ្ឋ ក ថា

## សុទត្តសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងសុទត្តសូត្រទី ៨ តទៅនេះ ៖*

**[៣០៥]** *បទថា កេនចិទេវ ករណីយេន បានដល់ ប្រាថ្នាយកពាណិជ្ជកម្ម ។ អនាថបិណ្ឌិកគហបតី និងរាជគហសេដ្ឋី ជាបងប្អូនថ្លៃនិងគ្នា ។ កាលណា ក្នុងក្រុងរាជគ្រឹះ មានទំនិញបញ្ចូនចេញមានតម្លៃច្រើន កាលនោះ រាជគហសេដ្ឋីនាំយកទំនិញនោះទៅក្រុងសាវត្ថីដោយរទេះរាប់រយ សម្រាកក្នុងទីប្រមាណមួយយោជន៍ ឲ្យអ្នកដទៃដឹងថា ខ្ញុំមកហើយ ។ អនាថបិណ្ឌិកគហបតី សម្រាកក្នុងទីប្រមាណមួយយោជន៍ ឲ្យអ្នកដទៃដឹងថា ខ្ញុំមកហើយ ។ អនាថបិណ្ឌិកគហបតី ទៅទទួលធ្វើបដិសណ្ឋារៈដល់គេហើយ ទើបឡើងយានតែមួយជាមួយគ្នាចូលទៅក្រុងសាវត្ថី ។ ប្រសិនបើទំនិញលក់ចេញបានរហ័ស គេក៏លក់ បើលក់មិនដាច់ គេក៏នឹងរក្សាទុកក្នុងផ្ទះបងស្រី ហើយក៏ចេញទៅ ។ សូម្បីអនាថបិណ្ឌិកគហបតី ក៏ធ្វើយ៉ាងនោះដូចគ្នា ក្នុងកាលនោះ អនាថបិណ្ឌិកគហបតីនេះ បានទៅដោយករណីយកិច្ចនោះឯង ។ ប្រការនោះ លោក*

សំដៅដល់ករណីយកិច្ចនោះ ទើបពោលហើយ ។

ក៏ក្នុងថ្ងៃ នោះ រាជគហសេដ្ឋី បានស្តាប់ដំណឹងថា អនាថបិណ្ឌិកគហបតីមកសម្រាកនៅក្នុងទីប្រមាណមួយយោជន៍ បញ្ជូនដំណឹងទៅហើយដើម្បីនឹងបានដឹងថា ខ្លួនមកហើយ ទើបបានទៅវត្តដើម្បីស្តាប់ធម៌ ។ គេស្តាប់ធម្មកថាហើយ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដើម្បីឆាន់ក្នុងថ្ងៃស្អែក ទើបឲ្យជួយគ្នាជីកចង្ក្រាន និងពុះឧសជាដើមក្នុងផ្ទះរបស់ខ្លួន ។ សូម្បីអនាថបិណ្ឌិក-គហបតីគិតថា លោកសេដ្ឋី នឹងធ្វើការទទួលយើងឥឡូវនេះ នឹងធ្វើឥឡូវនេះ តែសូម្បីត្រង់ទ្វារផ្ទះ ក៏មិនបានការទទួល ទើបចូលទៅខាងក្នុងផ្ទះ ក៏បានការបដិសណ្ឋារៈទាំងមិនច្រើនគ្នា ។ ការបដិសណ្ឋារៈបានមានប្រមាណប៉ុណ្ណេះថា លោកមហាសេដ្ឋី លោកមិនទៀយហត់ក្នុងដំណើរផ្លូវដែលមកកាន់ក្នុងត្រកូលឬ ។ អនាថបិណ្ឌិកគហបតីនោះ ឃើញការខ្វល់ខ្វាយច្រើនរបស់លោកសេដ្ឋីនោះ ក៏ញាំងពាក្យឲ្យប្រព្រឹត្តទៅដោយន័យមកហើយក្នុងខន្ធកៈថា បពិត្រលោកគហបតី លោកនឹងមានអាវាហមង្គលឬ ដូច្នេះ បានស្តាប់ពាក្យថា ព្រះពុទ្ធអំពីមាត់របស់រាជគហសេដ្ឋីនោះ ក៏កើតបីតិ ៥ យ៉ាង ។ បីតិនោះតាំងឡើងតាំងពីសីសៈរបស់អនាថបិណ្ឌិកគហបតីនោះ ដរាបដល់ខ្នងជើង ពីខ្នងជើង

ផ្សាយទៅដរាបដល់សីសៈ តាំងឡើងក្នុងចំណែកទាំងពីររួមចុះមកត្រង់កណ្តាល តាំងឡើងត្រង់កណ្តាល ផ្សាយទៅក្នុងចំណែកទាំងពីរខាង ។ គេត្រូវបីតិពាល់ត្រូវមិនមានចន្លោះ ទើបពោលថា គហបតី សូមលោកពោលពាក្យថា ព្រះពុទ្ធម្តងទៀតចុះ ។ គហបតិពោលថា ព្រះពុទ្ធ ដូច្នេះ ។ គេសួរបីដងយ៉ាងនេះហើយ ទើបពោលពាក្យថា ពុទ្ធោ នោះឯង រកបានលំបាកក្នុងលោក ។ លោកសំដៅដល់ប្រការនេះ ទើបពោលថា អនាថបិណ្ឌិកគហបតីបានស្តាប់ហើយក៏បន្លឺពាក្យថា ព្រះពុទ្ធទ្រង់ឧប្បត្តិហើយក្នុងលោក ដូច្នេះ ។

បទថា **ឯតទវោច អកាលោ ខោ អជ្ជ** សេចក្តីថា អនាថបិណ្ឌិក-គហបតីសួរលោកសេដ្ឋីថា គហបតី ព្រះសាស្តាប្រថាប់នៅទីណា ។ គ្រានោះលោកសេដ្ឋីទើបប្រាប់ដល់អនាថបិណ្ឌិកគហបតីថា ធម្មតា ព្រះពុទ្ធទាំងឡាយចូលជិតបានដោយលំបាក ដូចជាអាសេរ្សិស ព្រះសាស្តា ប្រថាប់នៅក្នុងព្រៃជាទីចោលសាកសព បុគ្គលដូចលោកមិនអាចនឹងទៅគាល់ក្នុងវេលានេះ ក្នុងទីនោះបានទេ ។ គ្រានោះ លោកសេដ្ឋី បានមានការត្រិះរិះហើយយ៉ាងនោះ ។ បទថា **ពុទ្ធគតាយ សតិយា និបជ្ជិ** សេចក្តីថា បានឮថា ក្នុងថ្ងៃនោះ សូម្បីចិត្តរបស់អនាថបិណ្ឌិកគហបតី មិនបានគិតដល់រទេះទំនិញ ឬក្នុងអ្នកប្រើ មិន

ទទួលទានអាហារពេលល្ងាច បានឡើងទៅកាន់ប្រាសាទជាន់ទី ៧ ក៏ធ្វើការស្វាធ្យាយថា ពុទ្ធោ ពុទ្ធោ លើទីដេកដ៏ប្រសើរដែលគេរៀបទុក និងតាក់តែងទុកយ៉ាងល្អ ហើយដេកលក់ទៅ ។ ព្រោះហេតុនោះ លោកទើបពោលថា កាលមានសតិរលឹកដល់ព្រះពុទ្ធ ទើបលក់ទៅ ។

បទថា **រត្តិយា សុទំ តិក្ខត្តុំ វុដ្ឋាសិ បភាតន្តិ មមញ្ញមានោ** សេចក្តីថា កាលបឋមយាមកន្លងទៅ គេក្រោកឡើងរលឹកដល់ព្រះពុទ្ធ ។ ក្នុងកាលនោះ សេចក្តីជ្រះថ្លារបស់អនាថបិណ្ឌិកនោះ បានកើតឡើងយ៉ាងមានកម្លាំង ។ ពន្លឺដែលកើតពីបីតិបានមានហើយ ។ សេចក្តីងងឹតក៏បាត់ទៅ ។ ដូចប្រទីបពាន់ដួងឆេះឡើង និងដូចព្រះចន្ទព្រះអាទិត្យរះឡើង ដូច្នោះ ។ អនាថបិណ្ឌិក-គហបតីនោះគិតថា យើងដល់ហើយនូវសេចក្តីជ្រះថ្លា ហើយស្មានថា ព្រះ-អាទិត្យរះ ដូច្នេះ ហើយក៏ក្រោកឡើងឈរលើផ្ទៃប្រាសាទ សម្លឹងមើលព្រះចន្ទ គិតថា យាមមួយកន្លងទៅហើយ នៅសល់ពីរយាមទៀត ទើបចូលទៅដេកវិញ ។ ដោយឧបាយនោះ គេក្រោកឡើង ៣ ដង គឺ ក្នុងទីបំផុតមជ្ឈិមយាម ចំណែកក្នុងទីបំផុតនៃបច្ឆិមយាម ក្រោកឡើង ក្នុងវេលាចវេលាជិតភ្លឺ ដើរសំដៅទៅកាន់ទ្វារធំ ។ ទ្វារ ៧ ជាន់បានបើកឯង ។ គេចុះអំពីប្រាសាទដើរ

ទៅចន្លោះផ្លូវ ។

បទថា **វិវរឹសុ** សេចក្ដីថា អមនុស្សទាំងឡាយគិតថា មហាសេដ្ឋីនេះចេញទៅដោយគិតថា យើងនឹងទៅបម្រើព្រះពុទ្ធ គេនឹងតាំងនៅក្នុងសោតាបត្តិផលដោយការឃើញគ្រាដំបូងនោះឯង នឹងបានជាឧបដ្ឋាកដ៏ប្រសើរនៃព្រះរតនត្រ័យ ធ្វើសង្ឃារាមឲ្យជាស្ថានទីដែលប្រៀបផ្ទឹមមិនបាន យើងនឹងមិនបើកទ្វារទទួលពួកព្រះអរិយៈដែលមកពីទិសទាំងបួន តែចំពោះមហាសេដ្ឋីនេះ មិនគួរបិទទ្វារឡើយ ដូច្នេះ ទើបបានបើកហើយ ។

**[៣០៦]** បទថា **អន្តរធាយិ** សេចក្ដីថា បានឮថា ក្រុងរាជគ្រឹះ មានមនុស្សពាសពេញខាងក្នុងក្រុង ៩ កោដិ ខាងក្រៅក្រុង ៩ កោដិ រួមបានមនុស្ស ១៨ កោដិ ចូលទៅអាស្រ័យនៅក្រុងរាជគ្រឹះនោះ ។ ពួកមនុស្សមិនអាចនឹងនាំយកអ្នកស្លាប់ចេញទៅខាងក្រៅក្រុងខុសវេលាបាន ទើបដាក់ត្រង់ធរណីទ្វារចោលទៅខាងក្រៅ ។ មហាសេដ្ឋីចេញទៅខាងក្រៅក្រុង ជើងក៏ជាន់សាកសពដែលនៅស្រស់ ។ ជើងម្ខាងបានជាន់ប៉ះសាកសពដែលនៅស្រស់ ។ ជើងម្ខាងទៀតជាន់សាកសពស្ទួយដទៃទៀត ។ ហ្វូងរុយក៏ហើរឡើងប្រវាត់ចេញជុំវិញ ។ ក្លិនស្អុយក៏ប៉ះខ្ទប់នឹងច្រមុះ ។ សេចក្ដីជ្រះថ្លាក្នុង

ព្រះពុទ្ធ ក៏ថយចុះ ។ ព្រោះហេតុនោះ ពន្លឺរបស់មហាសេដ្ឋីនោះ ក៏អន្តរធាន ទៅ ។ ភាពងងឹតប្រាកដឡើង ។ បទថា **សទ្ទមនុស្សាវេសិ** សេចក្ដីថា សិវកយក្ខគិតថា យើងនឹងញ៉ាំងសេចក្ដីឧស្សាហ៍ឲ្យកើតដល់សេដ្ឋី បានបញ្ចេញ សំឡេងឲ្យឮ ដោយសំឡេងដ៏ពីរោះដូចអ្នកគោះកណ្ដឹងមាស ដូច្នោះ ។

បទថា **សតំ កញ្ញាសហស្សានិ** សេចក្ដីថា សូម្បីបទដំបូងភ្ជាប់នឹង បទ **សហស្ស** នេះឯង ក្នុងសេចក្ដីនេះ មានអធិប្បាយដូច្នេះថា ស្រីក្រមុំ មួយសែន ដំរីមួយសែន សេះមួយសែន រថមួយសែន ។ មួយសែនៗ លោក សម្ដែងទុកហើយ ដោយប្រការដូច្នេះ ។

បទថា **បទវីតិហារស្ស** បានដល់ មួយជំហានក្នុងចន្លោះជើងទាំងពីរ ក្នុងការដើរទៅធម្មតា ឈ្មោះថា ការឈានជើងទៅមួយជំហាន ។ បទថា **កលំ នាគ្ឃន្តិ សោឡសឹ** សេចក្ដីថា មួយចំណែកដែលគេជាចែក ១៦ ដង ដោយ ១៦ ដង យ៉ាងនេះគឺ ចែកការឈានមួយជំហានចេញជា ១៦ ចំណែក យក ១៦ ចំណែកនោះ ដកយកតែមួយចំណែក ចែកជា ១៦ ចំណែកទៀត ។ យក ១៦ ចំណែកនោះ ដកមួយចំណែក ចែកជា ១៦ ចំណែកទៀត ឈ្មោះថា ចំណិតទី ១៦ ។ បួនសែនទាំងនេះ រមែងមិនដល់ចំណិតទី ១៦ នោះ មាន

ពាក្យអធិប្បាយថា ចេតនាដែលប្រព្រឹត្តទៅក្នុងចំណែក ពោលគឺ ចំណិតទី ១៦ នោះ របស់បុគ្គលកំពុងទៅកាន់វិហារ ជាចេតនាដែលក្រៃលែងជាង ការបាននេះ ប្រមាណប៉ុណ្ណេះ គឺ ដំរីមួយសែន សេះមួយសែន រថមួយសែន ។ ស្រីក្រមុំមួយសែន ក៏ស្រីក្រមុំទាំងនោះឯង ដែលប្រដាប់កែវមណី និងកុណ្ឌលជារាជធីតានៅក្នុងជម្ពូទ្វីបទាំងអស់ ។ សួរថា ក៏ការទៅវិហារនេះ លោកកាន់ហើយដោយអំណាចរបស់អ្នកណា ។ ឆ្លើយថា របស់អ្នកទៅកាន់វិហារហើយតាំងនៅក្នុងសោតាបត្តិផលដោយមិនមានអន្តរាយ និងដោយអំណាចនៃបុគ្គលដែលទៅដោយគិតថា យើងនឹងធ្វើការបូជាដោយគ្រឿងក្រអូប និងផ្កាឈើជាដើម នឹងថ្វាយបង្គំព្រះចេតិយ ស្តាប់ធម៌ បូជាដោយទៀន និងធូប និមន្តព្រះសង្ឃ ថ្វាយទាន នឹងតាំងនៅក្នុងសិក្ខាបទ ឬថា ដល់សរណៈ ដូច្នេះ រមែងគួរដូចគ្នា ។

បទថា **អន្ធការោ អន្តរធាយិ** សេចក្តីថា ន័យថា លោកសេដ្ឋីគិតថា យើងធ្វើសេចក្តីសម្គាល់ថា យើងនៅម្នាក់ឯង សូម្បីការប្រកបសេចក្តីព្យាយាមក៏មានតែយើង ព្រោះហេតុអ្វី យើងទើបត្រូវខ្លាចបា្ន ដូច្នោះ ទើបបានជាអ្នកក្លៀវក្លា ។ គ្រានោះ សេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធមានកម្លាំង កើតឡើងហើយ ។

ព្រោះដូច្នោះ សេចក្តីងងឹតទើបអន្តរធានទៅ ។ សូម្បីក្នុងវារៈដ៏សេស ក៏មានន័យនេះឯង ។ មួយវិញទៀត បុគ្គលដែលដើរទៅខាងមុខៗ បានឃើញសាកសពច្រើនយ៉ាង ជាដើមថា រាងភ្នំមានសាច់ និងឈាមជាប់នៅក្នុងផ្លូវនៃព្រៃជាទីចោលសាកសពដែលគួរខ្លាច បានឮ សំឡេងសុនខស្រែក និងចចកជាដើម ។ គេញ៉ាំងសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធ ឲ្យចម្រើនរឿយៗ ញ៉ាំញីអន្តរាយទាំងអស់នោះបាន ។

**[៣០៩]** បទថា *ឯហិ សុទត្ត* សេចក្តីថា បានឮថា សេដ្ឋីនោះដើរបណ្តើរគិតបណ្តើរថា ក្នុងលោកនេះ មានតិរ្ថិយឈ្មោះបូរណកស្សបៈជាដើម តែងពោលថា យើងទាំងឡាយជាព្រះពុទ្ធ យើងទាំងឡាយជាព្រះពុទ្ធ យើងគប្បីដឹងភាពដែលសាស្តាជាព្រះពុទ្ធបានយ៉ាងណាហ្ន៎ ។ គ្រានោះឯង លោកសេដ្ឋីមានសេចក្តីត្រិះរិះយ៉ាងនេះថា មហាជនតែងស្គាល់ឈ្មោះ ដែលកើតដោយអំណាចគុណរបស់យើង តែអ្នកណាៗ មិនស្គាល់កុលទត្តិយៈជាឈ្មោះរបស់យើង ក្រៅអំពីយើង បើថា ព្រះពុទ្ធមាន ព្រះអង្គក៏ទ្រង់ហៅយើងដោយឈ្មោះថា កុលទត្តិកៈ ។ ព្រះសាស្តាទ្រង់ដឹងវារៈចិត្តរបស់គេហើយ ទើបត្រាស់យ៉ាងនេះ ។

បទថា **បរិនិព្វុតោ** សេចក្ដីថា ព្រាហ្មណ៍បានរំលត់ហើយ ដោយការរំលត់កិលេស ។

បទថា **អាសត្តិយោ** ប្រែថា តណ្ហា ។ បទថា **សន្តិ** ប្រែថា សេចក្ដីស្ងប់រម្ងាប់កិលេស ។ បទថា **បប្បុយ្យ** ប្រែថា ដល់ហើយ ។ ក៏ព្រះសាស្ដាត្រាស់ព្រះតម្រាស់នេះ ទើបត្រាស់អនុបុព្វីកថា ដល់សេដ្ឋីនោះ ហើយក៏ទ្រង់ប្រកាសសច្ចៈ ៤ ក្នុងទីបំផុត ។ សេដ្ឋីស្ដាប់ព្រះធម៌ទេសនាហើយ តាំងនៅក្នុងសោតាបត្តិផល និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ផ្ដើមថ្វាយមហាទានតាំងពីថ្ងៃស្អែកតទៅ ។ ឥស្សរជន មានព្រះបាទពិម្ពិសារជាដើម បញ្ជូនសាសន៍ទៅដល់សេដ្ឋីថា លោកសេដ្ឋីជាអាគន្តុកៈ វត្ថុណាមិនល្មម លោកចូរឲ្យគេនាំវត្ថុនោះអំពីទីនេះចុះ ។ តែលោកសេដ្ឋីហាមជនទាំងអស់ថា ល្មមហើយ ព្រោះពួកលោកមានកិច្ចច្រើន អនាថបិណ្ឌិកសេដ្ឋីបានថ្វាយមហាទាន ៦ ថ្ងៃ ដោយសម្បត្តិដែលខ្លួននាំមកដោយរទេះ ៥០០ ។ ក៏ក្នុងទីបំផុតនៃការថ្វាយទាន គេទូលព្រះមានព្រះភាគទ្រង់ទទួលដល់ការនៅចាំវស្សាក្នុងក្រុងសាវត្ថី ហើយបានថ្វាយទានមួយសែនគ្រប់ៗ យោជន៍ កាលឲ្យគេសាងវិហារ ៤០ កន្លែងក្នុងចន្លោះផ្លូវទៅកាន់ក្រុងរាជគ្រឹះនឹងក្រុងសាវត្ថី អនាថបិណ្ឌិកសេដ្ឋី បានទៅ

កាន់ក្រុងសាវត្ថី ហើយឲ្យគេសាងជេតវនមហាវិហារ ស្រេចហើយ បានវេរ

ថ្វាយចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។

ចប់អដ្ឋកថា សុទត្តសូត្រទី ៨

# អ ដ្ឋ ក ថា

## បឋមសុក្កាសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបឋមសុក្កាសូត្រទី ៩ តទៅនេះ ៖

[៣១២] បទថា **រថិកាយ រថិកំ** សេចក្តីថា កាលកាន់យកច្រកមួយទៅអំពីច្រកនោះ ទៅកាន់ច្រកមួយទៀត បានឈ្មោះថា ចេញពីច្រកមួយចូលទៅកាន់ច្រកមួយ ។

សូម្បីក្នុងផ្លូវត្រឡែងកែង ក៏មានន័យនេះឯង ។ ក្នុងបទថា **រថិកាយ** នេះ ប្រែថា ច្រក ។ បទថា **សិង្ឃាដកំ** ប្រែថា ផ្លូវត្រឡែងកែង ។ ក្នុងបទថា **កិម្មេ កតា** សេចក្តីថា មនុស្សទាំងឡាយនោះ ធ្វើអ្វីដល់យើង គឺ ធ្វើអ្វីយើងបាន ។ បទថា **មធុបិតាវ សេយរេ** សេចក្តីថា រមែងដេកដូចជាបុគ្គលផឹកទឹកឃ្មុំមានក្លិនក្រអូប ។ ន័យថា បុគ្គលផឹកទឹកឃ្មុំដែលមានក្លិនក្រអូប មិនអាចនឹងលើកសីសៈឡើងបាន រមែងដេកដោយមិនដឹងខ្លួន ព្រោះដូច្នោះ យក្ខទើបពោលយ៉ាងនេះ ។

បទថា **តញ្ច បន អប្បដិវានីយំ** សេចក្តីថា ក៏កាលសុក្កាភិក្ខុនីសម្តែង

ធម៌នោះ អ្នកណានឹងជំទាស់មិនបាន ។ ពិតណាស់ ភោជនខាងក្រៅ សូម្បីនឹងឆ្ងាញ់ក៏ពិត តែរមែងមិនពេញចិត្តដល់អ្នកដែលបរិភោគរឿយៗ គប្បីត្រូវហាម គឺ គប្បីត្រូវនាំចេញដោយពាក្យថា លោកចូរនាំទៅចុះ ប្រយោជន៍អ្វីដោយភោជននេះហ្ន៎ ធម៌នេះមិនដូច្នោះទេ ។ ពិតណាស់ បណ្ឌិតទាំងឡាយកាលស្តាប់ធម៌នេះ រហូតដល់អស់មួយរយឆ្នាំខ្លះ មួយពាន់ឆ្នាំខ្លះ ក៏មិនឆ្អែតឡើយ ព្រោះហេតុនោះ យក្ខទើបពោលថា បុគ្គលណានឹងជំទាស់មិនបាន ។ បទថា **អសេចនកមោជវំ** បានដល់ មានឱជាដែលមិនបានតាក់តែង ដូចយ៉ាងថា សូម្បីបាយបាយាសមិនលាយដោយវត្ថុខាងក្រៅជាដើម តែយកទឹកដោះថ្លា ទឹកឃ្មុំ និងស្ករលាយចូលគ្នាហើយ រមែងមានឱជារសឆ្ងាញ់ យ៉ាងណា ធម៌នេះមិនដូច្នោះទេ ។ ក៏ធម៌នេះ ជាធម៌ពីរោះ និងមានឱជាតាមធម្មតារបស់ខ្លួន នឹងយកវត្ថុដទៃមកដាក់ចូល ក៏មិនមែន ។ ព្រោះហេតុនេះ យក្ខទើបពោលថា មានឱជាដោយមិនបានលាយ ។ បទថា **មញ្ញេ សប្បញ្ញា** សេចក្តីថា ដូចបុរសជាបណ្ឌិតទាំងឡាយតែងផឹក ។ បទថា **វលាហកមិវ បន្ថគូ** សេចក្តីថា ដូចអ្នកធ្វើដំណើរក្នុងរដូវក្តៅ បានផឹកទឹកហូរធ្លាក់មកពីចន្លោះពពក ដូច្នោះ ។

ចប់អដ្ឋកថា បឋមសុក្កាសូត្រទី ៩

# អ ដ្ឋ ក ថា

## ទុតិយសុក្កាសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងទុតិយសុក្កាសូត្រទី ១០ តទៅនេះ ៖*

**[៣១៤]** *បទថា បុញ្ញំ វត បសវិ ពហុំ សេចក្តីថា ឧបាសកប្រសព្វបុណ្យច្រើនហ្ន៎ ។*

ចប់អដ្ឋកថា ទុតិយសុក្កាសូត្រទី ១០

# អ ដ្ឋ ក ថា

## ចីរាសូត្រទី ១១

*ចីរាសូត្រទី ១១ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា ចីរាសូត្រទី ១១

# អដ្ឋកថា

## អាឡវកសូត្រទី ១២

គប្បីជ្រាបវិនិច្ឆ័យក្នុងអាឡវកសូត្រទី ១២ តទៅនេះ ៖

**[៣១៧]** បទថា **អាឡវិយំ** បានដល់ ទីនៅនោះ គេហៅថាដែនខ្លះ ថាក្រុងខ្លះ ឈ្មោះថា ក្រុងអាឡវី ។ ទីនៅនោះឯង តាំងនៅក្នុងទីប្រមាណ មួយគាវុតមិនឆ្ងាយពីក្រុង ។

ព្រះមានព្រះភាគទ្រង់ប្រថាប់នៅក្នុងទីនោះ ចូលទៅអាស្រ័យក្រុងនោះ លោកពោលថា ប្រថាប់នៅក្នុងដែនអាឡវី ។ ក៏ក្នុងបទថា **អាឡវកស្ស យក្ខស្ស ភវនេ** នេះ មានអនុបុព្វីកថាតទៅនេះ បានឮថា ព្រះរាជាព្រះនាម **អាឡវកៈ** ទ្រង់លះបង់គ្រឿងប្រើប្រាស និងពួកស្រីរបាំជាច្រើនចោល ស្តេចទៅបង្ក្រាបចោរ ដើម្បីការពារព្រះរាជាជាសត្រូវ និងដើម្បីធ្វើសេចក្តីព្យាយាម អំពីថ្ងៃទី ៧ ក្នុងថ្ងៃមួយ ទ្រង់ធ្វើកតិកានឹងកងទ័ពថា បើម្រឹគគេចចេញទៅខាងអ្នកណា ម្រឹគនោះជាភារៈរបស់អ្នកនោះប៉ុណ្ណោះ ។ គ្រានោះ ម្រឹគគេចចេញទៅខាងព្រះរាជានោះឯង ។ ព្រះរាជាទ្រង់ដល់ព្រមដោយសន្ទុះ ទ្រង់កាន់ធ្នូ

ជាប់តាមម្រឹគនោះ ទ្រង់ទៅអស់បីយោជន៍ ។ ចំណែកម្រឹគមានកម្លាំងរត់បាន ត្រឹមតែបីយោជន៍ប៉ុណ្ណោះ ។ គ្រានោះ ព្រះរាជាទ្រង់សម្លាប់ម្រឹគនោះ ដែលអស់ជើង ចូលទៅកាន់កំពង់ទឹក ឈរកាប់ម្រឹគជាពីរកំណាត់ សូម្បីមិនត្រូវការដោយសាច់ តែវែកមកដើម្បីបានផុតពីកំហុសថា ព្រះរាជាមិនអាចចាប់ម្រឹគបាន ដូច្នេះ ទ្រង់ឃើញដើមជ្រៃធំមានម្លប់ត្រឈឹងត្រឈៃនៅមិនឆ្ងាយក្រុង ទើបស្តេចទៅគល់ដើមជ្រៃនោះ ដើម្បីបន្ទោបង់សេចក្តីនឿយហត់ ។ ក្នុងដើមជ្រៃនោះ អឡវកយក្ខ បានទីនៅអំពីសម្នាក់មហារាជ ស៊ីសត្វដែលចូលទៅកាន់ឱកាសដែលពាល់ត្រូវហើយដោយម្លប់ក្នុងបរិវេណរបស់ដើមឈើនោះ ។ ព្រះរាជាទ្រង់ឃើញយក្ខនោះ ចូលមកដើម្បីនឹងស៊ី ។ ព្រះរាជាទ្រង់បានធ្វើកតិកាជាមួយនឹងយក្ខនោះថា លោកចូរលែងយើងចុះ យើងនឹងបញ្ជូនមនុស្ស និងអាហារមួយថាសមក សម្រាប់លោករាល់ៗ ថ្ងៃ ។ យក្ខទូលថា ព្រះអង្គរវល់តែស្រវឹងដោយគ្រឿងឧបភោគ ទ្រង់នឹងរលឹកមិនបាន តែចំពោះខ្ញុំព្រះអង្គនឹងមិនបានស៊ីសត្វដែលមិនចូលមកដល់ទីនៅ និងទីដែលមិនបានទទួលអនុញ្ញាត ខ្ញុំព្រះអង្គ គប្បីសាបសូន្យចាកសេចក្តីចម្រើន ដូច្នេះ ទើបខ្ញុំព្រះអង្គមិនលែង ។

ព្រះរាជាត្រាស់ថា បើថ្ងៃណា យើងមិនបានបញ្ជូនមកឲ្យ ថ្ងៃនោះ លោកចូរទៅកាន់វាំងរបស់យើង ហើយចាប់យើងស៊ីចុះ ។ យក្ខទើបព្រលែងព្រះរាជា ហើយស្ដេចទ្រង់ទៅកាន់ព្រះនគរ ។ កងទ័ពតាំងបន្ទាយនៅមាត់ផ្លូវ ឃើញព្រះរាជាហើយ ក៏ក្រាកឡើងទូលថា បពិត្រមហារាជ ព្រះអង្គទ្រង់នឿយហត់ ព្រោះព្រះអង្គមានភ័យមកដល់ឬ ដូច្នេះ ។ ព្រះរាជាទ្រង់ប្រាប់រឿងដែលប្រព្រឹត្តទៅនោះ ស្ដេចទៅកាន់ព្រះនគរ សោយព្រះក្រយាហារព្រឹកហើយ ហៅអ្នករក្សាព្រះនគរមក ទ្រង់ប្រាប់រឿងនោះ ។ អ្នករក្សាព្រះនគរទូលថា បពិត្រព្រះអង្គដ៏ចម្រើន តើព្រះអង្គកំណត់វេលា ឬមិនបានកំណត់ ។ ព្រះរាជាត្រាស់ថា នែ៎នាយ យើងមិនបានកំណត់ទុកទេ ។ អ្នករក្សាព្រះនគរក្រាបទូលថា ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ធ្វើនេះមិនត្រូវ ព្រោះពួកអមនុស្ស រមែងបានត្រឹមតែការកំណត់ទុកប៉ុណ្ណោះ កាលមិនកំណត់ទុកជនបទនឹងត្រូវបៀតបៀន បពិត្រព្រះអង្គ រឿងនេះចូរលើកទុកចុះ ថ្វីត្បិតព្រះអង្គបានធ្វើយ៉ាងនេះហើយ តែសូមព្រះអង្គទ្រង់មានសេចក្ដីខ្វល់ខ្វាយតិច ហើយសោយរាជជាសុខចុះ ខ្ញុំព្រះអង្គនឹងធ្វើវត្ថុដែលគួរក្នុងរឿងនេះ ។ គេក្រោកឡើងពីព្រឹកព្រលឹម ឈរត្រង់ទ្វារគុកពោលថា អ្នកណាត្រូវការមានជីវិត អ្នកនោះ

ចូរចេញទៅចុះ សំដៅយកពួកជនដែលត្រូវប្រហារ អ្នកណាចេញទៅមុន គេក៏នាំអ្នកនោះទៅផ្ទះឲ្យផឹកទឹក ឲ្យបរិភោគ បញ្ជូនទៅដោយពាក្យថា អ្នកចូរឲ្យថាសអាហារនេះដល់យក្ខចុះ ។ យក្ខនិម្មិតអត្តភាពដែលគួរខ្លាច ហើយទំពារស៊ីអ្នកដែលចូលទៅកាន់គល់ឈើនោះឯង ដូចទំពារមើមដំឡូង ដូច្នោះ ។ បានឮថា ដោយអានុភាពរបស់យក្ខ សរីរៈទាំងអស់មានសក់ជាដើមរបស់ពួកមនុស្ស ដូចជាដុំទឹកដោះថ្លា ។ ពួកអ្នកដែលគេប្រើឲ្យកាន់កត្តទៅឲ្យយក្ខឃើញយក្ខនោះហើយខ្លាច ទើបប្រាប់ដល់គ្នីគ្នា ។ ព្រះរាជាក៏ចាប់ពួកចោរឲ្យយក្ខស៊ីចាប់តាំងពីនោះ ដូច្នេះ ។ ពួកមនុស្សឈប់ធ្វើចោរកម្ម ។ សម័យតមកគុកក៏ទទេ ព្រោះចោរថ្មីមិនមាន ព្រោះចោរចាស់អស់ទៅ ។ គ្រានោះអ្នករក្សាព្រះនគរ ទូលព្រះរាជាហើយ ។ ព្រះរាជាទើបឲ្យមនុស្សយកទ្រព្យចំណែករបស់ព្រះអង្គទៅទុកចោលត្រង់ថ្នល់ក្នុងក្រុង ដោយព្រះតម្រិះថា ធ្វើដូចម្ដេច ឲ្យបុគ្គលណានីមួយគប្បីកាន់យកនូវទ្រព្យដោយសេចក្ដីលោភ សូម្បីបុគ្គលណាៗ ក៏មិនប៉ះពាល់ទ្រព្យនោះសូម្បីដោយជើង ។ ព្រះរាជា កាលមិនបានចោរ ទើបត្រាស់ប្រាប់ដល់អាមាត្រទាំងឡាយ ។ ពួកអាមាត្រទូលថាពួកខ្ញុំព្រះអង្គនឹងបញ្ជូនមនុស្សចាស់ទៅម្ដងម្នាក់ៗ តាមលំដាប់ត្រកូល សូម្បីតាម

ធម្មតារបស់មនុស្សចាស់ទាំងនោះ ក៏ជិតនឹងស្លាប់ដែរ ។ ព្រះរាជាត្រាស់ហាមថា មនុស្សទាំងឡាយនឹងធ្វើការចងគំនុំថា ព្រះរាជាទ្រង់បញ្ជូនឳពុករបស់យើងបញ្ជូនតារបស់យើងទៅ អ្នកទាំងឡាយកុំពេញចិត្តក្នុងប្រការនោះឡើយ ។ ពួកអាមាត្រទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ ពួកខ្ញុំព្រះអង្គនឹងបញ្ជូនទារកទៅ ក៏ទារកដែលមានសភាពបែបនោះ មិនទាន់មានសេចក្ដីសឡាញ់ថា នេះម៉ែរបស់យើង នេះឳពុករបស់យើង ដូច្នេះ ។ ព្រះរាជាទ្រង់អនុញ្ញាតហើយ ។ ពួកអាមាត្រក៏បានធ្វើយ៉ាងនោះឯង ។ មាតារបស់ក្មេងក្នុងក្រុងនាំពួកក្មេងទៅ និងស្ត្រីមានគភ៌គេចចេញទៅ ពួកគេចិញ្ចឹមក្មេងឲ្យចម្រើនធំធាត់ក្នុងជនបទដទៃទើបនាំមក ។ ដោយអាការយ៉ាងនេះឯង កន្លងទៅហើយអស់ ១២ ឆ្នាំ ។

តមកថ្ងៃមួយ ពួកអាមាត្រស្វែងរកទូទៅទាំងព្រះនគរ ក៏មិនបានទារកសូម្បីតែម្នាក់ ទើបទូលព្រះរាជាថា បពិត្រព្រះអង្គ ទារកក្នុងព្រះនគរមិនមានឡើយ ក្រៅអំពីអាឡវកកុមារ ដែលជាឱរសរបស់ព្រះអង្គខាងក្នុងបុរី ។ ព្រះរាជាត្រាស់ថា យើងស្រឡាញ់បុត្តរបស់យើង យ៉ាងណា សូម្បីមនុស្សក្នុងលោកទាំងអស់ក៏ដូច្នោះដែរ វត្ថុដែលគួរស្រឡាញ់ក្រៃលែងជាងខ្លួន មិនមាន

ឡើយ លោកចូរទៅ ចូរឲ្យបុត្រនោះ ហើយរក្សាជីវិតរបស់យើងចុះ ។ សម័យនោះ មាតារបស់អាឡវកកុមារ ឲ្យបុត្រងូតទឹក ហើយតុបតែងធ្វើដោយឈ្នួតពីរជាន់ អន្តុយឲ្យបុត្រផ្ទុំលើភ្លៅ ។ រាជបុរសទៅហើយក្នុងទីនោះ តាមបង្គាប់របស់ព្រះរាជា ចាប់យកព្រះរាជបុត្តនោះជៀសចេញទៅ មេដោះ និងមាតាទ្រង់ត្អូញត្អែរ មួយអន្ទើដោយព្រះរាជទេវី ១ ម៉ឺន ៦ ពាន់នាក់ថា ស្អែកនេះនឹងជាភិក្ខារបស់យក្ខ ។ ថ្ងៃនោះ ព្រះមានព្រះភាគស្តេចតើនឡើងក្នុងវេលាជិតភ្លឺ ទ្រង់ចូលមហាករុណាសមាបត្តិ ក្នុងមហាគន្ធកុដិជេតវនវិហារ កាលទ្រង់ត្រួតមើលលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញឧបនិស្ស័យរបស់អាឡវកកុមារសម្រេចអនាគាមិផល និងយក្ខសម្រេចសោតាបត្តិផល ព្រមទាំងសត្វ ៨៤.០០០ បាននូវធម្មចក្ខុក្នុងទីបំផុតនៃទេសនា ដូច្នេះ ។

ព្រះមានព្រះភាគព្រះអង្គនោះ កាលភ្លឺច្បាស់ហើយ ទ្រង់ធ្វើភត្តកិច្ចជាខាងដើម កាលសម្រេចរៀបរយល្អហើយ កាលថ្ងៃឧបោសថនៃកាឡបក្ខប្រព្រឹត្តទៅ ក្នុងគ្រាព្រះអាទិត្យលិច ទ្រង់យាងទៅហើយតែមួយព្រះអង្គឯងដោយមិនមានភិក្ខុជាគម្រប់ពីរ ទ្រង់បាត្រ និងចីវរ ស្តេចចេញចាកអំពីក្រុងសាវត្ថីទៅ ៣០ យោជន៍ ដោយព្រះបាទ ស្តេចចូលទៅកាន់ទីនៅរបស់យក្ខ

នោះ ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រះមានព្រះភាគប្រថាប់ក្នុងទីនៅរបស់អឡវកយក្ខ ។

សួរថា ក៏ព្រះមានព្រះភាគប្រថាប់ត្រង់ដើមជ្រៃ ឬក្នុងទីនៅរបស់អាឡវកយក្ខ ។ ឆ្លើយថា ក្នុងទីនៅ ។ ប្រៀបដូចពួកយក្ខ រមែងឃើញទីនៅរបស់ខ្លួន យ៉ាងណា សូម្បីព្រះមានព្រះភាគ ក៏ដូច្នោះ ។ ព្រះមានព្រះភាគព្រះអង្គនោះ ស្តេចទៅក្នុងទីនោះ ប្រថាប់ឈរជិតទ្វារ ។ ក្នុងកាលនោះ អាឡវកយក្ខបានទៅកាន់យក្ខសមាគមក្នុងព្រៃហិមវន្ត ។ លំដាប់នោះ យក្ខមាននាមថា គទ្រភៈ ជាអ្នករក្សាទ្វាររបស់អាឡវកយក្ខ ចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ស្តេចមកក្នុងវេលាវិកាលឬ ។

ព្រះ : មែន គទ្រភៈ តថាគតមកវេលាវិកាល បើអ្នកមិនចង្អៀតចង្អល់ចិត្តទេ តថាគតគប្បីនៅក្នុងទីនៅរបស់អាឡវកយក្ខមួយយប់ ។

គ : បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនចង្អៀតចង្អល់ចិត្តទេ ម្យ៉ាងទៀត យក្ខនោះកាចឃោឃៅ មិនធ្វើការអភិវាទជាដើម សូម្បីដល់មាតាបិតា គេមិនពេញចិត្តការនៅក្នុងទីនេះរបស់ព្រះមានព្រះភាគឡើយ ។

ព្រះ ៖ ម្នាលគទ្រភៈ តថាគតដឹងទីនៅរបស់អាឡវកយក្ខនោះ អន្តរាយណាមួយនឹងមិនមានដល់តថាគត បើអ្នកមិនចង្អៀតចង្អល់ចិត្តទេ តថាគតគប្បីបានសម្រាកមួយយប់ ។

គទ្រភយក្ខ ៖ បានក្រាបទូលពាក្យនោះចំពោះព្រះមានព្រះភាគ សូម្បីលើកទីពីរថា បពិត្រព្រះអង្គដ៏ចម្រើន អាឡវកយក្ខ ដូចក្បៀងក្តៅ មិនស្គាល់ថាមាតាបិតា ថាសមណព្រាហ្មណ៍ ឬថា ធម៌ រមែងធ្វើចិត្តរបស់បុគ្គលដែលមកហើយក្នុងទីនេះ ឲ្យវង្វេងវាយខ្លះ ហែកបេះដូងខ្លះ ចាប់ត្រង់ជើងគ្រវែងទៅត្រើយសមុទ្រឯណោះ ឬចក្រវាឡខាងឯណោះខ្លះ ។ ព្រះមានព្រះភាគត្រាស់សូម្បីលើកទីពីរថា ម្នាលគទ្រភៈ តថាគតដឹង បើអ្នកមិនចង្អៀតចង្អល់ចិត្តទេ តថាគតគប្បីសម្រាកបានមួយយប់ ។

គ ៖ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនចង្អៀតចង្អល់ចិត្តទេ ម្យ៉ាងទៀត យក្ខនោះនឹងគប្បីសម្លាប់ខ្ញុំព្រះអង្គ ដែលមិនបានសូមអនុញ្ញាត បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងប្រាប់ដល់យក្ខនោះ ។

ព្រះ ៖ អើ ម្នាលគទ្រភៈ សូមអ្នកប្រាប់បានតាមសប្បាយចុះ ។

គៈ ៖ បពិត្រព្រះអង្គដ៏ចម្រើន បើយ៉ាងនោះ សូមព្រះអង្គចូលដឹងចុះ

ដូច្នេះ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយផ្ទោះមុខទៅកាន់ហិមវន្ត ទើបជៀសចេញទៅ ។ សូម្បីទ្វារដែលជាទីនៅ បានបើកឯងថ្វាយព្រះដ៏មានព្រះភាគ ។ ព្រះមានព្រះភាគស្តេចចូលទៅខាងក្នុងទីនៅរបស់អាឡវកយក្ខ ក៏បល្ល័ង្កណាដែលសម្រេចដោយទិព្វរតនៈ ដែលអាឡវកយក្ខអង្គុយហើយក្នុងថ្ងៃមង្គលជាដើម ដែលកំណត់ទុកហើយ សោយនូវសិរី ព្រះមានព្រះភាគ ស្តេចប្រថាប់ហើយលើបល្ល័ង្កនោះ លើបល្ល័ង្កនោះ ទ្រង់បញ្ចេញរស្មីពណ៌មាស ។ ស្ត្រីទាំងឡាយរបស់យក្ខ ឃើញរស្មីពណ៌មាសនោះហើយ ក៏មកថ្វាយបង្គំព្រះ-មានព្រះភាគអង្គុយចោមរោម ។ ព្រះមានព្រះភាគ ត្រាស់បកិណ្ណកធម្មកថាដល់ស្ត្រីទាំងនោះ ដោយន័យជាដើមថា ក្នុងកាលមុន ពួកនាងថ្វាយទាន សមា-ទានសីល បូជាបុគ្គលដែលគួរបូជា ទើបបានសម្បត្តិនេះ សូម្បីក្នុងកាលឥឡូវនេះ សូមពួកនាងចូរធ្វើយ៉ាងនោះចុះ កុំជាអ្នកមានឥស្សា និងមច្ឆរិយៈដល់គ្នានិងគ្នាឡើយ ។ ស្ត្រីទាំងនោះ ស្តាប់សំឡេងរំពងដ៏ពីរោះរបស់ព្រះមាន-ព្រះភាគហើយ ឲ្យសាធុការពាន់ដង ទើបអង្គុយចោមរោមព្រះមានព្រះភាគ ។ ឯគទ្រភយក្ខ ទៅព្រៃហិមវន្ត ប្រាប់ដល់អាឡវកយក្ខនោះថា សូមតេជៈ បពិត្រលោកនិរទុក្ខ លោកគប្បីជ្រាប ព្រះមានព្រះភាគប្រថាប់ហើយក្នុងវិមានរបស់

លោក ។ អាឡវកយក្ខនោះ ធ្វើសញ្ញាដល់គទ្រភយក្ខថា លោកចូរស្ងៀមចុះ យើងទៅហើយ នឹងធ្វើវត្តដែលគួរធ្វើ ។ ន័យថា យក្ខនោះកើតសេចក្ដីខ្មាស ក្នុងបរិស័ទ ព្រោះដូច្នោះ ទើបបានធ្វើយ៉ាងនោះ ដោយគិតថា អ្នកណាៗ កុំបានឮត្រង់កណ្ដាលបរិស័ទ ។

ក្នុងកាលនោះ សាតាគិរិយក្ខ និងហេមវតយក្ខ គិតថា យើងថ្វាយបង្គំព្រះមានព្រះភាគក្នុងព្រះជេតពនហើយ នឹងទៅសមាគមយក្ខ ព្រមទាំងបរិវារ ទៅផ្លូវអាកាសដោយយានផ្សេងៗ គ្នា ។ ក៏ក្នុងអាកាសគ្រប់កន្លែង មិនមានផ្លូវសម្រាប់ពួកយក្ខឡើយ ។ ផ្លូវនិងផ្លូវទល់គ្នាដល់វិមាន ដែលអណ្ដែតនៅក្នុងអាកាស ។ ចំណែកវិមានរបស់អាឡវកយក្ខ តាំងនៅលើផែនដី មានអ្នករក្សា លោមព័ទ្ធដោយកំផែង មានខ្លោងទ្វារដែលចាត់ចែងល្អហើយ វិមានកម្ពស់បីយោជន៍ ដូចហិបដែលពាសដោយសំណាញ់មាសពីខាងលើ ខាងលើវិមាននោះ មានផ្លូវដើរ ។ យក្ខទាំងនោះ មកដល់ប្រទេសនោះហើយ មិនអាចនឹងទៅបាន ។ ក៏ក្នុងចំណែកខាងលើឱកាសដែលព្រះពុទ្ធប្រថាប់ហើយ ដរាបដល់ភវគ្គព្រហ្ម អ្នកណាៗ មិនអាចនឹងរំលងទៅបាន ។ យក្ខទាំងនោះរំពឹងថា នេះអ្វីហ្ន៎ ឃើញព្រះមានព្រះភាគហើយ ទើបចុះមកថ្វាយបង្គំ ដូចដុំដីដែលគេ

បោះទៅក្នុងអាកាសហើយធ្លាក់ចុះ ស្តាប់ធម៌ ធ្វើប្រទក្សិណក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពួកខ្ញុំព្រះអង្គនឹងទៅយក្ខសមាគម កាលគេសរសើរវត្ថុបី គឺ ព្រះរតនត្រ័យហើយ បានទៅកាន់យក្ខសមាគម អាឡវកយក្ខ ឃើញយក្ខទាំងនោះ ក៏ថយ បានធ្វើឱកាសថា សូមលោកទាំងឡាយចូរអង្គុយទីនេះចុះ ។ យក្ខទាំងនោះប្រកាសដល់អាឡវកយក្ខថា អាឡវកៈ ជាលាភរបស់លោក ព្រោះព្រះមានព្រះភាគប្រថាប់នៅក្នុងទីនៅរបស់លោក សូមអ្នកមានអាយុចូរចូលទៅអង្គុយជិតព្រះមានព្រះភាគចុះ ។ "ព្រះមានព្រះភាគ ប្រថាប់នៅក្នុងទីនៅយ៉ាងនេះ មិនមែនប្រថាប់នៅត្រង់គល់ដើមជ្រៃ ដែលជាស្ថានទីនៅរបស់អាឡវកយក្ខ ។ ព្រោះហេតុនោះ លោកទើបពោលថា សម័យមួយ ព្រះមាន-ព្រះភាគ ប្រថាប់ក្នុងទីនៅរបស់អាឡវកយក្ខក្នុងក្រុងអាឡវី" ។ គ្រានោះឯងអាឡវកយក្ខ ។ល។ បានពោលពាក្យនោះថា លោកចូរចេញទៅសមណៈ ។ សួរថា ក៏ព្រោះហេតុអ្វី អាឡវកយក្ខនេះ ទើបបានពោលពាក្យនោះ ។ ឆ្លើយថា ព្រោះបំណងនឹងឲ្យសមណៈក្រោធ ។ ក្នុងសេចក្តីនោះ គប្បីជ្រាបសេចក្តីសម្ព័ន្ធចាប់តាំងពីដើមទៅយ៉ាងនេះ ក៏ព្រោះអ្នកមិនមានសទ្ធា បើនិយាយរឿងសទ្ធា ក៏និយាយបានលំបាក ។ ដូចអ្នកទ្រុស្តសីលជាដើម នឹងនិយាយរឿង

សីលជាដើម ក៏និយាយបានដោយលំបាក ដូច្នោះ អាឡវកយក្ខនេះ ស្តាប់ការសរសើរព្រះមានព្រះភាគពីសម្នាក់របស់យក្ខទាំងនោះហើយ ជាអ្នកមានហទយៈព្ធតជៈ តជៈ ព្រោះសេចក្តីក្រោធខាងក្នុង ដូចដុំអំបិលដែលដាក់ក្នុងភ្លើង ទើបនិយាយថា អ្នកណាហ្ន៎ជាព្រះមានព្រះភាគនោះ ដែលចូលទៅកាន់ទីនៅរបស់យើង ។ យក្ខទាំងនោះពោលថា លោកមានអាយុមិនស្គាល់ព្រះមានព្រះភាគដែលជាសាស្តារបស់ពួកយើង កាលពោលដោយន័យជាដើមថា ទ្រង់ស្ថិតនៅក្នុងភពតុសិត ត្រួតមើលមហាវិលោកនៈទាំង ៥ រហូតដល់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ពោលដល់បុព្វនិមិត្ត ៣២ ប្រការក្នុងបដិសន្ធិជាដើម ទើបពោលថា អ្នកមានអាយុ លោកមិនបានឃើញហេតុអស្ចារ្យសូម្បីទាំងនេះ ។ អាឡវកយក្ខនោះ សូម្បីឃើញហើយ ក៏និយាយថាមិនឃើញ ដោយអំណាចសេចក្តីក្រោធ ។ យក្ខទាំងឡាយពោលថា អ្នកមានអាយុ លោកគប្បីឃើញ ឬមិនឃើញក៏ដោយ ប្រយោជន៍អ្វីដោយលោកនឹងឃើញ ឬមិនឃើញ លោកនឹងធ្វើអ្វីព្រះសាស្តារបស់ពួកយើងបាន លោកបើប្រៀបនឹងព្រះសាស្តានោះ ប្រាកដដូចជាកូនគោដែលកើតក្នុងថ្ងៃនោះ ក្នុងទីជិតគោធំដែលទ្រទ្រង់នូវកម្លាំង ឬដូចកូនដំរីជំទង់ ក្នុងទីជិតដំរីចុះប្រេង ឬថា ដូចចចកចាស់ ក្នុងទីជិតស្តេចម្រឹគ

មាន.កលម្អដោយពេម ដែលសំយុងមានពន្លឺភ្លឺផ្លេក ឬក៏ដូចកូនក្អែកបាក់ស្លាប ក្នុងទីជិតស្តេចគ្រុឌ មានទំហំធំ ១៥០ យោជន៍ លោកចូរទៅ ចូរធ្វើកិច្ចដែលលោកគួរធ្វើចុះ ។

កាលពួកយក្ខពោលយ៉ាងនេះ អាឡវកយក្ខក៏ក្រោធ ក្រោកឡើងតន្ត្រំជើងឆ្វេងលើផែនមនោសិលា ពោលថា ថ្ងៃនេះ ពួកអ្នកឯងនឹងបានដឹងថា តើព្រះសាស្តារបស់ពួកអ្នកឯង មានអានុភាពច្រើន ឬថា យើងមានអានុភាពច្រើន ដូច្នេះ ហើយលើកជើងស្តាំជាន់កំពូលភ្នំកៃលាសដែលមានកម្ពស់ប្រមាណ ៦០ យោជន៍ ។ ព្រោះដូច្នោះ ដុំថ្មក៏ខ្ចាយចេញជាបំណែក ដូចដំដោយញញួរដែក គេឈរលើភ្នំនោះ ប្រកាសថា យើងជាអាឡវកយក្ខ ។ សំឡេងក៏ខ្ចរ-ខ្ចាយទៅទូទាំងជម្ពូទ្វីប ។

បានឮថា មនុស្សក្នុងជម្ពូទ្វីប បានឮសំឡេង ៤ យ៉ាងគ្រប់គ្នា គឺ សេនាបតីយក្ខឈ្មោះ **បុណ្ណកៈ** ឈ្នះការភ្នាល់របស់ព្រះបាទធនញ្ជ័យកោរព្យៈ ទះដៃប្រកាសថា យើងឈ្នះហើយ ។ ក្នុងកាលសាសនារបស់ព្រះមានព្រះភាគព្រះនាមថា **កស្សបៈ** សាបសូន្យចុះ សក្កទេវរាជ ជាទេវានមិន្ទ ឲ្យវិស្សុកម្ម-ទេវបុត្រក្លែងជាសុនខ ប្រកាសថា យើងនឹងខាំភិក្ខុអាក្រក់ ភិក្ខុនីអាក្រក់ ឧបា-

សក ឧបាសិកា និងអធម្មវាទីបុគ្គលទាំងពួង ។

កាលព្រះនគរត្រូវព្រះរាជា ៧ ព្រះអង្គ ចូលទៅបិទហើយ ព្រោះមាននាងបភាវតីជាហេតុ ក្នុងកុសជាតក ព្រះមហាបុរសលើកនាងបភាវតីឡើងកាន់កដំរី ចេញទៅអំពីព្រះនគរ ប្រកាសថា យើងជា **សីហស្សរកុសមហារាជ** ។ អាឡវកយក្ខ ឈរលើកំពូលភ្នំកៃលាស ។ ពិតណាស់ ក្នុងគ្រានោះ អាឡវកយក្ខ ក៏បានដូចគ្នានឹងបុគ្គលឈរប្រកាសត្រង់ទ្វារក្នុងសកលជម្ពូទ្វីប ។ មួយទៀត ព្រៃហិមពាន្តទទឹងបីពាន់យោជន៍ ញាប់ញ័រហើយដោយអានុភាពរបស់យក្ខ ។ យក្ខនោះ បណ្ដាលឲ្យខ្យល់ព្យុះកើតឡើង ដោយគិតថា យើងនឹងឲ្យសមណៈចេញទៅដោយខ្យល់ព្យុះទាំងនោះឯង ។ ខ្យល់ទាំងនោះ តាំងឡើងហើយពីទិសខាងកើតជាដើមទៅ ទម្លាយកំពូលភ្នំបានប្រមាណកន្លះយោជន៍ មួយយោជន៍ ពីរយោជន៍ បីយោជន៍ រំលើងដើមឈើក្នុងព្រៃជាដើមទាំងឫសបក់ទៅកាន់អាឡវីនគរ ទម្លាយរោងដំរីចាស់ឲ្យជាកម្ទេចផង់ ។ ក្បឿងប្រក់ក៏អណ្ដែតទៅក្នុងអាកាស ។ ព្រះមានព្រះភាគទ្រង់អធិដ្ឋានថា អន្តរាយចូរកុំមានដល់អ្នកណាៗ ឡើយ ។ ខ្យល់ទាំងនោះ មកដល់ព្រះទសពល ក៏មិនអាចដើម្បីធ្វើឲ្យសូម្បីត្រឹមតែចីវរញ័របាន ។ អំពីនោះ បណ្ដាលឲ្យភ្លៀងធំធ្លាក់

ដោយគិតថា យើងនឹងឲ្យទឹកជន់លិចសមណៈស្លាប់ ។ ពពកតាំងឡើងខាង លើ ញុំាងភ្លៀងឲ្យធ្លាក់ ភ្លៀងរយពាន់មេជាដើម ដោយអានុភាពរបស់យក្ខ នោះ ។ ផែនដីក៏ប្រហោងដោយកម្លាំងទឹកភ្លៀង ។ អន្លង់ទឹកធំជន់មកលើដើម ឈើក្នុងព្រៃជាដើម មិនអាចដើម្បីនឹងឲ្យសូម្បីត្រឹមតែទឹកមួយដំណក់សើមដល់ ចីវរព្រះទសពលបាន ។ អំពីនោះ បណ្តាលឲ្យភ្លៀងដុំថ្មធ្លាក់ កំពូលភ្នំធំៗ មានផ្សែង និងភ្លើងឆេះសន្ធោសន្ធៅ អណ្តែតមកតាមផ្លូវអាកាស មកដល់ ព្រះទសពលក្លាយជាកម្រងផ្កាឈើទិព្វ ។ អំពីនោះ បណ្តាលឲ្យភ្លៀងគ្រឿង សស្ត្រាធ្លាក់ ។ សស្ត្រា មានដាវ លំពែង កូនសជាដើម ដែលមានមុខម្ខាង មានមុខទាំងពីរខាង មានផ្សែង និងភ្លើងឆេះសន្ធោសន្ធៅអណ្តែតមកតាមផ្លូវ អាកាស មកដល់ព្រះទសពលហើយ ក៏ក្លាយជាផ្កាឈើទិព្វ ។ អំពីនោះ បណ្តាល ឲ្យភ្លៀងរងើកភ្លើងធ្លាក់ ។ រងើកភ្លើងមានពណ៌ស្រដៀងផ្កាចារ អណ្តែតមក តាមផ្លូវអាកាស ខ្ចរខ្ចាយជាផ្កាឈើទិព្វធ្លាក់ជិតព្រះបាទព្រះទសពល ។ តពីនោះ បណ្តាលឲ្យភ្លៀងផេះក្តៅធ្លាក់ ។ ផេះក្តៅ ហុយទ្រលោមអណ្តែតមកតាមផ្លូវ អាកាស ធ្លាក់ចុះមកជាលំអិតខ្លឹមចន្ទន៍ជិតព្រះបាទព្រះទសពល ។ អំពីនោះ បណ្តាលឲ្យភ្លៀងខ្សាច់ធ្លាក់ ។ ខ្សាច់ដ៏ល្អិតមានផ្សែង និងភ្លើងឆេះសន្ធោសន្ធៅ

អណ្តែតមកតាមផ្លូវអាកាស ធ្លាក់ចុះមកជាផ្កាឈើទិព្វ ជិតព្រះបាទព្រះទស-ពល ។ អំពីនោះ បណ្តាលឲ្យភ្លៀងកក់ធ្លាក់ ភ្លៀងកក់នោះ មានផ្សែង និងភ្លើងឆេះសន្ធោសន្ធៅអណ្តែតមកតាមផ្លូវអាកាស ធ្លាក់ចុះមកជាគ្រឿងក្រអូបទិព្វជិតព្រះបាទព្រះទសពល ។ អំពីនោះ បណ្តាលឲ្យភាពងងឹតតាំងឡើង ដោយគិតថា យើងនឹងឲ្យសមណៈខ្លាច ហើយគេចចេញទៅ ។ ភាពងងឹតនោះដូចគ្នានឹងភាពងងឹតប្រកបដោយអង្គ ៤ មកដល់ព្រះទសពលក៏បាត់ទៅ ដូចត្រូវពន្លឺព្រះអាទិត្យកម្ចាត់ ដូច្នោះ ។ យក្ខ កាលមិនអាចឲ្យព្រះមានព្រះភាគជៀសចេញទៅបានដោយខ្យល់ព្យុះ ភ្លៀងធំ ភ្លៀងថ្ម ភ្លៀងសស្ត្រា ភ្លៀងរងើកភ្លើង ភ្លៀងផេះក្តៅ ភ្លៀងខ្សាច់ ភ្លៀងកក់ និងដោយសេចក្តីងងឹត រួមទាំង ៩ យ៉ាងនេះ ចូលទៅរកព្រះមានព្រះភាគដោយខ្លួនឯង ដោយសេនាមានអង្គបួន ហែហមដោយពួកភូតបិសាច មានរូបច្រើនយ៉ាង ដើម្បីប្រហារព្រះ-មានព្រះភាគ មានប្រការផ្សេងៗ គ្នា ពួកភូតទាំងនោះ ធ្វើអាការប្លែកចម្លែកច្រើនប្រការហាក់ដូចជានាំគ្នាមកនៅពីលើព្រះមានព្រះភាគ ហើយពោលថា ពួកអ្នកឯងចូរចាប់ ចូរសម្លាប់ចោលចុះ ដូច្នេះ ។ តែក៏មិនអាចចូលទៅជិតព្រះ-មានព្រះភាគបាន ដូចរុយមិនអាចចូលទៅជិតដុំលោហៈដែលក្តៅ ដូច្នោះ ។

សូម្បីយ៉ាងនេះ មារត្រឡប់ហើយក្នុងវេលាមកត្រង់ពោធិមណ្ឌលប៉ុណ្ណោះ យ៉ាងណា ពួកភូតមិនខ្វាចដូច្នោះ បានធ្វើសេចក្តីបៀតបៀនអស់វេលាប្រមាណកន្លះយប់ ។ អាឡវកយក្ខ កាលមិនអាចឲ្យព្រះមានព្រះភាគញាប់ញ័របាន សូម្បីដោយការសម្តែងវត្ថុដែលគួរខ្លាចច្រើនប្រការប្រមាណកន្លះយប់ ដោយអាការយ៉ាងនេះហើយ ទើបគិតថា បើដូច្នោះ មានតែយើងគប្បីចោល ទុស្សាវុធដែលអ្នកណាៗ ធ្វើឲ្យបរាជ័យមិនបាន ដូច្នេះ ។

ន័យថា អាវុធ ៤ យ៉ាង គឺ វជិរាវុធរបស់ស្តេចសក្កៈ ១ គទាវុធរបស់ស្តេចវេស្សវ័ណ ១ នយនាវុធរបស់ស្តេចយមរាជ ១ ទុស្សាវុធរបស់អាឡវកយក្ខ ១ ជាអាវុធប្រសើរក្នុងលោក ។

ក៏បើស្តេចសក្កៈក្រោធ ប្រហារវជិរាវុធលើកំពូលភ្នំសិនេរុ ភ្នំក៏លិចចុះទៅខាងក្រោមបានរហូតដល់ ១៦៨.០០០ យោជន៍ ។ គទាវុធ ដែលស្តេចវេស្សវ័ណគ្រវែងទៅក្នុងវេលាក្រោធ វាយសីសៈរបស់យក្ខច្រើនពាន់ឲ្យធ្លាក់ចុះហើយ ត្រឡប់មកតាំងនៅក្នុងកណ្តាប់ដៃវិញ ។ ដោយហេតុត្រឹមតែស្តេចយមរាជក្រោធ សម្លឹងដោយនយនាវុធ ពួកកុម្ភណ្ឌច្រើនពាន់ ដួលវិនាសទៅ

ដូចស្មៅនៅលើភ្លើងក្តៅ ។ បើអាឡវកយក្ខក្រោធ គប្បីគ្រវែងទុស្សាវុធទៅក្នុងអាកាស ភ្លៀងមិនធ្លាក់រហូតដល់អស់ ១២ ឆ្នាំ បើគ្រវែងទៅលើផែនដី រុក្ខជាតិមានដើមឈើ និងស្មៅទាំងអស់ជាដើម ក្រៀមស្វិតហើយ នឹងមិនដុះឡើងទៀតក្នុងរវាង ១២ ឆ្នាំ ។ បើគ្រវែងទៅក្នុងសមុទ្រ ទឹកនឹងរីងអស់ ដូចតំណក់ទឹកលើភ្លើងក្តៅ ។ បើគ្រវែងទៅត្រង់ភ្នំ សុមេរុភ្នំសិនេរុ ភ្នំក៏ខ្ទាយជាបំណែកតូចធំ ។ អាឡវកយក្ខនោះ គ្រវែងទុស្សាវុធដែលមានអានុភាពច្រើនយ៉ាងនេះ ក៏ក្លាយជាសំពត់ជូតព្រះបាទ ។ ទេវតាជាច្រើនក្នុងម៉ឺនលោកធាតុបានមកប្រជុំគ្នាថា ថ្ងៃនេះ ព្រះមានព្រះភាគនឹងទូន្មានអាឡវកយក្ខ ពួកយើងនឹងស្តាប់ធម៌ក្នុងទីនោះ ។ សូម្បីទេវតាទាំងឡាយ ប្រាថ្នានឹងសរសើរយុទ្ធវិធីក៏មកប្រជុំគ្នាហើយ ។ អាកាសសូម្បីទាំងអស់ បានពេញហើយដោយទេវតាយ៉ាងនេះ ។ គ្រានោះ អាឡវកយក្ខត្រាច់ទៅហើយ ទើបគុបវត្ថាវុធទៅខាងលើជិតព្រះមានព្រះភាគ ។ វត្ថាវុធនោះ បញ្ចេញសំឡេងគួរខ្លាច មានផ្សែងនិងភ្លើងឆេះសន្ធោសន្ធៅក្នុងអាកាសដូចផ្គេកបន្ទោរ មកដល់ព្រះមានព្រះភាគហើយ ធ្លាក់ចុះជិតព្រះបាទក្លាយជាកំណាត់សំពត់ជូតព្រះបាទ ដើម្បីទម្លាយមានះរបស់យក្ខ ។ អាឡវកយក្ខ ឃើញដូច្នោះ ក៏ដល់ភាពជាអ្នកអស់អំណាច

អស់សេចក្ដីក្រអឺតក្រទម ថយចុះនូវមានះដែលរឹងត្អឹង ប្រៀបដូចគោបាក់ស្នែង ដូចពស់ត្រូវដកចង្កូម ទើបគិតថា ទុស្សាវុធរបស់យើងមិនអាចគ្របសង្កត់សមណៈបាន ព្រោះហេតុអ្វីហ្ន៎ ។ ឱ! ព្រោះហេតុតែសមណៈនេះ ប្រកបដោយមេត្តាចិត្តទេតើ ។ បើដូច្នោះ យើងបន្សាត់ចិត្តរបស់សមណៈនោះឲ្យប្រាសចាកនូវមេត្តា ប្រការនោះ លោកពោលទុកដោយសម្ពន្ធដូច្នេះថា គ្រានោះឯងអាឡវកយក្ខ ចូលទៅគាល់ព្រះមានព្រះភាគ ។បេ។ សមណៈ លោកចូរចេញទៅ សមណៈក្នុងសេចក្ដីនោះ មានអធិប្បាយដូច្នេះថា ព្រោះលោកមិនបានទទួលអនុញ្ញាតពីយើង ចូលទៅកាន់ទីនៅរបស់យើងហើយ អង្គុយត្រង់កណ្ដាលផ្ទះ ដូចម្ចាស់របស់ផ្ទះ ប្រការនេះគឺ ការបរិភោគវត្ថុដែលគេមិនបានឲ្យ និងការប្រេបូកប្រេបល់ជាមួយស្ត្រីដែលមិនគួរដល់សមណៈ ដូច្នោះ បើលោកតាំងនៅក្នុងសមណធម៌ សូមលោកចូរចេញទៅចុះ ។ ចំណែកអាចារ្យខ្លះពោលថា អាឡវកយក្ខនេះឯង ពោលពាក្យគ្រោតគ្រាតដទៃទាំងនោះហើយ ទើបបានពោលពាក្យនេះ យ៉ាងនេះ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ដឹងថា អាឡវកយក្ខ ជាអ្នករឹងត្អឹង អ្នកណាៗ ក៏មិនអាចណែនាំដោយភាពរឹងត្អឹងតបវិញបាន ព្រោះថា កាលអ្នកណាៗ ធ្វើសេចក្ដីរឹងត្អឹងតប ក៏ត្រឡប់ជាអ្នក

រឹងត្អឹងឡើងខ្លាំង ដូចអ្នកជះទឹកត្រង់ច្រមុះរបស់សុនខដែលប្រទុសរ៉ាយ សុនខនោះ គប្បីប្រទុសរ៉ាយឡើងដោយប្រមាណក្រៃលែង ដូច្នោះ ចំណែកអាឡ-វកយក្ខ អាចណែនាំបានដោយភាពទន់ភ្លន់ប៉ុណ្ណោះ ដូច្នេះ ទ្រង់ទទួលពាក្យជាទីស្រឡាញ់របស់អាឡវកយក្ខនោះ ដោយព្រះតម្រាស់ជាទីស្រឡាញ់ថា ល្អណាស់ អ្នកមានអាយុ ទើបស្តេចចេញទៅ ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រះមានព្រះភាគ ក៏ស្តេចចេញទៅ ដោយព្រះតម្រាស់ថា ល្អហើយអ្នកមានអាយុ ។ អំពីនោះ អាឡវកយក្ខ ជាអ្នកមានចិត្តទន់ ដោយគិតថា សមណៈនេះ ជាអ្នកប្រដៅងាយ និយាយតែមួង ក៏ចេញទៅ ។ យើងគប្បីគ្របសង្កត់សមណៈអ្នកនៅសប្បាយ ឲ្យចេញទៅបាន តែការច្បាំងអស់មួយយប់ មិនមែនជាហេតុ ដូច្នេះ ទើបគិតទៀតថា យើងមិនអាចដឹងបាន សូម្បីឥឡូវនេះថា សមណៈនេះចេញទៅ ព្រោះជាអ្នកប្រដៅងាយ ឬថា ក្រោធហើយ ទើបចេញទៅ ណ្ហើយចុះ យើងនឹងសាកល្បងមើល ។ លំដាប់នោះទើបពោលថា សមណៈ លោកចូលមកវិញ ។ គ្រានោះ ព្រះមានព្រះភាគកាលត្រាស់ពាក្យជាទីស្រឡាញ់ដល់អាឡវកយក្ខ ដែលយល់ថា សមណៈនេះមានចិត្តទន់ នឹងជាអ្នកប្រដៅងាយទៀត ទ្រង់ធ្វើការកំណត់ចិត្ត ទើបត្រាស់ថា

ល្អហើយ អ្នកមានអាយុ ស្ដេចក៏ចូលទៅ ។ អាឡវកយក្ខសាកល្បងភាពជាអ្នកប្រដៅងាយនោះឯងរឿយៗ ទើបពោលលើកទីពីរ លើកទីបីថា សមណៈចូរចេញមក លោកចូរចេញទៅ សមណៈ លោកចូរចូលមក ដូច្នេះ ។ សូម្បីព្រះមានព្រះភាគទ្រង់បានធ្វើតាមហើយយ៉ាងនោះ ។ បើព្រះមានព្រះភាគមិនគប្បីធ្វើតាមចិត្តរបស់យក្ខដែលរឹងត្អឹង នឹងរឹតតែរឹងត្អឹងឡើងឡើង មិនគប្បីជាភាជនៈនៃធម្មកថា ។ ដូចបុត្រតូច រមែងប្រាថ្នាវត្ថុណា មាតាតែងឲ្យវត្ថុនោះ ឬធ្វើវត្ថុនោះហើយ ទើបលួងលោមបុត្រតូចដែលស្រែកយំឲ្យឈប់យំបាន យ៉ាងណា យក្ខនោះពោលវត្ថុណា ព្រះមានព្រះភាគទ្រង់បានធ្វើវត្ថុនោះ ដើម្បីលួងលោមឲ្យយក្ខដែលស្រែកយំដោយការស្រែកយំ គឺ កិលេសឲ្យឈប់ ដូច្នោះ ។

មួយទៀត មេដោះឲ្យវត្ថុណាមួយសម្រាប់ផឹកដល់ទារក ដែលមិនបានផឹកហើយ ឲ្យបានផឹកយ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះ ឱបរឹតទុកនូវពាក្យដែលពោលហើយដល់យក្ខនោះ ដើម្បីឲ្យយក្ខបានផឹកទឹកដោះ គឺ លោកុត្តរធម៌ ដែលទ្រង់បានធ្វើហើយ ។ មួយទៀត បុរសប្រាថ្នានឹងសម្រេចរបស់ឆ្ងាញ់ ៤ យ៉ាង ឲ្យពេញក្នុងឃ្លោក រមែងជម្រះខាងក្នុងឃ្លោកនោះឲ្យស្អាតយ៉ាងណា ព្រះមានព្រះភាគទ្រង់ប្រាថ្នានឹងដាក់របស់ឆ្ងាញ់ ៤ យ៉ាង គឺ លោ-

កុត្តរធម៌ឲ្យពេញក្នុងចិត្តរបស់យក្ខ ដូច្នោះ ទើបទ្រង់ធ្វើការចេញ និងការចូល ជាបជាប់បីដង ក៏ដើម្បីឲ្យមន្ទិល គឺ សេចក្តីក្រោធខាងក្នុងរបស់យក្ខនោះ អស់ ។ គ្រានោះ អាឡវកយក្ខកើតចិត្តលាមកឡើងថា សមណៈនេះប្រដៅងាយ យើងបង្គាប់ថា លោកចូរចេញ ក៏ចេញ ។ បង្គាប់ថា លោកចូរចូល ក៏ចូល បើដូច្នោះ យើងនឹងឲ្យសមណៈនេះលំបាករហូតអស់មួយយប់ ញ៉ាំងអារុណឲ្យរះ យ៉ាងនេះហើយ គប្បីចាប់ត្រង់ជើងគ្រវែងទៅត្រង់ច្រាំងទន្លេគង្គា ដូច្នេះ ទើបពោលគ្រាទី ៤ ថា លោកចូរចេញ សមណៈ ។

**[៣១៨]** ព្រះមានព្រះភាគទ្រង់ជ្រាបប្រការនោះហើយ ទើបត្រាស់ថា **ន ខ្វាហន្តំ** ។ កាលយក្ខនោះពោលយ៉ាងនេះ ព្រះមានព្រះភាគទ្រង់ជ្រាបថា យក្ខស្វែងរកករណីយកិច្ចដ៏ក្រៃលែងឡើងជាងនោះ នឹងសម្គាល់បញ្ហាដែលគួរសួរប្រការនោះ នឹងជាធម្មកថាមុខ ទើបត្រាស់ថា **ន ខ្វាហន្តំ** ។ សព្ទថា **ន** ក្នុងបទនោះ ចុះក្នុងអត្ថថា បដិសេធ ។ សព្ទថា **ខោ** ចុះក្នុងអត្ថថា អវធារណៈ ។ បទថា **អហំ** គឺ សម្តេចខ្លួន ។ បទថា **តំ** គឺ ពាក្យដែលជាហេតុ ព្រោះហេតុនោះឯង គប្បីឃើញអត្ថក្នុងសេចក្តីនេះយ៉ាងនេះថា ព្រោះអ្នកគិតយ៉ាងនេះ ដូច្នោះ អ្នកមានអាយុ តថាគតនឹងមិនចេញទៅទេ វត្ថុណាដែលអ្នក

គួរធ្វើ អ្នកចូរធ្វើវត្ថុនោះចុះ ។

សូម្បីក្នុងកាលមុន អាឡវកយក្ខធ្លាប់បានសួរបញ្ហាដល់ពួកតាបស និងបរិញ្វជក អ្នកមានឫទ្ធិមកកាន់វិមានរបស់ខ្លួន ក្នុងវេលាទៅតាមផ្លូវអាកាស ដោយការគិតយ៉ាងនេះថា វិមានមាស ឬវិមានប្រាក់ ឬវិមានកែវមណីណាមួយ មាននៅ បានយ៉ាងណាហ្ន៎ ! អើ ! បើដូច្នោះ ពួកយើងនឹងមើលវិមាននោះ ដូច្នេះ កាលមិនអាចឆ្លើយបញ្ហាបាន ទើបបៀតបៀនដោយធ្វើចិត្តឲ្យរវើរវាយ ជាដើម ដូច្នោះ ទើបសម្គាល់ថា យើងនឹងបៀតបៀនសូម្បីព្រះមានព្រះភាគ យ៉ាងនោះ ទើបពោលពាក្យជាដើមថា **បញ្ហំ តំ** ដូច្នេះ ។

សួរថា ក៏បញ្ហា យក្ខនោះរៀនមកពីណា ។ ឆ្លើយថា បានឮថា មាតា បិតារបស់គេចូលទៅរកព្រះមានព្រះភាគព្រះនាមថា **កស្សប:** រៀនបានបញ្ហា ៨ ប្រការ ព្រមទាំងពាក្យឆ្លើយ ។ លោកទាំងនោះ ឲ្យអាឡវកយក្ខរៀនទុក ហើយក្នុងវេលាកម្មោះ ។ គេភ្លេចពាក្យឆ្លើយអស់ដោយកាលកន្លងទៅ ។ តអំពីនោះគិតថា សូម្បីបញ្ហាទាំងនេះចូរកុំវិនាសឡើយ ដូច្នេះ ទើបឲ្យសរសេរ លើផែនមាស សម្រេចដោយជាវហិង្គុលហើយរក្សាទុកក្នុងវិមាន ។ បញ្ហាទាំង នោះ សុទ្ធតែជាបញ្ហារបស់ព្រះពុទ្ធ ទាំងជាវិស័យរបស់ព្រះពុទ្ធប៉ុណ្ណោះ ។

អន្តរាយទាំងឡាយ មានអន្តរាយនៃលាភដែលលះបង់ដើម្បីព្រះពុទ្ធទាំងឡាយ ក្តី អន្តរាយជីវិតក្តី ការកម្ចាត់ព្រះសព្វញ្ញុតញ្ញាណ និងរស្មីមួយព្យាមក្តី អ្នកណាៗ ក៏មិនអាចធ្វើបាន ដូច្នេះ ព្រះមានព្រះភាគទ្រង់ស្តាប់បញ្ហានោះហើយ កាលទ្រង់សម្តែងពុទ្ធានុភាពដែលមិនទូទៅនោះក្នុងលោក ទើបត្រាស់ពាក្យជាដើមថា តថាគតមិនឃើញអ្នកណាឡើយក្នុងលោកព្រមទាំងទេវលោក ។

ព្រះមានព្រះភាគ ទ្រង់ហាមសេចក្តីគិតបៀតបៀនរបស់អាឡវកយក្ខនោះយ៉ាងនេះហើយ កាលឲ្យគេកើតសេចក្តីឧស្សាហ៍ក្នុងការសួរបញ្ហា ទើបត្រាស់ថា ណ្ហើយចុះ អ្នកមានអាយុ អ្នកចូរសួរបញ្ហាតាមដែលអ្នកប្រាថ្នាចុះ ។ សេចក្តីនៃបញ្ហានោះថា បើអ្នកប្រាថ្នានឹងសួរ ចូរអ្នកសួរចុះ ព្រោះថា ការឆ្លើយតបបញ្ហា មិនជារឿងធ្ងន់សម្រាប់តថាគត ។

មួយទៀត ព្រះមានព្រះភាគ ទ្រង់បវារណា (បើកឱកាស) ដោយប្រើសព្វញ្ញុបវារណា ដែលមិនទូទៅដល់ព្រះបច្ចេកពុទ្ធ ព្រះអគ្គសាវក និងមហាសាវកថា ចូរសួរតាមដែលអ្នកចង់ចុះ តថាគតនឹងឆ្លើយបញ្ហានោះទាំងអស់ដល់អ្នក កាលព្រះមានព្រះភាគទ្រង់បវារណា (បើកឱកាស) ដោយប្រើសព្វញ្ញុបវារណាហើយយ៉ាងនេះ លំដាប់នោះ អាឡវកយក្ខ ទើបក្រាបទូលសួរ

ព្រះមានព្រះភាគដោយគាថា ។

[៣១៩] បទថា **កឹសូធ វិត្តំ** សេចក្តីថា អ្វី ជាទ្រព្យក្នុងលោកនេះ ។ បទថា **វិត្តំ** ប្រែថា ទ្រព្យ ។ ក៏ទ្រព្យនោះ រមែងធ្វើសេចក្តីរីករាយចិត្ត ពោល គឺ បីតិ ព្រោះដូច្នោះ ទើបហៅថា ទ្រព្យជាគ្រឿងរីករាយនៃចិត្ត ។ បទថា **សុចិណ្ណំ** ប្រែថា ធ្វើទុកល្អហើយ ។ បទថា **សុខំ** បានដល់ សេចក្តីត្រេកអរ ផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **អាវហាតិ** បានដល់ រមែងនាំមក គឺ រមែង មក គឺ រមែងឲ្យ បានដល់ ផ្តេតស្កប់ស្កល់ ។ បទថា **ហវេ** ជានិបាតចុះក្នុង អត្ថថា មាំ ។ បទថា **សាទុតរំ** បានដល់ ល្អក្រៃលែង ។ ព្រះបាលីថា **សាធុតរំ** ដូច្នេះក៏មាន ។ បទថា **រសានំ** បានដល់ ធម៌ ។ បទថា **កថំ** គឺ ដោយប្រការដូចម្តេច ។ តើជីវិតរបស់អ្នករស់នៅដូចម្តេច ឈ្មោះថា រស់នៅ ប្រសើរ ។ ក៏ **សានុនាសិក** ដើម្បីងាយដល់ការប្រព័ន្ធគាថា ។ ម្យ៉ាងទៀត ព្រះបាលីថា **កឹជីវិំជីវិតំ** សេចក្តីថា ការរស់នៅដូចម្តេចនៃជីវិតរបស់បុគ្គល នោះ ។ អាឡវកយក្ខ ទើបទូលសួរបញ្ហា ៤ ប្រការទាំងនេះ ដោយគាថានេះ យ៉ាងនេះថា

អ្វី ជាទ្រព្យដ៏ប្រសើររបស់បុគ្គលក្នុងលោកនេះ

*អ្វី ដែលបុគ្គលប្រព្រឹត្តល្អហើយនាំសេចក្តីសុខ*

*មកឲ្យ របស់អ្វី ដែលមានរសឆ្ងាញ់ជាងរសទាំង*

*ឡាយ អ្នកប្រាជ្ញទាំងឡាយពោលថា បុគ្គលរស់*

*នៅដូចម្តេច ឈ្មោះថា រស់នៅប្រសើរ ។*

**[៣២០]** *លំដាប់នោះ កាលព្រះមានព្រះភាគ នឹងទ្រង់វិសជ្ជនាតាមន័យដែលព្រះកស្សបទសពលទ្រង់វិសជ្ជនាដល់គេ ទើបត្រាស់គាថា នេះថា* ***សទ្ធីធ វិត្តំ*** *ជាដើម ។ គប្បីជ្រាបពាក្យថា ទ្រព្យក្នុងគាថានោះ ទ្រព្យជាគ្រឿងរីករាយនៃចិត្ត មានមាសប្រាក់ជាដើម រមែងនាំមកនូវសេចក្តីសុខក្នុងការប្រើប្រាស់ រមែងការពារសេចក្តីទុក្ខដែលកើតអំពីសេចក្តីស្រេកឃ្លានជាដើម រមែងរម្ងាប់ភាពក្រលំបាក រមែងជាហេតុឲ្យបានកែវមុនី មុក្តាជាដើម និងរមែងនាំមកនូវការបន្តនៃលោក យ៉ាងណា សូម្បីសទ្ធា ទាំងដែលជាលោកិយៈ និងលោកុត្តរៈ រមែងនាំមកនូវវិបាកជាសុខ ទាំងជាលោកិយៈ និងលោកុត្តរៈ តាមដែលកើតឡើង រមែងការពារទុក្ខ មានជាតិ និងជរាជាដើម របស់អ្នកបដិបត្តិតាមនាទីរបស់សទ្ធា រមែងរម្ងាប់សេចក្តីក្រនៃគុណ និងជាហេតុឲ្យបាននូវរតនៈមានសតិសម្ពោជ្ឈង្គៈជាដើម ដូច្នោះ* ***សទ្ធា*** *លោកពោលថា ជាទ្រព្យគ្រឿង*

វិកការនៃចិត្ត ព្រោះបាត់ថា រមែងនាំមកនូវសេចក្តីបន្តនៃលោក តាមព្រះពុទ្ធ-

វចនៈថា ៖

*អ្នកមានសទ្ធា ដល់ព្រមដោយសីល បរិបូណ៌ដោយយស*

*និងភោគៈ ទៅកាន់ទីណាៗ គេរមែងបូជាក្នុងទីនោះៗ ។*

ក៏ព្រោះទ្រព្យ គឺ សទ្ធានេះ ជាធម៌ជាប់តាមទៅ មិនទូទៅដល់អ្នកដទៃ ជាហេតុនៃសម្បត្តិទាំងពួង ជាមូលនៃទ្រព្យ មានមាស និងប្រាក់ជាដើមដែលជាលោកិយៈ ។ ពិតណាស់ អ្នកមានសទ្ធា កាលធ្វើបុណ្យ មានទានជាដើម រមែងបាននូវទ្រព្យ ។ ចំណែកអ្នកមិនមានសទ្ធា មានចិត្តមិនជាប្រយោជន៍ប៉ុណ្ណោះ ព្រោះដូច្នោះ ទ្រព្យគ្រឿងវិកការនៃចិត្ត គឺ សទ្ធា លោកទើបពោលថា ជាទ្រព្យដ៏ប្រសើរ ។ បទថា **បុរិសស្ស** គឺ សម្តែងការកំណត់យ៉ាងឧក្រិដ្ឋ ។ ព្រោះដូច្នោះ ទ្រព្យ គឺ សទ្ធា សូម្បីរបស់ស្ត្រីជាដើម ក៏គប្បីជ្រាបថា ប្រសើរ មិនមែនរបស់បុរសតែម្យ៉ាង ប៉ុណ្ណោះ ។ បទថា **ធម្មោ** គឺ កុសលធម៌ ១០ ឬធម៌ មានទាន និងសីលជាដើម ។ បទថា **សុចិណ្ណោ** បានដល់ ធ្វើល្អហើយ គឺ ប្រព្រឹត្តល្អហើយ ។ បទថា **សុខមាវហាតិ** សេចក្តីថា នាំមកនូវសេចក្តីសុខរបស់មនុស្ស ដូចសេចក្តីសុខរបស់សោណសេដ្ឋីបុត្ត និងព្រះរដ្ឋបាលជាដើម

សេចក្តីសុខជាទិព្វ ដូចសេចក្តីសុខរបស់ព្រះឥន្ទ្រ និងនិព្វានសុខ ដូចសេចក្តីសុខរបស់ព្រះមហាបទុមជាដើម ដែលជាទីបំផុតនៃសេចក្តីសុខ ។ **សច្ចៈ** សព្ទនេះ ក្នុងបទថា **សច្ចំ** រមែងប្រាកដក្នុងអត្ថជាច្រើន ពោលគឺ **ប្រាកដក្នុងវាចាសច្ចៈ** ក្នុងបទជាដើមថា គប្បីពោលពាក្យសច្ចៈ មិនគប្បីក្រោធជាដើម ។ **ប្រាកដក្នុងវិរតិសច្ចៈ** ក្នុងបទជាដើមថា សមណព្រាហ្មណ៍ តាំងនៅក្នុងសច្ចៈ ដូច្នេះ ។ **ប្រាកដក្នុងទិដ្ឋិសច្ចៈ** ក្នុងបទជាដើមថា អ្នកទាំងឡាយ ជាអ្នកពោលសច្ចៈផ្សេងៗគ្នា ហើយក៏ជាអ្នកតាំងនៅក្នុងកុសលទៀត ម្តេចក៏នៅតែទាស់គ្នា ដូច្នេះ ។ **ប្រាកដក្នុងព្រាហ្មណសច្ចៈ** ក្នុងបទថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណសច្ចៈមាន ៤ យ៉ាងនេះ ។ **ប្រាកដក្នុងបរមត្ថសច្ចៈ** ក្នុងបទជាដើមថា សច្ចៈមានតែមួយ មិនមានទី ២ ដូច្នេះ ។ **ប្រាកដក្នុងអរិយសច្ចៈ** ក្នុងបទជាដើមថា សច្ចៈ ៤ តើមានកុសលប៉ុន្មាន ។ តែក្នុងទីនេះ លោកបំណងយកវាចាសច្ចៈ ធ្វើបរមត្ថសច្ចឲ្យជានិព្វាន និងធ្វើវិរតិសច្ចៈឲ្យទៅជាខាងក្នុង ។ សមណព្រាហ្មណ៍រមែងញ៉ាំងទឹក គឺ សច្ចៈ ឲ្យប្រព្រឹត្តទៅក្នុងអំណាចដោយអានុភាពនៃសច្ចៈ រមែងឆ្លងត្រើយនៃជាតិ ជរា និងមរណៈបាន ។ សច្ចៈ (នោះ) ដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

គេរាប់ទឹកដោយពាក្យសច្ច បណ្ឌិតរមែងកម្ចាត់ពិសបាន
ដោយពាក្យសច្ចៈ ភ្លៀងធ្លាក់ចុះដោយសច្ចៈ សមណព្រាហ្មណ៍
អ្នកតាំងនៅក្នុងសច្ចៈ រមែងប្រាថ្នាសេចក្តីស្ងប់ រសណា
នីមួយមាននៅលើផែនដី រសនៃសច្ចៈប្រសើរជាងរសដែល
នៅលើផែនទុំះ ។ សមណព្រាហ្មណ៍អ្នកតាំងនៅក្នុងសច្ចៈ
រមែងឆ្លងត្រើយនៃជាតិ ជរា និងមរណៈបាន ។

បទថា សាធុតរំ សេចក្តីថា ប្រសើរជាង ពីរោះជាង ប្រណីតជាង ។ បទថា រសានំ សេចក្តីថា រសទាំងនេះ មានលក្ខណៈដែលគប្បីលិទ្ធបាន ដោយន័យជាដើមថា រសដែលកើតអំពីឫស រសដែលកើតអំពីដើម ។ ការនៅដោយធម៌ជាគ្រឿងកម្ចាត់កិលេស វៀរទោស និងព្យញ្ជនៈដ៏សេសជាដើមពួកណាមួយ លោកហៅថា ធម្មរស ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរសផ្លែឈើទាំងពួង ព្រះគោតមដ៏ចម្រើន មានរូបមិនមានរស ម្នាលព្រាហ្មណ៍ រសនៃរូប រសនៃសំឡេងណាមួយ មិនជាអាបត្តិព្រោះរស ។ ធម្មវិន័យនេះ មានរសតែមួយ គឺ វិមុត្តិជារស ។ ព្រះមានព្រះភាគទ្រង់ជាអ្នកមានចំណែកនៃអត្ថរស នៃធម្មរស ។ ក្នុងរសទាំងនោះ ។ ពាក្យសច្ចៈទុំះឯង

ប្រសើរជាង សច្ចៈនោះឯងល្អជាង ។ ឬថា បទថា **សាធុតរំ** ប្រែថា ប្រសើរជាង ក្រៃលែងជាង ។ ពិតហើយ រសនៃឫសជាដើម រមែងញ៉ាំងរាងកាយឲ្យជំធាត់ ។ ឈ្មោះថា នាំមកនូវសេចក្តីសុខ ដែលប្រកបដោយសង្កិលេស ។ រសនៃសច្ចៈ គឺ រសនៃវិរតិសច្ចៈ និងវាចាសច្ចៈ រមែងឧបត្ថម្ភដល់សមថៈ និងវិបស្សនាជាដើម ។ ឈ្មោះថា នាំមកនូវសេចក្តីសុខ ដែលមិនប្រកបដោយសង្កិលេស ។ **វិមុត្តិរស** ឈ្មោះថា ល្អ ព្រោះមានរស គឺ បរមត្ថសច្ចៈដែលបានអប់រំហើយ ។ អត្ថរស និងធម្មរសក៏ដូចគ្នា ។ ព្រោះអាស្រ័យអត្ថ និងធម៌ ដែលជាឧបាយឲ្យសម្រេចវិមុត្តិរសនោះ ប្រព្រឹត្តទៅ ។

ក៏ក្នុងបទថា **បញ្ញាជីវី** នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា អ្នកមានភ្នែកខ្វាក់ម្ខាង ឬទាំងសងខាង បុគ្គលដែលមានភ្នែកខ្វាក់ម្ខាង ឬទាំងសងខាងនេះ សូម្បីជាគ្រហស្ថ បំពេញវត្តបដិបត្តិរបស់គ្រហស្ថ មានការឧស្សាហ៍ធ្វើការងារ ជាអ្នកដល់នូវសរណៈ ជាអ្នកចែកទាន សមាទានសីល និងរក្សាឧបោសថជាដើម ឬជាបព្វជិតបំពេញវត្តបដិបត្តិរបស់បព្វជិត ពោលគឺ សីលដែលមិនឲ្យក្តៅក្រហាយ មានចិត្តវិសុទ្ធិដ៏ក្រៃលែងជាដើម ដោយបញ្ញា លោកពោលថា ជីវិតរបស់អ្នករស់នៅដោយបញ្ញានោះ គឺ ជាជីវិតប្រសើរបំផុត ។

**[៣២១]** *យក្ខបានស្តាប់បញ្ហាទាំង ៤ ដែលព្រះមានព្រះភាគទ្រង់វិសជ្ជនាយ៉ាងនេះហើយ ក៏ពេញចិត្ត កាលនឹងសួរបញ្ហាដ៏សេស ៤ ប្រការទៀត ទើបពោលពាក្យសួរថា* ***កថំសុ តរតិ ឱឃំ*** *ដូច្នេះ (បុគ្គលឆ្លងឱឃៈបានដោយអ្វី) ជាដើម ។*

**[៣២២]** *លំដាប់នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់វិសជ្ជនាដោយន័យមុន ទើបត្រាស់គាថាថា* ***សទ្ធាយ តរតិ*** *ជាដើម (បុគ្គលឆ្លងឱឃៈបានដោយសទ្ធា) ។ ក្នុងសេចក្តីនោះ បុគ្គលណាឆ្លងឱឃៈ ៤ យ៉ាងបាន បុគ្គលនោះរមែងឆ្លងអន្លង់សង្សារក៏បាន កន្លងផុតវដ្តទុក្ខក៏បាន រមែងបរិសុទ្ធិចាកមន្ទិល គឺ កិលេសក៏បាន កាលបើដូច្នោះ អ្នកមិនមានសទ្ធា កាលមិនជឿក៏ឆ្លងឱឃៈមិនបាន ។ អ្នកប្រមាទហើយ ដោយការបណ្តោយចិត្តទៅក្នុងកាមគុណ ៥ ក៏ឆ្លងអន្លង់សង្សារមិនបាន ព្រោះជាប់នៅក្នុងកាមគុណនោះ ។ បុគ្គលខិលប្រឡូសទាំងលាយឡំដោយអកុសលធម៌ រមែងនៅជាទុក្ខ អ្នកមិនមានបញ្ញាមិនដឹងផ្លូវបរិសុទ្ធិ រមែងមិនបរិសុទ្ធិ ព្រោះដូច្នោះ កាលព្រះមាន-ព្រះភាគទ្រង់សម្តែងភាពជាបដិបក្ខនោះ ទើបត្រាស់គាថានេះ ។ ក៏កាលត្រាស់គាថានេះ យ៉ាងនេះហើយ ព្រោះសទ្ធិន្ទ្រិយជាបទដ្ឋាននៃសោតាបត្តិយង្គៈ ដូច្នោះ*

ទើបទ្រង់ប្រកាសសោតាបត្តិមគ្គ ដែលជាគ្រឿងឆ្លងឱឃៈ គឺ ទិដ្ឋិ និងឲ្យបាន សោតាបន្ន ដោយបទនេះថា **សទ្ធាយ តរតិ ឱឃំ** (បុគ្គលឆ្លងឱឃៈបាន ដោយសទ្ធា) ។ ក៏ព្រោះព្រះសោតាបន្នមិនប្រកបដោយសេចក្តីប្រមាទ ពោល គឺ ធ្វើកិច្ចជាប់តគ្នា ដោយការចម្រើនកុសលធម៌ បំពេញមគ្គទី ២ វៀរមគ្គ ដែលនឹងមកកាន់លោកនេះចេញត្រឹមតែមួយភ្លែតប៉ុណ្ណោះ រមែងឆ្លងអន្លង់- សង្សារ ដែលជាទីតាំងនៃភវោឃៈដ៏សេស ដែលឆ្លងមិនបានដោយសោតាបត្តិ- មគ្គ ដូច្នោះ ទើបទ្រង់ប្រកាសសកទាគាមិមគ្គ ដែលជាគ្រឿងឆ្លងភវោឃៈ និង ព្រះសកទាគាមី ដោយបទនេះថា **អប្បមាទេន អណ្ណវំ** (បុគ្គលរមែងឆ្លងសមុទ្រ បានដោយសេចក្តីមិនប្រមាទ) ដូច្នេះ ។ កាលព្រះសកទាគាមីបំពេញមគ្គទី ៣ ដោយសេចក្តីព្យាយាម រមែងកន្លងបង់នូវកាមទុក្ខ ដែលជាទីតាំងនៃកាមោឃៈ និងកំណត់ថា ជាកាមោឃៈដែលមិនទាន់បានកន្លង ដោយសកទាគាមិមគ្គ ដូច្នោះ ទើបទ្រង់ប្រកាសអនាគាមិមគ្គ ដែលជាគ្រឿងឆ្លងកាមោឃៈ និងឲ្យបានជា ព្រះអនាគាមី ដោយបទនេះថា **វីរយេន ទុក្ខមច្ចេតិ** (បុគ្គលរមែងកន្លងសេចក្តី ទុក្ខបានដោយសេចក្តីព្យាយាម ដូច្នេះ) ។ កាលព្រះអនាគាមីបំពេញបញ្ញានៃ មគ្គទី ៤ ដែលបរិសុទ្ធិដោយចំណែកមួយ ដោយបញ្ញាដ៏បរិសុទ្ធិ ប្រាសចាក

កក់ គឺ កាម លះមន្ទិលដ៏ក្រៃលែង ពោលគឺ អវិជ្ជាដែលលះមិនបាន ដោយអនាគាមិមគ្គ ដូច្នោះ ទើបទ្រង់ប្រកាសអរហត្តមគ្គ និងឲ្យបានសម្រេចជាព្រះអរហន្ត ដែលជាគ្រឿងឆ្លងអវិជ្ជា ដោយបទនេះថា **បញ្ញាយ បរិសុជ្ឈតិ** (បុគ្គលរមែងបរិសុទ្ធិដោយបញ្ញា) ដូច្នេះ ។ ក៏ក្នុងទីបំផុតនៃគាថាដែលព្រះមានព្រះ-ភាគត្រាស់ដោយធម៌ មានព្រះអរហត្តជាទីបំផុតនេះ យក្ខក៏បានតាំងនៅក្នុងសោតាបត្តិផល ។

**[៣២៣]** ឥឡូវនេះ យក្ខកាន់យកបទថា បញ្ញា ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងបទនេះថា **បញ្ញាយ បរិសុជ្ឈតិ** នោះ កាលនឹងសួរបញ្ហាដែលលាយដោយលោកុត្តរៈ ដោយបដិភាណរបស់ខ្លួន ទើបទូលសួរគាថា ៦ បទនេះថា **កថំសុ លភតេ បញ្ញំ** (បុគ្គលរមែងបានបញ្ញាដោយអ្វី) ជាដើម ។ ក្នុងបទទាំងនោះ បទថា **កថំសុ** ជាពាក្យសួរដែលមិនយុត្តិក្នុងទីទាំងពួង ។ ពិតណាស់ យក្ខនេះដឹងអត្ថ មានបញ្ញាជាដើមហើយ ទើបសួរយុត្តិនៃអត្ថនោះថា បុគ្គលរមែងបានបញ្ញាដោយអ្វី គឺ ដោយយុត្តិអ្វី ដោយហេតុអ្វី ។

**[៣២៤]** ក្នុងទ្រព្យជាដើម ក៏មានន័យនេះឯង ។ លំដាប់នោះ ព្រះមាន-ព្រះភាគកាលនឹងទ្រង់សម្ដែងការបានបញ្ញាដោយហេតុ ៤ យ៉ាង ដល់យក្ខនោះ

ទើបត្រាស់ពាក្យថា **សទ្ទហានោ** ជាដើម ។ គប្បីជ្រាបសេចក្តីនៃធម៌នោះ (ដូចតទៅនេះ) ព្រះអរហន្ត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវករបស់ព្រះពុទ្ធ បានដល់និព្វានដោយធម៌ដែលផ្សេងដោយកាយសុចរិតជាដើម ក្នុងខាងដើម និងផ្សេងដោយពោធិបក្ខិយធម៌ ៣៧ ប្រការក្នុងខាងចុង យ៉ាងណា បុគ្គលជឿធម៌របស់ព្រះអរហន្តនោះ ទើបបានបញ្ញា ទាំងជាលោកិយៈ និងលោកុត្តរៈដើម្បីសម្រេចព្រះនិព្វាន ។ ក៏ការបាននោះ រមែងមិនបានដោយធម៌ត្រឹមតែសទ្ធាប៉ុណ្ណោះ ។ ក៏ព្រោះបុគ្គលមានសទ្ធាហើយ តែងចូលទៅរក កាលចូលទៅរក ក៏ចូលទៅអង្គុយជិត កាលចូលទៅអង្គុយជិត រមែងផ្ទៀងត្រចៀក ផ្ទៀងត្រចៀកហើយ រមែងស្តាប់ធម៌ ដូច្នោះ ចាប់ផ្តើមតាំងពីចូលទៅរក ដរាបដល់បានស្តាប់ធម៌ ស្តាប់ដោយល្អហើយ រមែងបាន (បញ្ញា) ។ តើលោកពោលទុកយ៉ាងណា ។ លោកពោលទុកថា គេជឿធម៌នោះហើយ ចូលទៅរកអាចារ្យឧបជ្ឈាយ៍តាមកាលវេលា ចូលទៅអង្គុយជិត ថ្វាយបង្គំដោយការធ្វើវត្តបដិបត្តិ កាលណាមានចិត្តត្រេកអរក្នុងការចូលទៅអង្គុយជិត គឺ រមែងជាអ្នកប្រាថ្នានូវអ្វីណាមួយៗ កាលនោះគេតែងផ្ទៀងត្រចៀកស្តាប់ ព្រោះភាពជាអ្នកប្រាថ្នាដើម្បីស្តាប់ រមែងបាននូវ (បញ្ញា) ។ សូម្បីកាលគេតាំង

ចិត្តស្តាប់យ៉ាងនេះហើយ ជាអ្នកមិនប្រមាទដោយមិនទៅប្រាសចាកសតិ ជាអ្នកពិចារណាដោយភាពជាអ្នកដឹងពាក្យសុភាសិត និងទុព្ភាសិត ក៏រមែងបាន (បញ្ញា) ដូចគ្នា ។ មិនមែនអ្នកអំពីក្រៅនេះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ជាអ្នកមិនប្រមាទ ជាអ្នកពិចារណា ដូច្នេះ ។ ព្រោះគេបដិបត្តិតាមវត្តបដិបត្តិដែលប្រព្រឹត្តទៅដើម្បីបានបញ្ញាដោយសទ្ធា ស្តាប់ឧបាយជាគ្រឿងចូលដល់បញ្ញាដោយការតាំងចិត្តស្តាប់ គឺ ដោយសេចក្តីគោរព មិនវង្វេងភ្លេចក្នុងធម៌ដែលទ្រទ្រង់ទុកហើយ ដោយសេចក្តីមិនប្រមាទ កាន់យកមិនលើសមិនខ្វះ និងសេចក្តីមិនខុស ធ្វើឲ្យពិស្តារដោយភាពជាអ្នកពិចារណា ឬជាអ្នកផ្ទៀងត្រចៀកដោយការតាំងចិត្តស្តាប់ហើយ ស្តាប់ធម៌ដែលជាហេតុបានបញ្ញា លុះស្តាប់ដោយសេចក្តីមិនប្រមាទហើយ ទ្រទ្រង់ចាំធម៌ ពិចារណាអត្ថនៃធម៌ដែលទ្រទ្រង់ចាំទុកហើយ ដោយការពិចារណា ធ្វើបរមត្ថសច្ចៈឲ្យជាក់ច្បាស់ដោយលំដាប់ ព្រោះដូច្នោះ ព្រះមានព្រះភាគត្រូវសួរថា **កថំសុ លភតេ បញ្ញំ** (បុគ្គលបានបញ្ញាដោយអ្វី) កាលនឹងទ្រង់សម្តែងហេតុ ៤ យ៉ាងនេះ ដល់អាឡវកយក្ខនោះ ទើបត្រាស់គាថានេះថា **សទ្ទហានោ** ។ល។ **វិចក្ខណោ** ដូច្នេះ ។ ឥឡូវនេះ កាលនឹងទ្រង់វិសជ្ជនាបញ្ហា ៣ ប្រការដទៃអំពី

នោះ ទើបត្រាស់គាថានេះថា **បដិរូបការី** ជាដើម ។ ក្នុងគាថានេះ បុគ្គលណាមិនធ្វើកាលទេសៈជាដើមឲ្យវិនាសអស់ ធ្វើការងារឲ្យសមគួរ គឺ ឲ្យជាឧបាយដែលនឹងបានទ្រព្យជាលោកិយៈក្តី និងលោកុត្តរៈក្តី ហេតុនេះ បុគ្គលនោះទើបឈ្មោះថា **បដិរូបការី** (បុគ្គលមានការងារសមគួរតាមកាល) ។ បទថា **ធុរវា** គឺ មិនដាក់ធុរៈ ដោយអំណាចសេចក្តីព្យាយាមផ្លូវចិត្ត ។ បទថា **ឧដ្ឋាតា** សេចក្តីថា ប្រកបដោយសេចក្តីឧស្សាហ៍ ដោយអំណាចសេចក្តីព្យាយាមផ្លូវកាយ មានសេចក្តីតស៊ូពុះពារមិនធូរថយ ដោយន័យជាដើមថា ក៏បុគ្គលណា មិនសម្គាល់សេចក្តីត្រជាក់ និងក្តៅឲ្យក្រៃលែងទៅជាងស្មៅ ។ បទថា **វិន្ទតេ ធនំ** សេចក្តីថា បុគ្គលរមែងបានលោកិយទ្រព្យ ដូចចូឡកន្តេវាសីសេដ្ឋី បានទ្រព្យ ៤ សែនដោយមិនយឺតយូរ ព្រោះអាស្រ័យកណ្តុរមួយ និងបានលោកុត្តរទ្រព្យ ដូចព្រះមហាតិស្សត្ថេរៈបួសក្នុងវ័យចាស់ ។ ព្រះថេរៈគិតថា យើងនឹងនៅដោយឥរិយាបថ ៣ ប៉ុណ្ណោះ ដូច្នេះ ហើយធ្វើវត្តបដិបត្តិក្នុងវេលាងងុយដេក ក៏យកស្លឹកឈើជ្រលក់ទឹកដាក់លើសីសៈ ចុះទឹកប្រមាណត្រឹម.កដើម្បីកម្ចាត់សេចក្តីងងុយដេក លោកបានសម្រេចព្រះអរហត្តក្នុងវស្សាទី ១០ ។ បទថា **សច្ចេន** សេចក្តីថា បុគ្គលរមែងបានទទួលកិត្តិស័ព្ទយ៉ាងនេះ

ថា ជាអ្នកពោលពាក្យសត្យៈ ពោលពាក្យពិតដោយវចីសច្ចៈខ្លះ ថាជាព្រះ-ពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវក ដោយបរមត្ថសច្ចៈខ្លះ ។ បទថា **ទទំ** សេចក្តីថា បុគ្គលឲ្យវត្ថុណានីមួយដែលគេប្រាថ្នាត្រូវការ តែងធ្វើនូវការចង តែងបង្កើននូវមិត្តទាំងឡាយបាន ។ ឬថា អ្នកឲ្យរបស់មិនល្អ ក៏រមែងបាន របស់មិនល្អ ។ ឬថា សង្គហវត្ថុ ៤ គប្បីជ្រាបថា លោកក៏កាន់យកទានជាប្រធាន ។ លោកពោលទុកថា បុគ្គលរមែងចងពួកមិត្តបានដោយការឲ្យនោះ ។

គ្រាព្រះមានព្រះភាគទ្រង់វិសជ្ជនាបញ្ហា ៤ ប្រការ ដោយន័យដែលលាយដោយលោកិយៈ និងលោកុត្តរៈចូលគ្នា ទាំងគ្រហស្ថ និងបព្វជិតយ៉ាងនេះហើយ ឥឡូវនេះទ្រង់វិសជ្ជនាបញ្ហាទី ៥ នេះថា **កថំ បេច្ច ន សោចតិ** (បុគ្គលស្លាប់ទៅហើយនឹងមិនសោកសៅដោយអ្វី ទើបត្រាស់ពាក្យជាដើមថា **យស្សេតេ** ដូច្នេះ ។

គប្បីជ្រាបសេចក្តីនៃប្រការនោះ (ដូច្នេះ) គ្រហស្ថអ្នកបរិភោគកាមមានសទ្ធា ព្រោះប្រកបដោយសទ្ធាដែលជាហេតុឲ្យកើតកល្យាណធម៌ទាំងពួងដែលត្រាស់ទុកក្នុងបទនេះថា **សទ្ទហានោ អរហតំ** (ជឿធម៌របស់អរហន្ត) ជាអ្នកគ្រប់គ្រងផ្ទះ បរិភោគនូវកាមគុណ ឬជាអ្នកស្វែងរកនូវកាមគុណ ៥ ក្នុង

ពាក្យនេះថា **សទ្ធស្ស ឃរមេសិនោ** (អ្នកគ្រប់គ្រងផ្ទះ) មានធម៌ ៤ យ៉ាងនេះ គឺ សច្ចៈ ដូចដែលត្រាស់ទុកហើយក្នុងបទនេះថា **សច្ចេន កិត្តឹ បប្បោតិ** (បុគ្គល រមែងបានទទួលកិត្តិស័ព្ទដោយពាក្យសត្យៈ) ធម៌ដែលត្រាស់ទុកហើយថា ដែលឈ្មោះថា បញ្ញា រមែងបានព្រោះការស្ដាប់ដោយល្អ ដូចក្នុងបទនេះថា **សុស្សូសំ លភតេ បញ្ញំ** (កាលស្ដាប់ដោយល្អ រមែងបាននូវបញ្ញា) ធិតិដែលត្រាស់ទុកហើយ ដែលឈ្មោះថា ធុរៈ និងដែលឈ្មោះថា ឧស្សាហ៍ ក្នុងបទនេះថា **ធុរវា ឧដ្ឋាតា** (ជាអ្នកមានធុរៈ និងជាអ្នកមានសេចក្ដីតស៊ូ) និងចាគៈ ដូចដែលត្រាស់ទុកហើយក្នុងបទនេះថា **ទទំ មិត្តានិ គន្ថតិ** អ្នកឲ្យរមែងចងពួកមិត្តបាន ។ បទថា **ស វេ បេច្ច ន សោចតិ** សេចក្ដីថា បុគ្គលលះលោកនេះទៅកាន់លោកដទៃ រមែងមិនសោកសៅក្នុងលោកទាំងពីរ ។

កាលព្រះមានព្រះភាគទ្រង់វិសជ្ជនាបញ្ហាទី ៥ យ៉ាងនេះហើយ កាលនឹងជាស់តឿនយក្ខនោះ ទើបត្រាស់ពាក្យជាដើមថា **ឥង្ឃ អញ្ញេបិ** (ចូរសួរធម៌សូម្បីដទៃទៀតចុះ ។

ក្នុងបទទាំងនោះ បទថា **ឥង្ឃ** ជានិបាតចុះក្នុងអត្ថនៃពាក្យជាស់តឿន ។ បទថា **អញ្ញេបិ** សេចក្ដីថា ចូរសួរធម៌ដទៃចំពោះសមណព្រាហ្មណ៍ជាច្រើន

ទៀតចុះ ។ ឬថា ចូរសួរសមណព្រាហ្មណ៍ជាច្រើនដែលបេជ្ញាខ្លួនថា ជាសព្វញ្ញូ មានបូរណកស្សបៈជាដើម សូម្បីដទៃទៀតចុះ ។ ឬថា បើនឹងមានហេតុដែលបានទទួលកិត្តិស័ព្ទឲ្យក្រៃលែងជាងសច្ចៈ ដូចដែលតថាគតពោលទុកហើយក្នុងបទនេះថា **សច្ចេន កិត្តឹ បប្បោតិ** (បុគ្គលរមែងបានទទួលកិត្តិស័ព្ទដោយពាក្យសត្យៈ) ។ ឬថា នៅមានហេតុឲ្យបានទទួលលោកិយបញ្ញា និងលោកុត្តរបញ្ញាដែលក្រៃលែងជាងទមៈ ដែលព្រះមានព្រះភាគត្រាស់ទុកដោយអាងដល់បញ្ញាថា **សុស្សូសា** ក្នុងបទថា **សុស្សូសំ លភតេ បញ្ញំ** (កាលតាំងចិត្តស្តាប់ដោយល្អ រមែងបាននូវបញ្ញា) ។ ឬថា ហេតុជាគ្រឿងចងនូវមិត្តដែលក្រៃលែងជាងចាគៈ ដូចដែលត្រាស់ទុកហើយក្នុងបទនេះថា **ទទំ មិត្តានិ គន្ថតិ** (អ្នកឲ្យរមែងចងពួកមិត្តបាន) ។ ឬថា ហេតុដែលជាគ្រឿងឲ្យបានលោកិយទ្រព្យនិងលោកុត្តរទ្រព្យដែលក្រៃលែងជាងខន្តិ ពោលគឺ សេចក្តីព្យាយាម ដោយអត្ថថា នាំទៅនូវភារៈដ៏ធ្ងន់ តាមដែលទ្រង់អាស្រ័យអំណាចនៃហេតុនោះៗត្រាស់ទុកហើយ ដោយឈ្មោះថា ធុរៈ និងដោយសេចក្តីឧស្សាហ៍ ក្នុងបទនេះថា **ធុរវា ឧដ្ឋាតា** ។ ឬថា ហេតុដែលមិនសោកសៅ ព្រោះលះអំពីលោកនេះទៅកាន់លោកដទៃ ឲ្យក្រៃលែងជាងធម៌ ៤ យ៉ាងនេះ ដែលត្រាស់ទុកយ៉ាង

នេះថា **សច្ចំ ធម្មោ ធិតិ ចាគោ** នេះជាការពណ៌នាសេចក្តីព្រមទាំងការភ្ជាប់សេចក្តីដោយសន្ធេបក្នុងបទនេះថា **ឥធ វិជ្ជតិ** ដូច្នេះ (មាននៅក្នុងលោកនេះ) តែគប្បីចែកបទមួយៗ ដោយន័យដែលលើកអត្ថ លើកបទ និងពណ៌នាបទ ហើយជ្រាបការពណ៌នាអត្ថដោយពិស្តារ ។

កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ យក្ខនឹងគប្បីសួរសមណព្រាហ្មណ៍ដទៃដោយសេចក្តីសង្ស័យណា ព្រោះជាអ្នកលះបង់សេចក្តីសង្ស័យនោះហើយ ទើបពោលថា ឥឡូវនេះខ្ញុំព្រះអង្គនឹងគប្បីសួរសមណព្រាហ្មណ៍ជាច្រើនដូចម្តេចកើត ដូច្នេះ កាលនឹងឲ្យអ្នកដែលនៅមិនដឹងហេតុ ដែលមិនសួរឲ្យដឹង ទើបពោលថា **យោហំ អជ្ជ បជានាមិ យោ អត្ថោ សម្បរាយិកោ** ដូច្នេះ (ថ្ងៃនេះខ្ញុំព្រះអង្គទើបតែដឹងថា ប្រយោជន៍ណាមាននៅក្នុងសម្បរាយភព) ។

**[៣២៥]** ក្នុងបទទាំងនោះ បទថា **អជ្ជ** អធិប្បាយថា កំណត់វេលាមានក្នុងថ្ងៃនេះជាដើម ។ បទថា **បជានាមិ** គឺ ដឹងដោយប្រការតាមដែលត្រាស់ហើយ ។ បទថា **យោ អត្ថោ** សេចក្តីថា ទ្រង់សម្តែងវត្តបដិបត្តិក្នុងបច្ចុប្បន្នដែលត្រាស់ទុកហើយដោយន័យថា **សុស្សូសំ លភតេ បញ្ញំ** (បុគ្គល

កាលស្តាប់ដោយល្អ រមែងបាននូវបញ្ញា) ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ទ្រង់សម្តែងវត្តបដិបត្តិក្នុងលោកខាងមុខ ដែលធ្វើការលះលោកនេះទៅហើយ មិនមានសេចក្តីសោកសៅ ដែលត្រាស់ទុកហើយថា **យស្សេតេ ចតុរោ ធម្មា** (អ្នកណាមានធម៌ ៤ យ៉ាងនេះ) ដោយបទថា **សម្បរាយិកោ** ដូច្នេះ ។ ក៏បទថា **អត្ថោ** នេះ ជាឈ្មោះរបស់ហេតុ ។ ពិតណាស់ ស័ព្ទថា **អត្ថ** នេះ រមែងប្រព្រឹត្តទៅក្នុងអត្ថនៃបាឋៈ ក្នុងបទទាំងឡាយជាដើមយ៉ាងនេះថា **សាត្ថំ សព្យញ្ជនំ** (ព្រមដោយអត្ថ ព្រមដោយព្យញ្ជនៈ) ។ ប្រព្រឹត្តទៅក្នុងសេចក្តីត្រូវការ ក្នុងបទជាដើមថា **អត្ថោ មេ គហបតិ ហិរញ្ញសុវណ្ណេន** ម្នាលគហបតី យើងត្រូវការប្រាក់ និងមាស ។ ប្រព្រឹត្តទៅក្នុងសេចក្តីចម្រើន ក្នុងបទជាដើមថា **ហោតិ សីលវតំ អត្ថោ** (សេចក្តីចម្រើនរមែងមានដល់អ្នកមានសីល) ។ ប្រព្រឹត្តទៅក្នុងទ្រព្យ ក្នុងបទជាដើមថា **ពហុជនោ ភជ្ជតេ អត្ថហេតុ** (មនុស្សជាច្រើនបែកគ្នាព្រោះទ្រព្យ) ។ ប្រព្រឹត្តទៅក្នុងប្រយោជន៍ ក្នុងបទជាដើមថា **ឧភិន្នមត្ថំ ចរតិ** (រមែងប្រព្រឹត្តប្រយោជន៍ដល់លោកទាំងពីរ) ។ ប្រព្រឹត្តទៅក្នុងហេតុ ក្នុងបទជាដើមថា **អត្ថេ ជាតេ ច បណ្ឌិតំ** (ក៏កាលហេតុកើតឡើង រមែងត្រូវការបណ្ឌិត) ។ ក៏ឯស័ព្ទថា **អត្ថ** ក្នុងទីនេះ

ប្រព្រឹត្តទៅក្នុងហេតុ ។ ព្រោះដូច្នោះ ហេតុនៃការបានបញ្ញាជាដើម ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នយ៉ាងណា និងហេតុនៃសេចក្តីលះលោកនេះទៅហើយមិនមានសេចក្តីសោកសៅប្រព្រឹត្តទៅក្នុងសម្បរាយភពយ៉ាងណា យើងរមែងដឹងហេតុនោះឯងតាមន័យដែលព្រះមានព្រះភាគត្រាស់ហើយក្នុងថ្ងៃនេះ ឥឡូវនេះ យើងនឹងគប្បីសួរសមណព្រាហ្មណ៍ជាច្រើនដូចម្តេចទៀត ដូច្នេះ គប្បីជ្រាបសេចក្តីដោយសន្ធេបក្នុងសេចក្តីនេះ យ៉ាងនេះ ។

យក្ខទើបពោលយ៉ាងនេះថា **បជានាមិ យោ អត្ថោ សម្បរាយិកោ** (ហេតុណាដែលមានក្នុងសម្បរាយភពយើងបានដឹង) កាលនឹងសម្តែងសេចក្តីដែលញាណនោះជាមូលរបស់ព្រះមានព្រះភាគ ទើបពោលថា **អត្ថាយ វត មេ ពុទ្ធោ** (ព្រះពុទ្ធស្តេចមកប្រថាប់ក្នុងក្រុងអាឡវីដើម្បីជាប្រយោជន៍ដល់យើង) ។

ក្នុងបទទាំងនោះ បទថា **អត្ថាយ** គឺ ដើម្បីប្រយោជន៍ ឬដើម្បីសេចក្តីចម្រើន ។ បទថា **យត្ថ ទិន្នំ មហប្ផលំ** សេចក្តីថា ទានដែលឲ្យក្នុងព្រះពុទ្ធព្រះអង្គណាមានផលច្រើន យើងស្គាល់ព្រះពុទ្ធទ្រង់ជាអគ្គទក្ខិណេយ្យ-បុគ្គលព្រះអង្គនោះដោយចាគៈ ដែលត្រាស់ទុកក្នុងបទថា **យស្សេតេ ចតុរោ**

ធម្មា (បិគ្គលណាមានធម៌ ៤ យ៉ាងនេះ) ។ តែអាចារ្យពួកខ្លះពោលថា ទ្រង់សំដៅយកព្រះសង្ឃ ទើបត្រាស់យ៉ាងនេះ ។ គ្រាយក្ខសម្តែងការសម្រេចប្រយោជន៍ដល់ខ្លួនដោយគាថានេះ យ៉ាងនេះហើយ ឥឡូវនេះនឹងសម្តែងវត្តបដិបត្តិដើម្បីប្រយោជន៍ដល់អ្នកដទៃ ទើបពោលពាក្យជាដើមថា យេីងនោះនឹងត្រាច់ទៅ ។

ក្នុងបទទាំងនោះ បទថា **គាមា គាមំ** សេចក្តីថា អំពីទេវគ្រាមទៅកាន់ទេវគ្រាម ចាកពីទេវនគរទៅកាន់ទេវនគរ ។ បទថា **នមស្សមានោ សម្ពុទ្ធំ ធម្មស្ស ច សុធម្មតំ** សេចក្តីថា ការត្រាស់ដឹងដោយល្អរបស់ព្រះពុទ្ធ និងជាធម៌ដ៏ល្អនៃព្រះធម៌ ដោយន័យជាដើមថា ព្រះមានព្រះភាគ ត្រាស់ដឹងប្រពៃដោយព្រះអង្គឯងហ្ន៎ ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ ល្អហើយ ។ ដោយអំណាច ច សព្ទ ក៏ជាការពោលថា ខ្ញុំនឹងត្រាច់សរសើរហើយៗ នូវការបដិបត្តិដ៏ល្អរបស់ព្រះសង្ឃ ខ្ញុំព្រះអង្គនមស្ការហើយ ប្រកាសនូវធម៌ ដោយបទជាដើមថា ព្រះសង្ឃសាវករបស់ព្រះមានព្រះភាគបដិបត្តិល្អហើយហ្ន៎ ដូច្នេះ ។ ក្នុងទីបំផុតនៃគាថានេះ អរុណក៏ប្រាកដ ការបញ្ចេញសំឡេងឲ្យសាធុការ ការនាំអាឡវកកុមារមកកាន់ទីនៅរបស់យក្ខ បានមានក្នុងខណៈតែមួយព្រមគ្នា

ដោយប្រការដូច្នេះ ។ ពួករាជបុរសបានឮសំឡេងសាធុការហើយ នឹកថា សំឡេងសាធុការបែបនេះ រមែងមិនបន្លឺឡើងសម្រាប់មនុស្សពួកដទៃ វៀរ ព្រះពុទ្ធ ព្រះមានព្រះភាគស្តេចមកហើយហ្ន៎ បានឃើញរស្មីព្រះសរីរៈរបស់ ព្រះមានព្រះភាគ មិនឈរខាងក្រៅដូចមុន អស់សេចក្តីសង្ស័យ ហើយចូល ទៅនៅខាងក្នុង ឃើញព្រះមានព្រះភាគប្រថាប់គង់នៅក្នុងទីនៅរបស់យក្ខ និង ឃើញយក្ខឈរផ្គងអញ្ជលី ទើបពោលនឹងយក្ខថា ម្នាលមហាយក្ខ ព្រះរាជ-កុមារនេះ គេនាំមកដើម្បីពលីកម្មដល់លោក អញ្ជើញលោកចូរទំពារស៊ី ឬ អញ្ជើញស៊ីគេ ឬធ្វើតាមត្រូវការចុះ ។ យក្ខនោះខ្មាស ព្រោះខ្លួនជាព្រះសោ-តាបន្ន និងកាលត្រូវគេពោលយ៉ាងនេះចំពោះព្រះភ័ក្ត្រព្រះមានព្រះភាគ ដោយ ពាក្យប្លែក ទើបយកដៃទាំងពីរត្រកងព្រះកុមារនោះ បង្អោនចូលទៅរកព្រះ-មានព្រះភាគ ដោយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កុមារនេះគេបញ្ជូន មកឲ្យខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមថ្វាយកុមារនេះចំពោះព្រះមានព្រះភាគ ធម្មតា ព្រះពុទ្ធទាំងឡាយជាអ្នកអនុគ្រោះដោយប្រយោជន៍ សូមព្រះមានព្រះភាគមេត្តា ទទួលក្មេងនេះ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ក្មេងនេះចុះព្រះអង្គ ។ ក៏យក្ខនោះ ពោលគាថានេះថា ៖

ខ្ញុំព្រះអង្គពេញចិត្ត ត្រេកអរថ្វាយកុមារនេះដែលមានបុញ្ញ-
លក្ខណៈទាំងវាយសព្វព្រះកាយ មានទ្រង់ទ្រាយបរិបូណ៌
ចំពោះព្រះអង្គ សូមព្រះអង្គអ្នកមានចក្ខុ មេត្តាទទួលទុក
ដើម្បីជាប្រយោជន៍ ដល់សត្វលោកចុះ ។

ព្រះមានព្រះភាគទ្រង់ទទួលកុមារទុកហើយ ។ កាលទ្រង់នឹងទទួល ក៏ពោលគាថា ៣ បាទ ដើម្បីធ្វើមង្គលដល់យក្ខ និងកុមារ ។ យក្ខញុាំង កុមារនោះឲ្យដល់ព្រះអង្គជាសរណៈ ឲ្យបរិបូណ៌ដោយបាទទី ៤ ដល់ ៣ ដង គឺ ៖

កុមារនេះ ចូរមានអាយុវែង ម្នាលយក្ខអ្នកចូរមាននូវ
សេចក្តីចម្រើន និងមានសេចក្តីសុខ ចូរជាអ្នកមិនឈឺ តាំង
នៅដើម្បីជួយជាប្រយោជន៍ដល់សត្វលោក កុមារនេះ ចូល
ដល់ព្រះពុទ្ធជាសរណៈ ។

កុមារនេះ ចូរមានអាយុវែង ម្នាលយក្ខ អ្នកចូរមាន
នូវសេចក្តីចម្រើន និងមានសេចក្តីសុខ ចូរជាអ្នកមិនឈឺ
តាំងនៅដើម្បីជាប្រយោជន៍ដល់សត្វលោក កុមារនេះ ចូល

ដល់ព្រះធម៌ជាសរណៈ ។

កុមារនេះ ចូរមានអាយុវែង ម្នាលយក្ខ អ្នកចូរ
មាននូវសេចក្តីចម្រើន និងមានសេចក្តីសុខ ចូរជាអ្នកមិន
ឈឺ តាំងនៅដើម្បីជាប្រយោជន៍ដល់សត្វលោក កុមារនេះ
ចូលដល់ព្រះសង្ឃជាសរណៈ ។

ព្រះមានព្រះភាគ បានប្រទានកុមារដល់ពួករាជបុរសដោយព្រះតម្រាស់ថា អ្នកទាំងឡាយ ចូរញ៉ាំងកុមារនេះឲ្យចម្រើន ហើយសឹមបញ្ជូនឲ្យតថាគតវិញ ។ កុមារនោះ ទើបមានឈ្មោះថា **ហត្ថកអឡវកៈ** ព្រោះទៅកាន់ដៃយក្ខអំពីដៃរបស់ពួករាជបុរស ទៅកាន់ព្រះហស្តរបស់ព្រះមានព្រះភាគអំពីដៃយក្ខ ហើយទៅកាន់ដៃរបស់ពួករាជបុរសអំពីព្រះហស្តរបស់ព្រះមានព្រះភាគទៀត ។ អ្នកស្រែ និងអ្នកធ្វើការងារក្នុងព្រៃជាដើម ឃើញពួករាជបុរសនាំកុមារនោះត្រឡប់មក ខ្លាច ហើយសួរថា យក្ខមិនត្រូវការកុមារព្រោះនៅក្មេងពេកឬ ។ ពួករាជបុរសប្រាប់រឿងទាំងអស់ថា លោកទាំងឡាយកុំខ្លាចឡើយ ព្រោះព្រះ-មានព្រះភាគធ្វើភ័យឲ្យបាត់ហើយ ដូច្នេះ ។ អំពីនោះមក អ្នកនគរអាឡវីទាំងអស់ ក៏ពោលថា ល្អហើយៗ បែរមុខឆ្ពោះទៅរកយក្ខ ដោយសំឡេងគឹកកងៗ

ដូចគ្នាតែម្យ៉ាង លាន់ឡើង ។

កាលដល់វេលាដែលព្រះមានព្រះភាគស្តេចទៅភិក្ខាចារ សូម្បីយក្ខក៏កាន់បាត្រចីវរមកពាក់កណ្តាលផ្លូវ ទើបត្រឡប់ ។ កាលព្រះមានព្រះភាគស្តេចត្រាច់ទៅបិណ្ឌបាត ទ្រង់ធ្វើកត្តកិច្ចស្រេចហើយ ប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរដែលគេក្រាលទុកល្អហើយ ត្រង់គល់ឈើដែលស្វាត់ត្រង់កន្លែងមួយជិតទ្វារក្រុង ។ តពីនោះ ព្រះរាជា និងអ្នកក្រុងព្រមដោយជនពួកធំ រួមគ្នាតែមួយ ចូលទៅគាល់ព្រះមានព្រះភាគថ្វាយបង្គំហើយ អង្គុយចោមរោម ហើយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ទូន្មានយក្ខដែលកាចបានយ៉ាងណា ។ ព្រះមានព្រះភាគទ្រង់ធ្វើនូវការច្បាំង (ប្រាប់) ដល់រាជបុរសទាំងនោះជាដើម ហើយត្រាស់ថា យក្ខញាំងភ្លៀង ៩ ប្រភេទឲ្យធ្លាក់យ៉ាងនេះ ធ្វើឲ្យគួរស្ញុតខ្លាចយ៉ាងនេះ សួរបញ្ហាយ៉ាងនេះ តថាគតវិសជ្ជនាដល់យក្ខនោះយ៉ាងនេះ ទើបត្រាស់អាឡវកសូត្រនោះ ។

ក្នុងទីបំផុតនៃធម្មកថា ធម្មាភិសម័យបានមានដល់ប្រជាជន ៨៤.០០០ តអំពីនោះមក ព្រះរាជា និងអ្នកក្រុងធ្វើទីនៅរបស់យក្ខក្នុងទីជិតទីនៅរបស់ស្តេចវេស្សវ័ណមហារាជផ្លាស់គ្រឿងសក្ការៈ មានផ្កាឈើ គ្រឿងក្រអូបជាដើម

ឲ្យជាគ្រឿងជន្លាយជាប្រចាំ ។ គេព្រលែងកុមារនោះអ្នកដល់កាលជាវិញ្ញូជន ហើយថា លោកអាស្រ័យព្រះមានព្រះភាគ ទើបបានជីវិត ចូរទៅ ចូលទៅអង្គុយជិតព្រះមានព្រះភាគ និងភិក្ខុសង្ឃ ។ ហត្ថកអាវឡកៈនោះ ចូលទៅអង្គុយជិតព្រះមានព្រះភាគ និងភិក្ខុសង្ឃ ខាងក្រោយមកមិនយូរក៏តាំងនៅក្នុងអនាគាមិផល រៀនព្រះពុទ្ធវចនទាំងពួង មានឧបាសក ៥០០ ជាបរិវារ ។ ព្រះមានព្រះភាគ ទ្រង់ប្រកាសគេទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយកំពូលរបស់ឧបាសកជាសាវករបស់តថាគត អ្នកសង្គ្រោះប្រជុំជនដោយវត្ថុ ៤ គឺ ហត្ថកអាឡវកៈ ។

ចប់អដ្ឋកថា អាឡវកសូត្រទី ១២

## ចប់យក្ខសំយុត្ត ត្រឹមតែប៉ុណ្ណេះ

### រួមក្នុងវគ្គនេះមាន ១២ អដ្ឋកថា


១-អដ្ឋកថាឥន្ទកសូត្រ
២-អដ្ឋកថាសក្កសូត្រ
៣-អដ្ឋកថាសូចិលោមសូត្រ
៤-អដ្ឋកថាមណិភទ្ទសូត្រ
៥-អដ្ឋកថាសានុសូត្រ
៦-អដ្ឋកថាបិយង្ករសូត្រ
៧-អដ្ឋកថាបុនព្វសុសូត្រ
៨-អដ្ឋកថាសុទត្តសូត្រ
៩-អដ្ឋកថាបឋមសុក្កាសូត្រ
១០-អដ្ឋកថាទុតិយសុក្កាសូត្រ
១១-អដ្ឋកថាចីរសូត្រ
១២-អដ្ឋកថាអាឡវកសូត្រ

# សក្កសំយុត្ត វគ្គទី ១

## អ ដ្ឋ ក ថា

### សុវីរសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងសុវីរសូត្រទី ១ នៃវគ្គទី ១ តទៅនេះ ៖*

**[៣២៧]** *បទថា **អភិយំសុ** គឺសួរថា ច្បាំងគ្នាក្នុងកាលណា ។ ឆ្លើយថា ក្នុងកាលណាមានកម្លាំង (ខ្លាំងជាង) ក្នុងកាលនោះក៏ច្បាំងតវិញ ។ ក្នុងសូត្រនោះ មានអនុបុព្វិកថាដូច្នេះ បានឮថា ស្ដេចសក្កៈជាមាណព ឈ្មោះ **មឃៈ** ក្នុងអចលគ្រាមក្នុងដែនមគធៈ នាំបុរស ៣០ នាក់ ធ្វើកល្យាណកម្ម បំពេញវត្តបទ ៧ ធ្វើកាលៈក្នុងទីនោះហើយទៅកើតក្នុងទេវលោក ។ ទេវតាពួកចាស់ៗ ជាម្ចាស់ទីកន្លែង ឃើញមឃមាណពនោះព្រមទាំងបរិស័ទប្រកបទៅដោយឋានៈ ១០ ដោយអានុភាពនៃកម្មដ៏ខ្លាំងក្លា គិតថា ទេវបុត្រដែលជាអាគន្តុកៈមកហើយ ទើបត្រៀមទឹកគន្ធបានៈដើម្បីផឹក ។ សក្កៈទេវរាជបានឲ្យពាក្យជាស់តឿនដល់បរិស័ទជាបរិវាររបស់ខ្លួនថា ម្នាលអ្នកនិរទុក្ខ អ្នកកុំផឹកទឹកគន្ធបានៈ ចូរសម្ដែងត្រឹមតែអាការផឹកប៉ុណ្ណោះ ។ ពួកគេបានធ្វើយ៉ាងនោះ ។*

ទេវបុត្រម្ចាស់ទឹកខ្មៅងផឹកទឹកគន្ធបាន: ដែលគេនាំចូលទៅឲ្យដោយពែងមាស តាមត្រូវការ ក៏ស្រវឹងដួលដេកនៅលើផែនដីមាសក្នុងទីនោះៗ ។ សក្កទេវរាជ ពោលថា អ្នកទាំងឡាយ ចូរចាប់ពួកគេទាំងមេទាំងកូនទៅ ដូច្នេះ ហើយចាប់ គ្រវែងជើងគ្រវែងទៅកាន់ជើងភ្នំសិនេរុ ។ ទេវបុត្រទាំងពួងសូម្បីនៅសល់ ក៏ ទៅធ្លាក់ចុះក្នុងទីនោះ ដោយតេជ:នៃបុណ្យរបស់សក្កទេវរាជ ។ ទេវបុត្រ ទាំងនោះដឹងខ្លួនក្នុងវេលាដែលខ្លួននៅកណ្តាលភ្នំសិនេរុ ទើបពោលថា ពួកយើង មិនផឹកសុរាផង ពួកយើងមិនបានផឹកសុរាផង ។ ចាប់តាំងពីនោះ ទើបបាន ឈ្មោះថា អសុរ ។ ខាងក្រោយមក ដែនអសុរមានប្រមាណមួយម៉ឺនយោជន៍ ដែលតាំងឡើងតាមរដូវ ព្រោះបច្ច័យនៃកម្មរបស់ពួកគេ ក៏កើតឡើងក្នុងផ្ទៃ ខាងក្រោមនៃភ្នំសិនេរុ ។ សក្កទេវរាជ តាំងការរក្សាដើម្បីត្រូវការមិនឲ្យទេវ-បុត្រទាំងនោះត្រឡប់មក ។ លោកពោលសំដៅសេចក្តីថា ៖

ការឃុំគ្រងរក្សា ៥ យ៉ាង តាំងនៅក្នុងចន្លោះក្រុង
ដែលមិនមានអ្នកណាច្បាំងបានទាំងពីរ គឺ នាគ គ្រុឌ កុម្ភណ្ឌ
យក្ខ និងមហារាជទាំង ៤ ។

ពិតណាស់ ក្រុងទាំងពីរ គឺ ទេវនគរ និងអសុរនគរ ឈ្មោះថា ជា

ក្រុង ដែលមិនមានអ្នកណាច្បាំងបាន ក៏ព្រោះជាក្រុងដែលមិនអាចដណ្តើមយកដោយការច្បាំង ក៏កាលណាពួកអសុរមានកម្លាំងខ្លាំងជាង កាលនោះពួកទេវតាក៏គេចចូលទៅកាន់ក្រុង ទ្វារក្រុងក៏បិទ សូម្បីពួកអសុរទាំងសែន ក៏មិនអាចនឹងធ្វើអ្វីបាន ។ កាលណាពួកទេវតាមានកម្លាំងខ្លាំងជាង កាលនោះពួកអសុរគេចចូលទៅកាន់ក្រុង ទ្វារក្រុងក៏បិទ សូម្បីពួកសក្កទេវរាជទាំងសែន ក៏មិនអាចនឹងធ្វើអ្វីបាន ។ ក្រុងទាំង ២ នេះ ទើបឈ្មោះថា **ក្រុងអយុជ្ឈា** ដោយប្រការដូច្នេះ ។

សក្កទេវរាជតាំងរក្សាទុកក្នុងទី ៥ កន្លែង មានទាគជាដើមនេះ ចន្លោះក្រុងទាំង ២ នោះ ក្នុងស្ថានទី ៥ កន្លែង ។ ក្នុងទីនោះ ពួកនាគ លោកកាន់យកដោយសព្ទថា ទឹក ។

ពិតណាស់ ពួកនាគនោះ មានកម្លាំងនៅក្នុងទឹក ។ ការការពាររបស់ពួកនាគនោះនៅត្រង់ជួរទី ១ នៃភ្នំសិនេរុនោះ ។ ពួកគ្រុឌ កាន់យកដោយសព្ទថា **ករោដិ** ។ បានឮថា បាយ និងទឹករបស់ពួកគ្រុឌនោះ ឈ្មោះ **ករោដិ** ពួកគ្រុឌបានឈ្មោះតាមបាយ និងទឹកនោះ ការការពាររបស់ពួកគ្រុឌនោះនៅត្រង់ជួរទី ២ ។ ពួកកុម្ភណ្ឌ កាន់យកដោយសព្ទថា **បយស្សុករិ** ។

បានព្រួថា ពួកកុម្ភណ្ឌនោះ ជាពួកទានព និងរក្ខសៈ ។ ការការពារ របស់ពួកកុម្ភណ្ឌទាំងនេះ នៅត្រង់ជួរទី ៣ ។ ពួកយក្ខកាន់យកដោយស័ព្ទថា ទមនយុទ្ធ ។ បានព្រួថា ពួកយក្ខនោះ ជាអ្នកបង្ក្រាបពួកអ្នកលេងដែលប្រព្រឹត្ត មិនរៀបរយ ។ ការការពាររបស់ពួកយក្ខនេះនៅត្រង់ជួរទី ៤ ។ បទថា ចតុរោ ច មហត្តា គឺ មហារាជទាំង ៤ ដែលពោលហើយ ។ ការការពាររបស់ មហារាជទាំងនេះនៅត្រង់ជួរទី ៥ ។ ព្រោះដូច្នោះ បើពួកអសុរក្រោធ មានចិត្ត ទោមនស្ស ក៏ចូលទៅកំទេចក្រុងរបស់ពួកទេវតាក្នុងការច្បាំង ។ ទីណាជា ព្រំដែនដំបូងនៃភ្នំពួកនាគ រមែងការពារទីនោះ ។ ពួកដទៃដ៏សេស ក៏ការពារ ទីដទៃដ៏សេស ។ ឯពួកអសុរនោះ ដូចគ្នានឹងទេវតាជាន់តាវត្តឹង្ស ដោយសម្បត្តិ គឺ អាយុ ពណ៌សម្បុរ កិត្តិយស និងភាពជាធំ ។ ព្រោះដូច្នោះ ពួកគេទើប មិនដឹងខ្លួន ក្នុងចន្លោះកាលនៃផ្កាជ្រទៀងរីក ទើបដឹងថា នេះមិនមែនក្រុង របស់ទេវតា ផ្កាបារិឆត្តរីកក្នុងក្រុងរបស់ទេវតានោះ តែក្នុងទីនេះ មានដើម ជ្រទៀង ពួកយើងត្រូវពួកសក្កៈចាស់ បញ្ឆោតឲ្យផឹកសុរា ឯយើងនឹងទៅ កាន់ទេវនគរវិញ ពួកយើងនឹងដណ្តើម យើងនឹងច្បាំងជាមួយពួកទេវនគរនោះ ដូច្នេះ ហើយឡើងជិះដំរី សេះ និងរថ ប្រដាប់ដោយមាស ប្រាក់ កែវមណី

និងកែវផលឹក ត្រៀមច្បាំង សំឡេងស្គររបស់អសុរ ញែកទឹកក្នុងមហាសមុទ្រ ចេញជា ២ ចំណែក ត្រៀមស្រេចហើយ ។ ក្នុងវេលានោះ ពួកអសុរនោះ ច្បាំងជាមួយពួកនាគជាគ្រាដំបូង ។ ក្នុងការច្បាំងនោះ សម្បុរ ឬស្បែករបស់អ្នកណាៗ មិនដាច់ ។ ឈាមក៏មិនចេញ ។ ត្រឹមតែញ៉ាំងគ្នានិងគ្នាឲ្យក្តៅក្រហាយ ដូចពួកក្មេងយកពពៃឈើជល់គ្នាប៉ុណ្ណោះ ។ ពួកនាគទាំងរយកោដិ ពាន់កោដិច្បាំងជាមួយពួកអសុរនោះ បណ្តេញពួកអសុរនោះទៅកាន់ក្រុងអសុរ ហើយ ទើបត្រឡប់មក ។

កាលណាពួកអសុរមានកម្លាំងខ្លាំងជាង កាលនោះពួកនាគក៏ដកថយ ទៅរួបរួមគ្នាជាមួយពួកគ្រុឌ ច្បាំងក្នុងជួរទី ២ ។ សូម្បីក្នុងពួកគ្រុឌជាដើម ក៏មានន័យនេះ ។ តែកាលណាពួកអសុរញាំញីទីទាំង ៥ កន្លែងនោះបាន កាលនោះ ៥ កងពល ដកថយទៅរួបរួមគ្នាតែមួយ ។ ក្នុងខណៈនោះ មហារាជទាំង ៤ ចូលទៅក្រាបទូលការប្រព្រឹត្តទៅនៃចម្បាំងដល់ស្តេចសក្កៈ ។ សក្កទេវរាជស្តាប់ពាក្យក្រាបទូលរបស់មហារាជនោះហើយ ទើបស្តេចឡើងកាន់វេជយន្តរថកម្ពស់ ១៥០ យោជន៍ ចេញទៅដោយខ្លួនឯង ឬបញ្ជូនព្រះឱរសមួយអង្គទៅ ។ ក្នុងវេលានោះ សក្កទេវរាជត្រូវការនឹងបញ្ជូនព្រះឱរសទៅ

ទើបពោលពាក្យជាដើមថា ម្នាលបាសុវីរៈ ដូច្នេះ ។

បទថា ឯវំ កទ្ធនុវាតិ ខោ សេចក្តីថា (សុវីរទេវបុត្រពោលថា ) ករុណាថ្ងៃវិសេស ដូច្នេះឯង ។ បទថា បមាទំ អាបាទសិ ប្រែថា បានធ្វើសេចក្តីប្រមាទ ។ អធិប្បាយថា សុវីរទេវបុត្រ មាននាងទេពអប្សរមួយពាន់ហែហម ចុះកាន់ថ្នល់ធំសម្រេចដោយមាសប្រវែង ៦០ យោជន៍ ត្រាច់លេងនក្ខត្រនៅក្នុងសួននន្ទនវ័នជាដើម ។

**[៣២៨]** បទថា **អនុដ្ឋហំ** ប្រែថា មិនឧស្សាហ៍ ។ បទថា **អវាយាមំ** ប្រែថា មិនព្យាយាម ។

**[៣២៩]** បទថា **អលស្វាយំ** កាត់បទថា **អលសោ អយំ** ប្រែថា នេះខ្ជិលច្រអូស ។ បទថា **ន ច កិច្ចានិ ការយេ** ប្រែថា មិនធ្វើកិច្ចអ្វីៗ ។ បទថា **សព្វកាមសមិទ្ធស្ស** ប្រែថា ជាអ្នកសម្រេចដោយកាមគុណទាំងពួង ។ បទថា **តម្មេ សក្កវរំ ទិស** សេចក្តីថា សុវីរទេវបុត្រពោលថា បពិត្រស្តេចសក្កៈដ៏ប្រសើរបំផុតរបស់ពួកទេវៈ មេត្តាចង្អុល គឺ ប្រាប់នូវវត្ថុដ៏ប្រសើរ គឺឋានៈដែលខ្ពស់បំផុត ឱកាសនោះដល់ខ្ញុំ ។

**[៣៣២]** បទថា **និព្វានស្ស ហិ សោ មគ្គោ** សេចក្តីថា ផ្លូវនៃនិព្វាន

ឈ្មោះថា ឋានដែលមិនធ្វើកម្មដើម្បីជីវិត ។

ចប់អដ្ឋកថា សុវីរសូត្រ ទី ១

# អ ដ្ឋ ក ថា

## សុសិមសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុងសុសិមសូត្រ ទី ២ តទៅនេះ ៖

**[៣៣៥]** បទថា សុសិមំ គឺ បុត្រមួយអង្គ មានឈ្មោះយ៉ាងនេះ ក្នុងចំណោមបុត្រមួយពាន់អង្គរបស់សក្កទេវរាជ ។

ចប់អដ្ឋកថា សុសិមសូត្រទី២

# អ ដ្ឋ ក ថា

## ធជគ្គសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យ ក្នុងធជគ្គសូត្រទី ៣ តទៅនេះ ៖

[៣៨៣] បទថា *សមុបព្យូឡ្ហា* គឺ ប្រជុំគ្នា រួមគ្នាជាកង ។ បទថា *ធជគ្គំ ឧល្លោកេយ្យាថ* សេចក្តីថា បានឮថា រថរបស់ស្តេចសក្កៈប្រវែង ១៥០ យោជន៍ ផ្នែកខាងក្រោយនៃរថនោះប្រវែង ៥០ យោជន៍ កណ្តាលតួរថប្រវែង ៥០ យោជន៍ ផ្នែកក្បាលនៃរថប្រវែង ៥០ យោជន៍ ។ អាចារ្យពួកខ្លះពង្រីកប្រមាណនោះជា ២ ស្មើគ្នា ពោលថា ប្រវែង ៣០០ យោជន៍ខ្លះ ។ ក្នុងរថនោះ តាំងទុកនូវបល្ល័ង្កប្រមាណមួយយោជន៍ តាំងឆត្រសកម្ពស់ ៣ យោជន៍ ទុកខាងលើ ។ ត្រង់នឹមមួយ ទឹមសេះអាជានេយ្យ ១.០០០ ។ គ្រឿងតាក់តែងដ៏សេសមិនមានប្រមាណ (គឺរាប់មិនបាន) ។ ក៏ទង់របស់រថនោះ លើកឡើងកម្ពស់ ២៥០ យោជន៍ ។ ទង់ដែលត្រូវខ្យល់បក់ ក៏មានសំឡេងដូចជាតន្ត្រីប្រកបដោយអង្គ ៥ សក្កទេវរាជត្រាស់ថា ពួកអ្នកចូរមើលទង់នោះ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះកាលពួកទេវតាឃើញទង់នោះ គិតថា

ព្រះរាជារបស់យើងមកឈរនៅក្នុងទីខាងចុងបរិស័ទ ដូចសសរដែលគេកប់ យើងមិនខ្លាចអ្នកណា ដូច្នេះ ទើបមិនខ្លាច ។

បទថា **បជាបតិស្ស** សេចក្តីថា បានឮថា បជាបតិទេវរាជនោះ មានពណ៌សម្បុរដូចនឹងសក្កទេវរាជ មានអាយុស្មើគ្នា បានទីអង្គុយក្នុងលំដាប់ទី ២ ។ បន្ទាប់មកក៏វរុណទេវរាជ និងឦសានទេវរាជ ។ ឯវរុណទេវរាជបានទីអង្គុយក្នុងលំដាប់ ទី ៣ ឦសានទេវរាជបានទីអង្គុយក្នុងលំដាប់ទី ៤ ។ បទថា **បលាយិ** សេចក្តីថា ចាញ់ពួកអសុរហើយឈរត្រង់រថនោះ ឬឃើញទង់សូម្បីមានប្រមាណតិច ក៏គេចចេញទៅជាធម្មតា ។

**[៣៨៤]** បទថា ***ឥតិបិ សោ ភគវា*** ជាដើម មានសេចក្តីពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។

**[៣៨៥]** បទថា ***ឥទមវោច*** សេចក្តីថា ព្រះមានព្រះភាគបានត្រាស់ធជគ្គបរិត្តនេះ ។ អានុភាពរបស់បរិត្តណា រមែងប្រព្រឹត្តទៅក្នុងអាណាខេត្ត គឺ ក្នុងសែនកោដិចក្រវាឡ ។

ពិតហើយ បុគ្គលទាំងឡាយនឹកដល់បរិត្តនេះ រមែងផុតចាកទុក្ខ មានយក្ខភ័យ និងចោរភ័យជាដើម មានចំនួនរាប់មិនបាន ។ សេចក្តីស្ងប់អំពីទុក្ខ

ដទៃចូរលើកទុកចុះ ។ ពិតណាស់ អ្នកមានចិត្តជ្រះថ្លាហើយ ទឹកដល់បរិត្ត នេះ រមែងបានទីពឹងសូម្បីក្នុងអាកាស ។ ក្នុងសេចក្ដីនោះ មានរឿងដូច្នេះ ។

បានឮថា កាលគេកំពុងលាបកំបោរសត្រង់ទីយវាបិចេតិយ ប្រុស កម្មោះម្នាក់ភ្លាត់ជើងធ្លាក់ពីវេទិកាជាន់លើ ចុះមកត្រង់ប្រហោងព្រះចេតិយ ។ ភិក្ខុ សង្ឃឈរខាងក្រោម ពោលថា អ្នកចូរទឹកដល់ធជគ្គបរិត្ត ។ គេតក់ស្លុតភ័យ ខ្លាចស្លាប់ ទើបពោលថា ធជគ្គបរិត្តជួយខ្ញុំផង ដូច្នេះ ។ ឥដ្ឋ ២ ដុំ ក៏ផុស ចេញមកអំពីប្រហោងចេតិយ តាំងជាជណ្ដើរឲ្យគេភ្លាម ។ មនុស្សទាំងឡាយ ក៏ទម្លាក់ជណ្ដើរល្វើដែលនៅខាងលើ ។ ឥដ្ឋដែលធ្វើជាជណ្ដើរនោះ ក៏តាំង នៅដូចដើម ។

ចប់អដ្ឋកថា ធជគ្គសូត្រ ទី ៣

# អ ដ្ឋ ក ថា

## វេបចិត្តិសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង **វេបចិត្តិសូត្រទី ៤** តទៅនេះ ៖

**[៣៤៧]** បទថា **វេបចិត្តិំ** សេចក្តីថា បានឮថា គេជាប្រធានរបស់ពួកអសុរ ។ បទថា **យេន** ត្រឹមតែជានិបាត ។ បទថា **នំ** ប្រែថា នោះ ។ បទថា **កណ្ឋបញ្ចមេហិ** សេចក្តីថា មានចំណង ៥ កន្លែង គឺ ត្រង់ដៃ ២ ត្រង់ជើង ២ និងត្រង់ក ១ ក៏គ្រឿងចងនោះ រមែងមកកាន់គន្លងចក្ខុ គឺ បិទបាំងឥរិយាបថ ដូចសរសៃឈូក និងដូចសរសៃពីងពាង ។ ក៏ត្រូវគេចងដោយគ្រឿងចងទាំងនោះទុកដោយចិត្ត ក៏រមែងរួចផុតដោយចិត្ត ។

**[៣៤៨]** បទថា **អក្កោសតិ** សេចក្តីថា គេរមែងជេរដោយអក្កោសវត្ថុ ១០ ទាំងនោះថា អ្នកឯងជាចោរ អ្នកឯងជាពាល អ្នកឯងជាអ្នកវង្វេង អ្នកឯងជាអូដ្ឋ អ្នកឯងជាគោ អ្នកឯងជាលា អ្នកឯងជាសត្វនរក អ្នកឯងជាសត្វតិរច្ឆាន អ្នកឯងមិនមានសុគតិ អ្នកឯងប្រាថ្នាតែទុគតិប៉ុណ្ណោះ ។ បទថា **បរិភាសតិ** សេចក្តីថា ពោលពាក្យជាដើមទាំងនេះ គម្រាមថា ម្នាលសក្កៈ

កញ្ចាស់ លោកនឹងឈ្នះគ្រប់វេលាមិនបាន កាលណាពួកអសុរឈ្នះ កាលនោះ យើងនឹងចងលោកយ៉ាងនេះខ្លះ នឹងឲ្យដេកត្រង់ទ្វាររបស់ដែនអសុរ ហើយវាយខ្លះ ។ សក្កទេវរាជ មានជ័យជំនះហើយ ក៏មិនធ្វើទុកក្នុងចិត្តដល់ពាក្យរបស់ស្តេចអសុរនោះ មិនចាប់អារម្មណ៍ (មិនទទួលពាក្យរបស់) វេបចិត្តនោះ ដើរចេញចូលសុធម្មាទេវសភា ។

[៣៤៩] បទថា **អជ្ឈភាសិ** សេចក្តីថា មាតលីទេវបុត្រពិចារណាថា សក្កទេវរាជនេះ អត់ធន់ចំពោះពាក្យគ្រោតគ្រាតទាំងនេះ ព្រោះសេចក្តីខ្លាចឬ ឬថា ព្រោះជាអ្នកប្រកបដោយអធិវាសនខន្តិ ទើបទូលហើយ ។

[៣៥០] បទថា **ទុព្ពល្យេន** ប្រែថា ដោយភាពទន់ខ្សោយ ។ បទថា **បដិសំយុជេ** ប្រែថា នឹងគប្បីសេពគប់ គឺ នឹងគប្បីស្និទ្ធស្នាល ។

[៣៥១] បទថា **បភិជ្ជេយ្យុំ** ប្រែថា នឹងគប្បីប្រេះឆា ។ បាលីថា **បកុជ្ជេយ្យុំ** ខ្លះ ។ បទថា **បរំ** ប្រែថា សត្រូវ ។

[៣៥២] បទថា **យោ សតោ ឧបសម្មតិ** សេចក្តីថា បុគ្គលណាមានសតិចូលទៅរម្ងាប់ អធិប្បាយថា យើងចូលទៅរម្ងាប់ គឺ ហាមជនពាលនោះ ។

[៣៥៣] បទថា **យទា នំ មញ្ញតិ** សេចក្តីថា សម្គាល់ទោសនោះ

ព្រោះហេតុណា ។ បទថា **អជ្ឈារូហតិ** ប្រែថា សង្កត់សង្កិន ។ បទថា **គោវ ភិយ្យោបលាយិនំ** សេចក្តីថា ហ្វូងគោឈរមើលគោ ២ ក្បាល កំពុងជល់គ្នា ក្នុងចំណោមគោទាំងពីរនោះ កាលគោមួយមិនទាន់បោលទៅ ហ្វូងគោក៏មិនដេញ តែកាលណាគោណាមួយបោលទៅ កាលនោះពួកគោទាំងពួង ក៏នាំគ្នាដេញគោដែលបោលទៅនោះ យ៉ាងណា បុគ្គលពាលក៏គ្របសង្កត់នូវបុគ្គលដែលអត់ធន់ ក៏ដូច្នោះ ។

**[៣៥៤]** បទថា **សទត្ថបរមា** ប្រែថា មានប្រយោជន៍ខ្លួនជាសំខាន់ ។ បទថា **ខន្ត្យា ភិយ្យោ ន វិជ្ជតិ** សេចក្តីថា ក្នុងប្រយោជន៍ដែលមានប្រយោជន៍របស់ខ្លួនជាសំខាន់នោះ ប្រយោជន៍ដ៏ក្រៃលែងជាងខន្តិមិនមាន ។ បទថា **តមាហុ បរមំ ខន្តី** សេចក្តីថា បុគ្គលណាមានកម្លាំង រមែងអត់ធន់បាន លោកពោលខន្តិនោះរបស់បុគ្គលនោះថា ជាសំខាន់ ។ កម្លាំងដែលកើតអំពីសេចក្តីមិនដឹង ឈ្មោះថា កម្លាំងរបស់បុគ្គលពាល ។ កម្លាំងរបស់បុគ្គលពាលនោះជាកម្លាំងរបស់អ្នកណា កម្លាំងនោះមិនមែនជាកម្លាំងទេ លោកមិនហៅកម្លាំងនោះថា ជាកម្លាំងទេ ។ បទថា **ធម្មគុត្តស្ស** សេចក្តីថា បុគ្គលដែលធម៌រក្សាហើយ ឬបុគ្គលរក្សាធម៌ ។ បទថា **បដិវត្តា** ប្រែថា ជាអ្នកពោលមាត់ងាយ ។

ឬថា គប្បីពោលតិះដៀលថាយ៉ាងណាមួយក៏ដោយ ។ ប៉ុន្តែថា ឈ្មោះថា ជាអ្នកញ៉ាំងបុគ្គលតាំងនៅក្នុងធម៌ឲ្យញាប់ញ័រមិនមាន ។ បទថា **តស្សេវ តេន-បាបិយោ** សេចក្ដីថា សេចក្ដីអាក្រក់របស់បុគ្គលនោះ រមែងមាន ព្រោះសេចក្ដីក្រោធនោះ ។ សួរថា ជាសេចក្ដីអាក្រក់របស់អ្នកណា ។ ឆ្លើយថា ជារបស់អ្នកដែលក្រោធ តបបុគ្គលដែលក្រោធ ។ បទថា **តិកិច្ឆន្តានំ** ជាពហុវចនៈប្រើក្នុងឯកវចនៈ ។ អធិប្បាយថា រក្សាប្រយោជន៍ទុកបាន ។

បទថា **ជនា មញ្ញន្តិ** សេចក្ដីថា បុថុជ្ជនល្ងង់ខ្លៅ រមែងសម្គាល់ថាបុគ្គលល្ងង់ខ្លៅនេះ រមែងសម្គាល់បុគ្គលដែលញ៉ាំងប្រយោជន៍ទាំង ២ ចំណែកគឺ របស់ខ្លួន និងរបស់អ្នកដទៃមានសភាពបែបនេះ ឲ្យសម្រេច ។ បទថា **ធម្មស្ស អកោវិទា** សេចក្ដីថា មិនឆ្លាតក្នុងអរិយសច្ច ៤ ។

**[៣៩៥]** បទថា **ឥធ** ប្រែថា ក្នុងសាសនានេះ ។ បទថា **ខោ តំ** ត្រឹមតែនិបាត ។

ចប់អដ្ឋកថា វេបចិត្តិសូត្រទី ៤

# អ ដ្ឋ ក ថា

## សុភាសិតជយសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុងសុភាសិតជយសូត្រទី ៥ តទៅនេះ ៖*

**[៣៥៧]** *បទថា **អសុរិន្ទំ ឯតទវោច** សេចក្តីថា បានពោលពាក្យនេះដោយភាពជាអ្នកឆ្លាត ។ បានឮថា ស្តេចអសុរនោះ មានការគិតយ៉ាងនេះថា ការពោលដោះស្រាយការប្រកាន់របស់អ្នកដទៃមុន ជាការធ្ងន់ តែការពោលបណ្តោយតាមពាក្យរបស់អ្នកដទៃក្នុងខាងក្រោយ តែងសប្បាយ ។*

*បទថា **បុព្វទេវា** សេចក្តីថា អ្នកមកនៅយូរក្នុងទេវលោក រមែងជាម្ចាស់មុន ។*

*អធិប្បាយថា លោកទាំងឡាយចូរពោលពាក្យដែលមកតាមប្រពៃណីរបស់អ្នកមុន ។*

**[៣៦២]** *បទថា **អទណ្ឌាវចរា** សេចក្តីថា វៀរចាកការកាន់ដំបង ។ អធិប្បាយថា មិនមានដូចក្នុងពាក្យនេះថា គប្បីកាន់ដំបង ឬកាំបិត ។*

ចប់អដ្ឋកថា សុភាសិតជយសូត្រទី ៥

# អ ដ្ឋ ក ថា

## កុលាវកសូត្រទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុងកុលាវកសូត្រ ទី ៦ តទៅនេះ ៖

**[៣៦៤]** បទថា *អជ្ឈភាសិ* សេចក្តីថា បានឮថា សំឡេងរថ សំឡេងសេះអាជានេយ្យ សំឡេងទន់ ដូចសំឡេងរន្ទះលាន់ឮដោយជុំវិញ មានដល់ស្តេចសក្កៈ ដែលឆ្ពោះមុខចូលព្រៃរការនោះ ។ ពួកគ្រុឌជាសត្វមានកម្លាំងក្នុងព្រៃរការនោះ បានឮសំឡេងនោះហើយ ក៏នាំគ្នាគេចទៅ ។ ពួកគ្រុឌដែលចាស់ជរា ដែលអស់កម្លាំងព្រោះរោគ និងកូនសត្វដែលនៅមិនទាន់ដុះស្លាប មិនអាចនឹងគេចបាន ខ្លាចស្លាប់ ភ័យតក់ស្លុត ស្រែកទ្រហឹងអឺងអាប់ ។ ស្តេចសក្កៈបានឮសំឡេងនោះហើយ ទើបត្រាស់សួរសារថីមាតលីថា សំឡេងអ្វីបា ។ សារថីមាតលីក្រាបទូលថា បពិត្រទេវៈ ពួកគ្រុឌបានឮសំឡេងរថរបស់ព្រះអង្គមិនអាចនឹងគេចបានទើបស្រែក ។ ស្តេចសក្កៈបានស្តាប់ពាក្យនោះហើយ មានព្រះទ័យប្រកបដោយព្រះករុណា ទើបត្រាស់ ។

បទថា *ឦសាមុខេន* គឺ បែរជន្ទោលរបស់រថ ។ រថនឹងមិនពារលើ

សំបុកបក្សីដោយជន្ទោល យ៉ាងណា លោកចូរគេចពីសំបុកសត្វនោះ ដោយបែរជន្ទោលរថ ដូច្នោះ ។ ព្រោះថា រថដែលកើតដោយបុណ្យជាបច្ច័យ បែរមុខឆ្ពោះទៅត្រង់ភ្នំចក្រវាឡក្តី ត្រង់ភ្នំសិនេរុក្តី មិនទើសទាក់នឹងអ្វីៗ រមែងទៅដោយអំណាចការទៅក្នុងអាកាស ។ បើនឹងគប្បីទៅកាន់ផ្លូវព្រៃរកានោះ ដូចកាលរទេះធំទៅកណ្តាលព្រៃល្ហុក្តី កណ្តាលព្រៃល្ហុងក្តី ព្រៃទាំងអស់នោះ ក៏ត្រូវជាន់ខ្ទេចខ្ទី យ៉ាងណា សូម្បីព្រៃរកានោះ ក៏ដូច្នោះ ។

ចប់អដ្ឋកថា កុលាវកសូត្រទី ៦

# អ ដ្ឋ ក ថា

## នទុព្ភិយសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុងនទុព្ភិយសូត្រទី ៧ តទៅនេះ ៖

[៣៦៦] បទថា ឧបសង្កមិ សេចក្តីថា ស្តេចសក្កៈនេះត្រិះរិះថា យើងមិនគួរប្រទូសរ៉ាយសូម្បីដល់អ្នកដែលជាសត្រូវជាមួយយើង ។ សក្កទេវរាជគិតតទៅថា ឈ្មោះថា អ្នកដែលជាសត្រូវជាមួយស្តេចវេបចិត្តិនោះ ក្រៅពីយើងមិនមាន យើងនឹងសាកល្បងមើលស្តេចវេបចិត្តិនោះមុន គេឃើញយើងហើយនឹងប្រទូសរ៉ាយ ឬមិនប្រទូសរ៉ាយ ទើបចូលទៅរក ។

[៣៦៧] បទថា តិដ្ឋ វេបចិត្តគហិតោសិ សេចក្តីថា ស្តេចសក្កៈត្រាស់ថា ម្នាលស្តេចវេបចិត្តិ លោកចូរឈប់ក្នុងទីនេះចុះ លោកត្រូវយើងចាប់ហើយ ។ ព្រមនឹងតម្រាស់របស់ស្តេចសក្កៈនោះ ស្តេចវេបចិត្តិក៏ត្រូវចងរឹតដោយចំណងមានចំណងកជាគម្រប់ ៥ ។ បទថា សបស្សុ ច មេ សេចក្តីថា ស្តេចសក្កៈត្រាស់ថា ម្នាលវេបចិត្តិ អ្នកចូរស្បថ ដើម្បីកុំឲ្យប្រទូស្តដល់យើងទៀត ។

[៣៦៨] បទថា យំ មុសា ភណតោ បាបំ សេចក្តីថា លោកពោល

សំដៅដល់បាបរបស់ព្រះបាទចេតិយរាជ ក្នុងបឋមកប្បក្នុងកប្បនេះ ។ បទថា **អរិយូបវាទិនោ** បានដល់ បាប ដូចបាបរបស់កិក្ខុកោកាលិកៈ ។ បទថា **មិត្ត-ទ្ទុនោ ច យំ បាបំ** បានដល់ បាបរបស់អ្នកមានចិត្តប្រទូសរ៉ាយក្នុងព្រះមហា-សត្វ ក្នុងមហាកបិជាតក ។ បទថា **អកតញ្ញុនោ** បានដល់ បាបរបស់ជន អកតញ្ញូ ដូចទេវទត្ត ។ ន័យថា ក្នុងកប្បនេះ មាន ៤ មហាកប្ប ។

ចប់អដ្ឋកថា ឆទុត្តិយសូត្រទី ៧

# អ ដ្ឋ ក ថា

## វិរោចនអសុរិន្ទសូត្រទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុងវិរោចនអសុរិន្ទសូត្រទី ៨ តទៅនេះ ៖

**[៣៦៩]** បទថា **អជ្ឈំសុ** បានដល់ ឈរដូចមនុស្សយាមទ្វារ ។

**[៣៧០]** បទថា **និដ្ឋិតា** ប្រែថា សេចក្តីសម្រេច ។ លោកអធិប្បាយថា បុគ្គលជាបុរស គួរព្យាយាមឲ្យទាល់តែសម្រេចប្រយោជន៍ ។ គាថាទី ២ ជារបស់សក្កទេវរាជ ។

**[៣៧១]** ក្នុងបទទាំងនោះ បទថា **ខន្តយា ភិយ្យោ** សេចក្តីថា ប្រយោជន៍ទាំងឡាយរបស់បុរស ឈ្មោះថា សម្រេចល្អហើយ តែប្រយោជន៍អ្វីដែលក្រៃលែងជាងខន្តិ មិនមាន ។

**[៣៧៣]** បទថា **អត្ថជាតា** បានដល់ មានកិច្ចកើតហើយ ។

ពិតណាស់ ដែលឈ្មោះថា សត្វ ដែលមិនមានកិច្ចកើតហើយ សូម្បីទាំងក្តែស្រុក និងក្តែព្រៃជាដើម រមែងមិនមាន ។ សូម្បីត្រឹមតែដើរទៅខាងនេះខាងណោះ ក៏ជាកិច្ចដូចគ្នា ។

បទថា **សំយោគបរមកត្វេវ សម្ភោគា សព្វបាណិនំ** ប្រែថា គ្រឿងបរិភោគរបស់សត្វទាំងពួង មានការផ្សំយ៉ាងក្រៃលែង អធិប្បាយថា ព្រោះបាយដែលរក្សាទុកមួយយប់ជាដើម មិនគួរបរិភោគ ។ តែបាយទាំងនោះ កំដៅឲ្យក្តៅហើយ ផ្សំដោយទឹកដោះថ្លា ទឹកឃ្មុំ ទឹកអំពៅជាដើម ជារបស់គួរបរិភោគ ។ ដោយហេតុនោះ លោកទើបពោលថា **សំយោគបរមកត្វេវ សម្ភោគា សព្វ-បាណិនំ** ដូច្នេះ ។ បទថា **និប្ផន្នសោភិនោអត្ថា** សេចក្តីថា ឈ្មោះថា ប្រយោជន៍ទាំងនេះសម្រេចហើយ ទើបល្អ ។ គាថាទី ៤ ក៏ជារបស់សក្កទេវរាជ សូម្បីក្នុងគាថាទី ៤ នោះ គប្បីជ្រាបសេចក្តីដោយន័យដែលពោលហើយ ។

ចប់អដ្ឋកថា វិរោចនអសុរិន្ទសូត្រទី ៨

# អ ដ្ឋ ក ថា

## អារញ្ញកសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុង *អារញ្ញកសូត្រទី ៩* តទៅនេះ ៖

**[៣៧៤]** បទថា *បណ្ណកុដីសុ សម្មន្តិ* សេចក្ដីថា ឥសីទាំងឡាយអាស្រ័យនៅក្នុងបណ្ណសាលា សម្បូរណ៍ដោយទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃ និងទីចង្ក្រមជាដើមក្នុងដងព្រៃ ដែលគួររីករាយក្នុងហិមវន្តប្រទេស ។ ទេវៈទាំងពីរនេះ គឺ សក្កទេវរាជ និងស្ដេចវេបចិត្តិ ត្រូវជាកូនប្រសារឱពុកក្មេកគ្នា ពេលខ្លះក៏ឈ្លោះគ្នា ពេលខ្លះក៏ត្រាច់ទៅជាមួយគ្នា តែក្នុងពេលនេះត្រាច់ទៅជាមួយគ្នា ។

**[៣៧៥]** បទថា *អជលិយោ* បានដល់ ស្បែកជើងក្រាស់ច្រើនជាន់ ។ បទថា *ខគ្គំ ឱលគ្គេត្វា* បានដល់ ស្ពាយដាវ ។ បទថា *ឆត្តេន* បានដល់ កាន់ឆត្រសជាទិព្វទុកខាងលើ ។ បទថា *អបព្យាមតោ ករិត្វា* ប្រែថា ចម្ងាយមិនដល់មួយព្យាម ។

**[៣៧៦]** បទថា *ចិរទក្ខិតានំ* ប្រែថា ប្រព្រឹត្តវត្តមកយូរ ។ ឥសីទាំង

ឡាយពោលថា លោកចូរថយចេញទៅអំពីទីនេះ ចូរវៀរចេញអំពីទីនេះ កុំឈរលើខ្យល់ ។

[៣៧៧] បទថា *ន ហេតុំ ទេវា* សេចក្តីថា ពួកទេវតាមិនមានសេចក្តីសម្គាល់ក្នុងកិរិយរបស់អ្នកមានសីលនេះថា បដិកូលទេ ។ លោកសម្តែងទុកថា ពួកទេវតាមានសេចក្តីសម្គាល់ក្នុងកិរិយរបស់អ្នកមានសីលថា គួរប្រាថ្នា គួររីករាយ គួរពេញចិត្តទាំងនោះឯង ។

ចប់អដ្ឋកថា អារញ្ញកសូត្រទី៩

# អ ដ្ឋ ក ថា

## សមុទ្ទកសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមុទ្ទកសូត្រទី ១០ តទៅនេះ ៖*

**[៣៧៩]** *បទថា **សមុទ្ទតីរេ បណ្ណកុដីសុ** សេចក្តីថា ពួកឥសីអាស្រ័យនៅក្នុងបណ្ណសាលា មានប្រការដូចពោលហើយលើឆ្នេរខ្សាច់ មានពណ៌ដូចផែនប្រាក់ នាខ្នងមហាសមុទ្រក្នុងចក្រវាឡ ។ បទថា **សិយាបិ នំ** កែជា **សិយាបិ អម្ហាកំ** ប្រែថា គប្បីមានដល់ពួកយើង ។ បទថា **អភយទក្ខិណំ យាចេយ្យាម** បានដល់ សូមអភ័យទាន ។ បានឮថា ដោយច្រើន សង្គ្រាមរវាងទេវតា និងអសុរ ត្រង់លើខ្នងមហាសមុទ្រ ។ ជ័យជំនះរមែងមិនមានដល់ពួកអសុរគ្រប់កាល ។ ពួកអសុរ មានការចាញ់ជាច្រើនលើកនោះឯង ។ ពួកអសុរទាំងនោះ ចាញ់ទេវតាហើយ នាំគ្នាគេចទៅតាមផ្លូវអាស្រមបទរបស់ពួកឥសី ក្រោធថា សក្កទេវរាជប្រឹក្សាជាមួយពួកឥសីទាំងនេះ ធ្វើយើងឲ្យវិនាស ដោយពួកលោកចាប់ទាំងមេចាប់ទាំងកូន ។ ពួកអសុរទើបនាំគ្នាទម្លាយធ្នាំងទឹកផឹក និងសាលា ទីចង្ក្រមជាដើមក្នុងអាស្រមបទនោះ ។ ពួកឥសីកាន់*

យកផលាផលអំពីព្រៃត្រឡប់មកឃើញ ក៏ជួយគ្នាធ្វើឲ្យដូចដើម ដោយសេចក្តីលំបាកទៀត ។ សូម្បីពួកអសុរទាំងនោះ ក៏ធ្វើឲ្យវិនាសយ៉ាងនោះរឿយៗ ។ ព្រោះដូច្នោះ ពួកឥសីស្តាប់ថា ឥឡូវនេះ សង្គ្រាមរវាងទេវតា និងអសុរប្រាកដឡើង ដូច្នេះ ទើបគិតយ៉ាងនោះ ។

**[៣៨០]** បទថា **កាមំ ករោ** បានដល់ ធ្វើតាមសេចក្តីប្រាថ្នា ។ បទថា **ភយស្ស អភយស្ស វា** កែជា **ភយំ វា អភយំ វា** ប្រែថា ភ័យ ឬអភ័យ ។ លោកអធិប្បាយសេចក្តីនេះទុកថា ប្រសិនបើលោកប្រាថ្នានឹងឲ្យអភ័យ ក៏ល្មមឲ្យអភ័យបាន ប្រសិនបើលោកប្រាថ្នានឹងឲ្យភ័យ ក៏ល្មមនឹងឲ្យភ័យបាន តែសម្រាប់ពួកអាត្មា លោកចូរឲ្យអភ័យទានចុះ ដូច្នេះ ។

**[៣៨១]** បទថា **ទុដ្ឋានំ** ប្រែថា អ្នកប្រទូសរ៉ាយហើយ គឺ អ្នកក្រោធហើយ ។

**[៣៨២]** បទថា **បវុត្តំ** គឺ ដែលគេសាបព្រោះទុកក្នុងស្រែ ។

**[៣៨៣]** បទថា **តិក្ខត្តុំ ឧព្វិជ្ជតិ** សេចក្តីថា ស្តេចអសុរបរិភោគកត្តក្នុងពេលល្ងាច ហើយឡើងទីដេក ដេកមួស្របក់ ក៏ក្រោកឡើងឈរស្រែកជុំវិញដូចត្រូវលំពែងចាក់រយផ្ទៃ ។ កពអសុរមួយម៉ឺនយោជន៍ ដល់ភាពប្របូកប្របល់

ថា នេះជាអ្វី ។ លំដាប់នោះ ពួកអសុរនាំគ្នាមកសួរស្ដេចអសុរ នេះជាអ្វី ។ ស្ដេចអសុរមិននិយាយអ្វីឡើយ ។ សូម្បីក្នុងយាមទីពីរជាដើមក៏មានន័យនេះឯង ។ ដោយប្រការដូច្នេះ កាលពួកអសុរ នាំគ្នាលួងលោមស្ដេចអសុរថា កុំខ្លាចឡើយមហារាជ ដូច្នេះ ជរាបដល់អរុណរះឡើង ។ តាំងពីនោះមក ស្ដេចអសុរ ក៏មានចិត្តញាប់ញ័រ កើតអាការឈឺដោយប្រការដូច្នេះ ។ ដោយហេតុនោះឯង ស្ដេចអសុរនោះ ទើបកើតឈ្មោះម្យ៉ាងទៀតថា **វេបចិត្តិ** ។

ចប់អដ្ឋកថា សមុទ្ទកសូត្រទី ១០

## ចប់វគ្គទី ១

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា


១-អដ្ឋកថាសុវីរសូត្រ
២-អដ្ឋកថាសុសិមសូត្រ
៣-អដ្ឋកថាធជគ្គសូត្រ
៤-អដ្ឋកថាវេបចិត្តិសូត្រ
៥-អដ្ឋកថាសុភាសិតជយសូត្រ
៦-អដ្ឋកថាកុលាវកសូត្រ
៧-អដ្ឋកថានទុព្ភិយសូត្រ
៨-អដ្ឋកថាវិរោចនអសុរិន្ទសូត្រ
៩-អដ្ឋកថាអារញ្ញកសូត្រ
១០-អដ្ឋកថាសមុទ្ទកសូត្រ

# ទេវ វគ្គទី ២

## អ ដ្ឋ ក ថា

### បឋមទេវសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង **បឋមទេវសូត្រទី ១** នៃទុតិយវគ្គ ដូចតទៅ ៖

**[៣៨៥]** បទថា **វត្តបទានិ** បានដល់ ចំណែកនៃវត្ត ។ បទថា **សមត្តានិ** គឺ បរិបូរណ៌ហើយ ។ បទថា **សមាទិន្នានិ** គឺ កាន់យកហើយ បទថា **កុលេ ជេដ្ឋាបចាយី** សេចក្តីថា ធ្វើសេចក្តីកោតក្រែងអ្នកជាធំក្នុងត្រកូលជាដើម ថា តាយាយ ឪពុកមា ម្តាយមីង អ៊ំប្រុស អ៊ំស្រី ។ បទថា **សណ្ហវាចោ** បានដល់ មានវាចាផ្អែមល្ហែមទន់ភ្លន់គួរស្រឡាញ់ ។ បទថា **មុត្តចាគោ** បានដល់ បរិច្ចាគហើយ ។ បទថា **បយតបាណី** បានដល់ លាងដៃដើម្បីឲ្យទេយ្យធម៌ ។ បទថា **វោស្សគ្គរតោ** បានដល់ ត្រេកអរក្នុងការលះបង់ ។ បទថា **យាចយោគោ** បានដល់ ជាអ្នកគួរដល់អ្នកដទៃគប្បីសូម ឬថា អ្នកប្រកបដោយការបូជានុ៎ះឯង ឈ្មោះថា **យាចយោគោ** ។ បទថា **ទានសំវិភាគរតោ** បានដល់ ត្រេកអរហើយក្នុងការឲ្យ និងការចែករំលែក ។

ចប់អដ្ឋកថា បឋមទេវសូត្រទី ១

# អ ដ្ឋ ក ថា

## ទុតិយទេវសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយទេវសូត្រទី ២ តទៅនេះ ៖

**[៣៨៨]** បទថា **មនុស្សភូតោ** បានដល់ មឃមាណពជាមនុស្សក្នុងស្រុកអចលគ្រាម ដែនមគធៈ ។ បទថា **អាវសថំ អទាសិ** សេចក្ដីថា មឃមាណពបានសាងទីសម្រាកឲ្យដល់មហាជនក្នុងផ្លូវបែកជា ៤ ។ បទថា **សហស្សម្បិ អត្ថានំ** បានដល់ ហេតុសូម្បីមួយពាន់ ។ ឬថា កាលនិយាយពាក្យមួយពាន់រួមចុះដោយមនុស្សមួយពាន់នាក់ សក្កៈជាស្ដេចទេវតា តាំងនៅក្នុងបទតែមួយ វិនិច្ឆ័យថា នេះប្រយោជន៍របស់ជននេះ នេះប្រយោជន៍របស់ជននេះ ។

ចប់អដ្ឋកថា ទុតិយទេវសូត្រទី ២

# អ ដ្ឋ ក ថា

## តតិយទេវសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយទេវសូត្រទី ៣ តទៅនេះ ៖

**[៣៩១]** បទថា **ឧបសង្កមិ** សេចក្តីថា ស្តេចលិច្ឆវីព្រះនាមមហាលិ គិតថា ជនទាំងឡាយនិយាយគ្នាថា សក្កទេវរាជ យើងនឹងទូលសួរសេចក្តីនេះ ចំពោះព្រះទសពលថា ស្តេចសក្កៈមានឬហ្ន៎ អ្នកណាធ្លាប់ឃើញស្តេចសក្កៈ នោះ ដូច្នេះ ទើបចូលទៅគាល់ព្រះមានព្រះភាគ ។

**[៣៩២]** បទថា **តញ្ច បជានាមិ** ជាឯកវចនៈចុះក្នុងពហុវចនៈ ។ អធិប្បាយថា តថាគតដឹងធម៌ទាំងឡាយនោះ ។ បានឮថា ស្តេចសក្កៈ ជាមាណពឈ្មោះថា **មឃៈ** ក្នុងអចលគ្រាម ដែនមគធៈក្នុងអត្តភាពមុន ជាបណ្ឌិត ជាអ្នកឆ្លាត ។ មឃមាណពនោះ មានចរិយា ដូចចរិយារបស់ព្រះពោធិសត្វ គេនាំមនុស្ស ៣៣ នាក់ ទៅធ្វើកល្យាណកម្ម ។ ថ្ងៃមួយ គេពិចារណាដោយបញ្ញារបស់ខ្លួន ជញ្ជូនសម្រាមចេញទាំងពីរខាងក្នុងកន្លែងដែលមហាជនប្រជុំគ្នា កណ្តាលស្រុក ហើយបានធ្វើកន្លែងនោះ ឲ្យជាទីគួររីករាយ ។ គេសាងមណ្ឌប

ក្នុងទីនោះទៀត ។ កាលកន្លងទៅ គេបានសាងសាលាទៀត ។ មួយវិញទៀត គេចេញពីស្រុកត្រាច់ទៅមួយគាវុត កន្លះយោជន៍ បីគាវុតខ្លះ មួយយោជន៍ខ្លះ បានធ្វើទីដែលមិនរាបស្មើឲ្យរាបស្មើជាមួយនឹងសម្មាញ់ទាំងនោះ ។

សម្មាញ់ទាំងអស់ទាំងនោះ រួមចិត្តគ្នាសាងស្ពានក្នុងទីដែលគួរមានស្ពានក្នុងទីនោះៗ សាងមណ្ឌបជាដើមក្នុងទីដែលគួរដល់មណ្ឌប សាលា ស្រះបោក្ខរណី សួនផ្កាឈើជាដើម បានធ្វើបុណ្យជាច្រើន ។

**[៣៩៣]** មឃៈ បំពេញវត្តបទ ៧ លុះបែកធ្លាយរាងកាយហើយ បានទៅកើតក្នុងឋានតាវត្តឹង្សជាមួយនឹងពួកសម្មាញ់ ។ ព្រះមានព្រះភាគទ្រង់ជ្រាបហេតុទាំងពួងនោះ ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា បានជាសក្កទេវរាជ បាននាមថា ជាសក្កៈ ព្រោះប្រព្រឹត្តធម៌ពួកណា តថាគតដឹងធម៌ទាំងនេះផង ។ នេះជាសង្ខេបកថា ក្នុងការដល់ភាពជាសក្កទេវរាជ បាននាមថា ជាសក្កៈ ។ ចំណែកសេចក្តីពិស្តារ លោកពោលទុកហើយក្នុងសក្កៈបញ្ហាវណ្ណនា អដ្ឋកថាទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ។

ចប់អដ្ឋកថា តតិយឆេវសូត្រទី ៣

# អ ដ្ឋ ក ថា

## ទឡិទ្ទសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង **ទឡិទ្ទសូត្រទី ៤** តទៅនេះ ៖

**[៣៩៦]** បទថា **មនុស្សទឡិទ្ទោ** គឺ មនុស្សកំសត់ ។ បទថា **មនុស្សកបណោ** គឺ ដល់ភាពជាមនុស្សគួរករុណា ។ បទថា **មនុស្សវរាកោ** គឺ ជាមនុស្សអាក្រក់ ។

**[៣៩៧]** បទថា **តត្រ** ប្រែថា ក្នុងទីនោះ ។ ឬក្នុងសេចក្តីរឿងនោះ ។ បទថា **ឧជ្ឈាយន្តិ** ប្រែថា សម្លឹងទោស បានដល់ គិតតែសេចក្តីអាក្រក់ ។ បទថា **ខិយ្យន្តិ** គឺ ពោលប្រកាស ។

បទថា **វិបាចេន្តិ** គឺ និយាយបើកបង្ហាញក្នុងទីនោះៗ ។ ក្នុងបទនេះថា **ឯសោ ខោ មារិស** មានអនុបុព្វីកថាដូចតទៅនេះ ៖

បានឮថា ទេវបុត្រនោះ កាលព្រះពុទ្ធនៅមិនទាន់ទ្រង់ឧប្បត្តិ បានកើតជាព្រះរាជាក្រុងពារាណសី ក្នុងដែនកាសី ទ្រង់ធ្វើប្រទក្សិណព្រះនគរ ដែលលើកទង់ជ័យ និងទង់សំពត់ឡើង ប្រដាប់ដោយគ្រឿងប្រដាប់ព្រះនគរយ៉ាងល្អ

ដោយសិរីសម្បត្តិរបស់ព្រះអង្គ ដែលពពួកជនសម្លឹងមើលដោយភ្នែកតែមួយ ។ ក៏សម័យនោះ ព្រះបច្ចេកពុទ្ធមួយអង្គ មានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ ដល់ព្រមដោយការទូន្មានខ្លួនយ៉ាងល្អ មកអំពីភ្នំគន្ធមាទន៍ ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងនោះ ។ ចំណែកមហាជនលះបង់សេចក្ដីកោតក្រែងក្នុងព្រះរាជា សម្លឹងមើលព្រះបច្ចេកពុទ្ធតែម្យ៉ាង ។ ព្រះរាជាទ្រង់ត្រិះរិះថា ឥឡូវនេះ ក្នុងពពួកជននេះ សូម្បីម្នាក់ក៏មិនសម្លឹងមើលយើង នេះរឿងអ្វី កាលសម្លឹងមើល ក៏ឃើញព្រះបច្ចេកពុទ្ធ ។ ព្រះបច្ចេកពុទ្ធនោះក៏ជរាមានព្រះជន្មច្រើន ។ សូម្បីចីវររបស់លោកក៏គ្រាំគ្រា ។ សរសៃអំបោះរយីងរយោងអំពីទីនោះៗ ។ ព្រះរាជាទតឃើញព្រះបច្ចេកពុទ្ធ អ្នកបំពេញបារមីមកអស់ពីរអសង្ខេយ្យមួយសែនកប្ប ត្រឹមតែចិត្តជ្រះថ្លា ឬត្រឹមតែលើកដៃសំពះក៏មិនមាន ។ ព្រះរាជានោះទ្រង់ក្រោធថា បព្វជិតនេះ មិនសម្លឹងមើលយើងដោយសេចក្ដីប្រណែន ទ្រង់ត្រិះរិះថា បុគ្គលនេះកើតរោគឃ្លង់ដណ្ដប់សំពត់ ហើយទ្រង់ស្ដោះទឹកមាត់ស្ដេចជៀសចេញទៅ ។ ដោយវិបាករបស់កម្មនោះ ព្រះរាជាទើបទៅកើតក្នុងមហានរក វិបាកដែលសល់មកកាន់មនុស្សលោក បដិសន្ធិក្នុងគភ៌របស់ស្ត្រីទីទាល់ក្រ ក្នុងក្រុងរាជគ្រឹះ ។ តាំងពីវេលាបដិសន្ធិ ស្ត្រីនោះមិនបានអាហារ

ពេញពោះត្រឹមតែទឹកបាយ ។ កាលទារកនោះនៅក្នុងផ្ទៃ ត្រចៀក និងច្រមុះលាយគ្នា ។ កាលក្មេងចេញចាកផ្ទៃមាតា កើតរោគឃ្លង់ មានសក់ស្កូវសស្គុះ ។ ឈ្មោះថា មាតាបិតាជាអ្នកផ្ដាក់ខ្លួនក្រលំបាក ។ ដោយហេតុនោះ មាតារបស់ទារកនោះ បាននាំទឹកបាយខ្លះ ទឹកខ្លះ ឲ្យដល់ទារករហូតដល់វេលាដែលមិនអាចនឹងកាន់អំបែងត្រាច់ទៅបាន ក៏កាលទារកនោះ អាចត្រាច់សូមទានបាន មាតាទើបប្រគល់អំបែងឲ្យក្នុងដៃ ពោលថា អ្នកឯងនឹងទទួលខុសត្រូវតាមកម្មរបស់ខ្លួន ហើយក៏គេចចេញទៅ ។ តាំងពីនោះមក សាច់របស់ទារកនោះបែកជាដំបៅទូទាំងរាងកាយ ។ ទឹករងៃក៏ហូរ ។ រងទុក្ខវេទនាយ៉ាងក្រៃលែង ។ អាស្រ័យប្រកផ្លូវដេកស្រែកហ៊ោរហូតអស់នៃយប់ ។ ដោយសំឡេងបរិទេវនាគួរឲ្យអាណិតដល់ក្មេងនោះ ពួកមនុស្ស ដែលនៅជាប់ថ្នល់នោះក៏មិនបានដេកអស់មួយយប់ ។ តាំងពីនោះមក គេទើបមានឈ្មោះថា សុប្បពុទ្ធ ព្រោះអត្ថថា ធ្វើអ្នកដេកឲ្យភ្ញាក់ ។

គ្រាសម័យតមក កាលព្រះមានព្រះភាគ ស្ដេចយាងដល់ក្រុងរាជគ្រឹះ អ្នកក្រុងនិមន្តព្រះសាស្ដា សាងមហាមណ្ឌបកណ្ដាលព្រះនគរ បាននាំគ្នាថ្វាយទាន ។

សូម្បីនាយសុប្បពុទ្ធកើតរោគឃ្លង់ ក៏បានទៅអង្គុយក្នុងទីជិតរោងទាន អ្នកក្រុងអង្គាសព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដោយរបស់ទំពារ របស់ឆាន់ដ៏ប្រណីត បានឲ្យបាយយាគូ និងកត្តុដល់សុប្បពុទ្ធខ្លះ ។ កាលសុប្បពុទ្ធបរិភោគភោជនដ៏ប្រណីតហើយ ក៏ចិត្តមានអារម្មណ៍តែមួយ ។ ក្នុងទីបំផុតកត្តកិច្ច ព្រះសាស្តាទ្រង់ធ្វើអនុមោទនា និងទ្រង់ប្រកាសសច្ចធម៌ ។ នាយសុប្បពុទ្ធអង្គុយក្នុងទីដែលខ្លួនអង្គុយនោះ កាលចប់ទេសនា បញ្ជូនញាណទៅតាមក្រសែនៃធម្មទេសនា បានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះសាស្តាទ្រង់ក្រោកឡើងស្តេចទៅកាន់ព្រះវិហារ ។ សូម្បីនាយសុប្បពុទ្ធនោះ ក៏ពាក់ស្បែកជើង កាន់អំបែង កាន់ឈើច្រត់ទៅទីលំនៅរបស់ខ្លួន ត្រូវមេគោជល់ស្លាប់ ទៅកើតក្នុងទេវលោកក្នុងវារៈចិត្តទីពីរ ដូចទម្លាយផ្ទាំងដីហើយបានផ្ទាំងមាស អាស្រ័យបុណ្យរបស់ខ្លួនទើបរុងរឿងកន្លងពួកទេវតាដទៃ ។ ទេវានមិន្ទ កាលនឹងសម្តែងដល់ហេតុនោះ ទើបពោលពាក្យមានជាដើមថា **ឯសោ ខោ មារិស** ដូច្នេះ ។

**[៣៩៨]** បទថា **សទ្ធា** បានដល់ សទ្ធាដែលកើតរួមជាមួយមគ្គ ។ បទថា **សីលញ្ច យស្ស កល្យាណំ** បានដល់ កល្យាណសីលដែលលោកពោលថា អរិយកន្តសីលរបស់ព្រះអរិយសាវក ។ ក្នុងលំដាប់នោះ សីល

សូម្បីមួយរបស់ព្រះអរិយសាវក ឈ្មោះថា មិនគួរប្រាថ្នារមែងមិនមាន ក្នុង
សេចក្តីនេះ លោកបំណងយកបញ្ចសីលដែលមិនលះបង់ សូម្បីក្នុងកពផ្សេងៗ ។

ចប់អដ្ឋកថា ឧឡិន្ទសូត្រទី ៤

# អ ដ្ឋ ក ថា

## រាមណេយ្យកសូត្រទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុង *រាមណេយ្យកសូត្រទី ៥* តទៅនេះ ៖

[៤០០] បទថា *អារាមចេត្យា* បានដល់ ចេតិយក្នុងសួន ។ បទថា *វនចេត្យា* បានដល់ ចេតិយត្រង់ភ្នំ និងព្រៃ ។ សូម្បីក្នុងបទទាំងពីរនោះ គប្បីជ្រាបថា ឈ្មោះថា ចេតិយ ព្រោះអត្ថថា ធ្វើឲ្យកើតសេចក្តីគោរព ។ បទថា *មនុស្សរាមណេយ្យស្ស* គឺ ជាស្ថានទីដែលគួររីករាយរបស់មនុស្ស ។ ឥឡូវនេះ ព្រះមានព្រះភាគកាលទ្រង់ទីងសម្តែងដល់ភូមិដែលគួររីករាយ ដោយអំណាចជាភូមិដែលគួររីករាយរបស់មនុស្ស ទើបត្រាស់ថា *គាមេ វា* ដូច្នេះជាដើម ។

ចប់អដ្ឋកថា រាមណេយ្យកសូត្រទី ៥

# អ ដ្ឋ ក ថា

## យញ្ញមានសូត្រទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុង យជមានសូត្រទី ៦ តទៅនេះ ៖

**[៤០២]** បទថា យជមានានំ ប្រែថា បូជា ។ បានឮមកថា ក្នុងគ្រានោះ ពួកអ្នកដែនអង្គៈ និងមគធៈ បានកាន់យកទឹកដោះថ្លា ទឹកឃ្មុំ និងទឹកអំពៅជាដើមដ៏ប្រសើរប្រចាំឆ្នាំ ដឹកឧសដោយរទេះប្រមាណ ៦០ រទេះ គរទុកក្នុងកន្លែងមួយ ហើយបង្កាត់ភ្លើង ខណៈដែលភ្លើងឆេះ ដាក់របស់ដ៏ប្រសើរទាំងអស់នោះ ដោយបំណងថា ពួកយើងនឹងបូជាមហាព្រហ្ម ។ បានឮថា ការជឿរបស់ពួកគេថា ដាក់ចុះម្តង នឹងឲ្យផលស្មើមួយសែន ។ សក្កទេវរាជត្រិះរិះថា ពួកមនុស្សទាំងអស់នេះ កាន់យករបស់ដ៏ប្រសើរទាំងពួង ដុតក្នុងភ្លើង ដោយបំណងថា ពួកយើងនឹងបូជាមហាព្រហ្ម ធ្វើវត្ថុគ្មានផល កាលយើងឃើញហើយ ពួកគេចូរកុំវិនាសឡើយ យើងនឹងធ្វើឲ្យពួកគេថ្វាយដល់ព្រះពុទ្ធនិងព្រះសង្ឃប៉ុណ្ណោះ ហើយនឹងប្រសព្វបុណ្យដ៏ច្រើន ដូច្នេះ កាលពួកមនុស្សធ្វើគំនរឧសឲ្យរុងរឿង លុះបានសម្លឹងមើលហើយ ទើបទ្រង់ក្លែងខ្លួនជាព្រហ្ម

ក្នុងថ្ងៃ ១៥ កើត កាលមហាជនក្រឡេកមើលហើយទុំះឯង បានធ្វើដូចជាវេចចន្ទមណ្ឌលចេញទៅ ។ មហាជន លុះឃើញហើយ ក៏នាំគ្នាគិតថា មហាព្រហ្ម ស្តេចមកទទួលគ្រឿងបូជានេះ ទើបលុតជង្គង់ចុះនឹងផែនដី ផ្គងអញ្ជលីបង្អោនទមស្ការ ។ ពួកព្រាហ្មណ៍ពោលថា ពួកលោកសម្គាល់ថា យើងនិយាយលេងឬ ឥឡូវនេះពួកលោកចូរមើលចុះ ព្រះព្រហ្មអង្គនេះ មកទទួលគ្រឿងបូជារបស់ពួកយើងដោយដៃខ្លួនឯង ។ សក្កទេវរាជ ស្តេចមកឈរនៅកណ្តាលអាកាស ខាងលើគំនរឧស ត្រាស់សួរថា សក្ការៈនេះ ដើម្បីអ្នកណា មានអ្នកទូលថា បពិត្រមហាព្រហ្មដ៏ចម្រើន ដើម្បីព្រះអង្គ សូមព្រះអង្គទ្រង់ទទួលគ្រឿងបូជារបស់ពួកខ្ញុំចុះ ។ មហាព្រហ្មត្រាស់ថា បើដូច្នោះ ពួកលោកចូរមក កុំចោលគ្រឿងថ្វីង ហើយថ្វីងដោយដៃ ព្រះសាស្តាប្រថាប់នៅវិហារជិតៗ ពួកយើងនឹងទូលសួរព្រះអង្គថា ឲ្យទានដល់អ្នកណា ទើបនឹងមានផលច្រើន ដូច្នេះ ។ សក្កទេវរាជ ទ្រង់នាំពួកអ្នកដែនទាំងពីរទៅគាល់ព្រះសាស្តា កាលនឹងទូលសួរ ទើបត្រាស់យ៉ាងនេះ ។ ក្នុងបទទាំងនោះ បទថា **បុញ្ញ-បេក្ខានំ** បានដល់ ប្រាថ្នាបុណ្យ គឺ មានសេចក្តីត្រូវការបុណ្យ ។ បទថា **ឱបធិកំ បុញ្ញំ** បានដល់ បុណ្យមានឧបធិជាវិបាក ។

[៤០៣] បទថា *សង្ឃេ ទិន្នំ មហប្ផលំ* សេចក្តីថា ទានដែលថ្វាយក្នុងព្រះអរិយសង្ឃ រមែងមានផលធំទូលាយ ។ កាលទេសនាចប់ ជន ៨៤.០០០ បានផឹកទឹក គឺ អមតធម៌ ។ បន្ទាប់ពីនោះមក ពួកមនុស្សបាននាំគ្នាថ្វាយទានដ៏ប្រសើរទាំងពួងដល់ភិក្ខុសង្ឃ ។

ចប់អដ្ឋកថា យជមានសូត្រទី ៦

# អ ដ្ឋ ក ថា

## វន្ទនសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុង *វន្ទនសូត្រទី ៧* តទៅនេះ ៖

**[៤០៥]** បទថា **ឧដ្ឋាហិ** ប្រែថា ចូរក្រោកឡើង គឺ ចូរប្រឹងប្រែងព្យាយាម ។ បទថា **វិជិតសង្គាម** សេចក្តីថា សក្កទេវរាជ ហៅព្រះមានព្រះភាគយ៉ាងនេះ ព្រោះព្រះមានព្រះភាគទ្រង់ឈ្នះកិលេស មានរាគៈជាដើម និងផ្ចាញ់ពលរបស់មារប្រមាណ ១២ យោជន៍ ។ បទថា **បន្នភារ** បានដល់មានភារៈ គឺ ខន្ធ កិលេស អភិសង្ខារ ដែលដាក់ចុះហើយ ។ បទថា **បណ្ណរសាយ រត្តិំ** គឺ ពេលយប់ថ្ងៃ ១៥ កើត ។

ចប់អដ្ឋកថា វន្ទនសូត្រទី ៧

# អ ដ្ឋ ក ថា

## បឋមសក្កនមស្សនសូត្រទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុង **បឋមសក្កនមស្សនសូត្រទី ៨** តទៅនេះ ៖

**[៤០៨]** បទថា **បុថុទ្ទិសា** បានដល់ ទិសធំ ៤ និងទិសតូច ៤ ។ បទថា **កុម្មា** បានដល់ អ្នកនៅលើផែនដី ។

**[៤០៩]** បទថា **ចិររត្តំ សមាហិតេ** បានដល់ អ្នកមានចិត្តតាំងមាំហើយដោយឧបចារៈ និងអប្បនា រហូតដល់អស់រាត្រីយូរ ។ បទថា **វន្ទេ** បានដល់ ខ្ញុំសូមថ្វាយបង្គំ ។ បទថា **ព្រហ្មចរិយបរាយនេ** អធិប្បាយថា ប្រព្រឹត្តព្រហ្មចរិយៈ ជាការប្រព្រឹត្តដ៏ប្រសើរជាដើមថា ដេកម្នាក់ឯង ឆាន់ម្នាក់ឯង ក្នុងទីបំផុតជីវិត រហូតដល់អស់ ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ។ល។ ៦០ ឆ្នាំខ្លះ ។ បទថា **បុញ្ញករា** បានដល់ អ្នកធ្វើបុណ្យ មានជាដើមយ៉ាងនេះថា ថ្វាយបច្ច័យ ៤ បូជាដោយផ្កាម្លិះមួយថ្នាំង បូជាប្រទីបមួយពាន់ដួង ។ បទថា **សីលវន្តោ** សេចក្តីថា តាំងនៅក្នុងភាពជាឧបាសក ប្រកបដោយសីល ៥ ខ្លះ សីល ១០ ខ្លះ ។ បទថា **ធម្មេន ទារំ បោសេន្តិ** បានដល់ មិនធ្វើចោរកម្ម មានការជីក

ឧម្មគ្គជាដើម ចិញ្ចឹមរក្សាបុត្រភរិយាដោយកសិកម្ម គោរក្ខកម្ម និងពាណិជ្ជ-កម្មជាដើម ។

**[៤១១]** *បទថា* ***បមុខោ រថមារុហិ*** *បានដល់ ជាប្រធាន គឺ ជាបុគ្គលប្រសើររបស់ទេវតាទាំងឡាយ ស្តេចឡើងរថ ។*

ចប់អដ្ឋកថា បឋមសក្កនមស្សនសូត្រទី ៨

# អ ដ្ឋ ក ថា

## ទុតិយសក្កនមស្សនសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសក្កនមស្សនសូត្រទី ៩ តទៅនេះ ៖

**[៤១២]** បទថា **ភគវន្តំ នមស្សតិ** សេចក្តីថា សក្កទេវរាជផ្ចង់ សំពត់ពីរជាន់ឆៀងស្មា អង្គុយលុតជង្គង់បែបព្រហ្ម ប្រណម្យអញ្ជលីលើសិរសៈ ។

**[៤១៣]** បទថា **សោ យក្ខោ** បានដល់ សត្វនោះ ។

**[៤១៤]** បទថា **អនោមនាមំ** បានដល់ មានព្រះនាមមិនថោកថយ ដោយព្រះនាមដែលជានិមិត្តនៃគុណ ព្រោះមិនមានភាពថោកទាបដោយគុណទាំងពួង ។ បទថា **អវិជ្ជាសមតិក្កមា** បានដល់ ឈានកន្លងអវិជ្ជា ដែលមានវដ្តៈជាមូល ព្រោះបិទបាំងអរិយសច្ច ៤ ជាដើម ។ បទថា **សេក្ខា** បានដល់ ព្រះសេក្ខៈ ៧ ពួក ។ បទថា **អបចយារាមា** គឺ ត្រេកអរក្នុងកិរិយាកម្ចាត់វដ្តៈ ។ បទថា **សិក្ខរេ** ប្រែថា រមែងសិក្សា ។

ចប់អដ្ឋកថា ទុតិយសក្កនមស្សនសូត្រទី៩

# អ ដ្ឋ ក ថា

## តតិយសក្កនមស្សនសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុង **តតិយសក្កនមស្សនសូត្រទី ១០** តទៅនេះ ៖

**[៤១៨]** បទថា **អជ្ឈភាសិ** សេចក្តីថា ព្រោះហេតុអ្វី មាតលិសង្គាហកទេវបុត្រនេះ ទើបពោលយ៉ាងនេះរឿយៗ ។ បានឮមកថា សក្កទេវរាជមានព្រះសូរសេងពីរោះក្នុងវេលាត្រាស់ ព្រោះមានព្រះទន្តស្និទ្ធ បន្ទឺព្រះសូរសេងខ្ទាំងដូចសំឡេងកណ្តឹងមាស ។ មាតលិសង្គាហកទេវបុត្រនិយាយថា យើងនឹងបានស្តាប់ព្រះសូរសេងនោះរឿយៗ ។ បទថា **បូតិទេហសយា** សេចក្តីថា ឈ្មោះថា ដេកសន្ធត់លើកាយស្អុយ ព្រោះដេកសន្ធត់លើរាងកាយរបស់មាតាដែលស្អុយ ឬសរីរៈរបស់ខ្លួនឯង ។ បទថា **និមុគ្គា កុណបស្មេតេ** គឺ បុគ្គលទាំងនេះ លិចនៅក្នុងសាកសព ពោលគឺ ផ្ទៃមាតារហូតអស់ ១០ ខែ ។

**[៤១៩]** បទថា **ឯតំ នេសំ បិហយាមិ** បានដល់ យើងពេញចិត្តមារយាទរបស់លោកដែលមិនមានផ្ទះទាំងនោះ ។ បទថា **ន តេសំ កោដ្ឋេ ឱបេន្តិ** សេចក្តីថា បុគ្គលនឹងមិនរក្សាស្រូវរបស់លោកទាំងនោះទុកក្នុងជង្រុក

គឺ អន្ទរបស់លោកទាំងនោះ មិនមាន ។ បទថា **ន កុម្ភា** បានដល់ មិនរក្សាទុកក្នុងក្អម ។ បទថា **ន កឡោបិយំ** បានដល់ មិនរក្សាទុកក្នុងកញ្ជើ ។ បទថា **បរនិដ្ឋិតមេសនា** បានដល់ ស្វែងរករបស់ដែលឆ្អិនស្រេចក្នុងផ្ទះនោះៗ ដែលសម្រេចដើម្បីពួកអ្នកដទៃ ដោយកិច្ចាចារវត្ត ។ បទថា **តេន** បានដល់ ដោយការស្វែងរកយ៉ាងនេះ ។ បទថា **សុព្វតា** បានដល់ សមាទានវត្តល្អហើយ រហូតអស់ ១០ ឆ្នាំខ្លះ ៦០ ឆ្នាំខ្លះ ។ បទថា **សុមន្តនិនោ** គឺ មានប្រក្រតីពោលពាក្យជាសុភាសិត យ៉ាងនេះថា យើងនឹងស្វាធ្យាយធម៌ នឹងបដិបត្តិធុតង្គ នឹងបំពេញសមណធម៌ ដូច្នេះ ។ បទថា **តុណ្ហីភូតា សមណញ្ចរា** សេចក្តីថា សូម្បីពោលធម៌ ក៏នៅព្រំពង់ រហូតអស់យាមទាំង ៣ ដូចសំឡេងផ្គរលាន់ ។

សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះមិនមានពាក្យដែលគ្មានប្រយោជន៍ ។ បទថា **បុថុមច្ចា ច** បានដល់ ពួកសត្វជាច្រើនឈ្មោះគ្នា ។ បទថា **អត្ថទណ្ឌេសុ និព្វុតា** បានដល់ រំលត់បានក្នុងអាជ្ញាដែលកាន់យកហើយ ដើម្បីបៀតបៀនអ្នកដទៃ គឺ លះបង់អាជ្ញាចេញហើយ ។ បទថា **សាទានេសុ អនាទានា** សេចក្តីថា កាលសត្វទាំងឡាយមានសេចក្តីប្រកាន់មាំ លោកមិនមាន

សេចក្ដីប្រកាន់មាំ ព្រោះមិនប្រកាន់មាំ សូម្បីចំណែកមួយនៃភព និងកំណើត ជាដើម ។

ចប់អដ្ឋកថា តតិយសក្កនមស្សនសូត្រទី ១០

## ចប់វគ្គទី ២

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា


១-អដ្ឋកថាបឋមទេវសូត្រ ២-អដ្ឋកថាទុតិយទេវសូត្រ
៣-អដ្ឋកថាតតិយទេវសូត្រ ៤-អដ្ឋកថាទលិទ្ទសូត្រ
៥-អដ្ឋកថារាមណេយ្យកសូត្រ ៦-អដ្ឋកថាយជមានសូត្រ
៧-អដ្ឋកថាវន្ទនសូត្រ ៨-អដ្ឋកថាបឋមសក្កនមស្សនសូត្រ
៩-អដ្ឋកថាទុតិយសក្កនមស្សនសូត្រ ១០-អដ្ឋកថាតតិយសក្កនមស្សនសូត្រ

# សក្កបញ្ចក

## វគ្គទី ៣

## អដ្ឋកថា

### យជ្ជសូត្រទី ១

[៤២២] *យជ្ជសូត្រទី ១ នៃវគ្គតតិយវគ្គ មានសេចក្តីងាយទាំងអស់នោះឯង ។*

---

# អ ដ្ឋ ក ថា

## ទុព្វណ្ណិយសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុព្វណ្ណិយសូត្រទី ២ តទៅនេះ ៖*

**[៤២៥]** *បទថា* ***ទុព្វណ្ណោ*** *បានដល់ មានសម្បុរដូចជន្លត់ត្រូវភ្លើងឆេះ ។ បទថា* ***ឱកោដិមកោ*** *បានដល់ ពោះកំប៉ោង ។ បទថា* ***អាសនេ*** *បានដល់ បណ្ឌុកម្ពលសិលា ។*

**[៤២៦]** *បទថា* ***កោធភក្ខោ យក្ខោ*** *នេះ ប្រែថា យក្ខនោះឈ្មោះ* ***កោធភក្ខ*** *(មានសេចក្ដីក្រោធជាអាហារ) ជាឈ្មោះដែលសក្កទេវរាជដាក់ឲ្យ ។ យក្ខម្នាក់នោះ ជារូបាវចរព្រហ្ម ។ បានឮមកថា ន័យថា សក្កទេវរាជដល់ព្រមដោយកម្លាំង គឺ ខន្តិ ទើបស្ដេចមកដើម្បីសាកល្បងមើល ។ ក៏អវរុទ្ធកយក្ខមិនអាចចូលទៅកាន់ទីដែលរក្សាទុកបែបនេះបាន ។*

**[៤២៧]** *បទថា* ***ឧបសង្កមិ*** *សេចក្ដីថា សក្កទេវរាជស្ដាប់ពួកទេវតាហើយ គិតថា មិនអាចឲ្យយក្ខនេះញាប់ញ័របានដោយពាក្យគ្រោតគ្រាត ឯអ្នកប្រព្រឹត្តបន្ទាបខ្លួនតាំងនៅក្នុងខន្តិ ទើបអាចឲ្យយក្ខនោះចៀសចេញទៅបាន ដូច្នេះ*

មានបំណងនឹងឲ្យយក្ខនោះចៀសចេញទៅដោយប្រការនោះ ទើបស្តេចចូលទៅរក ។ បទថា **អន្តរធាយិ** សេចក្តីថា កាលសក្កទេវរាជទ្រង់តាំងនៅក្នុងខន្តិធ្វើសេចក្តីគោរពយ៉ាងខ្លាំងក្លាឲ្យប្រាកដ សម្តែងសេចក្តីបន្ទាបខ្លួន យក្ខនោះមិនអាចនឹងនៅលើអាសនៈរបស់សក្កទេវរាជបាន ទើបចៀសចេញទៅ ។ ពាក្យថា **សុ** ក្នុងបទនេះថា **ន សុបហតចិត្តោម្ហិ** ត្រឹមតែនិបាត ។ លោកពោលថា យើងជាអ្នកមានចិត្តដែលទោសៈមិនបៀតបៀនហើយ ។ បទថា **នាវត្តេន សុវានយោ** លោកពោលថា យើងមិនឲ្យធម៌ជាគ្រឿងត្រឡប់ចិត្ត ព្រោះសេចក្តីក្រោធនាំទៅបានដោយងាយទេ គឺ យើងមិនមែនជាអ្នកចេះតែធ្វើដោយងាយទៅតាមអំណាចដោយសេចក្តីក្រោធ ។

ពាក្យថា **វេ** ក្នុងបទថា **ន វេ ចិរាហំ** ត្រឹមតែនិបាត ។ លោកពោលថា យើងមិនក្រោធមកយូរហើយ ។

ចប់អដ្ឋកថា ទុព្វណ្ណិយសូត្រទី ២

# អ ដ្ឋ ក ថា

## មាយាសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង មាយាសូត្រទី ៣ តទៅនេះ ៖

**[៤២៩]** បទថា **អាពាធិកោ** បានដល់ មានអាពាធជាទម្ងន់ ដោយអាពាធដែលកើតហើយក្នុងវេលាពួកឥសីផ្ដាសា ។ បទថា **វាចេហិ មំ** សេចក្ដីថា សក្កទេវរាជត្រាស់ថា ប្រសិនបើលោកប្រាប់កលល្បិចដល់យើង យើងទើបនឹងព្យាបាលលោក ។ បទថា **មា ខោ ត្វំមារិស វាចេសិ** សេចក្ដីថា ពួកអសុរពោលថា កុំប្រាប់កលល្បិច សក្កទេវរាជនឹងបៀតបៀនពួកយើង តែបើសក្កទេវរាជនឹងដឹងកលល្បិចនោះ ពួកយើងនឹងវិនាស សក្កទេវរាជកុំធ្វើឲ្យពួកយើងវិនាស ព្រោះប្រយោជន៍របស់ខ្លួនម្នាក់ឯងឡើយ ទើបហាម ។

**[៤៣០]** បទថា **សម្ពរោវសតំ សមំ** សេចក្ដីថា ស្ដេចអសុរវេបចិត្តិពោលថា ក៏ពួកលោកជាអ្នកតាំងនៅក្នុងធម៌ ពួកលោកមិនគួរពេញចិត្តក្នុងកលល្បិច នឹងអន្ទះអន្ទែងដូចស្ដេចអសុរមានកលល្បិច ប្រកបដោយកលល្បិចឆេះក្នុងនរករហូតអស់មួយរយឆ្នាំ ។

សួរថា ក៏សក្កទេវរាជអាច ព្យាបាលសេចក្តីក្រោធរបស់ស្តេចអសុរវេបចិត្តិបានឬ ។

ឆ្លើយថា អាច ។

សួរថា យ៉ាងណា ។

ឆ្លើយថា បានឮមកថា ក្នុងកាលពួកឥសីតាំងនៅ ព្រោះដូច្នោះ សក្កទេវរាជក៏នាំស្តេចអសុរវេបចិត្តិទៅរកឥសីឲ្យលើកទោស ដោយអាការយ៉ាងនេះ ស្តេចអសុរវេបចិត្តិនឹងគប្បីមានសេចក្តីសុខ តែមិនធ្វើយ៉ាងនោះ ក៏ជៀសចេញទៅ ព្រោះត្រូវលួងលោម ។

ចប់អដ្ឋកថា មាយាសូត្រ ទី ៣

# អ ដ្ឋ ក ថា

## អច្ចយសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង អច្ចយសូត្រទី ៤ តទៅនេះ ៖

[៤៣១] បទថា *សម្បយោជេសុំ* ប្រែថា ឈ្លោះគ្នា ។ បទថា *អច្ចសរា* បានដល់ បំពានហួស ។ អធិប្បាយថា ភិក្ខុមួយរូប បានពោលពាក្យបំពានលើភិក្ខុមួយរូប ។

[៤៣៣] បទថា *យថាធម្មំ ន បដិគ្គណ្ហាតិ* បានដល់ មិនលើកទោស ។

[៤៣៤] បទថា *កោធោ វោវសមាយាតុ* លោកសម្ដែងថា សេចក្ដីក្រោធចូរមកក្នុងអំណាចរបស់ពួកលោក ពួកលោកកុំទៅក្នុងអំណាចរបស់សេចក្ដីក្រោធ ។ ពាក្យថា *ហិ* ក្នុងបទនេះថា *មា ច មិត្តេ ហិ វោជរា* ត្រឹមតែនិបាត ។ សេចក្ដីវិនាសក្នុងមិត្តធម៌ កុំកើតដល់ពួកលោក ។ម្យ៉ាងទៀត ជាតតិយាវិភត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ អធិប្បាយថា សេចក្ដីវិនាសកុំកើតក្នុងមិត្តធម៌ គឺថា ចូរកុំមានដល់ភាពជាមិត្តដោយប្រការដទៃ ។ បទថា *អគរហិយំ មា គរហិត្ថ* សេចក្ដីថា កុំតិះដៀលអ្នកមិនគួរតិះដៀល គឺ បុគ្គលដែល

ជាទីណាស្រេច ។

ចប់អដ្ឋកថា អច្ចយសូត្រទី ៤

# អ ដ្ឋ ក ថា

## អក្កោធសូត្រទី ៥

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអក្កោធសូត្រទី ៥ តទៅនេះ ៖

[៤៣៦] បទថា មា វោ កោធោ អជ្ឈភវិ សេចក្តីថា សេចក្តីក្រោធ កុំបានគ្របសង្កត់ពួកលោក ពួកលោកទាំងឯង ចូរគ្របសង្កត់សេចក្តីក្រោធ ។ បទថា មា ច កុជ្ឈិត្ថកុជ្ឈតំ សេចក្តីថា កាលគេក្រោធ កុំក្រោធតប ។ បទថា អក្កោធោ បានដល់ មេត្តា និងធម៌ជាបុព្វភាគរបស់មេត្តា ។ បទថា អហឹសា បានដល់ករុណា និងធម៌ជាបុព្វភាគរបស់ករុណា ។ បទថា អថ បាបជនំ កោធោ បព្វតោវាភិមទ្ទតិ សេចក្តីថា សេចក្តីក្រោធដូចជាភ្នំ រមែងញាំញីដល់បុគ្គលលាមក ដូច្នោះ ។

ចប់អដ្ឋកថា អក្កោធសូត្រ ទី ៥

## ចប់វគ្គទី ៣

### រួមក្នុងវគ្គនេះមាន ៥ អដ្ឋកថា

១-អដ្ឋកថាយញ្ញា ២-អដ្ឋកថាឧព្វណ្ណិយ ៣-អដ្ឋកថាមាយា
៤-អដ្ឋកថាអច្ចយ ៥-អដ្ឋកថាអក្កោធ

# ចប់វណ្ណនា

# សារត្ថប្បកាសិនី

## អដ្ឋកថាសំយុត្តនិកាយ សគាថវគ្គ

### ដោយប្រការដូច្នេះ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 US |

តាមរយៈភិក្ខុធម្មប្បញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ
នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក

| | |
|---|---|
| -សមាគមពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | $ 300 US |
| -ភិក្ខុវិជ្ជាសម្បន្នោ ឈួម សំបូរ និងឧបាសិកាគង់ គី | $ 200 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 105 US |
| -ឧបាសិកា ជីវ យួម និងស្វាមី ព្រមទាំងបុត្ត | $ 101 US |
| -ឧបាសក សោម រតនៈ និងភរិយា " ខេត្តព្រៃវែង " | $ 100 US |
| -សីលវត្តី នួន សូនី និងបុត្ត នាងវ៉ង់ | $ 100 US |
| -លោក គ្រី សុភី និងភរិយា ផៃ សុណាំង ព្រមទាំងបុត្ត | $ 100 US |
| -លោក តឹក គ្រី និងភរិយា ព្រមទាំងបុត្ត | $ 100 US |
| -ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព | $ 100 US |
| -ឧបាសក លន ចំរើន ឧបាសិកា ម៉ុក ថានិ | $ 100 US |
| -ឧបាសក ម៉ៅ ប៊ួយ ឧបាសិកា ម៉ៅ លន់<br>-ម៉ៅ ម៉ារ៉ា និងសៀង ថៃបញ្ញារិទ្ធ ព្រមទាំងបុត្ត<br>-ម៉ៅ ម៉ារ៉ង ម៉ៅ គឹមអាន ម៉ៅ គឹមសៀង<br>-ម៉ៅ ប៊ុនសន្ថា ក្ហួយស្រី ធន់ សន្ថានី | $ 700 US |
| -ឧបាសិកា ពិន សាមឿន និងបុត្ត | $ 50 US |
| -ឧបាសិកា ពិន សាម៉ុន និងបុត្ត | $ 50 US |
| -ឧបាសិកា ប៊ុន សារ៉ុម និងបុត្ត | $ 50 US |
| -ឧបាសិកា គង់ ជី និងបុត្ត | $ 50 US |

| | |
|---|---|
| -ឧបាសិកា ឡាច ម៉ាឡៃ និងបុត្ត | $ 50 US |
| -ឧបាសិកា ទូត ច័ន្ទវណ្ណី និងបុត្ត | $ 50 US |
| -ឧបាសិកា ម៉ែន សាវ៉ាត | $ 50 US |
| -ឧបាសិកា ពិន សាត | $ 50 US |
| -ឧបាសិកា អ៊ុំ សាត | $ 50 US |
| -លោក ណៃ សារិន និងឧបាសិកា ជា សូភី | $ 50 US |
| -លោក កែវ ណាត និងឧបាសិកា សឹម គឿន | $ 50 US |
| -ឧបាសក កុក ឆាយ និងកូនប្រុស ឧបាសក តាំង សុផល និងភរិយា ព្រមទាំងបុត្ត នៅខេត្តបាត់ដំបង | $ 50 US |
| -ឧបាសិកា សៀន សេង និងបុត្ត | $ 20 US |
| -ឧបាសក ឡាង ឆរី និងភរិយា ព្រមទាំងបុត្ត | $ 20 US |
| -ឧបាសក ម៉ឺន ប៊ុនហេង និងឧបាសិកា កូវ៉ាញ | $ 20 US |
| -ឧបាសក ប៉ោ ហេង និងឧបាសិកា លន់ ឈុនលី | $ 20 US |
| -ឧបាសិកា ពិន សាម៉ុន | $ 20 US |
| -ឧបាសក កែវ សារិន ឧបាសិកា សំឯម | $ 15 US |
| -ឧបាសិកា ប៊ុន សារុំ | $ 10 US |
| -ឧបាសិកា ហាក់ សៃហេង | $ 10 US |
| -ឧបាសិកា ទេព សុផល | $ 10 US |
| -ឧបាសិកា ទេព ណាម | $ 10 US |
| -ឧបាសក គឹម កក់ និងភរិយា ពិសី | $ 10 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 10 US |
| -ឧបាសិកា តាំង ផល្លា ព្រមទាំងស្វាមី និងបុត្ត | $ 10 US |
| -ឧបាសក តាំង សុខឡាយ ភរិយា និងបុត្ត | $ 10 US |
| -អ្នកស្រី បុប្ផាអ៊ីវ និងស្វាមី ព្រមទាំងបុត្ត | $ 10 US |
| -ឧបាសក យិន ឈូ និងភរិយា ព្រមទាំងបុត្ត | $ 6 US |
| -ឧបាសក តាំង សុខឡាយ ឧបាសិកា សន ស៊ីណែត និងបុត្ត នៅខេត្តបាត់ដំបង | $ 5 US |

## តាមរយៈភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ប្រទេសអូស្ត្រាលី

| | |
|---|---|
| -ភិក្ខុ ចៅ សៀប " អូស្ត្រាលី " | 100 AUS |
| -ពុទ្ធបរិស័ទច្រើននាក់ " ម៉ែលបិន " | 955 AUS |
| -បុណ្យនៅផ្ទះឧបាសិកា លឹម ស៊ូឆេង | 627 AUS |
| -បុណ្យនៅផ្ទះឧបាសិកា ស៊ុយ មន្ថា ព្រមទាំងកូនចៅ | 450 AUS |
| -បុណ្យនៅផ្ទះឧបាសិកា អ៊ូច សុផល្លី ព្រមទាំងបុត្ត | 400 AUS |
| -ឧបាសក ឡៅ គឹមងួន ឧបាសិកា ដួង លី | 200 AUS |
| -បុណ្យនៅផ្ទះឧបាសិកា តែ យក់ហ៊ុន | 200 AUS |
| -ឧបសិកា គង់ សារឿម | 200 AUS |
| -លោកជំទាវ " ឯកអគ្គរដ្ឋទូតអាឡឺម៉ង់ " | 100 US |
| -ឧបាសិកា កូវ សារី | 100 AUS |
| -ឧបាសិកា ឈ គិមស៊ិន និងបុត្ត សំ ថានី | 100 AUS |
| -លោក ឥន ចារ៉ាន់ ឧបាសិកា យ៉ុម យ៉ា | 100 AUS |
| -ឧបាសក ឌី មុយ ឧបាសិកា តែ ចាន់ណារ៉ា | 100 AUS |
| -ឧបាសិកា ឯម ផាយ៉,ឆេង លន់,ម៉ា ឈួអៀ,អាបួយ | 70 AUS |
| -ឧបាសក ឈិត ទ្រី ឧបាសិកា បាន់ ណៃហ៊ាង | 50 AUS |
| -ឧបាសិកា សុឃឿន ប៊ូ | 50 AUS |
| -ឧបាសក ឡុង ហ៊ន ឧបាសិកា លិម យូអេង និងបុត្ត | 50 AUS |
| -ឧបាសិកា ហេង ប៉េគី ព្រមទាំងកូនចៅ | 50 AUS |
| -ឧបាសិកា ស៊ុម គិមហេង | 50 AUS |
| -ឧបាសិកា ឃីម វីឡាត់ | 50 AUS |
| -ឧបាសក តូ សឿន ឧបាសិកា មាន សុវត្ថិ និងបុត្ត | 50 AUS |
| -ឧបាសក មង្គល ផន ឧបាសិកា គឹម លាភ ( មាណ) | 50 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 50 AUS |
| -ឧបាសិកា ផ្លោក វណ្ណា | 40 AUS |
| -ឧបាសិកា សំ សុមុន្ថា ស្វាមី និងបុត្ត | 30 AUS |
| -ឧបាសិកា រ័ត្ន គីមសាន | 30 AUS |
| -ឧបាសិកា ខូវ ម៉េងលួង ព្រមទាំងស្វាមី និងបុត្ត | 30 AUS |
| -ឧបាសក ហៀក ប៉េងហួរ ឧបាសិកា ផ្លោក ម៉ុង | 30 AUS |
| -ឧបាសិកា ទូច សីណា និងស្វាមី | 20 AUS |

| | |
|---|---|
| -ឧបាសក ស៊ូ យីម ឧបាសិកា ស៊ូ សៀងតិច | 20 AUS |
| -ឧបាសក ប៉េង គ្រីគួ ឧបាសិកា គឹម សៀងគួ | 20 AUS |
| -ឧបាសិកា គង់ សម្បត្តិ | 20 AUS |
| -ឧបាសិកា ចំរើន វ៉ាក់ជិត | 20 AUS |
| -ឧបាសិកា តែ យក់ហ៊ុន | 20 AUS |
| -ឧបាសិកា យ៉ា យ៉ុម | 20 AUS |
| -ឧបាសិកា លឹម ស៊ូឆេង | 20 AUS |
| -ឧបាសក សន់ ប៊ុនភារ ឧបាសិកា កាំង គីមហាន | 20 AUS |
| -ឧបាសិកា ហេង ងួនអ៊ុម | 20 AUS |
| -ឧបាសិកា យានី | 20 AUS |
| -សេង សៀងឈុន | 20 AUS |
| -ឧបាសក វ៉ាន់ យ៉ាណូរ៉េត ឧបាសិកា វ៉ាន់យ៉ាណូរី | 20 AUS |
| -ឧបាសិកា អ៊ុច សុផល្លី | 20 AUS |
| -ឧបាសិកា ឡាច សារីម | 15 AUS |
| -ចៃស៊ីម,ចៃខេង,អាមួយ | 15 AUS |
| -ឧបាសិកា កួវ សារី | 15 AUS |
| -ឧបាសិកា ទូច ស៊ីណា | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លីសាង | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លាង ហុងប៊ុន | 10 AUS |
| -ឧបាសិកា សៀ ចន្ថា និងគ្រួសារ | 10 AUS |
| -ឧបាសិកា កាំង អ៊ីវហ៊ួច | 10 AUS |
| -ឧបាសក ក្រូច សាន | 10 AUS |
| -ឧបាសិកា សា ចាន់ថា | 10 AUS |
| -ឧបាសក យឹម វ៉ាន់ ឧបាសិកា អ៊ុំ ខេង | 10 AUS |
| -ឧបាសក សុខ ជួន ឧបាសិកា សុខ ធួក | 10 AUS |
| -ឧបាសិកា អេង ងីមសុខ | 10 AUS |
| -ឧបាសក ឃុត សរ ឧបាសិកា សុខ សច្ចា | 10 AUS |
| -ឧបាសិកា កេសរកូល និងគ្រួសារ | 5 AUS |
| -ឧបាសិកា វាំណ្ណនីសា | 5 AUS |
| -ឧបាសិកា សាន់ ឆាយ, គីម ស្រួន | 5 AUS |

| | |
|---|---|
| -ភិក្ខុ ឆុំ សារឿន និងពុទ្ធបរិស័ទ វត្តពន្លឺពុទ្ធចក្ក | 620 USA |
| -ឧបាសក សោមរតនះ ឧបាសិកា ស៊ុប វណ្ណា និងបុត្ត | 200 USA<br>និង 1 លានរៀល |
| -ឧបាសក តាំង សុផល ឧបាសិកា ឡុង កេន និងបុត្ត | 30 USA |
| -ហាង ពិភពកុំព្យូទ័រ | 20 USA |
| -ឧបាសិកា តាំង ផល្លា និងស្វាមី ព្រមទាំងបុត្ត | 10 USA |
| -ឧបាសក ហេង វីរិន្ទ និងភរិយា ព្រមទាំងបុត្ត | 10 USA<br>និង 2 ម៉ឺនរៀល |
| -ឧបាសក តាំង សុខឡាយ និងភរិយា ព្រមទាំងបុត្ត | 10 USA |
| -ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមយន់ និងកូនចៅ | 5 USA<br>និង 1 ម៉ឺនរៀល |
| -ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ធីតា និងកូនចៅ | 5 USA<br>និង 1 ម៉ឺនរៀល |
| -ឧបាសិកា កំសត់ នៅស្រុកសំឡូត | 30000 រៀល |
| -ឧបាសក ម៉េង ប៊ិច ព្រមទាំងកូនចៅ | 20000 រៀល |
| -ឧបាសិកា ហួន ណងសីម | 20000 រៀល |
| -ឧបាសិកា គាត ស៊ីណា | 20000 រៀល |
| -ឧបាសិកា ទេព គឹមហ៊ | 20000 រៀល |
| -ឧបាសិកា ហេង គួ | 20000 រៀល |
| -ឧបាសិកា គី ពេញ | 20000 រៀល |
| -ម៉ាឧបាសិកា ឆាយ អ៊ីសែង | 20000 រៀល |
| -ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្ត | 20000 រៀល |
| -ឧបាសក ហុង ជ្រិន ឧបាសិកា ឡេង ចំរើន និងកូនចៅ | 20000 រៀល |
| -ឧបាសិកា កែ ថន | 10000 រៀល |
| -ឧបាសិកា អ៊ុយ លឹង | 10000 រៀល |
| -យុវជន ស៊ូ តារា | 10000 រៀល |